ឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍកម្ពុជា ឆ្នាំ២០១០-២០១២

ការត្រួតពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករតាមដានរួមរបស់វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១០

ខែកញ្ញា ឆ្នាំ២០១២

ឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអភិវឌ្ឍកម្ពុជា ឆ្នាំ២០១០-២០១២

ការត្រួតពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងសូចនាករតាមដានរួម
របស់វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១០

រៀបរៀង និងបោះពុម្ពដោយ៖
គម្រោងគោលនយោបាយអភិវឌ្ឍន៍ របស់កម្មវិធីបញ្ហាអភិវឌ្ឍន៍ នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
រចនាអត្ថបទដោយ៖
លោក ភួន យូ មន្ត្រីព័ត៌មាន និងបោះពុម្ពផ្សាយ

សេចក្តីបញ្ជាក់:

រាល់សេចក្តីថ្លែងការណ៍ យោបល់ និងទស្សនៈដែលមាននៅក្នុងឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ គឺជាកម្មសិទ្ធិរបស់អ្នកនិពន្ធ ឬតំណាងអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ និងជាអ្នកទទួលខុសត្រូវចំពោះការលើកឡើងខាងក្នុងឯកសារនីមួយៗ និងមិនឆ្លុះបញ្ចាំងនូវទស្សនៈ ឬជំហររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ទេ។ រាល់ខ្លឹមសារនៅក្នុងឯកសារនេះអាចធ្វើការដកស្រង់ជាឯកសារយោង ឬបោះពុម្ពឡើងវិញបានដោយមានការរក្សាសិទ្ធិជូនអ្នកបោះពុម្ព និងអ្នកនិពន្ធឯកសារស្តីពីជំហរអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យនីមួយៗ។

© រក្សាសិទ្ធិដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ខែកញ្ញា ឆ្នាំ២០១២

ឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអភិវឌ្ឍកម្ពុជា ឆ្នាំ២០១០-២០១២

ការត្រួតពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
និងសូចនាករតាមដានរួមរបស់វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១០

ខែកញ្ញា ឆ្នាំ២០១២

មាតិកា

មាតិកា.....I

បុព្វកថា.....III

សេចក្តីថ្លែងអំណរគុណ.....IV

បញ្ជីអក្សរកាត់.....V

បញ្ជីរាយនាមអង្គការដែលផ្តល់ឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាល.....IX

សេចក្តីសង្ខេប.....X

សេចក្តីផ្តើម.....១

ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍនៃប្រទេសកម្ពុជា.....២

ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍនៃប្រទេសកម្ពុជា.....៣

អភិបាលកិច្ចល្អ.....៧

ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន.....៨

វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា.....១៣

ការគ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និងរ៉ែ.....២២

កំណែទម្រង់លទ្ធិប្រជាធិបតេយ្យ ច្បាប់ និងប្រព័ន្ធយុត្តិធម៌.....៣០

កំណែទម្រង់ការបោះឆ្នោត និងប្រជាធិបតេយ្យ.....៣១

កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ.....៤១

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធជាតិដើម្បីប្រសិទ្ធភាពនៃការអភិវឌ្ឍ.....៤៦

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ តម្លាភាព និងភាពអាចទុកចិត្តបាននៃថវិកា.....៤៧

ការកែលម្អតម្លាភាពនៃព័ត៌មានហិរញ្ញប្បទាន និងសង្គតិភាពជាមួយប្រព័ន្ធជាតិដើម្បីសម្រេចបាននូវ
លទ្ធផលអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពឈានឡើង.....៦០

ការអភិវឌ្ឍជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ.....៧០

វិស័យកសិកម្ម និងទឹក.....៧១

កំណែទម្រង់ដីធ្លី.....៧៩

វិស័យព្រៃឈើ.....៩៤

ផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានពីការពង្រីកឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា.....១០០

វិស័យជលផល.....១០៨
កិច្ចការពារ ការអភិរក្សបរិស្ថាន និងការប្រែប្រួលអាកាសធាតុ.....១១៣
ការអភិវឌ្ឍទំនប់វារីអគ្គិសនី និងវិស័យថាមពល.....១២៣
ការអភិវឌ្ឍធនធានមនុស្ស ១៣១
វិស័យអប់រំ.....១៣២
សុខាភិបាល.....១៤០
ការព្រួយបារម្ភលើបញ្ហាពលកម្ម និងលក្ខខណ្ឌការងារនៅក្នុងប្រទេសកម្ពុជា.....១៦៧
ពិការភាព៖ កិច្ចអភិវឌ្ឍន៍ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ.....១៧២
សិទ្ធិកុមារ.....១៨២
ផែនការអភិវឌ្ឍន៍ជាតិ.....១៨៩
ធ្វើការរួមគ្នាឆ្ពោះទៅកាន់ការសម្រេចបានភាពជាម្ចាស់របស់ប្រទេសលើផែនការអភិវឌ្ឍន៍ជាតិ ១៩០

បុព្វកថា

ក្នុងកំឡុងពេលជាងមួយទសវត្សរ៍នេះ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ជាតួអង្គសំខាន់មួយមិនអាចខ្វះបានក្នុងដំណើរការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាល បានចូលរួមចំណែកជាធាតុចូលរបស់ខ្លួនទៅក្នុងវេទិកាពិភាក្សាជាន់ខ្ពស់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ជាច្រើន។ ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ចាប់ផ្តើមពីការចូលរួមកិច្ចប្រជុំនៃគណៈកម្មាធិការអន្តរជាតិស្តីពីការស្តារប្រទេសកម្ពុជាឡើងវិញ (ICORC) ក្នុងឆ្នាំ១៩៩៥ ទៅកិច្ចប្រជុំក្រុមពិគ្រោះយោបល់ (CG) ពីឆ្នាំ២០០២ រហូតដល់ឆ្នាំ២០០៦ និងចុងក្រោយមកបានចូលរួមក្នុងកិច្ចប្រជុំនៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ក្នុងឆ្នាំ២០០៧ ឆ្នាំ២០០៨ និងឆ្នាំ២០១០។ ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលទៅក្នុងកិច្ចប្រជុំទាំងនេះ ត្រូវបានចាត់ទុកជាយន្តការសម្រាប់ការពិភាក្សាលើវឌ្ឍនភាពអភិវឌ្ឍន៍របស់កម្ពុជា និងការគៀងគរជំនួយអភិវឌ្ឍន៍សម្រាប់កម្ពុជា។ ទោះបីកិច្ចប្រជុំជាន់ខ្ពស់រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ពោលគឺវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៤ ត្រូវបានពន្យារពេលរហូតដល់ឆ្នាំ២០១៤ ដោយរាជរដ្ឋាភិបាលក្តី អង្គការមិនមែនរដ្ឋាភិបាល នៅតែបន្តតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករតាមដានរួម របស់រាជរដ្ឋាភិបាល និងបានចងក្រងឯកសារជំហររបស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអភិវឌ្ឍន៍កម្ពុជាឆ្នាំ ២០១០-២០១២។

ដើម្បីបានជាឯកសារជំហររបស់អង្គការមិនមែនរដ្ឋាភិបាលនេះ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាបានប្រមូលព័ត៌មានពាក់ព័ន្ធពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិដែលធ្វើការតាមវិស័យនានានៅកម្ពុជាចាប់តាំងពីចុងឆ្នាំ ២០១១ មក។ ឯកសារជំហរនេះ ផ្តល់នូវការសង្កេត និងអនុសាសន៍ដោយផ្អែកលើសមិទ្ធិកម្មការងាររបស់រាជរដ្ឋាភិបាល ដោយមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍ នៅក្នុងការធ្វើការងារដើម្បីសម្រេចបានតាមសូចនាករតាមដានរួម ក៏ដូចជាវឌ្ឍនភាពដែលសម្រេចបាន នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ក្នុងចន្លោះឆមាសទី២ ឆ្នាំ២០១០ និងឆមាសទី១ ឆ្នាំ២០១២។

ដោយផ្អែកលើសកម្មភាពប្រតិបត្តិការ និងបទពិសោធន៍របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិដែលធ្វើការនៅកម្រិតមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលទាំងនេះមានលទ្ធភាពក្នុងការផ្តល់នូវការអង្កេតដែលគួរឲ្យមានភាពជឿជាក់អំពីផលប៉ះពាល់ពីការអភិវឌ្ឍន៍ និងពាំនាំនូវសំលេងរបស់ជនក្រីក្រ និងសហគមន៍ងាយរងគ្រោះ ដើម្បីឲ្យមានការយកចិត្តទុកដាក់ពីសំណាក់អ្នករៀបចំគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្តទាំងនៅក្នុងជួរ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។

សហគមន៍អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាសូមវាយតម្លៃខ្ពស់ចំពោះការផ្តល់ឱកាស និងរួមបញ្ចូលអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យទៅក្នុងដំណើរការវាយតម្លៃវឌ្ឍនភាពនៃការអភិវឌ្ឍន៍នៅកម្ពុជាកន្លងមក តាមរយៈការចែករំលែកនូវការអង្កេត និងអនុសាសន៍សម្រាប់ការរៀបចំគោលនយោបាយអភិវឌ្ឍន៍ដែលពាក់ព័ន្ធតាមវិស័យ។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាល ព្យាយាមធានាឲ្យបានថាធាតុចូលដែលមាននៅក្នុងឯកសារនេះមានលក្ខណៈស្ថាបនា គួរឲ្យជឿជាក់ និងក្នុងន័យគាំទ្រ ព្រមទាំងចង់ឲ្យមានការច្របាច់បញ្ចូលយោបល់រួមនានាដែលអាចជួយរួមចំណែកកាត់បន្ថយភាពក្រីក្រ នៅក្នុងព្រំដែនការងាររបស់ខ្លួន។

ឯកសារជំហររបស់អង្គការមិនមែនរដ្ឋាភិបាលនេះ មានគោលបំណងចូលរួមចំណែកក្នុងកិច្ចពិភាក្សាកម្រិតគោលនយោបាយ និងជួយជាព័ត៌មានដល់កិច្ចពិភាក្សាដែលនឹងកើតមាននៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) លើកទី១៩ ប្រព្រឹត្តិទៅនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងត្រូវបានប្រើប្រាស់សម្រាប់ជាឯកសារយោងដ៏សំខាន់សម្រាប់ភាគីពាក់ព័ន្ធដែលមកពីអង្គការមិនមែនរដ្ឋាភិបាល រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ដែលទាំងអស់គ្នាធ្វើការរួមគ្នាដើម្បីកាត់បន្ថយភាពក្រីក្រ និងភាពប្រសើរឡើងនៅកម្ពុជា។

សេចក្តីថ្លែងអំណរគុណ

សេចក្តីថ្លែងការណ៍ពីបញ្ហាតាមវិស័យរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ ត្រូវបានរៀបចំឡើងដោយមានការចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ជាមួយនឹងសមាជិកបណ្តាញអង្គការមិនមែនរដ្ឋាភិបាល និងក្រុមការងារអង្គការមិនមែនរដ្ឋាភិបាលនានា។ ការរៀបចំជាឯកសារនេះឡើងគឺមិនអាចធ្វើទៅរួចនោះទេ ប្រសិនបើពុំមានជំនួយពីបុគ្គលិក និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។

ព័ត៌មានដែលមាននៅក្នុងឯកសារជំហរទាំងនេះ គឺផ្អែកលើបទពិសោធន៍របស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យការងារអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាការចូលរួមក្នុងកិច្ចពិភាក្សាគោលនយោបាយនៅកម្រិតក្រុមការងារបច្ចេកទេសនៅកម្ពុជា។ ការរៀបរៀង និងសង្ខេបឯកសារនេះរបស់អង្គការមិនមែនរដ្ឋាភិបាលទៅលើបញ្ហាអាទិភាពនានាត្រូវបានសម្របសម្រួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងអង្គការមេឌីខាំ។

បញ្ជីឈ្មោះអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមផ្តល់ជាឯកសារជំហរនៅទំព័របន្ទាប់ បង្ហាញពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលដើរតួនាទីជាអ្នកដឹកនាំការសម្របសម្រួល ប្រមូលកែសម្រួល និងព្រាងឯកសារជំហររបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យរបស់ខ្លួន។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងអង្គការមេឌីខាំ សូមទទួលស្គាល់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងពេលវេលា ថាមពល និងធាតុចូលដែលត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ និងដែលបានចូលរួមចំណែកឲ្យមានការបោះពុម្ពឯកសារនេះ។

បញ្ជីអក្សរកាត់

ACL	ច្បាប់ប្រឆាំងអំពើពុករលួយ
ACU	អង្គភាពប្រឆាំងអំពើពុករលួយ
ADD	អង្គការសកម្មភាពលើពិការភាព និងអភិវឌ្ឍន៍
ADHOC	សមាគមអាដហុក (សិទ្ធិមនុស្ស និង អភិវឌ្ឍនៅកម្ពុជា)
API	វិទ្យាស្ថានគោលនយោបាយ និងតស៊ូមតិ
CAR	ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
CCC	គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
CCHR	មជ្ឈមណ្ឌលសិទ្ធមនុស្សកម្ពុជា
CCJAP	គំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា
CDC	ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
CDCF	វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា
CDHS	អង្គេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា
CDPO	អង្គការជនពិការកម្ពុជា
CDRI	វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
CEA	សមាគមន៍សេដ្ឋកិច្ចកម្ពុជា
CEDAC	មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
CEDAW	អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ
CESCR	គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌
CHRAC	គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគម ការពារសិទ្ធិមនុស្សកម្ពុជា
CISA	សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម
CLEC	មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍
CLP	ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
CMDG	គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
CNCC	ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
CNCW	ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
CNMC	គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
CNPA	អាជ្ញាធរប្រេងកាតជាតិកម្ពុជា
COHRE	មជ្ឈមណ្ឌលស្តីសិទ្ធលំនៅឋាន និងការបណ្តេញចេញ
CoM	ទីស្តីការគណៈរដ្ឋមន្ត្រី
COMFREL	គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
CLJR	ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
CPI	សន្ទស្សន៍អំពើពុករលួយ
CPWP	គណៈកម្មាធិការលើស្ងួយស្ត្រីក្នុងវិស័យនយោបាយ

CRDB	គណៈកម្មាធិការនីតិសម្បទាន និងអភិវឌ្ឍកម្ពុជា
CRRT	សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CSARO	អង្គការកែច្នៃ និងអនាម័យសហគមន៍
CSF	មូលនិធិឃុំ/សង្កាត់
DAC	ក្រុមប្រឹក្សាសកម្មភាពជនពិការ
DPA	អភិវឌ្ឍ និង ភាពជាដៃគូក្នុងសកម្មភាព
DP	ដៃគូអភិវឌ្ឍន៍
DPA	អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព
ECCC	អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
EFA	ការអប់រំសម្រាប់ទាំងអស់គ្នា
EI	ឧស្សាហកម្មនិស្សារណកម្ម
EIC	វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា
EISEI	ផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានពីការពង្រីកឧស្សាហកម្មនិស្សារណកម្ម
EITI	គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម
ELC	សម្បទានដីសេដ្ឋកិច្ច
EMO	អង្គការតាមដានការបោះឆ្នោត
ESP	ផែនការយុទ្ធសាស្ត្រអប់រំ
FA	រដ្ឋបាលព្រៃឈើ
FACT	អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល
FAO	អង្គការចំណីអាហារ និងកសិកម្ម នៃអង្គការសហប្រជាជាតិ
FiA	រដ្ឋបាលជលផល
FLPN	បណ្តាញជីវភាពអាស្រ័យព្រៃឈើ និងចំការឈើដាំ
FWCU	សហគមន៍កសិកររប្រើប្រាស់ទឹក
GDCC	គណៈកម្មាធិការសម្រមសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍
GHG	ឧស្ម័នផ្ទះកញ្ចក់
GMO	សារពាង្គកាយកែច្នៃសេនេទិក
HCMC	គណៈកម្មាធិការគ្រប់គ្រង់មណ្ឌលសុខភាព
HEF	មូលនិធិសមធម៌សុខភាព
HI	អង្គការជនពិការអន្តរជាតិ
HIS	ប្រព័ន្ធព័ត៌មានសុខភាព
HIV	វីរុសហីវ
HSP2	ផែនការយុទ្ធសាស្ត្រលើវិស័យសុខាភិបាល ២០០៨-២០១៥

IDPoor	អត្តសញ្ញាណកម្មគ្រួសារក្រីក្រ
ILO	អង្គការពលកម្មអន្តរជាតិ
IMM	កិច្ចប្រជុំអន្តរក្រសួង
IMR	អត្រាមរណៈទារក
IP	ជនជាតិដើមភាគតិច
LAC	អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា
LICADHO	សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LMAP	គម្រោងរដ្ឋបាល និងគ្រប់គ្រង់ដីធ្លី
MLMUPC	ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
MMR	អត្រាស្លាប់របស់មាតា
MoE	ក្រសួងបរិស្ថាន
MoInfo	ក្រសួងព័ត៌មាន
MoLVT	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
MoNASRI	ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
MoSAVY	ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
MoWA	ក្រសួងកិច្ចការនារី
MoWRM	ក្រសួងធនធានទឹក និងឧត្តុនិយម
MoU	អនុស្សារណៈយោគយល់
MRD	ក្រសួងអភិវឌ្ឍន៍ជនបទ
NAA	អាជ្ញាធរសវនកម្មជាតិ
NCDD	គណៈកម្មាធិការជាតិគ្រប់គ្រងវិមជ្ឈការ និងសហវិមជ្ឈការ
NCDP	មជ្ឈមណ្ឌលជាតិនៃជនពិការ
NCHADS	មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ
NEP	ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ
NFP	កម្មវិធីជាតិព្រៃឈើ
NGO	អង្គការមិនមែនរដ្ឋាភិបាល
NGOCRC	គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ
NLC/S	សម្ព័ន្ធជាតិឃុំ សង្កាត់
NPA	ផែនការសកម្មភាពជាតិ
NP-SNDD	កម្មវិធីជាតិ ស្តីពីការអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
NSDP	ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
ODA	ហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ
PD	សេចក្តីថ្លែងការទីក្រុងប៉ារីស ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទាន

PFM	ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
PFMRP	កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
PIP	កម្មវិធីវិនិយោគសាធារណៈ
PHD	មន្ទីរសុខាភិបាលខេត្ត
PRN-C	បណ្តាញកាត់បន្ថយថ្នាំកសិកម្មនៅកម្ពុជា
PRSP	ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ
RCAF	កងយោធពលខេមរៈភូមិន្ទ
REDD+	ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ
RGC	រាជរដ្ឋាភិបាលកម្ពុជា
RHMC	គណៈកម្មាធិការគ្រប់គ្រងមន្ទីពេទ្យបង្អែក
SAW	យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក
SCM	ឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ
SLC	សម្បទានដីសង្គមកិច្ច
SLR	ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ
SNA	រដ្ឋបាលថ្នាក់ក្រោមជាតិ
SNEC	ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
SPF	ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ
STD	ជំងឺកាមរោគ
TOFE	តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ
TVK	ទូរទស្សន៍ជាតិនៃកម្ពុជា
TWG	ក្រុមការងារបច្ចេកទេស
TWGAW	ក្រុមការងារបច្ចេកទេសលើវិស័យកសិកម្ម និងធនធានទឹក
TWGF	ក្រុមការងារបច្ចេកទេសលើវិស័យជលផល
TWG-PFM	ក្រុមការងារបច្ចេកទេសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
TWG-P&H	ក្រុមការងារបច្ចេកទេស-ភាពជាដៃគូ និងសុខុដុមណីយកម្ម
UNCRC	អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ
UNCRPD	អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ
UNESCAP	គណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ
UNFPA	មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជន
UNICEF	មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ
UNTAC	អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា
YRDP	អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន

បញ្ជីរាយនាមអង្គការដែលផ្តល់ឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាល

ល.រ	ឯកសារជំហរតាមវិស័យ	អង្គការដែលបានផ្តល់ឯកសារ
១	ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍនៃប្រទេសកម្ពុជា	គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
២	ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន	វិទ្យាស្ថានគោលនយោបាយ និងតស៊ូមតិ (API)
៣	វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា	វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) និងអង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា (CCSP)
៤	ការគ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និងរ៉ែ	សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT)
៥	កំណែទម្រង់ការបោះឆ្នោត និងប្រជាធិបតេយ្យ	គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៦	កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ	គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា(CHRAC)
៧	កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF)
៨	ការកែលម្អតម្លាភាពនៃព័ត៌មានហិរញ្ញប្បទាន និងសង្គតិភាពជាមួយប្រព័ន្ធជាតិ	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF)
៩	វិស័យកសិកម្ម និងទឹក	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) និងមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)
១០	កំណែទម្រង់ដីធ្លី	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា(NGOF) បណ្តាញប្រព្រឹត្តកម្មតាំងទីតាំងទីលំនៅថ្មី បណ្តាញដីធ្លីដើម្បីអភិវឌ្ឍន៍ និងបណ្តាញអង្គការគាំទ្រសិទ្ធជនជាតិដើមភាគតិច
១១	វិស័យព្រៃឈើ	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) និងបណ្តាញជីវភាពអាស្រ័យព្រៃឈើ និងចំការឈើដាំ
១២	ផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានពីការពង្រីកឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា	អង្គការអភិវឌ្ឍ និងភាពជាដៃគូក្នុងសកម្មភាព(DPA) បណ្តាញផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានក្នុងឧស្សាហកម្មនិស្សារណកម្ម (EISEI)
១៣	វិស័យជលផល	អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)
១៤	កិច្ចការពារ ការអភិរក្សបរិស្ថាន និងការប្រែប្រួលអាកាសធាតុ	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) និងបណ្តាញវេទិកាបរិស្ថាន
១៥	ការអភិវឌ្ឍទំនប់វារីអគ្គិសនី និងវិស័យថាមពល	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) និងសម្ព័ន្ធទន្លេកម្ពុជា (RCC)
១៦	វិស័យអប់រំ	ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ (NEP)
១៧	សុខាភិបាល	អង្គការមេឌីខាំ (MEDiCAM)
១៨	បញ្ហាពលកម្ម និងលក្ខខណ្ឌការងារក្នុងប្រទេសកម្ពុជា	សហភាពការងារកម្ពុជា (CLC)
១៩	ពិការភាព	អង្គការជនពិការកម្ពុជា (CDPO)
២០	សិទ្ធិកុមារ	សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC)
២១	ភាពជាម្ចាស់របស់ប្រទេសលើផែនការអភិវឌ្ឍន៍ជាតិ	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF)

សេចក្តីសង្ខេប

ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជា គ្របដណ្តប់បញ្ហាអភិវឌ្ឍន៍ជាច្រើន និងមានការចូលរួមយ៉ាងជិតស្និទ្ធជាមួយប្រជាជនកម្ពុជាមកពីគ្រប់ជីវភាព និងស្ថានភាពសង្គម-សេដ្ឋកិច្ច។ វត្ថុបំណងរួមគ្នានៃអង្គការយើងខ្ញុំ គឺលើកកំពស់ស្ថានភាពរបស់ពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះក្នុងសង្គមកម្ពុជា។ តាមរយៈចំណេះដឹងរួមគ្នារបស់យើងអំពីពលរដ្ឋសាមញ្ញនៅថ្នាក់មូលដ្ឋាន សង្គមស៊ីវិលស្ថិតក្នុងទីតាំងល្អប្រសើរក្នុងការជួយរាជរដ្ឋាភិបាលកម្ពុជាលើការរៀបចំគោលនយោបាយរបស់ខ្លួន ដោយចែករំលែក និងផ្តល់យោបល់ និងសំណើដ៏មានតម្លៃអំពីគោលនយោបាយអភិវឌ្ឍន៍ និងការអនុវត្ត។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាបានចូលរួម និងបានផ្តល់ធាតុចូលយ៉ាងច្រើនទៅកាន់វេទិកាកម្រិតខ្ពស់រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ក្នុងទសវត្សកន្លងទៅ តាមរយៈការចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ (CG) ចាប់តាំងពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៦ និងបន្ទាប់មកបានចូលរួមនៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) រហូតមកដល់ពេលបច្ចុប្បន្ន។ ការចូលរួមនេះគឺជាយន្តការមួយ ដើម្បីពិភាក្សាវឌ្ឍនភាពនៃការអភិវឌ្ឍ និងការកៀរគរជំនួយអភិវឌ្ឍន៍របស់កម្ពុជា។

ទោះបីជាវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទីបួន ត្រូវបានពន្យារពេលដល់ឆ្នាំ២០១៤ក្តី ចាប់តាំងពីចុងឆ្នាំ ២០១១ មក សហគមន៍អង្គការមិនមែនរដ្ឋាភិបាល បានប្រមូលឯកសារ និងបញ្ហាតាមវិស័យសរុបចំនួន២១ ដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល/ក្រុមតាមវិស័យដោយមានការរួមវិភាគទាន និងការពិគ្រោះយោបល់ពីបណ្តាញរបស់ខ្លួន។ ឯកសារទាំងនេះ បង្ហាញពីទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាលទាក់ទងនឹងស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍរបស់កម្ពុជា ក្នុងគោលបំណងផ្តល់មតិ និងអនុសាសន៍បែបស្ថាបនាអំពីវឌ្ឍនភាពដែលសម្រេចបាន ក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម សូចនាករតាមដានរួមគ្នា ព្រមទាំងបញ្ហានានាដែលពុំមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងនៅក្នុងសូចនាករតាមដានរួម ចាប់តាំងពីកិច្ចប្រជុំលើកទីបីនៃវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាកាលពីខែមិថុនា ឆ្នាំ២០១០ ដោយឯកសារមួយចំនួនបានផ្តល់បច្ចុប្បន្នភាពរហូតដល់ខែកញ្ញា ឆ្នាំ២០១២។

ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍកម្ពុជា

អង្គការសង្គមស៊ីវិលបានដើរតួសំខាន់ក្នុងការអភិវឌ្ឍនៅកម្ពុជា ក្នុងរយៈពេលបីទសវត្សកន្លងទៅ និងបានរួមចំណែកយ៉ាងច្រើនលើការលើកកំពស់ និងការពង្រឹងសមត្ថភាពបុគ្គល និងសហគមន៍ ការជម្រុញឲ្យមានគោលនយោបាយគិតគូរដល់ផលប្រយោជន៍ទាំងអស់គ្នា និងប្រកបដោយសមធម៌ ការពារសិទ្ធិរបស់អ្នកទន់ខ្សោយ និងការបំពេញការងារ ឆ្ពោះទៅកាន់សាមគ្គីភាពសង្គម។

កាលពីពេលថ្មីៗនេះ របាយការណ៍មួយរបស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាដែលមានចំណងជើងថា "វិភាគទានរបស់អង្គការសង្គមស៊ីវិលចំពោះការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០១១" បានឲ្យដឹងថា អង្គការសង្គមស៊ីវិលបានរួមវិភាគទាន ចំនួន៥៥០លានដុល្លារ ទៅក្នុងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជាកាលពីឆ្នាំមុន។ ផ្អែកលើអង្កេតមួយដែលបានធ្វើចំពោះអង្គការសង្គមស៊ីវិលចំនួន៣០៩ នៅបួនខេត្ត និងនៅភ្នំពេញ របាយការណ៍បានរកឃើញថាអង្គការសង្គមស៊ីវិលមានកិច្ចប្រឹងប្រែងក្នុងវិស័យសំខាន់ៗ ចំនួនបួន ហើយអង្គការសង្គមស៊ីវិលជាច្រើនមានសកម្មភាពលើសពីមួយវិស័យ។ ក្នុងចំនោមអង្គការទាំងនោះ ៧២%ធ្វើសកម្មភាពក្នុងវិស័យអប់រំ និងបណ្តុះបណ្តាល ៣៩%ក្នុងវិស័យសុខាភិបាល ៣៣%ក្នុងអភិវឌ្ឍន៍សហគមន៍ និង៣៣%ក្នុងវិស័យសុខុមាលភាព និងសិទ្ធិកុមារ។

ការស្រាវជ្រាវនេះបង្ហាញថា យ៉ាងហោចណាស់មានប្រជាជនកម្ពុជាពី៦៥០.០០០ ទៅ១លាននាក់ ឬច្រើនជាងនេះ បានទទួលអត្ថប្រយោជន៍ពីសកម្មភាពរបស់អង្គការសង្គមស៊ីវិលចំនួន៣០៩ ដែលបានអង្កេត។ នៅក្នុងវិស័យអង្គការសង្គមស៊ីវិលទាំងមូល ដែលមានអង្គការប្រមាណជា១.៣៥០ កំពុងដំណើរការ ហើយដែលបានចុះបញ្ជី មានការប៉ាន់ស្មានថា

ប្រជាជនកម្ពុជាពី២០ទៅ៣០ភាគរយ ឬប្រជាជនចំនួនមួយភាគបួន គឺជាអ្នកទទួលផលដោយផ្ទាល់ពីសកម្មភាពនានា របស់អង្គការសង្គមស៊ីវិល។ របាយការណ៍ ក៏បានធ្វើចំណាលផងដែរថា អង្គការសង្គមស៊ីវិល ផ្តល់ការងារដល់ប្រជាជនកម្ពុជាចំនួន៥២.៦៥០នាក់ក្នុងមុខតំណែងមានជំនាញ ដែលមានឱកាសសម្រាប់អភិវឌ្ឍសមត្ថភាព ព្រោះថាអង្គការចំនួន ៦៧% មានបុគ្គលិកដែលទទួលការអប់រំជាមធ្យម កម្រិតបរិញ្ញាបត្រ ឬខ្ពស់ជាងនេះ។

ជាមួយនឹងការចូលរួមរបស់ប្រជាពលរដ្ឋសាមញ្ញក្នុងការងារអភិវឌ្ឍន៍នៅតាមវិស័យជាច្រើនបែបនេះ សហគមន៍អង្គការសង្គមស៊ីវិល គឺជាតួអង្គអភិវឌ្ឍន៍សំខាន់ដែលសាកសមទទួលបាននូវការទទួលស្គាល់ និងការចូលរួម ក្នុងកិច្ចពិភាក្សាគោលនយោបាយ និងការរៀបចំគោលនយោបាយ ដែលវាសនា និងអនាគតរបស់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះទទួលរងឥទ្ធិពល ទោះវិជ្ជមាន ឬអវិជ្ជមានក្តី។

អភិបាលកិច្ចល្អ

អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ថា រាជរដ្ឋាភិបាលមានចំណងលើកកម្ពស់សេរីភាពក្នុងការស្វែងរក និងទទួលព័ត៌មាន ព្រមទាំងលើកកំពស់តម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អ។ ទោះជាយ៉ាងណាក្តី បញ្ហាជាក់លាក់មួយចំនួនក្នុងអភិបាលកិច្ចល្អ នៅតែបង្កើតបញ្ហាប្រឈមនានាក្នុងការសម្រេចបាននូវយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ទោះបីក្របខណ្ឌគោលនយោបាយស្តីពី**ការទទួលបានព័ត៌មាន** ត្រូវបានរៀបចំឡើងដែលមានការចូលរួមតាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ គេគប្បីកត់សំគាល់ថាច្បាប់ស្តីពីការទទួលបានព័ត៌មាន នៅតែជាសេចក្តីព្រាងនៅឡើយ។ ច្បាប់នេះនឹងជួយបង្កើនភាពជឿជាក់ និងទំនុកចិត្តរវាងរដ្ឋាភិបាល និងប្រជាជនកម្ពុជា។

លទ្ធផលនៃការសិក្សាពីរដាច់ដោយឡែកពីគ្នានៅឆ្នាំ២០០៩ កត់សំគាល់អំពីតម្រូវការ និងកាផ្គត់ផ្គង់ព័ត៌មាន សាធារណៈ។ តាមការវាយតម្លៃមួយរបស់ធនាគារពិភពលោកបង្ហាញថា ការទទួលបានព័ត៌មានត្រូវបានកំហិតលើព័ត៌មានលម្អិតចំពោះចំណូល ថវិកា និងចំណាយសាធារណៈ។ ហេតុនេះ សិក្ខាសាលា និងវេទិកានានាដែលដឹកនាំដោយ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(API) បានធ្វើការសន្និដ្ឋានថា ប្រជាពលរដ្ឋចង់ទទួលបានព័ត៌មានដែលប៉ះពាល់ ដោយផ្ទាល់ដល់ជីវភាពគ្រួសារ ដូចជាអនុក្រឹត្យ និងគោលនយោបាយអភិវឌ្ឍន៍ ផែនការអភិវឌ្ឍន៍ឃុំ ព្រមទាំងថវិកា និងចំណាយឃុំ ជាដើម ប៉ុន្តែ មានពលរដ្ឋជាច្រើននៅមិនទាន់អាចទទួលបានព័ត៌មានទាំងនេះនៅឡើយ។ ការទទួលបាន ព័ត៌មានគឺជាធាតុសំខាន់មួយក្នុងការសម្រេចបាននូវអភិបាលកិច្ចល្អ ប៉ុន្តែប្រសិនបើគ្មានច្បាប់ស្តីពីការទទួលបានព័ត៌មានទេ នោះ ប្រជាពលរដ្ឋនឹងជួបការលំបាកក្នុងការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ អង្គការមិនមែនរដ្ឋាភិបាល សូមស្នើដោយទទូចឲ្យអនុម័តច្បាប់ស្តីពីការទទួលបានព័ត៌មាន ដោយមានសូចនាករលទ្ធផលជាក់លាក់ និងច្បាស់លាស់ ព្រមទាំងកាលកំណត់សម្រាប់ផ្តល់លទ្ធផលផងដែរ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាត្រូវបានលើកទឹកចិត្តឲ្យ ផ្សព្វផ្សាយព័ត៌មានបន្ថែម រាប់ទាំងគោលនយោបាយ និងថវិកា ព្រមទាំងរបាយការណ៍សវនកម្មទាន់ពេលវេលា។

ដោយសារអភិបាលកិច្ចល្អមានសារសំខាន់ចំពោះការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើនការយកចិត្តទុកដាក់ចំពោះ**វិមជ្ឈការ និងវិសហមជ្ឈការ**។ គេអាចឃើញការដាក់ចំណុចនេះបញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណ ក្នុងបំណងពង្រឹង និងពង្រីកប្រជាធិបតេយ្យនៅមូលដ្ឋាន និងជម្រុញការអភិវឌ្ឍនៅមូលដ្ឋាន ដើម្បីកាត់បន្ថយភាពក្រីក្រ។ ទោះបីជាមានវឌ្ឍនភាពចំពោះកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលសព្វថ្ងៃ ក្រុមប្រឹក្សាឃុំអាចបញ្ចោញមតិកាន់តែច្រើន ក្នុងដំណើរការអភិវឌ្ឍន៍ គេសង្កេតឃើញថា ជាទូទៅមន្ត្រីនៅថ្នាក់មូលដ្ឋាន គ្មានជំនាញ និងគ្មានធនធានសមស្របក្នុងការផ្តល់សេវាសាធារណៈ ឬឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ឡើយ។ ជាមួយគ្នានេះ ក៏មានបញ្ហាក្នុងការបណ្តុះទំនាក់ទំនងសាធារណៈល្អ និងទ្រទ្រង់ការទទួលបានសេវាសាធារណៈ ក៏ដូចជា បញ្ចោញព័ត៌មានសាធារណៈដើម្បីបង្កើនតម្លាភាព គណនេយ្យភាព និងការចូលរួមរបស់ពលរដ្ឋផងដែរ។

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានស្វាគមន៍ ហើយដើម្បីបន្តពង្រឹងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលផ្តល់អនុសាសន៍ លើចំណុចដូច

តទៅ រួមមាន៖ សំណុំយន្តការដាក់បញ្ចូល ដោយមានការចូលរួមពីតួអង្គអភិវឌ្ឍន៍ផ្សេងៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើមុខងារក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ ហើយបង្កើតអនុក្រុម/អនុគណៈកម្មាធិការបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់អនុកម្មវិធីទាំងប្រាំមួយនៃ IP3 សម្រាប់ខេត្តនីមួយៗ។ ការអនុវត្តគម្រោងអភិវឌ្ឍសមត្ថភាពក្នុងភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជំនាញ ជាមួយនឹងការណែនាំ និងបង្វឹក កំពុងប្រព្រឹត្តទៅ និងការពង្រឹង ជាថ្មីនូវការអនុវត្តច្បាប់អង្គការ ព្រមទាំងផ្សព្វផ្សាយគោលការណ៍ណែនាំ និងយន្តការច្បាស់លាស់ ដើម្បីពង្រឹងបន្ថែម និងអនុវត្តច្បាប់នៅថ្នាក់ជាតិ និងក្រោមជាតិ ដោយមានការចូលរួមពិត ប្រាកដជាមួយតួអង្គអភិវឌ្ឍន៍នានា។

អភិបាលកិច្ចល្អមិនត្រឹមតែគ្របដណ្តប់លើការគ្រប់គ្រងសេវាសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែក៏គ្របដណ្តប់**ការគ្រប់គ្រងចំណូលពីធនធានសាធារណៈ (ប្រេង ឧស្ម័ន និងរ៉ែ)** ផងដែរ។ ក្នុងន័យនេះ អង្គការមិនមែនរដ្ឋាភិបាលសូមវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំក្របខណ្ឌនិយ័តកម្មស្តីពីឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា ដោយសារមានសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីសារពើពន្ធ (សេចក្តីព្រាងច្បាប់ស្តីពីការយកពន្ធចំពោះប្រតិបត្តិការប្រេង) ដែលបានផ្ញើទៅកាន់ក្រុមប្រឹក្សារដ្ឋមន្ត្រីដើម្បីសុំការឯកភាព ព្រមទាំងការកសាងសេចក្តីព្រាងប្រកាសស្តីពីការប្រមូលពន្ធចំពោះប្រតិបត្តិការប្រេង និងសេចក្តីព្រាងច្បាប់ស្តីពីការយកពន្ធចំពោះប្រតិបត្តិការជីកយករ៉ែ។

យើងសូមលើកសរសើរចំពោះការបន្តប្តេជ្ញាចិត្តខ្ពស់ក្នុងការបើកចំហ និងចំពោះតម្លាភាពនេះ ប៉ុន្តែទន្ទឹមនឹងនេះ គេឃើញមានកង្វះខាតក្នុងការគ្រប់គ្រងចំណូលប្រកបដោយតម្លាភាពពីផ្នែកឧស្សាហកម្មនិស្សារណកម្មនេះតែម្តង។ បច្ចុប្បន្ននេះ ការយល់ដឹងរបស់សាធារណជនអំពីកិច្ចអភិវឌ្ឍន៍ និងការគ្រប់គ្រងចំណូលឧស្សាហកម្មនិស្សារណកម្ម នៅមានកម្រិតនៅឡើយ ហើយនៅក្នុងឯកសាររបស់រដ្ឋាភិបាលមានការកត់ត្រាតែមួយបន្ទាត់ជាតួលេខសរុបអំពី "ចំណូលពីឧស្សាហកម្មនិស្សារណកម្ម" ប៉ុណ្ណោះ នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយចំណូលនេះ ត្រូវបានដកចេញពីតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋាភិបាលចាប់តាំងពីខែសីហា ឆ្នាំ២០១១ មកម្ល៉េះ។ ទោះជាយ៉ាងណាក្តី ក្រុមការងារបច្ចេកទេសអន្តរក្រសួងទទួលបន្ទុកលើការសិក្សា និងអនុវត្តគោលការណ៍ស្តីពីគំនិតផ្តួចផ្តើមលើតម្លាភាព ឧស្សាហកម្មនិស្សារណកម្ម មិនបានរាយការណ៍បន្ថែមអំពីការអនុម័ត និងការអនុវត្តគោលការណ៍ទាំងនោះឡើយ។ សូមយកចិត្តទុកដាក់បន្ថែមក្នុងការលើកកំពស់ការគ្រប់គ្រងប្រកប ដោយតម្លាភាពចំពោះធនធានសាធារណៈទាំងនេះ តាមរយៈការផ្តល់ព័ត៌មាន និងការបោះផ្សាយក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ការអនុម័តសមាជិកភាពក្នុង គំនិតផ្តួចផ្តើមអំពីតម្លាភាពឧស្សាហកម្មនិស្សារណកម្ម និង/ឬគោលការណ៍នានា ដូចមានបញ្ជាក់នៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការពិគ្រោះយោបល់សាធារណៈចំពោះសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាក្នុងពេលខាងមុខ ដើម្បីធានាឲ្យមានការចូលរួម និងពិភាក្សាពីសំណាក់ភាគីពាក់ព័ន្ធនានា។

កំណែទម្រង់លទ្ធិប្រជាធិបតេយ្យ ច្បាប់ និងប្រព័ន្ធយុត្តិធម៌

វឌ្ឍនភាពលើវិស័យលទ្ធិប្រជាធិបតេយ្យ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បំពេញបន្ថែមលើអភិបាលកិច្ចល្អ ដោយសារ អ្វីទាំងអស់នេះ បង្កើតបានជាមូលដ្ឋានដើម្បីឲ្យមានការរៀបចំស្ថាប័នបានល្អប្រសើរ។ ការរៀបចំចាត់ចែងទាំងនេះ ជម្រុញ ឲ្យនីតិរដ្ឋ មានសង្គតិភាពជាមួយនឹងការការពារបុរេលក្ខណ៍សំខាន់ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព ដូចជាសមធម៌ និងសិទ្ធិមនុស្ស ជាដើម។

រាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការរៀបចំការបោះឆ្នោត បានប្រឹងប្រែក្នុងការកែលំអ**កំណែទម្រង់ការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ**។ ការបង្កើនការចុះឈ្មោះអ្នកបោះឆ្នោតនៅឆ្នាំ២០១១ គឺជាជំហានសំខាន់មួយសម្រាប់ កំណែទម្រង់ការបោះឆ្នោត ពិសេសចំពោះការសម្រេចចិត្តពន្យារសុពលភាពអត្តសញ្ញាណបណ្ណ ដើម្បីឲ្យអ្នកដែលមាន អត្តសញ្ញាណបណ្ណហួសសុពលភាព មានលទ្ធភាពចូលរួមបោះឆ្នោតក្រុមប្រឹក្សាឃុំនៅឆ្នាំ២០១២។ កិច្ចប្រឹងប្រែងបន្ថែម រួមមានការបង្កើនចំនួនថ្ងៃសម្រាប់អនុញ្ញាតឲ្យអ្នកបោះឆ្នោតចុះឈ្មោះ ដែលធ្វើឲ្យចំនួនអ្នកបោះឆ្នោតវ័យក្មេងកើនឡើង ចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១១។

ទោះជាយ៉ាងណាក្តី គេគប្បីកត់សំគាល់ថាសេចក្តីប្រកាសគោលនយោបាយជាក់លាក់អំពីកំណែទម្រង់ការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ នៅមិនទាន់ត្រូវបានពិភាក្សាលម្អិត ដោយសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ មិនទាន់ត្រូវបានបើកចំហច្រើននៅឡើយ ធ្វើឲ្យលំបាកដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងការឆ្លុះបញ្ចាំង ទំនាក់ទំនងរវាងគោលនយោបាយបោះឆ្នោត និងការអនុវត្ត។ អនុសាសន៍សម្រាប់កែលំអកំណែទម្រង់ការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យសំដៅពង្រឹងស្ថាប័នផ្លូវការរបស់កម្ពុជា និងពង្រឹង ក្របខណ្ឌប្រជាធិបតេយ្យនៅកម្ពុជា។ អនុសាសន៍រួមមាន កំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លើសមាសភាពរបស់គណៈកម្មាធិការនេះ ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត និងដំណើរការចុះឈ្មោះបោះឆ្នោតឲ្យមានភាពសាមញ្ញ និងមានលក្ខណៈជាប្រព័ន្ធ ការជំនួសប្រព័ន្ធបោះឆ្នោតមិនផ្ទាល់ ទៅជាការបោះឆ្នោតដោយផ្ទាល់នៅក្រុមប្រឹក្សានានាថ្នាក់ក្រោមជាតិ និងនៅព្រឹទ្ធសភា ការបង្កើនសេរីភាពសារព័ត៌មាន និងលទ្ធភាពស្មើគ្នា ចំពោះប្រព័ន្ធផ្សព្វផ្សាយសម្រាប់គណបក្សនយោបាយនានា ក្នុងអំឡុង ពេលបោះឆ្នោត ការបង្កើនចំនួនអាសនៈសភាសម្រាប់បណ្តាខេត្តដែលមានកំណើនប្រជាជន និងការបង្កើតច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ។

ទោះបីកំណែទម្រង់ការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យមានការផ្លាស់ប្តូរច្រើនក្នុងរយៈប៉ុន្មានឆ្នាំកន្លងទៅថ្មីៗ ក្តីគួរឲ្យសោកស្តាយដែល**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌** មិនបានអនុវត្តតាមសំណើ។ ច្បាប់គ្រឹះសំខាន់ៗបីដែលទាក់ទងដល់ប្រព័ន្ធតុលាការនៅមិនទាន់សម្រេចនៅឡើយ ហើយគ្មានវឌ្ឍនភាពច្រើនឡើយ។ សេចក្តីព្រាងច្បាប់គ្រឹះទាំងនោះរួមមានច្បាប់ស្តីពីការរៀបចំតុលាការ និងអយ្យការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីវិសោធនកម្ម ការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ យើងសូមវាយតម្លៃខ្ពស់ និងទទួលស្គាល់ថា ជាលើកទីមួយ ហើយដែលតុលាការទាំងបួន ត្រូវបានកែសម្រួលទៅជាតុលាការគំរូ។ ទោះជាយ៉ាងណាក្តី ចាប់តាំងពីចុងឆ្នាំ២០១១ មក សង្គមស៊ីវិលមិនបានទទួលរបាយការណ៍បន្ថែមអំពីវឌ្ឍនភាពឡើយ ធ្វើឲ្យសង្គមស៊ីវិលលំបាកក្នុងការសង្កេតការរីកចម្រើន លើវិស័យកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

យើងសូមស្នើឲ្យច្បាប់គ្រឹះទាំងឡាយដែលទាក់ទងនឹងប្រព័ន្ធយុត្តិធម៌ត្រូវបញ្ចប់រួចរាល់ គ្មានការអូសបន្លាយពេលវេលាតទៅទៀត សូមឲ្យបន្តការបណ្តុះបណ្តាលអ្នកមានវិជ្ជាជីវៈផ្នែកប្រព័ន្ធយុត្តិធម៌ និងមេធាវី ហើយក៏សូមបន្តបង្កើនតុលាការគំរូផងដែរ។ ក្នុងន័យនេះ សង្គមស៊ីវិលទទួចឲ្យមានការផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពទៅកាន់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីរួមចំណែកចំពោះដំណើរការកែទម្រង់ច្បាប់ និងតុលាការ។

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធជាតិដើម្បីប្រសិទ្ធភាពនៃការអភិវឌ្ឍ

មានការទទួលស្គាល់ថា មានវឌ្ឍនភាពជាច្រើននៅក្នុង**កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ជាពិសេសលើផ្នែកតម្លាភាព និងភាពជឿទុកចិត្តបាននៃថវិកា។ វឌ្ឍនភាពគួរឲ្យកត់សំគាល់នៅក្នុងដំណើរការកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ស៊ីគ្នាជាមួយអត្ថិភាពនៃឯកសារថវិកា ដូចជាការផ្សព្វផ្សាយរបាយការណ៍សវនកម្មឆ្នាំ២០០៧ កាលពីខែវិច្ឆិកា ឆ្នាំ២០១១ ដោយអាជ្ញាធរជាតិសវនកម្ម។ អត្ថិភាពនៃឯកសារនានាបានអនុញ្ញាតឲ្យអង្គការ មិនមែនរដ្ឋាភិបាលផ្តល់មតិ និងការវិភាគ ព័ត៌មានបានកាន់តែសុក្រិត។ ឧទាហរណ៍ មានដូចជាការផលិត និងផ្សព្វផ្សាយព្រឹត្តបត្រស្ថិតិប្រចាំខែបានទាន់ពេលវេលារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាដើម។ ក្រៅពីនេះ មានការផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈកាលពីខែឧសភា ឆ្នាំ២០១១ ដែលអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលផ្តល់យោបល់ ក្នុងនោះមានជាអាទិ៍ ការផ្តល់យោបល់លើការពង្រីក "ខ" ដែលចែងអំពីទោសបញ្ញត្តិ ហើយយោបល់ទាំងនោះត្រូវបានពិចារណានៅពេលកសាងបញ្ចប់ច្បាប់នេះ។

ផ្អែកលើវឌ្ឍនភាពជាដុំកំភួន ដែលសម្រេចបាននៅក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការផ្សព្វផ្សាយ ឯកសារថវិកាមួយចំនួនឲ្យបានទាន់ពេលវេលានិងបានញឹកញាប់ ដូចជា របាយការណ៍សវនកម្មជាដើម នឹងបានទទួលការស្វាគមន៍។ ការបំបែកតួលេខតាមសាមីក្រសួងនៅក្នុងរបាយការណ៍ត្រួតពិនិត្យប្រចាំខែនិងពាក់កណ្តាលឆ្នាំ ព្រម

ទាំងតារាង ប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋាភិបាលប្រចាំឆ្នាំស្តីពីការអនុវត្តច្បាប់ថវិកា ក៏សូមលើកសរសើរជាបន្ត ដើម្បីឲ្យមានតម្លាភាព បន្ថែមទៀត និងដើម្បីអនុញ្ញាតឲ្យភាគីពាក់ព័ន្ធនានាវាស់ស្ទង់ភាពជឿទុកចិត្តបាននៃថវិកា របស់សាមីក្រសួង ធៀបជាមួយតួលេខផែនការនៅក្នុងច្បាប់ថវិកា។ អង្គការមិនមែនរដ្ឋាភិបាលក៏សូមលើកទឹកចិត្តដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនល្បឿនរៀបចំបញ្ចប់ព្រឹត្តបត្របំណុល និងរង់ចាំទទួលបាននូវឯកសារបោះផ្សាយការងារនេះនៅឆ្នាំ២០១២ នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការផ្សព្វផ្សាយសេចក្តី ព្រាងច្បាប់ថវិកា និងឯកសារថវិកាដទៃទៀតដែលមានលក្ខណៈជាប្រព័ន្ធនិងបានទាន់ពេលវេលា ក្នុងទម្រង់ផ្សព្វផ្សាយជាសាធារណៈ ឬតាមរយៈការស្នើសុំ នឹងលើកបង្កើនតម្លាភាពថវិកាយ៉ាងច្រើននៅកម្ពុជា ព្រមជាមួយគ្នានេះផងដែរ ក៏អនុញ្ញាតិឲ្យមានការចូលរួមក្នុងដំណើរការពិភាក្សា និងការចូលរួមពិតប្រាកដ មុនពេលអនុម័តថវិកា។

អង្គការមិនមែនរដ្ឋាភិបាល សូមសរសើរគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំពោះការដាក់បញ្ចូលតំណាងអង្គការមិនមែនរដ្ឋាភិបាលទៅក្នុងបណ្តាញក្រុមការងារបច្ចេកទេស និងការងារកសាងសមត្ថភាព ក៏ដូចជាការប្រើប្រាស់ក្រុមការងារបច្ចេកទេសភាពជាដៃគូនិងសុខដុមនីយកម្ម ធ្វើជាយន្តការត្រួតពិនិត្យ។ ទំនាក់ទំនងទាំងនេះ និងការចែករំលែកចំណេះដឹង គប្បីបន្តអនុវត្ត ព្រោះការធ្វើបែបនេះជួយជម្រុញ **ប្រព័ន្ធជាតិនានាឆ្ពោះទៅរកការសម្រេចបានលទ្ធផលអភិវឌ្ឍន៍កាន់តែមានប្រសិទ្ធភាពបន្ថែមទៀត**។ ដោយមានចំណេះដឹង បច្ចេកទេស និងទស្សនាទានជ្រៅជ្រះ រួមចំណែកចំពោះការបង្កលក្ខណៈអំណោយផលកាន់តែច្រើន ចំពោះការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងដំណើរការសម្របសម្រួលជំនួយ ប្រព័ន្ធទាំងនេះមានគោលដៅផ្តល់អត្ថប្រយោជន៍ ដល់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសប្រជាជនក្រីក្រនិងជនងាយរងគ្រោះ ដែលកំពុងទាមទារឲ្យមានកិច្ចប្រឹងប្រែងរួមគ្នា និងមានការសម្របសម្រួល។

ទោះជាយ៉ាងណាក្តី សូមស្នើឲ្យដាក់បញ្ចូលតំណាងអង្គការមិនមែនរដ្ឋាភិបាល យ៉ាងហោចណាស់ចំនួនមួយរូប ទៅក្នុងការងារវិបស្សនា (ប្រជុំដកពិសោធន៍) និងការកសាងសមត្ថភាពក្រុមការងារបច្ចេកទេស ដើម្បីឲ្យមានការចូលរួម និងសុខុដុមនីយកម្មនៅគ្រប់វិស័យ។ រាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍គប្បីប្រឹងប្រែងរួមគ្នាបន្ថែមទៀតលើសង្គតិភាព និងតម្លាភាពនៃព័ត៌មានស្តីពីជំនួយ ពោលគឺមូលដ្ឋានទិន្នន័យហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ កម្មវិធីវិនិយោគសាធារណៈ និងច្បាប់ថវិកាជាតិ។ ការបន្សុំព័ត៌មាននេះនឹងធ្វើឲ្យមានការវិភាគត្រឹមត្រូវ ដើម្បីកំណត់ថាតើការកសាងផែនការ និងការរៀបចំថវិកាមានទំនាក់ទំនងជាមួយអាទិភាពនៃការអភិវឌ្ឍឬយ៉ាងណា ដែលការណ៍នេះលើកកំពស់ដល់ដំណើការតម្លាភាព និងគណនេយ្យភាព។

ការផ្សព្វផ្សាយឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៨ ដែលបានអនុម័ត ដោយក្រុមប្រឹក្សារដ្ឋមន្ត្រីកាលពីខែកុម្ភៈ ឆ្នាំ២០១២ ជាការស្វាគមន៍បន្ថែមទៀតចំពោះព័ត៌មាន និងតម្លាភាពសារពើពន្ធ។ ឯកសារនេះផ្តល់មធ្យោបាយល្អមួយឆ្ពោះទៅកង្កើនកម្រិតតម្លាភាពថវិកានៅកម្ពុជា ក៏ដូចជាធានាឲ្យការគ្រប់គ្រងបំណុល មាននិរន្តរភាព ដើម្បីឲ្យលទ្ធផលអភិវឌ្ឍន៍មានប្រសិទ្ធភាពបន្ថែមទៀត។

ការអភិវឌ្ឍជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ

គោលនយោបាយទ្រទ្រង់ការគ្រប់គ្រងធនធានធម្មជាតិ ក៏ដូចជាគោលនយោបាយទាំងឡាយដែលការពារការអភិវឌ្ឍ និងសេដ្ឋកិច្ចជនបទ មានសារសំខាន់ជាខ្លាំងចំពោះដំណើរការអភិវឌ្ឍដោយចីរភាពរបស់កម្ពុជា ដោយសារប្រជាជនកម្ពុជាភាគច្រើនពឹងផ្អែកលើធនធានធម្មជាតិ និងសេដ្ឋកិច្ចជនបទទាំងនេះ។

អង្គការមិនមែនរដ្ឋាភិបាល សូមកោតសរសើរដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់ **វិស័យកសិកម្មនិងទឹក** ពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រសួងធនធានទឹក និងឧតុនិយម ដែលបានពង្រឹង និងស្តារនីតិសម្បទាប្រព័ន្ធធារាសាស្ត្រ ពង្រឹងការរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិនានា ព្រមទាំង គោលនយោបាយផ្សេងៗ ដើម្បីឲ្យសម្រេចបានយ៉ាងមានប្រសិទ្ធភាពនូវគោលនយោបាយកសិកម្ម និងទឹក។

ថ្វីបីមានកិច្ចខិតខំប្រឹងប្រែងចម្រុះ នៅក្នុងការរៀបចំផែនការក្តី គេឃើញមានកង្វះខាតមួយចំនួន ពិសេសទាក់ទិននឹងយុទ្ធសាស្ត្រ និងបទប្បញ្ញត្តិផ្សេងៗ សម្រាប់ការធ្វើកសិកម្មខ្នាតតូច។ ខណៈដែល ជំនួញកសិកម្ម និងប្រព័ន្ធធារាសាស្ត្រខ្នាតធំ នៅតែបន្តលើកកម្ពស់ផលិតភាព និងបង្កើនសក្តានុពលនាំចេញ វាមានសារៈសំខាន់ណាស់ដែលយុទ្ធសាស្ត្រកសិកម្ម និងទឹក របស់កម្ពុជា ផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនភាគច្រើន ដែលពឹងផ្អែកលើការធ្វើកសិកម្មលើផ្ទៃដីតូចៗ។ មានការស្នើសុំជាអនុសាសន៍មួយចំនួន ទាក់ទងនឹងហិរញ្ញប្បទាន ការរៀបចំផែនការ និងនិរន្តរភាព នៃវិស័យកសិកម្ម និងទឹក ដែលរួមមាន៖ ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់គម្រោងបង្កើនផលិតភាពស្រូវ ដូចជាការធ្វើកសិកម្មតាមគោលការណ៍ធម្មជាតិ និងប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ក៏ដូចជាប្រព័ន្ធប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យម ដើម្បីទ្រទ្រង់ សមាគមកសិករ ការបង្កើតនូវផែនទីចង្អុលផ្លូវស្តីពីការអនុវត្តយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្មនិងទឹក ដោយមានការ ពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ការបង្កើននូវការផ្គត់ផ្គង់ធាតុចូលកសិកម្ម ដូចជាគ្រាប់ពូជ និងជី ព្រមទាំងរៀបចំ គ្រប់គ្រងឲ្យមានការប្រើប្រាស់ឲ្យបានត្រឹមត្រូវ និងប្រកបដោយសុវត្ថិភាព ការបន្តស្រាវជ្រាវ និងធ្វើពិសោធន៍ ដើម្បីកំណត់ រកគ្រាប់ពូជដែលមានគុណភាព ដែលអាចមានទិន្នផលខ្ពស់ ការបង្កើនចំនួនសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីគ្រប់គ្រង ប្រព័ន្ធធារាសាស្ត្រឲ្យបានសមស្រប និងការកំណត់ជាអាទិភាពនូវការបង្កើនផ្ទៃដីស្រោចស្រពដល់ដីស្រែចំការតូចៗ។

ស្របជាមួយវិស័យកសិកម្ម ប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ គ្រួសារប្រកបរបរនេសាទនៅកម្ពុជាត្រូវបានរកឃើញថាបានជួបការលំបាក ទាំងគ្រួសារក្រីក្រ និងមិនក្រីក្រ ដោយសារការលំបាកធំធេង ដែលបណ្តាលមកពីការឡើងថ្លៃស្បៀងអាហារ និងការបន្តធ្លាក់ចុះនៃប្រាក់ចំណូលដែលបណ្តាលមកពីដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ច។ ទំនុកបម្រុង និងការយកចិត្តទុកដាក់បន្ថែម គប្បីត្រូវបានផ្តោតទៅលើ**វិស័យផលផល** ពិសេសដោយពិចារណាអំពីការរួមចំណែកនៃផ្នែកនេះ ចំពោះសន្តិសុខស្បៀងនៅថ្នាក់ជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ច។

ដើម្បីលើកកំពស់ជីវភាពរស់នៅ ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច និងសន្តិសុខស្បៀង អង្គការមិនមែនរដ្ឋាភិបាលសូមស្នើឲ្យដាក់វិស័យជលផលថ្នាក់ក្រោមជាតិឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ទៅក្នុងអាទិភាពទាំងឡាយរបស់ឃុំ និងស្រុក។ សកម្មភាពបែកខ្ញែកគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពួកគេអាចមិនបានដឹងអំពីដំណើរការវិមជ្ឈការនានា អាចធ្វើឲ្យអន្តរាយដល់ការនេសាទដោយចីរភាព ពិសេសការនេសាទខុសច្បាប់ និងសហគមន៍នេសាទដែលគ្មានការ គ្រប់គ្រង និងមិនបានចុះបញ្ជី។ បន្ថែមលើការដោះស្រាយបញ្ហាទាំងនេះ ផែនការគ្រប់គ្រងដែលមានប្រសិទ្ធភាព ត្រូវរៀបចំឡើងតាមរយៈវេទិកាដែលមានការចូលរួម និងមានការពិគ្រោះយោបល់ទូលំទូលាយជាមួយអ្នកប្រើប្រាស់ធនធាននៅមូលដ្ឋាន ដើម្បីឲ្យការរៀបចំផែនការពិចារណាលើស្ថានភាពសង្គម និងបរិស្ថាន សម្រាប់ឲ្យការគ្រប់គ្រងវិស័យ ជលផលបានប្រកបដោយនិរន្តរភាពជំនួសមុខឲ្យពលរដ្ឋទាំងឡាយ។ ហើយទាំងសមត្ថភាពគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ និងសមត្ថភាពគ្រប់គ្រងរបស់សហគមន៍នេសាទ គប្បីត្រូវបានពង្រឹង។

ដូចបានបញ្ជាក់រួចមកហើយ ដោយសារគ្រួសារភាគច្រើនបង្កើតឱកាសសេដ្ឋកិច្ចរបស់គេតាមរយៈកសិកម្ម និងការនេសាទ ការមានលទ្ធភាពទទួលបានដីប្រកបដោយសមធម៌ និងសន្តិសុខលើការកាន់កាប់ដីធ្លី មានសារៈសំខាន់ ជាសារវន្តចំពោះការអភិវឌ្ឍសេដ្ឋកិច្ច។ គោលនយោបាយ និងនីតិវិធីរដ្ឋបាលនានា ទាក់ននឹង**កំណែទម្រង់ដីធ្លី** ចាំបាច់ត្រូវតែពង្រឹងដោយហេតុថាលទ្ធភាពទទួលបានដីប្រកបដោយសមធម៌ និងសន្តិសុខដីធ្លីនៅមិនទាន់សម្រេចបាននៅឡើយ។ បច្ចុប្បន្នប្រជាជនក្រីក្រនៅទីក្រុង និងជនបទ នៅតែប្រឈមមុខនឹងអសន្តិសុខលើការកាន់កាប់ដីធ្លី ព្រមទាំងការបណ្តេញចេញដោយបង្ខំ។ អង្គការមិនមែនរដ្ឋាភិបាល មានកង្វល់ចំពោះការបន្ត និងការកើនឡើងនូវការប្រើប្រាស់កម្លាំងយោធាក្នុងវិវាទដីធ្លី ដោយសារព្រឹត្តិការណ៍ហឹង្សាបានកើនឡើងរវាងអាជ្ញាធរប្រដាប់អាវុធ និងប្រជាពលរដ្ឋ ដែលការពារដីរបស់ពួកគេ និងសិទ្ធិលើធនធានធម្មជាតិ ដោយសន្តិភាព។

ខណៈដែលអង្គការមិនមែនរដ្ឋាភិបាល ទទួលស្គាល់ដំណើរការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ ដែលបានផ្តល់បណ្ណកម្មសិទ្ធិចំនួន១,៧ លានច្បាប់ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១១ បញ្ហាជាក់ស្តែងមួយចំនួននៅតែបន្ត ដែលក្នុងនោះប្រជាពលរដ្ឋជាច្រើន ពិសេសនៅតំបន់ទីក្រុង នៅតែជួបបញ្ហាជាច្រើនជុំវិញការចុះបញ្ជីដីធ្លី។ បន្ថែមពីលើនេះ ការបណ្តេញ

ចេញ និងការតាំងទីលំនៅជាថ្មីនៅតែបន្តកើតមាន បន្ទាប់ពីមានការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលប្រការនេះ បង្ហាញថា ធាតុមួយនៃបណ្តាធាតុសំខាន់បំផុតសម្រាប់សន្តិសុខគ្រួសារ ពោលគឺ គោលនយោបាយគ្រប់ជ្រុងជ្រោយ ស្តីពីការតាំងទីលំនៅជាថ្មី និងបទប្បញ្ញត្តិទាក់ទិនទាំងឡាយ នៅពុំទាន់មាននៅឡើយ។ អង្គការមិនមែនរដ្ឋាភិបាល ស្វែងរកការបំភ្លឺអំពីជំហានបន្ទាប់ លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការតាំងទីលំនៅក្រៅផ្លូវការ និងសង្ឃឹមថានឹងមានការ ពិគ្រោះយោបល់ជាសាធារណៈពេញលេញមួយលើសេចក្តីព្រាងបន្ទាប់។

ជាងនេះទៅទៀត ការធ្វើចំណាត់ថ្នាក់ដីរដ្ឋដោយអាជ្ញាធរមូលដ្ឋាន គប្បីត្រូវបានបញ្ឈប់ ដោយដីរដ្ឋគួរត្រូវបានកំណត់អត្តសញ្ញាណ កំណត់ព្រំដី និងចុះបញ្ជីដោយតម្លាភាព ស្របតាមស្មារតីអនុក្រឹត្យ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋ។ ទន្ទឹមគ្នានេះដែរ ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិច គប្បីត្រូវបានពន្លឿន ព្រោះថាសហគមន៍ទាំងនេះមានកង្វល់ថា ដំណើរការយឺតនៃការចុះបញ្ជី អាចធ្វើឲ្យមានការបាត់បង់ដី និងការលំបាកផ្សេងៗក្នុងការទទួលបានបណ្ណកម្មសិទ្ធិដី សហគមន៍។

ជារួម រាជរដ្ឋាភិបាលកម្ពុជា គប្បីស្វែងរកយន្តការទាំងឡាយ ដើម្បីបង្កើនល្បឿននៃដំណើរការដ៏មានតម្លាភាពនៃការបែងចែកដីធ្លីប្រកបដោយសមធម៌។ ខណៈដែលសម្បទានដីសង្គមកិច្ច ត្រូវបានអនុវត្ត ដោយបែងចែកដីទៅឲ្យគ្រួសារ គ្មានដី និងក្រីក្រ សម្បទានទាំងនេះហាក់ដូចជាមិនសូវសំខាន់ បើធៀបជាមួយនឹងចំនួនក្បាលដី និងទំហំដី ដែលត្រូវ បានផ្តល់ឲ្យសម្រាប់សម្បទានសេដ្ឋកិច្ច។ ដើម្បីពន្លឿន និងធ្វើដំណើរការផ្តល់ដីសម្បទានសង្គមកិច្ចឲ្យមានលក្ខណៈជាប្រព័ន្ធ ដីដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច គប្បីផ្ទេរទៅជាសម្បទានដីសង្គមកិច្ច ហើយក្រសួងពាក់ព័ន្ធដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ ចាំបាច់ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីរៀបចំវិធីសាស្ត្ររួមគ្នាមួយ សំដៅកំណត់អត្តសញ្ញាណដី កសិកម្មសមស្របសម្រាប់សម្បទានដីសង្គមកិច្ច និងរៀបចំផែនការសម្បទានដីសង្គមកិច្ចនៅថ្នាក់ជាតិ។

អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើ**វិស័យព្រៃឈើ**ទទួលស្គាល់បំណងរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសរដ្ឋបាលព្រៃឈើ លើការដាំដើមឈើលើដីវិចារិល ការកំណត់ព្រំប្រទល់ព្រៃឈើនិងតំបន់ការពារ បង្កើនការអនុម័តចំនួននៃសហគមន៍ព្រៃឈើ និងការធ្វើឲ្យមានភាពចូលរួមកាន់តែច្រើនក្នុងដំណើរការរៀបចំផែនទីបង្ហាញផ្លូវREDD+ ថ្នាក់ជាតិ ដូចដែលត្រូវបានលើកឡើងនៅក្នុងសូចនាករតាមដានរួម។ ប៉ុន្តែ អង្គការមិនមែនរដ្ឋាភិបាលសូមស្នើសុំឲ្យរាជរដ្ឋាភិបាលកម្ពុជា/រដ្ឋបាលព្រៃឈើ កំណត់និយមន័យនៃព្រៃឈើជា "ព្រៃឈើធម្មជាតិ" និងមិនរាប់បញ្ចូលចំការឈើដាំ បង្កើនទំហំសហគមន៍ព្រៃឈើ សម្រួលនិងពន្លឿននីតិវិធីចុះបញ្ជីសហគមន៍ព្រៃឈើនិងសហគមន៍តំបន់ការពារ និងធានាអោយមានការពារដល់សហគមន៍ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាល ដោយមានការចូលរួមពេញលេញពីសហគមន៍ និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តវិធានការដែលមានការឯកភាពជាអន្តរជាតិ និងមានការលើកទឹកចិត្តចំពោះគម្រោង REDD។

អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងផ្នែក**ការពារបរិស្ថាន អភិរក្ស និងការប្រែប្រួលអាកាសធាតុ** មានកង្វល់អំពីការដែលសូចនាករតាមដានរួម លើវិស័យព្រៃឈើ និងបរិស្ថាន កំពុងផ្តោតជាសំខាន់តែលើវិស័យព្រៃឈើ ដោយមិនបានដោះស្រាយបញ្ហាប្រែប្រួលធាតុអាកាសឲ្យបានគ្រប់គ្រាន់ឡើយ។ មានការស្នើសុំឲ្យរាជរដ្ឋាភិបាលកម្ពុជា ដាក់បញ្ចូលសំណុំសូចនាករតាមដានរួមដោយឡែក ដែលផ្តោតជាពិសេសលើការប្រែប្រួលធាតុអាកាស និងការកាត់បន្ថយ គ្រោះមហន្តរាយ ដើម្បីសម្រួលដល់យន្តការគណនេយ្យភាព និងការវាយតម្លៃលើសមិទ្ធកម្មនៃការងារដែលកំពុងត្រូវបានអនុវត្តលើបញ្ហាទាំងនេះ។

អង្គការមិនមែនរដ្ឋាភិបាល វាយតម្លៃខ្ពស់ចំពោះការបង្កើតអនុក្រឹត្យ និងប្រកាស គ្រប់គ្រងលើដំណើរការនៃការរៀបចំឡើងនូវ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ខណៈដែលមានការកត់សំគាល់ ផងដែរថាគុណភាព នៃការវាយតម្លៃទាំងនោះនៅមិនទាន់បានល្អនៅឡើយ ហើយជាទូទៅអង្គការសង្គមស៊ីវិល មិនទាន់ទទួលបាននូវពេល វេលាគ្រប់គ្រាន់សម្រាប់ពិនិត្យមើល និងផ្តល់យោបល់លើរបាយការណ៍ទាំងនោះនៅឡើយ។ ជារួម អនុសាសន៍ខាងក្រោមត្រូវបានគូសបញ្ជាក់ ដើម្បីធានាឲ្យការអភិវឌ្ឍមាននិរន្តរភាពលើផ្នែកបរិស្ថាន ដែលរួមមាន: ការចាត់តាំងគណៈកម្មាធិការតាមដានការ

ផ្តល់នូវពេលវេលាឲ្យបានគ្រប់គ្រាន់ដល់អង្គការសង្គមស៊ីវិល ក្នុងការផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាឲ្យមានការវាយតម្លៃប្រកបដោយគុណភាព ការរៀបចំគោលការណ៍ណែនាំច្បាស់លាស់ដើម្បីអប់រំសហគមន៍អំពីការកាត់បន្ថយគ្រោះមហន្តរាយ ដែលត្រូវបានបញ្ចូលទៅក្នុងកម្មវិធីអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនានា លើវិស័យកសិកម្ម ថាមពល ព្រៃឈើ ធនធានទឹក ឧស្សាហកម្ម និងសុខាភិបាល ការរៀបចំឲ្យបានឆាប់រហ័សនូវច្បាប់នានាពាក់ព័ន្ធនឹងបរិស្ថាន ដែលនៅមិនទាន់បានព្រាងនៅឡើយ ប៉ុន្តែដែលត្រូវបានគ្រោងឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៩-២០១៣ ការអភិវឌ្ឍថាមពលអគ្គិសនី និងការកាត់បន្ថយនូវការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការបង្កើតក្រុមការងារ បច្ចេកទេសស្តីពីបរិស្ថាន និងការប្រែប្រួលធាតុអាកាស។

ជាមួយគ្នានេះដែរ អង្គការមិនមែនរដ្ឋាភិបាល សូមកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយ**ផលប៉ះពាល់បរិស្ថាន និងសង្គម ពីឧស្សាហកម្មនិស្សារណកម្ម (ប្រេង ឧស្ម័ន និងរ៉ែ)**។ យ៉ាងនេះក្តី គេសង្កេតឃើញមានកង្វល់មួយចំនួនទាក់ទិននឹង ការអនុវត្តច្បាប់រ៉ែបច្ចុប្បន្ន ការផ្លាស់ប្តូរទីកន្លែង និងសំណង ការទទួលបានព័ត៌មានពីស្តារ និងទាន់ពេលវេលា កង្វះការពិគ្រោះយោបល់ពេញលេញលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការដែលសមត្ថភាពផ្នែកស្ថាប័ននៅមានកម្រិតនៅឡើយ។ អាស្រ័យហេតុនេះ អង្គការមិនមែនរដ្ឋាភិបាល សូមស្នើឲ្យរាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ មេត្តាពង្រឹងនូវក្របខណ្ឌច្បាប់ដែលមានស្រាប់អនុញ្ញាតឲ្យមានការចូលរួមជាសាធារណៈឲ្យបានពេញលេញក្នុងដំណើរការពង្រាងច្បាប់ គោលនយោបាយពាក់ព័ន្ធនានា និងរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពិនិត្យមើលឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រង ធនធានរ៉ែ និងការធ្វើអាជីវកម្មរ៉ែ ដោយមានការពិគ្រោះយោបល់ឲ្យបានជិតដល់ជាមួយនឹងផ្នែកទាំងឡាយនៃសង្គម ដែលរងផលប៉ះពាល់ ដើម្បីធានាឲ្យមានការការពារគ្រប់គ្រាន់ចំពោះប្រជាជន និងបរិស្ថាន ដែលស្របតាមស្តង់ដារអន្តរជាតិ សម្រាប់វិស័យរ៉ែ និងផ្សព្វផ្សាយព័ត៌មានដល់សាធារណជនតាមរយៈប្រព័ន្ធអ៊ិនធើណិត។

បន្ថែមពីលើនេះ ដៃគូអភិវឌ្ឍន៍មកពីប្រទេសដែលមានក្រុមហ៊ុនរ៉ែនៅកម្ពុជា គប្បីធ្វើយ៉ាងណាធ្វើការជាមួយ រដ្ឋាភិបាលរបស់ខ្លួន និងក្រុមហ៊ុនទាំងនេះ ដើម្បីធានាឲ្យបានថាក្រុមហ៊ុនទាំងនេះគោរពតាមស្តង់ដារអន្តរជាតិខ្ពស់បំផុត នៃការប្រតិបត្តិល្អ។ ក្នុងន័យសំខាន់ដូចគ្នានេះ ក្រុមហ៊ុនរ៉ែត្រូវបានលើកទឹកចិត្តឲ្យបណ្តុះបណ្តាលសមាជិកបុគ្គលិកទាំងអស់អំពីសន្តិសុខ ដោយអនុលោមតាម គោលការណ៍ស្មគ្រចិត្តរវាងចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ស្តីពីសន្តិសុខ និងសិទ្ធិមនុស្ស និងបង្កើតកម្មវិធីអប់រំ និងផែនការបណ្តុះបណ្តាលផ្សេងៗ (ដោយមានកាលកំណត់អនុវត្តជាក់លាក់មួយ) សម្រាប់បុគ្គលិកកម្ពុជា ដើម្បីធានាឲ្យបានថាបុគ្គលិកក្នុងស្រុក មានជំនាញគ្រប់គ្រាន់ក្នុងការបំពេញការងារក្នុងតំណែងបច្ចេកទេសនានា។

ក្តីកង្វល់នានាជុំវិញការកសាង**ទំនប់វារីអគ្គិសនី និងវិស័យថាមពល** មានសង្គតិភាពជាមួយកង្វល់នានាលើការការពារបរិស្ថាន និងការប្រែប្រួលធាតុអាកាស។ ខណៈដែលរាជរដ្ឋាភិបាលកម្ពុជា បានឈានទៅមុខក្នុងការបង្កើន ការប្រើប្រាស់ថាមពលកកើតជាថ្មី តាមរយៈការផ្តត់ផ្គង់អគ្គិសនីទៅកាន់ទីជនបទ និងការជម្រុញការធ្វើវិមជ្ឈការផលិតកម្ម ថាមពលអគ្គិសនី ការអភិវឌ្ឍទំនប់វារីអគ្គិសនីធំៗលើទន្លេសំខាន់ៗដូចជា ទន្លេសេសាន ជាដើម អាចធ្វើឲ្យខូចខាត បរិស្ថានធ្ងន់ធ្ងរដោយប៉ះពាល់ជាអវិជ្ជមានចំពោះការផ្តត់ផ្គង់ទឹក ធនធានជលផល ធនធានដីធម្មជាតិ និងធនធានសមុទ្រ។ អង្គការមិនមែនរដ្ឋាភិបាលមានកង្វល់ថា ការសាងសង់ទំនប់វារីអគ្គិសនីធំៗទាំងនេះ នៅភាគ នីរតីនៃប្រទេសកម្ពុជា អាចបង្កើនការធ្វើឲ្យប្រែដល់ទឹកក្រោមដីនៅតំបន់ឆ្នេរ ធ្វើឲ្យប៉ះពាល់ដល់កសិកម្មនៅក្នុងតំបន់នោះ។

ទាក់ទិននឹងសូនាការតាមដានរួម មានការស្នើសុំឲ្យរាជរដ្ឋាភិបាលកម្ពុជា ជម្រុញការប្រើប្រភពថាមពលដែលមានប្រសិទ្ធភាព ដែលមានផលប៉ះពាល់តិចបំផុតលើបរិស្ថាន ហើយរៀបចំ និងផ្សព្វផ្សាយគោលនយោបាយ និងច្បាប់ផ្សេងៗ ធ្វើយ៉ាងណាធានាឲ្យការអភិរក្សបរិស្ថានប្រកបដោយចីរភាព និងជីវភាពរស់នៅរបស់សហគមន៍ក្លាយជាអាទិភាព នៅក្នុងវិស័យថាមពល។ ដោយហេតុថា បញ្ហាមួយចំនួនមិនត្រូវបានលើកឡើងនៅក្នុងសូចនាករតាមដានរួម មានការស្នើសុំឲ្យទទួល

ស្គាល់នូវអាទិភាពមួយចំនួន ដើម្បីការពារបរិស្ថាន និងសិទ្ធិសហគមន៍ ដែលចំណុចទាំងនោះរួមមាន ការអនុវត្តកិច្ចប្រតិបត្តិល្អប្រសើរកម្រិតអន្តរជាតិ ស្តីពីសំណងចំពោះសហគមន៍រងផលប៉ះពាល់អវិជ្ជមានពីទំនប់វារីអគ្គិសនី និងការដោះស្រាយទំនាស់ឆ្លងព្រំដែនទឹក ដើម្បីធ្វើយ៉ាងណាកុំឲ្យគម្រោងវារីអគ្គិសនីឆ្លងដែនប៉ះពាល់ជាអវិជ្ជមានដល់ សហគមន៍នានានៅកម្ពុជា។

ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្សគប្បីយល់ថាជាការវិនិយោគមួយ ដែលធ្វើឲ្យប្រជាជនកម្ពុជា ជាពិសេសកុមារ និងយុវជនកម្ពុជាអាចឈានទៅសម្រេចបាននូវសក្តានុពលសង្គម និងសេដ្ឋកិច្ចរបស់ខ្លួន។

គេឃើញមានការរីកចម្រើនយ៉ាងច្រើននៅក្នុង**វិស័យអប់រំ** តាមរយៈការវាស់ស្ទង់ដោយសូចនាករតាមដានរួម ដោយអត្រាសិស្សឡើងថ្នាក់បានកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំសិក្សា ២០០៩-២០១០ មក។ ជាងនេះទៅទៀត ផែនការសកម្មភាពអភិវឌ្ឍន៍គ្រូបង្រៀន (២០១០-២០១៤) ទទួលស្គាល់ថា គុណវុឌ្ឍិសិក្សារបស់គ្រូបង្រៀនចាំបាច់ត្រូវបង្កើន ដើម្បីធ្វើឲ្យអ្នកអប់រំមានជំនាញសមស្របក្នុងការអប់រំសិស្ស។ ការបង្កើនសមត្ថភាព និងបទពិសោធន៍របស់គ្រូបង្រៀនគឺជាបញ្ហាសំខាន់មួយជាសារវន្តពាក់ព័ន្ធនឹងការលើកកំពស់គុណភាពអប់រំនៅកម្ពុជា។

បញ្ហានានានៅក្នុងវិស័យអប់រំនៅតែកើតមាន ប៉ុន្តែមានបញ្ហាសំខាន់ៗដែលចាំបាច់ត្រូវចាត់វិធានការជាបន្ទាន់ នោះគឺ កង្វះគ្រូបង្រៀននិងកង្វះបុគ្គលិកចំពោះសាលារៀននៅតំបន់ឆ្ងាយដាច់ស្រយាល ប្បញ្ញត្តិអំពីការតម្លើងថ្នាក់ និងការធានាឲ្យមានការអនុវត្តបទប្បញ្ញត្តិនានាចំពោះកម្មវិធីអប់រំរបស់ដៃគូអភិវឌ្ឍន៍ ធានាឲ្យមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានសេវាអប់រំ កាត់បន្ថយឧបសគ្គលើការចំណាយរបស់មាតាបិតាសិស្សនិងកាត់បន្ថយថ្លៃសាលាក្រៅប្រព័ន្ធ ការរក្សាចំនួនសិស្សនិងការកាត់បន្ថយចំនួនសិស្សបោះបង់ចោលការសិក្សា បង្កើនគុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ និងជាចុងបញ្ចប់គឺការពង្រឹងការអភិវឌ្ឍស្ថាប័ន ព្រមទាំងការកសាងសមត្ថភាពដើម្បីធ្វើវិមជ្ឈការ។

បញ្ហាមួយចំនួននៅតែមាន ដោយសារការគ្រប់គ្រងមិនត្រឹមត្រូវនូវធនធានអប់រំនិងបុគ្គលិក ដែលធ្វើឲ្យប៉ះពាល់ជាខ្លាំង ដល់តំបន់ជនបទដាច់ស្រយាល និងតំបន់ដែលមានស្ថានភាពលំបាកលំបិននានា។ ដោយបញ្ហាកង្វះគ្រូបង្រៀន នៅតែជាបញ្ហាធ្ងន់ធ្ងរមួយចំពោះគុណភាពអប់រំ សូមជូនយោបល់សូមពង្រីកគោលនយោបាយជ្រើសរើសគ្រូបង្រៀននៅមូលដ្ឋានទៅកាន់តំបន់ជនបទដាច់ស្រយាលនិងតំបន់ដែលមានស្ថានភាពលំបាកលំបិន សូមពិចារណាអំពីការបែងចែងឡើងវិញនូវថវិកាបុគ្គលិកនិងការកែលំអប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីឲ្យការបើកផ្តល់ប្រាក់បៀវត្សប្រព្រឹត្តទៅបានត្រឹមត្រូវ និងទាន់ពេលវេលា។ ការធានាឲ្យបានថា អ្នកអប់រំទទួលបានការបណ្តុះបណ្តាលនិងទទួលបានការលើកទឹកចិត្តសមស្រប មិនត្រឹមតែកែលំអលើបញ្ហាបុគ្គលិកប៉ុណ្ណោះទេ ប៉ុន្តែក៏អាចលើកកំពស់គុណភាពអប់រំផងដែរ ព្រោះថាកុមារនិងយុវជននឹងរៀនសូត្រពីគ្រូដែលមានជំនាញ។ ជាមួយនឹងការមានឧបករណ៍លើកទឹកចិត្តសមស្រប និងការផ្តល់បៀវត្សបានត្រឹមត្រូវដល់គ្រូបង្រៀន បញ្ហាថ្លៃសាលាក្រៅផ្លូវការដែលច្រើនតែជាបន្ទុកចំណាយបន្ថែមចំពោះគ្រួសារក្រីក្រ ក៏អាចលុបបំបាត់បានដែរ។ ជាងនេះទៅទៀត ធនធាននានា ដូចជាសាលារៀននិងសៀវភៅសិក្សាថ្មីៗដែលមានគុណភាព ក៏ចាំបាច់ត្រូវពិចារណាផងដែរក្នុងការកសាងផែនការនិងក្នុងការរៀបចំថវិកា។ តាមរយៈបុគ្គលិក និងសម្ភារៈដែលមានគុណភាព គេអាចកាត់បន្ថយអត្រារៀនត្រួតថ្នាក់និងអត្រាបោះបង់ចោលការសិក្សា ដែលធ្វើឲ្យការចំណាយធនធានមានប្រសិទ្ធភាព ហើយកុមារទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដើម្បីឲ្យទទួលជោគជ័យ។

ទន្ទឹមនឹងវឌ្ឍនភាពក្នុងវិស័យអប់រំ អង្គការមិនមែនរដ្ឋាភិបាល ក៏សូមអបអរសាទរចំពោះក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជាផងដែរ ក្នុងការសម្រេចបាននូវសមិទ្ធផលជាច្រើនលើ**វិស័យសុខាភិបាល** រួមមានការធ្លាក់ចុះនូវប្រេវ៉ាឡង់មេរោគអេដស៍ ដោយធានាឲ្យអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ទាំងអស់បានទទួលការព្យាបាលដោយថ្នាំពន្យារជីវិត ការបង្កើនអន្តរាគមន៍ចំពោះជម្ងឺរបេងដែលមានអត្រាជាសះស្បើយកើនដល់ ៩២% និងអត្រារកឃើញមេរោគរបេង ៦២% ការកាត់បន្ថយអត្រាស្លាប់យ៉ាងច្រើនចំពោះកុមារអាយុតិចជាងប្រាំឆ្នាំក៏ដូចជាអត្រាស្លាប់របស់មាតា ការធានាឲ្យផែនការលុប

បំបាត់ជម្ងឺគ្រុនចាញ់អនុវត្តបានត្រឹមត្រូវដែលត្រូវសម្រេចឲ្យបាននៅឆ្នាំ២០១៥ ព្រមទាំងមានសញ្ញាបង្ហាញថាជម្ងឺតេតាណុសនិងកញ្ជ្រឹលក៏កំពុងជិតផុតរលត់ហើយដែរ និងការលើកកំពស់សេវាថែទាំសុខភាពចំពោះអ្នកដែលកំពុងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រតាមរយៈមូលនិធិសមធម៌សុខភាព។

ទោះបីជាមានសមិទ្ធផលជាច្រើនក្តី អង្គការមិនមែនរដ្ឋាភិបាលសូមលើកឡើងនូវបញ្ហាប្រឈមមួយចំនួន ដើម្បីទាញការចាប់អារម្មណ៍ពីសំណាក់អ្នករៀបចំគោលនយោបាយ និងដៃគូសុខាភិបាល។ បច្ចុប្បន្ននេះ អន្តរាគមន៍ដែលផ្តល់លទ្ធផលខ្ពស់ក្នុងការលើកកំពស់សេវាសុខភាពមាតា ទារក និងកុមារ មានមិនគ្រប់គ្រាន់ រួមមាន (១) សង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងការថែទាំទារក (២) ការរំលូតកូនដោយសុវត្ថិភាពនិងការរៀបចំផែនការគ្រួសារ (៣)ការថែទាំទារកទើបកើត និងអាហារូបត្ថម្ភ។ ខណៈពេលដែលកម្ពុជានៅត្រូវការការគាំទ្ររយៈពេលវែង ដើម្បីរក្សាជោគជ័យនៃការឆ្លើយតបចំពោះ មេរោគអេដស៍/ជំងឺអេដស៍ ការគាំទ្រផ្នែកហិរញ្ញវត្ថុចាំបាច់ត្រូវផ្តោតលើគោលការណ៍ភាពជាម្ចាស់នៃប្រទេសកម្ពុជា ដោយកសាងប្រព័ន្ធថែទាំសុខភាពកាន់តែបានល្អប្រសើរ ដែលអាចធានាឲ្យមានចីរភាពលើការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ដោយគ្មានការគាំទ្រពីបរទេស។ គប្បីទាញផលឲ្យបានជាអតិបរមាពីការគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីកសាងប្រព័ន្ធសុខាភិបាលជាតិឯករាជ្យដែលមានសមត្ថភាពត្រួតពិនិត្យការគ្រប់គ្រងថ្នាំពេទ្យនិងត្រួតពិនិត្យការគ្រប់គ្រងការផ្គត់ផ្គង់ ការទទួលបានការថែទាំសុខភាពដែលមានគុណភាព និងប្រព័ន្ធបញ្ជូនអ្នកជំងឺ។ ដើម្បីធានាបាននូវភាពជាម្ចាស់របស់កម្ពុជាចំពោះប្រព័ន្ធថែទាំសុខភាពជាតិ ការលើកកំពស់និងការថែទាំសុខភាពអាចត្រូវបានបង្កើនឡើង ហើយសេវាសុខភាពសាធារណៈ សម្រាប់ពលរដ្ឋកម្ពុជាជាពិសេសសម្រាប់ពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះ អាចត្រូវបានគ្រប់គ្រងដោយប្រសិទ្ធភាព ដើម្បីឲ្យមានលទ្ធផលអភិវឌ្ឍន៍ធនធានមនុស្សកាន់តែប្រសើរ។

ប្រជាជនដែលទទួលបានការអប់រំ ហើយដែលមានសុខភាពល្អ គឺជាមូលដ្ឋានគ្រឹះនៃកម្លាំងពលកម្មដែលមានប្រសិទ្ធភាព និងផលិតភាព។ ទោះជាយ៉ាងណាក្តី **កង្វល់ស្តីពីការងារ និងលក្ខខណ្ឌការងារ** នៅតែជាមូលហេតុធ្វើឲ្យមានក្តីកង្វល់នៅកម្ពុជា។ ជាមួយនឹងកម្លាំងពលកម្មភាគច្រើនបំរើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រុមពលរដ្ឋទាំងនេះមានប្រាក់ចំណូលទាបនិងប្រាក់ឈ្នួលមិនសមរម្យ មិនបានទទួលបានអត្ថប្រយោជន៍សន្តិសុខសង្គមនិងសន្តិសុខការងារ មានលក្ខខណ្ឌការងារមិនសមស្រប ហើយច្រើនមានគ្រោះថ្នាក់ និងចូលរួមតិចតួចទៅក្នុងសហជីពនិងសមាគមកម្មករ។

លក្ខខណ្ឌការងារល្អនឹងផ្តល់បរិយាកាសសមស្របចំពោះនិយោជិតឲ្យនៅតែមានផលិតភាព និងមានសុខភាពល្អ។ ក្នុងន័យនេះជាសំខាន់ រាជរដ្ឋាភិបាលកម្ពុជាអាចបង្កើតយន្តការសមស្របដើម្បីអនុវត្តច្បាប់ការងារ ក៏ដូចជាលិខិតូបករណ៍ច្បាប់ជាតិ និងអន្តរជាតិចំពោះស្តង់ដារការងារ។ ការផ្តល់មធ្យោបាយចាំបាច់ដើម្បីលើកកំពស់សិទ្ធិរបស់កម្មករ ដូចជាកិច្ចព្រមព្រៀងចរចារួមគ្នា និងលទ្ធភាពចូលសហជីពនិងសមាគម មិនត្រឹមតែលើកកំពស់លក្ខខណ្ឌការងារប៉ុណ្ណោះទេ ប៉ុន្តែក៏មានសក្តានុពលបង្កើនផលិតភាពនិងពាណិជ្ជកម្មផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាអាចបន្តធានាឲ្យមានលក្ខខណ្ឌការងារល្អប្រសើរ ដើម្បីបង្កើនផលិតភាពនិងពាណិជ្ជកម្ម តាមរយៈការអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវស្តង់ដារការងារ ច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិ ការបន្តគម្រោង "រោងចក្រកាន់តែល្អប្រសើរ" ដែលគាំទ្រដោយអង្គការពលកម្មអន្តរជាតិ ការជួយសម្រួលការងារនៅបរទេសចំពោះកម្មករ និងការផ្សាភ្ជាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយតម្រូវការទីផ្សារ។

ការអភិវឌ្ឍធនធានមនុស្ស មិនត្រឹមតែត្រូវអនុវត្តលើប្រជាជនដែលតំណាងចំនួនភាគច្រើនប៉ុណ្ណោះទេ ក៏ត្រូវដាក់បញ្ចូលនូវ**សិទ្ធិកុមារ និងពិការភាព** ផងដែរ។ បញ្ហាប្រឈមចំពោះការអភិវឌ្ឍធនធានមនុស្ស ច្រើនកើតឡើងចំពោះអ្នកទាំងឡាយណា ដែលគ្មានលទ្ធភាពជម្រុញឲ្យមានការគាំទ្រចំពោះពួកខ្លួន។ បច្ចុប្បន្ននេះ គ្មានយន្តការតាមដានសមស្របចំពោះសកម្មភាពនានាដែលធានាឲ្យបានទៅដល់កុមារក្រីក្រនិងកុមារងាយរងគ្រោះ ក៏ដូចជាអ្នកដែលមានពិការភាពឡើយ។ ខណៈពេលដែលរាជរដ្ឋាភិបាលជាហត្ថលេខីមួយនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនពិការ និងពិធីសារមិនចាប់បង្ខំ (ដែលត្រូវផ្តល់សច្ចាប័ន) និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារចាំបាច់ត្រូវអនុវត្ត។ គោលនយោបាយត្រូវពង្រឹង ហើយប្រព័ន្ធផ្សេងៗត្រូវកសាងដើម្បីជម្រុញឲ្យមានការចូលរួមរបស់កុមារ និងអ្នករស់នៅក្នុងពិការភាពក្នុងសង្គម ដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍប្រកបដោយសមធម៌ និងមានភាពជិតស្និទ្ធ។

ផែនការអភិវឌ្ឍន៍ជាតិ

អង្គការសង្គមស៊ីវិល សូមវាយតម្លៃខ្ពស់ចំពោះឱកាសដែលផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ និងការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការនេះ និងសូមអះអាងសារជាថ្មីនូវការប្តេជ្ញារបស់យើងចូលរួមក្នុងន័យស្ថាបនាជាមួយរាជរដ្ឋាភិបាលកម្ពុជា លើកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម និងយុទ្ធសាស្ត្រចតុកោណ។ ជាមនសិការខាងសង្គមកិច្ច និងសេដ្ឋកិច្ចរបស់យើង អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល មិនត្រឹមតែសម្តែងការវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលរបស់រដ្ឋាភិបាលកម្ពុជាក៏សូមលើកឡើងនូវកង្វល់របស់យើងអំពីសកម្មភាពជាក់ស្តែង ដែលហាក់បីដូចជាមិនស្របគ្នា ឬខុសពីគោលដៅគោលនយោបាយទាំងឡាយដែលមានចែងនៅក្នុងសូចនាករតាមដានរួម (JMIs) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣។ ដើម្បីធានា **ភាពជាម្ចាស់របស់ប្រទេសលើផែនការអភិវឌ្ឍន៍ជាតិ** អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល សូមអំពាវនាវឲ្យរដ្ឋាភិបាលធ្វើឲ្យសម្រេចបាននូវការប្តេជ្ញាចិត្តរបស់ខ្លួន ដែលមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម និងគិតគូឲ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលយ៉ាងទូលំទូលាយក្នុងដំណើរការរៀបចំរបាយការណ៍នានាទៅពេលអណាគត លើការអនុវត្តផែនការអភិវឌ្ឍន៍ជាតិ និងការបង្កើតផែនការអភិវឌ្ឍន៍ថ្មី ដោយធ្វើឲ្យប្រសើរឡើងនូវធាតុចូល ទិន្នផល លទ្ធផល និងសូចនាករនៃផលប៉ះពាល់ និងដាក់បញ្ចូលតារាងម៉ាទ្រីសគោលនយោបាយ។

សេចក្តីផ្តើម

ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជាបានគ្របដណ្តប់ទៅលើបញ្ហាអភិវឌ្ឍន៍យ៉ាងទូលំទូលាយ និងបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយជីវិត និងស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជា។ មូលដ្ឋានគន្លឹះជារួមរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ គឺការចូលរួមចំណែកសម្រេចគោលបំណងក្នុងការលើកកម្ពស់ស្ថានភាពជីវភាពរបស់ជនក្រីក្រ និងក្រុមងាយរងគ្រោះនៅក្នុងសង្គមកម្ពុជា។ តាមរយៈការរួមបញ្ចូលគ្នានូវការយល់ដឹងពីថ្នាក់មូលដ្ឋាន អង្គការសង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ក្នុងការជួយជ្រោមជ្រែងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំធ្វើគោលនយោបាយ តាមរយៈការចែករំលែក និងផ្តល់យោបល់ត្រឡប់ព្រមទាំងសំណូមពរទាក់ទងនឹងគោលនយោបាយអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយទាំងនោះ។

កាលពីឆ្នាំកន្លងមក សហគមន៍អង្គការមិនមែនរដ្ឋាភិបាល បានរៀបចំជាឯកសារស្តីពីជំហរ និងបញ្ហាដែលកើតមានតាមវិស័យរបស់ខ្លួនទៅលើប្រធានបទនានាមានចាប់ពីវិស័យកសិកម្ម កំណែទម្រង់ដីធ្លី វិស័យព្រៃឈើ និងអភិបាលកិច្ចល្អ សម្រាប់ជាធាតុចូលទៅក្នុងកិច្ចប្រជុំនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF)។ ចាប់តាំងពីចុងឆ្នាំ២០១១ សហគមន៍អង្គការមិនមែនរដ្ឋាភិបាល បានដាក់បញ្ចូលគ្នានូវឯកសារស្តីពីជំហរ និងបញ្ហាតាមវិស័យចំនួន២១ដែលបានរៀបចំដោយក្រុមអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ដោយមានការចូលរួមចំណែកពី និងមានការពិគ្រោះយោបល់ជាមួយអង្គការបណ្តាញរបស់ខ្លួន។ កាលពីចុងឆ្នាំ២០១១ ក្រុមអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យបានពិភាក្សាអំពីការរៀបចំឯកសារជំហរនេះសម្រាប់ដាក់ជូនកិច្ចប្រជុំ CDCF លើកទីបួន។ អង្គការមិនមែនរដ្ឋាភិបាលបានយល់ស្របគ្នាថា ឯកសារជំហររបស់អង្គការមិនមែនរដ្ឋាភិបាល គប្បីបន្តផ្តោតលើការតាមដានសូចនាករតាមដានរួម (JMI) និងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ខណៈដែលលើកឡើងនូវបញ្ហាសំខាន់ៗដទៃទៀតផងដែរ ដោយផ្អែកលើការសង្កេត ក្នុងកំឡុងឆ្នាំ២០១០-២០១២។ បន្ថែមលើការអង្កេត និងអនុសាសន៍របស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ឯកសារស្តីពីជំហរអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ក៏មានដាក់បញ្ចូលផងដែរនូវករណីសិក្សាដែលឆ្លុះបញ្ចាំងនូវហេតុការណ៍ជាក់ស្តែងដែលកើតឡើងនៅកម្រិតមូលដ្ឋាន។ ប៉ុន្តែ កិច្ចប្រជុំ CDCF លើកទីបួនត្រូវបានពន្យារពេលដល់ឆ្នាំ ២០១៤ ដូច្នេះឯកសារស្តីពីជំហរអង្គការមិនមែនរដ្ឋាភិបាល នឹងត្រូវបានផ្សព្វផ្សាយ និងចូលរួមចំណែកក្នុងកិច្ចពិភាក្សាគោលនយោបាយនៅឯកិច្ចប្រជុំលើកទី១៩ របស់គណកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២។

ឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យទាំងនេះ បង្ហាញនូវទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាល អំពីស្ថានភាពនៃការអភិវឌ្ឍនៅកម្ពុជានាពេលបច្ចុប្បន្ន ក្នុងគោលបំណងផ្តល់នូវយោបល់ត្រឡប់វិញ និងអនុសាសន៍ក្នុងន័យស្ថាបនា ទៅលើវឌ្ឍនភាពដែលសម្រេចបាននៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម និងសូចនាករតាមដានរួមគ្នា ចាប់តាំងពីកិច្ចប្រជុំវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ក្នុងខែមិថុនា ឆ្នាំ២០១០ ដោយមានឯកសារមួយចំនួនបានផ្តល់បច្ចុប្បន្នភាពរហូតដល់ខែកញ្ញា ឆ្នាំ២០១២។

ការចូលរួមចំណែក
របស់អង្គការសង្គមស៊ីវិលក្នុង
ការអភិវឌ្ឍនៃប្រទេសកម្ពុជា

ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុង ការអភិវឌ្ឍនៃប្រទេសកម្ពុជា

របាយការណ៍ "វិភាគទានរបស់អង្គការសង្គមស៊ីវិលចំពោះការអភិវឌ្ឍនៃប្រទេសកម្ពុជា ឆ្នាំ២០១១" ដែលធ្វើឡើងដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា នៅឆ្នាំ២០១២ បានពណ៌នាអំពីការប្តេជ្ញាចិត្តរបស់អង្គការសង្គមស៊ីវិលដែលមានភាពច្បាស់លាស់បំផុតនៅក្នុងប្រទេសកម្ពុជា ចំពោះប្រសិទ្ធភាពអភិវឌ្ឍរបស់ខ្លួនផ្ទាល់ រួមទាំងការស្រាវជ្រាវ ការរៀនសូត្រ តម្លាភាព និងការប្តេជ្ញាចិត្តក្នុងការកែលម្អអ្វីដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនោះ។

របាយការណ៍នេះពណ៌នាអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនៅចុងឆ្នាំ២០១១ ស្តីពីវិភាគទានរបស់អង្គការសង្គមស៊ីវិលទាំងឡាយរបស់ប្រទេសកម្ពុជា ចំពោះការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងប្រជាធិបតេយ្យ ព្រមទាំងព័ត៌មានសំខាន់ៗស្តីពីស្ថានភាពបច្ចុប្បន្នរបស់វិស័យសង្គមស៊ីវិល។ របាយការណ៍នេះគឺជាការធ្វើបច្ចុប្បន្នកម្មនៃវិភាគទានដំបូង របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា នៅក្នុងវិស័យនេះ ពោលគឺរបាយការណ៍ "វាយតម្លៃឆាប់រហ័ស" ស្តីពីវិភាគទានរបស់សង្គមស៊ីវិលចំពោះការអភិវឌ្ឍដែលត្រូវបានបោះពុម្ពនៅឆ្នាំ២០១០ ដែលបានរៀបរាប់លម្អិតអំពីវិភាគទានដ៏រឹងមាំរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងវិស័យមួយចំនួន (សុខភាពសាធារណៈ ពិការភាព ការអប់រំ ការអភិវឌ្ឍសហគមន៍) ព្រមទាំងតាមរយៈការតស៊ូមតិ និងការរៀបចំគោលនយោបាយសាធារណៈ។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ មានការកើនឡើងយ៉ាងខ្លាំងនូវទំហំ វិសាលភាព និងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលជាសកល និងនៅប្រទេសកម្ពុជា។ ការកើនឡើងដ៏ច្រើននូវចំនួនអង្គការសង្គមស៊ីវិលគឺដោយសារតែវិភាគទានដ៏សំខាន់ និងដែលគេអាចមើលឃើញយ៉ាងច្បាស់របស់អង្គការសង្គមស៊ីវិល ចំពោះជីវិតសង្គមសេដ្ឋកិច្ច និងប្រជាធិបតេយ្យ លើសពីការផ្តល់សេវាសង្គមជាមូលដ្ឋានដែលរដ្ឋាភិបាលមិនអាចធ្វើបាន ឬនឹងមិនធ្វើ។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមរបស់អង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងបញ្ហានៃការអភិវឌ្ឍ ក៏ត្រូវបានគាំទ្រដោយបទដ្ឋាន និងនិយាមស្តីពីសិទ្ធិមនុស្សអន្តរជាតិ រួមទាំងកាតព្វកិច្ចលើរដ្ឋជាភាគីផងដែរ៖ ការចូលរួមនេះមានសារៈសំខាន់ណាស់ចំពោះការងាររបស់អង្គការសង្គមស៊ីវិលទាំងឡាយពាក់ព័ន្ធនឹងគណនេយ្យភាពសង្គម និងអភិបាលកិច្ចល្អ ការលើកកម្ពស់និងការពារសិទ្ធិមនុស្ស ការយកចិត្តទុកដាក់ដល់មន្ត្រីរាជការ និងការជំរុញការចូលរួមរបស់ពលរដ្ឋនៅក្នុងជីវិតសង្គម និងដំណើរការធ្វើសេចក្តីសម្រេច ប្រៀបដូចជាលំហាត់បន្ថយប្រជាធិបតេយ្យកំពុងថយចុះ។

ទិន្នន័យបែបបរិមាណនៅក្នុងការស្រាវជ្រាវនេះ ជួយឲ្យដឹងអំពី លក្ខណៈ អាទិភាព និងសកម្មភាពរបស់អង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជា ក៏ដូចជាឲ្យដឹងថានណាជាអ្នកទទួលផលពីការងារនិង វិភាគទានរបស់អង្គការទាំងនេះចំពោះការអភិវឌ្ឍជាតិ។ ការវិភាគនៃទិន្នន័យបែបបរិមាណនេះ រកឃើញកាន់តែលម្អិតនូវវិភាគទានសម្រាប់ប្រជាជនក្រីក្រ រាប់ចាប់ពីការផ្តល់សេវាដល់ការកសាងសមត្ថភាព និងចាប់ពីការផ្លាស់ប្តូរគោលនយោបាយដល់ការពង្រឹងប្រព័ន្ធ។

ជំហានដំបូងនៅក្នុងការកំណត់វិភាគទានរបស់អង្គការសង្គមស៊ីវិលទាំងឡាយ គឺការបញ្ជាក់អំពីចំនួនរបស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពយ៉ាងសកម្ម និងចូលរួមនៅក្នុងសកម្មភាពជាក់ស្តែង ព្រោះអង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលបានចុះបញ្ជីកាលពីមុន បានផ្លាស់ប្តូរគោលបំណង ឬលែងមានសកម្មទៀតហើយ។ ជំរឿនអង្គការមិនមែនរដ្ឋាភិបាល និងសមាគមទាំងអស់ដែលត្រូវបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិ ការអន្តរជាតិ ចាប់ពីឆ្នាំ១៩៩០ ដល់ចុងឆ្នាំ២០១០ បានបញ្ជាក់ថាមានអង្គការដែលត្រូវបានចុះបញ្ជីចំនួន១២២៦ ក្នុងចំណោម ៣.៤៩២ កំពុងមានសកម្មភាព ដែលនាំទៅដល់ការប៉ាន់ស្មានចុងក្រោយថាមានអង្គការសកម្មចំនួន១.៣៥០ ដោយផ្អែកលើការចុះបញ្ជីប្រចាំឆ្នាំជាមធ្យមនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

អ្នកផ្តល់សម្ភាសនៅក្នុងការសិក្សានេះ បានទទួលស្គាល់ផលប្រយោជន៍ដោយផ្ទាល់ដល់ការរស់នៅរបស់ប្រជាជនកម្ពុជាយ៉ាងតិចពី ៦៥០.០០០ នាក់ទៅ១លាននាក់។ ដោយប្រៀបធៀបចំនួនអ្នកទទួលផល នៅក្នុងការសិក្សានេះ ជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលប្រហែល ១,៣៥០ នៅប្រទេសកម្ពុជា ឃើញថាប្រជាជនកម្ពុជាពី ២,៨ ទៅ ៤,៥លាននាក់ ឬប្រជាជនប្រហែល២០-៣០ភាគរយ (វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៩) ទទួលបានប្រយោជន៍ដោយផ្ទាល់ពីសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ។

ក្រាហ្វិកខាងក្រោមនេះបង្ហាញនូវភាគរយនៃអង្គការសង្គមស៊ីវិល ដែលត្រូវបានអង្កេត ដែលធ្វើការងារដើម្បីផ្តល់ផលប្រយោជន៍ដល់ក្រុមអត្តគាហកគោលដៅក្នុងចំនួនណាមួយ ទោះបីជាមានក្រុមអត្តគាហកផ្សេងទៀតជាច្រើន ដែលត្រូវបានរាយការណ៍ថាត្រូវបានកំណត់គោលដៅដោយសកម្មភាពរបស់អង្គការសង្គមស៊ីវិលក៏ដោយ។



ទិន្នន័យពីអង្គការសង្គមស៊ីវិល ចំនួន៣០៨ ក្នុងចំណោម៣០៩ ដែលត្រូវបានអង្កេត បញ្ជាក់អំពីថវិកាប្រចាំឆ្នាំសរុបជាមធ្យមចំនួន១៤៦ លានដុល្លារអាមេរិក។ ដោយទាញសេចក្តីសន្និដ្ឋានពីទិន្នន័យនោះរហូតដល់អង្គការមិនមែនរដ្ឋាភិបាលសកម្មប្រហែល១.៣៥០ ទាំងជាតិ និងអន្តរជាតិនៅប្រទេសកម្ពុជា គេស្មើឡើងនូវការផ្តល់ថវិកាប្រចាំឆ្នាំសរុបនៅក្នុងតំបន់ចំនួន៥៥០ លានដុល្លារអាមេរិក សម្រាប់វិស័យអង្គការមិនមែនរដ្ឋាភិបាល ទោះបីជាក្រោយពេលពិចារណាដល់ជំនួយ និងការផ្តល់ថវិការវាងអង្គការមិនមែនរដ្ឋាភិបាល ខ្ពស់ជាងអ្វីដែលត្រូវបានប៉ាន់ស្មានកាលពីមុនដោយក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍កម្ពុជា (CDC) ហើយការបញ្ជាក់គឺថា វិស័យអង្គការមិនមែនរដ្ឋាភិបាលតែមួយ បានចំណាយនៅក្នុងវិស័យសង្គមអស់យ៉ាងច្រើនស្មើរតែដូចរដ្ឋាភិបាលដែរ។ មួយផ្នែកនៃប្រាក់នេះ ត្រូវបានចំណាយទៅលើការជួលប្រជាជនកម្ពុជាប្រហែល៥២.៦៥០ នាក់ នៅក្នុងតំណែងជំនាញ ដោយមានឱកាសកសាងសមត្ថភាពខ្ពស់ជាងមុន។ អ្នកផ្តល់សម្ភាសដល់ការអង្កេតជិត ៦៩ ភាគរយក៏បានស្មើឡើងផងដែរថា កម្រិតវប្បធម៌ជាមធ្យមនៅក្នុងអង្គការរបស់ពួកគេ គឺកម្រិតសាកលវិទ្យាល័យ ឬខ្ពស់ជាងនេះ។

ទោះបីជាមានការពិបាកក្នុងការវាស់វែងទំហំពិតប្រាកដរបស់វិស័យអង្គការសង្គមស៊ីវិលទាំងមូលក៏ដោយ វិស័យអង្គការមិនមែនរដ្ឋាភិបាលរួមចំណែកយ៉ាងខ្លាំង នៅក្នុងការអភិវឌ្ឍកម្រិតមូលដ្ឋានរបស់អង្គការសង្គមស៊ីវិលកម្ពុជា ដោយផ្តល់ថវិកាប្រហែល៤៤ លានដុល្លារអាមេរិក ដល់អង្គការតាមសហគមន៍មូលដ្ឋាន - ជាមូលដ្ឋាននៃសេដ្ឋកិច្ចកម្ពុជា។

ផ្អែកលើការចំណាយទូទៅរបស់អង្គការនីមួយៗ និងសកម្មភាពដែលត្រូវបានរាយការណ៍របស់អង្គការទាំងឡាយ ក្រាហ្វិកខាងក្រោមបង្ហាញអំពីការប៉ាន់ស្មានមួយ អំពីរបៀបដែលការចំណាយរបស់អង្គការសង្គមស៊ីវិល ទាំងឡាយនៅប្រទេសកម្ពុជា ត្រូវបានផ្តល់ដល់វិស័យ ឬប្រធានបទចម្បង។



នេះក៏ព្រោះតែការចូលរួមរបស់សង្គមស៊ីវិលត្រូវបានទទួលស្គាល់ថាមានសារៈសំខាន់ចំពោះការអភិវឌ្ឍ ដែលអង្គការសង្គមស៊ីវិល ទាំងឡាយត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងដំណើរការអន្តរជាតិស្តីពីប្រសិទ្ធភាពជំនួយ ដែលបានទទួលស្គាល់ចំណុចខ្លាំងជាក់លាក់របស់អង្គការសង្គមស៊ីវិលទាំងឡាយ។ ដោយឡែក ផែនការសកម្មភាពទីក្រុង Accra ឆ្នាំ ២០០៨ និយាយអំពីវិភាគទានកាន់តែកើនឡើង និងបទពិសោធន៍ដ៏មានតម្លៃ ដែលអង្គការផ្តល់ទទួលស្គាល់អង្គការសង្គមស៊ីវិល ទាំងឡាយថាជា "ភាគីអភិវឌ្ឍន៍ឯករាជ្យនៅក្នុងសិទ្ធិរបស់ខ្លួនផ្ទាល់" ប្តេជ្ញាចិត្តចំពោះការចូលរួមកាន់តែច្រើនរបស់ម្ចាស់ជំនួយ និងរដ្ឋាភិបាលជាដៃគូ រួមជាមួយនឹងអង្គការសង្គមស៊ីវិលទាំងឡាយ និងជំរុញឲ្យដៃគូអភិវឌ្ឍន៍ ដទៃទៀតដែលធ្វើការជាមួយ អង្គការសង្គមស៊ីវិលទាំងឡាយ ផ្តល់បរិយាកាសអនុគ្រោះមួយ ដែលបង្កើនវិភាគទានរបស់ពួកគេចំពោះការអភិវឌ្ឍ។ ការប្តេជ្ញាចិត្តចំពោះសង្គមស៊ីវិលនេះ ត្រូវបានឯកភាពបន្ថែមនៅក្នុងភាពជាដៃគូ Busan សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព នៅចុងឆ្នាំ២០១១។ យុទ្ធសាស្ត្រចតុកោណរបស់រាជ រដ្ឋាភិបាលកម្ពុជា (ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព) ក៏បាន "ស្វាគមន៍ដល់ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ នៅក្នុងដំណើរការស្តារ និងអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងនៅក្នុងការលើកកម្ពស់ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស" យ៉ាងជាក់លាក់ផងដែរ។

ដោយមានមោទនភាពចំពោះវិភាគទាន និងការជឿទុកចិត្តរបស់ខ្លួនទៅលើជំហររបស់ខ្លួននៅក្នុងអភិវឌ្ឍ អង្គការសង្គមស៊ីវិលយកចិត្តទុកដាក់ចំពោះបញ្ហាប្រឈម ដែលភាគីអភិវឌ្ឍន៍ដទៃទៀតបង្ហាញនៅក្នុងកិច្ចពិភាក្សាដែលមានលក្ខណៈនយោបាយកាន់តែខ្លាំងឡើង អំពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងប្រសិទ្ធភាព និងគណនេយ្យភាពរបស់អង្គការសង្គមស៊ីវិលទាំងឡាយ។ របាយការណ៍នេះបង្ហាញថា អង្គការសង្គមស៊ីវិលភាគច្រើនដែលត្រូវបានអង្កេត មានការប្តេជ្ញាចិត្តខ្ពស់ចំពោះគោលការណ៍ជាមូលដ្ឋាននៃអភិបាលកិច្ចល្អ នៅក្នុងអង្គការរបស់ខ្លួន តាមរយៈលក្ខន្តិកៈ ការរាយការណ៍

ជាទៀងទាត់ និងការធ្វើសវនកម្មហិរញ្ញវត្ថុ។ ការស្រាវជ្រាវក៏បញ្ជាក់ផងដែរថា អង្គការសង្គមស៊ីវិល ជាច្រើនមានបំណងចូលរួមនៅក្នុងប្រព័ន្ធទទួលវិញ្ញបនបត្រដោយស្មគ្រចិត្តលើអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ នៃអង្គការមិនមែនរដ្ឋាភិបាលដែលភាគីសង្គមស៊ីវិលកម្ពុជាបានបង្កើតដើម្បីកែលម្អស្តង់ដារ និងគណនេយ្យភាព។

ក្រាហ្វិកខាងក្រោមនេះបង្ហាញអំពីការវិវត្តន៍របស់វិស័យអង្គការសង្គមស៊ីវិល ឆ្ពោះទៅរកទិដ្ឋភាពសំខាន់ៗទាំងនេះ នៃអភិបាលកិច្ចល្អ ដោយបង្ហាញនូវការប្តេជ្ញាចិត្ត និងកាលានុវត្តភាពខ្ពស់សម្រាប់ការវិវត្តន៍បន្ថែម។



អង្គការសង្គមស៊ីវិល ទាំងឡាយមានឆន្ទៈក្នុងការបង្កើនវិភាគទានរបស់ខ្លួនចំពោះការអភិវឌ្ឍ ដូចត្រូវបានទាមទារនៅក្នុងផែនការសម្មភាពទីក្រុង Accra ហើយការប្តេជ្ញាចិត្តរបស់អង្គការទាំងនេះមានភាពប្រាកដប្រជាយ៉ាងច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងនៃគោលការណ៍អ៊ីស្តង់ប៊ុលស្តីពីប្រសិទ្ធភាព ការអភិវឌ្ឍរបស់អង្គការសង្គមស៊ីវិល នៅឆ្នាំ២០១០ និងក្របខ័ណ្ឌអន្តរជាតិស្តីពីប្រសិទ្ធភាពអភិវឌ្ឍអង្គការសង្គមស៊ីវិល នៅឆ្នាំ២០១១។

ក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើនការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិល ទាំងឡាយចំពោះការអភិវឌ្ឍនៅប្រទេសកម្ពុជា អង្គការសង្គមស៊ីវិលនឹងបន្តធ្វើការបង្កើតបរិយាកាសអនុគ្រោះមួយ ដែលអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិលទាំងឡាយបង្កើនការចូលរួមចំណែករបស់ខ្លួនចំពោះការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងប្រជាធិបតេយ្យ។ អង្គការសង្គមស៊ីវិលទាំងឡាយក៏នឹងបន្តធ្វើការក្រាមភាពជាដៃគូស្មើភាពគ្នានិងគោរពគ្នាទៅវិញទៅមកជាមួយដៃគូអភិវឌ្ឍន៍ ដែលអាចទ្រាំទ្រនឹងសម្ពាធ បញ្ហាប្រឈម និងវិវាទនាំទៅរកការស្ថាបនា ដែលនឹងកើតឡើងពីតួនាទីដ៏សំខាន់ និងខុសប្លែកពីគេរបស់ខ្លួននៅក្នុងការអភិវឌ្ឍជាមិនខាន។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
លោក លន់ ហូរិទ្ធី នាយកប្រតិបត្តិ
ទូរស័ព្ទចល័ត៖ (៨៥៥-១២) ៨០២ ៣៨៤
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ១៥២ ទូរសារ៖ (៨៥៥-២៣) ២១៦ ០០៩
www.ccc-cambodia.org

អតិបាលកិច្ចល្អ

ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

១. សេចក្តីផ្តើម

រដ្ឋាភិបាលកម្ពុជាចាត់ទុកអភិបាលកិច្ចល្អថាជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្រចតុកោណ ក្នុងការសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍។ សិទ្ធិទទួលព័ត៌មាន គឺជាធាតុផ្សំដ៏ចាំបាច់មួយ ដើម្បីសម្រេចបាននូវគោលដៅអភិបាលកិច្ចល្អ។ សិទ្ធិនេះ អាចជួយឲ្យប្រជាជនទទួលបានព័ត៌មាននានាទាក់ទងទៅនឹងសកម្មភាពរបស់រដ្ឋាភិបាល ហើយជួយដល់រដ្ឋាភិបាលក្នុងការធ្វើសកម្មភាពប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៅកម្ពុជា ការមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានគឺមានភាពចាំបាច់ណាស់សម្រាប់ប្រជាពលរដ្ឋ។ ច្បាប់នេះនឹងជួយជំរុញឲ្យមានជំនឿជាក់ និងការទុកចិត្តគ្នាទៅវិញទៅមករវាងរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល ជាពិសេសប្រជាជនកម្ពុជា។ ច្បាប់នេះ នឹងជួយពង្រឹងសិទ្ធិអំណាច និងលើកទឹកចិត្តប្រជាពលរដ្ឋ កាន់តែច្រើនឡើងចូលរួមក្នុងដំណើរការនយោបាយ និងអភិវឌ្ឍន៍ ដើម្បីឈានទៅរកការអភិវឌ្ឍន៍ដែលមានចីរភាព។

ក្រុមការងារស្តីពីសិទ្ធិទទួលព័ត៌មាន ត្រូវបានបង្កើតនៅឆ្នាំ២០០៣ ដែលមានអង្គការជាតិ និងអន្តរជាតិចំនួន ដប់ប្រាំបួន បានចូលរួមធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាលក្នុងការដើរតួនាទីយ៉ាងសំខាន់ គាំទ្រឲ្យមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ ក្រុមការងារបានសហការជាមួយក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដើម្បីបង្កើតក្របខណ្ឌគោលនយោបាយ ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលជាឯកសារគោលសម្រាប់ណែនាំ និងគាំទ្រស្ថាប័នរដ្ឋាភិបាល នៅពេលដែលធ្វើសេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធិទទួលបានព័ត៌មានឲ្យមានលក្ខណៈតាមបទដ្ឋានអន្តរជាតិ ព្រមទាំងបានធ្វើការជាមួយគណបក្សនយោបាយចំនួន ដប់មួយ ដើម្បីដាក់បញ្ចូលនូវសិទ្ធិទទួលព័ត៌មានទៅក្នុងកម្មវិធីនយោបាយរបស់ពួកគេ។ ខណៈពេលដែលមានវឌ្ឍនភាព មួយចំនួន ក្នុងការបង្កើតក្របខណ្ឌគោលនយោបាយ យើងពុំឃើញមានជំហានណាឆ្ពោះទៅរកការអនុម័តនៅឡើយ។

អង្គការក្រៅរដ្ឋាភិបាល សូមថ្លែងអំណរគុណចំពោះវេទិកា កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដើម្បីកម្ពុជា ដែលបានផ្តល់ឱកាសឲ្យចែករំលែកការសង្កេត និងកង្វល់ ដូចមានការគូសបញ្ជាក់ដូចខាងក្រោម៖

២. សូចនាករតាមដានរួម

ចំណុចដៅ	សកម្មភាពដែលត្រូវអនុវត្ត	ស្ថាប័នទទួលខុសត្រូវរបស់រដ្ឋាភិបាល	ក្រុមការងារបច្ចេកទេសពាក់ព័ន្ធ
១៧.ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ	គោលនយោបាយ ឬ ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានមិនមានចែងក្នុងសូចនាករតាមដានរួមគ្នា ដែលបានឯកភាពក្នុង វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដើម្បីកម្ពុជាលើកទី ៣-ថ្ងៃទី ២-៣ ខែមិថុនា ឆ្នាំ ២០១០ សម្រាប់ការអនុវត្ត និងតាមដាន ក្នុងចន្លោះពីវេទិកាកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍ដើម្បី កម្ពុជាលើកទី៣ ទៅលើកទី៤ ឡើយ។	MONASRI COM	TWG-LJR

ការតាមដានលើវឌ្ឍនភាពស្តីពីសកម្មភាពដែលត្រូវបានអនុវត្ត /ការវិភាគពីលទ្ធផល

សកម្មភាពដែលត្រូវអនុវត្ត	អង្គការក្រៅរដ្ឋាភិបាលឲ្យយោបល់លើការរីកចំរើន ហើយប្រសិនបើមានកង្វះខាត ភស្តុតាងជាក់ស្តែង ឬ បទពិសោធន៍ពីមូលដ្ឋានត្រូវតែផ្តល់ជូន	អនុសាសន៍ចំពោះកង្វះខាត ឬ ការរីកចំរើន
សូចនាករតាមដានរួម ទី១៧	អង្គការមិនមែនរដ្ឋាភិបាលសូមថ្លែងអំណរគុណ ចំពោះការបង្កើតសេចក្តីព្រាងគោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មានដ៏មានតម្លៃនេះ ដែលបានប្រព្រឹត្តទៅតាមបែបដោយមានការចូលរួម តាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាហើយអង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ថារាជរដ្ឋាភិបាលកម្ពុជា មានបំណងនឹងអនុម័តលើសេចក្តីព្រាងក្របខណ្ឌគោលនយោបាយ និងច្បាប់ នេះនៅពេលណាមួយ។ ទោះជាយ៉ាងណាក៏ដោយ មានការកត់សំគាល់ថារហូតមកទល់ពេលនេះ សេចក្តីព្រាងក្របខណ្ឌគោលនយោបាយនេះ ស្ថិតនៅ ក្រសួង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (MONASRI) នៅឡើយ។ មានការកើនឡើងនូវឆន្ទៈនិងសកម្មភាពរបស់សមាជិកតំណាងរាស្ត្រទាមទារឲ្យមាន ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន បានស្នើឡើងដោយតំណាងរាស្ត្រមកពីគណបក្សជំទាស់ (គណបក្សសមរង្សី) ទៅរដ្ឋសភានៅខែមីនា ឆ្នាំ២០១២។ ខណៈនេះដែរ គំរូនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានមួយផ្សេងទៀត ត្រូវបានពង្រាងដោយអង្គការសង្គមស៊ីវិល (ក្រុមការងារសិទ្ធិទទួលព័ត៌មាន)។ យើងក៏បានសង្កេតឃើញជាវិជ្ជមានថា រដ្ឋាភិបាលបានជំរុញឲ្យមានតម្លាភាពដែលគាំទ្រទាំងស្រុងលើយុទ្ធនាការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មានដូចជាចេញសេចក្តីណែនាំឲ្យបង្កើតអ្នកនាំពាក្យ និងមន្ត្រីទំនាក់ទំនងនៅថ្នាក់ក្រោមជាតិ និងណែនាំឲ្យបើកចំហព័ត៌មានសេវាកម្មសាធារណៈទាំងអស់។ រាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាធ្វើការជាមួយអង្គការសង្គមស៊ីវិល និងភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងពិភាក្សាពីសារៈសំខាន់នៃការមានច្បាប់ស្តីពីសិទ្ធិ ទទួលបានព័ត៌មាន និងបានធ្វើការសិក្សាវិភាគច្បាប់ កម្ពុជា ចំនួន៣១០ច្បាប់ និង១៨៨អនុក្រឹត្យ ដើម្បីពិនិត្យមើលពីកម្រិតនៃការបើកចំហព័ត៌មាន និងសិទ្ធិទទួល បានព័ត៌មានក្នុងច្បាប់ និងអនុក្រឹត្យទាំងនោះ។	ប្រទេសកម្ពុជាជាប្រធាន ASEAN កំពុងបន្តអនុវត្តការងារជាអាទិភាពកំណត់សម្រាប់ឆ្នាំ២០១២ ក្រោមប្រធានបទ "សហគមន៍តែមួយ វាសនាតែមួយ"។ ប្រទេសកម្ពុជាជាប្រធាន ASEAN ប៉ុន្តែ កម្ពុជាយើងមិនទាន់មាន ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននេះទេ។ ហើយមានប្រទេសជាសមាជិកអាស៊ានជាច្រើនផ្សេងទៀតបានអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននេះរួចហើយ។ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក៏បានទទួលស្គាល់ថា ការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននឹងជាការរួមចំណែក ដ៏សំខាន់ក្នុងការសម្រេចជោគជ័យលើគោលដៅអភិវឌ្ឍន៍សហវត្សកម្ពុជាផងដែរ។ ដូច្នេះក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (MONASRI) ដែលបានពង្រាងក្របខ័ណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលបាន ព័ត៌មានគួរសហការជាមួយក្រសួងព័ត៌មានអង្គភាពប្រឆាំងអំពើ ពុករលួយក្នុងការស្វែងរកមធ្យោបាយរៀបចំឲ្យមានច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដោយមានការចូលរួមពីអង្គការសង្គមស៊ីវិល។

៣. សកម្មភាព និងយុទ្ធសាស្ត្រសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ (លើកលែងប្រសិនបើបញ្ហាមិនមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ)

ទំព័រ*	កថាខណ្ឌ**	អង្គការក្រៅរដ្ឋាភិបាលឲ្យយោបល់លើការ រីកចំរើន ហើយប្រសិនបើមានកង្វះខាតភស្តុតាង ជាក់ស្តែង ឬបទពិសោធន៍ពីមូលដ្ឋាន ត្រូវតែផ្តល់ជូន	អនុសាសន៍ចំពោះកង្វះខាត
១៧៥-១៧៦ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ភាសាខ្មែរ	៣០៣-៣០៤	អង្គការមិនមែនរដ្ឋាភិបាលបានទទួលស្គាល់ថា រដ្ឋាភិបាលមានគោលជំហរលើកកម្ពស់សិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ និងលើកកម្ពស់តម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អ។ យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ចំណុច ១.១.ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ក.គោលនយោបាយអទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៤ ដែលចែងនៅចំណុច ៣៣៣. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅតែជារបៀបវារៈអាទិភាពខ្ពស់នៃបញ្ជីរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា។.... ការរៀបចំ និងជំរុញអនុម័តច្បាប់គោលដៅទៀតជាមូលដ្ឋាន នឹងនៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ។ ៣៣៤. នៅពេលដែលការរៀបចចំច្បាប់ទាំងនេះ កំពុងដំណើរការ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្ត អនុវត្តវិធានការម៉ឺងម៉ាត់ជាយុទ្ធសាស្ត្រនានា ដើម្បីលុបបំបាត់ឫសគល់នៃអំពើពុករលួយ តាមរយៈ សកម្មភាពដែលមានទំនាក់ទំនងទៅវិញទៅមក ដូចខាងក្រោម ៖ - ការគាំទ្រនិងការចូលរួមពីសាធារណជន ៖ ការគាំទ្រនិងការចូលរួមពីសាធារណជន គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការការពារ ការកាត់បន្ថយ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចបានគោលបំណងនេះរាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញ និងការពារ សិទ្ធិសេរីភាព ក្នុងការស្វែងរក ការទទួលបាន និង ការផ្សព្វផ្សាយព័ត៌មានស្តីពីករណីអំពើពុករលួយ ក្នុងប្រព័ន្ធផ្សព្វផ្សាយ។ ទោះជាដូចនេះក្តីការងារនេះត្រូវបានធ្វើឡើង ក្នុងរបៀបមួយដែលមានការទទួលខុសត្រូវ និងមានទំនុកចិត្ត ដោយគោរពនូវ សិទ្ធិសេរីភាព ភាពស្មោះត្រង់ និងសេចក្តីថ្លៃថ្នូរបស់ប្រជាជនទាក់ទងនឹងការការពារសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ។ សូចនាករតាមដាន៣ រួម ដែលបានឯកភាពក្នុង វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដើម្បីកម្ពុជា លើកទី៣-ថ្ងៃ	**អនុសាសន៍ចំពោះរាជរដ្ឋាភិបាល** ▪ អង្គការមិនមែនរដ្ឋាភិបាលសំណូមពរ រាជរដ្ឋាភិបាលកម្ពុជាបង្កើតច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឲ្យបានសម្រាប់រដ្ឋាភិបាល និងសភាអណ្តត្តិទីបួននេះ ដោយកំណត់ សូចនាករ និងពេលវេលានៃលទ្ធផលឲ្យបានជាក់លាក់។ ▪ រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្កើនការផ្សព្វផ្សាយឲ្យបានទៀងទាត់ និងធ្វើឲ្យសាធារណជន ទទួលបាននូវព័ត៌មានអំពីគោលនយោបាយ ព័ត៌មានស្តីពីហិរញ្ញវត្ថុ និងព័ត៌មានផ្លូវការផ្សេងទៀតដែលជា សេចក្តីត្រូវការ និងចាំបាច់របស់ប្រជាជនកម្ពុជា។ ▪ រាជរដ្ឋាភិបាលកម្ពុជាគួរតែបង្កើតក្រុមការ ងារមួយដោយមានការចូលរួមពីក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល ដើម្បី បង្កើតយុទ្ធសាស្ត្រ និតិវិធី និងយន្តការ ដើម្បីជាភាពងាយស្រួល ក្នុងការអនុវត្តសិទ្ធិទទួលព័ត៌មាននៅពេលដែលច្បាប់នេះត្រូវបានអនុម័ត។ ▪ អង្គការសង្គមស៊ីវិលសំណូមពរយ៉ាងខ្លាំង ឲ្យមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឲ្យបានសម្រាប់រដ្ឋាភិបាល និងសភាអណ្តត្តិទីបួននេះ ដែលបានសន្យាក្នុងគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជានៅឆ្នាំ ២០០៨។ **អនុសាសន៍ចំពោះម្ចាស់ជំនួយ**

		ទី ២-៣ ខែមិថុនា ឆ្នាំ ២០១០ សម្រាប់ការអនុវត្ត និងតាមដានក្នុងចន្លោះពីវេទិកាកិច្ចសហបតិបត្តិការ អភិវឌ្ឍន៍ដើម្បីកម្ពុជាលើកទី៣ ទៅលើកទី៤ សូចនាករតាមដានរួមគ្នាទី១៧- ការប្រឆាំងអំពើពុករលួយបានកត់សំគាល់ឃើញ ថាមិនមានសូចនាករជាក់លាក់ទៅលើគោលនយោបាយ ឬច្បាប់ ស្តីពីសិទ្ធិទទួលព័ត៌មាននេះទេ។ តាមរបាយការណ៍វាយតម្លៃរបស់ធនាគារពិភពលោក នៅខែកុម្ភៈ ២០០៩[1] អះអាងថា ការទទួលបានព័ត៌មានលម្អិតទាក់ទងទៅនឹង ប្រាក់ចំណូល/ ពន្ធដារ ថវិកា និងចំណាយ នៅមានកម្រិត។ អង្គការមិនមែនរដ្ឋាភិបាលពេញចិត្តចំពោះការ ផ្សព្វផ្សាយរបាយការណ៍សវនកម្មជាតិ។ ទោះជា យ៉ាងណាក៏ដោយក៏ការបើកចំហព័ត៌មានមិនទាន់ពេលវេលា (របាយការណ៍សវនកម្មជាតិ ២០០៦ផ្សព្វផ្សាយនៅឆ្នាំ២០០៩)។ បន្ថែមពីនេះទៀត តាមរយៈសិក្ខាសាលា និងវេទិកា[2]ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលធ្វើឡើងដោយក្រុមការងារសិទ្ធិទទួលព័ត៌មាននៅឆ្នាំ ២០០៩ ក៏បានរកឃើញផងដែរថាប្រជាជនចង់បានព័ត៌មានអំពី គោលនយោបាយ ការអភិវឌ្ឍន៍សហគមន៍ ថវិកា និងចំណាយ ដែលទាក់ទងទៅនឹងការការពារជីវភាពរស់នៅរបស់ពួកគេ ប៉ុន្តែពួកគេមិនអាចទទួលបានព័ត៌មានទាំងនោះ។ ប្រជាជនក៏បានបង្ហាញពីកង្វល់នៃ ការមិនទទួល បានព័ត៌មានទាំងនោះ វាប៉ះពាល់ជាអវិជ្ជមាន ដល់ជីវភាពរស់នៅរបស់ពួកគេ ដូចជា បាត់បង់ទ្រព្យសម្បត្តិ ធ្វើការសម្រេចចិត្តខុស សុខភាពមិនល្អ កង្វះពុទ្ធិនិងការយល់ដឹង និងបាត់បង់ការជំនឿជាក់ និងការទុកចិត្តគ្នាទៅ វិញទៅមក និងទំនាក់ទំនងល្អរវាង រដ្ឋាភិបាល និងប្រជាជន។ របាយការណ៍ឆ្នាំ២០០៧ របស់ក្រសួងផែនការ និងកម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិអះអាងថា ចាំបាច់ត្រូវមានតម្លាភាព សមភាព ក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធ និងការចូលរួមពេញលេញ ពីសំណាក់ប្រជាជន និងសហគមន៍នៅជនបទច្រើន ថែមទៀតទាក់ទងទៅនឹង	▪ អង្គការមិនមែនរដ្ឋាភិបាលសំណូមពរម្ចាស់ជំនួយបែងចែកធនធានដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសិទ្ធិ របស់ពួកគេក្នុងការទទួលបានព័ត៌មាន សាធារណៈ និងតម្រូវការឲ្យមានច្បាប់មួយនៅកម្ពុជា ដើម្បីពង្រឹងឲ្យមានតម្លាភាព និងគណនេយ្យភាព។ ▪ អង្គការមិនមែនរដ្ឋាភិបាលសំណូមពរម្ចាស់ជំនួយលើកទឹកចិត្តដៃគូរបស់ពួកគេឲ្យ ផ្តោត និងដាក់បញ្ចូលគោលការណ៍ ស្តីពីសិទ្ធិទទួលព័ត៌មាន ទៅក្នុងគម្រោង/កម្មវិធី ជាបញ្ហា អន្តរវិស័យ។

[1] ទំនាក់ទំនងរវាងរដ្ឋ និងប្រជាពលរដ្ឋៈ ការសិក្សាមួយនៃការចូលរួមចំណែកនៃសង្គមស៊ីវិល ក្នុងអភិបាលកិច្ចល្អក្នុងប្រទេសកម្ពុជា ដោយ ធនាគារពិភពលោក ខែកុម្ភៈ ២០០៩ ទំព័រ ២១

[2] ក្រុមការងារសិទ្ធិទទួលព័ត៌មានបានរៀបចំវេទិកា និងសិក្ខាសាលា ស្តីពីសិទ្ធិទទួលព័ត៌មានក្នុង ៩ខេត្ត (២០០៨-២០០៩) ដែលមាន អ្នកចូលរួម ៩១០ នាក់ ស្ត្រី ២២០នាក់ ដែលជាតំណាងឱ្យរដ្ឋបាលមូលដ្ឋាន អង្គការសង្គមស៊ីវិល វិស័យឯកជន សិស្ស សហគមន៍ ដែលបានបង្ហាញពីបញ្ហាទាក់ទង នឹងសិទ្ធិទទួលព័ត៌មានចន្លោះ ២០០៨-២០០៩

		ការសម្រេចចិត្តអំពីដីធ្លី ដែលពាក់ព័ន្ធទៅនឹងជីវភាពរស់នៅ សន្តិសុខ និងសុខុមាលភាពរបស់ពួកគេ[3]។ ការស្រាវជ្រាវស្តីពីសិទ្ធិទទួលព័ត៌មានមួយបានធ្វើ ឡើងដោយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយលើចំនួនអ្នកឆ្លើយតប ៧៣៧នាក់ ក្នុងចំនួន ៣៥ភូមិ ក្នុងបួនខេត្ត ខែវិច្ឆិកា ឆ្នាំ២០១១ បានរកឃើញថា ៤៦ភាគរយនៃសមាជិក សហគមន៍បានស្នើសុំព័ត៌មានពីកម្រិតភូមិ និងឃុំ និងបានទទួលព័ត៌មានទាំងឡាយដែលបានស្នើសុំ។ ប៉ុន្តែ លើសពី៣០ភាគរយនៃ អ្នកបានស្នើសុំមិនបានពេញចិត្តទេ។ ការស្រាវជ្រាវរកឃើញថា ប្រជាពលរដ្ឋដែលក្រីក្រមានការពិបាកខ្លាំង ក្នុងការស្នើសុំ និងទទួលបានព័ត៌មាន។[4] ការមិនមានច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន វាមានការលំបាកណាស់សម្រាប់ប្រជាពលរដ្ឋ ក្នុងការចូលរួមក្នុងដំណើរអភិវឌ្ឍន៍ប្រទេសជាតិ ប្រកបដោយចីរភាព។	

** លេខទំព័រនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣*

*** កថាខណ្ឌ នៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣*

ព័ត៌មានទំនាក់ទំនង

ចំពោះព័ត៌មានបន្ថែមអំពីបញ្ហានានាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

ក្រុមការងារស្តីពីសិទ្ធិទទួលព័ត៌មាន
លោក ណៃប ស៊ីនថៃ
នាយកវិទ្យាស្ថានគោលនយោបាយ និងតស៊ូមតិ និងជាអ្នកតំណាងក្រុមការងារស្តីពីសិទ្ធិទទួលព័ត៌មាន
ទូរស័ព្ទ៖ (៨៥៥-២៣)២១៣ ៤៨៦ ឬ (៨៥៥-៧៧)៥៥៥ ៦៧៩
អ៊ីម៉ែល៖ apioffice@apiinstitute.org, sinthayneb@apiinstitute.org
គេហទំព័រ៖ www.apiinstitute.org
អាសយដ្ឋាន៖ អគារភ្នំពេញវីឡា លេខ១២៤ ជាន់ទី២ បន្ទប់លេខ២០៦ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

[3] Expanding Choices for Rural People: Cambodia Human Development Report 2007′, The Ministry of Planning and UNDP Cambodia, 2007. p. 6

[4] Access to Information Baseline Survey, Advocacy and Policy Institute, November 2011, page 7

វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

១. ទិដ្ឋភាពទូទៅ

ប្រវត្តិសាស្ត្របង្ហាញឲ្យឃើញថា ដំណើរការអភិវឌ្ឍតម្រូវឲ្យធ្វើនគរូបនីយកម្មទ្រង់ទ្រាយធំ និងប្រជាជនធ្វើសកម្មភាពមិនមែនធ្វើកសិកម្ម។ ការពង្រឹងដីកសិកម្ម និងការប្រើគ្រឿង យន្តធ្វើកសិកម្ម អមដំណើរជាមួយនឹងដំណើរការនេះដែលជួយបង្កើនផលិតភាព ដីនិងកម្លាំង ពលកម្ម។ ដំណើរការនេះក៏សម្រួលផងដែរ ដល់ការកំណត់គោលដៅសេវាកម្មសង្គមក្នុងចំណោមស្រទាប់ប្រជាជន។ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដំណាក់កាលបន្ទាប់ គួររួមបញ្ចូលទាំងការលើកស្ទួយឲ្យមាន ការរីកលូតលាស់នៃក្រុងតូចៗ និងទីរួមខេត្តនានា។

កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក៏ត្រូវបានដាក់ឲ្យអនុវត្តផងដែរ។ ហើយយើងសង្កេតឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ មានតួនាទីកាន់តែសំខាន់ នៅក្នុងដំណើរការអភិវឌ្ឍ ដោយហេតុថាមានការផ្ទេរធនធាន សម្រាប់អនុវត្តផែនការ នៅកម្រិតនោះ។ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ត្រូវបានចែងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ (ឆ្នាំ២០០៥)។ យុទ្ធសាស្ត្រចតុកោណ ផ្តោតជាសំខាន់លើកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ដែលមានគោលដៅពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ នៅមូលដ្ឋាន និងលើកកម្ពស់ការអភិវឌ្ឍនៅមូលដ្ឋាន ដើម្បីកាត់បន្ថយភាពក្រីក្រ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១០-២០១៤ ជាមួយនឹងផែនការអនុវត្តបីឆ្នាំ (IP3) ក៏បានបន្តដំណើរការទៅមុខទៀតយ៉ាងរលូន។ រួមមានច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់ (ឆ្នាំ២០០២) និងច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ឆ្នាំ២០០៨)។ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានបោះឆ្នោតជ្រើសតាំងជាលើកដំបូង នៅឆ្នាំ២០០២ រីឯ ក្រុមប្រឹក្សាស្រុកត្រូវបានបង្កើតឡើង នៅឆ្នាំ២០១០។ ក្រុមប្រឹក្សាទាំងពីរប្រភេទនេះ និងមន្ត្រី ដែលបានជ្រើសតាំងនៅ កម្រិតមូលដ្ឋានជាទូទៅ ជំនាញ សមត្ថភាព និងធនធាននៅមានកម្រិត ក្នុងការផ្តល់សេវាសាធារណៈ ឬឆ្លើយតបទៅនឹង តម្រូវការរបស់សហគមន៍ និងការបង្កើតទំនាក់ទំនងសាធារណៈល្អ និងគាំទ្រដល់ការទទួលបានព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានសាធារណៈឲ្យមាន តម្លាភាព គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋកាន់តែខ្លាំងឡើយ។

សូចនាករតាមជានរួម១៨: វិមជ្ឈការ និងវិសហមជ្ឈការ

លទ្ធផលរយៈពេលមធ្យម	ធាតុចេញ(លទ្ធផល)	សូចនាករ	សកម្មភាព	ស្ថាប័នសម្របសម្រួល	ស្ថាប័នអនុវត្តន៍
ការផ្តល់សេវាសាធារណៈបានខិតជិតប្រជាពលរដ្ឋតាមរយៈការធ្វើស្ថាប័នភាវូបនីយកម្ម ប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ ក្រោមជាតិ	រចនាសម្ព័ន្ធ ប្រព័ន្ធ និងនិតិវិធីប្រតិបត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើង និងកែសម្រួលតាមស្មារតីច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលការណ៍នៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ	១-នៅដំណាច់ឆ្នាំ ២០១១ មន្ត្រីនៅតាមសាលារាជ ធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ជិត ១០០០០នាក់) និងនៅផ្នែកទាំងបួន របស់ គណៈកម្មាធិការប្រតិបត្តិ (គ.ប្រ)បានធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មី និង	១-រៀបចំ និងអនុវត្តផែនការលម្អិតសម្រាប់រយៈពេល៣ឆ្នាំ ២-សិក្សាដកពិសោធន៍ និងធ្វើសមាហរណកម្មរចនាសម្ព័ន្ធ និងប្រព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៣-ធ្វើសមាហរណកម្មមន្ត្រីនៅតាមសាលា	RGC TWC on D&D	RGC and DPs

		មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍មុខ ងាររបស់ខ្លួនស្របតាមច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តិជាធរមាន។ ២-កំណើនថវិការបស់រដ្ឋបាល ថ្នាក់ក្រោមជាតិឆ្នាំ ២០១១ (ទាំងពីប្រភពរាជរដ្ឋាភិបាល និងពីដៃគូអភិវឌ្ឍន៍)។	រាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក និងសាលាខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពជាមូលដ្ឋាន ៤-បង្កើតយន្តការដើម្បីធ្វើសមាហរណកម្ម និងពង្រឹង សមត្ថភាព បណ្តានាយកដ្ឋាន ចំណុះអគ្គ នាយកដ្ឋាន រដ្ឋបាល មូលដ្ឋានរបស់ក្រសួង មហាផ្ទៃ និងក្រសួង ស្ថាប័ន នានា ៥-រៀបចំលិខិតបទដ្ឋានគតិយុត្តិសំខាន់ៗ សម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៦-ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិនៅថ្នាក់ក្រោម ជាតិត្រូវបានអនុម័ត		

២. ការតាមដានការរីកចម្រើននៃសកម្មភាពចាំបាច់/ការវាយតម្លៃលទ្ធផលការងារ

ការរួបរួមគ្នារបស់សង្គមស៊ីវិលដើម្បីលើកកម្ពស់វិមជ្ឈការនៅប្រទេសកម្ពុជា ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ គឺជាក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ (WGPD)។ WGPD ជាសម្ព័ន្ធភាព នៃអង្គការអន្តរជាតិ និងកម្ពុជា និងបុគ្គលមិនស្វែងរកប្រាក់ចំណេញ មិនប្រកាន់បក្សពួក ដែលបានប្តេជ្ញា លើកកម្ពស់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅប្រទេសកម្ពុជា តាំងពីពេលដែលត្រូវបានបង្កើតឡើង នៅឆ្នាំ ២០០៣ មកម្ល៉េះ។ ទស្សនៈរបស់ WGPD នេះគឺចង់ឲ្យបានសង្គមកម្ពុជាមួយ ដែលប្រជាជនទាំងអស់ចូលរួម យ៉ាងពិតប្រាកដ នៅក្នុងដំណើរការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងមានលទ្ធភាព ទទួលបានស្មើៗគ្នានូវសេវាកម្មសាធារណៈប្រកប ដោយគុណភាព និងឆាប់រហ័ស តាមរយៈការលើក កម្ពស់សម្លេងជា សមូហភាព និងការចូលរួមដ៏មានអត្ថន័យរបស់ សង្គមស៊ីវិលជាមួយនឹងរាជរដ្ឋាភិបាល នៅគ្រប់ កម្រិតទាំងអស់ ដើម្បីពង្រឹង ដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

អង្គការមិនមែនរដ្ឋាភិបាល វាយតម្លៃខ្ពស់ចំពោះឱកាសដែលបានផ្តល់ដោយវេទិកាកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍កម្ពុជា ដើម្បីចែក រំលែកការសង្កេត និងកង្វល់របស់ពួកគេ ដូចដែលត្រូវបានគូសបញ្ជាក់ ខាងក្រោម។

ការតាមដានវឌ្ឍភាពនៃសកម្មភាពចាំបាច់/ការវាយតម្លៃលទ្ធផលការងារ

សកម្មភាពចាំបាច់	យោបល់របស់អង្គការមិនមែនរដ្ឋាភិបាល អំពីការរីកចម្រើន និងប្រសិនបើមានកង្វះខាត ត្រូវផ្តល់ភស្តុតាង ឬបទពិសោធន៍ច្បាស់លាស់ ពីថ្នាក់មូលដ្ឋាន	អនុសាសន៍ចំពោះកង្វះខាត ឬការរីកចម្រើន
វិមជ្ឈការ និង វិសហមជ្ឈការ	អង្គការមិនមែនរដ្ឋាភិបាលបានវាយតម្លៃខ្ពស់ និងទទួលស្គាល់ថា រាជរដ្ឋាភិបាលកម្ពុជាមានការរីកចម្រើនជាវិជ្ជមានដ៏គួរឲ្យកត់សម្គាល់ពាក់ព័ន្ធនឹងវិមជ្ឈការ និង វិសហមជ្ឈការ ដូចខាងក្រោម ៖ ១.បង្កើត និងអនុវត្តកម្មវិធីអនុវត្តលម្អិតរយៈពេល ៣ឆ្នាំ។ ការរីកចម្រើន និងសមិទ្ធផលនៃផែនការ អនុវត្តរយៈពេល ៣ ឆ្នាំដំបូង (IP3 ឆ្នាំ២០១១-២០១៣) ៖ IP3 បានសម្រេចដោយជោគជ័យនូវបុរេ លក្ខខណ្ឌ ចម្បង។ ភាគច្រើន សម្រាប់ការអនុវត្ត កម្មវិធីដោយ រលូន។ ឯកសារ កម្មវិធី IP3 ត្រូវបានធ្វើបញ្ចាប់ជាមួយអនុកម្មវិធីចំនួនប្រាំមួយ ៖ - ការអភិវឌ្ឍគោលនយោបាយនិងការសម្របសម្រួលកម្មវិធី៖ លេខាធិការដ្ឋាន NCDD ជាអ្នកអនុវត្ត - ការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ SNA៖ ក្រសួងមហាផ្ទៃ ជាអ្នកអនុវត្ត - ការគ្រប់គ្រងធនធានមនុស្ស SNA៖ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈជាអ្នកអនុវត្ត - ធនធាន SNA៖ MEFជាអ្នកអនុវត្ត - ប្រព័ន្ធរៀបចំផែនការ និងកម្មវិធីវិនិយោគ SNA៖ MOP ជាអ្នកអនុវត្ត	១. ធានាឲ្យមានយន្តការរួមបញ្ចូលគ្នាច្បាស់លាស់ ដោយមានការចូលរួមពីតួអង្គអភិវឌ្ឍនានានៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នេះរួមបញ្ចូល ទាំងការកែលម្អ មុខងារ TWG វិមជ្ឈការ និង វិសហមជ្ឈការ។ បង្កើតក្រុមការងារបច្ចេកទេសថ្នាក់ក្រោម/គណៈកម្មការសម្រាប់អនុវត្តអនុ កម្មវិធីប្រាំមួយនៃ IP3 និងសម្រាប់ខេត្តនីមួយៗ។ ២. គួរមានលទ្ធភាពទទួលបានអនុស្សរណៈនៃការយោគយល់ ច្បាប់ និងបទបញ្ជា ផែនការឲ្យបានច្រើនជាងមុន ដើម្បីឲ្យមានការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព និងការ អនុវត្តកម្មវិធីវិមជ្ឈការ និង វិសហមជ្ឈការ និងច្បាប់ស្តីពីការ គ្រប់ គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ៣.គម្រោងអភិវឌ្ឍសមត្ថភាពគួរត្រូវបានបង្កើតឡើង និងអនុវត្ត ដោយសហការជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជំនាញ។

	- ការបង្កើនសមត្ថភាពរបស់ក្រុមប្រឹក្សាសមាគមន៖ សម្ព័ន្ធជាតិក្រុមប្រឹក្សាឃុំ-សង្កាត់ ជាអ្នកអនុវត្ត អនុកម្មវិធីទាំង ៦ នេះទើបតែសម្រេច និងអនុវត្ត ហើយតួអង្គ អភិវឌ្ឍគន្លឹះមួយចំនួន ដូចជាអង្គការសង្គមស៊ីវិល និង វិស័យ ឯកជនមិនទាន់ត្រូវបានបញ្ចូលទាំងស្រុងទៅក្នុង រចនាសម្ព័ន្ធ/យន្តការ សម្រាប់ការអនុវត្តអនុកម្មវិធីទាំងនេះប្រកប ដោយប្រសិទ្ធភាពនៅឡើយទេ។ មានក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ជាតិ ដើម្បីសម្រប សម្រួលបញ្ហាបច្ចេកទេស ពាក់ព័ន្ធនឹងវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ជាតិ ប៉ុន្តែហាក់ដូចជាមានយន្តការមិនទាន់ច្បាស់លាស់ ដើម្បីធ្វើការ សម្របសម្រួល រវាងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិទេ។ អនុស្សរណៈនៃការយោគយល់រវាងNCDD និងក្រសួងពាក់ព័ន្ធ (MEF, MOI, SSCS, NLCS) និងខេត្ត-រាជធានីទាំង ២៤ ត្រូវបានចុះហត្ថលេខា។ ទោះជាយ៉ាងនេះក្តី អនុស្សរណៈនៃការយោគយល់ភាគច្រើនមិនមានសម្រាប់សាធារណជន ដើម្បីឲ្យពួកគេអាចចូលរួមក្នុង ការធានាថា អនុស្សរណៈនៃការយោគយល់ដែលបានចុះ ហត្ថលេខា ត្រូវបានអនុវត្តយ៉ាងពេញលេញ និងប្រកបដោយ ប្រសិទ្ធភាពឡើយ។ សកម្មភាពចម្បង។ជាច្រើនដែលផ្តោតគោលដៅចំពោះខេត្ត-រាជធានី ត្រូវបានអនុវត្ត ប៉ុន្តែរដ្ឋបាលថ្នាក់ ក្រោមជាតិនៅរង់ចាំការអភិវឌ្ឍ ប្រព័ន្ធ និងនីតិវិធី ប្រតិបត្តិការរបស់ក្រុងស្រុកខណ្ឌ។ ខេត្តកំពុងអនុវត្ត គម្រោងអភិវឌ្ឍន៍សហគមន៍ និងផ្តល់ការគាំទ្រដល់សកម្មភាពដោយប្រើមូលនិធិ ប្រតិបត្តិការរបស់ខ្លួន និងបន្តផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំសង្កាត់សម្រាប់ការរៀបចំផែនការ និងការអនុវត្តមូលនិធិឃុំសង្កាត់។ តាមរយៈ NCDD រាជរដ្ឋាភិបាលកម្ពុជា បានវិនិយោគប្រាក់ ៨០-៩០ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ នៅក្នុងគម្រោង ទ្រង់ទ្រាយតូចចំនួនជាង ៤.០០០	នេះរួមបញ្ចូល ទាំងថវិកា សម្រាប់ការអភិវឌ្ឍសមត្ថភាព ដែលគួរត្រូវបានបែងចែកតាមសមាមាត្រ សមស្របដល់តួអង្គមិនមែនរដ្ឋ។ ខ្លឹមសារនៃការបណ្តុះបណ្តាលគួរមាន ជំនាញអនុវត្ត និងជំនាញវិភាគ ហើយវគ្គបណ្តុះបណ្តាល នីមួយៗគួរបើកចំហសម្រាប់មន្ត្រីមិនមែនរាជរដ្ឋាភិបាលឲ្យចូលរួម។ ការតាមដាននិង ការបណ្តុះបណ្តាលជាបន្តបន្ទាប់ត្រូវផ្តល់ជូនដល់សិក្ខាកាម។ ៤. គួរបន្តពង្រឹងការអនុវត្ត ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋ បាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ហើយតួអង្គ អភិវឌ្ឍទាំងអស់ និងសាធារណជន គួរចូលរួមឲ្យបានកាន់តែច្រើន នៅក្នុង ដំណើរការពិគ្រោះយោបល់អំពី ការធ្វើសេចក្តីព្រាង និងអនុវត្តច្បាប់ និងបទបញ្ជា។ ៥. គោលការណ៍ និងយន្តការច្បាស់លាស់ទាំងអស់ ដើម្បីពង្រឹង និង អនុវត្តច្បាប់ គួរត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយ ដោយសហការប្រកបដោយអត្ថន័យជាមួយតួអង្គអភិវឌ្ឍ។

	គម្រោង តាំងពីឆ្នាំ២០០៩ មក។ ៣៤% នៃភូមិចំនួន ១៤.០០០ និងប្រជាជនចំនួន ៤.២៧៩.៤៦៨ នាក់ ទទួលផលពីគម្រោងនេះ។ គម្រោងដែល បានអនុវត្ត មានដូចជា ៖ ផ្លូវក្រាលគ្រួសក្រហម ស្ពាន គម្រោង ស្រោចស្រព ប្រព័ន្ធទឹកស្អាត និងអនាម័យ សាលារៀន និងមណ្ឌលសុខភាព។ លើសពីនេះទៀត អាជ្ញាធរ បានចាត់វិធានការចាំបាច់នានា ដើម្បីជួយដល់ កសិករ ក្នុងការប្រកបរបរ ចិញ្ចឹមសត្វ បង្កើតការងារខ្នាតតូច បង្កើនភាពយល់ ដឹងអំពី យេនឌ័រ និងផ្តល់ការ បណ្តុះបណ្តាល ដើម្បីធ្វើឲ្យស្តង់ដារនៃការរស់នៅរបស់ប្រជាជន កាន់តែមានភាពល្អប្រសើរ។ ២.សិក្សាបង្ហាញ និងបញ្ចូលរចនាសម្ព័ន្ធ និងប្រព័ន្ធនៃ ExCom ទៅក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ ក្រោមជាតិ។ ៣.ធ្វើសមាហរណកម្មបុគ្គលិកបច្ចុប្បន្ននៅសាលារាជ ធានី សាលាខេត្ត សាលាក្រុង សាលាស្រុក និងសាលា ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី យោងតាមច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជា មួយនឹងការអភិវឌ្ឍ សមត្ថភាពសមស្រប។ មន្ត្រីជាង៧.០៣៥ នាក់ ដែលធ្វើការនៅក្នុងប្រព័ន្ធ វិម ជ្ឈការ ត្រូវបានបណ្តុះបណ្តាល អំពីការរៀបចំផែនការ និងផែនការវិនិយោគ៣ ឆ្នាំរំកិល។ រាជធានី និងខេត្ត ទាំងអស់ បច្ចុប្បន្ន បានបញ្ចប់ផែនការអភិវឌ្ឍ របស់ខ្លួន សម្រាប់កម្រិតវិមជ្ឈការ និងទទួលបាននូវការ ឯកភាព ពី MOI។ បន្ទាប់មក ទីប្រឹក្សា IP3 និងបុគ្គលិក ត្រូវ បានជ្រើសរើស សម្រាប់ក្រសួង និង រដ្ឋបាលអនុវត្ត ថ្នាក់ក្រោមជាតិ។ ទីបី ផែនការការងារប្រចាំឆ្នាំ និង ថវិកាសម្រាប់ ឆ្នាំ២០១១ ត្រូវបានតាក់តែងឡើង។ វគ្គបណ្តុះបណ្តាលភាគច្រើនត្រូវបានផ្តល់ជូនសម្រាប់ តែមន្ត្រីរាជរដ្ឋាភិបាលប៉ុណ្ណោះនិងត្រូវបានសម្រប សម្រួលដោយអ្នកជំនាញ របស់រាជរដ្ឋាភិបាល/អ្នក ពិគ្រោះយោបល់ ដែលបានចាត់តាំង ដែលមិនពាក់ព័ន្ធ ជាមួយ អង្គការមិនមែនរដ្ឋាភិបាលជំនាញឡើយ។	

	ហើយប្រធានបទភាគច្រើនគឺផ្តោតទៅលើជំនាញអនុវត្ត ដូចជាការរៀបចំផែនការ និងផែនការ ៣ឆ្នាំរំកិល។ ដើម្បីជាការលើកទឹកចិត្តចំពោះ កិច្ចខំប្រឹងប្រែងនេះ ជំនាញស្រាលៗដូចជា ទំនាក់ទំនងរវាងបុគ្គល ការផ្លាស់ប្តូរ អកប្បកិរិយា ភាពជាអ្នកដឹកនាំ ការកៀងគរធនធាន ទស្សនទាន នៃការអភិវឌ្ឍប្រកប ដោយនិរន្តរភាព និងការ រីកចម្រើន និងជំនាញធ្វើការសម្របសម្រួល។ល។ គួរត្រូវបាន បណ្តុះបណ្តាលដល់មន្ត្រីទាំងឡាយ។ ៤. បង្កើតយន្តការ ដើម្បីបញ្ចូល និងពង្រឹងសមត្ថភាពរបស់នាយកដ្ឋាន MoI ក្រសួង និងស្ថាប័នផ្សេងទៀត។ កម្មវិធីជាតិរយៈពេលដប់ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ៖ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅខែ ឧសភា ឆ្នាំ២០១០ ហើយនៅខែសីហា ឆ្នាំ២០១០ NP-SNDD ត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវការ។ NP-SNDD នឹងត្រូវបានយកមកអនុវត្តជាបីដំណាក់កាល នៅចន្លោះពីឆ្នាំ២០០៩ ដល់ឆ្នាំ ២០១៩។ ការបង្កើនសមត្ថភាពរបស់ក្រុមប្រឹក្សាសមាគម ត្រូវបានដឹកនាំដោយសម្ព័ន្ធជាតិក្រុមប្រឹក្សា ឃុំ/សង្កាត់ ដែលជាអ្នកអនុវត្ត។ ការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ SNA ត្រូវបានដឹកនាំដោយ ក្រសួងមហាផ្ទៃដែលជាអ្នកអនុវត្ត។ ការគ្រប់គ្រងធនធានមនុស្ស SNA ត្រូវបានដឹកនាំដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលជាអ្នកអនុវត្ត។ ៥.រៀបចំលិខិតបទដ្ឋានគតិយុត្តច្បាប់គន្លឹះៗ ដើម្បីគាំទ្រដល់កំណែទម្រង់ រដ្ឋបាលថ្នាក់ក្រោមជាតិ យោងតាមច្បាប់អង្គការ។ គណៈកម្មការជាតិអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ (NCDD) បានពង្រាងច្បាប់ ក្រឹត្យ អនុក្រឹត្យ មួយចំនួន និងបទបញ្ជាផ្សេងទៀត ដោយផ្តោតជាសំខាន់ លើការរៀបចំស្ថាប័ននានា ដើម្បីធានាថារដ្ឋ បាលថ្នាក់ក្រោមជាតិ (SNA) បំពេញអាណត្តិ របស់ខ្លួនដែលមានបញ្ជាក់នៅក្នុងច្បាប់ស្តីពី	

	ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ CSO បានសង្កេតឃើញថា គណៈកម្មាធិការមួយចំនួននៅថ្នាក់ក្រោមជាតិដូចជា គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការ ស្ត្រី និងកុមារ និងគណៈ កម្មាធិការលទ្ធកម្ម និងគណៈកម្មាធិការចាំបាច់ដទៃផ្សេងទៀតនៅក្នុងខេត្តមួយចំនួនមិនមានដំណើរការពេញលេញនោះទេ ហើយតួអង្គអភិវឌ្ឍ ចម្បងៗ មួយចំនួននៅតែមិនទាន់បញ្ចូលទៅក្នុង ដំណើរការធ្វើសេចក្តីព្រាងច្បាប់ និងបទបញ្ញត្តិដែល ពួកគេរំពឹងថានឹងត្រូវបានបញ្ចូល ដើម្បីចែករំលែក លទ្ធផល និងយោបល់របស់ពួកគេ។ ៦.ច្បាប់ស្តីពីរបបហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ និងការគ្រប់គ្រង ទ្រព្យសម្បត្តិត្រូវបានអនុម័ត រួចដោយពិគ្រោះយោបល់ជាមួយ MEF, NCDD ក៏បានធ្វើសេចក្តីព្រាងផងដែរ លើច្បាប់ ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ ក្រោមជាតិ ដែលរដ្ឋសភាជាតិបានអនុម័តនាពេល បច្ចុប្បន្ន នេះ។ CSO មានទស្សនៈយល់ឃើញថាអាចនឹងមានបញ្ហាចោទ ប្រសិនបើគ្មានគោលការណ៍ ដឹកនាំអនុវត្ត និងយន្តការច្បាស់លាស់ ដើម្បីពង្រឹងច្បាប់នោះទេ។	

៣. សកម្មភាព/យុទ្ធសាស្ត្រសំខាន់ៗដែលបានដកស្រង់ពីបច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់ផែនការ អភិវឌ្ឍយុទ្ធសាស្ត្រ ថ្នាក់ជាតិ(អាចមិនជ្រើសរើសបាន ប្រសិនបើបញ្ហាមិនមាននៅក្នុងបច្ចុប្បន្នកម្មរបស់ ផែនការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់ជាតិ)

វគ្គ	សារ
៣៤៧ និង ៣៤៨	កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៣៤៧ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដោយអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងដាក់ចេញនូវ វិធានការថ្មីៗដើម្បីធានានូវការអនុវត្ត ប្រកបដោយប្រសិទ្ធភាពនៃ "ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ " ជាពិសេស ការអភិវឌ្ឍន៍ និងការអនុវត្តនៃក្របខ័ណ្ឌច្បាប់ ដែលទាក់ទិននឹង ការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចង្អុលបង្ហាញ យ៉ាងច្បាស់ពីតួនាទី សិទ្ធិអំណាច អំណាច និងទំនួលខុសត្រូវ ។ ច្បាប់នេះនឹងត្រូវអនុវត្ត យ៉ាងប្រុងប្រយ័ត្ន នៅក្នុងដំណាក់កាល ទាំងឡាយ ។ ក្រសួង និងភ្នាក់ងារនីមួយៗនឹងរៀបចំផែនការ សកម្មភាពច្បាស់លាស់ ក្នុងការធ្វើប្រតិភូកម្ម អំណាច និងមុខតំណែងពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ។ ការគ្រប់គ្រង ហិរញ្ញវត្ថុដែលបាន ធ្វើវិមជ្ឈការនឹងត្រូវបានអនុវត្តផងដែរនៅក្នុងរបៀបមួយដែលអាចបត់បែនបាន តាម ដំណាក់កាល សម្រាប់រយៈពេលមធ្យមមួយដើម្បីឲ្យមានការកសាងសមមត្ថភាពនៅកម្រិតថ្នាក់ក្រោមជាតិ។ គណៈកម្មការជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ

	ថ្នាក់ ក្រោមជាតិកំពុងតែរៀបចំកម្មវិធីអនុវត្ត ថ្នាក់ជាតិរយៈពេល១០ឆ្នាំ។ ៣៤៨ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រដ្ឋាភិបាលសម្រាប់កំណែទម្រង់ វិមជ្ឈការ និង វិសហមជ្ឈការ និងដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មការជាតិអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិកំពុងតែ អភិវឌ្ឍកម្មវិធីអនុវត្តរយៈពេល ១០ ឆ្នាំ ដែលហៅថា កម្មវិធីសម្រាប់អភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ។ កម្មវិធីនេះនឹង រួមមានបីដំណាក់កាល៖ ដំណាក់កាលទី ១ មានរយៈពេលបីឆ្នាំ ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១២ នឹងផ្តោតទៅលើការបង្កើត និងស្ថាបនាកម្មនៃ រចនាសម្ព័ន្ធ និងក្របខ័ណ្ឌ អភិបាលកិច្ចល្អនៅកម្រិតជាតិ និងកម្រិតថ្នាក់ក្រោមជាតិ។ ដំណាក់កាលទី ២ ក៏មានរយៈពេលបីឆ្នាំដែរ គឺចាប់ពីឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៥ នឹងផ្តោត ទៅលើការពង្រឹង និងកែលំអរចនាសម្ព័ន្ធ និងក្របខ័ណ្ឌការងារទាំងនោះដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាព ក្នុងការដាក់ចេញ និងអនុវត្តគោលនយោបាយទាំងនោះសម្រាប់តំបន់របស់គេរៀងៗខ្លួន ដើម្បីធ្វើឲ្យប្រសើរឡើងនូវការផ្តល់ សេវាសាធារណៈ។ ដំណាក់កាលទី ៣ មានរយៈពេលបួនឆ្នាំ ចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩ នឹងផ្តោតទៅលើការផ្លាស់ប្តូរសមាសភាព និងសកម្មភាពនៃកម្មវិធីដើម្បី ធានាឲ្យកាន់តែទទួលបាននូវជោគ ជ័យបន្ថែមទៀត និងបន្តធ្វើឲ្យប្រសើរឡើង នូវការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យតាមរយៈ ចំណេះដឹងដែលបានទទួល និងបទពិសោធន៍ដែលបានពីដំណាក់កាលទី១ និង ដំណាក់កាលទី២។

យោបល់របស់អង្គការមិនមែនរដ្ឋាភិបាលអំពីការរីកចម្រើន និងប្រសិនបើមានកង្វះខាត ត្រូវផ្តល់ភស្តុតាង ឬបទពិសោធន៍ច្បាស់លាស់ ពីថ្នាក់មូលដ្ឋាន	**អនុសាសន៍ចំពោះកង្វះខាត**
អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ថារាជរដ្ឋាភិបាលមានបំណងលើកកម្ពស់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ក្នុងកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ។ គណៈកម្មការជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (NCDD) បានធ្វើសេចក្តីព្រាងលើ ច្បាប់ ក្រឹត្យ អនុក្រឹត្យ មួយចំនួន និងបទបញ្ជាផ្សេងទៀត ដោយផ្តោត ជាសំខាន់លើការរៀបចំស្ថាប័ននានា ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ត្រូវបានអនុម័ត ដោយទីស្តីការគណៈរដ្ឋមន្ត្រី NP-SNDD ត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវ ការនិងផែនការបីឆ្នាំបានបង្កើត។ មន្ត្រី ដែលធ្វើការនៅក្នុងប្រព័ន្ធវិមជ្ឈការ ត្រូវបានបណ្តុះ បណ្តាល។ តាមរយៈ NCDD រាជរដ្ឋាភិបាលកម្ពុជា បានវិនិយោគ	១. អភិវឌ្ឍគម្រោងកសាងសមត្ថភាព ដោយសហការជាដៃគូវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជំនាញ ដើម្បីពង្រឹងសមត្ថភាពរបស់ ក្រុមប្រឹក្សា ដែលទើបបង្កើតឡើងនាពេលថ្មីៗនេះ និងមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសពាក់ព័ន្ធនឹងការយល់ដឹងអំពី សិទ្ធិអំណាច និងទំនួលខុសត្រូវ របស់ខ្លួន ភាពជាអ្នកដឹកនាំ និងការធ្វើសេចក្តីសម្រេច និងយល់ពីគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ និង ការចូលរួមរបស់ពួកគេទៅក្នុងដំណើការ ធ្វើសេចក្តីសម្រេច។ ២. បង្កើតយន្តការចូលរួមច្បាស់លាស់មួយ ដែលភ្ជាប់ទំនាក់ទំនងរាជរដ្ឋាភិបាល/វិមជ្ឈការ និងវិសហមជ្ឈការ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល (NGO) នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នៅគ្រប់ខេត្ត-រាជធានីទាំងអស់។ ៣.គួរបង្កើនការពិគ្រោះយោបល់ ជាមួយសារធាណជនឲ្យបានច្រើនជាងមុន អំពីការបង្កើតក្របខ័ណ្ឌច្បាប់ ដែលពាក់

ប្រាក់រាប់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ នៅក្នុងគម្រោងទ្រង់ទ្រាយតូច ចំនួនរាប់ពាន់ជួយប្រជាជនបានរាប់លាននាក់។	ព័ន្ធនឹងវិមជ្ឈការ និងវិសហមជ្ឈការ ដូចជាច្បាប់ ក្រឹត អនុក្រឹត និងគោលការណ៍ណែនាំដែលគាំទ្រដល់ការ អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ៤. តុល្យភាពគម្រោងកសាងសមត្ថភាព មិនត្រឹមតែផ្តល់ដល់មន្ត្រីរាជការរបស់ រាជរដ្ឋាភិ បាលថ្នាក់ក្រោមជាតិ ប៉ុន្តែគួរតែផ្តល់បន្ថែមដល់ក្រុមសង្គមស៊ីវិលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធផងដែរ គឺដើម្បីបង្កើនការចូលរួមដោយពិតប្រាកដ និងទៀងទាត់ "រៀនសូត្រពីការអនុវត្ត" ពីអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ក្នុងដំណើរការកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ការអនុវត្តសកម្មភាពនៃ NP-SNDD/IP3 ៥. បើកចំហឲ្យមានការចូលរួមដើម្បី ស្ថាបនាពីអង្គការសង្គមស៊ីវិលនៅកម្រិតគោលនយោបាយ ទៅក្នុងការអនុវត្តអនុកម្មវិធីទាំងប្រាំមួយនៃ NP-SNDD/IP3 ដើម្បីបង្កើនការទទួលខុសត្រូវភាពជាម្ចាស់ការ និងគណនេយ្យភាពនៃកម្មវិធីដោយក្រសួងតាមផ្នែកផ្សេងៗ ចំពោះប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធថ្នាក់ ក្រោមជាតិ។

**ទំព័រលេខក្នុង NSDP បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣*

***កថាខណ្ឌលេខក្នុង NSDP បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣*

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

គណៈកម្មការដឹកនាំ WGPD

លោក ឡាំ សុជាតិ គណៈកម្មការដឹកនាំ WGPD និងជានាយករង នៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
អាសយដ្ឋាន៖ អគារភ្នំពេញវីឡាលេខ ១២៤ ជាន់ទី ២ បន្ទប់លេខ ២០៦ ផ្លូវលេខ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ
ទូរសព្ទ៍៖ (៨៥៥) ២៣ ២១ ៣៤ ៨៦/ ទូរសារ៖ (៨៥៥) ២៣ ២១ ៣៤ ៨៧
ទូរសព្ទ៍ដៃ៖ (៨៥៥-១២) ៧១ ៨៦ ១១
អ៊ីម៉ែល៖ socheatlam@apiinstitute.org

លោកស្រី ប្រាក់ សុខានី នាយិកាប្រតិបត្តិ នៃអង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា (CCSP)
អាសយដ្ឋាន៖ ផ្លូវ សុធារស (៣) មជ្ឈមណ្ឌលភ្នំពេញ អគារ F បន្ទប់លេខ ០៨៩ ជាន់ក្រោម ១២៣០១ ភ្នំពេញ
ទូរសព្ទ៍៖ (៨៥៥) ២៣ ២១ ០៣ ៨០
អ៊ីម៉ែល៖ ed@ccspcambodia.org

ការគ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និងរ៉ែ

១. សេចក្តីផ្តើម

សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT) ជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដែលមានអង្គការសមាជិកចំនួន៧គឺ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) អង្គការភាពជាដៃគូក្នុងសកម្មភាព (DPA) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) អង្គការអនុផលព្រៃឈើ (NTFP) អង្គការស្មារកម្ពុជា មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) និងអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) និងសមាជិកគាំទ្រជាឯកត្តបុគ្គល និងអង្គការចំនួន ៨០០នាក់។

CRRT មានឆន្ទៈចូលរួមក្នុងន័យស្ថាបនាជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាថា ចំណូលដែលបានពីឧស្សាហកម្មនិស្សារណកម្ម (ប្រេង ឧស្ម័ន និងរ៉ែ) ត្រូវបានគ្រប់គ្រងប្រកបដោយតម្លាភាព និងគណនេយ្យភាព ដែលធ្វើឲ្យសាធារណជនទូទៅអាចយល់ដឹងបាន។ ដោយមានការជួយជ្រោមជ្រែងពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) CRRT ធ្វើការតាមដានទៅលើគោលបំណង ១១.២ "បង្កើត និងអនុវត្តន៍នូវគោលនយោបាយប្រេង ឧស្ម័ន និងរ៉ែ យន្តការគ្រប់គ្រងប្រាក់ចំណូលប្រកបដោយតម្លាភាព រួមមាន EITI និងសមត្ថភាពនៃការវាយតម្លៃនិងការប្រមូល ចំណូល" នៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ជំហានទី២ ដែលត្រូវបានគូសបញ្ជាក់ផងដែរក្នុងសូចនាករតាមដានរួម(JMI)ទី១៩ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ព័ត៌មានទំនាក់ទំនងរបស់លេខាធិការដ្ឋាន CRRTអាចស្វែងរកបាននៅខាងក្រោម រួមទាំងគេហទំព័រ និងអ៊ីមែលដើម្បីទទួលបានព្រឹត្តប័ត្រប្រចាំពីរខែម្តងរបស់CRRT។

២. សូចនាករតាមដានរួម (សូចនាករតាមដានរួមទី១៩)

ស្ថាប័នសម្របសម្រួល៖ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ/គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ/ក្រុមការងារបច្ចេកទេសកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ស្ថាប័នអនុវត្ត៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងដែលពាក់ព័ន្ធ

លទ្ធផលរយៈពេលមធ្យម	ធាតុចេញ	សូចនាករធាតុចេញ	សកម្មភាព៖ គោលដៅកំណត់	សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ
១៩.ពង្រឹងភាពជឿទុកចិត្តនៃថវិកា និងបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ	១. គោលនយោបាយចំណូលព្យាករណ៍ និងប្រមូលចំណូល និងពង្រឹងសមត្ថភាព និងតម្លាភាពក្នុងការប្រមូលចំណូល ...	២. ក្របខ័ណ្ឌច្បាប់ឧស្សាហកម្មនិស្សារណកម្មត្រូវបានអនុម័ត និងអនុវត្តន៍ ៣. ពង្រឹងតម្លាភាពក្នុងការគ្រប់គ្រងចំណូលពន្ធ និងមិនមែនពន្ធ	២. រៀបចំសេចក្តីព្រាងច្បាប់ស្តីពីពន្ធលើប្រេង និងឧស្ម័ន ៣. ពង្រឹងការព្យាករណ៍ចំណូលប្រព័ន្ធប្រមូលចំណូលនិងសមត្ថភាព ...	១. ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានសមាសភាគសំខាន់ៗដែលបានចូលរួមបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ (ផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) ២. កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ និងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំជាច្រើន ត្រូវបានរៀបចំ ដើម្បីពិភាក្សា និងតាមដានត្រួតពិនិត្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

២.១ ការបង្កើតនូវក្របខ័ណ្ឌគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្ម

CRRT សូមអបអរសាទរចំពោះរាជរដ្ឋាភិបាលសម្រាប់ការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងក្នុងការធ្វើឲ្យប្រសើរឡើងនូវគោលនយោបាយចំណូល និងរដ្ឋបាលជាទូទៅ ជាពិសេសការគ្រប់គ្រងឧស្សាហកម្មនិស្សារណកម្មប្រកបដោយតម្លាភាព និង**ប្រសិទ្ធភាព**។ CRRT បានកត់សម្គាល់នូវវឌ្ឍនភាពសំខាន់ៗក្នុងការបង្កើតនូវក្របខ័ណ្ឌច្បាប់ដើម្បីគ្រប់គ្រងឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា ជាពិសេសក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ជំហានទី២។

យោងតាមរបាយការណ៍វឌ្ឍនភាព PFMRP ឆ្នាំ២០១១[5] សេចក្តីព្រាងច្បាប់ស្តីពីការធ្វើវិសោធនកម្មលើច្បាប់ស្តីពីពន្ធ (សេចក្តីព្រាងច្បាប់ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត) ត្រូវបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការអនុម័ត ខណៈពេលដែលប្រកាសស្តីពីការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងសេចក្តីព្រាងច្បាប់ស្តីពីពន្ធលើប្រតិបត្តិការ ធនធានរ៉ែ កំពុងត្រូវបានរៀបចំ។ របាយការណ៍នេះ ក៏បានគូសបញ្ជាក់ផងដែរនូវការពិភាក្សាជាបន្តរបស់ក្រុមការងារបច្ចេកទេសអន្តរក្រសួងស្តីពីការកៀងគរចំណូលពីវិស័យប្រេង និងឧស្ម័ន។ ជាងនេះទៅទៀត ចំណាត់ថ្នាក់ថវិកា (ចំណាត់ថ្នាក់សេដ្ឋកិច្ច) និងតារាងគណនេយ្យរួម ត្រូវបានពិនិត្យក្នុងការរៀបចំសម្រាប់ការណែនាំពីប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ (FMIS) និងកត់ត្រាគ្រប់គម្រោងម្ចាស់ជំនួយទាំងអស់ទៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុថ្នាក់ជាតិតែមួយ។

ក្រៅពីនេះ ការបើកទូលាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើបញ្ហាដែលទាក់ទងទៅនឹងឧស្សាហកម្មនិស្សារណកម្មបច្ចុប្បន្នត្រូវបានកត់សម្គាល់ក្នុងការអនុវត្តជាក់ស្តែង។ ទាំងនេះ រួមបញ្ចូលនូវវត្តមានរបស់មន្ត្រីពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ក្នុងការធ្វើបច្ចុប្បន្នកម្ម និងការពិភាក្សាទៅលើប្រតិបត្តិការធនធានរ៉ែ នៅក្នុង "សិក្ខាសាលាស្តីពី តម្លាភាពក្នុងការគ្រប់គ្រងប្រាក់ចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម" ដែលត្រូវបានសហការរៀបចំឡើងដោយ NGO Forum និងCRRT កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២។ ការបើកទូលាយនេះ ត្រូវបានមើលឃើញបន្ថែមទៀតនៅពេលដែល MIME ឆ្លើយតបតាមការស្នើសុំពី NGO Forum ពីការពន្យល់បញ្ជាក់ពីតួនាទីរបស់ MIME នៅក្នុងការគ្រប់គ្រងវិស័យរ៉ែ និងឯកសារផ្លូវច្បាប់មួយចំនួនដែលទាក់ទងវិស័យរ៉ែ និងរបាយការណ៍សង្ខេបប្រចាំឆ្នាំ២០១១ និងផែនការ សកម្មភាពសម្រាប់ឆ្នាំ២០១២ របស់អគ្គនាយកដ្ឋានធនធានរ៉ែ។

២.២ ចំណុចដែលត្រូវការកែលំអបន្ថែម

វឌ្ឍនភាពដែលបានលើកឡើងខាងលើឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ដែលបានគូសបញ្ជាក់នៅក្នុងកថាខ័ណ្ឌ៣៧១ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) បច្ចុប្បន្នកម្ម ២០០៩-២០១៣ បានលើកឡើងថា "រាជរដ្ឋាភិបាលប្តេជ្ញាគ្រប់គ្រងប្រកបដោយ**ប្រសិទ្ធភាព** តម្លាភាព និងគណនេយ្យភាពនៃចំណូលពីការទាញយករ៉ែ ប្រេង និងឧស្ម័ន"។ ទោះជាយ៉ាងនេះក្តី CRRT ទន្ទឹមគ្នានេះ ក៏បានធ្វើការសង្កេតនូវចំណុចដែលត្រូវកែលម្អមួយចំនួនក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ហើយនិងការគ្រប់គ្រងចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម ព្រមទាំងអំពាវនាវឲ្យផ្តោតការយកចិត្តទុកដាក់ និងធ្វើសកម្មភាពបន្ថែមទៀតពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងប្រកបដោយតម្លាភាពទៅលើធនធានសាធារណៈនេះ។

កង្វះខាតការពិគ្រោះយោបល់ជាសាធារណៈទៅលើសេចក្តីព្រាងច្បាប់ និងបទបញ្ញត្តិសំខាន់ៗស្តីពីការគ្រប់គ្រងប្រាក់ចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម

[5] របាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ (PFMRP) ត្រូវបានបង្ហាញជូនដល់ដៃគូអភិវឌ្ឍន៍ ក្រសួងពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលមួយចំនួនតូច នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលក្នុងនោះ NGO Forum ជាសមាជិក) ហើយរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ឆមាស និងត្រីមាស អាចរកបាននៅក្នុងគេហទំព័រ http://www.pfm.gov.kh។

តួនាទីដ៏សំខាន់របស់សង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងការលើកកម្ពស់តម្លាភាពត្រូវបានគូសបញ្ជាក់នៅក្នុងផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់កៀងគរ និងគ្រប់គ្រងចំណូលពីធនធានប្រេង ឧស្ម័ន និងរ៉ែ ព្រមទាំងការទទួលស្គាល់សម្ព័ន្ធភាពCRRT ពីសំណាក់អាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) ដោយការដាក់បញ្ចូលគេហទំព័ររបស់ CRRT ទៅក្នុងគេហទំព័ររបស់ខ្លួន។ ទោះបីជាយ៉ាងនេះក្តី តាមការសង្កេតឃើញថា មិនមានការពិគ្រោះយោបល់ជាសាធារណៈត្រូវបានធ្វើឡើង ឬការធ្វើការជាមួយសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាល ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាទៅលើ សេចក្តីព្រាងច្បាប់ទាក់ទងទៅនឹងវិស័យឧស្សាហកម្មនិស្សារណកម្មដ៏មានសារៈសំខាន់នេះទេ បើទោះជាមានការស្នើសុំពីសំណាក់សង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាលក្តី។ ច្បាប់ និងបទបញ្ញត្តិទាំងនេះ នឹងបង្កើតនូវក្របខ័ណ្ឌរឹងមាំមួយ ថាតើ អាជ្ញាប័ណ្ណ និងសម្បទាននឹងត្រូវបានផ្តល់ជូន ដោយរបៀបណា នៅទីណា ហើយស្ថិតក្រោមកាលៈទេសៈអ្វីខ្លះ ចំណូលនឹងត្រូវបានបង់ជូន និងរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា ហើយបញ្ហា សេដ្ឋកិច្ច និងសង្គមអ្វីខ្លះដែលនឹងជៈឥទ្ធិពលដល់ប្រទេសកម្ពុជាសម្រាប់រយៈពេលច្រើនឆ្នាំខាងមុខ។ ការបញ្ចេញនូវសេចក្តីព្រាងច្បាប់ និងបទបញ្ញត្តិ សម្រាប់ពិគ្រោះយោបល់ជាសាធារណៈ នឹងផ្តល់នូវឱកាសដល់សាធារណជន និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍវិស័យនេះ ព្រមជាមួយការបង្កើននូវតម្លាភាពបន្ថែមទៀតក្នុងការគ្រប់គ្រងចំណូលពីធនធានសាធារណៈនេះ។ សំខាន់ជាងនេះទៅទៀត សកម្មភាពដូចនេះនឹងផ្តល់ជាសញ្ញា ពីការប្តេជ្ញាចិត្តពិតប្រាកដរបស់រាជរដ្ឋាភិបាល ដែលបានលើកឡើងក្នុង កថាខ័ណ្ឌ៣៨៧ នៃផែន ការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ថា *"រាជរដ្ឋាភិបាលកម្ពុជាយល់ថាអង្គការសង្គមស៊ីវិល គឺជាដៃគូអភិវឌ្ឍយ៉ាងសំខាន់ក្នុងដំណើរការនៃការអភិវឌ្ឍន៍ជាតិ។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជម្រុញលើកទឹកចិត្តដល់អង្គការ សង្គមស៊ីវិលដែលត្រូវបាន បង្កើតឡើងដោយស្របច្បាប់ និងដំណើរការដោយផ្អែកលើមូលដ្ឋានអភិបាលកិច្ចល្អក្នុងការធ្វើឲ្យមានចំណែកពាក់ព័ន្ធទៅ ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រទេសជាតិ និងក្នុងការធ្វើឲ្យប្រសើរឡើង ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងលើកទឹកចិត្តដល់ការចូលរួមទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ"*។ លើសពីនេះទៅទៀត កថាខ័ណ្ឌ៣៨៩ ក៏បានសង្កត់ធ្ងន់ផងដែរ ថា *"រាជរដ្ឋាភិបាលកម្ពុជាគោតសរសើរចំពោះការចូលរួមយ៉ាងសកម្មរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការ អភិវឌ្ឍន៍ជាតិ តាមរយៈការរួមចំណែកដោយស្មោះស្ម័គ្រ និងដោយសុទ្ធចិត្ត ទាំងធនធានហិរញ្ញវត្ថុ និងប្រតិបត្តិការ។ រាជរដ្ឋាភិបាលកម្ពុជា យល់ថា ធនធាន និងជំនាញការ ដែលបានផ្តល់ដោយអង្គការសង្គមស៊ីវិល គឺជាធាតុចូលយ៉ាង សំខាន់នៅក្នុងដំណើរការគោលនយោបាយ ដើម្បីឈានទៅសម្រេចលទ្ធផលអភិវឌ្ឍន៍ដែលចង់បាន។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តធានានូវការចូលរួមយ៉ាងសកម្មរបស់អង្គការសង្គមស៊ីវិលនៅក្នុងយន្តការពិគ្រោះយោបល់"*។

ការធ្វើឲ្យកាន់តែប្រសើរនូវតម្លាភាពក្នុងការគ្រប់គ្រងចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម តាមរយៈការអនុម័ត និងការអនុវត្តនូវគោលការណ៍ EITI

សកម្មភាព	សូចនាករការអនុវត្តសំខាន់ៗ	គោលដៅសំខាន់ៗ		
		២០០៩	២០១០	២០១១
១១.២ បង្កើតនិងអនុវត្តគោលនយោបាយចំណូលពីប្រេង/ឧស្ម័ន/រ៉ែ យន្តការគ្រប់គ្រងប្រកបដោយតម្លាភាពលើ លំហូរចំណូលដោយរួមទាំង EITI ការវាយតម្លៃ និងសមត្ថភាពប្រមូលចំណូល។	របបសារពើពន្ធលើប្រេង/ឧស្ម័ន/រ៉ែ ត្រូវបានកំណត់ និងក្របខ័ណ្ឌច្បាប់ ត្រូវបានអនុម័ត និងចាប់ផ្តើមអនុវត្ត	របបសារពើពន្ធត្រូវ បានកំណត់ ការសិក្សាពី EITI ត្រូវ បានបញ្ចប់ ជម្រើសគោល នយោបាយគ្រប់គ្រងចំណូលប្រេង/ឧស្ម័ន/រ៉ែ ត្រូវបានរៀបចំ និងឯកភាព	EITI ត្រូវបានអនុវត្តជាបឋម ក្របខ័ណ្ឌគ្រប់គ្រងចំណូលប្រេង/ឧស្ម័ន/រ៉ែ ត្រូវបានបង្កើត	EITI ត្រូវបានអនុវត្ត ក្របខ័ណ្ឌច្បាប់គ្រប់គ្រងចំណូលពីប្រេង/ឧស្ម័ន/រ៉ែ ត្រូវបានអនុវត្ត

ប្រភព៖ PFMRP, CAP2, Progress Summary Matrix

យោងទៅលើរបាយការណ៍វឌ្ឍនភាពឆ្នាំ២០០៩ ស្តីពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ក្រុមការងារអន្តរក្រសួងដែលកៀងគរ និងគ្រប់គ្រងប្រាក់ចំណូលពីប្រេង ឧស្ម័ន និងធនធានរ៉ែដទៃផ្សេងទៀត គឺទទួលខុសត្រូវក្នុងការសិក្សា និងអនុវត្តន៍នូវគោលការណ៍នៃគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI)។ ទោះបីជាយ៉ាងនេះក្តី វឌ្ឍនភាពនៃការអនុម័ត និងការអនុវត្តគោលការណ៍ EITI មិនត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ឆ្នាំ២០១០ និង២០១១ ដូចដែលបានកំណត់គោលដៅនៅក្នុងផែនការសកម្មភាពរួមរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ជំហានទី២។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារ ក្រោយមកត្រូវបានលើកឡើង នៅក្នុងរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១១ ប៉ុន្តែមិនបានគូសបញ្ជាក់នូវសកម្មភាពលម្អិតដែលពណ៌នាពីដំណើរការអនុវត្តនាពេលកន្លងមក។ ដោយគ្មានព័ត៌មានបែបនេះ ប្រជាពលរដ្ឋនឹងមិនទទួលបាននូវព័ត៌មានស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ឆ្ពោះទៅសម្រេចបាននូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះតម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងចំណូលទាំងនេះ ដូចដែលបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម និងការអនុវត្តគោលការណ៍ EITI ហើយសង្ឃឹមថា លេខាធិការដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Secretariat) រួមជាមួយក្រុមការងារបច្ចេកទេសអន្តរក្រសួងនឹងដាក់បញ្ចូលនូវព័ត៌មានថ្មីៗស្តីពីដំណើរការនេះ នៅក្នុងរបាយការណ៍លើកក្រោយរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាមួយនឹងព័ត៌មាននេះ សាធារណជននឹងយល់ដឹងពីវឌ្ឍនភាព និងបញ្ហាប្រឈមដែល រាជរដ្ឋាភិបាលបាននិងកំពុងជួបប្រទះក្នុងការអនុម័តគោលការណ៍ EITI។

ការផ្សព្វផ្សាយព័ត៌មានស្តីពីការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្មជាសាធារណៈនៅមានកម្រិត

បន្ថែមលើការមិនមានព័ត៌មានស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលការណ៍ EITI ព័ត៌មានដែលទាក់ទងទៅនឹងការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្ម ត្រូវបានបង្ហាញយ៉ាងច្បាស់ថានៅមានកម្រិតនៅឡើយ បើផ្អែកទៅលើការស្ទាបស្ទង់មតិចំនួនពីរលើកកន្លងមក។ ការស្ទាបស្ទង់មតិលើកទី១ ត្រូវបានធ្វើឡើងនៅចុងឆ្នាំ ២០១០ ដោយវិទ្យាស្ថានសេដ្ឋកិច្ចនៃកម្ពុជា (EIC) សហការជាមួយ CRRT សិក្សាក្នុងចំណោមម្ចាស់ ឬតំណាងសហគ្រាសធុនតូច និងមធ្យមចំនួន ៥៤៨នាក់ ក្នុងខេត្តចំនួន១៦ (ខេត្តដែលមានសហគ្រាសធុនតូច និងមធ្យមច្រើនជាង២០០សហគ្រាស) នៅក្នុងប្រទេសកម្ពុជា។ លទ្ធផលបានបង្ហាញថា ម្ចាស់សហគ្រាសធុនតូច និងមធ្យម មិនសូវស្គាល់ពាក្យ "ឧស្សាហកម្មនិស្សារណកម្ម" ទេ ប៉ុន្តែពួកគាត់ក្នុងចន្លោះពី២០%-៦០% ធ្លាប់លើអំពីឧស្សាហកម្មប្រេងឆៅ ឧស្ម័នធម្មជាតិ និងរ៉ែ។ ស្ទើរតែទាំងអស់នៃពួកគាត់ មិនបានដឹងពីការអភិវឌ្ឍន៍បច្ចុប្បន្ន (ការរុករក និងការទាញយក) នៃធនធាននេះ។ ជាងនេះទៅទៀត ប្រមាណពាក់កណ្តាលនៃអ្នកឆ្លើយទាំងអស់ មិនបានដឹងថាតើរាជរដ្ឋាភិបាលបានទទួលចំណូលពីឧស្សាហកម្មនេះឬទេ ហើយក្នុងចំណោមអ្នកដែលជឿជាក់ថារាជរដ្ឋាភិបាលទទួលបានចំណូល ឬនឹងទទួលបាននាអនាគតនោះ ក៏មិនបានដឹងពីចំនួនពិតប្រាកដ ដោយផ្អែកទៅលើព័ត៌មានដែលទទួលបានពីទូរទស្សន៍ វិទ្យុ កាសែត និងការនិយាយតៗគ្នា (ដែលមិនត្រូវបានបញ្ជាក់ជាផ្លូវការ)។ ព័ត៌មានស្តីពីឈ្មោះ និងសកម្មភាពរបស់អង្គភាព ស្ថាប័ន ឬក្រុមហ៊ុន ដែលធ្វើការ លើឧស្សាហកម្មនិស្សារណកម្ម មិនច្បាស់ចំពោះអ្នកឆ្លើយ។ ព័ត៌មានដែលចាប់អារម្មណ៍បំផុតសម្រាប់សហគ្រាសធុនតូច និងមធ្យមដែលធ្វើអង្កេតនេះ រួមមានព័ត៌មានទាក់ទងនឹងការរុករក ការផលិត និងផលប្រយោជន៍ដែលអាចទទួលបាន ដោយរួមមានព័ត៌មានស្តីពីសក្តានុពលចំណូលផងដែរ។

ការស្ទាបស្ទង់មតិមួយទៀត ត្រូវបានធ្វើឡើងនៅក្នុងខែកញ្ញា ដល់ខែតុលា ឆ្នាំ២០១១ ដោយ NGO Forum ជាមួយនិស្សិត ៣៧៧នាក់ ដែលតំណាងឲ្យសកលវិទ្យាល័យឯកជនចំនួន៧ នៅទីក្រុងភ្នំពេញ។ សកលវិទ្យាល័យរបស់រដ្ឋទាំង៧ ក្នុងចំណោមសកលវិទ្យាល័យទាំង ១៤ ដែលបានជ្រើសរើសដោយស្មើភាពគ្នា មិនអនុញ្ញាត្តិឲ្យធ្វើអង្កេតនៅក្នុងសកលវិទ្យាល័យរបស់គេទេ។ ការស្ទាបស្ទង់មតិនេះ បានវាយតម្លៃទៅលើបរិមាណព័ត៌មានដែលនិស្សិតទទួលបាន និងការយល់ឃើញរបស់ពួកគេទៅលើការគ្រប់គ្រងចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្មនាពេលអនាគត។ របកគំហើញសំខាន់ៗបង្ហាញថា ៩២% នៃអ្នកដែលត្រូវបានសំភាសន៍បាននិយាយថា ពួកគេយល់ដឹងពីការអភិវឌ្ឍន៍នៃវិស័យឧស្សាហកម្មនិស្សារណកម្ម។ ទោះជាយ៉ាងនេះក្តី ពួកគេវាយតម្លៃកម្រិតនៃការយល់ដឹងរបស់ពួកគេ (ឬភាគរយនៃព័ត៌មាន ដែលពួកគេ

ទទួលបាន) ត្រឹមតែ ១៤% ៣៣% និង ៤៨% រៀងៗគ្នា ថាមានកម្រិតទាបណាស់ ទាប និងមធ្យម។ ប្រមាណ ៤៣% នៃអ្នកឆ្លើយ គិតថារាជរដ្ឋាភិបាលបានទទួលចំណូលពីឧស្សាហកម្មនិស្សារណកម្ម រីឯ ១៧% ទៀតគិតថាមិនទាន់ បានទទួលចំណែកអ្នកនៅសល់ប្រមាណ៤0% មិនដឹងថា រាជរដ្ឋាភិបាលបានទទួលចំណូលពីវិស័យ នេះឬទេ។ ជាមធ្យម អ្នកឆ្លើយតិចជាងពាក់ កណ្តាលមិនដឹងអំពីដំណើរការនៃការផ្តល់អាជ្ញាប័ណ្ណ ក្រុមហ៊ុនដែលបានអាជ្ញាប័ណ្ណ ច្បាប់ និងបទបញ្ញត្តិផ្សេងៗដែលរាជរដ្ឋាភិបាលកំពុងបង្កើតដើម្បីគ្រប់គ្រងឧស្សាហកម្មនិស្សារណកម្ម។ ប្រមាណជាជិត ៩៥% នៃអ្នក ឆ្លើយគាំទ្រថា រាជរដ្ឋាភិបាលគួរធ្វើការពិគ្រោះយោបល់ជាសាធារណៈទៅលើរាល់សេចក្តីព្រាងច្បាប់ និងបទបញ្ញត្តិ។ លទ្ធផលក៏បង្ហាញផងដែរថា ប្រមាណជា៦0%នៃអ្នកឆ្លើយយល់ថា រាជរដ្ឋាភិបាលមានលទ្ធភាពក្នុងការប្រមូល និងប្រើ ប្រាស់ចំណូលពីឧស្សាហកម្មនិស្សារណកម្មប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ក្នុងកម្រិតមធ្យម និងទាបជាងមធ្យម ខណៈមានតែប្រមាណជា ១0% ទៅ ២0% យល់ថាមានកម្រិតខ្ពស់ ហើយតិចជាង ៣% យល់ថាខ្ពស់ខ្លាំង។

លទ្ធផលនៃការស្ទាបស្ទង់ទាំងពីរលើកនេះបង្ហាញថា ការយល់ដឹងរបស់ប្រជាពលរដ្ឋសកម្មបំផុតស្តីពីការអភិវឌ្ឍឧស្សាហកម្មនិស្សារណកម្ម គឺនៅមានកម្រិតទាបនៅឡើយ ខណៈដែលព័ត៌មានស្តីពីចំណូលពីវិស័យនេះរឹតតែមានកម្រិតតិចតួចទៅទៀត។ កម្រិតព័ត៌មាននាពេលបច្ចុប្បន្ននេះ មិនបានផ្តល់ព័ត៌មានដល់សាធារណជនអំពីកិច្ចខិតខំប្រឹងប្រែងនិងវឌ្ឍនភាពរបស់រាជរដ្ឋាភិបាលដែលកំពុងតែអនុវត្តនោះទេ ហើយអាចបណ្តាលឲ្យមានការយល់ខុសរបស់សាធារណជនទៅលើការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងវិស័យនេះប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដូចដែលបានយល់ឃើញនៅក្នុងការស្ទាបស្ទង់មតិនេះ។ ជាងនេះទៅទៀត កង្វះខាតនូវព័ត៌មានជាសាធារណៈស្តីពីឧស្សាហកម្មនិស្សាហកម្ម ក៏ជាឧបសគ្គរាំងស្ទះដល់ការចូលរួមពីសាធារណជន និងការធានានូវតម្លាភាពក្នុងការគ្រប់គ្រងនូវធនធានសាធារណៈនេះ។

បន្ថែមលើកម្រិតទាបនៃការយល់ដឹងរបស់សាធារណជន ស្តីពីការអភិវឌ្ឍន៍ និងការគ្រប់គ្រងចំណូលឧស្សាហកម្មនិស្សារណកម្ម ព័ត៌មានស្តីពីចំណូលពីវិស័យនេះ ជាពិសេសចំណូលបានពីប្រេង និងឧស្ម័ន ត្រូវបានគេកត់សម្គាល់ឃើញមានផ្សព្វផ្សាយជាសាធារណៈជាចំនួនសរុប ដែលត្រូវបានកត់ត្រាតែមួយបន្ទាត់នៅក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) ជា "ប្រាក់ចំណូលពីឧស្សាហកម្មនិស្សារណកម្ម" ហើយដែលមិនមានតួលេខតាំងពីខែមិថុនា ឆ្នាំ២0១១ មកម្ល៉េះ។ ខណៈដែលខ្វង់ចំណូលពីឧស្សាហកម្មនិស្សារណកម្មដែលមិនមានតួលេខនេះ ត្រូវបានដកចេញពីតារាង TOFE ក្នុងខែសីហា និងវិច្ឆិកា ឆ្នាំ២0១១ តារាងTOFE ក៏ត្រូវបានបង្ហាញជាផ្នែកមួយនៅក្នុងព្រឹត្តប័ត្រស្ថិតិប្រចាំខែរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលសាធារណជនអាចរកជាវបានទាន់ពេលវេលាជាង។ ចំពោះតារាង TOFE នៅក្នុងព្រឹត្តប័ត្រនេះ ចំណូលពីឧស្សាហកម្មនិស្សារណកម្មត្រូវបានរក្សាទុកដដែល បើទោះជាមិនមានចំណូលក៏ដោយ។ ផ្អែកលើការបញ្ជាក់អះអាងរបស់មន្ត្រីនៅនាយកដ្ឋានគោលនយោបាយ និងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មូលហេតុដែលខ្វង់នេះត្រូវបានដកចេញ គឺដោយសារតែមិនមានព័ត៌មានថ្មីៗស្តីពីចំណូលពីវិស័យនេះរាយការណ៍ពីឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ហើយខ្វង់នេះនឹងត្រូវបានបង្ហាញឡើងវិញ នៅពេលដែលមានការរាយការណ៍ពីចំណូលទទួលបានពីឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។ CRRT សូមស្នើសុំថា ខ្វង់ចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្មគួរត្រូវបានរក្សាទុកដដែល ព្រមជាមួយការរាយការណ៍តួលេខទទេ ជាជាងការដកចេញ បើទោះជាមិនទាន់មានប្រាក់ចំណូលបន្ថែមពីប្រេង និងឧស្ម័នក៏ដោយ។ ការដកខ្វង់នេះចេញដោយមិនបានជូនដំណឹងអាចបណ្តាលឲ្យមានការ បរិយាយខុសៗគ្នាពីអ្នកពាក់ព័ន្ធផ្សេងៗដែលចាប់អារម្មណ៍ទៅលើបញ្ហានេះ។

កាលពីខែធ្នូ ឆ្នាំ២00៩ មន្ត្រីនៃក្រុមការងារបច្ចេកទេសអន្តរក្រសួង បានផ្តល់នូវបទបង្ហាញជូនដល់ សមាជិករដ្ឋសភានូវតារាងដែលបង្ហាញពីប្រភេទផ្សេងៗគ្នានៃចំណូល ជាមួយនឹងតារាងដោយឡែកពីគ្នាសម្រាប់ចំណូលពីរ៉ែ និងប្រេង/ឧស្ម័ន ហើយតារាងនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់របាយការណ៍របស់ EITI។ បើយោងតាមប្រកាសលេខ១៤៤៨ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ (២00៧) ការលម្អិតនូវចំណូលពីផលនៃសម្បទាន និងការជួលដីធ្លី បង្ហាញចំណូលដាច់ដោយឡែកពីសម្បទានប្រេង/ឧស្ម័ន និងសម្បទានរ៉ែ។ លើសពីនេះទៅទៀត ចំណូលដែលបានមកពីសម្បទានរ៉ែត្រូវបានលម្អិតជាចំណូលពីអាជីវកម្មរ៉ែ សួយសារថ្លៃឈ្នួល (ការ

ជួលដីរុករ៉ែ) ប្រចាំឆ្នាំ និងសួយសារដី (ការជួលដីមិនមានរ៉ែ)។ ដូច្នេះ ដើម្បីអាចយល់ដឹងបានពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះការគ្រប់គ្រងចំណូលប្រកបដោយតម្លាភាព CRRT សូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ផ្តល់នូវព័ត៌មានលម្អិតពីចំណូលពីឧស្សាហកម្មនិស្សារណកម្ម ដែលបានកំណត់នៅក្នុងមាតិកាថវិកា ក្នុងតារាងTOFE ក៏ដូចជាការពង្រឹងនូវការផ្តល់ព័ត៌មានឲ្យបានទាន់ពេលស្តីពីការរាយការណ៍ចំណូលពីឧស្សាហកម្មនិស្សារណកម្មនៅក្នុងតារាង TOFE និងតារាង TOFE ផ្នាល់ផងដែរ។

៣. សកម្មភាព/យុទ្ធសាស្ត្រសំខាន់ៗពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ(NSDP) បច្ចុប្បន្នកម្ម ២០០៩-២០១៣

ផ្នែក	ខ្លឹមសារ
៣៧១	រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនូវចំណូលដែលទទួលបានមកពីការធ្វើអាជីវកម្មលើធនធានរ៉ែ និងប្រេងកាត និងឧស្ម័ន។
៤៦៦	រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកធនធានប្រេងកាត និងឧស្ម័នកម្ពុជា គឺជាសក្តានុពលថ្មីដ៏សំខាន់សម្រាប់ធានាបាននូវសន្តិសុខថាមពល និងជាប្រភពនៃធនធានដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលវែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជានឹងរៀបចំក្របខ័ណ្ឌគោលនយោបាយ និងក្របខណ្ឌគតិយុត្តិ សម្រាប់វិស័យ នេះដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ធនធាននេះក្នុងបុព្វហេតុនៃការអភិវឌ្ឍសេដ្ឋកិច្ច និងការលើកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។
៤៧២	ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤នៃរដ្ឋសភា អាជ្ញាធរប្រេងកាត ជាតិកម្ពុជា នឹងផ្តោតការយកចិត្តទុកដាក់លើ: - បន្តរកចំណូលឲ្យបានជាអតិបរមាជូនរាជរដ្ឋាភិបាល តាមរយៈចំណូលជាសួយសារ ការបែងចែកផល ពន្ធលើប្រាក់ចំណេញ និងចំណូលពន្ធផ្សេងៗទៀត ទាក់ទងនឹងអាជីវកម្មប្រេងកាត និងឧស្ម័ន ដើម្បីចូលរួមក្នុងការបង្កើននូវសមត្ថភាពហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា។ - បង្កើតគោលនយោបាយ ច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋាននានាសម្រាប់វិស័យប្រេងកាត ដើម្បីធានានូវប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់ធនធានប្រេងកាត និងឧស្ម័នសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ - យកចិត្តទុកដាក់រៀបចំផែនការសម្រាប់ការប្រើប្រាស់ឧស្ម័នដែលនៅលាយឡំជាមួយប្រេងកាត ដែលនឹងទទួលបានពីផលិតកម្មប្រេងកាត ដើម្បីកុំឲ្យឧស្ម័នទាំងនោះក្លាយជាសំណល់ដែលឆេះចោលនៅក្នុងខ្យល់។ - លើកកម្ពស់សកម្មភាពឲ្យបានសមស្របសម្រាប់កែច្នៃធនធានប្រេងកាត ប្រកបដោយលក្ខណៈសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីបង្កើតកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម។ - ជម្រុញការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានប្រេងកាត និងឧស្ម័ន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ - បង្កើនការគ្រប់គ្រង និងតាមដានលើការអនុវត្តកិច្ចព្រមព្រៀងប្រេងកាតឲ្យមានប្រសិទ្ធភាពជាងមុន។ - ជម្រុញការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍដោយផ្តោតលើបញ្ហាប្រេងកាត និងឧស្ម័ន។

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចិត្តចំពោះតម្លាភាព គណនេយ្យភាព និងប្រសិទ្ធផល ក្នុងការគ្រប់គ្រងធនធាននិស្សារណកម្ម ដោយបង្កើតនូវច្បាប់ និងបទបញ្ញត្តិគ្រប់គ្រងសំខាន់ៗ ដូចដែលបានលើកឡើងនៅក្នុងសូចនាករតាមដានរួម (JMI) និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP)។ CRRT មើលឃើញថា វិស័យប្រេង ឧស្ម័ន និងរ៉ែ មិនទាន់ទទួលបានការយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់នៅក្នុង NSDP បច្ចុប្បន្នកម្ម ២០០៩-២០១៣ នៅឡើយទេ។ ទោះបីជាចំណូលទាំងនេះកំពុងត្រូវបានទទួលស្គាល់ថាជាធនធានដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលវែងក៏ដោយ ក៏ NSDP បច្ចុប្បន្នកម្ម មិនបានបរិយាយឲ្យបានល្អិតល្អន់ពីរចនាសម្ព័ន្ធគ្រប់គ្រង ប្រព័ន្ធ និងវិធានការ ដែលនឹងត្រូវ ដាក់

ឲ្យមាន ដើម្បីធានាឲ្យការអនុវត្ត និងការគ្រប់គ្រងឧស្សាហកម្មនិស្សារណកម្មបានត្រឹមត្រូវតាមខ្សែចង្វាក់តម្លៃ (value chain) លើកលែងតែសកម្មភាពអនុវត្តសម្រាប់ CNPA។

ដូចដែលបានចង្អុលបង្ហាញច្បាស់ពីខាងដើម ការផ្សព្វផ្សាយព័ត៌មាន គឺជាតម្រូវការខ្ពស់តាមវិធីដែលធ្វើឲ្យប្រជាពលរដ្ឋយល់ដឹងអំពីការអភិវឌ្ឍរបស់វិស័យដ៏មានសារៈសំខាន់មួយនេះ តាមរយៈកិច្ចខិតខំប្រឹងប្រែង និងវឌ្ឍនភាពជាប្រចាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលចូលរួមចំណែកសម្រេចបានតម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្ម។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) អាជ្ញាធរប្រេងកាតជាតិកម្ពុជា (CNPA) និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) បានបោះជំហានឆ្ពោះទៅបង្កើនការយល់ដឹងដល់សាធារណជន តាមរយៈការផ្សព្វផ្សាយព័ត៌មាននៅក្នុងគេហទំព័ររបស់ខ្លួន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្សព្វផ្សាយនូវចំណូលពីឧស្សាហកម្មនិស្សារណកម្មនៅក្នុងតារាង TOFE ហើយបានបង្ហោះនៅក្នុងគេហទំព័ររបស់ខ្លួន ប៉ុន្តែព័ត៌មាននៅតែស្ថិតក្នុងទម្រង់សរុបនៅឡើយ។ ផ្ទុយទៅវិញ គេហទំព័ររបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គនាយកដ្ឋានធនធានរ៉ែរបស់ខ្លួន គឺមិនអាចចូលមើលបាន ឬមិនដំណើរការរយៈពេលពីរបីខែកន្លងមកហើយ។ ចំពោះអាជ្ញាធរប្រេងកាតជាតិកម្ពុជា គេហទំព័ររបស់ខ្លួនត្រូវបានធ្វើឲ្យប្រសើរឡើងជាមួយនឹងព័ត៌មានដ៏មានសារៈប្រយោជន៍ស្តីពីការអភិវឌ្ឍវិស័យ ប្រេង និងឧស្ម័ន ដោយរួមទាំងផែនទីប្លុកប្រេង និងប្រវត្តិនៃការធ្វើសិក្សា seismic ព្រមជាមួយ នឹងការតភ្ជាប់ទំនាក់ទំនង ទៅនឹងគេហទំព័ររបស់ CRRT។ អ្វីដែលគួរឲ្យកត់សំគាល់បំផុតនោះគឺថា ក្រុមហ៊ុនដែលទទួលបាននូវកិច្ចព្រមព្រៀងបែងចែកផលិតផល (PSC) ត្រូវបាន ដាក់បង្ហាញឈ្មោះនៅក្នុងប្លុកប្រេងនិមួយៗក្នុងដែនសមុទ្រ និងដីគោក។ ដូច្នេះ CRRT សូមកោតសរសើរចំពោះអាជ្ញាធរប្រេងកាតជាតិកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះការផ្សព្វផ្សាយព័ត៌មានស្តីពីចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម និងក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀង។ ទន្ទឹមគ្នា នេះផងដែរ CRRT សូមអំពាវនាវដល់អាជ្ញាធរប្រេងកាតជាតិកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្តនូវកិច្ចការ នេះតទៅទៀត និងធ្វើឲ្យកាន់តែប្រសើរឡើងនូវមាតិកានៃខ្សែចង្វាក់តម្លៃនៃឧស្សាហកម្មនិស្សារណកម្ម (ជាពិសេសព័ត៌មាន ស្តីពីការបើកប្លុកប្រេង សម្រាប់ដេញថ្លៃ ការប្រកាសពីការដេញថ្លៃ ឈ្មោះក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ ឬកិច្ចព្រមព្រៀង ប្រភេទនៃកិច្ចសន្យា តំបន់រុករក និងទាញយក ប្រភេទធនធាន ឈ្មោះក្រុមហ៊ុនដែលបង់ភាគទាន ឈ្មោះភ្នាក់ងាររបស់រដ្ឋាភិបាលដែលទទួលយកការបង់ភាគទាន។ល។) នៅក្នុងគេហទំព័ររបស់ខ្លួន ខណៈដែល CRRT អំពាវនាវ ដោយទទូចសូមឲ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ធ្វើឲ្យគេហទំព័ររបស់ខ្លួនមានដំណើរការឡើងវិញ ហើយផ្សព្វផ្សាយ ព័ត៌មានដែលទាក់ទងទៅនឹងប្រតិបត្តិការ និងការរុករករ៉ែឲ្យបានពិស្តារ និងទៀងទាត់តាមដែលអាចធ្វើទៅបាន។

៤. អនុសាសន៍

ខណៈដែល CRRT ទទួលស្គាល់នូវវឌ្ឍនភាព និងបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលក្នុងឧស្សាហកម្មនិស្សារណកម្ម CRRT សូមអំពាវនាវដោយស្ថាបនាដល់សកម្មភាពរបស់រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីពិចារណាដោះស្រាយបញ្ហា និងកង្វះខាតខាងលើដោយ៖

- អនុញ្ញាតិឲ្យមានការចូលរួមពីសាធារណជន និងអង្គការសង្គមស៊ីវិល ក្នុងដំណើរការនៃការធ្វើសេចក្តីព្រាងច្បាប់ស្តីពីប្រេងកាត សេចក្តីព្រាងច្បាប់ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត សេចក្តីព្រាងច្បាប់ស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ រួមទាំងបទបញ្ញត្តិដែលទាក់ទងផ្សេងៗទៀត តាមរយៈការចែករំលែកនូវសេចក្តីព្រាងច្បាប់ទាំងនេះ និងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់សាធារណជនធ្វើការពិនិត្យ និងពិគ្រោះយោបល់។

- ចូលជាសមាជិករបស់ EITI និង/ឬ អនុវត្តគោលការណ៍របស់ EITI ដែលបានចែងនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- ពង្រឹងនូវភាពទៀងទាត់ និងភាពគ្រប់ជ្រុងជ្រោយនៃចំណូលបច្ចុប្បន្នរបស់វិស័យនេះ ដែលបានរាយការណ៍នៅក្នុងតារាង TOFE និងព័ត៌មានទាក់ទងផ្សេងៗទៀតស្របតាមចង្វាក់តម្លៃឧស្សាហកម្មនិស្សារណកម្ម (ការដេញថ្លៃ ការផ្តល់អាជ្ញាប័ណ្ណ កិច្ចព្រមព្រៀង ការគ្រប់គ្រងចំណូល និងការចំណាយលើទំនិញសាធារណៈ និងការកាត់បន្ថយភាពក្រីក្រ) នៅក្នុងទម្រង់ដែលសាធារណជនអាចប្រើប្រាស់បាន ឧទាហរណ៍ គេហទំព័ររបស់ក្រសួងនិមួយៗមានដំណើរការល្អ។

- ចូលរួមឲ្យកាន់តែសកម្ម និងទូលំទូលាយ នៅក្នុងការពិភាក្សា និងឆ្លើយតបទៅសាធារណជន និងអង្គការសង្គមស៊ីវិល តាមការអំពាវនាវ ឬតម្រូវការលើបញ្ហាទាក់ទងទៅនឹងការគ្រប់គ្រងចំណូលពីវិស័យឧស្សាហកម្មនិស្សារណកម្ម។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT)
លោក ណៃប ស៊ីនថៃ ប្រធានគណកម្មការប្រតិបត្តិ នៃសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT) និងជានាយក វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
ទូរស័ព្ទ៖ (៨៥៥) ២៣-២១៣-៤៨៦
អ៊ីមែល៖ sinthayneb@apiinstitute.org
លោក ឆាយ សាវ៉ាត នាយកប្រតិបត្តិ នៃសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT)
ទូរស័ព្ទ៖ (៨៥៥) ២៣-២១៧-៦០៧
អ៊ីមែល៖ crrtdirector@gmail.com
អាសយដ្ឋាន៖ #៨៨ ផ្លូវ៤៦៨ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា

កំណែទម្រង់លទ្ធិប្រជាធិបតេយ្យ ច្បាប់ និងប្រព័ន្ធយុត្តិធម៌

កំណែទម្រង់ការបោះឆ្នោត និងប្រជាធិបតេយ្យ

១. សេចក្តីផ្តើម

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល/ COMFREL) មានគោលបំណងបង្កើតបរិយាកាសមួយដែលសម្រួលដល់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងមានអត្ថន័យពិតប្រាកដក្រោយការបោះឆ្នោត។ ខុមហ្វ្រែល នៅតែបន្តស្វែងរកកិច្ចគាំទ្រដើម្បីកំណែទម្រង់ និងធ្វើឲ្យប្រសើរឡើងតាមរយៈកិច្ចពិភាក្សា លើបញ្ហាជាច្រើនដែលកើតមាននៅក្នុងប្រទេសកម្ពុជា ដែលនាំឲ្យប៉ះពាល់ដល់មុខងារនៃការបោះឆ្នោត ដោយ សេរី និងយុត្តិធម៌ ប្រជាធិបតេយ្យ អភិបាលកិច្ចប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋ។ អង្គការសង្គមស៊ីវិលកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងៗទៀត (គណបក្សនយោបាយ ក្រុមប្រឹក្សាឃុំសង្កាត់ សមាជិកនៃ រដ្ឋសភាជាតិ និងមន្ត្រីអាជ្ញាធរ បោះឆ្នោតមូលដ្ឋាន) ដែលជាអ្នកមានឥទ្ធិពលវិជ្ជមានដោយសារការស្វែងរកកិច្ច គាំទ្រយុទ្ធនាការជាច្រើន ការផ្តល់ប្រឹក្សាយោបល់ និងការប្រើប្រាស់វេទិកាជាច្រើន ដែលនាំឲ្យមានការចូលរួមជាអតិបរិមា ដើម្បីធ្វើការពិចារណា រកដំណោះស្រាយផ្សេងៗក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រជាធិបតេយ្យ និងការបោះឆ្នោតក្នុងប្រទេស កម្ពុជា។ លទ្ធផលដែល ទទួលបានគឺមានភាពវិជ្ជមាន ទាំងចំនួនអ្នកដែលបានចូលរួមពិភាក្សា និងគុណភាពនៃអនុសាសន៍ដែលបានផ្តល់។ ប្រជាធិបតេយ្យ អាចរឹងមាំបានដោយសារតែមានការអនុវត្ត និងឆន្ទៈគាំទ្រឲ្យមានការជូនដំណឹងច្រើនទៀតពីការធ្វើសេចក្តី សម្រេចចិត្តដោយបុគ្គលសាធារណៈ ជាអ្នកដែលត្រូវបានលើកទឹកចិត្តដើម្បីពិចារណាលើអ្វីដែលជាប្រជាធិបតេយ្យ តិចឬ ច្រើន ហើយដើម្បីពិចារណាលំដាប់នៃការកំណែទម្រង់ដែលធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធបោះឆ្នោតនៅកម្ពុជា។ ខុមហ្វ្រែល និងភាគីពាក់ព័ន្ធ នៅតែបន្តជម្រុញឲ្យរាជរដ្ឋាភិបាលពិនិត្យឡើងវិញនូវកំណែទម្រង់សំខាន់ៗក្នុងប្រព័ន្ធបោះឆ្នោត និងការពារបរិយាកាសប្រជាធិបតេយ្យ និងសិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជា។

២. សូចនាករតាមដានរួម

មិនមានសូចនាករតាមដានរួមស្តីពីការបោះឆ្នោត។

៣. សកម្មភាពសំខាន់ៗ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម

កថាខណ្ឌ	សារ
៣១៨	រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្ត ដើម្បីសម្រេចឲ្យបាននូវបណ្តាគោលដៅអាទិភាពរបស់ខ្លួននៅក្នុងនីតិកាលទី៤ នៃរដ្ឋសភា ដោយធានានូវៈ ចីរភាព សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដើម្បីលើកកម្ពស់វិធានការច្បាប់ ការពារសិទ្ធមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

វឌ្ឍនភាពដែលត្រូវបានតាមដានលើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម

ខុមហ្វ្រែល រកឃើញថា ការសរុបលទ្ធផលនៃការបោះឆ្នោតមុនៗ គឺត្រូវបានអធិប្បាយនៅក្នុងផ្នែក២ នៃជំពូក ២ ក្នុងផែនការណ៍យុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ទោះបីជាយ៉ាងនេះក្តី ការផ្សព្វផ្សាយគោលនយោបាយជាក់លាក់ជាច្រើនសម្រាប់កំណែទម្រង់ការបោះឆ្នោត និងប្រជាធិបតេយ្យ គឺមិនត្រូវបានពិភាក្សាឲ្យបានល្អិតល្អន់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ទេ។ លក្ខណៈបែបនេះបង្កើតឲ្យមានការលំបាកសម្រាប់អង្គការសង្គមស៊ីវិលដូចជា ខុមហ្វ្រែល ដើម្បីឆ្លើយតបតាមរយៈកិច្ចសង្កេតការណ៍របស់ខ្លួននៅលើតំណរភ្ជាប់រវាងគោលនយោបាយដែលបាន

ផ្សព្វផ្សាយ ឬការប្តេជ្ញាចិត្តលើដំណើរការបោះឆ្នោត និងការប្រតិបត្តិរបស់ខ្លួន ក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ២០១០ និងឆ្នាំ ២០១១។ របាយការណ៍អង្កេតការណ៍របស់ ខុមហ្វ្រែល បានផ្តែកទាំងស្រុងទៅលើការអង្កេតការណ៍របស់ខ្លួនលើដំណើរការ បោះឆ្នោត និងការអនុវត្តប្រជាធិបតេយ្យ ពហុបក្សនៅកម្ពុជា។

៤. បញ្ហាសំខាន់ដែលមិនមានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឬសូចនាករតាមដានរួម

ខុមហ្វ្រែល កំពុងប្រើប្រាស់សេចក្តីថ្លែងការណ៍នេះដើម្បីធ្វើការវាយតម្លៃលើបញ្ហាដំណើរការបោះឆ្នោត និងលម្ហ ប្រជាធិបតេយ្យ ដោយផ្តែកលើកិច្ចសង្កេតការណ៍ ទស្សនវិស័យ នៃអង្គការសង្គមស៊ីវិលឯករាជ្យ និងមិនប្រកាន់ បក្សពួកនៅ ក្នុងប្រទេសកម្ពុជា។ វាជាសេចក្តីសង្ខេបនៃរបាយការណ៍មុនៗ និងបច្ចុប្បន្ន ស្តីពី ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែ ទម្រង់នៅកម្ពុជា ដែលបានដឹកនាំដោយ ខុមហ្វ្រែល ក្នុងឆ្នាំ២០១០ និង២០១១។

សេចក្តីសង្ខេបស្តីពីបញ្ហាជាច្រើនដែលបានសង្កេតឃើញនៅក្នុងការអនុវត្តការបោះឆ្នោត និងលម្ហប្រជាធិបតេយ្យ

កាលពីមុនៗ ភាគីពាក់ព័ន្ធនឹងការបោះឆ្នោត បានលើកឡើងនូវក្តីកង្វល់ទាក់ទងនឹងភាពមិនប្រក្រតី និងបច្ចេកទេស ដែលមានលក្ខណៈលំបាកក្នុងការចុះឈ្មោះអ្នកបោះឆ្នោត។ មានការអះអាងថា ការចុះឈ្មោះបោះឆ្នោតបែបនោះ មិនបាន ធានាសិទ្ធិបោះឆ្នោតរបស់ពលរដ្ឋរាល់រូប ហើយអាចនឹងលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជា [6] ។ ប្រព័ន្ធចុះឈ្មោះអ្នក បោះឆ្នោតប្រចាំឆ្នាំ ត្រូវបានគេរកឃើញដោយភាគីពាក់ព័ន្ធជាច្រើនរាប់បញ្ចូលទាំង គណៈកម្មាធិការជាតិរៀបចំការបោះ ឆ្នោត (គ.ជ.ប) ផងដែរថា ជាឧបសគ្គមួយដែលធ្វើឲ្យមានបញ្ហាទាំងអស់នោះកើតមានឡើង[7]។ ដូច្នេះអនុសាសន៍មួយចំនួន លើកឡើងពីប្រតិបត្តិការចុះឈ្មោះអ្នកបោះឆ្នោត គួរតែធ្វើឲ្យងាយស្រួលជាងនេះ ដោយដាក់កាតព្វកិច្ចក្នុងការប្រើប្រាស់នូវ អត្តសញ្ញាណប័ណ្ណជាតិ។ នៅក្នុងឆ្នាំ២០១១ មានអ្នកបោះឆ្នោតចំនួន៩២% បានប្រើអត្តសញ្ញាណប័ណ្ណរបស់ពួកគេ ដើម្បី ចុះឈ្មោះបោះឆ្នោត។ ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែមានអត្តសញ្ញាណប័ណ្ណទេ។ ជាងនេះទៅទៀត រហូតមកដល់ ខែមិថុនា ឆ្នាំ២០១១ ក៏មិនទាន់ច្បាស់នៅឡើយថា តើមានអត្តសញ្ញាណប័ណ្ណចំនួនប៉ុន្មានដែលនឹងត្រូវផុតសុពលភាព មុនពេលការ បោះឆ្នោតមកដល់ ហើយអាចប្រើប្រាស់សម្រាប់ការបោះឆ្នោតលើកក្រោយ។ បញ្ហានេះបានលេចឡើង នូវការសង្ស័យជា ច្រើនដែលថា ជាចេតនា ឬអចេតនាលើទម្រង់ចុះឈ្មោះបោះឆ្នោតក្លែងក្លាយនៅតែអាចកើតមាន។ ជំទាស់ ទៅនឹងសាវតា នេះ ខុមហ្វ្រែលបានយកចិត្តទុកដាក់ផងដែរលើប្រតិបត្តិការណ៍ចុះឈ្មោះប្រចាំឆ្នាំ២០១១នេះ។ ខុមហ្វ្រែល បានដាក់ ពង្រាយអ្នកអង្កេតការណ៍ចំនួន ៤៧នាក់ ដើម្បីអង្កេតលើការចុះឈ្មោះបោះឆ្នោត និងអ្នកសង្កេតចំនួន ២៣១ នាក់ ដើម្បី សម្ភាសន៍អ្នកបោះឆ្នោត និងធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោត។

នៅក្នុងឆ្នាំ២០១១ ខុមហ្វ្រែល បានរកឃើញថា ភាពវិជ្ជមាន គឺមានកិច្ចខិតខំប្រឹងប្រែងជាច្រើនដែលទទួលយក ដោយ រាជរដ្ឋាភិបាលកម្ពុជា និងគ.ជ.ប ដើម្បីធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធចុះឈ្មោះបោះឆ្នោត។ ជាដំបូង រាជរដ្ឋាភិបាលកម្ពុ ជាបានធ្វើការដោះស្រាយបញ្ហាទៅលើអត្តសញ្ញាណប័ណ្ណដែលផុតសុពលភាព ក្នុងឆ្នាំ២០១១ ដោយការអនុម័ត អនុក្រឹត្យ មួយ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ដោយបន្តសុពលភាពនៃអត្តសញ្ញាណប័ណ្ណប្រហែលជាង ៤លាន ឲ្យអាចប្រើ

---

[6] ក្រោយការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្នុងឆ្នាំ២០០៨ ខុមហ្វ្រែល បានប៉ាន់ប្រមាណថា ប្រហែល ៤៤0,000 អ្នកបោះឆ្នោតអាចមិនបាន អនុវត្តសិទ្ធិបោះឆ្នោតរបស់ពួកគេ ពីព្រោះពួកគេមិនអាចរកឈ្មោះរបស់ពួកគេនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬមិនអាចរកការិយាល័យបោះឆ្នោតរបស់ពួក គេ តាមការប៉ាន់ប្រមាណ ចំនួនអ្នកបោះឆ្នោតអាចតិចជាង ពីព្រោះតែការចុះឈ្មោះពីរដង។ សវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្សេងទៀត ដែលបានធ្វើមុន ពេលបោះឆ្នោតឆ្នាំ២០០៨ ដោយ អង្គការនិកហ្ស៊ិច ខុមហ្វ្រែល មជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់ និងអង្គការ អិនឌីអាយ បានបង្ហាញថា អ្នកបោះឆ្នោតច្រើនជាង ៥៧,000 នាក់ (0.៧%) ត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយមិនត្រឹមត្រូវ។ ដូចគ្នាផងដែរ ក្រុមបេសកម្មអង្កេតការណ៍បោះឆ្នោតសហគមន៍ អឺរ៉ុប (EUEOM) បានសន្និដ្ឋានសម្រាប់ការបោះឆ្នោតក្នុងឆ្នាំ២០០៨ថា "... មានអ្នកបោះឆ្នោតជាច្រើនដែលត្រូវបានបំបាត់សិទ្ធិបោះឆ្នោតដោយការយល់ ច្រឡំ..."។ ការលំបាកក្នុងការចុះឈ្មោះបោះឆ្នោតបានលើកឡើង ដោយមន្ទិលសង្ស័យជាច្រើនក្នុងចំណោមគណបក្សនយោបាយថា ការចុះឈ្មោះបោះ ឆ្នោតមានភាពលម្អៀងជាប្រព័ន្ធទៅរកគណបក្សប្រជាជនកម្ពុជា តាមរយៈការចោទប្រកាន់ជាច្រើនដែលនៅតែមិនទាន់បានបញ្ចាក់។

[7] អង្គការ អិនឌីអាយ (NDI)៖ កំណែទម្រង់ការបោះឆ្នោតនៅកម្ពុជា - របាយការណ៍កម្មវិធីប្រឹក្សាយោបល់ ខែសីហា ឆ្នាំ២០០៩ ទំព័រ ៨-២៩

ប្រាស់រហូតដល់ចុងឆ្នាំ២០១៣។ អនុក្រឹត្យនេះអនុញ្ញាតឲ្យអ្នកបោះឆ្នោតស្របច្បាប់ ប្រើប្រាស់អត្តសញ្ញា ណប័ណ្ណទាំងនោះ សម្រាប់ការបោះឆ្នោតដែលនឹងមកដល់នៅពេលខាងមុខបាន។ លើសពីនេះទៀត មានវិសោធនកម្ម ច្បាប់បោះឆ្នោត និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា និងគ.ជ.ប បានធ្វើឲ្យប្រសើរនូវការចុះឈ្មោះអ្នកបោះឆ្នោត ប្រចាំឆ្នាំ។ នេះរាប់បញ្ចូលថា គ.ជ.ប និងក្រសួងមហាផ្ទៃ បានសម្រេចដើម្បីជំនួសលិខិតបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោតដ៏ចម្រូងចម្រាស់ "*ទម្រង់ ១០១៨*" ដោយទម្រង់ថ្មីមួយ ដែលមានឈ្មោះថា "លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត"។ លិខិតបញ្ជាក់អត្តសញ្ញាណក្រោយនេះ នឹងលំបាកដើម្បីសម្រួលជាងទម្រង់ចាស់ដូចជា តំរូវឲ្យយករូបថតពីរ(២)សន្លឹកជាចាំបាច់ទៅជាមួយក្នុងការស្នើសុំលិខិតនេះ។ យោងតាម គ.ជ.ប លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតចំនួន ៤២៦,១១៦ សន្លឹក ត្រូវបានចេញឲ្យប្រើប្រាស់សម្រាប់អ្នកបោះឆ្នោតក្នុងឆ្នាំ២០១១។ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងគ.ជ.ប នៅពេលនេះអាចត្រូវបានត្រួតពិនិត្យចំពោះនីតិវិធីនៃការចេញទម្រង់នេះដោយអ្នកសង្កេតការណ៍បោះឆ្នោតខុមហ្វ្រែលផងដែរ។ ករណីនេះមិនដូចជាករណីដែលបានកើតឡើងកាលពីឆ្នាំ២០០៨ នោះទេ នៅពេលដែល គ.ជ.ប និងក្រុមប្រឹក្សាឃុំ-សង្កាត់ មិនបានផ្តល់នូវចំនួនតួលេខសរុបនៃទម្រង់ ១០១៨ ដែលបានចេញ ខណៈដែលខុមហ្វ្រែល បានរកឃើញមានការចេញឲ្យប្រើប្រាស់ប្រហែលជា ៤៤០,០០០ នៃទម្រង់ទាំងអស់។[8] ជាលទ្ធផលវិជ្ជមានមួយទៀតដែរ អនុសាសន៍របស់ខុមហ្វ្រែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃការបោះឆ្នោតដែលទើបបានបង្កើតថ្មី ឬកំណត់ព្រំដែននៃឃុំ-សង្កាត់ ត្រូវបានទទួលយកដោយ គ.ជ.ប។ គ.ជ.ប បានយល់ស្របថា ក្រុមប្រឹក្សាឃុំ-សង្កាត់ចាស់ នៅតែទទួលខុសត្រូវសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតបឋមដោយគិតថាអ្នកដែលបានស្នើទៅរស់នៅក្នុងឃុំ-សង្កាត់ថ្មី មិនត្រូវចុះឈ្មោះសម្រាប់ការបោះឆ្នោតម្តងទៀត។[9]

បន្ថែមពីនេះទៀត វិសោធនកម្មច្បាប់បោះឆ្នោត ត្រូវបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១១ ដើម្បីធានាថា អ្នកបោះឆ្នោតថ្មីដែលទើបតែមានសិទ្ធិបោះឆ្នោត មានពេលច្រើនថែមទៀតដើម្បីចុះឈ្មោះសម្រាប់ការបោះឆ្នោតដែលនឹងមកដល់ក្នុងឆ្នាំ២០១២ និង២០១៣។ អំឡុងពេលនៃការចុះឈ្មោះអ្នកបោះឆ្នោតទាំងស្រុង រាប់បញ្ចូលទាំងបច្ចុប្បន្នកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត មានការបន្ថែមពី ៩០ថ្ងៃ ទៅដល់ ១២០ថ្ងៃ ជាថេរវេលានៃការចុះឈ្មោះផ្លូវការដែលបានបន្ថែមពី ២០ថ្ងៃ ទៅ ៤៥ថ្ងៃ និងអំឡុងនៃបណ្តឹងបានបន្ថែមពី ៥ថ្ងៃ ទៅ ១០ថ្ងៃ។ ដូចគ្នាដែរ ចំនួននៃអ្នកមានសិទ្ធិបោះឆ្នោត បានកើតឡើងត្រឹម ៦៦០,២១០ នាក់ ចន្លោះឆ្នាំ២០០៨ ដល់ឆ្នាំ២០១១។ ក្នុងឆ្នាំ២០០៨ អ្នកមានសិទ្ធិបោះឆ្នោតចំនួន ៨,៥៤៣,២៨៣ នាក់ ត្រូវចុះឈ្មោះបោះឆ្នោត ឯអ្នកចុះឈ្មោះក្នុងឆ្នាំ២០១១ មានចំនួន ៩,២០៣,៤៩៣ ដែលនៅក្នុង នោះមានស្ត្រីចំនួន ៤,៨៦១,៨៥៣ និង ៣.៤លាននាក់ គឺជាយុវជនដែលមានអាយុចន្លោះពី ១៨ឆ្នាំ ទៅ ៣០ឆ្នាំ[10]។ តួលេខនេះ បានបង្ហាញជាទូទៅថា ការចុះឈ្មោះអ្នកបោះឆ្នោតបានប្រតិបត្តិដោយទទួល ជោគជ័យនៅពេលនេះ។ ទោះបីជាយ៉ាងណា មានការព្រួយបារម្ភមួយចំនួនទៀតដែលទាក់ទងទៅនឹងចំនួនតួលេខពិត ប្រាកដនៃអ្នកមានសិទ្ធិបោះឆ្នោត និងគុណភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោតនាពេលបច្ចុប្បន្នសម្រាប់ការបោះឆ្នោតពេលក្រោយ។ តួលេខរបស់ គ.ជ.ប បានអះអាងថា បានចុះឈ្មោះអ្នកបោះឆ្នោត ១០៤% នៃអ្នកបោះឆ្នោត ខណៈដែលខុមហ្វ្រែល បានរកឃើញថា មានត្រឹមតែ ៩៤% នៃអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ ដែលបានចុះបញ្ជីពិតប្រាកដ។ សវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់ ខុមហ្វ្រែល ក្នុងឆ្នាំ២០១១ បានរកឃើញថា ១៧.២% នៃអ្នកបោះឆ្នោតដែលបានចុះបញ្ជី មិនមានទិន្នន័យកត់ត្រានៅក្នុងបញ្ជីអ្នកបោះឆ្នោតឆ្នាំ២០១១ (ឈ្មោះរបស់ពួកគេមិនអាចរកឃើញ ឬមានការ ផ្លាស់ប្តូរឈ្មោះ) តួលេខនេះគឺមានកម្រិតទាបជាង ១៨.៥% ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឆ្នាំ២០០៨។ ទោះបីជាយ៉ាងណា អ្នកចុះឈ្មោះខ្លះ ក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោតប្រមាណ ១,៥ លាននាក់ អាចទំនងជានឹងបាត់បង់សិទ្ធិដើម្បីបោះឆ្នោតនៅពេលបោះឆ្នោតខាងមុខ។

នៅក្នុងឆ្នាំ២០១១ គណបក្សផ្សេងទៀត ក្រៅពីគណបក្សប្រជាជនកម្ពុជា នៅតែបន្តទាមទាឲ្យមានកំណែទម្រង់ គ.ជ.ប។ គ.ជ.បថ្នាក់ជាតិ គ.ជ.បថ្នាក់ខេត្ត និងគ.ជ.បថ្នាក់ឃុំ-សង្កាត់ ត្រូវបានគេដឹងថា ខ្វះខាតឯករាជភាព និងមានភាពមិន

[8] ខុមហ្វ្រែល ៖ ការបោះឆ្នោតជ្រើសតាំងសមាជិកសភាឆ្នាំ២០០៨ - របាយការណ៍ និងការវាយតម្លៃចុងក្រោយ (ភ្នំពេញ ឆ្នាំ២០០៨ ទំព័រ ១៧)

[9] របាយការណ៍ឃ្លាំមើលការបោះឆ្នោត (លទ្ធផលបឋមឆ្នាំ២០១១)

[10] គ.ជ.ប ៖ បញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការត្រូវបានបញ្ចាក់សុពលភាព ភ្នំពេញថ្ងៃទី៣ ខែមករា ឆ្នាំ២០១១; www.necelect.org.kh

លំអៀង ពីព្រោះគណបក្សប្រជាជនកម្ពុជា ជាអ្នកត្រួតត្រារដ្ឋបាលសាធារណៈ។ កាលពីមុន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមាសភាពសមាជិកនៃគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភានៃនីតិកាលចុងក្រោយ ប៉ុន្តែរូបមន្តនេះត្រូវបានផ្លាស់ប្តូរមុនពេលបោះឆ្នោតសភាឆ្នាំ២០០៣។ ដើម្បីកុំឲ្យមាន ភាពលំអៀងកើតឡើងចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រោយពេលទំនាស់រវាងតំណាងរាស្ត្រគណបក្ស នយោបាយជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចជាករណីដែលធ្លាប់កើតមានឡើងក្នុងពេលកំពុង បោះឆ្នោតតំណាងរាស្ត្រកាលពីឆ្នាំ ១៩៩៨។ ដោយយោងតាមការធ្វើវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០០៨ គ.ជ.ប គួរតែជាស្ថាប័ន ឯករាជ្យ និងអព្យាក្រឹត ហើយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់កម្រិត គួរតែអព្យាក្រឹត និងមិនលម្អៀង ក្នុងការអនុវត្តតួនាទីរបស់ខ្លួន។ ប៉ុន្តែមានប្បញ្ញត្តិមួយនៃច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ លើកឡើងថា មន្ត្រីបោះឆ្នោត ត្រូវតែសុំលាលែងជាបណ្តោះអាសន្នពី មុខងារនៅក្នុងគណបក្សនយោបាយ រហូតដល់ផុតអាណត្តិ ហើយមន្ត្រីបោះឆ្នោតត្រូវតែជ្រើសរើសដោយក្រសួងមហាផ្ទៃ គណៈរដ្ឋមន្ត្រី និងរដ្ឋសភា។ តាំងពីស្ថាប័នទាំងនោះត្រូវបានគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា បន្ទាប់ពីការបោះឆ្នោតរដ្ឋសភាឆ្នាំ២០០៨ ប្បញ្ញត្តិទាំងនោះមិនបានកាត់បន្ថយនូវមន្ទិលសង្ស័យក្នុងចំណោមគណបក្សនយោបាយដទៃ ក្រៅតែពីគណបក្សប្រជាជនកម្ពុជាថា មន្ត្រីរៀបចំការបោះឆ្នោតមិនមានអព្យាក្រឹត និងឯករាជ្យពិតប្រាកដឡើយ។

ទោះបីជាប្រព័ន្ធសមាមាត្រកម្រិតជាតិ ត្រូវបានធ្វើឡើងដោយប្បញ្ញត្តិនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បច្ចុប្បន្នគឺមានសមាសភាពសមាជិកគណបក្សប្រជាជនកម្ពុជាចំនួន ៥រូប គណបក្សហ៊្វុនស៊ិនប៉ិចចំនួន ២រូប និងគណបក្សសមរង្ស៊ីចំនួន ២រូប តែនៅកម្រិតខេត្ត ស្រុក ខណ្ឌ សង្កាត់ ប្រព័ន្ធសមាមាត្រនេះមិនទាន់យកទៅអនុវត្តនៅឡើយទេ។ ឯគណបក្សផ្សេងទៀត ក្រៅពីគណបក្សប្រជាជនកម្ពុជា បានផ្តល់អនុសាសន៍ក្នុងឆ្នាំ២០១១ ដើម្បីធ្វើការណែនាំនូវប្រព័ន្ធសមាមាត្រគ្រប់កម្រិតទាំងអស់នៃរដ្ឋបាលបោះឆ្នោត។ ការផ្តល់អនុសាសន៍នេះត្រូវបានសម្របសម្រួលដោយ ខុមហ្វ្រែល។ ក្នុងទស្សនៈរបស់គណបក្សដទៃក្រៅពីគណបក្សប្រជាជនកម្ពុជា កំណែទម្រង់នេះនឹងបង្កើនតម្លាភាព និងភាពគួរឲ្យជឿជាក់បាននៃរដ្ឋបាលបោះឆ្នោតសម្រាប់ការបោះឆ្នោតបន្តបន្ទាប់ដែលនឹងមកដល់។ ខុមហ្វ្រែល និងភាគីពាក់ព័ន្ធជាច្រើនបានរុញច្រានដើម្បីពិភាក្សាពីកំណែទម្រង់នេះ តែមកទល់នឹងពេលនេះ សំណើកំណែទម្រង់នេះមិនបានទទួលយកដើម្បីសម្រេចចិត្តនៅឡើយទេ។ ខុមហ្វ្រែល ជឿជាក់ថា ទោះបីជាកំណែទម្រង់នេះលើកយកនូវមន្ទិលសង្ស័យជាច្រើនអំពីឥទ្ធិពលនៃគណបក្សនយោបាយដទៃនៅក្នុងគណៈកម្មការបោះឆ្នោត ពេលដែលច្បាប់បោះឆ្នោតបច្ចុប្បន្ន ណែនាំថា គ.ជ.ប សម្រេចចិត្តត្រឹមតែមតិភាគច្រើនធម្មតាមួយ ហើយផ្តួចផ្តើមតម្រូវការយ៉ាងតិច សមាជិកគ.ជ.ប ៣រូប មានន័យថា គណបក្សនយោបាយដទៃទៀតក្រៅពី គណបក្សប្រជាជនកម្ពុជា នៅតែខ្វះមតិភាគច្រើននៅក្នុងគណៈកម្មាធិការនេះ។ កំណែទម្រង់នេះច្បាស់លាស់ណាស់នឹងបង្កើនតម្លាភាពនៃដំណើរការបោះឆ្នោត ហើយអនុញ្ញាតឲ្យគណបក្សដទៃក្រៅពីគណបក្សប្រជាជនកម្ពុជា ដើម្បីផ្តួចផ្តើមសំណើកំណែទម្រង់ក្នុងគណៈកម្មការរៀបចំ ការបោះឆ្នោតនៅគ្រប់កម្រិតទាំងអស់។

ពាក់ព័ន្ធនឹងចំនួនអាសនៈរដ្ឋសភាបច្ចុប្បន្ន ខុមហ្វ្រែល និងភាគីពាក់ព័ន្ធជាច្រើន រាប់បញ្ចូល ក្រុមបេសកកម្មអង្កេតការណ៍បោះឆ្នោតសហគមន៍អឺរ៉ុប (EUEOM) នៅកម្ពុជាឆ្នាំ២០០៨ បានផ្តល់អនុសាសន៍ដើម្បីបង្កើនចំនួនអាសនៈ សម្រាប់ការបោះឆ្នោតបន្ទាប់។ បើតាម ខុមហ្វ្រែល និង EUEOM ចំនួនអ្នកមានសិទ្ធិបោះឆ្នោត នៅមណ្ឌល ៤ ចំណោមមណ្ឌលទាំង ២៤ មានមណ្ឌលខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តកណ្តាល មានការកើនឡើងគួរ ឲ្យកត់សម្គាល់ ដែលតម្រូវឲ្យអាសនៈនៅមណ្ឌលទាំងនោះត្រូវបន្ថែមអាសនៈ ឲ្យស្របតាមគោលការណ៍អន្តរជាតិ ស្តីពី *"ការបោះឆ្នោតដោយសមភាព និងសកល"* ដែលបានថ្លែងនៅក្នុងមាត្រា ២១នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ EUEOM បានសន្និដ្ឋាននៅក្នុងរបាយការណ៍បោះឆ្នោតឆ្នាំ២០០៨ របស់ខ្លួនថា "បើតាមស្ថិតិដែលបានផ្តល់ដោយ វិទ្យាស្ថានជាតិស្ថិតិ ចំនួននៃពលរដ្ឋនៅក្នុងខេត្តនិមួយៗ តម្រូវឲ្យមានការកែប្រែខ្លះៗ ដោយសារការប្រែប្រួលដ៏សំខាន់ក្នុងចំណោមមណ្ឌលជាច្រើនក្នុងទំហំនៃពលរដ្ឋក្នុងមួយអាសនៈ។ ក្នុងករណីខ្លះ ការប្រែប្រួលមិនបានអនុលោមតាមគោលការណ៍នៃការបោះឆ្នោតដោយសមភាព និងសកល ដែលបានចែងក្នុងមាត្រា ២១នៃ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សទេ។ ទោះបីជាយ៉ាងណា

ក្នុងខែវិច្ឆិកា គណៈរដ្ឋមន្ត្រី បានសម្រេចរក្សាចំនួនអាសនៈបច្ចុប្បន្ន។ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញពីកម្រិតហិរញ្ញវត្ថុ ដែលបណ្តាលមកពី វិបត្តិហិរញ្ញវត្ថុពិភពលោក និងទឹកជំនន់ ក្នុងឆ្នាំ២០១១។ ទោះបីជាយ៉ាងណា ខុមហ្វ្រែល បានប៉ាន់ប្រមាណថា តម្លៃសម្រាប់ ១២៧ អាសនៈ នឹងបង្កើនត្រឹម ០.១២% នៃការចំណាយចរន្តសរុបនៃថវិកាជាតិឆ្នាំ២០១១ ដើម្បីបន្ថែមអាសនៈ។

បញ្ហាដ៏ធំផ្សេងទៀតនៃប្រព័ន្ធច្បាប់បោះឆ្នោតនាពេលបច្ចុប្បន្នដែលអាចដឹងបាន ក្នុងចំណោមភាគីពាក់ព័ន្ធក្នុងស្រុក និងអន្តរជាតិ គឺក្របខណ្ឌច្បាប់បោះឆ្នោតបច្ចុប្បន្ន។ ច្បាប់ ត្រូវបានយល់ឃើញថា មានភាពស្មុគស្មាញពេក ខ្វះខាតនីតិវិធីបណ្តឹងច្បាស់លាស់ និងយន្តការអនុវត្តឲ្យបានសមរម្យ។ ទោះបីជាយ៉ាងណា មិនទាន់មានកំណែទម្រង់ ណាមួយ ដែលបានផ្តួចផ្តើម ឬប្រកាសជូនដំណឹងដោយ គ.ជ.ប ដើម្បីធ្វើឲ្យមានក្របខណ្ឌច្បាប់បោះឆ្នោតដ៏ងាយស្រួល។ នាពេលថ្មីៗនេះ មានបណ្តឹង ៨ ផ្សេងៗគ្នាដែលដាក់ទៅ គ.ជ.ប។ លើសពីនេះទៀត ស្ថាប័នផ្សេងៗជាច្រើន បានចែករំលែកនូវ ការទទួលខុសត្រូវក្នុងការអនុវត្តច្បាប់បោះឆ្នោត រាប់បញ្ចូល គ.ជ.ប ក្រុមប្រឹក្សាធម្មនុញ្ញ និងតុលាការ។ ខុមហ្វ្រែល បានផ្តល់អនុសាសន៍នៅក្នុងរបាយការណ៍បោះឆ្នោតឆ្នាំ២០០៨ ពីការកំណែទម្រង់មួយចំនួនទាក់ទងនឹងក្របខណ្ឌច្បាប់ ដើម្បីបង្កើនភាពជឿទុកចិត្តនៅក្នុងកិច្ចការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ដូចគ្នានេះដែរ EUEOM Cambodia បានថ្លែងនៅក្នុងរបាយការណ៍ការបោះឆ្នោតរបស់ខ្លួនថា "ជាទូទៅ ក្របខណ្ឌច្បាប់ នៅតែជាសម្រង់អត្ថបទ ហើយមានកម្រិតខុសគ្នាតាមបទដ្ឋានជាច្រើនប្រភេទ និងធម្មជាតិ (រាប់បញ្ចូល បទប្បញ្ញត្តិ សារាចរណែនាំ សេចក្តីណែនាំ សៀវភៅណែនាំ សេចក្តីសម្រេច និងការអប់រំដែលបង្កើតឡើងដោយ គណៈកម្មាការជាតិរៀបចំការ បោះឆ្នោត និងក្រសួងពាក់ព័ន្ធជាច្រើន) ដោយពេលខ្លះបានធ្វើឲ្យមានការភ័ន្តច្រឡំលើច្បាប់ដែលគួរផ្សព្វផ្សាយ។ ច្បាប់មិនបានដាក់បទដ្ឋានឲ្យច្បាស់លាស់តាមហានានុក្រមរបស់វាទេ។ ភាពខ្វះខាតនៃការចូលរួមបង្កើតក្របខណ្ឌច្បាប់ ជាការ លំបាកមួយសម្រាប់ភាគីពាក់ព័ន្ធ ដើម្បីទទួលបានវិធានទាំងឡាយ និងត្រូវធ្វើឲ្យពួកគេយល់ឲ្យបានច្បាស់អំពីវិធាន ទាំងនោះ។

៥. អនុសាសន៍

១). បញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត

១.១. ជំរើសទី១ សំដៅលើការផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត

ការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត គួរតែផ្លាស់ប្តូរទាំងស្រុងដើម្បីឲ្យការ ចុះឈ្មោះបោះឆ្នោតមានភាពងាយស្រួល និងសាមញ្ញ ហើយនឹងធានាគុណភាពនៃបញ្ជីឈ្មោះបោះឆ្នោត។ ប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មី គឺធ្វើឡើងដើម្បីឲ្យពេលវេលានៃការចុះឈ្មោះបោះឆ្នោតមានលក្ខណៈអចិន្ត្រៃយ៍។ សម្រាប់អ្នកមានអាយុ ១៨ ឆ្នាំ ឬអ្នកដែលផ្លាស់ប្តូរទីលំនៅ អាចចុះឈ្មោះបោះឆ្នោតនៅក្នុងម៉ោងធ្វើការបាន។ រាជរដ្ឋាភិបាលគួរតែធ្វើវិសោធនកម្មលើនីតិវិធីក្នុងការធ្វើអត្តសញ្ញាណប័ណ្ណ សម្រាប់ប្រើបានអស់មួយជីវិត។ ប្រជាពលរដ្ឋត្រូវបានជម្រុញ ឲ្យប្តូររូបថតរបស់ពួកគាត់ បន្ទាប់ពីប្រើប្រាស់អត្តសញ្ញាណប័ណ្ណ ២០ឆ្នាំរួចមក។ ក្រសួងមហាផ្ទៃសហប្រតិបត្តិការជាមួយនឹងអ្នកជំនាញ និងម្ចាស់ជំនួយ កំពុងប្រឹងប្រែងក្នុងការផលិតកម្មវិធី ដើម្បីបង្កើតប្រព័ន្ធទិន្នន័យអត្តសញ្ញាណជីវសញ្ញាមួយ ខណៈពេល ដែលប្រជាពលរដ្ឋម្នាក់ៗ មានលេខអត្តសញ្ញាណប័ណ្ណអចិន្ត្រៃយ៍មួយផ្ទាល់ខ្លួន។

បញ្ជីឈ្មោះបោះឆ្នោតគួរតែត្រូវបានរួមបញ្ចូលជាមួយនឹងប្រព័ន្ធទិន្នន័យអត្តសញ្ញាណជីវសញ្ញា ហើយនឹងលេខ អចិន្ត្រៃយ៍អត្តសញ្ញាណប័ណ្ណរបស់ប្រជាពលរដ្ឋម្នាក់ៗ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរប្រើ ប្រព័ន្ធទិន្នន័យរបស់អត្តសញ្ញាណប័ណ្ណដើម្បីបង្កើតបញ្ជីឈ្មោះបោះឆ្នោត។

១.២. ជំរើសទី២ សំដៅលើការធ្វើឲ្យប្រព័ន្ធបច្ចុប្បន្នកាន់តែប្រសើរឡើង

ប្រព័ន្ធចុះឈ្មោះបច្ចុប្បន្ន គឺរក្សាទុកដដែល ក៏ប៉ុន្តែគ្រាន់តែធ្វើឲ្យប្រសើរឡើងនូវបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត ការចែកចាយប័ណ្ណព័ត៌មានរបស់អ្នកបោះឆ្នោត (VIN) ការធ្វើ/ចេញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់អត្តសញ្ញាណ សម្រាប់បំរើឲ្យការបោះឆ្នោត។

ក. បច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត

ដើម្បីធ្វើឲ្យគុណភាពបញ្ជីឈ្មោះបោះឆ្នោតកាន់តែប្រសើរឡើង ការធ្វើបច្ចុប្បន្នភាពបញ្ជីចុះឈ្មោះបោះឆ្នោត គួរត្រូវបានធ្វើឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយសហប្រតិបត្តិការ ជាមួយក្រុមប្រឹក្សាឃុំ។ មុនពេលធ្វើបច្ចុប្បន្នភាព ឬលុបឈ្មោះអ្នកបោះឆ្នោតដែលគាត់បានផ្លាស់ប្តូរទី លំនៅទៅកាន់ឃុំដទៃ ឬស្លាប់ ចេញពីបញ្ជីឈ្មោះ បោះឆ្នោត ក្រុមប្រឹក្សាឃុំត្រូវមានឯកសារបញ្ជាក់។ ផ្ទុយទៅវិញ អាស្រ័យដោយការបោះឆ្នោតធ្វើឡើងរៀងរាល់ ៥ឆ្នាំម្តង ក្នុងកំឡុងពេលនៃឆ្នាំបោះឆ្នោត គណៈកម្មការជាតិរៀបចំការបោះឆ្នោតដោយធ្វើការសហប្រតិបត្តិការជាមួយប្រធានឃុំ និងសមាជិកក្រុម ប្រឹក្សាឃុំ សង្កាត់ (សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ២នាក់ មកពី គណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ និងអាជ្ញាធរដែនដី ត្រូវតែទទួលខុសត្រូវក្នុងការរៀបចំបញ្ជីបោះឆ្នោតពិសេសមួយដែលធ្វើបច្ចុប្បន្នភាពយ៉ាងជាក់លាក់មួយសម្រាប់ឆ្នាំបោះឆ្នោត។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរតែតែងតាំងបុគ្គលិករបស់ខ្លួនជា ប្រធានក្នុងការ រៀបចំការចុះឈ្មោះបោះឆ្នោត និងការបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោតថ្នាក់ឃុំ ចំណែក ឯក្រុមប្រឹក្សាថ្នាក់ឃុំ និងស្មៀន ឃុំត្រូវធ្វើជាជំនួយការរបស់ប្រធាន។ ដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ គួរត្រូវបានផ្លាស់ប្តូរ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគួរប្រើបញ្ជី ចុះឈ្មោះបោះឆ្នោតរបស់ការបោះឆ្នោតចុងក្រោយ ហើយធ្វើការស្វែងរកអ្នកបោះឆ្នោតទាំងឡាយណាមិនបានទៅបោះឆ្នោតនៅការបោះឆ្នោតចុង ក្រោយនេះ។ ដូចនេះហើយគណៈ កម្មាជាតិរៀបចំការបោះឆ្នោតគួរតែយកចិត្តទុកដាក់ខ្លាំងតែលើប្រជា ពលរដ្ឋណា ដែលមិនបានបោះឆ្នោតនៅពេលបោះ ឆ្នោតចុងក្រោយហើយមិនចាំបាច់យកចិត្តទុកដាក់លើ ប្រជាពលរដ្ឋទាំងឡាយណាដែលបានបោះឆ្នោត ក្នុងពេលបោះឆ្នោត ចុងក្រោយនោះទេ។

ខ. សមាហរណកម្មនៃលេខអត្តសញ្ញាណប័ណ្ណ

លេខអត្តសញ្ញាណប័ណ្ណ គួរតែត្រូវបានបន្ថែមនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតដែល ធ្វើឲ្យវាងាយស្រួលសម្រាប់ អ្នកបោះឆ្នោត ក្នុងការស្វែងរកឈ្មោះរបស់ពួកគេ នៅក្នុងករណីដែលឈ្មោះ ថ្ងៃខែឆ្នាំ កំណើត ភេទ និងអាសយដ្ឋានមិន ត្រឹមត្រូវ។ បញ្ជីចុះឈ្មោះបោះឆ្នោតអាចត្រូវបានធ្វើការផ្ទៀងផ្ទាត់ (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងភេទ) ជាមួយលេខអត្តសញ្ញាណប័ណ្ណ។ លេខអត្តសញ្ញាណប័ណ្ណនេះ អាចដាក់ជំនួសលេខប័ណ្ណបង្កាន់ (ចុះឈ្មោះបោះឆ្នោត)។ គួរបន្ថែមកូលោនមួយទៀតនៅក្នុងបញ្ជីឈ្មោះបោះឆ្នោតសម្រាប់កំនត់សំគាល់ ករណីពិសេសចំពោះអ្នកបោះឆ្នោត ។

គ. ប័ណ្ណពត៌មានអ្នកបោះឆ្នោត (VIN)

ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត (VIN) គួរត្រូវបានចេញ និងចែកចាយជូនអ្នកដែលបានចុះឈ្មោះបោះឆ្នោតជាពិសេសអ្នក ចុះឈ្មោះបោះឆ្នោតទាំងឡាយណា ដែលស្ថានីយឬទីតាំងបោះឆ្នោតរបស់ពួកគេត្រូវ បានផ្លាស់ប្តូរដោយសារការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោតរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយការបង្ហាញព័ត៌មានយ៉ាងច្បាស់លាស់ពីស្ថានីយបោះឆ្នោត ប្រសិនបើប័ណ្ណព័ត៌មាន អ្នកបោះឆ្នោតត្រូវបានលុបចោលបញ្ជីចុះឈ្មោះបោះឆ្នោត ត្រូវតែបិទបង្ហាញនៅក្នុងភូមិនីមួយៗ។ ការចែក ចាយប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គួរតែបន្តធ្វើឡើងដោយ គណៈកម្មាធិការរៀបចំការបោះឆ្នោត ដោយសហប្រតិបត្តិការជាមួយ មេឃុំ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (សមាជិកក្រុមប្រឹក្សា ២នាក់ មកពីគណបក្សផ្សេងគ្នា) ស្មៀនឃុំ អង្គការសង្កេតការណ៍បោះឆ្នោត និងគណបក្សនយោបាយ ចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត

ដែលតម្រូវឲ្យទទួលខុសត្រូវក្នុងការងារ ដើម្បីឲ្យអ្នកចុះឈ្មោះបោះឆ្នោតទាំង ១០០% ទទួលនូវប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។

ឃ. *អត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់អត្តសញ្ញាណបំរើឲ្យការបោះឆ្នោត*

សម្រាប់សកម្មភាពបន្ទាន់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគួរតែបន្តអំពាវនាវជាសាធារណៈ និងជាញឹកញាប់អំពី សេចក្តីណែនាំក្នុងអនុញ្ញាតឲ្យប្រើប្រាស់អត្តសញ្ញាណប័ណ្ណដែលអស់សុពលភាពជាឯកសារសំគាល់ ក្នុងថ្ងៃបោះឆ្នោត។ មេឃុំគួរតែត្រូវបានណែនាំឲ្យមានតម្លាភាពក្នុងការចេញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់អត្តសញ្ញាណបំរើឲ្យការបោះឆ្នោត។ ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ រួមមានអង្គការសង្កេតការបោះឆ្នោតហើយនឹងគណបក្សនយោបាយចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតអាចត្រួតពិនិត្យផ្ទៀងផ្ទាត់ និងធ្វើសវនកម្មលើការចេញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាក់អត្តសញ្ញាណបំរើឲ្យការបោះឆ្នោត។

ង. *ការចុះឈ្មោះបោះឆ្នោត*

ក្រុមប្រឹក្សាឃុំសង្កាត់ និងគជបត្រូវពង្រឹងការអនុវត្តដំណើរការនៃការចុះឈ្មោះបោះឆ្នោតដែល អ្នកមានសិទ្ធិបោះឆ្នោត គួរតែទៅចុះឈ្មោះបោះឆ្នោតត្រូវបង្ហាញខ្លួននៅការិយាល័យបោះឆ្នោត និងបង្ហាញឯកសារនានាដែលតំរូវដោយនិតីវិធីចុះឈ្មោះបោះឆ្នោត។

២). គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

ក.ករណីផ្លាស់ប្តូរៈ រៀបចំរចនាសម្ព័ន្ធនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីឲ្យទៅជាស្ថាប័ននៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងធានានូវឯករាជ្យភាពជាមួយនឹងជំនឿទុកចិត្តពីអ្នកពាក់ព័ន្ធផ្សេងៗទៀត រដ្ឋសភា និងរដ្ឋាភិបាលគួរតែពិនិត្យ និងធ្វើវិសោធនកម្ម និងច្បាប់ពាក់ព័ន្ធផ្សេងៗ (កែប្រែប្រព័ន្ធបច្ចុប្បន្ន)

រដ្ឋសភា គួរវិសោធនកម្មមាត្រាខ្លះនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញដើម្បីចែងបង្កើតស្ថាប័ន គ.ជ.ប ។ ស្ថាប័ន គ.ជ.បត្រូវមានថវិកាស្វ័យតៗ។ ក្នុងករណីពិបាករកបុគ្គលអព្យាក្រិត្យ (ឬដើម្បីធានាតម្លាភាព និងការជឿជាក់) សមាសភាព គ.ជ.ប គួរមានសមាជិកចេញមកពី គណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភា ហើយសមាសភាពនេះមានដូចគ្នានៅគ្រប់លំដាប់ថ្នាក់រាជធានី ខេត្ត និងឃុំ សង្កាត់។ សម្រាប់រយៈពេលវែង អព្យាក្រិត្យ សមាសភាព គ.ជ.ប ត្រូវតែជ្រើសរើសដោយបើកចំហរ បេក្ខជនអព្យាក្រឹត្យ (មិនមែនសមាជិកគណបក្សនយោបាយ) ត្រូវឲ្យមានការគាំទ្រជាឯកច្ឆ័ន្ទពីគណបក្សនយោបាយក្នុងរដ្ឋសភា។

ខ.ករណីកែលំអៈកែលំអរចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីកសាងទំនុកចិត្តរបស់គណបក្សនយោបាយមកលើការងាររបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

គ.ជ.ប គួរពិនិត្យ និងធ្វើការកែលំអ

គ.ជ.ប ត្រូវខិតខំរកទីស្នាក់ការឯករាជ្យដាច់ដោយឡែកពីក្រសួងមហាផ្ទៃ។

ការជ្រើសរើសសមាសភាពគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (PEC) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (CEC) និងមន្ត្រីការិយាល័យបោះឆ្នោត ត្រូវធ្វើទៅតាមលក្ខណៈវិនិច្ឆ័យ ដែលបច្ចុប្បន្ន គ.ជ.ប បានកំណត់និងធានាថា មានសមាសភាពចម្រុះពីគណបក្សនយោបាយដែលមានអាសនៈនៅក្នុងសភា។ បង្កើតអង្គភាពស៊ើបអង្កេតចល័តមួយ (គណៈកម្មការស៊ើបអង្កេតជាបន្ទុករបស់ គ.ជ.ប) ហើយឲ្យមានមួយក្រុមក្នុងមួយខេត្ត។ ប្រាក់ឧបត្ថម្ភដល់ មន្ត្រីការិយាល័យបោះឆ្នោត គួរតែពី២០ ទៅ៤០ម៉ឺនរៀល។

៣). ប្រព័ន្ធបោះឆ្នោត

ក. .ករណីផ្លាស់ប្តូរ បង្កើតនូវប្រព័ន្ធបោះឆ្នោតចម្រុះមួយ

រដ្ឋសភា និងរដ្ឋាភិបាលគួរពិនិត្យ និងធ្វើវិសោធនកម្មច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធផ្សេងៗ ទៀត៖

ប្រព័ន្ធបោះឆ្នោតថ្នាក់ក្រោមជាតិ (ឃុំ/សង្កាត់ ខេត្ត/ក្រុង ស្រុក/ខណ្ឌ) ត្រូវថែមបេក្ខជនដែលត្រូវប្រើប្រាស់ប្រព័ន្ធបោះឆ្នោតចម្រុះ ដែលសម្លេងឆ្នោតបោះឲ្យដោយផ្ទាល់ទៅកាន់បេក្ខជន និងគណបក្សនយោបាយ។ ប្រព័ន្ធបោះឆ្នោត ថ្នាក់ជាតិ ត្រូវប្រើប្រព័ន្ធសមាមាត្រតែ (ជ្រើសរើសសមាជិកសភា)ប្រើរូប មន្តបែងចែកអាសនៈ តាមសម័យអ៊ុនតាក់។ មានចំនួនកូតាស្ត្រី ៥0% នៅក្នុងបញ្ជីឈ្មោះជាបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ហើយដាក់ក្នុងបញ្ជីលេខរៀងឆ្លាស់គ្នារាប់ពីខាងលើ។ សម្រាប់ពីរ ឬបីអាណត្តិទៅមុខទៀតប្រទេសកម្ពុជាគួរតែពិចារណាអំពីប្រព័ន្ធ បោះឆ្នោតចំរុះ ដោយឲ្យមានបញ្ជីឈ្មោះបេក្ខជនឯករាជ្យ និងបញ្ជីឈ្មោះបេក្ខជនគណបក្សក្នុងការឈរ ឈ្មោះបោះឆ្នោត។ អាណត្តិរបស់នាយករដ្ឋមន្ត្រី ត្រូវតែកំណត់ក្នុងរយៈពេលយ៉ាងយូរបំផុត២អាណត្តិក្នុង មួយជីវិត។

គណបក្សនយោបាយ គួរគាំទ្រឲ្យ៖

មានចំនួនកូតាស្ត្រី ៥0% នៅក្នុងបញ្ជីឈ្មោះជាបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយនិមួយៗ ហើយដាក់ ក្នុងបញ្ជីលេខរៀងឆ្លាស់គ្នារាប់ពីខាងលើ។ អាណត្តិរបស់នាយករដ្ឋមន្ត្រី ត្រូវតែកំណត់ក្នុងរយៈពេលយ៉ាង យូរបំផុត ២អាណត្តិក្នុង មួយជីវិតអាចចែងនៅក្នុងលក្ខន្តិកៈរបស់គណបក្ស អំពីបេក្ខភាពសម្រាប់តំណែងនាយករដ្ឋមន្ត្រី បានតែចំនួន២អាណត្តិ។

៤). ប្រព័ន្ធផ្សព្វផ្សាយ

ក .ករណីផ្លាស់ប្តូរៈ បង្កើតប្រព័ន្ធផ្សព្វផ្សាយបើកទូលាយ និងយុត្តិធម៌សម្រាប់ ដំណើរការនយោបាយ

រដ្ឋសភា និងរដ្ឋាភិបាលត្រូវធ្វើច្បាប់ដែលទាក់ទងនឹងវិទ្យុ និងទូរទស្សន៍ឬធ្វើច្បាប់ដែលពាក់ព័ន្ធផ្សេងៗ

គួរតែបង្កើតក្រុមប្រឹក្សានៃការចាក់ផ្សាយដែលមានសមាជិកជាសង្គមស៊ីវិល និងមកពីគ្រប់ គណបក្សដែលជាប់ឆ្នោតនៅក្នុងរដ្ឋសភាជាតិ។ ជួយសម្រួលដល់ការផ្តល់អាជ្ញាប័ណ្ណនិងបង្កើតប៉ុស្តិ៍វិទ្យុ ទូរទស្សន៍ដល់សាធារណៈជន ដែលមានលទ្ធភាព។

ខ .ករណីកែលំអ បង្កើតប្រព័ន្ធផ្សព្វផ្សាយបើកទូលាយ និងយុត្តិធម៌ សម្រាប់ដំណើរការនយោបាយ

គ.ជ.ប ខិតខំចូលរួមកែលម្អ

ជំរុញឲ្យវិទ្យុ ទូរទស្សន៍ ពិសេសវិទ្យុ និងទូរទស្សន៍ឯកជនត្រូវបើកចំហ និងផ្តល់លទ្ធភាពស្មើៗគ្នាដល់គណបក្សនយោបាយនានាដើម្បីថ្លែងទៅកាន់អ្នកបោះឆ្នោត ព្រមទាំងធានា ថាប្រព័ន្ធផ្សព្វផ្សាយឯកជនមិនល្មើសច្បាប់ស្តីពីការបោះឆ្នោត។ ត្រូវតែកំណត់ និងបែកចែកម៉ោងផ្សព្វផ្សាយឲ្យបានស្មើៗគ្នាគ្រប់ការឃោសនារបស់គណបក្សនយោយនីមួយៗ ក្នុងកំឡុងពេលប្រតិទិននៃការបោះឆ្នោតរបស់ គ.ជ.ប។ សុំឲ្យមានការពិន័យ ឬដាក់ទោសដល់បេក្ខជន ឬគណបក្សណា ដែលមិនបានគោរពក្រម សីលធម៌ និងច្បាប់ស្តីពីការបោះឆ្នោត។

អង្គការសង្គមស៊ីវិល

បង្កើតប៉ុស្តិ៍ ឬបង្កើតកម្មវិធីទូរទស្សន៍ ឬវិទ្យុឯករាជ្យបន្ថែមដើម្បីផ្សព្វផ្សាយដោយមិនលំអៀង។ គ្រប់ពត៌មានរបស់គណបក្សនយោបាយផ្សេងៗ រួមទាំងពត៌មានវិជ្ជមាន និង អវិជ្ជមានទៅដល់សាធារណជន។

គណបក្សនយោបាយ

ត្រូវគោរពក្រមសីលធម៌ក្នុងការឃោសនាបោះឆ្នោត និងច្បាប់ស្តីពីការបោះឆ្នោត។

៥). ហិរញ្ញវត្ថុគណបក្សនយោបាយ

ក. ករណីផ្លាស់ប្តូរ បង្កើតច្បាប់ និងយន្តការដើម្បីពង្រឹងយុទ្ធនានយោបាយ ឲ្យមានយុត្តិធម៌ និងអភិបាលកិច្ចល្អនៃហិរញ្ញវត្ថុឃោសនានយោបាយ។

៥-១. រដ្ឋសភា និងរដ្ឋាភិបាល ត្រូវធ្វើច្បាប់ស្តីពីហិរញ្ញវត្ថុឃោសនានយោបាយ (ឬច្បាប់ស្តីពី ហិរញ្ញវត្ថុគណបក្សនយោបាយ) និងធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ឬច្បាប់ដែលពាក់ព័ន្ធផ្សេងៗទៀត ៖
ក្នុងការឃោសនាបោះឆ្នោត បេក្ខជនដែលឈរឈ្មោះជាតំណាងរាស្ត្រមិនអាចចំណាយ ថវិកាលើសពី៣ម៉ឺនដុល្លាអាមេរិក និងបេក្ខជនដែលឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មិនត្រូវចំណាយឲ្យលើសពី៥ពាន់ដុល្លាអាមេរិក។

ខ. ករណីកែលំអ បើកចំហរបាយការណ៍គណនេយ្យហិរញ្ញវត្ថុនៃគណ/បក្ស នយោបាយ និងលើកតម្កើនការផ្តល់ហិរញ្ញវត្ថុ ពីរដ្ឋឲ្យទៅគណបក្សដែលក្រកួត ប្រជែងនៅពេលឃោសនាបោះឆ្នោត។

៥-២. រដ្ឋាភិបាល និងរដ្ឋសភាគួរតែពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីគណបក្សនយោបាយដែល រដ្ឋគួរតែផ្តល់ថវិកាជាតិជូនមក គណបក្សនយោបាយដែលប្រកួតប្រជែងឲ្យបានស្មើៗគ្នាតាមដែលអាចធ្វើទៅបាននៅពេលឃោសនាបោះឆ្នោត។

៥-៣. គ.ជ.ប ត្រូវអនុវត្តច្បាប់បោះឆ្នោតឲ្យមានប្រសិទ្ធភាព ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុគ្រប់គណបក្សប្រកួតប្រជែងបោះឆ្នោត (ចំណូល និងចំណាយ) ក្នុងពេលឃោសនាបោះឆ្នោត ហើយ គ.ជ.ប ត្រូវតែផ្សព្វផ្សាយរបាយការណ៍ មុនពេល បោះឆ្នោតម្តងទៀត។ ដាក់ទណ្ឌកម្មចំពោះគណបក្សនយោបាយណាដែលក្លែងបន្លំ របាយការណ៍ ចំណូលចំណាយ។

៥-៤. អង្គការសង្គមស៊ីវិលត្រូវចូលរួមអង្កេត និងតាមដានចំណូល និងចំណាយគ្រប់គណបក្សនយោបាយ និងផ្សព្វផ្សាយ របាយការណ៍នោះតាមប្រព័ន្ធឃោសនា នានាឲ្យដល់ប្រជាពលរដ្ឋ។

៥-៥. គណបក្សនយោបាយត្រូវតែធ្វើរបាយការណ៍ហិរញ្ញវត្ថុក្នុងការឃោសនាបោះឆ្នោតរបស់ខ្លួនទៅ គ.ជ.ប ហើយផ្សព្វផ្សាយរបាយការណ៍នេះទៅដល់ សាធារណជន ជាពិសេសដល់សមាជិករបស់ខ្លួន។

៦). ការអប់រំអ្នកបោះឆ្នោត៖ ការលំអការអប់រំអ្នកបោះឆ្នោត ជាពិសេស នៅតាម តំបន់ដាច់ស្រយាល និងតំបន់ជាតិភាគតិច

អ្នកពាក់ព័ន្ធទាំងអស់ដូចជា រដ្ឋសភា រដ្ឋាភិបាល គ.ជ.ប អង្គការសង្គមស៊ីវិល គណបក្សនយោបាយ និងអាជ្ញាធរមូលដ្ឋាន ត្រូវចូលរួមអប់រំដល់អ្នកបោះឆ្នោត ពិសេសត្រូវធ្វើនៅតាមតំបន់ដាច់ស្រយាល និងតំបន់ដែលមានជនជាតិដើមភាគតិច។ អប់រំតាមតំបន់ដាច់ស្រយាលឲ្យបានញឹកញាប់ ជាភាពយន្ត រូបភាព ថតចំលងដាក់ឌីស ទាំងការបកស្រាយជាភាសាជនជាតិដើម (ព្នង...) ហើយចែកជូនតាមផ្ទះ។ អ្នកភ្នាក់ងារស្ម័គ្រចិត្ត អប់រំតាមផ្ទះ និងមានរូបភាពងាយៗ យល់អំពីការបោះឆ្នោត។ កុំប្រើពាក្យបច្ចេកទេស។ តួសម្តែងរឿងអប់រំ គួរយកជនជាតិដើមភាគតិចចូលរួមសម្តែងអំពីការអប់រំ។ ភ្នាក់ងារស្ម័គ្រចិត្តចុះអប់រំតាមផ្ទះ ជាពិសេសបានដល់ស្ត្រីជនពិការ ចាស់ទុំ ដោយមានរូប ភាពងាយយល់ អំពីការបោះឆ្នោត។

៧). សេរីភាពនៃការបញ្ចេញមតិ និងប្រមូលផ្តុំពង្រីកប្រជាធិបតេយ្យ

រដ្ឋសភា និងរដ្ឋាភិបាលគួរកែលំអ និងជម្រុញ៖

ការកំណត់និយមន័យ និងពន្យល់ពាក្យសេរីភាពនៃការបញ្ចេញមតិឲ្យបានច្បាស់លាស់។ ការកំណត់ឲ្យបានច្បាស់អំពីធាតុផ្សំនៃបទល្មើស។ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ត្រូវបានគោរពឲ្យស្របតាមអ្នកមានអភ័យឯកសិទ្ធិ ដែលមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ។ ការកំណត់ឲ្យបានច្បាស់ អំពីនិយមន័យករណីដែលអាចក្លាយទៅជា បទល្មើស ដូចជាការផ្សព្វផ្សាយពត៌មានមិនពិត ឬការញុះញង់ ឬការជេរប្រមាថបរិហារកេរ្តិ៍។ ការសម្តែងមតិរបស់ ប្រជាពលរដ្ឋ និងគណបក្សនយោបាយ មិនគួរចាត់ទុកជាបទល្មើស ព្រហ្មទណ្ឌ។ ការបើកឲ្យទូលាយនូវការបញ្ចេញមតិរបស់ ប្រជាពលរដ្ឋ ដោយឡែក

សង្គមស៊ីវិល បើទោះបីមានការប៉ះពាល់ទៅលើទង្វើរបស់បុគ្គលសាធារណៈ និងស្ថាប័ន សាធារណៈត្រូវបាន លើកលែងការចោទប្រកាន់។ ការផ្សព្វផ្សាយអំពីច្បាប់ដែលពាក់ព័ន្ធ និងការបញ្ចេញមតិដល់សាធារណ ជនឲ្យបានយល់ ជ្រួតជ្រាបជៀសវាងការចោទប្រកាន់ផ្សេងៗ ការផ្សព្វផ្សាយអំពីមតិជំទាស់រិះគន់ និងសកម្មភាពរបស់គណបក្សមិនកាន់អំណាចក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋជាទៀងទាត់។

ការជំរុញឲ្យមានការបង្កើតវេទិកាសាធារណៈ ផ្សព្វផ្សាយដល់មូលដ្ឋានអំពីច្បាប់ និងអាច ឲ្យប្រជាពលរដ្ឋបញ្ចេញមតិបាន ដោយឡែកត្រូវមានការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ ឬការសម្រេចចិត្តផ្សេងៗ រួមទាំងធ្វើនៅតាមតំបន់ជនជាតិដើមភាគតិច។ គោលការណ៍ណែនាំពិសេស ដើម្បដកទម្លាប់របស់អាជ្ញាធរដែលទាមទារការស្នើសុំអនុញ្ញាតពីប្រជាពលរដ្ឋ ដើម្បីធ្វើសកម្មភាពបញ្ចេញមតិមកអនុវត្តទៅតាមច្បាប់វិញ។ រាល់ការធ្វើបាតុកម្មដោយសន្តិវិធីនៅទីកន្លែង សាធារណៈណាមួយ ត្រូវជូនដំណឹងត្រឹម អាជ្ញាធរនៅកន្លែងនោះជាការស្រេច។ ការដាក់ទណ្ឌកម្ម ចំពោះអ្នកដែល គំរាមកំហែងទៅម្ចាស់ ឬអ្នកគ្រប់គ្រងដែលផ្តល់ទី កន្លែងដើម្បីធ្វើការប្រមូលផ្តុំគ្នា។ ទីលានប្រជាធិបតេយ្យ គួរតែបង្កើត នៅកន្លែងទីប្រជុំជនក្បែរស្ថាប័នរដ្ឋ និងមិនកំណត់អ្នក ចូលរួម។ ទីលាននេះ គួរតែបង្កើតនៅកន្លែងទីប្រជុំជនក្បែរស្ថាប័នរដ្ឋ និងមិនកំណត់អ្នក ចូលរួម។ ទីលាននេះគួរតែត្រូវបានបង្កើតនៅថ្នាក់ស្រុកផងដែរ។ សុំឲ្យមានការបង្កើតមជ្ឈមណ្ឌលផ្តល់ ពត៌មាននៅគ្រប់កម្រិតនៅតាមមូលដ្ឋាន។ ការបង្កើនចំនួនប្រអប់សំបុត្រ ឲ្យបានគ្រប់ភូមិ (គណនេយ្យភាព) ការបញ្ចេញមតិ និងសំណូមពររបស់ប្រជាពលរដ្ឋរបស់ប្រជាពលរដ្ឋដែលសមស្រប ត្រូវមានការឆ្លើយតប និងដំណោះស្រាយឲ្យបានទាន់ពេលវេលា។

អង្គការសង្គមស៊ីវិលចូលរួម៖

បើកវគ្គបណ្តុះបណ្តាលអំពីច្បាប់សិទ្ធិមនុស្ស ប្រជាធិបតេយ្យដល់មូលដ្ឋានដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។ រៀបចំវេទិកាសាធារណៈផ្សព្វផ្សាយដល់មូលដ្ឋានអំពីច្បាប់ និងអាចឲ្យប្រជាពលរដ្ឋបញ្ចេញមតិបាន។

អាជ្ញាធរមូលដ្ឋាន និងអ្នកអនុវត្តច្បាប់ត្រូវតែគោរព និងគាំទ្រ៖

រាល់ការបញ្ចេញមតិរបស់ប្រជាពលរដ្ឋដែលប៉ះពាល់ទៅលើទង្វើរបស់បុគ្គលសាធារណៈ និងស្ថាប័នសាធារណៈ ត្រូវលើក លែងការចោទប្រកាន់។ រាល់ការបញ្ចេញមតិ និងសំណូមពររបស់ប្រជាពលរដ្ឋដែលសមស្រប និងត្រូវមានការឆ្លើយតប និងដំណោះស្រាយឲ្យបានទាន់ពេលវេលា។ ទីលានសេរីភាព គួរតែបង្កើតនៅកន្លែងប្រជុំជនក្បែរស្ថាប័នរដ្ឋ និងទូលាយ (អាចផ្ទុកប្រជាពលរដ្ឋបានច្រើន)។ រាល់ការធ្វើបាតុកម្មដោយសន្តិវិធីនៅកន្លែងសាធារណៈណាមួយត្រូវជូន ដំណឹងត្រឹមអាជ្ញាធរនៅកន្លែងនោះជាការស្រេច។ ឲ្យមានវគ្គបណ្តុះបណ្តាលអំពីច្បាប់ សិទ្ធិមនុស្សប្រជាធិបតេយ្យ ដល់មូលដ្ឋានដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។ ការបង្កើតមជ្ឈមណ្ឌលផ្តល់ពត៌មាន នៅគ្រប់កម្រិតនៅតាមមូលដ្ឋាន។ រក្សាសុវត្ថិភាព និងការពារសិទ្ធិអ្នកសម្តែងមតិ។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)
លោក គល់ បញ្ញា នាយកប្រតិបត្តិ
លេខទូរស័ព្ទ៖ (៨៥៥)-១២-៩៤២-០១៧
អ៊ីម៉ែល៖ comfrel@online.org
គេហទំព័រ៖ www.comfre.org

កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ

១. សេចក្តីផ្តើម

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា(CHRAC) គឺជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដែលមានសមាជិកចំនួន ២១ កំពុងធ្វើការលើកកំពស់ការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ក្នុងប្រទេសកម្ពុជា។ CHRAC ធ្វើការតាមដានក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធតុលាការ ដែលជាបញ្ហាដ៏មានសារៈសំខាន់ ក្នុងការធានាការអនុវត្តន៍សកម្មភាពចាំបាច់នានា នៅក្នុងសូចនាករតាមដានរួម(JMIs) និងនៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ (NSDP update 2009-2013) ។

២. សូចនាករតាមដានរួម

ខាងក្រោមជាសូចនាករតាមដានរួមពាក់ព័ន្ធទៅនឹងកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការដែល រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ប្តេជ្ញាអនុវត្តនិងតាមដានក្នុងកំឡុងពេលរវាងកិច្ចប្រជុំលើកទី៣ និងទី៤ នៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ។

លទ្ធផលរយៈពេលមធ្យម	ធាតុចេញ	សូចនាករធាតុចេញ	សកម្មភាព	សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ
កែលំអការប្រព្រឹត្តិទៅរបស់ប្រព័ន្ធតុលាការ	១-បញ្ចប់ការរៀបចំច្បាប់សំខាន់ៗដែលទាក់ទងនឹងតុលាការ	១-គណៈរដ្ឋមន្ត្រីអនុម័តច្បាប់សំខាន់ៗដែលពាក់ព័ន្ធទៅនឹងតុលាការមានដូចជា៖ ក-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ ខ-ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា គ-ច្បាប់ស្តីពីការធ្វើវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម	១-ពិនិត្យឡើងវិញនូវលំដាប់អាទិភាពនៃការត្រួតពិនិត្យផ្នែកបច្ចេកទេសសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ទាំងបី ២-ក្រុមការងារពិសេសដឹកនាំដោយក្រុមប្រឹក្សាអ្នកច្បាប់ពិនិត្យសេចក្តីព្រាងច្បាប់ទាំងនេះ ៣-ស្នើសេចក្តីព្រាងច្បាប់ទាំងនេះជូនកិច្ច ប្រជុំអន្តរក្រសួង ៤-គណៈរដ្ឋមន្ត្រីអនុម័តសេចក្តីព្រាងច្បាប់ទាំងនេះ ។	១-ជំនួយបច្ចេកទេសសម្រាប់ពិនិត្យផ្នែកបច្ចេកទេសដើម្បីធានាសង្គតិភាពជាមួយបទដ្ឋានអន្តរជាតិ ២-ការគាំទ្រពីដៃគូអភិវឌ្ឍន៍ធានាសង្គតិភាពនៃច្បាប់ទាំងបីជាមួយក្របខ័ណ្ឌច្បាប់និងគោលដៅនយោបាយរបស់រាជរដ្ឋាភិបាល
	២-ការអនុវត្តន៍ទស្សនទានតុលាការគំរូក្នុងតុលាការទាំង៤	២-ការអនុវត្តន៍សកម្មភាពអាទិភាព សម្រាប់ឆ្នាំ២០១១ រួមទាំងដំណើរការនៃការចុះបញ្ជីសំណុំរឿងនៅតុលាការគំរូទាំង ៤ ។	៥-បញ្ចប់ផែនការសកម្មភាពរបស់តុលាការគំរូទាំង៤ ៦-ក្រសួងយុត្តិធម៌និងតុលាការគំរូទាំង៤ឯកភាពលើសកម្មភាពអាទិភាពសម្រាប់ឆ្នាំ ២០១១-២០១២ ៧-ស្នើសំណើថវិកាសម្រាប់គាំទ្រផែនការឆ្នាំ ២០១១-២០១២ តាមទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	៣-ការគាំទ្រខាងផ្នែកថវិការបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវតម្រឹមជាមួយនឹង ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពរបស់តុលាការ ៤-សុខដុមនីយកម្ម នៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

ការតាមដានវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួម

១៦.១. បញ្ចប់ការរៀបចំច្បាប់ជាមូលដ្ឋាន ដែលទាក់ទងនឹងតុលាការ:

សូចនាករតាមដានរួមទាំងនេះ មិនទាន់បានសម្រេចពេញលេញនៅឡើយទេ នៅពេលដែលការរៀបចំច្បាប់ជាមូលដ្ឋានទាក់ទងនឹងតុលាការ ស្ថិតក្នុងដំណាក់កាលព្យួរទុកសម្រាប់ការរៀបចំជាបន្ត។ ក្នុងដំណាក់នេះ គេមិនបានកត់សម្គាល់ឃើញ ពីវឌ្ឍភាពនៃសេចក្តីព្រាងច្បាប់ជាមូលដ្ឋានទាំងនោះទេ។ ពត៌មានអំពីវឌ្ឍនភាពនៃច្បាប់ទាំងនោះ ក៏មិនអាចទទួលបានដោយងាយស្រួលផងដែរ។

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការ: សេចក្តីព្រាងច្បាប់នេះនៅមិនទាន់អនុម័តនោះទេ។ មកទល់ពេលនេះ សេចក្តីព្រាងច្បាប់នេះត្រូវបានពិនិត្យនិងផ្តល់យោបល់ដោយក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាអ្នក ច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី។

ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា: ដូចគ្នាដែរ សេចក្តីព្រាងច្បាប់នេះត្រូវបានធ្វើការត្រួតពិនិត្យ និងផ្តល់យោបល់ដោយក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ប៉ុន្តែមិនទាន់បញ្ជូនទៅរដ្ឋសភា ដើម្បីធ្វើការពិនិត្យ និងអនុម័តនៅឡើយទេ។

ច្បាប់ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម:ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រីបានត្រួតពិនិត្យសេចក្តីព្រាងច្បាប់រួចរាល់ ហើយបានបញ្ជូនយោបល់ទៅក្រសួងយុត្តិធម៌ ដើម្បីធ្វើការពិនិត្យឡើងវិញលើចំណុចមួយចំនួន។ បច្ចុប្បន្ននេះ ក្រសួងយុត្តិធម៌បានបញ្ជូនរួចជាស្រេចនូវសេចក្តីព្រាងច្បាប់ នោះជូនដល់ក្រុមប្រឹក្សាអ្នកច្បាប់ដើម្បីធ្វើការពិនិត្យជាបន្ត។ ពត៌មានលម្អិត និងការគ្រោងសម្រាប់ កិច្ចប្រជុំអន្តរក្រសួងទាក់ទងទៅនឹងការអនុម័តច្បាប់នេះ នៅមិនទាន់មាននៅឡើយទេ ដែលនាំឲ្យសង្គមស៊ីវិល យល់ឃើញថា បញ្ហានេះអាចមកពីឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញដំណើរការអនុម័តច្បាប់នេះជាបន្ត។

១៦.២. ការអនុវត្តសកម្មភាពអាទិភាពសម្រាប់ឆ្នាំ២០១១ រួមមានការចុះបញ្ជីសំណុំរឿងកំពុងដំណើរការ នៅក្នុងតុលាការគំរូទាំងបួន

ក. ការរៀបចំតុលាការគំរូ និងការអនុវត្តការចុះបញ្ជីសំណុំរឿងក្នុងតុលាការគំរូទាំង៤

ជាលើកដំបូង ប្រទេសកម្ពុជាបានរៀបចំឲ្យមានជាតុលាការគំរូ៤ រួមមានសាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្តកំពង់ចាម និងសាលាដំបូងខេត្តបន្ទាយមានជ័យ។ ក្រុមប្រឹក្សាកំណែទម្រង់នៃទីស្តីការគណៈរដ្ឋមន្ត្រី មានភារកិច្ចរៀបចំផែនការសកម្មភាព និងឯកសារពាក់ព័ន្ធសម្រាប់ការអនុវត្តគម្រោងតុលាការគំរូ។ កន្លងមក ក្រសួងយុត្តិធម៌និងសាលាដំបូងទាំង៤បានព្រមព្រៀងគ្នា រៀបចំនូវក្រុមការងារមួយដើម្បីអនុវត្តសកម្មភាពជាអាទិភាពចំនួន ៨ចំនុច ក្នុងឆ្នាំ២០១០-២០១១។ ក្រសួងយុត្តិធម៌បានសម្រេចសមិទ្ធផលលើសកម្មភាពអាទិភាពមួយចំនួននៅក្នុងផែនការសកម្មភាព និងបានរៀបចំសំណើថវិកាសម្រាប់គាំទ្រចំពោះការអនុវត្តន៍គម្រោងតុលាការគំរូដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តាមពត៌មានពីមន្ត្រីជាន់ខ្ពស់នៃក្រសួងយុត្តិធម៌ សំណើសុំថវិកា នៃគម្រោងនេះកំពុងស្ថិតក្នុងការពិចារណារបស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ផ្សាភ្ជាប់ទៅនឹងគម្រោងតុលាការគំរូ ការចុះបញ្ជីសំណុំរឿងនៅតុលាការគឺជាសកម្មភាពអាទិភាពមួយ ដែលសកម្មភាពនេះជាមធ្យោបាយសំខាន់មួយសម្រាប់ការគ្រប់គ្រង និងការវាស់វែងលើការបំពេញភារកិច្ចរបស់មន្ត្រីតុលាការតាមរយៈការរាប់សំណុំរឿងទទួលបានក្នុងកំឡុងខែនីមួយៗ។ ការវាស់វែងដូចនេះ អាចជួយទៅដល់ប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់តុលាការឲ្យកាន់ត្រឹមត្រូវ ។

គម្រោងសាកល្បងនេះបានចាប់ផ្តើមអនុវត្ត ដោយមានការគាំទ្រមូលនិធិពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ ប៉ុន្តែចាប់តាំងពីចុងឆ្នាំ២០១១មក សង្គមស៊ីវិលមិនទាន់ទទួលបានរបាយការណ៍ណាមួយស្តីពីវឌ្ឍនៈភាពទាក់ទងនឹងគម្រោងតុលាការគំរូនោះទេ។

ខ. ការបណ្តុះបណ្តាលជាបន្តចំពោះមន្ត្រីជំនាញតុលាការ: មេធាវី និងចៅក្រម

នៅឆ្នាំ២០១០-២០១១៖ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីបានបណ្តុះបណ្តាលសម្រាប់សិស្សមេធាវីជំនាន់ទី១១ ចំនួន៨៤រូប។ សិស្សមេធាវីជំនាន់ទី១១ ចំនួន៨៣រូបបានទទួលជោគជ័យ និងបានក្លាយជាមេធាវីស្រប តាមវិជ្ជាជីវៈ បន្ទាប់ពីបានបញ្ចប់កម្មវិធីបណ្តុះបណ្តាលនេះ។

នៅឆ្នាំ២០១០-២០១១៖ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការបានបណ្តុះបណ្តាលសិស្សចៅក្រមចំនួន៥៥រូប។ ក្នុងនោះ សិស្សចំនួន៣៣រូបនឹងក្លាយជាចៅក្រម និងសិស្សចំនួន២២រូបនឹងក្លាយជាព្រះរាជអាជ្ញា ដោយអាស្រ័យលើការប្រលងបញ្ចប់ការសិក្សាជាស្ថាពរ ។

គ. សិទ្ធិទទួលបាននូវយុត្តិធម៌

ដោយទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ក្រសួងយុត្តិធម៌បានរៀបចំជាមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌នៅថ្នាក់តំបន់ ដោយមាននៅតាមស្រុក/ខ័ណ្ឌ ក្នុងខេត្ត/ក្រុងនានា។ សរុបមាន មណ្ឌលសេវាកម្មចំនួន៣០ (មណ្ឌលចាស់មានចំនួន ២០ និងមណ្ឌលថ្មីមានចំនួន១០) ។ ការបង្កើតជាមណ្ឌលសេវាកម្មនេះ មានគោលបំណងផ្តល់នូវសេវាកម្មពិគ្រោះយោបល់ផ្នែកច្បាប់ជាសាធារណៈ សម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន និងជួយសម្របសម្រួលដោះស្រាយវិវាទផ្សេងៗដូចជា ករណីទំនាស់ក្នុងគ្រួសារ ទំនាស់ដីធ្លី ការបង្ករបួសស្នាមបន្តិចបន្តួច និងករណីបរិហាកេរ្តិ៍ជាដើម ។ អង្គការUNDP (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ) បានគាំទ្រគម្រោងនេះ ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០។ ហើយមកដល់ពេលនេះ គម្រោងនៅតែបន្តអនុវត្តការងារក្រោមការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌ ដែលជាផ្នែកមួយក្នុងការចូលរួមក្នុងវិស័យកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

សំណូមពរ៖

១៦.១. បញ្ចាប់ការរៀបចំច្បាប់ជាមូលដ្ឋាន ដែលទាក់ទងនឹងតុលាការ

រាជរដ្ឋាភិបាលគួរពន្លឿនការអនុម័តច្បាប់ជាមូលដ្ឋានដែលកំពុងស្ថិតនៅជាសេចក្តីព្រាងច្បាប់នៅឡើយ រួមមាន (ក) ច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការ និង (ខ) ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ដោយអនុញ្ញាតិ ឲ្យមានការចូលរួមពីផ្នែកដែលពាក់ព័ន្ធ ជាពិសេសការចូលរួមពីសំណាក់អង្គការសង្គមស៊ីវិល ដើម្បីឲ្យមានការចូលរួមបានទូលំទូលាយ នៅក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ។ ដើម្បីធានាឯករាជ្យភាព ពេញលេញរបស់អង្គចៅក្រម និងការដាក់វិន័យដល់ចៅក្រម ឬព្រះរាជអាជ្ញាដែលប្រព្រឹត្តខុស រាជរដ្ឋាភិបាលគួរពន្លឿនការអនុម័តលើច្បាប់ស្តីពីឋានៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា ដែលកំពុងស្ថិតក្នុងដំណាក់កាលព្រាងនៅឡើយ។ ជាពិសេស រាជរដ្ឋាភិបាលគួរបើកកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងគួរអនុញ្ញាតឲ្យមានការចូលរួមរបស់អង្គការនៅក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់នោះ។ លេខាធិការដ្ឋានសម្រាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានភាពឯករាជ្យ និងមានកញ្ចប់ថវិកាស្វយ័ត គួរតប្បីត្រូវបានបង្កើតឡើង ។

១៦.២. បន្តវឌ្ឍនភាពនៅក្នុងការផ្តល់សេវាកម្មតុលាការនិងដំណើរការលើគោលគំនិតតុលាការគំរូទាំង៤ និងនៅក្នុងការជ្រើសរើសបេក្ខជនវិជ្ជាជីវៈតុលាការប្រកបដោយតម្លាភាព និងការបណ្តុះបណ្តាល

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរតែបែងចែកធនធានឲ្យបានគ្រប់គ្រាន់ដល់ក្រសួងយុត្តិធម៌សម្រាប់ការអនុវត្តគម្រោងសាកល្បងស្តីពីតុលាការគំរូ ដើម្បីជំរុញនិងគាំទ្រប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ ដៃគូអភិវឌ្ឍន៍គួរបន្តការគាំទ្រដល់រាជរដ្ឋាភិបាល លើផ្នែកជំនួយហិរញ្ញវត្ថុនិងជំនួយបច្ចេកទេស ដើម្បីធានាឲ្យបាននូវការអនុវត្តដោយជោគជ័យ លើគម្រោងសាកល្បងនេះ។ ក្នុងនាមជាអ្នកបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រាជរដ្ឋាភិបាលគប្បីបង្កលក្ខណៈអំណោយផលឲ្យបានកាន់តែប្រសើរ ដើម្បីឲ្យមានការចូលរួមកាន់តែទូលំទូលាយពីសំណាក់អ្នកជំនាញផ្នែកច្បាប់ ដោយការធានាឲ្យបាននូវដំណើរការជ្រើសរើសប្រកបដោយតម្លាភាព។ តាមរយៈវត្តមានរបស់អ្នកជំនាញទាំងនោះនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ពួកគេនឹងបន្តវឌ្ឍនភាពទៅតាមជំនាញរបស់ខ្លួន។ រាជរដ្ឋាភិបាលគួរអនុវត្តវិធានការតឹងរឹងដើម្បី ប្រយុទ្ធ

ប្រឆាំងនឹងគ្រប់ទម្រង់ទាំងអស់នៃអំពើពុករលួយ និងភាពមិនប្រក្រតីផ្សេងៗ ដែលអាចកើតមានឡើងក្នុងកំឡុងពេល នៃការជ្រើសរើសបេក្ខជនសម្រាប់ការសិក្សានៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

៣. សកម្មភាព / យុទ្ធសាស្ត្រសំខាន់ៗ ដកស្រង់ចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣

កថាខណ្ឌ	ខ្លឹមសារ
៣៨១	កំណែទម្រង់ច្បាប់: បន្តជំរុញការអនុម័តច្បាប់គោលសំខាន់ៗ ដូចជាច្បាប់ស្តីពី ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ការតាមដានការអនុវត្តន៍ ផយអជ បច្ចុប្បន្នកម្ម

៣៨១៖ កំណែទម្រង់ច្បាប់

ទោះបីជាមានការអនុម័តច្បាប់សំខាន់ៗជាច្រើនក្នុងឆ្នាំ២០១១ ក៏ច្បាប់សំខាន់ៗចំនួន៣នៅស្ថិតជាសេចក្តីព្រាងនៅឡើយ រួមមាន ១-ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ២-ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ ៣-ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម។ វឌ្ឍនភាពយឺតយ៉ាវនៃច្បាប់ទាំងនេះបណ្តាលឲ្យមានភាពយឺតយ៉ាវ ដល់ដំណើរវិវត្តទៅមុខនៃច្បាប់សំខាន់ៗដ៏ទៃទៀតដែលទាក់ ទងនឹងដំណើរការផ្នែកច្បាប់និងតុលាការ រួមមានច្បាប់ក្រឡាបញ្ជីតុលាការ ច្បាប់ស្តីពីសារការីសាធារណៈ និងច្បាប់ស្តីពី អាជ្ញាសាលា។ ការយឺតយ៉ាវនៃការរៀបចំនិងអនុម័តច្បាប់ទាំងនេះ បានបង្កជាឧបសគ្គដល់ការបង្កើតតុលាការ ពិសេសមួយចំនួនដូចជា តុលាការការងារ តុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាល និងតុលាការអនីតិជន ជាដើម ។

រាជរដ្ឋាភិបាលក៏បានបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងបន្តអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌ដើម្បីឆ្លើយតបទៅនឹងតម្រូវការចំពោះដំណោះស្រាយវិវាទដីធ្លីដ៏ត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។ គេបានបង្កើតយន្តការដោះស្រាយវិវាទជាច្រើន ហើយបច្ចុប្បន្នគេកំពុងដំណើរការយន្តការទាំងនោះក្នុងរូបភាពជាការសម្របសម្រួលទៅលើវិវាទតូចៗ និងផ្តល់ជាសេវាពិគ្រោះយោបល់ផ្នែកច្បាប់ ដែលរួមមានគណៈកម្មការសុរិយោដី អាជ្ញាធរជាតិសម្រាប់ដំណោះស្រាយវិវាទដីធ្លី និងមជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌ (ស្ថិតនៅក្រោមគម្រោងសិទ្ធិទទួលបានយុត្តិធម៌)។ យ៉ាងណាមិញ គេសង្កេតឃើញនៅមានបញ្ហាប្រឈមជាច្រើន ដែលទាមទារការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាល ចំពោះវិធីសាស្ត្រកែលម្អយន្តការទាំងនេះប្រកបដោយប្រសិទ្ធភាពបំផុត។

សំណូមពរ៖

- រាជរដ្ឋាភិបាលគួរផ្តល់ឱកាសឲ្យមានការចូលរួមពិគ្រោះយោបល់ទូលំទូលាយពីសង្គមស៊ីវិល និងគួរជំរុញការអនុម័តច្បាប់ជាមូលដ្ឋានទាំងនេះឲ្យបានឆាប់រហ័សដើម្បីធានាឯករាជ្យភាពនៃអង្គចៅក្រម។

- ដៃគូអភិវឌ្ឍន៍គួរតែបន្តការគាំទ្រ សកម្មភាព របស់សង្គមស៊ីវិល ជាពិសេសអង្គការជំនួយផ្នែកច្បាប់ ដែលធ្វើការគាំទ្រដល់ជនក្រីក្រ និងជនងាយរងគ្រោះ នានា។

- រាជរដ្ឋាភិបាលគួរពង្រឹងគុណភាពនៃយន្តការដោះស្រាយវិវាទដែលមានស្រាប់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃដំណោះស្រាយវិវាទដីធ្លី ជាពិសេសអ្នកដែលកំពុងប្រឈមនឹងស្ថានភាពវិបត្តិដីធ្លី ។

៤. បញ្ហាសំខាន់ៗមិនមានក្នុងសូចនាករតាមដានរួម ឬផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម

អង្គការមិនមែនរដ្ឋាភិបាលសូមកោតសរសើរចំពោះវឌ្ឍនភាពនៃផ្នែកជាច្រើន ដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម។ ទន្ទឹមនឹងនេះ ក៏មានបញ្ហាមួយចំនួនទៀត ដែលគួរតែពិចារណាផងដែរគឺ៖

១. **អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ឬសាលាក្តីខ្មែរក្រហម**

រាជរដ្ឋាភិបាល អង្គការសហប្រជាជាតិ និងប្រទេសម្ចាស់ជំនួយ គួរតែបន្តធានាការប្រព្រឹត្តទៅដោយរលូននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ឬសាលាក្តីខ្មែរក្រហមដែលគាំទ្រដោយអង្គការសហប្រជាជាតិ។ ការប្រព្រឹត្តទៅដោយរលូនរបស់អង្គជំនុំជម្រះវិសាមញ្ញ អាចផ្តល់យុត្តិធម៌ជូនជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងកំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ (១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩) ដោយចៀសវាងបាននូវឧបសគ្គនានារួមមាន ឧបសគ្គនយោបាយ ថវិកា និងផ្នែកច្បាប់។ សង្គមស៊ីវិលចូលរួមអបអរសាទរ ចំពោះការវិត្តន៍នៃសំណុំរឿង០០១ សំណុំរឿង០០២ ប៉ុន្តែក៏សំដែងនូវការព្រួយបារម្ភចំពោះសំណុំ រឿង០០៣ និង០០៤ ដែលមិនទាន់មានសេចក្តីសម្រេចណាមួយនៅឡើយរហូតមកទល់នេះ ខណៈដែលគេសង្កេតឃើញមានការជ្រៀតជ្រែកខាងនយោបាយផងដែរ។

២. ការបង្កើនចំនួនសាលាឧទ្ធរណ៍នៅថ្នាក់តំបន់

ផ្នែកមួយនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ រាជរដ្ឋាភិបាលគួរពិចារណាលើការបង្កើនចំនួនសាលាឧទ្ធរណ៍ដើម្បីធានាយុត្តិធម៌ និងពន្លឿនការដោះស្រាយរឿងក្តីចំពោះគ្រប់ភាគីទាំងអស់នៅថ្ងៃខាងមុខ ។

សំណូមពរ៖

- តាមគ្រប់មធ្យោបាយទាំងអស់ រាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ គួរតែបន្តជួយគាំទ្រ ជាពិសេសផ្នែកថវិកា ទៅដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ដើម្បីឲ្យមានដំណើរការទៅមុខបានដោយរលូនគ្មានការរាំងស្ទះ និងធានាបាននូវឯករាជ្យភាព ក្នុងការផ្តល់នូវយុត្តិធម៌ជូនជនរងគ្រោះទាំងអស់។

- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) គួរដំណើរការឲ្យបានលឿននិងត្រឹមត្រូវ ដោយគោរពសិទ្ធិភាគីទាំងអស់ ដើម្បីធានាឲ្យបាននូវយុត្តិធម៌ពេញលេញ និងបង្កើតជាមរតកផ្នែកច្បាប់ សម្រាប់ជួយដល់កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការថ្នាក់ជាតិ និងសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរនៅពេលអនាគត។

- រាជរដ្ឋាភិបាលគួរបង្កើនចំនួនមន្ត្រីតុលាការក្នុងសាលាឧទ្ធរណ៍ដើម្បីបង្កើនប្រសិទ្ធភាពផ្នែកប្រព័ន្ធតុលាការ និងឆ្លើយតបនឹងតំរូវការ ដែលកើនឡើងចំពោះបញ្ហារឿងក្តីតុលាការនានា ។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
លោក ធន សារាយ ប្រធានសម្របសម្រួល CHRAC / ប្រធានសមាគមអាដហុក
លោក សួន ប៊ុនស័ក្តិ លេខាធិការប្រតិបត្តិ/ប្រធានលេខាធិការដ្ឋាន
ទូរស័ព្ទ៖ ៨៥៥-២៣ ៣០៥ ៦០៩ ទូរសារ៖ ៨៥៥-២៣ ២១៨ ៧៥៩
អ៊ីម៉ែល៖ chrac@everyday.com.kh, chrac@forum.org.kh
គេហទំព័រ៖ www.chrac.org

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធជាតិដើម្បីប្រសិទ្ធភាពនៃការអភិវឌ្ឍ

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ តម្លាភាព និងភាពអាចទុកចិត្តបាននៃថវិកា

១. សេចក្តីផ្តើម

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា គឺជាអង្គការសមាជិកភាពមួយ ដែលមានបេសកកម្មសម្របសម្រួល និងផ្តល់ដល់សមាជិក និងបណ្តាញនៃអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (CSOs) ផ្សេងទៀតនូវព័ត៌មាន ដើម្បីឲ្យមានការចូលរួមយ៉ាងសកម្មក្នុងការសុន្ទនា ការពិភាក្សា និងការតស៊ូមតិខាងគោលនយោបាយជាមួយនិងដើម្បីប្រជាជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា។

នៅក្នុងវិស័យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដោយមានការជួយគាំទ្រពីបណ្តាញអភិវឌ្ឍន៍សេដ្ឋកិច្ចនៃអង្គការមិនមែនរដ្ឋាភិបាល បានបង្កើតគម្រោងថវិកាជាតិក្នុងឆ្នាំ២០០៦ ដោយមានគោលដៅជារួមមួយធានាការយល់ដឹង និងការចូលរួមជាសាធារណៈនៅក្នុងដំណើរការថវិកាជាតិ។ រហូតមកដល់បច្ចុប្បន្ននេះ គម្រោងបានខិតខំជម្រុញតម្លាភាពថវិកា តាមរយៈការពិនិត្យមើលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[11] (PFMRP) របស់រាជរដ្ឋាភិបាលកម្ពុជា និងការវិភាគ និងស្រាវជ្រាវស្តីពីថវិកា ដើម្បីឆ្លុះបញ្ចាំងពីភាពទុកចិត្តបាននៃថវិកា និងថាតើអាទិភាពមានភាពស្របគ្នានឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ដែរឬទេ។ គម្រោងធ្វើការវិភាគរៀងរាល់ឆ្នាំលើច្បាប់ថវិកា [12] ដោយមានការចូលរួមចំណែកពីអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យនៅក្នុងវេទិកាបញ្ហាអភិវឌ្ឍន៍ (បណ្តាញនៃអង្គការមិនមែនរដ្ឋាភិបាលមួយ) និងក្រុមដទៃទៀតដែលមានចំណាប់អារម្មណ៍លើបញ្ហានេះ ដូចជាសមាគមសេដ្ឋកិច្ចកម្ពុជាជាដើម។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ជឿថាការកំណត់អាទិភាពថវិកាឲ្យបានសមស្របសម្រាប់វិស័យ ឬក្រសួងអាទិភាពទាំងឡាយ នឹងជួយធានាឲ្យផលនៃការអភិវឌ្ឍបានទៅដល់ក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គឺជាសមាជិកមួយនៃក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (TWG-PFM)។ គម្រោងថវិកាជាតិ ពិនិត្យមើលលើគោលដៅទី១២ ស្តីពីការគ្រប់គ្រងបំណុល គោលដៅទី១៤ ស្តីពីលទ្ធកម្មសាធារណៈ និងគោលដៅទី២៥.៤ ស្តីពីការរាយការណ៍ និងទំនាក់ទំងជាមួយសាធារណជន ដូចមានលើកឡើងនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដោយមានការយល់ព្រមពីសមាជិកបណ្តាញរបស់ខ្លួនបានរៀបចំឯកសារនេះ។ វឌ្ឍនភាពដែលបានពិនិត្យ និងកត់ត្រានៅក្នុងឯកសារនេះ ត្រូវបានកំណត់ដោយផ្អែកជាចម្បងលើព័ត៌មានដែលបានទទួលក្នុងកិច្ចប្រជុំទាំងឡាយរបស់ TWG-PFM របាយការណ៍វឌ្ឍនភាពដែលរៀបចំដោយគណៈម្នាធិការដឹកនាំការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្តីពីការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (មាននៅក្នុងគេហទំព័ររបស់គណៈកម្មាធិការ www.pfm.gov.kh) និងបទពិសោធន៍ របស់អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ដែលធ្លាប់បានព្យាយាមរកព័ត៌មានស្តីពីថវិកាពីប្រភពសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។

---

[11] ឯកសារនេះអាចទាញយកបានពីគេហទំព័ររបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈ www.pfm.gov.kh។

[12] ក្នុងអំឡុងឆ្នាំ ២០០៨-២០១០ សេចក្តីព្រាងច្បាប់ថវិកាត្រូវបានបញ្ចេញដោយគណៈកម្មការទីពីរនៃរដ្ឋសភាជូនវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើការវិភាគជូនសមាជិកសភាមុនពេលអនុម័តច្បាប់នេះ។ ប៉ុន្តែ ក្នុងឆ្នាំ ២០១១ សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១២ មិនត្រូវបានបញ្ចេញទេ ទោះបីមានការស្នើសុំច្រើនដងក្តី។ ប្រការនេះគឺជាវិលត្រឡប់ថយក្រោយទៅកាន់ស្ថានភាពមុនឆ្នាំ២០០៨ ដែលនៅពេលនោះ សេចក្តីព្រាងច្បាប់មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ។

ដោយផ្អែកលើគោលដៅដែលបានលើកឡើងខាងលើ មានការសង្កេតឃើញថារាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគឺជាកិច្ចខិតខំប្រឹងប្រែងមួយដែលសមទទួលបានការវាយតម្លៃខ្ពស់ពីអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ជាពិសេស លើជំហានទៅមុខក្នុងការបង្កើនតម្លាភាពនៅក្នុងដំណើរការថវិកាក្នុងឆ្នាំ២០១១។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផលិតព្រឹត្តិបត្រស្ថិតិប្រចាំខែបានទាន់ពេលវេលា ដោយព្រឹត្តិបត្រចុងក្រោយសម្រាប់ខែមីនា ឆ្នាំ២០១២ ត្រូវបានផ្សព្វផ្សាយក្នុងខែមេសា ឆ្នាំ ២០១២។ ក្រសួងក៏បានបញ្ចេញសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈក្នុងអំឡុងខែឧសភា ឆ្នាំ២០១១ ជូនវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់ជាមតិយោបល់ និងបានពិចារណាលើយោបល់របស់ក្រុមការងារនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដូចជាការពង្រីកបន្ថែមលើមាត្រាស្តីពីទោសប្បញ្ញត្តិ។ ក្រសួងក៏បានរៀបចំ ផងដែរនូវអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងខែមិថុនា ឆ្នាំ ២០១១ និងបានចូលរួមក្នុងការសុន្ទនាជាមួយសង្គមស៊ីវិលស្តីពីតម្លាភាពបំណុលនិងជំនួយ ដោយចូលរួមក្នុងសិក្ខាសាលាស្តីពីតម្លាភាពនៃព័ត៌មានស្តីពីជំនួយ និងលទ្ធផលអភិវឌ្ឍន៍ ដែលបានរៀនបចំឡើងដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលក្នុងខែតុលា ឆ្នាំ២០១១។ លើលពីនេះទៀត អាជ្ញាធរសវនកម្មជាតិបានផ្សព្វផ្សាយរបាយការណ៍សវនកម្មឆ្នាំ២០០៧ កាលពីខែវិច្ឆិកា ឆ្នាំ២០១១។ ជាមួយវឌ្ឍនភាពនេះ យើងខ្ញុំសង្ឃឹមថារាជរដ្ឋាភិបាលកម្ពុជានឹងបន្តលើកកម្ពស់តម្លាភាពបន្ថែមទៀតនៅក្នុងដំណើរការថវិកានៅក្នុងឆ្នាំ២០១២ ក៏ដូចជាឆ្នាំបន្តបន្ទាប់ទៀត។

២. សូចនាករតាមដានរួមគ្នាទី១៩៖ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

ស្ថាប័នសម្របសម្រួល៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:/ ក្រុមការងារបច្ចេកទេសលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ស្ថាប័នអនុវត្ត៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង/ ស្ថាប័នពាក់ព័ន្ធ (៣៩)

លទ្ធផលរយៈពេលមធ្យម	ធាតុចេញ	សូចនាករធាតុចេញ	សកម្មភាព៖ គោលដៅកំណត់	សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ
ពង្រឹងភាពជឿទុកចិត្តនៃថវិកា និងបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ	១. គោលនយោបាយចំណូល - ព្យាករណ៍ និងប្រមូលចំណូល និងពង្រឹងតម្លាភាព និងសមត្ថភាពក្នុងការប្រមូលចំណូល ២. គោលនយោបាយ ប្រព័ន្ធ និងសម្ភភាពគ្រប់គ្រងសាច់ប្រាក់និងបំណុល ត្រូវបានពង្រឹង ៣. ... ៤. បញ្ចប់ការរៀបចំអភិក្រមការងារដោយមានយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរត្រឹមត្រូវ និងមានផែនការទំនាក់ទំនងដើម្បីគ្រប់គ្រងការផ្លាស់ប្តូរទាំងនេះ និងសុំការអនុម័តពីថ្នាក់ដឹកនាំរបស់	១. បង្កើនការប្រមូលចំណូលឲ្យបាន ០.៥% ក្នុងមួយឆ្នាំ ធៀបនឹងផលិតផលក្នុងស្រុកសរុប ២. ក្របខ័ណ្ឌច្បាប់សម្រាប់ឧស្សាហកម្មរុករកត្រូវបានអនុម័ត និងអនុវត្ត ៣. បង្កើនតម្លាភាពក្នុងការគ្រប់គ្រងចំណូលពន្ធ និងមិនមែនសារពើពន្ធ ៤. បំណុលកកស្ទះ មិនឲ្យលើសពី ២% នៃចំណាយសរុប ៥. ចំណាយនាពាក់កណ្តាលឆ្នាំ ឬចុងឆ្នាំ មិនត្រូវតិចជាង៖ ៤៥% (សម្រាប់ត្រីមាសទី២)និង ៩៦%	១. ការបញ្ចប់ការរៀបចំឯកសារស្តីពីគោលនយោបាយចំណូល ២. រៀបចំសេចក្តីព្រាងច្បាប់ពន្ធដារស្តីពីប្រេងនិងឧស្ម័ន ៣. ពង្រឹងប្រព័ន្ធព្យាករណ៍ចំណូល ប្រព័ន្ធប្រមូលចំណូលនិងសមត្ថភាព ៤. បន្តកែលម្អការកត់-ត្រាអាណត្តិបើកប្រាក់ដល់កំណត់ ៥. ពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធរបាយការណ៍ប្រចាំឆមាស និងធ្វើវិសហ-មជ្ឈកាក្នុងការទទួលខុស	១. ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: មានសមាសភាគសំខាន់ៗដែលបានចូលរួមបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហ-ប្រតិបត្តិការ(ផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:) ២. កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះនិងកិច្ចប្រជុំត្រួតពិ-និត្យប្រចាំឆ្នាំជាច្រើនត្រូវបានរៀបចំដើម្បីពិភាក្សា និងតាមដាន

	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើអភិក្រមការងារ និងស្វែងរកការគាំទ្រពីថ្នាក់ដឹកនាំ ៥. ...	(សម្រាប់ត្រីមាសទី៤) ៦. ភាគរយនៃការទូ-ទាត់ទៅម្ចាស់ឥណ-ទាន និងបុគ្គលិកតាមរយៈប្រព័ន្ធធនាគារ មិនត្រូវតិចជាង ៨0% នៃតម្លៃ ៧. ... ៨. ដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងគណនេយ្យតាមប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុត្រូវបានរៀបចំ ៩. ...	ត្រូវ ៦. ធ្វើសនិទានកម្មគណនីធនាគារ និង បង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារពាណិជ្ជ ៧. ... ១១. អនុវត្តអភិក្រមការងារទៅក្នុងកម្មវិធីនៃប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ១២. ...	ត្រួតពិនិត្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គោលដៅទី១២ នៃPFMRP៖ បន្តកែលម្អការគ្រប់គ្រងបំណុល

ភាគទី១៖ ផែនការសកម្មភាពជំហានទី១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី២

គោលបំណង/ សកម្មភាព	សូចនាករគន្លឹះ (ឯកសារយោង PEFA)	គោលដៅ		
		ឆ្នាំ២00៨	ឆ្នាំ២00៩	ឆ្នាំ២0១0
១២.១... ១២.២. រៀបចំ និងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុល ១២.៣. បង្កើនការប្រើប្រាស់ប្រព័ន្ធទិន្នន័យបំណុល	... រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលប្រចាំឆ្នាំ គុណភាពនៃការកត់ត្រា និងរបាយការណ៍បំណុលក្នុងប្រទេស និងក្រៅប្រទេសត្រូវបានកែលម្អ	... ចាប់ផ្តើមរៀបចំយុទ្ធសាស្ត្របំណុលប្រចាំឆ្នាំ បង្កើតរបាយការណ៍តាមដានបំណុលប្រចាំត្រីមាស និងប្រចាំឆ្នាំ	... យុទ្ធសាស្ត្របំណុលប្រចាំឆ្នាំត្រូវបានរៀបចំ បង្កើតរបាយ-ការណ៍តាមដានបំណុលប្រចាំត្រីមាស និងប្រចាំឆ្នាំដែលមានលក្ខណៈពេញលេញព្រមទាំងធ្វើបច្ចុប្បន្នភាពនិងផ្ទៀងផ្ទាត់ជាប្រចាំ	... ត្រួតពិនិត្យឡើងវិញយុទ្ធសាស្ត្រដែលបានបង្កើត បង្កើតប្រព័ន្ធត្រួតពិនិត្យ តាមដាននិងការគ្រប់គ្រងបំណុលពេញលេញជាមួយនឹងរបាយការណ៍ស្ថិតិរបាយការណ៍គ្រប់គ្រងគ្រប់ជ្រុងជ្រោយ

ប្រភព: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ទំព័រ៥0 (ឯកសារភាសាខ្មែរ)

របាយការណ៍វឌ្ឍនភាពឆ្នាំ២0១១ ស្តីពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានផ្សព្វផ្សាយក្នុងខែកុម្ភៈ ឆ្នាំ២0១២ ហើយអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ និងឯកសារយុទ្ធសាស្ត្រស្តីពីការ

គ្រប់គ្រងបំណុលសាធារណៈ ត្រូវបានរៀបចំ និងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជារៀងគ្នាក្នុងខែមិថុនា ឆ្នាំ២០១១ និងខែកុម្ភៈ ឆ្នាំ២០១២។ មាត្រា២៩ នៃអនុក្រឹត្យតម្រូវឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្សព្វផ្សាយសេចក្តីសង្ខេបនៃឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈនៅក្នុងប្រភពសាធារណៈ។ ក្នុងខែមីនា ឆ្នាំ២០១២ ក្រសួងក៏បានផ្សព្វផ្សាយសេចក្តីសង្ខេបនៃឯកសារយុទ្ធសាស្ត្រនេះនៅលើគេហទំព័ររបស់ខ្លួន (www.mef.gov.kh)។ មាត្រា៣០ នៃអនុក្រឹត្យនេះ ក៏តម្រូវផងដែរឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផលិតរបាយការណ៍វិភាគនិរន្តរភាពបំណុល នៅក្នុងរយៈពេលពីរឆ្នាំរំកិល ឬតាមការចាំបាច់។ នៅក្នុងសិក្ខាសាលាដែលរៀបចំដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលកាលពីខែតុលា ឆ្នាំ២០១១ គេបានកត់សម្គាល់ថាមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូបបានលើកឡើងអំពីការរៀបចំព្រឹត្តិបត្របំណុល ដែលនឹងដាក់បញ្ចូលនូវព័ត៌មានទាក់ទិននឹងការវិភាគនិរន្តរភាពបំណុល។ នៅក្នុងសិក្ខាសាលាដដែលនោះ ក៏មានការបញ្ជាក់ផងដែរថាក្រសួង មិនបានប្រើប្រាស់នូវព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យស្តីពីហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ (ODA) ដែលមាននៅក្នុងគេហទំព័រនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (CRDB) នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) (http://cdc-khmer.biz) ដែលចុះផ្សាយនូវព័ត៌មានស្តីពីប្រាក់កម្ចីសម្បទាន ដោយរួមមានទាំងលក្ខខណ្ឌនៃជំនួយសម្រាប់ប្រទេសកម្ពុជានោះទេ។ យើងមានជំនឿថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាអ្នករក្សាទុកកិច្ចសន្យា មានព័ត៌មានដែលមានលក្ខណៈត្រឹមត្រូវ និងប្រមូលផ្តុំជាងទាក់ទិននឹងបរិមាណបំណុលសាធារណៈទាំងក្រៅ និងក្នុងប្រទេស។ មាត្រា៣៤ នៃអនុក្រឹត្យក៏ចែងផងដែរថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតឲ្យផ្សព្វផ្សាយព័ត៌មានស្តីពីការគ្រប់គ្រងបំណុល ហើយទម្រង់និងខ្លឹមសារនៃព័ត៌មានស្តីពីបំណុលត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល សូមអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការប្តេជ្ញាតាមផ្លូវច្បាប់របស់ខ្លួនក្នុងការធានាតម្លាភាពក្នុងការគ្រប់គ្រងបំណុល ដូចដែលមានចែងនៅក្នុងអនុក្រឹត្យ។ យើងខ្ញុំសូមកោតសរសើរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះការសម្រេចបាននូវលទ្ធផលដ៏ច្រើនខាងលើ និងកិច្ចខិតខំប្រឹងប្រែងក្នុងការកែលម្អតម្លាភាពថវិកានៅកម្ពុជា។ បន្ថែមលើនេះទៀត យើងខ្ញុំក៏បានកត់សម្គាល់ផងដែរថាទាំងការសិក្សានិងរបាយការណ៍ស្តីពីការវិភាគនិរន្តរភាព បំណុលនៅកំពុងត្រូវបានរៀបចំ។ យើងខ្ញុំសូមធ្វើការលើកទឹកចិត្តឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍ ពន្លឿនការបញ្ចប់ការងារនេះ ហើយយើងខ្ញុំក៏សង្ឃឹមផងដែរថា ព្រឹត្តិបត្របំណុលនេះនឹងត្រូវបានផ្សព្វផ្សាយក្នុងឆ្នាំ២០១២នេះ នៅក្នុងប្រភពសាធារណៈ (ពោលគឺគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។

គោលដៅទី១៤៖ កែលម្អលទ្ធកម្មសាធារណៈបន្ថែមទៀត

គោលបំណង/សកម្មភាព	សូចនាករគន្លឹះ (ឯកសារយោង PEFA)	គោលដៅ		
		ឆ្នាំ២០០៨	ឆ្នាំ ២០០៩	ឆ្នាំ២០០៨
...		...		
១៤.៥. បង្កើនភាពប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្មតាមរយៈ ការបង្កើនការផ្សព្វផ្សាយជាសាធារណៈ និងដោយចំហរ	គេហទំព័រលទ្ធកម្មសម្រាប់ដំណើរការ លទ្ធកម្មត្រូវបានបង្កើត និងប្រើប្រាស់		គេហទំព័រ ត្រូវបានបង្កើត	៥0% នៃការដេញថ្លៃ និងព័ត៌មានស្តីពីការប្រគល់កិច្ចសន្យាត្រូវបានបោះផ្សាយ

ប្រភព: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ទំព័រ៥៦ (ឯកសារភាសាខ្មែរ)

យោងតាមរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១១ ស្តីពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ និងផ្សព្វផ្សាយនៅក្នុងរាជកិច្ចក្នុងខែមករា ឆ្នាំ២០១២។ បន្តពីនេះ មានការចេញនូវសារាចរមួយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ

វត្ថុ លេខ០០១ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ ក្រុមការងារនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីច្បាប់ស្តីពីលទ្ធកម្មសាធារណៈ សូមធ្វើការកោតសរសើរដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបញ្ចេញនូវសេចក្តីព្រាងច្បាប់នេះ ដែលអនុញ្ញាតឲ្យមានការចូលរួមយោបល់[13] ពីអង្គការមិនមែនរដ្ឋាភិបាល ថ្វីបើពុំមានការពិគ្រោះយោបល់ទូលំទូលាយជាសាធារណៈលើសេចក្តីព្រាងច្បាប់នេះក្តី។

ចាប់តាំងពីដើមឆ្នាំ២០១១មក គេបានសង្កេតឃើញថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចាប់ផ្តើមផ្សព្វផ្សាយប្រកាសលទ្ធកម្មសាធារណៈនានានៅក្នុងទំព័រមួយនៃគេហទំព័ររបស់ខ្លួន។ សម្រាប់ឆ្នាំ២០១២ សេចក្តីជូនដំណឹងចំនួនប្រហែល១៤៨ ស្តីពីលទ្ធកម្ម ឬការដេញថ្លៃ ត្រូវបានចុះផ្សាយលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយគិតត្រឹមថ្ងៃទី៤ ខែឧសភា[14]។ ថ្វីបើសេចក្តីជូនដំណឹងទាំងនេះ ផ្តល់នូវរយៈពេលយ៉ាងហោចណាស់ក្នុងរវាង៣០ ឬ៦០ថ្ងៃ មុនពេលការដេញថ្លៃចាប់ផ្តើមក្តី ក៏ចន្លោះពេលពីថ្ងៃចេញសេចក្តីប្រកាស និងថ្ងៃចុះផ្សាយលើគេហទំព័រ ជាទូទៅគឺមានរយៈពេលវែង។ ជាងពាក់កណ្តាលនៃសេចក្តីជូនដំណឹងទាំងនេះ ត្រូវបានចុះផ្សាយនៅលើគេហទំព័រយឺតរហូតដល់១០ ទៅ៣៥ថ្ងៃ។ អាស្រ័យលើកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាស ប្រការនេះផ្តល់រយៈពេលតិចជាង១០ថ្ងៃ មុនពេលការដេញថ្លៃចាប់ផ្តើម។ ចំណុចនេះអាចជាការលំបាកសម្រាប់អ្នកដេញថ្លៃខ្លះក្នុងទទួលបានព័ត៌មានស្តីពីការដេញថ្លៃឲ្យបានទាន់ពេលវេលា ថ្វីបើសេចក្តីប្រកាសទាំងនេះអាចត្រូវបានផ្សព្វផ្សាយនៅលើក្តារព័ត៌មាននៃស្ថាប័ននីមួយៗដែលអនុវត្តលទ្ធកម្មសាធារណៈក្តី។ ជាជំហានដំបូង យើងខ្ញុំសូមអនុញ្ញាតស្នើសុំដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាបន្តឹងការអនុវត្តមាត្រា៤០ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលចែងថាសេចក្តីជូនដំណឹងស្តីពីបុរេលក្ខណសម្បត្តិ ការដេញថ្លៃ និងសេចក្តីកែសម្រួលនានា ត្រូវប្រកាសផ្សព្វផ្សាយតាមគេហទំព័រលទ្ធកម្មសាធារណៈ និងតាមសារព័ត៌មាន ហើយត្រូវបិទផ្សាយនៅលើក្តារព័ត៌មានរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។ អ្វីដែលគួរឲ្យសោកស្តាយ គឺការកំណត់ពេលវេលានៃការផ្សព្វផ្សាយសេចក្តីជូនដំណឹងនៅលើគេហទំព័រមិនត្រូវបានចែងនៅក្នុងមាត្រានេះទេ ដែលប្រការនេះពុំបានកំណត់នូវការតម្រូវតាមផ្លូវច្បាប់សម្រាប់ឲ្យក្រសួង/ស្ថាប័ននានាឆ្លើយតបទៅនឹងបញ្ហាផ្សព្វផ្សាយយឺតលើគេហទំព័រខាងលើ។

ការសង្កេតដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល លើសេចក្តីជូនដំណឹងអំពីការដេញថ្លៃលទ្ធកម្មសាធារណៈនៅក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងសប្តាហ៍ទី២ នៃខែឧសភា ឆ្នាំ២០១២ ឃើញថាសេចក្តីជូនដំណឹងទាំងឡាយដែលបានចុះផ្សាយមុនថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ ត្រូវបានដកចេញ ដោយអាចបណ្តាលមកពីការផុតកំណត់នៃកាលបរិច្ឆេទដេញថ្លៃ។ អង្គការមិនមែនរដ្ឋាភិបាល យល់ពីលក្ខណៈបច្ចេកទេសនៃការគ្រប់គ្រងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែទោះជាយ៉ាងណាក្តី យើងខ្ញុំសូមស្នើសុំឲ្យរក្សានូវសេចក្តីជូនដំណឹងទាំងនោះនៅលើគេហទំព័រ រហូតដល់ពេលគម្រោង ឬរយៈពេលផ្តល់សេវា ត្រូវបានបញ្ចប់ ឬក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ។ សេចក្តីជូនដំណឹងនិងការប្រគល់កិច្ចសន្យាគប្បីត្រូវរក្សាទុកជាមួយគ្នា ដើម្បីឲ្យសាធារណជនទូទៅអាចមើលឃើញនូវទំនាក់ទំនងរវាងឯកសារទាំងពីរ ក៏ដូចជាអាចធ្វើសវនកម្មសង្គមលើគុណភាព និងបរិមាណនៃសេវា ឬលទ្ធផលនៃគម្រោងលទ្ធកម្ម។ ប្រការនេះអាចគឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមនានារបស់រាជរដ្ឋាភិបាល ក្នុងការកែលម្អជំនឿរបស់សាធារណជន លើតម្លាភាពនៃប្រព័ន្ធលទ្ធកម្មសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងដោយហេតុនេះ ជម្រុញឲ្យប្រជាពលរដ្ឋបង់ពន្ធ ឬលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ។ ការដែលជំនឿសាធារណៈលើប្រព័ន្ធរបស់រាជរដ្ឋាភិបាលនៅមានកម្រិតទាប គឺត្រូវបានផ្តល់សក្ខីកម្មដោយការស្ទង់មតិតូចមួយជាមួយនិស្សិតសកលវិទ្យាល័យ ដែលធ្វើដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល កាលពីខែតុលា ឆ្នាំ២០១១ ស្តីពីជំនឿរបស់ពួកគេលើប្រសិទ្ធភាពនិងតម្លាភាពរបស់រាជរដ្ឋាភិបាល ក្នុងការប្រមូល និងគ្រប់គ្រងចំណូលពី

[13] សម្រាប់ព័ត៌មានលម្អិត សូមមើលយោបល់ជារួមរបស់អង្គការមិនមែនរដ្ឋាភិបាលលើសេចក្តីព្រាងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលអាចយកបានពីគេហទំព័ររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល (http://www.ngoforum.org.kh/eng/enallpublication.php)។

[14] តួលេខនេះត្រូវបានយកពីគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២ ប៉ុន្តែការមើលនៅថ្ងៃទី១០ ខែ ឧសភា ឆ្នាំ២០១២ បានបង្ហាញថាប្រហែលពាក់កណ្តាលនៃសេចក្តីជូនដំណឹងលទ្ធកម្មត្រូវបានលុបចេញ ជាពិសេសសេចក្តីជូនដំណឹងទាំងឡាយដែលបានប្រកាសមុនថ្ងៃទី១៥មីនា ឆ្នាំ២០១២។ គេមិនដឹងពីមូលហេតុនៃការលុបចេញនេះទេ និងថាតើសេចក្តីជូនដំណឹងអំពីការដេញថ្លៃទាំងនោះអាចរកបាននៅទីណា។

ឧស្សាហកម្មនិស្សារណកម្ម។ យ៉ាងហោចណាស់ ៦០% នៃអ្នកឆ្លើយចំនួន ៣៧៧នាក់ ដែលតំណាងឲ្យសកលវិទ្យាល័យ ឯកជនចំនួន៧ នៅរាជធានីភ្នំពេញ បានដាក់ពិន្ទុមធ្យម និងក្រោមមធ្យមចំពោះប្រសិទ្ធភាព និងតម្លាភាពនៃចំណូលពី ឧស្សាហកម្មនិស្សារណកម្មរបស់រាជរដ្ឋាភិបាល ខណៈដែលមានតែប្រហែលពី ១០% ទៅ ២០% ប៉ុណ្ណោះ ដែលបានដាក់ ពិន្ទុរាជរដ្ឋាភិបាលខ្ពស់នៅក្នុងការយល់ឃើញរបស់ពួកគេ។ តិចជាង ៣% បានផ្តល់ពិន្ទុខ្ពស់ខ្លាំង ខណៈដែលអ្នកនៅសល់ (ប្រហែល ១០%) បាននិយាយថាពួកគេមិនដឹង។

សមិទ្ធផលខាងលើគឺជាជំហានដ៏គួរឲ្យកត់សម្គាល់មួយ ដែលបានអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឆ្លើយតប នឹងចន្លោះប្រហោងនៃតម្លាភាពនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ។ ទោះជាយ៉ាងណាក្តីក៏ កិច្ចខិតខំប្រឹងប្រែងបន្ថែម ទៀតនៅតែជាការចាំបាច់ដើម្បីបំពេញចន្លោះប្រហោងនេះ។ នៅក្នុងរបាយការណ៍វឌ្ឍនភាពដដែល និងច្បាប់ស្តីពីលទ្ធកម្ម សាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ តាមរយៈសេចក្តីព្រាងអនុក្រឹត្យនេះ ក្រុមការងារនៃអង្គការមិនមែនរដ្ឋាភិបាល សូមអំពាវនាវដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ វត្ថុ មេត្តាអនុញ្ញាតឲ្យសាធារណជន ឬអង្គការសង្គមស៊ីវិលនានា បានចូលរួម ឬធ្វើសក្ខីភាព និងទទួលបានព័ត៌មានស្តីពីកិច្ច ដំណើរការលទ្ធកម្មសាធារណៈ ដូចជាការបើកឯកសារដេញថ្លៃ និងការប្រកាសលទ្ធផលដេញថ្លៃ ក៏ដូចជាព័ត៌មានទាក់ទិន នឹងការប្រគល់កិច្ចសន្យាជូនអ្នកដែលដេញថ្លៃឈ្នះ ដែលចំណុចទាំងអស់នេះគប្បីត្រូវបានចែងបន្ថែមទៀតនៅក្នុងអនុក្រឹត្យ នេះ។ បន្ថែមលើសេចក្តីជូនដំណឹង និងឯកសារដេញថ្លៃ ផែនការលទ្ធកម្មសាធារណៈគប្បីត្រូវបានផ្សាយជាសាធារណៈផង ដែរ។ ជាមួយនឹងការផ្សាយជាសាធារណៈនូវផែនការលទ្ធកម្ម និងការប្រគល់កិច្ចសន្យា សាធារណជនអាចចូលធ្វើសវនកម្មសង្គមលើគុណភាពនៃសេវាសាធារណៈដែលបានផ្តល់ ឬធ្វើសក្ខីកម្មលើតម្លាភាពនៃការ ដេញថ្លៃ ឬដំណើរការ លទ្ធកម្មសាធារណៈ។

គោលដៅទី២៥៖ កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដើម្បីធានាតម្លាភាព
ភាគទី២៖ ផែនការសកម្មភាពជំហានទី២ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី ២

គោលចំណង/ សកម្មភាព	សូចនាករគន្លឹះ (ឯកសារយោង PEFA)	គោលដៅ		
		ឆ្នាំ២០០៨	ឆ្នាំ ២០០៩	ឆ្នាំ ២០១០
...				
២៥. ៤. កែលម្អទម្រង់របាយការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន	ព័ត៌មានហិរញ្ញវត្ថុសំខាន់ៗអាចរកបាន៖ ឯកសារថវិកា របាយការណ៍អនុវត្តថវិកា ប្រចាំឆ្នាំ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍សវនកម្មផ្ទៃក្រៅ ការប្រគល់កិច្ចសន្យា ការផ្តល់ធនធានសម្រាប់ អង្គភាពសេវាមូលដ្ឋាន *(សូចនាករទី១០ នៃ PEFA)*	យ៉ាងហោចណាស់ត្រូវមានរបាយ-ការណ៍ ០៣ ក្នុងចំណោមរបាយការណ៍ទាំង ០៦	យ៉ាងហោចណាស់ត្រូវមានរបាយ-ការណ៍ ០៤ ក្នុងចំណោមរបាយការណ៍ទាំង ០៦	យ៉ាងហោចណាស់ត្រូវមានរបាយ-ការណ៍ ០៥ ក្នុងចំណោមរបាយការណ៍ទាំង ០៦

ប្រភព: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ទំព័រ៧៤ (ឯកសារភាសាខ្មែរ)

អង្គការមិនមែនរដ្ឋាភិបាល នៅតែកោតសរសើរខ្ពស់ដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុង ការផ្សព្វផ្សាយជាបន្តបន្ទាប់ និងជាប្រព័ន្ធនៅក្នុងប្រភពសាធារណៈ ពោលគឺគេហទំព័ររបស់ក្រសួង និងរាជកិច្ច នូវឯកសារ ថវិកាសំខាន់ៗដូចជា:

- សារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ថវិកា ត្រូវបានផ្សព្វផ្សាយនៅក្នុងរាជកិច្ច ក្នុងខែមេសា និងខែមិថុនា រៀងរាល់ឆ្នាំ
- តារាងប្រតិបត្តិការហិរញ្ញវត្ថុរាជរដ្ឋាភិបាលប្រចាំខែ និងប្រចាំឆ្នាំ
- ច្បាប់ថវិកាប្រចាំឆ្នាំដែលបានអនុម័តរួច
- ច្បាប់ស្តីពីការទូទាត់ថវិកាប្រចាំឆ្នាំដែលបានអនុម័តរួច ក្នុងរយៈពេលពីពីរទៅបីឆ្នាំក្រោយឆ្នាំសារពើពន្ធ
- របាយការណ៍សវនកម្មផ្ទៃក្រៅស្តីពីការអនុវត្តថវិកាឆ្នាំ២០០៦ និងឆ្នាំ២០០៧
- ប្រកាសស្តីពីចំណាត់ថ្នាក់សេដ្ឋកិច្ចថវិកាក្នុងឆ្នាំ២០០៧
- ព័ត៌មាន និងប្បញ្ញាត្តិផ្សេងទៀតស្តីពីថវិកា

តាមរយៈការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍អនុវត្តថវិកា (TOFE) ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ដែលមានលក្ខណៈកាន់តែពេញលេញ និងទាន់ពេលវេលា ប្រជាពលរដ្ឋនឹងទទួលបាននូវព័ត៌មាន និងបច្ចុប្បន្នកម្មទាន់ពេលវេលាអំពីការគ្រប់គ្រងថវិកាសាធារណៈរបស់រាជរដ្ឋាភិបាល និងអាចចូលរួមកាន់តែសកម្មឡើងនៅក្នុងដំណើរការថវិកា ក៏ដូចជាជម្រុញឲ្យរាជរដ្ឋាភិបាលមានគណនេយ្យភាពចំពោះថវិកា។ ការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការថវិកា អាចគឺជាកត្តាលើកមួយដែលជានាឲ្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែមានភាពជោគជ័យ។

រាជរដ្ឋាភិបាលកម្ពុជា បានផ្សព្វផ្សាយនូវព័ត៌មានស្តីពីការអនុវត្តថវិកាប្រចាំខែ និងប្រចាំឆ្នាំ នៅក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុរាជរដ្ឋាភិបាល (TOFE[15]) នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (www.mef.gov.kh) ចាប់តាំងពីឆ្នាំ២០០៩ មក។ តារាង TOFE ដែលកត់ត្រាតែតួលេខដុល ក៏ត្រូវបានបំពេញបន្ថែមផងដែរដោយ តួលេខប៉ាន់ស្មានបែងចែកតាមក្រសួងសាមីនៅក្នុងព្រឹត្តិបត្រស្ថិតិ [16] ប្រចាំខែដែលអាចរកជាវបានពីនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គេសង្កេតឃើញថា ព្រឹត្តិបត្រស្ថិតិប្រចាំខែនេះ ត្រូវបានរៀបចំឡើងទាន់ពេលវេលា ដែលព្រឹត្តិបត្រខែមីនា ឆ្នាំ ២០១២ ត្រូវបានចេញផ្សាយនៅក្នុងខែមេសា ឆ្នាំ២០១២។ យើងខ្ញុំបានជ្រាបថា តារាង TOFE ដែលផ្សព្វផ្សាយនៅលើគេហទំព័រ គឺជាឯកសារដែលទទួលបានការអនុម័តរួច ហើយការប្រមូលទិន្នន័យ ការផ្ទៀងផ្ទាត់ និងការសម្របសម្រួលតួរលេខថវិការវាងនាយកដ្ឋាននានាសម្រាប់ផ្សព្វផ្សាយនៅលើគេហទំព័រ គឺចាំបាច់ត្រូវការពេលវេលា។ យ៉ាងណាក្តី យើងខ្ញុំមានជំនឿថា ជាមួយនឹងការប្តេជ្ញាខាងផ្នែកគោលនយោបាយពីថ្នាក់គ្រប់គ្រងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការកំណត់ពេលសម្រាប់ការផ្សព្វផ្សាយនូវតារាង TOFE នៅពេលក្រោយនឹងត្រូវបានកែលម្អ ពីក្នុងរយៈពេលបីខែក្រោយខែអនុវត្ត មកពីរខែក្រោយខែអនុវត្ត។ លើសពីនេះទៀត យើងខ្ញុំក៏សង្ឃឹមផងដែរថាតួលេខអនុវត្តថវិកាបែងចែកតាមក្រសួងសាមីដែលមាននៅក្នុងព្រឹត្តិបត្រស្ថិតិប្រចាំខែ នឹងត្រូវបានអនុម័តដោយថ្នាក់គ្រប់គ្រងឲ្យផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងផងដែរ។

ការផ្ទៀងផ្ទាត់ដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល លើតួលេខបណ្តោះអាសន្ននៃការអនុវត្តថវិកាតាមក្រសួងសាមី បានបង្ហាញនូវភាពខុសគ្នាខ្លាំងពីតួលេខជាក់ស្តែងនៅក្នុងច្បាប់ទូទាត់ថវិកា ឬឯកសារគ្រប់គ្រងថវិកាជាតិភាគមួយៈច្បាប់ និងបទប្បញ្ញត្តិ។ ឧទាហរណ៍ តួលេខនៃការអនុវត្តថវិកាឆ្នាំ២០១០ សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចដែលបានរាយការណ៍នៅក្នុងព្រឹត្តិបត្រស្ថិតិគឺស្មើនឹង ៨៦៣% នៃវិភាជន៍ថវិកានៅក្នុងច្បាប់ថវិកា ខណៈដែលតួលេខដូចដែលត្រូវបានរាយការណ៍នៅក្នុងឯកសារគ្រប់គ្រងថវិកាឆ្នាំ២០១២ បានបង្ហាញថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចាយប្រហែល ១២៤% នៃវិភាជន៍ថវិការបស់ខ្លួននៅក្នុងឆ្នាំដដែល។ ភាពខុសគ្នានៃតួលេខដ៏ធំបែបនេះ អាចធ្វើឲ្យមានការបកស្រាយខុសលើការអនុវត្តថវិកា ឬភាពអាចទុកចិត្តបាននៃថវិកា តាមបណ្តាក្រសួង។ ក្នុងគោលបំណងបន្តប្រើប្រាស់តួលេខកាន់តែសុក្រឹត និងជាមួយនឹងការកោតសរសើរខ្ពស់ចំពោះគំនិតផ្តួចផ្តើមនៃព្រឹត្តិបត្រស្ថិតិនេះ យើងខ្ញុំសូមស្នើរសុំដោយអនុគ្រោះឲ្យមានការពិនិត្យពិច័យបន្ថែមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុនពេលផ្សព្វផ្សាយនូវតួលេខបណ្តោះអាសន្នទាំងនេះ។

---

[15] TOFE គឺជាអក្សរកាត់ពីពាក្យបារាំង 'Tableau d'Opération Financier d'Etat'។

[16] ឯកសារនេះមានតម្លៃ ២០,០០០ រៀល ឬ ៥ ដុល្លារអាមេរិកក្នុងមួយច្បាប់។

ចាប់តាំងពីការចាប់ផ្តើមការងារថវិកាក្នុងឆ្នាំ២០០៦ គេឃើញមានអវត្តមាននៃឯកសារណែនាំសម្រាយស្តីពីថវិកាជាតិដែលបោះផ្សាយដោយរាជរដ្ឋាភិបាល ដែលស្រដៀងគ្នាទៅនឹងសៀវភៅណែនាំអំពីថវិកាជាតិ ដែលបង្កើតឡើងដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលក្នុងឆ្នាំ២០០៧។ ជាការប្រតិបត្តិអភិបាលកិច្ចល្អ ឯកសារណែនាំសម្រាយនេះអាចជួយលើកកម្ពស់ឲ្យមានតំរូវការព័ត៌មានស្តីពីថវិកាពីសំណាក់សាធារណជន ជាពិសេសអ្នកដែលមិនបានដឹងច្រើនពីការងារថវិកា ដើម្បីឲ្យពួកគេអាចអាន និងយល់នូវខ្លឹមសារនៃឯកសារថវិកា និងចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការជម្រុញឲ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវលើការគ្រប់គ្រងថវិកា។ ម្យ៉ាងទៀត ពុំមានសទ្ទានុក្រម ឬវចនានុក្រម (ខ្មែរ) ស្តីពីពាក្យបច្ចេកទេសថវិកាដែលបានផ្សាយសម្រាប់សាធារណជន ដែលអាចលើកទឹកចិត្តឲ្យសាធារណជនចូលរួមក្នុងដំណើរការថវិកាឡើយ លើកលែងតែពាក្យគន្លឹះ និងបច្ចេកស័ព្ទថវិកាមួយចំនួនតូចដែលត្រូវបានពន្យល់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ១៤៤៨ ហសវ.ប្រ.ក ដែលត្រូវបានចេញផ្សាយនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ។ ឯកសារទាំងពីរនេះ លើកលែងតែឯកសារទាំងឡាយដែលវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល អាចមិនបានដឹង ប្រហែលគឺជាសទ្ទានុក្រម និងឯកសារណែនាំដែលមានផ្សាយជាសាធារណៈ សម្រាប់ជួយឲ្យអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋអាន និងយល់ពីចំណាត់ថ្នាក់ថវិកា ក៏ដូចជាសម្រាប់ដោះស្រាយចំណែកមួយនៃឧបសគ្គបច្ចេកទេសនៅក្នុងដំណើរការថវិកា។ ឧបសម្ព័ន្ធស្តីពីចំណាត់ថ្នាក់ថវិកាសម្រាប់ចំណូល និងចំណាយ ដែលភ្ជាប់នឹងប្រកាសនេះ ផ្តល់នូវការពិព័ណ៌នាសង្ខេបអំពីគោលបំណង នៃជំពូកថវិកាគណនី និងអនុគណនី នីមួយៗ ប៉ុន្តែឯកសារទាំងនេះ មិនមានបញ្ចូលនូវបច្ចេកស័ព្ទថវិកាទាំងអស់ដែលត្រូវបានប្រើនៅក្នុងដំណើរការថវិកាទេ។

យ៉ាងណាក្តី ឯកសារទាំងនេះក៏បង្ហាញយ៉ាងច្បាស់ផងដែរនូវកិច្ចខិតខំប្រឹងប្រែងមួយរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការធានាឲ្យបាននូវស្តង់ដារនៃចំណាត់ថ្នាក់ថវិកា និងប្លង់គណនីសម្រាប់ការអនុវត្តប្រកបដោយសង្គតិភាពតាមក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាដើម្បីកែលម្អ និងជួយសម្រួលដល់ទំនាក់ទំនងជាមួយសាធារណជនឲ្យមានប្រសិទ្ធភាព។ សំខាន់ជាងនេះទៀត តាមរយៈរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទីមួយឆ្នាំ២០១២ ស្តីពីការការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ គេក៏បានដឹងផងដែរថាសន្ទានុក្រមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានកំពុងរៀបចំ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល សង្ឃឹមថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តកិច្ចប្រឹងប្រែងនេះក្នុងការផ្សព្វផ្សាយនូវចំណាត់ថ្នាក់ថវិកា ឬប្លង់គណនីថ្មី និងឯកសារណែនាំស្តីពីថវិកាបន្ថែមទៀត និងជាពិសេសពន្លឿនការចេញផ្សាយនូវសន្ទានុក្រមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជំហានច្បាស់លាស់នេះ ប្រសិនបើអនុវត្តភ្លាម។ នឹងអាចជម្រុញឲ្យមានតួអង្គមិនមែនរដ្ឋាភិបាលសំខាន់ៗបន្ថែមទៀតនៅក្នុងដំណើរការថវិកា ក៏ដូចជាឲ្យក្រសួង/ស្ថាប័នសាមីមានសមត្ថភាពបន្ថែមទៀតក្នុងការពន្លឿនការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ លើសពីនេះទៀត យើងខ្ញុំមានជំនឿថាសទ្ទានុក្រមនេះ និង/ឬសៀវភៅណែនាំស្តីពីថវិកាជាតិ ឬថវិកាក្រសួងសាមី អាចបំពេញមុខងារជាកត្តាលើករមួយ និងលើកកម្ពស់តម្រូវការសាធារណៈសម្រាប់ព័ត៌មានស្តីពីថវិកានៅថ្នាក់ជាតិ (ថវិកាក្រសួងសាមី) និងថ្នាក់ក្រោមជាតិ (ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ និងឃុំ/សង្កាត់)។

ជាមួយនឹងព័ត៌មានពេញលេញ លម្អិត និងទាន់ពេលវេលា គេជឿជាក់ថាសាធារណជន និងភាគីពាក់ព័ន្ធនានាអាចវាយតម្លៃបានថាតើការអនុវត្តថវិការបស់ក្រសួងសាមីមានលក្ខណៈអាចទុកចិត្តបានយ៉ាងណា បើប្រៀបធៀបទៅនឹងវិភាជន៍ថវិកានៅក្នុងច្បាប់ថវិកា។ វាក៏បង្ហាញផងដែរពីការប្តេជ្ញារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះអាណត្តិរបស់ខ្លួននៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការលើកកម្ពស់កម្រិតនៃតម្លាភាពថវិកានៅកម្ពុជាតាមរយៈការកែលម្អទម្រង់របាយការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន។ *អង្គការមិនមែនរដ្ឋាភិបាល សូមអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា និងជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះជំហានវិជ្ជមានខាងលើ និងសង្ឃឹមថាតារាង TOFE ប្រចាំខែ និងប្រចាំឆ្នាំ (ដែលបានអនុម័ត) នឹងត្រូវបានផ្សព្វផ្សាយទាន់ពេលវេលានៅលើគេហទំព័រ ទន្ទឹមនឹងការផ្តល់ផងដែរនូវព័ត៌មានលម្អិតនៃការអនុវត្តថវិកាតាមក្រសួងសាមី។*

ក្នុងឆ្នាំ២០១០ អង្គការមិនមែនរដ្ឋាភិបាលបានសង្កេតឃើញថា របាយការណ៍វាយតម្លៃពាក់កណ្តាលឆ្នាំ ឬ របាយការណ៍ប្រចាំឆមាស ស្តីពីការអនុវត្តច្បាប់ថវិកាឆ្នាំ២០១០ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ជូនរដ្ឋសភា ក៏ត្រូវបានផ្សាយផងដែរនៅលើគេហទំព័ររបស់ក្រសួង។ ចំណុចនេះ គឺជាជំហានវិជ្ជមានមួយដែលគប្បីគួរបន្តជាប្រព័ន្ធ ដើម្បីធានាឲ្យបានថាការប្តេជ្ញារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការកែលម្អតម្លាភាពថវិកា ឬសម្រេចឲ្យបាននូវគោលដៅទី២៥ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើការកែលម្អទម្រង់របាយការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជននៅតែបន្ត។ អង្គការមិនមែនរដ្ឋាភិបាលជឿជាក់ថា មានតម្រូវការសាធារណៈច្រើនលើព័ត៌មានស្តីពីថវិកា ដោយយោងតាមបទពិសោធន៍នៃការធ្វើការសុន្ទនាតាមវិទ្យុ និងព្រឹត្តិការណ៍សាធារណៈផ្សេងទៀត។ អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចលើកកម្ពស់តម្រូវការនេះបន្ថែមទៀត តាមរយៈការផ្សាយរបាយការណ៍វាយតម្លៃពាក់កណ្តាលឆ្នាំនៅលើគេហទំព័ររបស់ក្រសួង ដោយប្រការនេះអាចមានចំណាយតិចតួច ឬក៏មិនមាន។

ការផ្សព្វផ្សាយឲ្យបានទាន់ពេលវេលា និងជាប្រព័ន្ធនូវសេចក្តីព្រាងច្បាប់ថវិកានៅក្នុងប្រភពសាធារណៈ ឬការផ្តល់ជូនតាមសំណើនូវឯកសារនេះ នឹងកែលម្អបានយ៉ាងច្រើននូវកម្រិតនៃតម្លាភាពថវិកានៅកម្ពុជា។

ផ្ទុយពីការដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់នូវសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១១ ក្នុងខែវិច្ឆិកា ឆ្នាំ២០១០ ដល់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១២ មិនត្រូវបានផ្តល់ទេនៅក្នុងឆ្នាំ២០១១ នៅពេលដែលឯកសារនេះត្រូវបានដាក់ជូនរដ្ឋសភាដើម្បីសុំការអនុម័ត ទោះបីជាមានការស្នើសុំច្រើនដងពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការទី២ នៃរដ្ឋសភាក្តី។ ប្រការនេះបណ្តាលឲ្យការវិភាគលើសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១២ សម្រាប់បង្ហាញជូនសមាជិកសភា និងព្រឹទ្ធសភា មិនអាចត្រូវបានធ្វើឡើងមុនការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះនៅរដ្ឋសភា នៅ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១១ ឡើយ។ នៅក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១០ ការវិភាគលើសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១១ របស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានសមាជិកសភា និងព្រឹទ្ធសភាស្វាគមន៍យ៉ាងទូលំទូលាយ និងវាយតម្លៃខ្ពស់។ ការវិភាគនេះបានផ្តល់នូវទស្សនៈរបស់អង្គការសង្គមស៊ីវិលលើវិភាជន៍ថវិកា និងការកំណត់អាទិភាពថវិកានៅក្នុងសេចក្តីព្រាងច្បាប់ថវិកា។

ដោយយល់ឃើញថា ការផ្សព្វផ្សាយឲ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ថវិកាមានការចំណាយហិរញ្ញវត្ថុតិចតួច ឬសឹងតែមិនមាន យើងខ្ញុំសូមស្នើសុំដល់រាជរដ្ឋាភិបាលកម្ពុជា មេត្តាប្រែក្លាយការប្តេជ្ញារបស់ខ្លួនចំពោះតម្លាភាពថវិកាឲ្យទៅជាការប្រតិបត្តិ ដោយផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១៣ និងឆ្នាំបន្តបន្ទាប់ទៀត នៅក្នុងប្រភពសាធារណៈ (ពោលគឺ តាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬផ្តល់ជូនតាមសំណើ) ក្នុងអំឡុងខែតុលា ឬខែវិច្ឆិកា នៃឆ្នាំ (យ៉ាងហោចណាស់ឲ្យបានពីរ ឬបីសប្តាហ៍ មុនសម័យប្រជុំសភាពេញអង្គដើម្បីពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ថវិកានេះ)។

ការធានាឲ្យបាននូវអភិបាលកិច្ចល្អនៅក្នុងដំណើរការថវិកា និងឯករាជ្យភាពរបស់អាជ្ញាធរសវនកម្មជាតិ តាមរយៈ ការផ្សព្វផ្សាយឲ្យបានទាន់ពេលវេលានូវរបាយការណ៍សវនកម្មផ្ទៃក្រៅ ក្នុងរង្វង់ពីរឆ្នាំក្រោយឆ្នាំសារពើពន្ធ។

នៅក្នុងគោលបំណងទី ២៥.៤ ស្តីពីការកែលម្អទម្រង់របាយការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាផ្សព្វផ្សាយរបាយការណ៍សវនកម្មផ្ទៃក្រៅ ការប្រគល់កិច្ចសន្យា និងធនធានដែលមានសម្រាប់អង្គភាពសេវាមូលដ្ឋានឲ្យបានត្រឹមឆ្នាំ២០១០។ ចាប់តាំងពីពេលនោះមក គេបានសង្កេតឃើញថារបាយការណ៍សវនកម្មផ្ទៃក្រៅលើការអនុវត្តថវិកាឆ្នាំ២០០៦ និងឆ្នាំ២០០៧ ត្រូវបានផ្សព្វផ្សាយរៀងគ្នាដោយអាជ្ញាធរសវនកម្មជាតិ ក្នុងខែកញ្ញា ឆ្នាំ២០០៩ និងខែតុលា ឆ្នាំ២០១១។ កាលកំណត់នៃការផ្សព្វផ្សាយរបាយការណ៍ទាំងពីរនេះ មានលក្ខណៈយឺតយ៉ាវឡើង ពីជិត ៣ឆ្នាំ ក្រោយដំណាច់ឆ្នាំសារពើពន្ធ ដល់ជិត ៤ឆ្នាំ។

ដោយផ្អែកលើនិយមន័យរបស់ ភាពជាដៃគូនៃថវិកាអន្តរជាតិ (IBP)[17] របាយការណ៍សវនកម្មផ្ទៃក្រៅដែលបានផ្សព្វផ្សាយដោយស្ថាប័នសវនកម្មកំពូល (ឧ. អាជ្ញាធរសវនកម្មជាតិ) គប្បីគួរស្ថិតក្នុងរង្វង់ពីរឆ្នាំក្រោយឆ្នាំសារពើពន្ធ។ ក្នុងករណីខាងលើនេះ របាយការណ៍សវនកម្មផ្ទៃក្រៅមិនត្រូវបានចាត់ទុកបានផ្សព្វផ្សាយជាសាធារណៈទេ។ ជាមួយចន្លោះពេលនេះ ប្រជាពលរដ្ឋមិនអាចដឹងបានទាន់ពេលអំពីប្រសិទ្ធផល និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទេ ហើយរបាយការណ៍ ដែលអាចប្រើបានសម្រាប់ជម្រុញឲ្យរាជរដ្ឋាភិបាលមានគណនេយ្យភាពលើការគ្រប់គ្រងមូលនិធិសាធារណៈ នឹងក្លាយទៅជាហួសកាលវេលា។ ស្នាដៃអនុវត្តរបស់ប្រទេសកម្ពុជានៅស្ថិតនៅឆ្ងាយខ្លាំងពីការប្រតិបត្តិល្អជាអន្តរជាតិ ដែលបានស្នើឡើងដោយអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។ ស្តង់ដារប្រតិបត្តិសម្រាប់ការដាក់របាយការណ៍សវនកម្មផ្ទៃក្រៅជូនស្ថាប័ននីតិប្បញ្ញត្តិ និងសាធារណជនតាមការកំណត់របស់អង្គការ OECD គឺស្ថិតក្នុងរង្វង់ប្រាំមួយខែក្រោយដំណាច់ឆ្នាំសារពើពន្ធ ខណៈដែល IMF កំណត់រយៈពេលមួយឆ្នាំក្រោយដំណាច់ឆ្នាំសារពើពន្ធ។

អង្គការមិនមែនរដ្ឋាភិបាលបានសង្កេតឃើញនូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ ដែលគេហទំព័ររបស់អាជ្ញាធរសវនកម្មជាតិ ត្រូវបានដាក់ឲ្យដំណើរការតាំងពីឆ្នាំ២០១១ មក។ ជាមួយគ្នានេះ របាយការណ៍សវនកម្មឆ្នាំ ២០០៦ ត្រូវបានចុះផ្សាយសម្រាប់សាធារណជនម្តងនៅលើគេហទំព័រនេះនាដើមឆ្នាំ២០១២ ប៉ុន្តែរបាយការណ៍នេះត្រូវបានដកចេញវិញនៅពេលស្វែរកម្តងទៀតនៅក្នុងខែមីនា ឆ្នាំ២០១២។ ប្រការនេះមិនមែនជាសញ្ញាវិជ្ជមានឡើយសម្រាប់អភិបាលកិច្ចល្អ និងតុល្យភាពអំណាចរវាងស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ ដោយសារតែកាលកំណត់នៃការផ្សព្វផ្សាយរបាយការណ៍សវនកម្ម មានលក្ខណៈកាន់តែយឺតយ៉ាវឡើងរួចទៅហើយ។

បើតាមទស្សនៈថវិកា យើងខ្ញុំក៏បានកត់សម្គាល់ឃើញផងដែរថាចំណែកនៃវិភាជន៍ថវិកាសម្រាប់អាជ្ញាធរសវនកម្មជាតិ នៅក្នុងច្បាប់ថវិកាមាននិន្នាការថយចុះពី ០.១៣% នៃថវិកាជាតិសរុបក្នុងឆ្នាំ២០០៦ ដល់ ០.០៦% ក្នុងឆ្នាំ ២០១២។ គិតតាមតួលេខជាក់ស្តែង ចំនួននេះបានកើនឡើងយ៉ាងតិចតួចពី ៥.៣៨១ លានរៀល ឬ ១,៣ លានដុល្លារអាមេរិក ទៅ ៦.៩៤៨ លានរៀល ឬ ១,៧ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ដែលកំនើននេះទំនងត្រូវបានប្រើប្រាស់ដើម្បីរក្សាការសន្យារបស់រាជរដ្ឋាភិបាលក្នុងការបង្កើនប្រាក់ខែមូលដ្ឋានប្រចាំឆ្នាំ ២០% ក៏ដូចជាដើម្បី ទប់ទល់នឹងអតិផរណា។ ទាំងតម្លៃជាភាគរយ និងជាតួលេខជាក់ស្តែងនេះ គឺស្រដៀងគ្នាទៅនឹងតួរលេខជាក់ស្តែងនៃការអនុវត្តថវិកាពីឆ្នាំ២០០៦ ដល់២០១១ ដែលថវិកានេះត្រូវបានប្រើប្រាស់សម្រាប់ចំណាយប្រតិបត្តិការ និងចំណាយរដ្ឋបាលរបស់អាជ្ញាធរសវនកម្មជាតិ ក្នុងរយៈពេលពេញមួយឆ្នាំ។ ដូចដែល បានលើកឡើងដោយអតីតអគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិក្នុងឆ្នាំ២០០៩ ផងដែរ អាជ្ញាធរសវនកម្មជាតិនៅមានវ័យក្មេង និងបាននឹងកំពុងប្រឈមមុខនឹងការលំបាកខាងហិរញ្ញវត្ថុ និងធនធានមនុស្សចាប់តាំងពីពេលបង្កើតឡើងក្នុងឆ្នាំ២០០០។ ការប្រៀបធៀបបានបង្ហាញថាថវិកាអាជ្ញាធរសវនកម្មជាតិ មានចំនួនស្ទើរតែបួនដងតិចជាងវិភាជន៍ថវិកា សម្រាប់អង្គភាពប្រឆាំងអំពើពុករលួយ ដែលត្រូវបានធ្វើឡើងជាលើកដំបូងនៅក្នុងច្បាប់ថវិកាឆ្នាំ២០១២ ដែលមានចំនួន ២២.១៤៥ លានរៀល ឬ ០.២១% នៃថវិកាជាតិសរុប។ ចំណែកថយចុះនេះ កំពុងបង្ហាញថាថវិការបស់អាជ្ញាធរសវនកម្មជាតិ អាចមិនអនុញ្ញាតឲ្យអាជ្ញាធរនេះពង្រីកសកម្មភាពសវនកម្មរបស់ខ្លួនឲ្យបានទូលំទូលាយនៅតាមក្រសួងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឡើយ។ អង្គការមិនមែនរដ្ឋាភិបាលសូមលើកទឹកចិត្តយ៉ាងខ្លាំងដល់រាជរដ្ឋាភិបាលកម្ពុជា មេត្តាបង្កើនវិភាជន៍ថវិកាជូនអាជ្ញាធរសវនកម្មជាតិ ឲ្យដល់កម្រិតមួយដែលអាចប្រៀបធៀបបានទៅនឹងវិភាជន៍ថវិការបស់អង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីធានាឲ្យបាននូវអភិបាលកិច្ចល្អ និងតុល្យភាពអំណាចរវាងស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ នៅក្នុងការគ្រប់គ្រងមូលនិធិសាធារណៈ ក៏ដូចជាធានាឲ្យបាននូវឯករាជ្យភាពរបស់អាជ្ញាធរសវនកម្មជាតិ។ ម្យ៉ាងទៀត យើងខ្ញុំក៏សូមលើកទឹកចិត្តផងដែរដល់រដ្ឋសភាមេត្តាធ្វើច្បាប់កំណត់ពីកម្រិតជាក់លាក់មួយនៃថវិកាសម្រាប់អាជ្ញាធរ

[17] ផ្អែកលើលទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១០ និងអង្កេតកាលពីឆ្នាំមុនៗ ក្របខ័ណ្ឌពេលវេលាពីរឆ្នាំនេះ គឺជាការប្រតិបត្តិអប្បបរមាដែលត្រូវបានសង្កេតឃើញនៅក្នុងប្រទេសស្ទើរតែទាំងអស់ដែលបានចូលរួមនៅក្នុងអង្កេតនេះ។ សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលគេហទំព័ររបស់អង្គការ IBP តាមរយៈ www.internationalbudget.org។

សវនកម្មជាតិ ដើម្បីធានាឲ្យបាននូវការបំពេញមុខងារប្រកបដោយប្រសិទ្ធភាព និងភាពពេញលេញរបស់អាជ្ញាធរនេះ ពោលគឺដូចគ្នានឹងការប្រតិបត្តិនៃមូលនិធិឃុំ/សង្កាត់ និងអង្គភាពប្រឆាំងអំពើពុករលួយ។ បើមិនមានការកំណត់តាមផ្លូវច្បាប់បែបនេះទេ នឹងមិនមានការធានាថាអាជ្ញាធរសវនកម្មជាតិនឹងមានធនធានគ្រប់គ្រាន់ជាប្រព័ន្ធក្នុងការបំពេញភារកិច្ចរបស់ខ្លួនទេ។

តាមការសង្កេត ច្បាប់ទូទាត់ថវិកាឆ្នាំ២០០៨ និងឆ្នាំ២០០៩ ត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា និងប្រកាសឲ្យប្រើដោយព្រះមហាក្សត្រក្នុងឆ្នាំ២០១១ ហើយច្បាប់ទូទាត់ថវិកាឆ្នាំ២០១០ ត្រូវបានអនុម័តដោយរដ្ឋសភាក្នុងឆ្នាំ ២០១២។ អង្គការមិនមែនរដ្ឋាភិបាលសូមអបអរសាទរចំពោះភាពប្រសើរឡើងដែលគួរឲ្យកត់សម្គាល់នៃកាលកំណត់ក្នុងការអនុម័តច្បាប់ទូទាត់ថវិកា ដែលសម្រេចបានក្នុងរយៈពេល ២ឆ្នាំ ក្រោយដំណាច់ឆ្នាំសារពើពន្ធ។ ដោយយោងតាមច្បាប់ស្តីពីសវនកម្ម សវនកម្មផ្ទៃក្រៅគឺត្រូវបានធ្វើឡើងលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ឬការអនុវត្តច្បាប់ថវិកា ហេតុដូចនេះ ជាមួយនឹងច្បាប់ទូទាត់ថវិកាទាំងបីដែលបានអនុម័តរួច របាយការណ៍សវនកម្មផ្ទៃក្រៅសម្រាប់ឆ្នាំ ២០០៨ ២០០៩ និង២០១០ គប្បីត្រូវបានផ្សព្វផ្សាយ (ដូចជាតាមរយៈគេហទំព័ររបស់អាជ្ញាធរសវនកម្មជាតិ) ឬផ្តល់ជូនតាមសំណើក្នុងឆ្នាំ២០១២ ឬយ៉ាងហោចណាស់ក្នុងអំឡុងពេលពីរឆ្នាំក្រោយដំណាច់ឆ្នាំសារពើពន្ធ។ យើងខ្ញុំជឿជាក់ថាថ្លៃចំណាយសម្រាប់ការផ្សព្វផ្សាយរបាយការណ៍គឺតិចតួច និងមិនគួរគឺជាឧបសគ្គចម្បងក្នុងការផ្សព្វផ្សាយរបាយការណ៍ទាំងនេះជាសាធារណៈទេ។

យោងតាមកិច្ចប្រជុំក្រុមការងារ TWG-PFM ក្នុងឆ្នាំ២០១១ និងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១១ អង្គការមិនមែនរដ្ឋាភិបាលសូមអបអរសាទរចំពោះវឌ្ឍនភាពដែលសម្រេចបានមកដល់ពេលបច្ចុប្បន្ននេះ និងបានជ្រាបដឹងពីបញ្ហាប្រឈម និងការប្តេជ្ញារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការសម្រេចបាននូវសមិទ្ធផលជាក់ស្តែង និងជំហានខាងមុខទៀត។ យ៉ាងណាក្តី តាមរយៈការសង្កេតរបស់យើងខ្ញុំតាំងពីឆ្នាំ២០១០មក មិនមានបច្ចុប្បន្នកម្ម ឬការរាយការណ៍ទាក់ទិននឹងការប្រគល់កិច្ចសន្យា និងធនធានដែលមាននៅតាមអង្គភាពសេវាមូលដ្ឋាន ជាពិសេសនៅក្នុងរបាយការណ៍វឌ្ឍនភាពឆ្នាំ ២០១១ ស្តីពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទេ លើកលែងតែឯកសារវិភាជន៍ថវិកាសម្រាប់ឃុំ/សង្កាត់ទាំងអស់នៅកម្ពុជាក្នុងឆ្នាំ២០១២ ដែលការអនុវត្តថវិកាទាំងនេះមិនត្រូវបានរាយការណ៍ទេ។ តាមការសង្កេតរបស់យើងខ្ញុំ ការប្រគល់កិច្ចសន្យាដែលនឹងត្រូវផ្សព្វផ្សាយ គប្បីគួរមានជាមួយគ្នានឹងការបញ្ចប់ស្រេចបាច់នៃគេហទំព័រលទ្ធកម្មសាធារណៈ។ យ៉ាងណាក្តី ខណៈដែលគេហទំព័រនេះនៅកំពុងត្រូវបានរៀបចំនៅឡើយ ដើម្បីបង្ហាញពីកម្រិតនៃការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះតម្លាភាពនៅក្នុងដំណើរការថវិកា ការប្រគល់កិច្ចសន្យាទាំងនោះក៏គប្បីត្រូវផ្សាយផងដែរតាមមធ្យោបាយផ្សេងទៀតដែលមានចំណាយតិចតួច (ពោលគឺ តាមរយៈទំព័រលទ្ធកម្មសាធារណៈ នៅក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬនៅក្នុងរាជកិច្ច)។ ***យើងខ្ញុំក៏សូមស្នើសុំផងដែរឲ្យមានការផ្សព្វផ្សាយនូវការប្រគល់កិច្ចសន្យា នៅក្នុងលទ្ធកម្មសាធារណៈ និងឧស្សាហកម្មនិស្សារណកម្ម (ដូចជា អាជ្ញាប័ណ្ណសម្រាប់ការរុករក និងការធ្វើអាជីវកម្មលើធនធានប្រេងកាតខុស្ន និងវ៉ី)***។ ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានសំខាន់ៗនៅក្នុងការប្រគល់កិច្ចសន្យា ដែលទាក់ទិននឹងគុណភាព និងបរិមាណនៃសេវា និងផលិតផល នឹងអនុញ្ញាតឲ្យប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចធ្វើសវនកម្មសង្គម និងរាយការណ៍អំពីទស្សនៈរបស់ប្រជាពលរដ្ឋលើសេវា និងផលិតផលសាធារណៈទាំងនោះ។

ក្នុងខែមេសា ឆ្នាំ២០១២ ឯកសារគ្រប់គ្រងថវិកាទាំង ៤ភាគ ដែលត្រូវបានផលិត និងផ្តល់ជូនតាមសំណើដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជារៀងរាល់ឆ្នាំ ត្រូវបានបំពេញបន្ថែមដោយឯកសារ ២ភាគទៀត ដែលរួមមានវិភាជន៍ថវិកាសម្រាប់ឃុំ/សង្កាត់ ខ័ណ្ឌ ស្រុក និងក្រុង ទាំងអស់នៅកម្ពុជា។ តាមទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាល វិភាជន៍ថវិកាសម្រាប់ឃុំ/សង្កាត់ទាំងអស់ អាចត្រូវបានចាត់ទុកថាជាគំនិតផ្តួចផ្តើមមួយនៃការផ្សព្វផ្សាយធនធានដែលមានសម្រាប់អង្គភាពសេវាមូលដ្ឋាន។ ប្រការនេះគឺជាជំហានជាក់ស្តែងមួយដែលបានធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ក្នុងការផ្សព្វផ្សាយជាសាធារណៈនូវវិភាជន៍ថវិកាសម្រាប់ថ្នាក់ក្រោមជាតិ ហើយយើងខ្ញុំសង្ឃឹមថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្សព្វផ្សាយនូវឯកសារទាំងពីរនេះ និងឯកសារគ្រប់គ្រងថវិកាភាគផ្សេងទៀតនៅលើគេហទំព័ររបស់ខ្លួន ដើម្បីអនុញ្ញាតឲ្យមានការទទួលបានយ៉ាងទូលំទូលាយជាសាធារណៈនូវព័ត៌មានស្តីពីថវិកា តាំងពីកម្រិតជាតិរហូតដល់ថ្នាក់មូលដ្ឋាន។ លើសពីនេះទៀត យើងខ្ញុំក៏សង្ឃឹមផងដែរថាជំហានដ៏សំខាន់នេះអាចត្រូវបានពង្រឹងតាមរយៈ

មធ្យោបាយទំនាក់ទំនងផ្សេងទៀតជាមួយសាធារណជន និងត្រូវបានពង្រីកទៅដល់វិស័យសំខាន់ៗផ្សេងទៀត ដូចជាសុខាភិបាល អប់រំ និងកសិកម្ម។ ព័ត៌មានស្តីពីធនធានដែលមានសម្រាប់អង្គភាពសេវាមូលដ្ឋានសម្រាប់វិស័យសុខាភិបាល គប្បីត្រូវបានដាក់ឲ្យអនុវត្តនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និង មន្ទីរពេទ្យថ្នាក់ខេត្ត និងថ្នាក់ជាតិ និងសម្រាប់វិស័យអប់រំ គប្បីត្រូវបានដាក់ឲ្យអនុវត្តនៅកម្រិតសាលារៀន។ ក្នុងករណីវិស័យកសិកម្ម ព័ត៌មានស្តីពីធនធានដែលមានគប្បីមាននៅកម្រិតស្រុក និងឃុំ ដែលតាមរយៈព័ត៌មាននេះ បុគ្គលិកផ្សព្វផ្សាយកសិកម្ម និងកសិករគប្បីត្រូវបានជូនព័ត៌មានអំពីធនធាន និងសេវាសាធារណៈអ្វីខ្លះដែលមានសម្រាប់ពួកគេ។

ការប្តេជ្ញាចំពោះការទទួលបាននូវទំនុកចិត្ត និងការកែលម្អតម្លាភាពថវិកា ក៏ត្រូវបានកំណត់យ៉ាងទូលាយផងដែរ ដោយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកថាខណ្ឌទី ២៨៩ និង ២៩០ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ បច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ ដែលផ្អែកជាសំខាន់លើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២។ កថាខណ្ឌ ២៩០ លើកឡើងថា ***"ការបង្កើនគណនេយ្យភាព និងការផ្តល់អំណាច នឹងត្រូវគាំទ្រដោយវិធានការជាច្រើន ដើម្បីកែលម្អប្រព័ន្ធព័ត៌មានវិទ្យា និងតម្លាភាព ស្តីពីអនុវត្តកាតព្វកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ស្ថាប័នទទួលថវិកានិងមន្ត្រីគ្រប់គ្រងថវិកា។"*** ជាការសង្កេតចុងក្រោយមួយលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្របខ័ណ្ឌពេលវេលានៃការសម្រេចនូវគោលដៅទាំងបីខាងលើ ហាក់បីដូចជាមានលក្ខណៈហួសពីកាលកំណត់ដែលបានកំណត់នៅក្នុង កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ដែលភាគច្រើនគឺត្រឹមឆ្នាំ២០១០។ គេបានសង្កេតឃើញថាពុំទាន់មានការធ្វើបច្ចុប្បន្នភាពណាមួយលើគោលដៅទាំងនោះនិងគោលដៅ ផ្សេងទៀតនៅក្នុងរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅឡើយទេ ដូចជាការ កំណត់នូវក្របខ័ណ្ឌពេលវេលាថ្មីមួយ សម្រាប់សម្រេចនូវគោលដៅទាំងនោះនៅក្នុងអំឡុងពេលអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២។ ដោយទទួលស្គាល់ពីបញ្ហាប្រឈម និងកិច្ចប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការដឹកនាំកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល សង្ឃឹមថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងដាក់បញ្ចូលវឌ្ឍនភាពទាក់ទិននឹងគោលដៅជាក់លាក់ទាំងនោះ និងសូចនាករ នៅក្នុងរបាយការណ៍វឌ្ឍនភាពស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាកំណត់នូវក្របខ័ណ្ឌពេលវេលា និងការប្តេជ្ញាដើម្បីសម្រេចគោលដៅទាំងនោះ។ យើងខ្ញុំមានជំនឿថាការធ្វើដូច្នេះ និងការសម្រេចបានគោលដៅទាំងអស់នេះ នឹងជួយធានាឲ្យបានប្រកដថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងទទួលបានជោគជ័យទាំងស្រុងមួយក្នុងការអនុវត្តដំណាក់កាលទីពីរនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៣. ទិសដៅអនាគតនៃការកែលម្អតម្លាភាពនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដើម្បីលើកស្ទួយបន្ថែមទៀតនូវជំនឿសាធារណៈលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ក៏ដូចជារួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា (ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងអាជ្ញាធរសវនកម្មជាតិ ដោយមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍នៅក្នុងក្រុមការងារ TWG-PFM សូមមេត្តាកំណត់ជាអាទិភាពនូវការសម្រេចបានតម្លាភាពថវិកាដោយ៖

1. ផ្សព្វផ្សាយរបាយការណ៍ ឬព្រឹត្តិបត្រតាមដានបំណុលប្រចាំត្រីមាស និងប្រចាំឆ្នាំ ឲ្យបានទាន់ពេលវេលានៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
2. បញ្ចប់ជាស្ថាពរនូវការរៀបចំគេហទំព័រលទ្ធកម្មសាធារណៈ។
3. ផ្សព្វផ្សាយការប្រគល់កិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈ និងឧស្សាហកម្មនិស្សារណកម្មតាមមធ្យោបាយទំនាក់ទំនងផ្សេង ទៀតជាមួយសាធារណជន ពោលគឺតាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរក្សាទុកសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃលទ្ធកម្មសាធារណៈដែលបានផ្សាយរហូតដល់ពេលចប់គម្រោង ឬក្នុងក្របខ័ណ្ឌពេលវេលាណាមួយជាក់លាក់។

4. ផ្សព្វផ្សាយ ឬបញ្ចេញព័ត៌មានស្តីពីធនធានដែលមាននៅតាមអង្គភាពសេវាមូលដ្ឋាននៅក្នុងវិស័យសុខាភិបាល អប់រំ និងកសិកម្ម ដូចដែលបានលើកឡើងជាក់លាក់ខាងលើ។
5. បង្កើនវិភាជន៍ថវិកាជូនអាជ្ញាធរសវនកម្មជាតិ យ៉ាងហោចណាស់ក្នុងចំនួនមួយប្រហាក់ប្រហែលនឹងថវិការបស់អង្គភាពប្រឆាំងអំពើពុករលួយក្នុងឆ្នាំ២០១២ ដើម្បីធានាឲ្យបាននូវតុល្យភាពអំណាចរវាងស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ។
6. ផ្សព្វផ្សាយរបាយការណ៍សវនកម្មឆ្នាំ២០០៨ ២០០៩ និង២០១០ នៅក្នុងប្រភពសាធារណៈ (ពោលគឺ តាមរយៈគេហទំព័ររបស់អាជ្ញាធរសវនកម្មជាតិ) ឲ្យបានមុនដំណាច់ឆ្នាំ២០១២ ដើម្បីឲ្យសាធារណជនអាចមើលឃើញថាតើរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងគ្រប់គ្រងមូលនិធិសាធារណៈយ៉ាងសមស្របឬទេ និងដើម្បីឲ្យពិន្ទុនៃតម្លាភាពថវិការបស់ប្រទេសកម្ពុជានៅក្នុងចំណាត់ថ្នាក់អន្តរជាតិបានប្រសើរឡើង ។
7. ផ្សព្វផ្សាយច្បាប់ថវិកា និងច្បាប់ទូទាត់ថវិកា ដែលបានអនុម័តហើយទាំងអស់នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[18]។
8. ដាក់បញ្ចូលតួលេខលម្អិតនៃការអនុវត្តថវិកាតាម ក្រសួងសាមី នៅក្នុងរបាយការណ៍ប្រចាំខែ របាយការណ៍វាយតម្លៃពាក់កណ្តាលឆ្នាំ ឬរបាយការណ៍ប្រចាំឆមាស និងតារាង TOFE ប្រចាំឆ្នាំស្តីពីការអនុវត្តច្បាប់ថវិកា និងកែលម្អកាលកំណត់នៃការផ្សព្វផ្សាយរបាយការណ៍ដែលបានអនុម័តហើយទាំងនេះ នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
9. លើកទឹកចិត្តឲ្យមានការចូលរួមជាសាធារណៈនៅក្នុងដំណើរការថវិកា តាមរយៈការបោះពុម្ពផ្សាយនូវសទ្ទានុក្រម ឬវចនានុ ក្រមថវិកា (ភាសាខ្មែរ) ឬសៀវភៅនៃនាំស្តីពីថវិការបស់ក្រសួងសាមី និងពន្លឿនការចេញផ្សាយនូវសទ្ទានុក្រមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
10. ផ្សព្វផ្សាយនូវរបាយការណ៍វឌ្ឍនភាពលម្អិតមួយ ស្តីពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ ដែលអាចដាក់បញ្ចូលនូវរបាយការណ៍វឌ្ឍនភាពស្តីពីគោលដៅជាក់លាក់ទាំងឡាយដែលបានលើកឡើងខាងលើ រួមជាមួយចំណុចខ្វះខាត និងការប្តេជ្ញាក្នុងការសម្រេចឲ្យបាននូវគោលដៅទាំងនេះ ក្នុងក្របខ័ណ្ឌពេលវេលាកំណត់ជាក់ លាក់មួយ។

ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីថវិកាខាងលើ នឹងអនុញ្ញាតឲ្យប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលអាចធ្វើសវនកម្មសង្គម ឬជួយពិនិត្យផលិតផល និងសេវាកម្ម សាធារណៈ ដែលផ្តល់ដោយក្រសួង/ស្ថាប័នសាមីរបស់រាជរដ្ឋាភិបាលកម្ពុជា ឬអ្នកម៉ៅការ។ ប្រការនេះ មានមុខងារមួយផ្នែកជាលំទ្ធខ័ណ្ឌចម្បងសម្រាប់ធានាតម្លាភាព ប្រសិទ្ធផល និងប្រសិទ្ធភាពថវិកានៅកម្ពុជា។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
លោក ឈិត សំអាត នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩ ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh គេហទំព័រ៖ www.ngoforum.org.kh និង www.cambodianbudget.org
អាសយដ្ឋាន៖ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

[18]មានតែច្បាប់ទូទាត់ថវិកាសម្រាប់ឆ្នាំ២០០៨ និង២០០៩ ប៉ុណ្ណោះដែលមាននៅលើគេហទំព័រមកដល់ត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ខណៈដែលច្បាប់មួយចំនួនធំទៀតទាំងពីឆ្នាំ១៩៩៤ រហូតដល់ឆ្នាំ២០០៩ អាចរកបានផងដែរនៅលើគេហទំព័ររបស់ នាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (http://www.tax.gov.kh/taxtypes.php)។

ការកែលម្អតម្លាភាពនៃព័ត៌មានហិរញ្ញប្បទាន និងសន្តតិភាពជាមួយប្រព័ន្ធជាតិ ដើម្បីសម្រេចបានទូវលទ្ធផលអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពឈានឡើង

១. សេចក្តីផ្តើម

នៅក្នុងបរិបទកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ (ដៃគូអភិវឌ្ឍន៍ /ម្ចាស់ជំនួយ) ផ្នែកឯកជន និងតួអង្គមិនមែនរដ្ឋ បានធ្វើការប្រឹងប្រែងច្រើនក្នុងការបោះជំហានទៅមុខចេញពីប្រសិទ្ធភាពហិរញ្ញប្បទាន ឆ្ពោះទៅកាន់ប្រសិទ្ធ ភាពអភិវឌ្ឍន៍ដែលទាក់ទិននឹងភាពជាដៃគូ និងតួនាទីរបស់ពួកគេក្នុងការទទួលបានជោគជ័យជាលទ្ធផលសម្រេចនានា។

ក្នុងឋានៈជាតួអង្គមិនមែនរដ្ឋមួយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) គឺជាអង្គការសមាជិកភាពមួយ ដែលត្រូវបានបង្កើតឡើងនៅដើមទសវត្សរ៍ ១៩៨០ ដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ក្នុងគោលបំណងធ្វើយុទ្ធនាការតស៊ូមតិដើម្បីបញ្ឈប់ការហាមឃាត់ជំនួយ ដែលត្រូវបានដាក់លើប្រទេសកម្ពុជានៅពេលនោះ។ បេសកកម្មរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល រួមមានការជួយសម្របសម្រួល និងផ្តល់ឱកាសជូនសមាជិកអង្គការមិនមែន-រដ្ឋាភិបាលជាបណ្តាញ អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ និងអង្គការសង្គមស៊ីវិលផ្សេងទៀត ដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងការសុន្ទនា ការពិភាក្សា និងការតស៊ូមតិខាងគោលនយោបាយ ជាមួយនិងដើម្បី ប្រជាជនក្រីក្រនិងងាយរងគ្រោះនៅកម្ពុជា។

ក្នុងឆ្នាំ ២០០៧ គម្រោងប្រសិទ្ធភាពជំនួយនៃកម្មវិធីអភិវឌ្ឍន៍នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ត្រូវបានបង្កើតឡើងដោយបណ្តាញពាណិជ្ជកម្ម និងសេដ្ឋកិច្ច។ គម្រោងនេះមានបំណងជម្រុញការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងយន្តការសម្របសម្រួលហិរញ្ញប្បទាន និងការសុន្ទនាអំពីប្រសិទ្ធភាពហិរញ្ញប្បទាន ព្រមទាំងប្រសិទ្ធភាពអភិវឌ្ឍន៍ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នៅកម្ពុជា ក៏ដូចជាតាមដានការគ្រប់គ្រងនិងការសម្របសម្រួលហិរញ្ញប្បទាន ដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។ ការងារនេះនឹងរួមចំណែកដល់ការធានាឲ្យបានថាហិរញ្ញប្បទានអន្តរជាតិកាន់តែមានលក្ខណៈសុខុដុមនីយកម្មនិងសម្របតាមអាទិភាពអភិវឌ្ឍន៍នានា និងនាំទៅដល់ការប្រើ ប្រាស់ហិរញ្ញប្បទាន កាន់តែប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលដើម្បីលទ្ធផលអភិវឌ្ឍន៍ (ពោលគឺ ការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍន៍ប្រកបដោយសមធម៌) នៅកម្ពុជា។ គម្រោងនេះក៏ធ្វើការដើម្បីគាំទ្ររាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ផងដែរ ឆ្ពោះទៅកាន់ការផ្តល់តម្លៃដល់និងការសម្រេចបាននូវភាពជាម្ចាស់របស់ប្រទេស និងគោលការណ៍ភាពជាដៃគូដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសអន្តរជាតិនានា ដូចជា សេចក្តីប្រកាសទីក្រុងប៉ារីស (PD) ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទាន (ឆ្នាំ២០០៥) ផែនការណ៍សកម្មភាពទីក្រុងអាក្រា (AAA-២០០៨) និងសេចក្តីថ្លែងការណ៍ស្តីពីលទ្ធផលក្រុងប៊ូសាន (ឆ្នាំ២០១១)។

ចាប់តាំងពីឆ្នាំ ២០០៩ គម្រោងបានចាប់ផ្តើមផ្តោតលើការងារស្រាវជ្រាវ[19] និងការងារតស៊ូមតិលើបញ្ហានានាជុំវិញតម្លាភាពហិរញ្ញប្បទាន ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងយន្តការសម្របសម្រួលហិរញ្ញប្បទាន និងលទ្ធផលអភិវឌ្ឍន៍។ គម្រោងនេះបានធ្វើការដើម្បីឲ្យមានការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នៅក្នុងការសុន្ទនានានា ជាមួយអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល ដើម្បីឆ្លុះបញ្ចាំងពីសេចក្តីប្រកាសអន្តរជាតិទាំងឡាយស្តីពីប្រសិទ្ធភាពហិរញ្ញប្បទាន (ពោលគឺ ការប្តេជ្ញាចំពោះតម្លាភាព និងគណនេយ្យភាព) និងសេចក្តីប្រកាសថ្នាក់ជាតិស្តីពីការបញ្ចេញហិរញ្ញប្បទានអភិវឌ្ឍន៍ជូនប្រទេសកម្ពុជា។

[19] ដើម្បីមើលឯកសារស្រាវជ្រាវទាំងនោះ សូមមើលគេហទំព័រនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល http://www.ngoforum.org.kh/eng/enpublications.php?docs=aepdoc

កថាខ័ណ្ឌ ៤៩ នៃសេចក្តីប្រកាសក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានចែងថា *"ម្ចាស់ជំនួយសន្យាថា: ផ្តល់ព័ត៌មានឲ្យបានទាន់ពេលវេលា ប្រកបដោយតម្លាភាព និងពេញលេញ ស្តីពីលំហូរហិរញ្ញប្បទានដើម្បីធ្វើឲ្យអាជ្ញាធរដៃគូអាចបង្ហាញរបាយការណ៍ថវិកាពេញលេញជូនស្ថាប័ននីតិបញ្ញត្តិ និងប្រជាពលរដ្ឋរបស់ខ្លួន"*។

កថាខ័ណ្ឌ ២៤ នៃផែនការណ៍សកម្មភាពទីក្រុងអាក្រា ពង្រឹងបន្ថែមលើសេចក្តីប្រកាសក្រុងប៉ារីសថា *"តម្លាភាព និងគណនេយ្យភាព គឺជាសមាសភាគចាំបាច់មិនអាចខ្វះបានសម្រាប់លទ្ធផលអភិវឌ្ឍន៍។ ...ក) យើងខ្ញុំនឹងធ្វើឲ្យជំនួយកាន់តែមានតម្លាភាព។ ប្រទេសកំពុងអភិវឌ្ឍនឹងសម្រួលការត្រួតពិនិត្យរបស់រដ្ឋសភា ដោយអនុវត្តតម្លាភាពកាន់តែច្រើនឡើងនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមានការផ្សព្វផ្សាយជាសាធារណៈនូវប្រាក់ចំណូល ថវិកាចំណាយ លទ្ធកម្ម និង សវនកម្ម។ ម្ចាស់ជំនួយនឹងផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានទៀងទាត់ ពិស្តារ និងទាន់ពេលវេលាស្តីពីបរិមាណ វិភាជន៍ និងនៅពេលណាដែលមានលទ្ធផលនៃចំណាយអភិវឌ្ឍន៍ដើម្បីជម្រុញឲ្យមានការធ្វើថវិកា គណនី និងសវនកម្មកាន់តែសុក្រឹតដោយប្រទេសកំពុងអភិវឌ្ឍន៍..."*។

កថាខ័ណ្ឌ ២៣ នៃភាពជាដៃគូក្រុងប៊ូសានដើម្បីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព អះអាងបន្ថែមទៀតនូវការប្តេជ្ញាខាងលើថា *"យើងនឹងធ្វើការដើម្បីកែលម្អការមានព័ត៌មាន និងលទ្ធភាពសាធារណៈក្នុងការទទួលព័ត៌មានស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងធនធានអភិវឌ្ឍន៍ផ្សេងទៀត ដោយកសាងលើការប្តេជ្ញារបស់យើងនៅក្នុងវិស័យនេះ។ ក្នុងន័យនេះ យើងខ្ញុំនឹង៖*

***ក)** ផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានទាំងស្រុងស្តីពីសកម្មភាពអភិវឌ្ឍន៍ដែលទទួលមូលនិធិសាធារណៈ ហិរញ្ញប្បទាន អាណត្តិនិងលក្ខខណ្ឌ និងវិភាគទាននៃសកម្មភាពទាំងនេះចំពោះលទ្ធផលអភិវឌ្ឍន៍ ដោយគោរពតាមកង្វល់ស្របច្បាប់អំពីព័ត៌មានដែលមានលក្ខណៈរសើបខាងពាណិជ្ជកម្ម។*

***ខ)** ក្នុងកម្រិតជាតិ យកចិត្តទុកដាក់លើការបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញប្បទានប្រកបដោយតម្លាភាព និងពង្រឹងសមត្ថភាពរបស់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីប្រើប្រាស់ព័ត៌មាននេះឲ្យបានកាន់តែប្រសើរឡើងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងដើម្បីជម្រុញគណនេយ្យភាព..."*។

ក្នុងឆ្នាំ២០១០ និង២០១១ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាបានផលិតរបាយការណ៍ស្រាវជ្រាវមួយស្តីពី"តម្លាភាពនៃព័ត៌មានស្តីពីជំនួយនៅកម្ពុជា: ការវាយតម្លៃលើសង្គតិភាពនៃកម្មវិធីវិនិយោគសាធារណៈ(PIP) និងមូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA Database)" និងព្រឹត្តិបត្រព័ត៌មានស្តីពី "លំហូរខ័ណ្ឌជំនួយនៃកម្ចីសម្បទានបរទេសសម្រាប់ប្រទេសកម្ពុជា"។ របាយការណ៍ស្រាវជ្រាវ[20] បង្ហាញពីរបកគំហើញជាក់ស្តែងទាក់ទិននឹងការប្តេជ្ញារបស់ដៃគូអភិវឌ្ឍន៍ និងប្រទេសទទួលហិរញ្ញប្បទានចំពោះតម្លាភាពហិរញ្ញប្បទានដែលនៅតែមានលក្ខណៈសមស្របសម្រាប់ពិចារណាដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ដើម្បីការកែលម្អនាពេលអនាគតចំពោះការរាយការណ៍ជូនសាធារណជននូវព័ត៌មានហិរញ្ញប្បទាន និងសង្គតិភាពនៃការរាយការណ៍ជាមួយនឹងថវិកាជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាជឿថា តម្លាភាពហិរញ្ញប្បទាននិងសង្គតិភាពកាន់តែច្រើននៅក្នុងប្រព័ន្ធជាតិ (ផែនការវិនិយោគសាធារណៈ PIP ថវិកាជាតិ និងការធ្វើផែនការជាតិ) គឺជាឈ្នាន់ដ៏សំខាន់ក្នុងការលើកទឹកចិត្តឲ្យមានការចូលរួមកាន់តែច្រើនឡើងពីអង្គការសង្គមស៊ីវិល និងរដ្ឋសភា។ បើគ្មានតម្លាភាពនិងសង្គតិភាពនៃព័ត៌មានហិរញ្ញប្បទាននៅក្នុងប្រព័ន្ធជាតិទេ សង្គមស៊ីវិលនិងរដ្ឋសភាមានការលំបាកក្នុងការចូលរួមក្នុងយន្តការសម្រប សម្រួលហិរញ្ញប្បទាន និងលំបាកក្នុងការជម្រុញឲ្យរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍មានគណនេយ្យភាពលើលទ្ធផលអភិវឌ្ឍន៍។

[20] សម្រាប់ព័ត៌មានទាំងស្រុងនិងព្រឹត្តិបត្រព័ត៌មាននេះ សូមមើលគេហទំព័ររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល៖ http://www.ngoforum.org.kh/eng/enpublications.php?docs=aepdoc

២. សូចនាករតាមដានរួមទី ២៖ ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ

ស្ថាប័នសម្របសម្រួល៖ ក្រុមប្រឹក្សាស្តារនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រុមការងារបច្ចេកទេស P&H
ស្ថាប័នអនុវត្ត៖ គ្រប់សាមីក្រសួង ដៃគូអភិវឌ្ឍន៍ ក្រុមការងារបច្ចេកទេស

លទ្ធផលរយៈពេលមធ្យម	ធាតុចេញ	សូចនាករធាតុចេញ	សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ
សុខដុមនីយកម្មនិងការតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ចូលរួមដល់ការសម្រេចគោលដៅនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដោយជំរុញលទ្ធផលក្នុងកម្រិតវិស័យ	អភិក្រមគ្រប់គ្រងតាមកម្មវិធីនិងភាពជាដៃគូក្នុងការអនុវត្តកម្មវិធីទូទាំងវិស័យចូលរួមក្នុងការកាត់បន្ថយភាពបែកខ្ញែកនិងបង្កើនភាពអាចទស្សន៍ទាយជាមុននៃហិរញ្ញប្បទានសហប្រតិបត្តិការ រួមមាន៖ ▪ ផែនការតាមវិស័យ ▪ ផែនការប្រតិបត្តិប្រចាំឆ្នាំ (រួមទាំងហិរញ្ញប្បទានសហប្រតិបត្តិការ) ▪ ការវាយតម្លៃសមត្ថភាព ▪ សូចនាករតាមដានរួមគ្នាស្តីពីហិរញ្ញប្បទានប្រតិបត្តិការ ▪ ការត្រួតពិនិត្យរួមដោយផ្អែកលើលទ្ធផល	១- ក. វិស័យដែលប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី - ទិន្នន័យមូលដ្ឋាន៖ ៧ - គោលដៅ៖១០ ខ. ធនធានដែលបានផ្តល់តាមអភិក្រមគ្រប់គ្រងទូទាំងវិស័យគិតជាភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិការ - ទិន្នន័យមូលដ្ឋាន៖ ២៨% (របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០) - គោលដៅ៖ ៥0% ២- កែលំអភាពអាចទស្សន៍ទាយជាមុននៃហិរញ្ញប្បទានសហប្រតិបត្តិការ ក. ភាពទស្សន៍ទានជាមុន៖ ក្របខ័ណ្ឌហិរញ្ញប្បទានណែនាំរយៈពេលមធ្យម +/- ១0% ខ. ដៃគូអភិវឌ្ឍន៍នីមួយៗ៖ ក្របខ័ណ្ឌហិរញ្ញប្បទានណែនាំរយៈពេលមធ្យម +/- ១៥% (ទិន្នន័យមូលដ្ឋានសម្រាប់ភាពទស្សន៍ទាយ ជាមុនសរុប =១0៤%) (ការអង្កេតតាមដាននៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសឆ្នាំ២00៨) ឬរបាយការណ៍ហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ ២00៨ ប្រសិនបើទាបខ្លាំងពេក	១- គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គជនា/គអក) នឹងផ្តល់ការសម្របសម្រួលដល់ក្រុមការងារ និងលេខាធិការដ្ឋាន (និងវគ្គបណ្តុះបណ្តាល) ២- គជនា/កអក ផ្តល់ការសម្របសម្រួលក្នុងការវាយតម្លៃសមត្ថភាពរបស់ក្រុមការងារ ឬក្រសួងតាមវិស័យ ៣- គជនា/ កអក ផ្តល់ការគាំទ្រសម្រាប់បង្កើតអភិក្រមគ្រប់គ្រងទូទាំងវិស័យនិងការអភិវឌ្ឍន៍សមត្ថភាព (រួមទាំងកិច្ចសហប្រតិបត្តិការបច្ចេកទេស) ដើម្បីកាត់បន្ថយភាពបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការនិងកែលម្អភាពអាចទស្សន៍ទាយជាមុន តាមរយៈការរៀបចំផែនការ /ការត្រួតពិនិត្យរួមគ្នា ៤- គជនា/កអក បន្តការងារស្តីពីការពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូ ៥- ក្រុមការងារភាពជាដៃគូ និងសុខដុមនីយកម្មនឹងដើរតួនាទីជាយន្តការត្រួតពិនិត្យ ៦- ក្រុមការងារភាពជាដៃគូ និងសុខដុមនីយកម្មផ្តល់ការគាំទ្រដល់ការសិក្សាស្តីពីការប្រើប្រាស់ប្រព័ន្ធជាតិ ៧- ដៃគូអភិវឌ្ឍន៍បញ្ជាក់យ៉ាងច្បាស់ពីការប្តេជ្ញាបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការនៅក្នុងឯកសារកម្មវិធីរបស់ខ្លួន

វឌ្ឍនភាពសង្កេតឃើញលើការអនុវត្តសូចនាករតាមដានរួម៖ ការជួយសម្រួលនៅក្នុងបណ្តាញក្រុមការងារបច្ចេកទេស និងយន្តការជួយត្រួតពិនិត្យគ្នា តាមរយៈក្រុមការងារបច្ចេកទេស P&H

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សូមវាយតម្លៃខ្ពស់ចំពោះគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) ដែលបានធ្វើការប្រឹងប្រែងច្រើនក្នុងការប្រែក្លាយការសន្យា ទៅជាការអនុវត្តជាក់ស្តែង ដោយការសន្យានោះត្រូវបានលើកឡើងនៅក្នុងគោលការណ៍កែសម្រួលស្តីពីតួនាទី និងមុខងាររបស់ក្រុមការងារបច្ចេកទេស (TWG) ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំទី១៨ នៃគណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) កាលពីថ្ងៃទី ២0 ខែ មេសា ឆ្នាំ២0១១ ។ រាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ បានទទួលយកតំណាងអង្គការមិនមែនរដ្ឋាភិបាលជាសមាជិកពេញសិទ្ធិនៅក្នុងក្រុមការងារបច្ចេកទេស និងផ្តល់ជូនពួកគេនូវឱកាស

សម្រាប់អភិវឌ្ឍសមត្ថភាពនៅក្នុងការគ្រប់គ្រងហិរញ្ញប្បទាន។ លើសពីនេះទៀត CRDB/CDC បានអញ្ជើញតំណាងពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងអង្គការម៉េឌីខាំ (MEDiCAM) ឲ្យចូលរួមក្នុងវិបស្សនាក្រុមការងារបច្ចេកទេស និងកិច្ចប្រជុំអន្តរក្រុមការងារបច្ចេកទេសស្តីពី "ការជម្រុញការប្រើប្រព័ន្ធរបស់ប្រទេស" នៅខេត្តសៀមរាបក្នុងខែមេសា និង ខែឧសភា ឆ្នាំ២០១១។ តំណាងអង្គការមិនមែនរដ្ឋាភិបាលបីរូបនៅក្នុងក្រុមការងារបច្ចេកទេស-ភាពជាដៃគូនិងសុខុដុមនីយកម្ម ក៏បានចូលរួមផងដែរនៅក្នុងវិបស្សនាក្រុមការងារបច្ចេកទេស ដែលបានរៀបចំដោយ CRDB/CDC នៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧-២៨ ខែកុម្ភៈ ឆ្នាំ២០១២។ នៅក្នុងកិច្ចប្រជុំទាំងនេះ តំណាងអង្គការមិនមែនរដ្ឋាភិបាលអាចយល់ដឹងពីវឌ្ឍនភាព និងយល់ស៊ីជម្រៅអំពីបញ្ហានានានៅតាមក្រុមការងារបច្ចេកទេស និងកំណត់លទ្ធភាពសម្រាប់ឲ្យអង្គការមិនមែនរដ្ឋាភិបាល ចូលរួមឲ្យបានកាន់តែសកម្មនិងកាន់តែប្រកបដោយការទទួលខុសត្រូវនៅក្នុងយន្តការទាំងនេះ។ យ៉ាងណាមិញ អង្គការសមាជិកភាព (រួមមានអង្គការNGO Forum អង្គការCCC និង អង្គការMEDiCAM) បានសម្តែងនូវការសោកស្តាយ ដោយCRDB/CDC មិនបានអញ្ជើញអង្គការទាំងនោះឲ្យចូលរួមក្នុងវិបស្សនាក្រុមការងារបច្ចេកទេសនាពេលថ្មីៗ ស្តីពីការរៀបចំសូចនាករតាមដានរួមដែលបានប្រារព្ធធ្វើក្នុងខេត្តព្រះសីហនុ កាលពីខែសីហា ឆ្នាំ២០១២កន្លងទៅ។ ក្នុងកិច្ចជំនួបបន្ទាប់ពីវិបស្សនានាពេលថ្មីៗនោះ CRDB/CDCបានបញ្ជាក់ពីមូលហេតុថា របៀបវារៈរបស់វិប្បនាមានភាពសមស្របច្រើនជាមួយនឹងក្រុមការងារបច្ចេកទេសតាមវិស័យ និងដៃគូអភិវឌ្ឍន៍ ដែលកំពុងធ្វើការបញ្ចប់សូចនាករ តាមដានរួម ឆ្នាំ២០១២ ដោយគោរពតាមគោលការណ៍គ្រប់គ្រងស្តីពីលទ្ធផលអភិវឌ្ឍន៍។ ការមិនបានអញ្ជើញអង្គការសមាជិកភាព មិនមានន័យថា អង្គការសមាជិកភាពនឹងទំនងជាត្រូវបានលើកឈ្មោះចេញពីវិបស្សនាក្រុមការងារបច្ចេកទេសនោះឡើយ ដោយរាជរដ្ឋាភិបាលបានទទួលស្គាល់ និងបញ្ជាក់សារជាថ្មីពីតួនាទីសំខាន់របស់សង្គមស៊ីវិលក្នុងនាមជា អ្នកចូលរួមដ៏មានសារៈសំខាន់ក្នុងកិច្ចការអភិវឌ្ឍប្រទេស។ តាមរយៈនេះ អង្គការសមាជិកភាពសូមស្នើសុំចំពោះរបៀបវារៈ ឲ្យមានភាពចូលរួមបន្ថែមទៀត សម្រាប់វិបស្សនាក្រុមការងារបច្ចេកទេសនាពេលបន្ទាប់ ដែលអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល អាចលើកស្ទួយគោលការណ៍គ្រប់គ្រងស្តីពីលទ្ធផលអភិវឌ្ឍន៍ ដើម្បីជាប្រយោជន៍ដល់អ្នក ក្រីក្រ និងងាយរងគ្រោះនៅឯថ្នាក់មូលដ្ឋាន។

ការរាប់បញ្ចូលតំណាងអង្គការមិនមែនរដ្ឋាភិបាលដោយ CRDB/CDCកាលពីពេលកន្លងមក បានឆ្លុះបញ្ចាំងការជួយសម្រួលដ៏ល្អសម្រាប់បណ្តាញក្រុមការងារបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពរបស់ក្រុមការងារបច្ចេកទេស។ យ៉ាងណាមិញ អង្គការមិនមែនរដ្ឋាភិបាល[21] សូមស្នើសុំពង្រីកការអញ្ជើញបន្ថែមទៀត ដោយស្នើសុំអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាលយ៉ាងហោចណាស់មួយរូបនៅក្នុងក្រុមការងារបច្ចេកទេសនីមួយៗ ឲ្យចូលរួមនៅក្នុងវិបស្សនាក្រុមការងារបច្ចេកទេស និងការកសាងសមត្ថភាព។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាសូមវាយតម្លៃខ្ពស់ចំពោះ CRDB/CDC ដែលបានផ្តល់វាគ្មិនមួយរូបដើម្បីធ្វើបទបង្ហាញជាក់ស្តែងមួយអំពីបញ្ញត្តិនៃប្រសិទ្ធភាពហិរញ្ញប្បទាន ប្រវត្តិ និងនិន្នាការនៅក្នុងបរិបទពិភពលោក ព្រមទាំងនិន្នាការនៅក្នុងស្រុក។ យើងខ្ញុំជឿថាប្រការនេះ គឺជាជម្រើសមួយទៀតដែលអង្គការមិនមែនរដ្ឋាភិបាល អាចទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន ហើយយើងខ្ញុំសង្ឃឹមថាការចែករំលែកចំណេះដឹងបែបនេះអាចបំពេញចន្លោះប្រហោងនៃទំនាក់ទំនងនិងចំណេះដឹងរវាងអង្គការមិនមែនរដ្ឋាភិបាល និងសាមីក្រសួង/ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍទាក់ទិននឹងយន្តការសម្របសម្រួលហិរញ្ញប្បទាននៅកម្ពុជា។ យើងខ្ញុំសូមជម្រុញការចែករំលែក ចំណេះដឹងនេះបន្តទៀត ហើយសូមពង្រីកបន្ថែមនូវការចែករំលែកចំណេះដឹងនេះផ្សារភ្ជាប់នឹង ចំណេះដឹងក៏ដូចជាបញ្ញត្តិបច្ចេកទេសកាន់តែស៊ីជម្រៅថែមទៀត ទាក់ទិននឹងការបកស្រាយនិងការសម្របទៅតាមសេចក្តីប្រកាសហិរញ្ញប្បទានអន្តរជាតិឲ្យស្របនឹងបរិបទកម្ពុជាដូចជា អភិក្រមផ្អែកលើកម្មវិធី(PBA) និងគ្លីនិក(PBA)ជាដើម។ យើងខ្ញុំជឿថាប្រការនេះនឹងរួមចំណែកដល់ការជួយសម្រួលបន្ថែមទៀតដល់បរិស្ថានអំណោយផល ដោយអាចអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលចូលរួមក្នុងកិច្ចដំណើរការសម្របសម្រួលហិរញ្ញប្បទាន ដើម្បីផលប្រយោជន៍និងអត្ថប្រយោជន៍រួមរបស់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេស

[21] អង្គការមិនមែនរដ្ឋាភិបាល" សំដៅលើអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យដែលគឺជាតំណាងនៅក្នុងក្រុមការងារបច្ចេកទេសទាំង ១៥។

ក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះ ដែលត្រូវការយ៉ាងខ្លាំងនូវកិច្ចប្រឹងប្រែងបែបប្រមូលផ្តុំ និងការសម្របសម្រួលរបស់យើងខ្ញុំ។

ដើម្បីកាត់បន្ថយភាពបែកខ្ញែក និងបង្កើនភាពអាចទស្សន៍ទាយជាមុនតាមរយៈដំណើរការធ្វើផែនការ/កិច្ចត្រួតពិនិត្យរួម CRDB បានធ្វើការយ៉ាងល្អជាមួយក្រុមការងារបច្ចេកទេស-ភាពជាដៃគូនិងសុខុដុមនីយកម្ម (TWG-P&H) ឲ្យបំពេញមុខងារជាយន្តការជួយត្រួតពិនិត្យ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការ MEDiCAM ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំរបស់ TWG-P&H ជាលើកទីមួយជាសមាជិកពេញសិទ្ធិ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ ក្រោយពេលមានសំណើសុំចូលជាសមាជិករបស់យើងខ្ញុំ។ ចំណុចនេះទទួលបានការវាយតម្លៃខ្ពស់ពីអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ដែលពួកគេអាចទទួលអត្ថប្រយោជន៍ដោយប្រយោលផងដែរ ពីការចែករំលែកព័ត៌មានដែលត្រូវបានបង្កើតដោយវិធីនេះ។ កិច្ចប្រជុំក្រុមការងារបច្ចេកទេស TWG-P&H ពិភាក្សាជាចម្បងលើរបាយការណ៍ប្រសិទ្ធភាពអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១១ ដែលឆ្លុះបញ្ចាំងលទ្ធផលជាក់ស្តែងកាន់តែច្រើនឡើង ជាជាងបញ្ហាត្តិនៃប្រសិទ្ធភាពហិរញ្ញប្បទាន។ ការចូលរួមនេះអនុញ្ញាតឲ្យវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការMEDiCAM ទទួលបាននូវព័ត៌មានមានប្រយោជន៍ និងជាយុទ្ធសាស្ត្រ ទាក់ទិននឹងការចាត់ចែងយន្តការសម្របសម្រួលហិរញ្ញប្បទាន ទាំងនៅកម្រិតក្នុងស្រុក និងកម្រិតអន្តរជាតិ។

ចំណុចគួរបំពេញបន្ថែមដែលសង្កេតឃើញនៅក្នុងការអនុវត្តសូចនាករតាមជានរួម៖ តម្លាភាពនៃព័ត៌មាន ស្តីពីហិរញ្ញប្បទាន

ដោយមានការកែលម្អច្រើនក្នុងរយៈពេលពីរបីឆ្នាំកន្លងមកនេះ មូលដ្ឋានទិន្នន័យODA (ជាប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធព័ត៌មានស្តីពីហិរញ្ញប្បទានដ៏ទៃទៀត) បានផ្តល់នូវអត្ថប្រយោជន៍ និងបង្ហាញពីការអនុវត្តជាក់ស្តែង ដល់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងសាធារណជនទូទៅ ដែលប្រើប្រាស់ព័ត៌មានស្តីពីហិរញ្ញប្បទាន។ ទោះបីជាមានភាពប្រសើរឡើងច្រើនចំពោះព័ត៌មានស្តីពីហិរញ្ញប្បទានក្រោយពេលបង្កើតមូលដ្ឋានទិន្នន័យ ODA នេះក្តី ក៏គេនៅតែឃើញមានភាពចាំបាច់ត្រូវការកិច្ចប្រឹងប្រែងបន្ថែមទៀត ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ក្នុងការធ្វើឲ្យមូលដ្ឋានទិន្នន័យ ហិរញ្ញប្បទានODA កម្មវិធីវិនិយោគសាធារណៈ(PIP) និងច្បាប់ថវិកាជាតិកាន់តែមានសង្គតិភាព និងតម្លាភាព។

របាយការណ៍ស្រាវជ្រាវមួយស្តីពី "តម្លាភាពនៃព័ត៌មានស្តីពីជំនួយនៅកម្ពុជា: ការវាយតម្លៃលើសង្គតិភាពនៃកម្មវិធីវិនិយោគសាធារណៈ (PIP) និងមូលដ្ឋានទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA Database)[22] បានរកឃើញថាមានកង្វះសង្គតិភាពនៃព័ត៌មានស្តីពីហិរញ្ញប្បទាន ដែលត្រូវបានកត់ត្រានៅក្នុងកម្មវិធីវិនិយោគសាធារណៈ និងមូលដ្ឋានទិន្នន័យ ODA ដែលបញ្ហានេះប្រហែលជាកើតមានឡើងដោយសារការប្រើប្រព័ន្ធនិងនីតិវិធីខុសគ្នារបស់មូលដ្ឋានទិន្នន័យទាំងពីរ។ ជាក់ស្តែង កម្មវិធីវិនិយោគសាធារណៈកត់ត្រានិងកំណត់អាទិភាពគម្រោងវិនិយោគសាធារណៈ ខណៈដែលមូលដ្ឋានទិន្នន័យ ODA កត់ត្រាគម្រោងទាំងអស់ដែលត្រូវបានធ្វើបច្ចុប្បន្នភាពដោយដៃគូអភិវឌ្ឍន៍ ហើយចំណុចនេះបាននាំទៅដល់ប្រការដែលថា មូលដ្ឋានទិន្នន័យ ODA មានគម្រោងច្រើនជាងកម្មវិធីវិនិយោគសាធារណៈ។ នៅក្នុងចំណោមគម្រោងសកម្មទាំង១៥១ នៅក្នុងកម្មវិធីវិនិយោគសាធារណៈ និង គម្រោងសកម្មទាំង២៧៧ ដែលត្រូវបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យ ODA សម្រាប់ឆ្នាំ ២០១០ គម្រោងចំនួន ៦៧ មានព័ត៌មានដូចគ្នានៅក្នុងមូលដ្ឋានទិន្នន័យនីមួយៗ។ មានការរកឃើញថែមទៀតថា នៅពេលដែលគម្រោងត្រូវបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យទាំងពីរ គម្រោងរួមភ្លាយជាខុសគ្នាលើឈ្មោះគម្រោង ចិរវេលា និងតំបន់គោលដៅ។ ភាពខុសគ្នាទាំងនេះនៅក្នុងឈ្មោះ និងចិរវេលាសម្រាប់គម្រោងតែមួយ គឺប្រហែលជាដោយសារសាមីក្រសួង (LMs) មិនបានចុះព័ត៌មានគម្រោងទាំងអស់ ពីក្នុងកិច្ចព្រមព្រៀងរវាងសាមីក្រសួង និងដៃគូអភិវឌ្ឍន៍។ ទម្រង់ខុសគ្នានៃការកត់ត្រា (ពោលគឺការចុះលេខកូដគម្រោង និងប្រភពផ្តល់មូលនិធិ) រវាងមូលដ្ឋានទិន្នន័យទាំងពីរ ធ្វើឲ្យ

[22] សម្រាប់របកគំហើញលម្អិត សូមមើលរបាយការណ៍ទាំងស្រុងដែលអាចទាញយកបានពីអាស័យដ្ឋានគេហទំព័រខាងលើ។

មានការលំបាកដល់ការតាមដានដោយអង្គការសង្គមស៊ីវិលលើគម្រោងពាក់ព័ន្ធ ដែលត្រូវបានកត់ត្រាក្រោមសាមីក្រសួងនៅក្នុងច្បាប់ថវិកា កម្មវិធីវិនិយោគសាធារណៈ និងមូលដ្ឋានទិន្នន័យODA។ ការចុះលេខកូដគម្រោង និងប្រភពផ្តល់មូលនិធិខុសគ្នា នៅក្នុងការរាយការណ៍ដោយមូលដ្ឋានទិន្នន័យ ODA (ដែលប្រើអភិក្រមយកម្ចាស់ជំនួយ ជាមូលដ្ឋាន) និង ការចុះលេខកូដគម្រោងនិងប្រភពផ្តល់មូលនិធិសម្របសម្រួលនៅក្នុងការរាយការណ៍ដោយកម្មវិធីវិនិយោគសាធារណៈ (ដែលប្រើអភិក្រមយកគម្រោងក្រោមសាមីក្រសួងនីមួយៗ ជាមូលដ្ឋាន) អាចនាំឲ្យមានភាពច្របូកច្របល់សម្រាប់អ្នកប្រើសាធារណៈលើមូលដ្ឋានទិន្នន័យទាំងពីរ ឬនាំឲ្យមានការវិនិច្ឆ័យខុសដោយពួកគេ លើកង្វះសង្គតិភាពក្នុងមូលដ្ឋានទិន្នន័យទាំងពីរ។

ម្យ៉ាងទៀត ការវិភាគមួយលើព្រឹត្តិបត្រព័ត៌មានស្តីពីលំហូរជំនួយនៃកម្ចីសម្បទានបរទេសសម្រាប់ប្រទេសកម្ពុជា (ទិន្នន័យត្រូវបានទាញយកនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១) បានរកឃើញថានៅក្នុងចំណោមគម្រោងប្រាក់កម្ចីសម្បទានចំនួន ១៨៣ គម្រោងចំនួន៣៧ (រួមមានគម្រោងគ្រោងចំនួន ៨) មិនមានព័ត៌មានស្តីពីអត្រាការប្រាក់ ឬប្រភេទអត្រាការប្រាក់ ឬរយៈពេលអនុគ្រោះ ឬរយៈពេលសង។ នៅក្នុងចំណោមគម្រោងទាំង៣៧នេះ គម្រោងចំនួន១៩មិនមានព័ត៌មានអំពីអត្រាការប្រាក់ គម្រោងចំនួន១៣មិនមានព័ត៌មានអំពីប្រភេទដែលថា តើវាជាអត្រាការប្រាក់មិនប្រែប្រួលឬប្រែប្រួល គម្រោងចំនួន ២៨មិនមានព័ត៌មានអំពីរយៈពេលអនុគ្រោះ និងគម្រោងចំនួន២៧មិនមានព័ត៌មានអំពីរយៈពេលសង។ ថ្វីបើព័ត៌មាននេះឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែង រួមទាំងការប្តេជ្ញាខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ក្នុងការផ្តល់ព័ត៌មានជូនសាធារណជនអំពីបំណុលពីក្រៅប្រទេសក៏ដោយ ក៏បញ្ហាខាងលើបង្ហាញពីកង្វះព័ត៌មានពេញលេញទាក់ទិននឹងកម្ចីសម្បទានបរទេសសម្រាប់ប្រទេសកម្ពុជា។ ចំណុចនេះគប្បីទទួលការយកចិត្តទុកដាក់បន្ថែមទៀតដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។ ឆ្លៀតឱកាសនេះ អង្គការមិនមែនរដ្ឋាភិបាលសូមសំដែងនូវការកោតសរសើរខ្ពស់ដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការមានឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលឆ្នាំ ២០១១-២០១៨ ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ និងការផ្សព្វផ្សាយសេចក្តីសង្ខេបនៃឯកសារយុទ្ធសាស្ត្រនេះនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណុចនេះគឺជាដំណើរឆ្ពោះទៅមុខដ៏ល្អមួយក្នុងការបង្កើនកម្រិតនៃតម្លាភាពថវិកានៅកម្ពុជា ក៏ដូចជាការធានាឲ្យបាននូវការគ្រប់គ្រងបំណុលប្រកបដោយនិរន្តរភាព។

នៅក្នុងសិក្ខាសាលាស្តីពី "តម្លាភាពនៃព័ត៌មានស្តីពីជំនួយ និងលទ្ធផលអភិវឌ្ឍន៍នៅកម្ពុជា" កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ គួរកត់សម្គាល់ថា តំណាងមួយរូបពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអះអាងថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនប្រើមូលដ្ឋានទិន្នន័យ CRDB/CDC ជាមូលដ្ឋានទេ ទាក់ទិននឹងទិន្នន័យប្រាក់កម្ចី ហើយចំណុចនេះមិនមែនមានន័យថាមូលដ្ឋានទិន្នន័យODA មិនមានភាពត្រឹមត្រូវនោះទេ។ លោកបានបន្តជំរាបជូនអ្នកចូលរួមសិក្ខាសាលាថាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានផែនការបោះផ្សាយព្រឹត្តិបត្របំណុលមួយដើម្បីផ្តល់ព័ត៌មាន និងធ្វើបច្ចុប្បន្នភាពជូនសាធារណជនអំពីស្ថានភាពបំណុលសាធារណៈនៅកម្ពុជា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាស្វាគមន៍ការសន្យានេះ និងសង្ឃឹមថានឹងឃើញការផ្សព្វផ្សាយព្រឹត្តិបត្របំណុលក្នុងឆ្នាំ ២០១២។ ដោយសារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនប្រើព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យ ODA យើងខ្ញុំសង្ឃឹមថាឯកសារទាំងស្រុងនៃរបាយការណ៍ស្តីពីបំណុលសាធារណៈនេះ ក៏នឹងដាក់បញ្ចូលផងដែរនូវព័ត៌មានទាក់ទិននឹងអាណត្តិនិងលក្ខខណ្ឌនៃប្រាក់កម្ចី (សម្បទាន) និង ចុះផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សំណូមពរ៖

1. ដើម្បីធានាឲ្យបាននូវទម្រង់ ព្រមទាំងលំហូរព័ត៌មានប្រកបដោយសង្គតិភាពនៅក្នុងចំណោមមូលដ្ឋានទិន្នន័យ ODA កម្មវិធីវិនិយោគសាធារណៈ និងច្បាប់ថវិកាជាតិ ហើយដោយសារម្ចាស់ជំនួយនីមួយៗប្រើលេខកូដផ្ទាល់ខ្លួនដើម្បីរាយការណ៍អំពីគម្រោងផ្សេងៗ **លេខកូដគម្រោងរួម និងព័ត៌មានសំខាន់ៗផ្សេងទៀត (រួមមានឈ្មោះ ប្រភពផ្តល់មូលនិធិ ថវិកា និងចិរវេលា) គួរគប្បីអនុម័តដោយស្ថាប័នកណ្តាលទាំងបួន រួមមាន CRDB/CDC ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដោយសម្របសម្រួលជាមួយដៃគូ**

អភិវឌ្ឍន៍។ ប្រការនេះគប្បីគឺជាដំណោះស្រាយអាចទទួលយកបានសម្រាប់ឲ្យម្ចាស់ជំនួយរាយការណ៍ទិន្នន័យអនុលោមតាមប្រព័ន្ធរបស់ប្រទេសកម្ពុជា ដូចដែលត្រូវបានសន្យានៅក្នុងសេចក្តីថ្លែងការណ៍ក្រុងប៊ូសានស្តីពីភាពជាដៃគូ។ លេខកូដគម្រោងរួមគប្បីត្រូវបានចុះនៅក្នុងមូលដ្ឋានទិន្នន័យ ODA និង កត់ត្រានៅក្នុងកម្មវិធីវិនិយោគសាធារណៈ ក៏ដូចជាច្បាប់ថវិកាជាតិ។ ចំពោះគម្រោងពហុម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍គប្បីសម្របសម្រួលក្នុងចំណោមពួកគេខ្លួនឯង ដើម្បីធានាឲ្យបានថាគម្រោងមួយមិនត្រូវបានកត់ត្រាលើសពីមួយដងដោយដៃគូអភិវឌ្ឍន៍ផ្សេងគ្នា។ មួយវិញទៀត កំណត់សម្គាល់មួយដែលប្រាប់ពីការកត់ត្រា ឬការចុះលេខកូដខុសគ្នានេះគប្បីត្រូវលើកឡើងឲ្យបានច្បាស់លាស់នៅក្នុងមូលដ្ឋានទិន្នន័យនីមួយៗ។

2. របាយការណ៍ស្រាវជ្រាវនោះបានស្នើនូវភាពចាំបាច់ជាបន្ទាន់មួយ ដែលត្រូវពង្រឹងនិងពន្លឿនតួនាទីសម្របសម្រួលរបស់ស្ថាប័នកណ្តាលទាំងបួន ពោលគឺ CRDB/CDC **ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)។ ស្ថាប័នកណ្តាលទាំងនេះ គប្បីជួបប្រជុំជាទៀងទាត់ដើម្បីពិនិត្យមើលព័ត៌មានគម្រោង។** កិច្ចប្រជុំទាំងនេះត្រូវបានគ្រោង ដោយអនុញ្ញាតឲ្យរាជរដ្ឋាភិបាលតាមដានព័ត៌មានស្តីពីហិរញ្ញប្បទានស្របតាមអាទិភាពទាំងឡាយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ស្ថាប័នកណ្តាលនេះត្រូវបានគេជឿថាពិតជាអាចពិនិត្យមើល និងកែសម្រួលសង្គតិភាពនៃព័ត៌មានគម្រោង (ឈ្មោះ ចិរវេលា ប្រភពផ្តល់មូលនិធិថវិកា និងលេខកូដគម្រោង) នៅក្នុងមូលដ្ឋានទិន្នន័យ ODA កម្មវិធីវិនិយោគសាធារណៈ និងច្បាប់ថវិកាជាតិ។

3. **កិច្ចព្រមព្រៀងទាំងឡាយដែលចុះហត្ថលេខាដោយដៃគូអភិវឌ្ឍន៍ និងសាមីក្រសួង គប្បីត្រូវបានប្រើជាប្រភពព័ត៌មានកណ្តាលសម្រាប់គម្រោងទាំងអស់ នៅពេលបញ្ចូលទិន្នន័យទៅក្នុងកម្មវិធីវិនិយោគសាធារណៈ និងមូលដ្ឋានទិន្នន័យ ODA។** កិច្ចព្រមព្រៀងគប្បីត្រូវបានកែតម្រូវជាមួយលេខកូដគម្រោងអនុម័តមួយ និងព័ត៌មានផ្សេងទៀត។ កិច្ចព្រមព្រៀងនេះគប្បីត្រូវបានប្រើដោយសាមីក្រសួង ដៃគូអភិវឌ្ឍន៍ ក្រសួងផែនការ និងCRDB/CDC សម្រាប់ផ្ទៀងផ្ទាត់ព័ត៌មានគម្រោងមុនពេលដាក់ផ្សាយនៅលើគេហទំព័រ ODA និងកម្មវិធីវិនិយោគសាធារណៈ។ ដៃគូអភិវឌ្ឍន៍និងសាមីក្រសួង គប្បីចាត់ឲ្យបុគ្គលិករបស់ខ្លួនបកប្រែ និងផ្ទៀងផ្ទាត់ឈ្មោះគម្រោងពីភាសាខ្មែរទៅជាភាសាអង់គ្លេស ឬ ពីភាសាអង់គ្លេសទៅជាភាសាខ្មែរ ហើយប្រការដ៏សំខាន់មួយគឺថាយ៉ាងហោចណាស់ គប្បីត្រូវមាន "សទ្ទានុក្រមពាក្យគន្លឹះមួយ" ជាភាសាអង់គ្លេសនិងភាសាខ្មែរ។

4. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍សូម**ផ្សព្វផ្សាយព័ត៌មានឲ្យបានកាន់តែច្រើនទាក់ទងនឹង "លក្ខខណ្ឌជំនួយ" នៃប្រាក់កម្ចីសម្បទាន (រួមទាំងថវិកា ដែលមិនមែនមានត្រឹមតែអត្រាការប្រាក់ រយៈពេលអនុគ្រោះ រយៈពេលសង និងលក្ខខណ្ឌនៃប្រាក់កម្ចីសម្បទាន)** សម្រាប់ប្រទេសកម្ពុជា ដើម្បីឲ្យប្រជាពលរដ្ឋកម្ពុជាបានទទួលព័ត៌មានអំពីលទ្ធភាពបន្ទុកនៃប្រាក់កម្ចីសម្បទានបរទេសដែលពួកគេត្រូវរ៉ាប់រងនាពេលអនាគត ដូចជាការបង់ពន្ធដើម្បីសងប្រាក់កម្ចីទាំងនោះជាដើម។ ប្រជាពលរដ្ឋកម្ពុជា ដែលគឺជា "អ្នកសងពិតប្រាកដនៃប្រាក់កម្ចីទាំងនោះ" មានសិទ្ធិដឹងអំពីជម្រើសនិងលក្ខខណ្ឌ ដែលរាជរដ្ឋាភិបាលកម្ពុជាប្រកាន់យកក្នុងការទទួលយកប្រាក់កម្ចីសម្បទានណាមួយ និងថាតើពួកគេត្រូវរ៉ាប់រងបន្ទុកប៉ុណ្ណា។

៣. លទ្ធផលអភិវឌ្ឍន៍នៃហិរញ្ញប្បទាន៖ ការពិនិត្យមើលគម្រោងប្រព័ន្ធស្រោចស្រព ដែលឧបត្ថម្ភមូលនិធិដោយដៃគូអភិវឌ្ឍន៍ និងថវិកាជាតិ[23]

[23] របកគំហើញសំខាន់ៗនៅក្នុងផ្នែកនេះ ត្រូវបានដកស្រង់ទាំងស្រុងពីសេចក្តីសង្ខេបនៃរបាយការណ៍ស្រាវជ្រាវទាំងស្រុងស្តីពី "ការរៀនសូត្រពីគម្រោងប្រព័ន្ធស្រោចស្រពនៅកម្ពុជា: អត្ថប្រយោជន៍និងបញ្ហាប្រឈម" ដែលអាចទាញយកបានពីhttp://www.ngoforum.org.kh/eng/enpublications.php?docs=aepdoc ឬhttp://www.ngoforum.org.kh/eng/enallpublication.php ហើយសូមចូលទៅក្នុងគម្រោងប្រសិទ្ធភាពជំនួយ ឬ គម្រោងថវិកាជាតិ។

ក្នុងឆ្នាំ២០១១ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាបានឧបត្ថម្ភឲ្យសមាគមសេដ្ឋកិច្ចកម្ពុជាធ្វើការស្រាវជ្រាវមួយស្តីពី "ការរៀនសូត្រពីប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា: អត្ថប្រយោជន៍និងបញ្ហាប្រឈម"។ ការស្រាវជ្រាវនេះ បានវាយតម្លៃសមត្ថភាពប្រព័ន្ធធារាសាស្ត្រ ឥទ្ធិពលរបស់ប្រព័ន្ធលើការផលិតស្រូវ និងពិនិត្យមើលបញ្ហាប្រឈមនានានៅក្នុងវិស័យធារាសាស្ត្រ ដោយធ្វើការវាយតម្លៃផ្ទាល់នៅមូលដ្ឋានលើប្រព័ន្ធធារាសាស្ត្រចំនួន ១២ នៅក្នុងខេត្តចំនួន ៨ ដែលស្ថិតនៅក្នុងវាលទំនាបនៃបឹងទន្លេសាបនិងទន្លេមេគង្គក្រោម។ ប្រព័ន្ធស្រោចស្រពចំនួនបួន ត្រូវបានជ្រើសរើសសម្រាប់ធ្វើអង្កេតលឿនមួយជាមួយកសិករចំនួន ១៨០ នាក់ ដើម្បីបង្ហាញអត្ថប្រយោជន៍នៃប្រព័ន្ធធារាសាស្ត្រលើផ្ទៃដីកសិកម្មដែលទទួលបានការស្រោចស្រព ប្រៀបធៀបជាមួយនឹងផ្ទៃដីកសិកម្មដែលមិនបានទទួលការស្រោចស្រព។

ផ្អែកលើលទ្ធផលនៃការសិក្សាលើឯកសារមានស្រាប់ គេសង្កេតឃើញថាផ្ទៃដីស្រោចស្រពនៅកម្ពុជាមិនមានសង្គតិភាពពីប្រភពមួយទៅប្រភពមួយនោះទេ។ រាជរដ្ឋាភិបាលកម្ពុជាបានរាយការណ៍ថាផ្ទៃដីស្រោចស្រពក្នុងឆ្នាំ ២០១០ មានទំហំ ១,១៦ លានហិកតា ដែលស្មើនឹង ៣៣%នៃផ្ទៃដីដាំដុះ ឬ៤២%នៃដីស្រែ។ តួលេខនេះតំណាងឲ្យកំណើនផ្ទៃដីស្រោចស្រពទំហំ ៥៧៩.០០០ ហិកតា ពីទំហំផ្ទៃដីស្រោចស្រពក្នុងឆ្នាំ ២០០៥។ កំណើនលោតផ្លោះបែបនេះនៃផ្ទៃដីស្រោចស្រពមិនត្រូវបានគាំទ្រយ៉ាងជាក់ស្តែងដោយចំណាយមូលធន ជាមធ្យមប្រហែល ៣៤ លានដុល្លារអាមេរិកក្នុងមួយឆ្នាំសម្រាប់ក្រសួងធនធានទឹកនិងឧតុនិយម ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៩ នោះទេ។ ម្យ៉ាងទៀត ធនាគារពិភពលោក (២០០៩) ដោយផ្អែកលើអង្កេតសង្គមនិងសេដ្ឋកិច្ច (CSES) ឆ្នាំ ២០០៧ បានប៉ាន់ស្មានថា ផ្ទៃដីស្រោចស្រពនៅកម្ពុជាមានទំហំប្រហែល ២៥% នៃដីកសិកម្ម។ លើសពីនេះទៀត ទិន្នន័យដែលទទួលបានពីទិន្នន័យឃុំបានបង្ហាញថា ផ្ទៃដីស្រោចស្រពនៅកម្ពុជាគឺមានទំហំប្រហែល ២១% នៃផ្ទៃដីស្រែដាំដុះក្នុងឆ្នាំ ២០០៨។

តាមរយៈការចុះវាយតម្លៃផ្ទាល់លើប្រព័ន្ធធារាសាស្ត្រចំនួន ១២ នៅក្នុងខេត្តចំនួនប្រាំបី គេបានរកឃើញថាផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រគ្របដណ្តប់តែលើ៣៣%ប៉ុណ្ណោះ នៃផ្ទៃដីស្រែវស្សាសរុបនៅក្នុងឃុំចំនួន២៤ ដែលមានលទ្ធភាពប្រើប្រព័ន្ធធារាសាស្ត្រស្តារឡើងវិញ។ ប្រការនេះបង្ហាញថា ទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រសម្រាប់ផ្ទៃដីស្រែវស្សាទូទាំងប្រទេសមានទំហំតិចជាង នៅពេលដែលមានឃុំជាច្រើនដែលមិនអាចទទួលការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រដែលបានស្តារឡើងវិញទាំងនេះ។ ការវាយតម្លៃបានបង្ហាញថែមទៀតថានៅក្នុងចំណោមដីស្រែសរុបនៅក្នុងឃុំ មានតែ ៩% ប៉ុណ្ណោះដែលកំពុងផលិតស្រូវដើមរដូវវស្សា (ខែមេសាដល់ខែសីហា) ដោយប្រើទឹកពីប្រព័ន្ធធារាសាស្ត្របំពេញបន្ថែមលើទឹកភ្លៀង និង ៣% បានធ្វើការដាំដំណាំបន្ថែមមួយមុខទៀតក្នុងរដូវប្រាំង (ខែធ្នូដល់ខែមេសា) ដែលពឹងផ្អែកទាំងស្រុងលើទឹកពីប្រព័ន្ធធារាសាស្ត្រទាំងនេះ។

ប្រព័ន្ធធារាសាស្ត្រស្តារឡើងវិញ ជាពិសេសប្រព័ន្ធដែលទទួលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជាធម្មតា អាចផ្គត់ផ្គង់ទឹកដើម្បីស្រោចស្រពលើផ្ទៃដីគ្រោងស្រោចស្រពទាំងមូលនៃគម្រោង[24] នៅក្នុងរដូវវស្សា ដោយមានទឹកបំពេញបន្ថែមពីទឹកភ្លៀង ប៉ុន្តែគេឃើញមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនផ្សារភ្ជាប់នឹងប្រព័ន្ធនេះ រួមមាន លទ្ធភាពស្រោចស្រពដោយ ប្រើប្រាស់ទឹកពីប្រព័ន្ធធារាសាស្ត្រនៅមានកម្រិត កង្វះប្រឡាយចែកចាយទឹកបន្តពីប្រឡាយមេនិងសំណង់ស្ទាក់ទឹក និងការរៀបចំប្លង់ប្រព័ន្ធមិនទាន់បានល្អ។ ផ្អែកលើទិន្នន័យដែលទទួលបានពីប្រព័ន្ធចំនួនប្រាំពីរ ២៣%នៃផ្ទៃដីគ្រោងស្រោចស្រពអាចមានលទ្ធភាពប្រើទឹកពីប្រព័ន្ធធារាសាស្ត្រដែលត្រូវបានកែលម្អសម្រាប់ធ្វើស្រែដើមរដូវវស្សា (ខែមេសាដល់ខែសីហា) ដោយមានទឹកបន្ថែមពីទឹកភ្លៀង ខណៈដែលផ្ទៃដីស្រែ១៣%ផ្សេងទៀតមានលទ្ធភាពដាំដំណាំបន្ថែមមួយមុខទៀតក្នុងរដូវប្រាំង (ខែធ្នូដល់ខែមេសា) លើផ្ទៃដីស្រែវស្សា។ ប៉ុន្តែ ការវាយតម្លៃនៅមូលដ្ឋានផ្ទាល់បានរកឃើញថា ផ្ទៃដីស្រោចស្រពជាក់ស្តែងដែលទទួលបានពីប្រព័ន្ធធារាសាស្ត្រខ្នាតធំទាំងឡាយ និងដែលត្រូវបានស្តារឡើងវិញដោយថវិការបស់រាជរដ្ឋាភិបាលកម្ពុជាគឺនៅមានកម្រិតដោយសារប្រព័ន្ធទាំងនេះមិនត្រូវបានសាងសង់ ឬជួសជុលទាំងស្រុងទេ។ ជាធម្មតា ប្រឡាយរងទី៣

[24] នៅក្នុងវិស័យធារាសាស្ត្រ ពាក្យ "ផ្ទៃដីគ្រោងស្រោចស្រព-Command Area" គឺសំដៅលើផ្ទៃដីដែលត្រូវបានរៀបចំឲ្យទទួលការស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ។ តាមជាក់ស្តែង ជាញឹកញាប់ប្រព័ន្ធនេះមិនអាចផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ឲ្យដល់ផ្ទៃដីគ្រោងស្រោចស្រពទាំងអស់ទេ។ មូលហេតុគឺអាចមកពីកង្វះប្រភពទឹក/ទឹកភ្លៀង និង/ឬ ការសាងសង់មិនមានលក្ខណៈពេញលេញ ។

មិនត្រូវបានសាងសង់ ឬជួសជុលនោះទេ។ កិច្ចប្រឹងប្រែងនោះអាចស្តារបានតែក្បាលហុងទឹក និង/ឬ ប្រឡាយមេ តាមរយៈការងារសំណង់ពីរបីឆ្នាំជាប់ៗគ្នា។ យ៉ាងណាមិញនៅក្នុងករណីខ្លះ ឃុំប្រើមូលនិធិរបស់ខ្លួនដើម្បីស្តារប្រឡាយរងទី៣មួយចំនួន ដើម្បីទាញយកទឹកធារាសាស្ត្រពីប្រឡាយមេបញ្ចូលទៅក្នុងស្រែ។

ប្រព័ន្ធធារាសាស្ត្រត្រូវបានសង្កេតឃើញថាបានផ្តល់អត្ថប្រយោជន៍មួយចំនួនជូនកសិករ ដែលរួមមានផ្តល់ទឹកបន្ថែមសម្រាប់ស្រោចស្រពស្រូវវស្សា អន្តរាគមន៍នៅពេលមានគ្រោះរាំងស្ងួត ការផលិតដំណាំបន្ថែមមួយមុខទៀតនៅដើមរដូវវស្សាឬរដូវប្រាំង ផលស្រូវកាន់តែខ្ពស់ ទីកន្លែងកំសាន្ត ប្រព័ន្ធរំដោះទឹកដើម្បីរំដោះទឹកលើសចេញពីវាលស្រែនៅពេលចាំបាច់ ការពង្រីកផលិតកម្មបន្លែ ផ្លូវសម្រាប់ការធ្វើដំណើរនិងការដឹកជញ្ជូនធាតុចូលនិងផលិតផលកសិកម្ម ការប្រើប្រាស់របស់គ្រួសារនិងសត្វ និងកំណើនមច្ឆាជាតិ។ ចំពោះផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រ ការស្ទង់មតិបែបរហ័សបានរកឃើញថាប្រព័ន្ធធារាសាស្ត្រមានផលប៉ះពាល់ច្រើនលើជីវភាពរបស់ប្រជាកសិករ។ កសិករភាគច្រើនដែលបានទទួលផលប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្របានរាយការណ៍ថា ប្រព័ន្ធធារាសាស្ត្របានធ្វើឲ្យជីវភាពរបស់ពួកគាត់ប្រសើរឡើង ជាពិសេសក្នុងចំណោមកសិករ ដែលអាចដាំដំណាំបន្ថែមមួយមុខទៀតនៅដើមរដូវវស្សា ឬក្នុងរដូវប្រាំង។ តាមការប្រៀបធៀបកសិករដែលមិនមានលទ្ធភាពប្រើ ឬទទួលប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ ត្រូវបានរាយការណ៍ថា ជីវភាពរបស់ពួកគាត់កាន់តែយ៉ាប់យ៉ឺននៅក្នុងឆ្នាំកន្លងទៅ ដែលមានភាគរយខ្ពស់ជាងកសិករដែលមានលទ្ធភាពប្រើ ឬទទួល ប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ។

បញ្ហាប្រឈមគន្លឹះមួយ ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការប្រកបដោយប្រសិទ្ធភាពនៃប្រព័ន្ធធារាសាស្ត្រ ត្រូវបានគេសង្កេតឃើញថា គឺផ្សារភ្ជាប់ទៅនឹងកង្វះទឹកធារាសាស្ត្រ។ ចំណុចនេះគឺ បណ្តាលមកពីមូលហេតុមួយចំនួន ពោលគឺហេដ្ឋារចនាសម្ព័ន្ធមិនពេញលេញរួមមាន កង្វះប្រឡាយរងទី៣និងសំណង់ស្នាក់ទឹក ការរៀបចំប្លង់/ការជួសជុលប្រព័ន្ធមិនបានល្អ ប្រភពទឹកមានកម្រិតដូចជា ស្ទឹងតូចឬអាងស្តុកទឹកដែលអាស្រ័យលើទឹកភ្លៀង ការដណ្តើមយកទឹកពីប្រព័ន្ធឆ្ងាយផ្សេងទៀតនៅខ្សែទឹកខាងលើ និង/ឬ ការស្នាក់ទឹកធារាសាស្ត្រសម្រាប់ការប្រើប្រាស់ក្នុងគោលបំណងផ្សេងៗ ទៀត។

សំណូមពរ៖

ដូច្នេះ ការសិក្សាស្នើសុំឲ្យគិតគូរដល់បញ្ហាខាងក្រោមដើម្បីកែលម្អប្រសិទ្ធភាពនៃវិស័យធារាសាស្ត្រនៅកម្ពុជា៖

1. ដោយកង្វះនូវប្រឡាយរងទី៣និងសំណង់ស្នាក់ទឹក ត្រូវបានរកឃើញថាជាឧបសគ្គចម្បងនៅក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក **ប្រព័ន្ធធារាសាស្ត្រគប្បីត្រូវបានសាងសង់ ឬស្តារនីតិសម្បទាដោយកសាងហេដ្ឋារចនាសម្ព័ន្ធពេញលេញ មានប្លង់ត្រឹមត្រូវ និងមានការតាមដានមើលការសាងសង់ ឬការស្តារនីតិសម្បទា**។ លើសពីនេះទៀត ការមានប្លង់ត្រឹមត្រូវ និងការតាមដានមើលការសាងសង់ ឬការស្តារនីតិសម្បទាប្រព័ន្ធនឹងជួយធានាឲ្យបានថាប្រព័ន្ធនឹងមិនផ្គត់ផ្គង់ទឹកខ្វះដល់ផ្ទៃដីគ្រោងស្រោចស្រពរបស់ប្រព័ន្ធ និងធានាឲ្យបានថាការគ្រប់គ្រងទឹកនឹងមិនត្រូវបានថមថយដោយរចនាសម្ព័ន្ធប្រព័ន្ធនោះទេ។

2. ដើម្បីការគ្រប់គ្រងប្រព័ន្ធស្រោចស្រព/ទឹក ឬ FWUCs ប្រកបដោយជោគជ័យ **ការដកពិសោធលើយន្តការផ្សេងទៀត គួរគប្បីយកមកសាកល្បងផងដែរ ដូចជាការគ្រប់គ្រងដែលដឹកនាំដោយផ្នែកឯកជន ឬថែទាំដោយអង្គការមិនមែនរដ្ឋាភិបាលជាដើម។** ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ/ទឹក ដឹកនាំដោយផ្នែកឯកជនអនុញ្ញាតឲ្យផ្នែកឯកជន (បុគ្គលឬក្រុមហ៊ុន) ដំណើរការប្រព័ន្ធតាមរយៈការដេញថ្លៃ។ ការគ្រប់គ្រងដែលថែទាំដោយអង្គការមិនមែនរដ្ឋាភិបាល គឺធ្វើឡើងក្នុងន័យអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលប្រកបដោយសមត្ថភាពនិងអាចទុកចិត្តបាន ជួយក្នុងការរៀបចំដំណើរការដែលមានលក្ខណៈជាស្ថាប័នរបស់FWUC ដែលត្រូវបានបង្កើតឡើងនៅក្នុងបណ្តាឆ្នាំដំបូង។ ទោះជាក្នុងករណីណាក៏ដោយ ប្រព័ន្ធផ្តល់គ្រឿងលើកទឹកចិត្តដ៏សមស្របមួយគួរត្រូវរៀបចំឡើងនៅនឹងកន្លែង។

3. **ការវិភាគថ្លៃចំណាយនិងអត្ថប្រយោជន៍ឲ្យបានស៊ីជម្រៅ លើប្រព័ន្ធធារាសាស្ត្រមានស្រាប់នៅតាមកន្លែងផ្សេងៗគ្នា និងប្រភេទដី នឹងផ្តល់ជាសក្តីភាពកាន់តែច្បាស់សម្រាប់ការសម្រេចចិត្តអំពីកន្លែងណាឬប្រព័ន្ធមួយណា ដែលគប្បីត្រូវកំណត់ជាអាទិភាព ដើម្បីធ្វើផែនការនិងប្រើប្រាស់ធនធានឲ្យបានកាន់តែប្រសើរឡើង។** ដោយសារប្រព័ន្ធធារាសាស្ត្រអាចផ្តល់អត្ថប្រយោជន៍ផ្សេងៗជាច្រើនក្រៅពីទឹកស្រោចស្រព ពហុប្រយោជន៍/មុខងារនៃប្រព័ន្ធធារាសាស្ត្រគប្បីត្រូវបានគិតគូរឲ្យបានជិតដល់ចំពោះការរៀបចំប្រព័ន្ធ និងត្រូវបានដាក់បញ្ចូលទៅក្នុងការគណនាថ្លៃចំណាយនិងអត្ថប្រយោជន៍ ដើម្បីអាចលើកកម្ពស់ប្រសិទ្ធភាពចំណាយរបស់គម្រោងសាងសង់ប្រព័ន្ធធារាសាស្ត្រនីមួយៗ។

4. **ដោយសារមានរបាយការណ៍ស្រដៀងៗគ្នា ស្តីពីតួលេខនៃទំហំស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រថ្នាក់ជាតិ មកពីប្រភពផ្សេងៗគ្នា វិធីមួយដើម្បីបំភ្លឺឬកំណត់សមត្ថភាព ឬលទ្ធភាពស្រោចស្រពជាក់ស្តែងនៃប្រព័ន្ធធារាសាស្ត្ររបស់កម្ពុជាទាំងមូល គឺជាប្រការចាំបាច់មួយ។** ចំណុចនេះអាចតម្រូវឲ្យមានការពិនិត្យមើលឡើងវិញដ៏មធ្យ័តមួយ ឬការស្ទង់មតិមួយដើម្បីបញ្ជាក់ពីស្ថិតិលទ្ធភាពស្រោចស្រពជាក់ស្តែងនៃប្រព័ន្ធធារាសាស្ត្រដែលបានសាងសង់ និងស្ថារនីតិសម្បទា ដោយមានការឯកភាពនៅក្នុងចំណោមភាគីពាក់ព័ន្ធ រួមទាំងស្ថាប័នរាជរដ្ឋាភិបាល និងទីភ្នាក់ងារដៃគូអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះ កិច្ចប្រឹងប្រែងដើម្បីកែលម្អវិធីប្រមូលទិន្នន័យនៅក្នុងចំណោមស្ថាប័នពាក់ព័ន្ធ និង/ឬមានសមត្ថកិច្ច ក៏គួរតែត្រូវអនុវត្តផងដែរ។

៤. សកម្មភាព/យុទ្ធសាស្ត្រសំខាន់ៗដែលបានសន្យាដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣

សម្រាប់សេចក្តីប្រកាសគោលនយោបាយសំខាន់ៗ និងសកម្មភាពនានាទាក់ទិននឹងសារៈសំខាន់នៃការរួមចំណែករបស់អង្គការសង្គមស៊ីវិលដល់ការអភិវឌ្ឍប្រទេសកម្ពុជា សូមមើលឯកសារគោលជំហរស្តីពី *"ការធ្វើការរួមគ្នាឆ្ពោះទៅកាន់ការសម្រេចបានភាពជាម្ចាស់របស់ប្រទេសលើផែនការអភិវឌ្ឍន៍ជាតិក្នុងឆ្នាំ ២០១៣"* ។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
លោក ឈិត សំអាត នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh និង www.cambodianbudget.org
អាសយដ្ឋាន៖ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

ការអភិវឌ្ឍជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ

វិស័យកសិកម្ម និងទឹក

១. សេចក្តីផ្តើម

កម្ពុជា គឺជាប្រទេសដែលមានខឿនសេដ្ឋកិច្ច ពឹងផ្អែកមួយភាគធំទៅលើវិស័យកសិកម្ម។ ប្រជាពលរដ្ឋប្រមាណ ៨០ភាគរយ រស់នៅតំបន់ជនបទ ដោយពឹងផ្អែកលើវិស័យកសិកម្មជាមុខរបរចំបងក្នុងការចិញ្ចឹមជីវិត រួមមានដំណាំស្រូវ ដំណាំគ្រប់មុខ និងការចិញ្ចឹមសត្វ ។ ផ្អែកលើរបាយការណ៍បូកសរុបការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១០-២០១១ ផលិតផលក្នុងស្រុកសរុប (GDP) ដែលបានមកពីវិស័យកសិកម្ម មានប្រមាណ២៩% ក្នុងឆ្នាំ២០១០ ដោយកើនឡើងប្រៀបធៀបជាមួយនឹងឆ្នាំ២០០៩ ដែលបានត្រឹមតែ២៨%តែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា ការកើនឡើងនេះនៅតែមានកម្រិតទាបនៅឡើយបើប្រៀបធៀបជាមួយនឹងកំណើនកាលពីឆ្នាំមុន។ និងការរួមចំណែកក្នុង ផលិតផលក្នុងស្រុកសរុបដែលបានមកពីវិស័យផ្សេងៗ។ ផលិតកម្មកសិកម្ម ដែលមានការកើនឡើងជាមធ្យមប្រចាំឆ្នាំប្រមាណជា ៤-៥% នៅចន្លោះឆ្នាំ ២០០៦-២០១០[25] ជាកំណើនមួយដែលមានសន្ទុះយឺតនៅឡើយ។

រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម បានខិតខំប្រឹងប្រែងក្នុងការកែលំអផលិតភាពក្នុងវិស័យកសិកម្ម និងពង្រឹង និងស្តារប្រពន្ធ័ស្រោចស្រពឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងតំរូវការស្រោចស្រពគ្រប់គ្រាន់នៅក្នុងវិសយ័កសិកម្ម តាមរយៈការរៀបចំជាផែនការយុទ្ធសាស្ត្រ បង្កើតក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោលនយោបាយនានា ដើម្បីធានាឲ្យគោលនយោបាយកសិកម្ម និងទឹក សម្រេចទៅបានប្រកបដោយប្រសិទ្ធភាព។ សមិទ្ធិផល សម្រេចបានមួយចំនួនរួមមាន ការរៀបចំជួសជុលស្តារ និងកសាងនូវប្រពន្ធ័ស្រោចស្រព នៅតាមតំបន់ជនបទ ការកសាងសមត្ថភាពមន្ត្រីរាជការ ការពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកជាដើម[26]។ ទន្ទឹមនឹងសមិទ្ធិផលទាំងនេះ នៅមានតំបន់មួយចំនួនដែលនៅមាន ការខ្វះខាតនូវការស្រោចស្រពជាក់ស្តែងតាមរយៈការស្រាវជ្រាវទៅលើប្រពន្ធ័ធារាសាស្ត្រចំនួន១២ នៅក្នុងខេត្តចំនួន៨ បានបង្ហាញថាមានតែផ្ទៃដី៣៣% ប៉ុណ្ណោះនៃផ្ទៃដីស្រែវស្សាសរុប នៅក្នុងឃុំទាំង២៤ ដែលមានលទ្ធភាពប្រើប្រពន្ធ័ ធារាសាស្ត្រស្តារឡើងវិញ[27]។ ជាងនេះទៅទៀតប្រពន្ធ័សម្រាប់គ្រប់គ្រងទឹកនៅពេលទឹកជំនន់ ព្រមទាំងប្រពន្ធ័រក្សាទឹកទុកក្រោយពេលទឹកជំនន់ដែលរួមចំណែកសម្រេចឲ្យបាននូវគោលនយោបាយនាំអង្ករចេញ ក៏ដូចជាការនាំចេញនូវផលិតផល កសិកម្មនានានៅលើទីផ្សារក្នុងតំបន់ និងអន្តរជាតិពុំទាន់មានដែរ។

នៅក្នុងឯកសារយុទ្ធសាស្ត្រសម្រាប់វិស័យកសិម្ម និងទឹក (SAW) សម្រាប់ឆ្នាំ (២០០៦-២០១០) មិនបានលើកឡើងពីថ្នាំកសិកម្មទាល់តែសោះ។ ចំណែកឯនៅក្នុងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) បានបង្ហាញអំពីចំណុចការប្រើប្រាស់ថ្នាំកសិកម្មសរីរាង្គ និងអសរីរាង្គឲ្យត្រឹមត្រូវទៅតាមលក្ខណៈបទដ្ឋាន ប៉ុន្តែនៅតែមិនទាន់បានបង្ហាញនូវការប្រើប្រាស់ប្រកបដោយសុវត្ថិភាព និងសមស្របទៅនឹងលក្ខណៈបច្ចេកទស ក៏ដូចជាការផ្សព្វផ្សាយនូវបច្ចេកទេសប្រកបដោយសុវត្ថិភាពដល់កសិកម្ម និងអ្នកប្រើប្រាស់ផ្ទាល់ផងដែរ។ ការគ្រប់គ្រង និងការប្រើប្រាស់សារធាតុគីមីនៅក្នុងវិស័យកសិកម្ម អាចជាឧបសគ្គ ធំដល់ការលូតលាស់វិស័យ កសិកម្មនៅកម្ពុជា ក៏ដូចជាការប្រកួតប្រជែងនៅក្នុងទីផ្សារតំបន់ និងអន្តរជាតិ និងគោលដៅនៃការនាំអង្ករចេញរបស់ រាជរដ្ឋាភិបាលដែលដាក់គោលដៅសម្រេចឲ្យបាន ១លានតោន ក្នុងឆ្នាំ២០១៥។ បណ្តាញកាត់បន្ថយថ្នាំកសិកម្មនៅកម្ពុជា (PRN-C) ត្រូវបានបង្កើតឡើងកាលពីឆ្នាំ១៩៩៩ ដោយវេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ បណ្តា

[25] របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ ២០១០-២០១១ និងទិសដៅឆ្នាំ ២០១១-២០១២ (ទំព័រ១៥-១៦)

[26] របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារលើវិស័យធនធានទឹក និងឧតុនិយមប្រចាំឆ្នាំ ២០១១ នៃក្រសួងធនធានទឹក និងឧតុនិយម

[27] របាយការណ៍ស្រាវជ្រាវការរៀនសូត្រពីគម្រោងធារាសាស្ត្រនៅកម្ពុជា៖ អត្ថប្រយោជន៍ និងបញ្ហាប្រឈម (NGOF ២០១១)

ញនេះមានដំណើរការដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយ ស្ថាប័នរាជរដ្ឋាភិបាលក្នុងការធ្វើការតាមដាន និងកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម នៅប្រទេសកម្ពុជា ដោយធ្វើការជំរុញឲ្យមានជំរើសផ្សេងៗទៀតសម្រាប់ការអនុវត្តនិរន្តរភាពកសិកម្ម និងជីវភាពរស់នៅ។

២. សូចនាការតាមដានរួម

ស្ថាប័នសម្របសម្រួល៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងធនធានទឹកនិងឧត្តុនិយម
-ស្ថាប័នអនុវត្ត៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម

លទ្ធផលរយៈពេលមធ្យម	ធាតុចេញ	សូចនាការធាតុចេញ	សកម្មភាព	សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ
បង្កើនផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម និងពិពិធកម្មកសិកម្ម និងកែលំអការរៀបចំ និងការគ្រប់គ្រងធនធានទឹក	១.ជម្រុញសុខដុម - នីយកម្ម និងការតម្រឹមក្នុងការរៀបចំផែនការការអនុវត្តន៍ តាមដាន និងវាយតម្លៃទាំងនៅថ្នាក់ជាតិនិង នៅថ្នាក់ក្រោមជាតិ	១. ផែនទីចង្អុលផ្លូវសម្រាប់ពន្លឿនអភិក្រមគ្រប់គ្រងកម្មវិធី ដើម្បីអនុវត្តយុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក ត្រូវបានអនុម័តដោយក្រុមការងារ	១. ពិនិត្យចំណាយ សាធារណៈ និងការ គ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈរបស់វិស័យកសិកម្ម និងទឹក ២. រៀបចំផែនទីចង្អុលផ្លូវ ដើម្បីអនុវត្តយុទ្ធសាស្ត្រស្តី ពីកសិកម្ម និងទឹក ៣. តម្រឹមថវិការដ្ឋ និង ធនធានមនុស្ស ទៅនឹងយុទ្ធសាស្ត្រកសិកម្ម និងទឹក ៤. ដាក់មូលនិធិរួមគ្នា សម្រាប់គាំទ្រសកម្មភាពជាក់លាក់ បង្កើតអភិក្រមគ្រប់គ្រង ទូទាំងកម្មវិធី សម្រាប់អនុវិស័យដែលមានការឯកភាពគ្នា ព្រមទាំងរៀបចំផែនការ និងបង្កើតយន្តការតាមដាន និងវាយតម្លៃរួមគ្នា	១. រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ប្តេជ្ញា និងធ្វើសកម្មភាពរួមគ្នាដើម្បីពន្លឿន អភិក្រមគ្រប់គ្រង ទូទាំងវិស័យ ដែលជាឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តី ពីកសិកម្ម និងទឹក
	២. ផលិតផលស្រូវ ផ្លែឈើ និងបន្លែ មានការកើនឡើង	២. ផលិតផលស្រូវ ផ្លែឈើ និងបន្លែ កើនឡើង ២-៣%	៥. បង្កើនការប្រើប្រាស់ គ្រាប់ពូជដែលមានគុណ ភាពល្អ និងការប្រើ ប្រាស់ជីដែលសមស្រប ៦. បង្កើនចំនួនអង្គការកសិករ ៧. បង្កើនផ្ទៃដីស្រោចស្រព ១% (២៥000 ហិចតាក្នុង ១ ឆ្នាំ) ៨. បង្កើនចំនួនសហគមន៍កសិករអ្នកប្រើប្រាស់ទឹក	២. រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍គាំទ្រ ផែនការសកម្មភាពរួមគ្នា ដើម្បីគាំទ្រការពង្រីកសេវា អង្គការកសិករ និងសេវាធារាសាស្ត្រ (រួមទាំងការបណ្តុះបណ្តាល វិស្វករផ្នែកធារាសាស្ត្រ និងមជ្ឈមណ្ឌលសេវាបច្ចេកទេស)

តាមដានវឌ្ឍនភាពសកម្មភាពនៃសូចរនាករតាមដានរួម

៧.១ ពិនិត្យចំណាយសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ វិស័យកសិកម្ម និងទឹក

តាមរយៈឯកសារចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ [28] ចំពោះចំណាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញថាមានគម្រោងចំណាយមួយចំនួន ដែលមិនបានទទួលនូវការគាំទ្រហិរញ្ញប្បទាន ដែលក្នុងនោះក៏មានគម្រោងមួយដែលផ្តោតទៅលើការបង្កើនផលិតភាព ដំណាំស្រូវនៅតំបន់ទំនាប។ គម្រោងនេះមានសារសំខាន់សម្រាប់ឆ្លើយតបទៅនឹងគោលនយោបាយនាំអង្ករចេញ។ ដោយ ឡែកចំពោះឯកសារចំណាយមូលធន របស់ក្រសួងធនធានទឹក និងឧត្តុនិយមក៏ពុំទាន់មានការគាំទ្រថវិកា លើការអនុវត្ត គម្រោងការពារទឹកជំនន់ និងគ្រោះរាំងស្ងួតនៅឡើយទេ។ កត្តាគ្រោះទឹកជំនន់ និងរាំងស្ងួតនេះ វាបានជះឥទ្ធិពលយ៉ាង ខ្លាំង ដល់ផលិតភាព និងផលិតផលកសិកម្ម ពីព្រោះកសិកម្មនៅកម្ពុជា នៅមានភាពពឹងផ្អែកលើ ធម្មជាតិនៅឡើយ។

អនុសាសន៍៖

- ជំរុញឲ្យមានការគាំទ្រទៅលើគម្រោងបង្កើនផលិតភាពដំណាំស្រូវនៅតំបន់ទំនាបជាអាទិភាព ដើម្បីចូលរួមចំណែក ក្នុងការបង្កើននូវផលិតផលស្រូវ និងឆ្លើយតបនឹងគោលនយោបាយនាំស្រូវចេញរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយ គាំទ្រកំចី សម្រាប់ប្រមូលទិញស្រូវរបស់សហគមកសិករ។
- គួរបង្កើនការចំណាយលើការ រៀបចំប្រពន្ធ័ធារាសាស្ត្រខ្នាតតូច និងមធ្យម ដើម្បី គ្រប់គ្រងទឹកសម្រាប់ប្រើប្រាស់ និងបង្ការក្នុងការស្រោចស្រពទៅលើវិស័យកសិកម្មនៅក្នុងអំឡុងពេល និងក្រោយពេលទឹកជំនន់ និងរាំងស្ងួត ។

៧.២ រៀបចំផែនទីចង្អុលផ្លូវ ដើម្បី អនុវត្តយុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក

ដោយផ្អែកទៅលើរបាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១០-២០១១ និង ទិសដៅសកម្មភាពសម្រាប់ឆ្នាំ ២០១១-២០១២ ចុះនៅខែមេសា ២០១១[29] និងរបាយការណរបស់ក្រសួងធនធានទឹក និង ឧតុនិយម[30] សង្កេតឃើញថា នៅក្នុងរបាយការណ៍ទាំងពីរនេះពុំទាន់បានបង្ហាញអំពីសកម្មភាពនៃការរៀបចំផែនទី ចង្អុលផ្លូវ ដើម្បីអនុវត្តយុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹកនៅឡើយទេ។

អនុសាសន៍៖

សូមបន្តរៀបចំបង្កើតនូវផែនទីចង្អុលបង្ហាញផ្លូវ សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីកសិកម្ម និងទឹក និងផ្តល់ឱកាស ឲ្យ មានពិគ្រោះយោបល់ឲ្យបានទូលំទូលាយជាមួយនឹងសង្គមស៊ីវិល និងធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដល់អ្នកដែល ពាក់ពន្ធ័។

៧.៣ *(មិនមានការលើកឡើង)*

៧.៤ *(មិនមានការលើកឡើង)*

៧.៥ បង្កើនការប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពល្អ និងការប្រើប្រាស់ជីដែលសមស្រប

ឆ្លងកាត់តាមរយៈរបាយការណ៍បូកសរុបការងារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១០-២០១១ ចុះនៅខែមេសា ឆ្នាំ២០១០ យើងខ្ញុំសូមចូលរួមអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការរៀបចំឲ្យមានជាមន្ទីរពិសោធន៍ទៅលើការស្រាវជ្រាវរកពូជស្រូវ និងដំណាំដែល

[28] ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២

[29] របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១០-២០១១ និងទិសដៅឆ្នាំ២០១២

[30] របាយការណ៍សកម្មភាព និងលទ្ធផលការងារលើវិស័យធនធានទឹក និងឧត្តុនិយម ប្រចាំឆ្នាំ២០១១

មានគុណភាព និងពូជសុទ្ធនៅតាមស្ថានីយ៍ពិសោធន៍ និងបានធ្វើការផ្សព្វផ្សាយបន្តទៅដល់កសិករ។ នៅក្នុងរបាយការណ៍នោះយើងសង្កេតឃើញថា ទិន្នផលស្រូវដែលមានការកើនឡើងនៅ ឆ្នាំ២០១០ ក្នុងកម្រិត៨.៧៥% ដែលបញ្ជាក់ឲ្យឃើញថាវាបណ្តាលមកពីកត្តាការប្រើប្រាស់ពូជដែលមានគុណ ភាពល្អជាកត្តារួមផ្សំមួយយ៉ាងសំខាន់។ ប៉ុន្តែទន្ទឹមនឹងការកើនឡើងនូវវឌ្ឍនភាពនៃទិន្នផលស្រូវនេះ វាក៏បាន សបញ្ជាក់ឲ្យឃើញពីការប្រើប្រាស់សារធាតុគីមី (ជីនិងថ្នាំកសិកម្ម)របស់កសិកររនៅមិនទាន់មានភាពត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស ដែលបណ្តាលឲ្យមានការប៉ះពាល់ ដល់សេដ្ឋកិច្ចប្រាក់ចំណេញសុខភាព និងបរិស្ថាន។

អនុសាសន៍៖

- សូមបន្តសកម្មភាពពិសោធន៍ស្រាវជ្រាវរកនូវប្រភេទពូជដែលមានគុណភាព និងទទួលបានទិន្នផលខ្ពស់ ប៉ុន្តែមិនប៉ះពាល់ដល់បរិស្ថាន និងសុខភាពទាំងអ្នកផលិត និងអ្នកប្រើប្រាស់ និងផ្សព្វផ្សាយឲ្យបានកាន់តែទូលំទូលាយដល់កសិករ ជាពិសេសពូជស្រូវ និងដំណាំសំខាន់ផ្សេងៗ ដើម្បីចូលរួមចំណែកឲ្យសម្រេចបាននូវគោលនយោបាយនាំអង្ករចេញនៅឆ្នាំ២០១៥ ។
- សូមគ្រប់គ្រងការធ្វើអាជីវកម្ម និងការប្រើប្រាស់សម្ភារកសិកម្មប្រកបដោយសុវត្ថិភាព និងទទួលខុសត្រូវត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស និងសុំឲ្យមានការផ្សព្វផ្សាយពីបច្ចេកទេសក្នុងការប្រើប្រាស់ រួមនឹងហានិភ័យ ដែលបណ្តាលពីការប្រើប្រាស់ ជីនិង ថ្នាំកសិកម្ម និងជំរុញឲ្យមានការផ្សព្វផ្សាយច្បាប់គ្រប់គ្រងជី និងថ្នាំកសិកម្ម ឲ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធ ជាពិសេសដល់កសិកររដែលអ្នកដែលប្រើប្រាស់ផ្ទាល់។

៧.៦ បង្កើនចំនួនអង្គការកសិករ

តាមរបាយការណ៍បូកសរុបការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១០-២០១១ បានបង្ហាញពីភាពចាំបាច់ និងការកើនឡើងនៃចំនួនអង្គការកសិករ។ យើងសូមអបអរសាទរចំពោះលទ្ធផលដែលសម្រេចបានក្នុងការបង្កើនចំនួនអង្គការកសិករ។

អនុសាសន៍៖

- ដើម្បីឲ្យអង្គការកសិកររដែលបានបង្កើតឡើងប្រកបដោយមានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាព ស្នើសុំឲ្យមានការពិគ្រោះយោបល់ ពីសំណាក់សហគមន៍នៅស្រទាប់ក្រោម ដើម្បីឲ្យមានភាពម្ចាស់ការ [31]។
- សូមបន្តគាំទ្រដល់អង្គការកសិកររដែលមានស្រាប់ ទាំងសហគមន៍កសិកររប្រើប្រាស់ទឹក និងសហគមន៍កសិករទូទៅដែលបង្កើតដោយក្រុមកសិករ និងដោយអង្គការមិនមែនរដ្ឋាភិបាលនានា
- សូមជួយរកទីផ្សារកសិផលដើម្បីឲ្យអង្គការកសិករទទួលបានតម្លៃកសិផលសមស្រប និងអាចចំណេញសម្រាប់បង្កើនជីវភាពគ្រួសារ។

៧.៧ បង្កើនផ្ទៃដីស្រោចស្រព ១% (២៥.០០០ ហិចតាក្នុង ១ឆ្នាំ)

តាមរយៈរបាយការណ៍របស់ក្រសួងធនធានទឹក និងឧត្តុនិយមប្រចាំឆ្នាំ២០១១ យើងខ្ញុំសូមអបអរសាទរចំពោះលទ្ធផលដែលក្រសួងធនធានទឹក និងឧត្តុនិយមបានសម្រេច ក្នុងការបង្កើនផ្ទៃដីស្រោចស្រពរហូតដល់ ៣៨.៧៩៦ហិកតា បើប្រៀបធៀបជាមួយនឹងឆ្នាំ២០១០ [32] ។ ប្រសិទ្ធភាពនៃប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតនៅឡើយ ដោយសារ

[31] ផែនការសកម្មភាពស្តីពី ការគ្រប់គ្រង និងការអភិវឌ្ឍលើវិស័យធនធានទឹក និងឧត្តុនិយម ដើម្បីរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី២ (២០០៩-២០១៣)

[32] របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងាររលើវិស័យធនធានទឹក និងឧត្តុនិយមប្រចាំឆ្នាំ ២០១១

ប្រព័ន្ធទាំងនោះមិនត្រូវបានធ្វើការសាងសង់ ឬជួសជុលទាំងស្រុងនោះទេ ហើយតាមរយៈរបាយការណ៍ក្រសួងធនធានទឹក និងឧតុនិយមប្រចាំឆ្នាំ២០១១បានបង្ហាញថា សកម្មភាពភាគច្រើនដែលសម្រេចបានគ្រាន់ជាការស្តារ និងជួសជុលឡើង វិញ។

អនុសាសន៍៖

គប្បីពង្រឹង និងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធស្រោចស្រពឲ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសលទ្ធភាពក្នុងការស្រោចស្រពនៅរដូវប្រាំង ប្រព័ន្ធប្រឡាយរងដើម្បីឲ្យអាចមានលទ្ធភាពស្រោចស្រពដល់វាលស្រែដែលនៅឆ្ងាយ ពីប្រឡាយមេជាដើម។

៧.៨ បង្កើនចំនួនសហគមន៍កសិករអ្នកប្រើប្រាស់ទឹក

យើងខ្ញុំសូមអបអរសាទរចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្រសួងធនធានទឹក និងឧតុនិយមដែលបានខិតខំប្រឹងប្រែងបង្កើតនិងបង្កើនសហគមន៍កសិករអ្នកប្រើប្រាស់ទឹកឲ្យមានចំនួនកើនឡើង។ ទោះបីមានការកើនឡើងនូវចំនួនសហគមន៍កសិករអ្នកប្រើប្រាស់ទឹកយ៉ាងនេះក្តី ក៏យើងនៅតែសង្កេតឃើញថាមានបញ្ហាមួយចំនួនកើតឡើងផងដែរ រួមមាន គម្រោងប្រព័ន្ធធារាសាស្ត្រខ្លះពុំមានបង្កើតជាសហគមន៍កសិករអ្នកប្រើប្រាស់ទឹក ជាក់ស្តែងគម្រោងធារាសាស្ត្រដែលផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាល។ លើសពីនេះទៅទៀតមានគម្រោងធារាសាស្ត្រខ្លះទៀតដែល បានបង្កើតសហគមន៍កសិករអ្នកប្រើប្រាស់ទឹករួចហើយ ប៉ុន្តែមានភាពអសកម្ម។ ជាក់ស្តែងនៅខេត្តតាកែវ មានសហគមន៍អ្នកប្រើប្រាស់ទឹកសរុបចំនួន២៦សហគមន៍ ប៉ុន្តែមានត្រឹមតែ១១សហគមន៍អ្នកប្រើប្រាស់ទឹកតែប៉ុណ្ណោះ ដែលបានចុះឈ្មោះក្នុងក្រសួងធនធានទឹក និងឧតុនិយម ហើយមានត្រឹមតែ២០%ប៉ុណ្ណោះដែលកំពុងដំណើរការ។ រីឯសហគមន៍អ្នកប្រើប្រាស់ទឹកដទៃៗទៀតដំណើរការមិនបានល្អ ឬមិនដំណើរការ[33]។ ភាពអសកម្មនៃសហគមន៍កសិករអ្នកប្រើប្រាស់ទឹក ទាំងនេះបណ្តាលមកពីមានការខ្វះចំនួនគណៈកម្មការគ្រប់គ្រង គណៈកម្មការគ្រប់គ្រងពុំមានអំណាចក្នុងការដឹកនាំដោយសារមានជំនាស់ផលប្រយោជន៍ជាដើម សមត្ថភាពរបស់គណៈកម្មការនៅមានកម្រិត ដែលបណ្តាលឲ្យមានការលំបាកក្នុងការសម្របសម្រួលក្នុងការចែកចាយទឹក។

អនុសាសន៍៖

- ស្នើសុំពង្រឹងតួនាទី និងការទទួលខុសត្រូវនៅក្នុងគណៈកម្មការសហគមន៍កសិករអ្នកប្រើប្រាស់ទឹក និងការដឹកនាំ។ ដោយពួកគេត្រូវមានតួនាទីក្នុងការផ្តល់ព័ត៌មានដល់កសិកររនៅពេលបញ្ចេញបញ្ចូលទឹក។ គណៈកម្មការគួរតែឲ្យមានប្រសិទ្ធភាពក្នុងការដឹកនាំក្រុមនេះប្រកបដោយប្រសិទ្ធភាព។
- គួរបង្កើតឲ្យមានគណៈកម្មការ សហគមន៍កសិករអ្នកប្រើប្រាស់ទឹក ពីគម្រោងដែលផ្តល់ហិរញ្ញប្បទានដែលផ្តល់ដោយរាជរដ្ឋាភិបាល។ គេសង្កេតឃើញថាមានតែគម្រោងហិរញ្ញប្បទានដែលផ្តល់ដោយម្ចាស់ជំនួយនានាតែប៉ុណ្ណោះដែលមាន រៀបចំបង្កើតគណៈកម្មការសហគមន៍កសិករអ្នកប្រើប្រាស់ទឹក។

៣. សកម្មភាព/យុទ្ធសាស្ត្រសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩- ២០១៣

កថាខណ្ឌ	ខ្លឹមសារ
៣៩៦	ដើម្បីបង្កើនផលិតកម្ម ការងារ និងប្រាក់ចំណូលនៅជនបទ និងធានាសន្តិសុខស្បៀងក៏ដូចជាបង្កើនការនាំចេញផលិតផលកសិកម្ម

[33] ការស្រាវជ្រាវស្តីពី ការរៀនសូត្រពីគម្រោងធារាសាស្ត្រនៅកម្ពុជា៖ អត្ថប្រយោជន៍ និងបញ្ហាប្រឈម (NGOF, ២០១០)

៣៩៨	ការបង្កើនការយកចិត្តទុកដាក់ក្នុងការស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្មកសិកម្ម ដែលកំពុងចាក់ឫសបន្តិចម្តងៗ និងការកើនឡើងនៃតម្លៃស្រូវអង្ករ ពោត សណ្តែក ដំឡូង និងកៅស៊ូ នឹងផ្តល់នូវការលើកទឹកចិត្តបន្ថែមទៀត ដល់ការអនុវត្តគោលនយោបាយពិពិធភាវូបនីយកម្មកសិកម្មនេះ។
៤០២	ដើម្បីជំរុញកំណើនផលិតកម្មកសិកម្ម សម្រាប់អំឡុងឆ្នាំ ២០០៩-២០១៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានា

៣៩៦ ដើម្បីបង្កើនផលិតកម្ម ការងារ និងប្រាក់ចំណូលនៅជនបទ និងធានាសន្តិសុខស្បៀងក៏ដូចជាបង្កើនការ នាំចេញផលិតផលកសិកម្ម

ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុង ផ្តោតការយកចិត្តទុកដាក់ជំរុញការនាំចេញផលិតផលកសិកម្ម ដូចជាការនាំអង្ករចេញជាដើម យើងមានការព្រួយបារម្ភចំពោះការគ្រប់គ្រង និងការផ្សព្វផ្សាយបច្ចេកវិទ្យាទៅដល់កសិកររនៅមិនទាន់បានទូលំទូលាយនៅឡើយ។

អនុសាសន៍៖

- រាជរដ្ឋាភិបាលគួរពង្រឹង និងបន្តគាំទ្រសហគ្រាសកសិកររលើសេវាផ្តល់ឥណទានលើម៉ាស៊ីនកិនស្រូវ សម្រាប់ការប្រមូលទិញ និងស្តុកស្រូវទុក ដើម្បីកាត់បន្ថយការនាំចេញស្រូវដោយមិនមានការអនុញ្ញាត្តិត្រឹមត្រូវ និងរក្សាបាននូវសន្តិសុខស្បៀង ក៏ដូចជាធានាឆ្លើយតបនឹងគោលនយោបាយនាំផលិតផលស្រូវ និងអង្ករចេញនៅ ឆ្នាំ២០១៥ ឲ្យបាន ១លានតោនក្នុងឆ្នាំ២០១៥។
- គួរកំណត់ឲ្យបានច្បាស់នូវក្រុមកសិកររគោលដៅដែលទទួលផលប្រយោជន៍នៃសកម្មភាពនីមួយៗ ដោយផ្តោតលើកសិករតូចតាច និងការលើកកំពស់ការអនុវត្តកសិកម្មចម្រុះ និងកសិកម្មសរីរាង្គជាជាងកសិដ្ឋានខ្នាតធំដែល ដាំដំណាំតែមួយប្រភេទ ឬកសិឧស្សាហកម្មដែលពឹងផ្អែកលើការប្រើប្រាស់ ថ្នាំកសិកម្ម និងជីគីមីច្រើន ឬការប្រើប្រាស់ពូជដែលមានតម្លៃខ្ពស់ ដែលអាចបណ្តាល ឲ្យកសិករតូចតាច និងអ្នកក្រីក្រមិនទទួលបាននូវអត្ថប្រយោជន៍ពីយុទ្ធសាស្ត្រនេះ និងពុំបានឆ្លើយតបនឹងការធានានូវសន្តិសុខស្បៀងផងដែរ។

៣៩៨ ពង្រឹងប្រព័ន្ធនៃសេវាផ្សព្វផ្សាយកសិកម្ម និងបច្ចេកទេសកសិកម្ម

ឆ្លងតាមសកម្មភាពជាក់ស្តែង និងរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញពីការខិតខំប្រឹងប្រែងក្នុងការបង្កើនការផ្សព្វផ្សាយផ្នែកបច្ចេកទេសកសិកម្មដល់កសិកររនៅតាមតំបន់ជនបទ។

អនុសាសន៍៖

- គប្បីផ្តល់ការគាំទ្រ និងបន្តការគាំទ្រដល់អង្គការសហគមន៍មូលដ្ឋាន ទាក់ទងនឹងសេវាផ្តល់ប្រឹក្សាផ្នែកបច្ចេកទេសកសិកម្ម ការផលិតនិងបន្សុទ្ធពូជស្រូវ ជីធម្មជាតិ ថ្នាំកសិកម្មផ្សំពីរុក្ខជាតិ ការគ្រប់គ្រងមុន និងក្រោយពេលប្រមូលផលជាដើម ដើម្បីរក្សាបាននូវធនធានក្នុងស្រុក និងការការពារពូជក្នុង ស្រុក។
- បង្កើនធនធានថវិកា និងធនធានមនុស្សក្នុងការស្រាវជ្រាវផ្នែកបច្ចេកទេសកសិកម្ម ការផ្តល់ប្រឹក្សាផ្នែកកសិកម្ម ការចងក្រងបទពិសោធន៍ និងលើកទឹកចិត្តកសិករឲ្យចេះចែករំលែកបទពិសោធន៍នៅក្នុងតំបន់ជនបទ និងលើកទឹកចិត្តការស្រាវជ្រាវដោយអ្នកជំនាញ និងការស្រាវជ្រាវដោយកសិករនៅក្នុងតំបន់ផ្ទាល់។

៤០២ យើងខ្ញុំសូមអបអរសាទរ ចំពោះការសម្រេចបាននូវការរៀបចំនូវច្បាប់ និងបទដ្ឋានមួយចំនួន ដើម្បីជំរុញកំណើនផលិតកម្មកសិកម្ម សម្រាប់អំឡុងឆ្នាំ ២០០៩-២០១៣ ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាមួយចំនួន។

អនុសាសន៍៖

សូមបន្ត និងជំរុញឲ្យមានការរៀបចំ និងពិគ្រោះយោបល់ទៅលើសេចក្តីព្រាងច្បាប់និងអនុក្រឹត្យនានា ដូចជាច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម ឲ្យបានកាន់តែឆាប់រហ័ស ដើម្បីធានាបាននូវផលិតផលកសិកម្មដែលមានគុណភាព សុវត្ថិភាពនិងធានាឲ្យបាននូវសុខមាលភាពដល់ទាំងអ្នកផលិត និងអ្នកបរិភោគ។

៤. បញ្ហាសំខាន់ៗដែលមិនមានក្នុងសូចនាករតាមដានរួម និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩ ២០១៣

យុវជននៅជនបទកាន់តែច្រើន និងកំពុងប្រឈមមុខនឹងអនាគតមិនប្រាកដប្រជា ដោយសារពួកគេមិនមានជំនាញ និងចំណេះដឹងមូលដ្ឋានចាំបាច់ ដើម្បីបន្តវេន និងគ្រប់គ្រងសេដ្ឋកិច្ចជនបទរបស់ខ្លួន ខណៈដែលមិនសូវមានឱកាសការងារក្រៅពីវិស័យកសិកម្មនៅជនបទ និងនៅតាមតំបន់ទីក្រុង។

អនុសាសន៍៖

គប្បីផ្តល់អាទិភាពនិងគាំទ្រឲ្យមានកម្មវិធីបណ្តុះបណ្តាល និងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់សិស្សនៅតាមវិទ្យាល័យ និងយុវជនដែលមិនបានទទួលការអប់រំនៅក្នុងសហគមន៍ជនបទ ដាក់បញ្ចូលបញ្ហានេះទៅក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ដើម្បីលើកទឹកចិត្តយុវជនជនបទបន្តចូលរួមលើកស្ទួយវិស័យកសិកម្មឲ្យមានវឌ្ឍនភាព

៥. អនុសាសន៍

អនុសាសន៍ខាងក្រោមនេះផ្តោតលើផែនការយុទ្ធសាស្ត្រ បទបញ្ញត្តិនានា និងកិច្ចសហប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពស្បៀង ការកាត់បន្ថយនូវភាពក្រីក្រ ការអភិវឌ្ឍន៍កសិ-អាជីវកម្មខ្នាតតូច និងមធ្យម ក្នុងចំណោមប្រជាកសិករនៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា៖

បង្កើតនូវប្រពន្ធ័ប្រពលវប្បកម្មកសិកម្មប្រកបដោយប្រសិទ្ធភាពតាមរយៈ ការលើកកំពស់ការផ្តល់នូវធនធានថវិកា និងធនធានមនុស្សក្នុងការអនុវត្តការងារនេះ ដើម្បីជាការគាំទ្រទៅលើការអនុវត្តល្អៗរបស់កសិករដូចជា ការអនុវត្តនូវបច្ចេកទេសធ្វើស្រែតាមបែបប្រពលវប្បកម្មដំណាំស្រូវ (SRI)។ រាជរដ្ឋាភិបាលគួរតែមានដាក់បញ្ចូលនូវកញ្ចប់ថវិកាទៅឲ្យអាជ្ញាធរមូលដ្ឋានសម្រាប់គាំទ្រទៅលើការរៀបចំប្រពន្ធ័ធារាសាស្ត្រខ្នាតតូច និងមធ្យម។

រាជរដ្ឋាភិបាលគួរតែមាន កញ្ចប់ថវិកាទៅដល់អាជ្ញាធរមូលដ្ឋាន ក្នុងការគាំទ្រកសិករក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈកិច្ចសិក្សាបង្កើត ឲ្យមានវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ទៅដល់យុវជននៅថ្នាក់មូលដ្ឋាន ចំពោះអ្នកដែលមានការចាប់អារម្មណ៍ក្នុងការធ្វើ ពាណិជ្ជកម្មលើវិស័យកសិកម្មបង្កើនការអប់រំទាក់ទងនឹងថ្នាំកសិកម្ម និងជំរុញការរៀបចំ និងអនុវត្តច្បាប់ក្នុងការគ្រប់គ្រងច្បាប់ថ្នាំកសិកម្ម រដ្ឋាភិបាល ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម គប្បីដាក់បញ្ចូលបញ្ហាគ្រប់គ្រងសារធាតុគីមីកសិកម្ម រួមមានថ្នាំកសិកម្ម និងជីកសិកម្ម ទៅក្នុងផែនការយុទ្ធសាស្ត្រកសិកម្ម និងទឹក (SAW)។

គប្បីផ្សព្វផ្សាយជាសាធារណៈ និងឲ្យបានទូលំទូលាយ **ច្បាប់គ្រប់គ្រងថ្នាំ និងជីកសិកម្ម**។ ច្បាប់នេះនឹងផ្តល់ជាមូលដ្ឋានសម្រាប់ពង្រឹងការអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពនូវការគ្រប់គ្រងការធ្វើពាណិជ្ជកម្ម ការនាំចូល ការនាំចេញ និងការ

ប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្មឲ្យមានប្រសិទ្ធភាព និងកាន់តែប្រសើរដើម្បីកាត់បន្ថយគ្រោះ ថ្នាក់ពីការប្រើប្រាស់ថ្នាំ និងជីកសិកម្ម។

បន្តជំរុញ និងបង្កើននូវផលិតកម្មកសិកម្មជាពិសេស ផលិតផលស្រូវ ឲ្យកាន់តែមានគុណភាព និងមានកម្រិត ស្តង់ដារទៅតាមតំរូវការ ទីផ្សារក្នុងតំបន់ និងអន្តរជាតិដើម្បីឆ្លើយតបនិងសម្រេចបាននូវគោលនយោបាយផលិតស្រូវ និងការ នាំអង្ករចេញ ។

ប្តេជ្ញាចិត្តក្នុងកិច្ចសហប្រត្តិការ និងចែករំលែកព័ត៌មានក្នុងចំណោមដៃគូអភិវឌ្ឍន៍ រាជរដ្ឋាភិបាល សង្គមស៊ីវិល លើការអប់រំ និងបង្កើនការយល់ដឹងក្នុងចំណោមកសិកររនៅតំបន់ជនបទ។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
លោក ឈិត សំអាត នាយកប្រតិបត្តិ
ទូរស័ព្ទ: (៨៥៥-២៣) ២១៤ ៤២៩
ទូរសារ: (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
គេហទំព័រ: www.ngoforum.org.kh និង www.cambodianbudget.org
អាស័យដ្ឋាន: ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)
លោក បណ្ឌិត យ៉ង សាំងកុមារ ប្រធាន
ទូរសព្ទ័លេខ៖ (៨៥៥-១២) ៨០២ ២០១
អ៊ីម៉ែល៖ yskoma@cedac.org.kh
គេហទំព័រ៖ www.cedac.org.kh
អាសយដ្ឋាន៖ ផ្ទះលេខ ១១៩ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ

កំណែទម្រង់ដីធ្លី

១. សេចក្តីផ្តើម

សូចនាករតាមដានរួម (JMIs) ខាងក្រោមត្រូវបានយល់ព្រមដោយការប្រជុំវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) លើកទីបីកាលពីថ្ងៃទី០២-០៣ ខែ មិថុនា ឆ្នាំ២០១០ និងមានចេតនាធ្វើឲ្យបានសម្រេចក្នុងរយៈពេលប្រហែល១៨ ខែ ។ កាលពីចុងឆ្នាំ ២០១១ រដ្ឋាភិបាលកម្ពុជាខកខានកោះហៅឲ្យមានការប្រជុំ វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) និងគណៈកម្មការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ (GDCC) ដូច្នេះហើយ សូចនាករតាមដានរួម មិនត្រូវបានបង្កើតឡើយ។ ឯកសារគោលជំហរនេះត្រូវបាន ផ្តល់យោបល់ រហូតដល់ខែសីហា ឆ្នាំ២០១២ ។

យើងទាំងអស់គ្នាសូមស្វាគមន៍ចំពោះបទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្អាកជាបណ្តោះអាសន្នក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងធ្វើការសើរើឡើងវិញចំពោះសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់។ បទបញ្ជារាប់បញ្ចូលទាំងបទបញ្ញាត្តិដែលទាក់ទិនទៅនឹងការអនុវត្ត គោលនយោបាយស្បែកខ្លា ។ ការអនុវត្តផែនការផ្តល់ប័ណ្ណកម្មសិទ្ធិបានត្រូវចាប់ផ្តើម និងសម្រេចបាន ៧០០០០ ក្បាលដី គិតរហូតដល់ដើមខែសីហា២០១២។ សង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនេះ ដែលអាចឃ្លាំមើលការអនុវត្ត ដើម្បីធានាឲ្យបានជោគជ័យដល់គោលដៅ ។

ទោះបីជាយ៉ាងណាក៏ដោយ ការទទួលបានដីដោយសមធម៌ និងសុវត្ថិភាពនៃការកាន់កាប់ដីសម្រាប់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះនៅទីប្រជុំជន និងជនបទមិនទាន់សម្រេចបាននៅឡើយ។ សហគមន៍ក្រីក្រនៅទីប្រជុំជន បន្តប្រឈមនឹងអសុវត្ថិភាពដីធ្លីនិងការផ្លាស់ប្តូរលំនៅដោយបង្ខំជាប្រចាំ។ ការផ្លាស់ប្តូរលំនៅដោយបង្ខំបែបហិង្សាកើតឡើងនៅទីប្រជុំជនជាពិសេសរាជធានីភ្នំពេញក៏ដូចជានៅតំបន់ជនបទ។ សង្គមស៊ីវិលមានការព្រួយបារម្ភចំពោះការកើនឡើងនូវ ការប្រើប្រាស់កំលាំងប្រដាប់អាវុធទាក់ទងនឹងជំលោះដីធ្លី។ យើងសង្កេតឃើញការកើនឡើងនូវអំពើហិង្សារវាងអាជ្ញាធរដែលប្រដាប់ដោយអាវុធ និងប្រជាពលរដ្ឋដែលការពារសិទ្ធិដីធ្លី និងធនធានធម្មជាតិដោយសន្តិភាព។ ឧប្បត្តិហេតុទាំងនោះតែងតែរំខានដោយសារតែពួកគេបង្ហាញពីការបង្កើនការត្រៀមលក្ខណៈជាស្រេចផ្នែកសន្តិសុខ និងកម្លាំងយោធាដើម្បីប្រើការប្រឆាំងដោយបង្ខំនឹងប្រជាពលរដ្ឋ។

២. សូចនាករតាមដានរួម

ស្ថាប័នសម្របសម្រួល៖ MLMUPC/GS CLP, SLC, GDCG, SNCDD MOI, GSSCL **ស្ថាប័នអនុវត្ត៖ MLMUPC/GS CLP, SLC, GDCG, SNCDD MOI, GSSCL**				
លទ្ធផលរយៈពេលមធ្យម	**ធាតុចេញ**	**សូចនាករធាតុចេញ**	**សកម្មភាព៖ ចំនុចដៅសម្រាប់វាស់វែង**	**សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ**
១. លើកស្ទួយវិស័យ រដ្ឋបាលដីធ្លី និងសុវត្ថិ ភាពនៃការកាន់កាប់ដីធ្លី	១. គោលនយោបាយរដ្ឋបាលដីធ្លី ការបែងចែកដី និងការគ្រប់គ្រងដីធ្លី ត្រូវបានពង្រឹង ២. ការចុះបញ្ជីដីធ្លីត្រូវបានពង្រឹងដោយផ្តោតលើគ្រួសារក្រីក្រ/ងាយរងគ្រោះ	១. សេចក្តីព្រាងគោលនយោបាយស្តីពីការវាយតម្លៃថ្លៃដី ២. សេចក្តីព្រាងគោលនយោបាយលំនៅឋាន ៣. កម្មវិធីអនុវិស័យគ្រប់គ្រងដីត្រូវបានអនុម័ត ៤. ប័ណ្ណកម្មសិទ្ធិដីមានលក្ខណៈជាប្រព័ន្ធចំនួន ១,៧លាន ត្រូវ	១. ពិភាក្សាផ្ទៃក្នុង ២. ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ៣. កែសម្រួលសេក្តីព្រាង ៤. ដាក់ជូនទៅក្រុមប្រឹក្សាគោល នយោបាយដីធ្លី ៥. បង្កើតកម្មវិធីអនុ វិស័យគ្រប់គ្រងដីធ្លី	១. ពង្រឹងយន្តការតាមដាន និងវាយតម្លៃ (សម្រាប់វិស័យដីធ្លី)

		បានចែកជូនប្រជាពលរដ្ឋ ៥. (ទិន្នន័យមូលដ្ឋាន៖ ប័ណ្ណកម្មសិទ្ធិ ចំនួន ១,២ លាន ត្រូវបានចែកជូនប្រជាពលរដ្ឋ) ៦. ភាគរយនៃស្ត្រីដែលមានប័ណ្ណកម្មសិទ្ធិដីធ្លី មានចំនួនច្រើនជាងបុរសដែលមានប័ណ្ណកម្មសិទ្ធិដីធ្លី ៧. (ទិន្នន័យមូលដ្ឋាន៖ cadastral Database) ៨. សហគមន៍ជនជាតិដើមភាគតិច ចំនួនបីត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាព	៦. អនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនៃកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី LASSP នៅក្នុងខេត្តចំនួន ១៥	
២. បង្កើនសមធម៌នៅក្នុងការបែងចែកដី	៣. ការអនុវត្តយន្តការសម្បទានដីសង្គមកិច្ច	៩. ពីខែមករា ឆ្នាំ២០១០ ដល់ខែធ្នូ ឆ្នាំ២០១១ ចំនួនឃុំដែលបានស្នើផែនការប្រើ ប្រាស់ដី ដែលបានឯកភាព កើនឡើងដល់ចំនួន ២០ (ទិន្នន័យមូលដ្ឋាន៖ ចំនួន ១០ ឃុំ) ១០. កម្មវិធីអនុវិស័យបែងចែកដីត្រូវបានអនុម័ត ១១. លទ្ធភាពស្វែងរកដីដែលសមស្របនៅទូទាំង ប្រទេស សម្រាប់សម្បទានដីសង្គមកិច្ច	៧. អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ៨. បង្កើតកម្មវិធី អនុវិស័យបែងចែកដី ៩. រៀបចំផែនទីចំពោះតំបន់ដែលមានដីទំនេរនិងសមស្របសម្រាប់ សម្បទានដីសង្គមកិច្ច	២. ដូចខាងលើ ៣. រៀបចំយន្តការតាមដាននិងវាយតម្លៃសម្រាប់កម្មវិធីអនុវិស័យបែងចែកដី

២.១. លើកស្ទួយវិស័យរដ្ឋបាលដីធ្លី និង សុវត្ថិភាពនៃការកាន់កាប់ដី

២.១.១. គោលនយោបាយសម្រាប់រដ្ឋបាល បែងចែក និង គ្រប់គ្រងដីត្រូវបានពង្រឹង

២.១.១.១. *សេចក្តីព្រាងគោលនយោបាយស្តីពីការវាយតម្លៃថ្លៃដី*

អង្គការមិនមែនរដ្ឋាភិបាល សូមស្វាគមន៍ការខិតខំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី/ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(CLPs/MLMUPC) ក្នុងការបញ្ចាក់ពីតំណាងសង្គមស៊ីវិល (ចំណុច ៥.៣ ក្នុងឯកសារភាសាខ្មែរ) ត្រូវតែបញ្ចូលជាសមាជិកនៅក្នុងគណៈកម្មាធិការវាយតម្លៃថ្លៃដីថ្នាក់ជាតិ រាជធានី/ខេត្ត និង ក្រុង/ស្រុក។

ទោះបីជាយ៉ាងនេះក្តី ឯកសារភាសាខ្មែរហាក់បីដូចជាមិនស៊ីចង្វាក់ជាមួយនឹងឯកសារភាសាអង់គ្លេស។ ដូច្នេះ ឯកសារភាសាអង់គ្លេស គប្បីចែងផងដែរ ថាការចូលរួមរបស់សង្គមស៊ីវិលនៅគ្រប់កម្រិតនៃ "គណៈកម្មាធិការវាយតម្លៃថ្លៃដី" គឺជាការចាំបាច់ ។

យើងខ្ញុំសូមលើកឡើងជាថ្មីនូវកង្វល់ទាំងឡាយដែលបានបង្ហាញរួចហើយ នៅក្នុងការពិគ្រោះយោបល់តាមមធ្យោបាយអេឡិកត្រូនិក-អ៊ីម៉ែល៖

- វិធីសាស្ត្រវាយតម្លៃថ្លៃដី៖ នីតិវិធីវាយតម្លៃថ្លៃដីគប្បីខ្លីដើម្បីជៀសវាងភាពខុសគ្នានៅក្នុងកាលៈទេសៈផ្សេងៗដែលមានឥទ្ធិពលលើតម្លៃដី។
- ជំហាននានានៃការអនុវត្តការវាយតម្លៃថ្លៃដី៖ ការរំលោភលើក្រមសីលធម៌គប្បីត្រូវដាក់ទណ្ឌកម្ម។ ក្រមសីលធម៌គប្បីស្របគ្នាជាមួយនឹងនីតិវិធីនៃការអនុវត្តការវាយតម្លៃថ្លៃដី។ ការដាក់ទណ្ឌកម្មលើការរំលោភក្រមសីលធម៌ គឺជាវិធីមួយសម្រាប់ធានាឲ្យបាននូវការវាយតម្លៃថ្លៃដីប្រកបដោយប្រសិទ្ធភាពនិងត្រឹមត្រូវ។

- ការប្រើប្រាស់ការវាយតម្លៃថ្លៃដីបែបរួម និងការវាយតម្លៃថ្លៃបែបជាក់លាក់៖ នៅក្នុងឯកសារភាសាខ្មែរនិងភាសាអង់គ្លេសការរាយមូលហេតុនៃភាពចាំបាច់នៃប្រព័ន្ធវាយតម្លៃថ្លៃដី ពាក់ព័ន្ធការហូតពន្ធតាមតម្លៃ គប្បីមានលក្ខណៈគិតគូរឲ្យបានជិតដល់បំផុត។
- យន្តការអនុវត្ត៖ នៅក្នុងឯកសារភាសាអង់គ្លេសគោលនយោបាយគួរបញ្ជាក់ថាតំណាងសង្គមស៊ីវិល ត្រូវបានរាប់បញ្ចូលនៅក្នុងគណៈកម្មាធិការវាយតម្លៃថ្លៃដីថ្នាក់ជាតិរាជធានី/ខេត្ត និងក្រុង/ស្រុក(ដោយសារចំណុចនេះក៏បានលើកឡើងផងដែរនៅក្នុងចំណុច ៥.៣ ការចូលរួមរបស់ផ្នែកឯកជន នៃឯកសារភាសាខ្មែរ)។ ម្យ៉ាងទៀតឯកសារភាសាអង់គ្លេសក៏គួរបញ្ជាក់ផងដែរថា ថ្នាក់ក្រុង/ស្រុកមានមានសមត្ថកិច្ចដោះស្រាយវិវាទលើការអនុវត្តការវាយតម្លៃថ្លៃដី(ចំណុចនេះក៏បានលើកឡើងផងដែរនៅក្នុងឯកសារភាសាខ្មែរ)។
- គណៈកម្មាធិការវាយតម្លៃថ្លៃដីក្រុង/ស្រុកគួរតែមានយន្តការមួយសម្រាប់ផ្តល់យោបល់ និងសំណើលើសេចក្តីសម្រេចណាមួយ (ឧទាហរណ៍ យន្តការតាមដាន) ជំនួសឲ្យគណៈកម្មាធិការថ្នាក់រាជធានី/ខេត្តនិងថ្នាក់ជាតិ។ ស្ថាប័នដែលទទួលពិចារណា សម្រេច និងផ្តល់មតិកែលម្អទៅឲ្យថ្នាក់ក្រុង/ស្រុកគប្បីមានលក្ខណៈឯករាជ្យ និង មានសមត្ថកិច្ចធ្វើសេចក្តីសម្រេចចិត្ត។
- គោលនយោបាយវាយតម្លៃថ្លៃដីគួរតែរួមមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងនីតិវិធីសម្រាប់ជ្រើសរើសតំណាងសង្គមស៊ីវិល ដើម្បីធានាថាពិធភាពនៃសង្គមស៊ីវិលត្រូវបានតំណាងយ៉ាងសមសម្រប។ តំណាងអង្គការសង្គមស៊ីវិល មិនគប្បីត្រូវបានរឹតត្បិតចំពោះតួនាទីជាអ្នកសង្កេតការណ៍សកម្មភាពណាមួយឡើយ។ ពួកគេគួរតែមានអាណត្តិមួយនៅក្នុងកិច្ច ដំណើរ ការដោះស្រាយវិវាទ នៅក្នុងគណៈកម្មាធិការវាយតម្លៃថ្លៃដីទាំងបីកម្រិត។
- ជាទូទៅ មន្ត្រីតាមដាននិងវាយតម្លៃថ្លៃដែលត្រូវបានចាត់ឲ្យដោះស្រាយវិវាទគួរតែបុគ្គលផ្សេងពីគណៈកម្មាធិការវាយតម្លៃថ្លៃដី និង គប្បីធ្វើសកម្មភាពក្នុងលក្ខណៈឯករាជ្យ។
- ទោះបីយ៉ាងក៏ដោយ មុនពេលធ្វើការវាយតម្លៃថ្លៃដីដ៏ត្រឹមត្រូវមួយ ចំណាត់ថ្នាក់ដី និងការធ្វើផែនការប្រើប្រាស់ដីត្រូវចងក្រងជាចាំបាច់។ យើងខ្ញុំសូមអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធទាំងឡាយសូមឲ្យចងក្រងឯកសារចំណាត់ថ្នាក់ដីទូទាំងប្រទេសមុនពេលវាយតម្លៃថ្លៃដី។ ដើម្បីពង្រឹងតម្លាភាពនៃការវាយតម្លៃថ្លៃដី យើងខ្ញុំសូមផ្តល់យោបល់ជារួមថាអង្គការមិនមែនរដ្ឋាភិបាលមានសមត្ថភាពចូលរួមសង្កេតនិងតាមដានការអនុវត្តការវាយតម្លៃថ្លៃដី។

យើងខ្ញុំសង្ឃឹមថាយោបល់ទាំងនេះ នឹងត្រូវបានលើកយកទៅពិចារណាដោយក្រសួង និងត្រូវបានដាក់បញ្ចូលក្នុងឯកសារចុងក្រោយមុនពេលអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី។ កិច្ចដំណើរការនៃការបញ្ចប់ និងការអនុម័តគោលនយោបាយគប្បីត្រូវបានពន្លឿន។ ដោយសារតែក្នុងឆ្នាំ២០១១ ពន្ធប្រចាំឆ្នាំ ត្រូវបានប្រមូលរួចហើយ ហើយតម្លៃពន្ធត្រូវបានកំណត់ដោយគណៈកម្មាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយប្រគល់សមត្ថកិច្ចតាមរយៈអនុក្រឹត្យ និងប្រកាស។

២.១.១.២. *សេចក្តីព្រាងគោលនយោបាយជាតិស្តីពីលំនៅឋាន*

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីលំនៅឋាន នៅមិនទាន់ត្រូវបានអនុម័តនៅឡើយ ហើយលើសពីនេះទៅទៀត ពុំមានការកំណត់ពេលវេលាច្បាស់លាស់សម្រាប់ការអនុម័ត និង ការអនុវត្តគោលនយោបាយនេះ នៅឡើយទេ។

ទោះបីជាក្នុងភាពជាក់ស្តែងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) បានសន្យាចែករំលែកឯកសារ ដែលបានធ្វើបច្ចុប្បន្នកម្មចុងក្រោយនៃសេចក្តីព្រាងគោលនយោបាយជាមួយអង្គការមិនមែនរដ្ឋាភិបាលមុនពេលដាក់សុំការអនុម័តក្តី[34] ក៏អង្គការមិនមែនរដ្ឋាភិបាលនៅតែមិនទាន់បាននៅឡើយទេ។ ពេលវេលា និងកិច្ចការពារដែលមានចែងក្នុងសេចក្តីព្រាងគោលនយោបាយស្តីពីលំនៅឋាន រួមមានការធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដែលនៅតែត្រូវបានចោទសួរដោយអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍។

[34] នៅក្នុងកិច្ចប្រជុំប្រចាំត្រីមាសជាមួយ MLMUPC កាលពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១១។

សហគមន៍ក្រីក្រនៅទីប្រជុំជននៅតែបន្តប្រឈមមុខនឹងអសុវត្ថិភាពនៃការកាន់កាប់ និងជាញឹកញាប់ត្រូវបានរងការបណ្តេញចេញដោយបង្ខំ។ ការបណ្តេញចេញដោយបង្ខំដោយប្រើហិង្សា នៅតែបន្តកើតឡើងនៅក្នុងតំបន់ទីប្រជុំជន ជាពិសេស នៅរាជធានីភ្នំពេញក៏ដូចជា នៅតំបន់ជនបទ។ ក្នុងឆ្នាំ២០១១ សមាជិកសហគមន៍បឹងកក់ក្នុងចំណោមសហគមន៍ផ្សេងទៀត បានទទួលរងការបណ្តេញចេញដោយបង្ខំ និង ការបាត់បង់សិទ្ធិលំនៅឋានរបស់ខ្លួន។

អង្គការមិនមែនរដ្ឋាភិបាល សូមស្វាគមន៍អនុក្រឹត្យដែលបានផ្តល់ដីទំហំ ១២,៤៤ ហិកតាពីគម្រោងអភិវឌ្ឍ ជូនប្រជាជនរងផលប៉ះពាល់នៅតំបន់បឹងកក់ សម្រាប់ការអភិវឌ្ឍនៅនឹងកន្លែង។ ប៉ុន្តែអនុក្រឹត្យនេះមិនបានកំណត់ទីកន្លែង និងព្រំប្រទល់ឲ្យបានច្បាស់លាស់បណ្តាលឲ្យសហគមន៍នៅតែមានការព្រួយបារម្ភនិងគ្មានសុវត្ថិភាព។ លើសពីនេះទៀត យើងខ្ញុំកត់សម្គាល់ដោយក្តីបារម្ភថាសមាជិកសហគមន៍មិនត្រូវបានរាប់បញ្ចូលក្នុងការអភិវឌ្ឍនៅនឹងកន្លែង។ ហើយការតវ៉ាពីសមាជិកសហគមន៍ត្រូវបានបំបែកដោយហិង្សា ។

នៅដើមឆ្នាំ ២០១២ ប្រជាពលរដ្ឋរស់នៅតំបន់បុរីកីឡានៅរាជធានីភ្នំពេញត្រូវបានបណ្តេញចេញដោយបង្ខំ។ [35] ប្រជាពលរដ្ឋខ្លះនៃប្រជាពលរដ្ឋរងផលប៉ះពាល់ ត្រូវបានផ្លាស់ប្តូរចេញចម្ងាយប្រហែល ៤៥ គីឡូម៉ែត្រ ពីទីកន្លែងបច្ចុប្បន្នរបស់ពួកគេ អ្នកខ្លះត្រូវបានរងរបួស ហើយអ្នកខ្លះទៀតត្រូវបានចាប់ខ្លួននិងឃុំខ្លួនក្នុងពន្ធនាគារ។ សាលារាជធានីភ្នំពេញបានគាំទ្រសកម្មភាពក្រុមហ៊ុន ដោយបានប្រើកងកម្លាំងប្រដាប់អាវុធក្នុងការអនុវត្តការបណ្តេញចេញដោយបង្ខំនេះ។

ការបណ្តេញចេញទាំងនេះ ត្រូវបានសាធារណៈជនរិះគន់ថាគ្មានការពិគ្រោះយោបល់ ការជូនដំណឹង ការផ្តល់សំណង ឬការតាំងលំនៅថ្មីសមរម្យឡើយ។ នៅពេលដែលមានផ្តល់សំណង ស្ទើរតែគ្រប់ករណីទាំងអស់ ប្រជាពលរដ្ឋត្រូវបានរងសម្ពាធ និងការបំភិតបំភ័យឲ្យទទួលយកសំណងមិនសមរម្យសម្រាប់លំនៅឋាន និងដីរបស់ពួកគាត់។

ការបណ្តេញចេញដោយបង្ខំនៅតែបន្តឲ្យមានការរំលោភសិទ្ធិមនុស្សយ៉ាងខ្លាំង។ ប្រទេសកម្ពុជា គឺជាភាគីមួយនៃសន្ធិសញ្ញាអន្តរជាតិនានា ត្រូវមានករណីកិច្ចទប់ស្កាត់ការបណ្តេញចេញដោយបង្ខំ និងការពារប្រជាពលរដ្ឋខ្លួនទល់នឹងការបណ្តេញចេញដោយបង្ខំ។

ការតាំងលំនៅថ្មីនៅក្រៅទីក្រុងស្ទើរតែគ្រប់ករណីទាំងអស់មិនមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដូចជា អគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត ក៏ដូចជាលទ្ធភាពទទួលបានសេវាអប់រំ និងសុខភាព។ ប្រជាពលរដ្ឋមិនអាចបន្តប្រកបរបរចិញ្ចឹមជីវិតដោយសារចម្ងាយផ្លូវពីកន្លែងប្រកបរបរចាស់របស់ពួកគេ និង ថ្លៃចំណាយដឹកជញ្ជូនខ្ពស់។ កង្វះប្រាក់ចំណូលប្រចាំថ្ងៃ គឺជាផលវិបាក ហើយកូនៗពួកគាត់ខ្លះត្រូវបោះបង់ចោលការសិក្សា។

ប្រការនេះ បានរួមចំណែកដល់កំណើនភាពក្រីក្រដែលផ្ទុយនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ សហគមន៍ទាំងនេះ និងសហគមន៍ជាច្រើនទៀត មិនមានលទ្ធភាពប្រើក្របខ័ណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិដែលមានស្រាប់ដើម្បីធានាសិទ្ធិដីធ្លីរបស់ខ្លួន ដែលជាហេតុធ្វើឲ្យធ្លាក់ខ្លួនកាន់តែក្រទៅៗ។

សារាចរលេខ០៣

អង្គការមិនមែនរដ្ឋាភិបាលវាយតម្លៃខ្ពស់ចំពោះឱកាសផ្តល់យោបល់លើសារាចរលេខ០៣ (C03) ដែលបានអនុម័តនេះដោយ មានលក្ខណៈស្របនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ (D&D) របស់រាជរដ្ឋាភិបាលកម្ពុជា និងបង្កើតកាលានុវត្តភាពសម្រាប់គំនិតផ្តួចផ្តើមនៅថ្នាក់ក្រោមជាតិ។ គម្រោងសាកល្បងអនុវត្តសារាចរលេខ ០៣ នៅខេត្តបាត់ដំបង គឺជាឧទាហរណ៍ជាក់ស្តែងសម្រាប់គំនិតផ្តួចផ្តើមនេះនៅមូលដ្ឋានដែលដឹកនាំដោយ សហគមន៍ សង្កាត់ក្រុង និងគាំទ្រដោយអង្គការអភិវឌ្ឍមួយចំនួន។ យើងខ្ញុំសូមទទួលស្គាល់ចរឹតលក្ខណៈវិមជ្ឈការនិងវិសហមជ្ឈការនៃសារាចរលេខ ០៣ នេះ នឹងត្រូវបានអនុវត្ត ស្របតាមស្ថានភាពមូលដ្ឋាននៅក្នុងក្រុងនិងស្រុក។

ប៉ុន្តែកត្តាគន្លឹះដែលសមស្របក្នុងការអនុវត្តគឺ ក) ឆន្ទៈរបស់អាជ្ញាធរក្នុងការកំណត់ដំណោះស្រាយឲ្យបានសមរម្យចំពោះលំនៅឋាន សម្រាប់ការតាំងលំនៅឋានបណ្តោះអាសន្ន ខ)ការលើកទឹកចិត្តពីអាជ្ញាធរឲ្យសហគមន៍ចូលរួមក្នុងការធ្វើ

[35] ដើម្បីទទួលបានព័ត៌មានបន្ថែម សូមមើល http://licadho-cambodia.org/pressrelease.php?perm=267

សេចក្តីសម្រេចចិត្ត និង ការអនុវត្ត និង គ) ការបើកទូលាយរបស់អាជ្ញាធរចំពោះការសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាលទាក់ទិននឹងកិច្ចដំណើរការអនុវត្ត។ ការអភិវឌ្ឍនៅនឹងកន្លែងគួរតែជាដំណោះស្រាយដំបូងដែលមាន អាទិភាពនៃការផ្លាស់ប្តូរលំនៅឋាន-ដោយសារវាគឺជាវិធីល្អបំផុតដើម្បីជៀសវាងភាពស្មុគស្មាញនៅក្នុងការអនុវត្ត និង ជាដំណោះស្រាយដែលមានការចំណាយតិចសម្រាប់ទាំងសហគមន៍ និង អាជ្ញាធរ ព្រមទាំងបង្ហាញពីអភិបាលកិច្ចល្អ។ ទាំងនេះមានភាពចាំបាច់នៃការកសាងសមត្ថភាពមន្ត្រីនៅថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់សង្កាត់ និងក្រុង/ស្រុក ដើម្បីជួយមន្ត្រីទាំងនោះបានយល់អំពីប្រភេទផ្សេងៗនៃការដោះស្រាយបញ្ហាលំនៅឋាន របៀបពិគ្រោះយោបល់ជាមួយសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងដំណាក់កាលនេះវាមានភាពឆាប់រហ័សពេកក្នុងការនិយាយថា សារាចរលេខ០៣គឺ ជាផ្នែកនៃគោលនយោបាយស្តីពីលំនៅដ្ឋាន ប៉ុន្តែការដោះស្រាយបញ្ហាលំនៅឋានដែលសម្រេចបាននៅក្នុងពេលអនុវត្តសារាចរលេខ០៣នឹងផ្តល់មេរៀនដ៏សំខាន់ (ទាំងវិជ្ជមាន និងអវិជ្ជមាន) ដែលរួមចំណែកដល់គោលនយោបាយស្តីពីលំនៅឋាន និងការអនុវត្តគោលនយោបាយនេះ។ សារាចរលេខ ០៣បានផ្តល់ការណែនាំ/ទិសដៅមួយ ប៉ុន្តែ ក្នុងអំឡុងពេលការអនុវត្តវានឹងមានសារៈសំខាន់ក្នុងការចងក្រងជាឯកសារដែលសារាចរលេខ ០៣ បានបំភ្លឺបន្ថែម និងកំណត់ពីឧបសគ្គនៅក្នុងក្របខ័ណ្ឌគតិយុត្តិបច្ចុប្បន្ន។ ការដោះស្រាយបញ្ហាលំនៅឋានដ៏ប្រសើរបំផុត គឺផ្អែកលើគោលការណ៍ "គោលនយោបាយ/ច្បាប់គឺសម្រាប់ប្រជាពលរដ្ឋ" ពុំមានលក្ខណាផ្ទុយនោះទេ ។

កង្វះឯកសារអំពីការធ្វើចំណាត់ថ្នាក់ដីគឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗ ចំពោះការវិភាគចំណាត់ថ្នាក់ដីប្រកបដោយតម្លាភាព។ ក្រុមសង្គមស៊ីវិលភាគច្រើនបានលើកឡើងពីការបារម្ភអំពីការស្វែងយល់លើនីតិវិធីនៃសារាចរលេខ ០៣ របស់អាជ្ញាធរមូលដ្ឋាននៅក្នុងការកំណត់អត្តសញ្ញាណដីសាធារណៈរបស់រដ្ឋដែលពុំមានលក្ខណៈច្បាស់លាស់។ បញ្ហាមួយទៀត គឺតម្លាភាព និងការសម្របសម្រួលជាមួយអ្នកតាំងទីលំនៅឋានបណ្តោះអាសន្នក្នុងមូលដ្ឋាន ក្នុងអំឡុងពេលប្រមូល និងផ្សព្វផ្សាយទិន្នន័យក្រោយពេលបញ្ចប់ដើម្បីប្រមូលអនុសាសន៍នានា។ ជាសក្ខីកម្មនៅរាជធានីភ្នំពេញ សហគមន៍មិនបានទទួលព័ត៌មានជាផ្លូវការច្បាស់លាស់ណាមួយពីអាជ្ញាធររបស់ខ្លួនស្តីពីស្ថានភាពដីសហគមន៍ ថាតើវាគឺជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ក្រោយពីមានការអង្កេតនៅក្នុងសហគមន៍របស់ពួកគេ។ សហគមន៍ក្នុងមូលដ្ឋានមិនត្រូវបានពិគ្រោះយោបល់អំពីកិច្ចដំណើរការ ដែលបានកំណត់ដោយសារាចរលេខ ០៣ នោះទេ។ ព័ត៌មានមិនច្បាស់លាស់អំពីស្ថានភាពដី និងទ្រព្យសម្បត្តិក្នុងសហគមន៍ធ្វើឲ្យសមាជិកក្នុងសហគមន៍មានការខ្វាយខ្វល់ និងជាមូលហេតុក្នុងការរារាំងការវិនិយោគដើម្បីអភិវឌ្ឍសហគមន៍របស់ពួកគេ។

២.១.១.៣. *កម្មវិធីអនុវិស័យគ្រប់គ្រងដីធ្លីត្រូវបានអនុម័ត*

កម្មវិធីអនុវិស័យគ្រប់គ្រងដីធ្លីត្រូវបានអនុម័តក្នុងខែ មិថុនា ឆ្នាំ ២០១០។

២.១.២. ការចុះបញ្ជីដីធ្លីត្រូវបានពង្រឹង ដោយយកចិត្តទុកដាក់លើគ្រួសារក្រីក្រ និងងាយរងគ្រោះ

២.១.២.៤[36]. *ប័ណ្ណកម្មសិទ្ធិដី ១,៧ លានត្រូវបានផ្តល់តាមរយៈចុះបញ្ជីជាប្រព័ន្ធ*

អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ថាដំណើរការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ (ចាប់ពីពេលនេះទៅ ហៅថា SLR) បានទទួលលទ្ធផលជាផ្លែផ្កាដែលបានផ្តល់ប័ណ្ណកម្មសិទ្ធិដីជាច្រើនឲ្យប្រជាពលរដ្ឋ។ គិតមកដល់ខែ វិច្ឆិកា ឆ្នាំ២០១១ កម្មវិធី SLR បានផ្តល់ប័ណ្ណកម្មសិទ្ធិដីចំនួន ១.៧៤០.៨៣៩ប័ណ្ណ[37] ប៉ុន្តែនៅមានការបារម្ភថា ខណៈដែលតំបន់ជាច្រើន ជាពិសេស តំបន់ជនបទនៃប្រទេស គឺមានលក្ខណៈងាយស្រួលសម្រាប់ចុះបញ្ជី តំបន់ដទៃទៀត ភាគច្រើននៅតំបន់ទីប្រជុំជនបានជួបប្រទះបញ្ហា។ តំបន់មួយចំនួនត្រូវបានបដិសេធ ពីដំណើរការដែលបានកំណត់ និងករណីធំៗមួយចំនួននៅទីប្រជុំជន

[36] លេខដែលប្រើក្នុងឯកសារនេះ គឺផ្អែកលើសូចនាករតាមដានរួម ឆ្នាំ២០១០-២០១២

[37] LASSP, ដីគឺជាជីវិត៖ ព្រឹត្តបត្រកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី ច្បាប់ទី២ ខែវិច្ឆិកា ឆ្នាំ២០១១។

ប្រជាពលរដ្ឋជាច្រើន ដែលមានសំអាងរឹងមាំលើសិទ្ធិភោគៈមិនអាចទទួលកិច្ចដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបាន។ ករណីខ្លះប្រជាពលរដ្ឋត្រូវបានបដិសេធក្នុងការផ្តល់ប័ណ្ណដោយហេតុផលស្របច្បាប់ បន្ទាប់ពីមាន ការប្រកាសតំបន់វិនិច្ឆ័យ។ ទោះបីជាយ៉ាងណាក៏ដោយ តំបន់វិនិច្ឆ័យខ្លះត្រូវបានអនុវត្តដោយភាគខ្លះ ចំណែកផ្នែកផ្សេងទៀតត្រូវបានរំលង ឬជៀសចេញ ដោយសំអាងថា "មានភាពស្មុគស្មាញ" ក្នុងការវិនិច្ឆ័យ ។

បញ្ហានៃការឃ្លៀលចេញត្រូវបានបញ្ជាក់ដោយអង្គការមិនមែនរដ្ឋាភិបាលខ្លះ ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍មួយចំនួនក៏បានបញ្ជាក់ដូចគ្នានេះដែរ។ ទោះបីជាយ៉ាងនេះក៏ដោយ ការស្រាវជ្រាវ ឬការធ្វើអន្តរាគមន៍តិចតួច ត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយបញ្ហា a)ហេតុអ្វីបានជាកើតមានការឃ្លៀលចេញ b)កំពុងកើតមានឡើងក្នុងកម្រិត/ទំហំណា c)ក្នុងដំណាក់កាលណានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និង d)តើផ្អែកលើគោលការណ៍ច្បាប់អ្វីខ្លះ (ប្រសិនបើមាន)។

ការស្រាវជ្រាវដែលបានធ្វើដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលក្នុងឆ្នាំ២០១២[38] ដើម្បីទទួលបានព័ត៌មានថែមទៀត បានបង្ហាញមូលហេតុ ចំពោះការឃ្លៀលចេញពីដំណើរការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដូចខាងក្រោម៖

- ការឃ្លៀលចេញពីដំណើរការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ មុនពេល ឬនៅក្នុងដំណាក់កាលដំបូងនៃដំណើរវាស់វែង និងកំណត់ព្រំដី។ ក្នុងករណីជាច្រើន ការឃ្លៀលចេញបានកើតឡើងដោយសារដីត្រូវបានលក់រួចឬត្រូវបានផ្តល់ឲ្យក្រុមហ៊ុនសម្រាប់អភិវឌ្ឍន៍ ឬទុកបម្រុងសម្រាប់ស្ថាបនាហេដ្ឋារចនាសម្ព័ន្ធដែលមានក្នុងផែនការប្រើប្រាស់ដីរបស់រាជរដ្ឋាភិបាលនាពេលអនាគត។ ប៉ុន្តែគេឃើញមានភស្តុតាងបង្ហាញថា នៅក្នុងករណីខ្លះការអនុម័តលើការលក់ដី ឬគម្រោងអភិវឌ្ឍន៍គឺមិនគោរពតាមច្បាប់ និងក្របខ័ណ្ឌគតិយុត្តិជាធរមាននោះទេហើយការឃ្លៀលចេញពីដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវបានធ្វើលើមូលដ្ឋានដែលថាការផ្តល់ប័ណ្ណកម្មសិទ្ធិដីឲ្យតំបន់ទាំងនោះគឺមានលក្ខណៈ "ស្មុគស្មាញពេក"។ ចំណុចនេះមិនមានមូលដ្ឋាននៅក្នុងក្របខ័ណ្ឌគតិយុត្តដែលបានបង្កើតឡើងក្រោមកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លីទេ។
- ដីដែលមានស្ថានភាពមិនច្បាស់លាស់ គ្រួសារជាច្រើនខកខានមិនបានទទួលប័ណ្ណកម្មសិទ្ធិដីដោយសារដីរបស់ពួកគេមាន "ស្ថានភាពមិនច្បាស់លាស់"។ ឧទាហរណ៍ ក្នុងករណីដែល ដីនោះជាទ្រព្យសម្បត្តិរបស់រដ្ឋ ឬ ប្រសិនបើដីមានព្រំជាប់ដីសាធារណៈរបស់រដ្ឋដែលនៅមិនទាន់បានកំណត់ព្រំច្បាស់លាស់។ បញ្ហាទាំងនេះ គួរតែអាចជៀសវាងបានតាមរយៈការគូសផែនទីដីរបស់រដ្ឋដោយមានការសម្របសម្រួលការងារ និងឲ្យមានតម្លាភាព។
- ដីដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ប្រជាពលរដ្ឋមួយចំនួនធំត្រូវបានបដិសេធក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដី ឬមានដីមួយផ្នែកនៃក្បាលដីរបស់ខ្លួនត្រូវបានឃ្លៀលចេញដោយសារដីនោះត្រួតស៊ីគ្នាលើដីរដ្ឋ។ ក្នុងករណីជាច្រើន ដីត្រូវបានឃ្លៀលចេញដោយដីត្រួតស៊ីគ្នាលើដីចំណីផ្លូវដែក ផ្លូវទឹក និងផ្លូវសាធារណៈ និងករណីខ្លះទៀតមាន ការអះអាងថាដីនោះគឺជាអចលនទ្រព្យរបស់រដ្ឋគឺមានភាពច្រម៉ងច្រម៉ាស់ខ្លាំង។

មូលហេតុផ្សេងទៀតដែលប្រជាពលរដ្ឋមិនបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លី រួមមាន៖

- អវត្តមាននៃអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬអ្នកជិតខាងរបស់ខ្លួន ក្នុងពេលកំណត់ព្រំដី។
- ដីដែលជាកម្មវត្ថុនៃជម្លោះ។ គ្មានប័ណ្ណកម្មសិទ្ធិត្រូវបានផ្តល់ចំពោះដីដែលមានវិវាទនោះទេ ទោះបីជាយ៉ាងនេះក៏ដោយករណីខ្លះវិវាទមិនត្រូវបានដោះស្រាយតាមរយៈយន្តការនៃការដោះស្រាយវិវាទដីធ្លីនោះឡើយ។ ដីមានវិវាទដែលមិនទាន់បានដោះស្រាយរួច ត្រូវបានកំណត់ថាជាឧបសគ្គធំមួយចំពោះដំណើរនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ។

[38]របាយការណ៍មិនទាន់ចោះពុម្ពនៅឡើយ

២.១.២.៦. ភាគរយនៃស្ត្រីដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីមានចំនួនច្រើនជាងបុរសដែលមានប័ណ្ណកម្មសិទ្ធិដីធ្លី

ភាគរយនៃទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ត្រីគឺ ១៩% ហើយភាគរយនៃ ទ្រព្យដែលជាកម្មសិទ្ធិរបស់បុរសគឺ ៨%នៃទ្រព្យរួមប្តីប្រពន្ធ គឺប្រហែល ៦២%។ ៦% នៃទ្រព្យសម្បត្តិ ត្រូវបានចុះបញ្ជីដោយអ្នកអ្នកមិនទាន់មានគ្រួសារ និង ៤% ជាកម្មសិទ្ធិរបស់បុគ្គលផ្សេងទៀត ។

អង្គការមិនមែនរដ្ឋាភិបាល សូមស្វាគមន៍ផែនការរបស់ក្រសួងក្នុងការធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់MLMUPC ឲ្យបានទៀងទាត់ ដោយដាក់បង្ហាញឯកសារពាក់ព័ន្ធទាំងជាភាសាខ្មែរ និងអង់គ្លេស រួមមានការដាក់បង្ហាញជាសាធារណៈនូវទិន្នន័យស្តីពីការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដោយមានការបែងចែកចំនួនយេនឌ័រ។ បច្ចុប្បន្នកម្មនេះ ត្រូវចាប់ផ្តើមក្នុងខែឧសភា ឆ្នាំ២០១២ ប៉ុន្តែ តាមយើងដឹងមិនទាន់មានទិន្នន័យដាក់ផ្សាយជាសាធារណៈនៅលើគេហទំព័រនេះទេ។

២.១.២.៨. សហគមន៍ជនជាតិដើមភាគតិចចំនួន ៣ត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាព

ជនជាតិដើមភាគតិច និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការដើម្បីជួយគាំទ្រសិទ្ធិរបស់ជនជាតិដើមភាគតិច សូមកោតសរសើរចំពោះការបញ្ចប់ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងតំបន់សាកល្បងចំនួន ៣។ យើងខ្ញុំក៏សូមស្វាគមន៍ផងដែរ ចំពោះការអនុម័តសារាចរអន្តរក្រសួង *"ស្តីពីវិធានការការពារបណ្តោះអាសន្នដែលការពារដីរបស់ជនជាតិដើមភាគតិចដែលត្រូវបានស្នើសុំសម្រាប់ការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាព ខណៈរង់ចាំកិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដី ស្របតាមនីតិវិធី ដែលនឹងត្រូវបានបញ្ចប់។"*

ប៉ុន្តែ ជនជាតិដើមភាគតិចនិងសង្គមស៊ីវិលនៅតែចាត់ទុកអនុក្រឹត្យស្តីពីនីតិវិធីសម្រាប់ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច មិនអនុលោមតាមស្តង់ដារអន្តរជាតិ និង មិនបានការពារយ៉ាងពេញលេញ ឬធានាសុវត្ថិភាពដីរបស់ជនជាតិដើមភាគតិចទេ។

ដំណើរការទូទៅនៃការចុះបញ្ជីដីសមូហភាពមានការយឺតយ៉ាវ – ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនៅតំបន់គោលដៅទាំងបីបានគ្រោងនឹងបញ្ចប់ក្នុងឆ្នាំ ២០០៩។ ដំណើរការនៃការចុះបញ្ជីដីសមូហភាពមានលក្ខណៈស្មុគ្រស្មាញ និងតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការល្អនៅក្នុងចំណោមក្រសួងពាក់ព័ន្ធទាំងអស់ ដូចជាក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ ជនជាតិដើមភាគតិច មានការបារម្ភថាពួកគេនឹងបាត់បង់ដីរបស់ខ្លួនមុនពេលដែលពួកគេអាចទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព។

យើងខ្ញុំមានសេចក្តីរីករាយដោយបានដឹងអំពីផែនការសម្រួលនីតិវិធីសម្រាប់ការចុះបញ្ជីដីសមូហភាព និងបង្កើនចំនួនបុគ្គលិកនិង ពង្រឹងសមត្ថភាពរបស់ពួកគេ។ ថវិកាដែលមានសម្រាប់គម្រោងនេះ នឹងត្រូវបានបង្កើន ដើម្បីធានាបង្កើនចំនួននៃប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ប៉ុន្តែ យើងខ្ញុំទើបតែបានដឹងថាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គ្រោងចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពចំនួនតែបីប៉ុណ្ណោះក្នុងមួយឆ្នាំ។ ចំពោះចំណុចនេះ យើងខ្ញុំសូមស្នើយ៉ាងទទូចសូមឲ្យបង្កើនចំនួននៃការចេញប័ណ្ណកម្មសិទ្ធិដីសមូហភាព។ យើងខ្ញុំសូមស្វាគមន៍ថែមទៀតចំពោះកិច្ចប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ក្នុងការជួយគាំទ្រការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពជនជាតិដើមភាគតិច។

ដោយសារនីតិវិធីដ៏វែងនៃការចុះបញ្ជីដីសមូហភាព គេចាំបាច់ត្រូវចាត់វិធានការបន្ថែមទៀតដើម្បីការពារដីរបស់ជនជាតិដើមភាគតិចមុនពេលចុះបញ្ជី។ ក្នុងន័យនេះ យើងខ្ញុំស្វាគមន៍ការចេញសារាចរអន្តរក្រសួងលេខ ០០១-លេខ ០០៤ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលហាមឃាត់ការលក់ដូរដីលើដីរបស់ជនជាតិដើមភាគតិច ជាវិធានការការពារបណ្តោះអាសន្ន។ ប៉ុន្តែ យើងខ្ញុំសោកស្តាយដែលសារាចរអន្តរក្រសួងមិនរាប់បញ្ចូលតំបន់ទាំងឡាយ"ដែលរាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍សម្រាប់ការវិនិយោគ ឬអភិវឌ្ឍន៍ – មុនពេលដែលវិធានការទាំងនេះចូលជាធរមាន"។ ការវិនិយោគ ឬអភិវឌ្ឍន៍នៅក្នុងតំបន់ទាំងនេះអាចមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិ និងជីវភាពរបស់ជនជាតិដើមភាគតិច។

សារាចរនេះសំដៅតែលើកិច្ចការពារបណ្តោះអាសន្នចំពោះសហគមន៍ជនជាតិដើមភាគតិច ដែលបានស្នើសុំប័ណ្ណកម្មសិទ្ធិសមូហភាពរួចហើយប៉ុណ្ណោះ។ ដូចដែលអង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងរួចហើយ "កិច្ចការពារបណ្តោះអាសន្នសម្រាប់ដីរបស់ជនជាតិដើមភាគតិច អាចសម្រេចបានតែដោយកិច្ចការពារបណ្តោះអាសន្នលើដីរបស់ជនជាតិដើម

ភាគតិច សម្រាប់សហគមន៍ទាំងអស់ដែលភាគច្រើនគឺជាជនជាតិដើមភាគតិច *ដោយមិនគិត*ថាតើសហគមន៍ទាំងនេះបានចុះបញ្ជីហើយឬនៅទេ។ ការអនុវត្តកិច្ចការពារបណ្តោះអាសន្នចំពោះតែសហគមន៍ត្រូវបានចុះបញ្ជីរួច មិនគោរពតាមស្តង់ដារអន្តរជាតិនៃការគោរពសិទ្ធិស្វ័យសម្រេច (ដែលជាគ្រឹះមួយនៃសេចក្តីប្រកាសអន្តរជាតិនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច)"។

ក្តីបារម្ភមួយទៀតទាក់ទិននឹងមាត្រា ៩ និង ១០ នៃអនុក្រឹត្យ។ បទប្បញ្ញត្តិទាំងនេះ មានន័យបញ្ជាក់ថាដីរបស់ជនជាតិដើមភាគតិចដែលពាក់ព័ន្ធក្នុងជម្លោះនឹងមិនត្រូវបានចុះបញ្ជីទេ។ វាហាក់ដូចជាប្រការដែលសហគមន៍ត្រូវបានទទួលរងនូវការបាត់បង់ដីថែមទៀត ក្នុងពេលដែលពួកគេរង់ចាំដោយគ្មានកាលកំណត់រហូតដល់ពេលដែលវិវាទត្រូវបានគេដោះស្រាយ។ ជាក់ស្តែងដីមួយភាគធំនៃដីដែលជនជាតិដើមភាគតិចរស់នៅលើគឺមានវិវាទ ដោយសារការទន្ទ្រានៃសម្បទានដីសេដ្ឋកិច្ច សម្បទានរ៉ែ និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀតលើដីរបស់ជនជាតិដើមភាគតិច។

មាត្រា ៦ និង ៧ នៃអនុក្រឹត្យកំណត់ទំហំត្រឹម៧ហិកតានៃព្រៃអ្នកតា និងព្រៃបញ្ចុះសពដែលអាចចុះបញ្ជី។ ប៉ុន្តែការកំណត់នេះមិនឆ្លុះបញ្ចាំងពីវប្បធម៌ប្រពៃណីរបស់ពួកគាត់ជាក់ស្តែងនោះទេ ដីព្រៃអ្នកតា និងព្រៃបញ្ចុះសពខ្លះគឺមានទំហំធំជាងការកំណត់៧ហិកតាទៅទៀតនោះ។

២.២. កំណើនសមធម៌នៅក្នុងការបែងចែកដី

២.២.៣. ការអនុវត្តយន្តការសម្បទានដីសង្គមកិច្ច

អង្គការមិនមែនរដ្ឋាភិបាល ស្វាគមន៍កិច្ចប្រឹងប្រែងចែកចាយដីជូនដល់គ្រួសារគ្មានដីធ្លី និងគ្រួសារក្រីក្រតាមរយៈការអនុវត្តសម្បទានដីសង្គមកិច្ច (SLCs)។ ទោះបីជាយ៉ាងណាក៏ដោយ មកដល់ពេលនេះ គឺមិនសូវមានវឌ្ឍនភាពនៃសមភាពក្នុងការបែងចែកដែរ។ របាយការណ៍វឌ្ឍនភាព[39]បាននិយាយថាថាទីតាំង ៤ កន្លែងនៅក្នុងឃុំ៤ នៃខេត្តចំនួន ៣ ដែលមានទំហំដីប្រហែល ៧.០០០ ហិកតា ត្រូវបានចែកចាយជូនគ្រួសារចំនួន ១.៦១៤ និង ស្ថិតក្រោមការអភិវឌ្ឍ[40]។ ឃុំចំនួនបីក្នុងខេត្តក្រចេះ ស្ថិតក្នុងដំណើរការនៃការចុះបញ្ជីដីឯកជនរបស់រដ្ឋ និង ការធ្វើផែនការប្រើប្រាស់ដី។ ដីទំហំប្រហែល ៣០.០០០ ហិកតា នៃផ្ទៃដីទំហំ ១៣៤.០០០ ហិកតា នៅក្នុងទីតាំងចំនួន ៤៩ នៅក្នុងខេត្តចំនួន ១៦ ដែលស្ថិតក្នុងដំណើរការនៃការកំពុងអនុវត្តសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ។ ដីសាធារណៈ និងដីឯកជនរបស់រដ្ឋមិនទាន់ត្រូវបានកំណត់ព្រំឲ្យបានត្រឹមត្រូវទេ នៅក្នុងកិច្ចដំណើរការនៃការកំណត់ដីដែលគ្រោងទុកសម្រាប់សម្បទានដីសង្គមកិច្ច។

ទិន្នន័យបច្ចុប្បន្ន[41] ពីអង្គការសង្គមស៊ីវិលបង្ហាញថាមកដល់ពេលនេះ ផ្ទៃដីទំហំប្រហែល ២.០៣៦.១៧០ ហិកតា ត្រូវបានប្រគល់ជាសម្បទានដីសេដ្ឋកិច្ចរួចហើយ ដែលផ្ទុយគ្នាស្រឡះពីទំហំផ្ទៃដីសរុបដែលគ្រោងទុកសម្រាប់សម្បទានដីសង្គមកិច្ច។ ខណៈដែលទទួលស្គាល់ភាពចាំបាច់ ខាងសេដ្ឋកិច្ចសម្រាប់ការវិនិយោគផ្នែកឯកជនក្តី ក៏គួរតែយកចិត្តទុកដាក់ពីសារៈសំខាន់ខាង សង្គមកិច្ចរបស់ប្រជាពលរដ្ឋក្រីក្រ និងជួបការលំបាកនៅក្នុងសង្គម នៅក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលដែរ។ ក្នុងន័យនេះ យើងគួរតែមានដីថែមទៀតជាចាំបាច់បែងចែកសម្រាប់សម្បទានដីសង្គមកិច្ច។ ដីដែលផ្តល់សម្រាប់សម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានគឺមានទំហំ ៦.៨០០ ហិកតា ដែលមានចំនួនតិចជាង បើប្រៀបធៀបនឹងដីដែលមានសម្រាប់ការអនុវត្តសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដែលមានទំហំប្រហែល ៣០.០០០ ហិកតា។ ចំណុចនេះបង្ហាញនូវភាពចាំបាច់ត្រូវពង្រឹងកិច្ចប្រឹងប្រែងក្នុងការផ្តួចផ្តើម និងការអនុវត្តសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន។

---

[39] របាយការណ៍ស្តីពីវឌ្ឍនភាពនៅក្នុងការអនុវត្តសុចនាករតាមដានរួម ក្រុមការងារបច្ចេកទេស-ដីធ្លី។

[40] របាយការណ៍ស្តីពីវឌ្ឍនភាពនៅក្នុងការអនុវត្តសុចនាករតាមដានរួមក្រុមការងារបច្ចេកទេស-ដីធ្លី។

[41] ពុះចែកកម្ពុជា សម្បទានមួយម្តងៗ ការវិភាគរួមរបស់អង្គការ LICADHO និង កាសែត Cambodia Daily, The Cambodia Daily, លេខ ៧៣០, ថ្ងៃសៅរ៍ និងអាទិត្យ ថ្ងៃទី១០–១១ ខែមីនា ឆ្នាំ២០១២។

បញ្ហាប្រឈមខាងក្រោម ត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម[42] និងតាមដឹងពុំទាន់មានកិច្ចប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះទេ។

១. ការអនុវត្តគម្រោង ទាមទារឲ្យមានការចូលរួមពីអាជ្ញាធរ និង ស្ថាប័នរាជរដ្ឋាភិបាល នៅក្នុងកម្រិតផ្សេងៗ ដែលជាហេតុបណ្តាលឲ្យមានកិច្ចដំណើរការមួយដែលត្រូវចំណាយពេលច្រើន។

២. ភាពយឺតយ៉ាវនៃការអភិវឌ្ឍ និង ការយល់ព្រមពីស្ថាប័នពាក់ព័ន្ធ ក៏គឺជាបញ្ហាប្រឈមដ៏សំខាន់ដែរ។

៣. ថវិកាមានកម្រិត និង ការគ្មានភាពបត់បែន ជាពិសេស សម្រាប់លទ្ធកម្មការសាងសង់ផ្លូវថ្នល់ ការឆ្ការសម្អាតសាលារៀន ស្ពាន បង្គោល និង បញ្ហាទាក់ទិនផ្សេងទៀត។

៤. ដីកាន់តែខ្ចីច ប៉ុន្តែ តម្រូវការកាន់តែខ្ពស់ឡើង។

២.២.៣.៩. ពីខែមករា ឆ្នាំ២០១០ ដល់ខែធ្នូ ឆ្នាំ២០១១ ចំនួនឃុំដែលបានស្នើផែនការប្រើប្រាស់ដីដែលបានឯកភាពរួច កើនឡើងដល់ ២០ (ទិន្នន័យមូលដ្ឋាន ១០ ឃុំ)

២.២.៣.១០. កម្មវិធីអនុវិស័យបែងចែកដីត្រូវបានអនុម័ត

កម្មវិធីអនុវិស័យបែងចែកដី ត្រូវបានអនុម័តក្នុងខែមិថុនា ឆ្នាំ២០១០ ជាផ្នែកមួយនៃកម្មវិធីវិស័យគ្រប់គ្រងដីធ្លី។

២.២.៣.១១. លទ្ធភាពស្វែងរកដីដែលសមស្រប ទូទាំងប្រទេសសម្រាប់សម្បទានដីសង្គមកិច្ច

ឃុំចំនួនបីក្នុងខេត្តក្រចេះស្ថិតក្នុងដំណើរការនៃការចុះបញ្ជីដីឯកជនរបស់រដ្ឋ និងការធ្វើផែនការប្រើប្រាស់ដី។

វឌ្ឍនភាព និង អនុវត្តន៍ក្របខ័ណ្ឌគតិយុត្តិទាក់ទិននឹងដីធ្លី និង លំនៅឋាន

ដូចបានពិភាក្សាខាងលើ និងត្រូវបានទទួលស្គាល់ដោយ ដៃគូអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ធាតុផ្សំសំខាន់ៗនៃក្របខ័ណ្ឌគតិយុត្តិ និង បទប្បញ្ញត្តិសម្រាប់ដីធ្លីនៅខ្វះខាតនៅឡើយ។ សមាសភាគមួយនៃសមាសភាគសំខាន់បំផុតដែលខ្វះខាតនោះ គឺគោលនយោបាយជាតិដ៏ពេញលេញមួយស្តីពីការតាំងលំនៅថ្មី និង បទប្បញ្ញត្តិពាក់ព័ន្ធ។

អង្គការមិនមែនរដ្ឋាភិបាលសូមស្នើសុំការបំភ្លឺអំពីជំហានបន្ទាប់សម្រាប់សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការតាំងលំនៅមិនរៀបរយ និងសង្ឃឹមថានឹងមានការរៀបចំការពិគ្រោះយោបល់ជាសាធារណៈដ៏មានអត្ថន័យមួយលើសេចក្តីព្រាងខាង មុខៗទៀត។

បទពិសោធន៍នៅកម្ពុជា និងនៅជុំវិញពិភពលោក បានបង្ហាញថា នៅពេលដែលមានការអនុវត្តការតាំងលំនៅថ្មីដោយគ្មានវិធានការការពារទាំងនេះ វានាំទៅដល់ការធ្វើឲ្យមានភាពក្រីក្រកាន់តែខ្លាំងចំពោះជនរងផលប៉ះពាល់។ គោលនយោបាយនេះគឺសំខាន់ចំពោះយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា នៅពេលដែលរាជរដ្ឋាភិបាលបន្តការស្វែងរក កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ជាអាទិភាពមួយ គោលនយោបាយជាតិស្តីពីការតាំងលំនៅថ្មី និង នីតិវិធីច្បាប់ដែលមានភាពស្របគ្នាជាមួយស្តង់ដារអន្តរជាតិ នឹងត្រូវអនុម័ត និងអនុវត្តដោយត្រឹមត្រូវ ចំពោះគ្រួសារដែលកាន់កាប់ដីរដ្ឋដោយខុសច្បាប់។ គោលនយោបាយគួរតែគាំទ្រភាពស្របច្បាប់របស់គ្រួសារទាំងនេះ តាមរយៈការព្រមព្រៀងជួល ឬជម្រើសកាន់កាប់ផ្សេងទៀត និងកំណត់ថាការបណ្តេញចេញនឹងត្រូវអនុវត្តបានតែក្នុងករណីចាំបាច់សម្រាប់ផលប្រយោជន៍សាធារណៈប៉ុណ្ណោះ។ ប្រសិនបើគ្រួសារណាមួយត្រូវរើលំនៅដ្ឋានចេញពីដីរដ្ឋ ការតាំងលំនៅថ្មីត្រូវតែធ្វើក្នុងលក្ខណៈមួយដែលមានភាពស្របគ្នាជាមួយកាតព្វកិច្ចក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

---

[42] "កម្រងយោបល់នៃអង្គការមិនមែនរដ្ឋាភិបាលលើសេចក្តីព្រាងរបាយការណ៍ពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣" ដែលបានដាក់ជូនក្រសួង/ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានចងក្រងក្នុងខែ វិច្ឆិកា ឆ្នាំ២០១១ដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា គម្រោងគោលនយោបាយអភិវឌ្ឍន៍។ អាចស្នើសុំបានពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល។

សេចក្តីព្រាង"អនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងតំបន់ទីប្រជុំជន" ត្រូវបានរៀបចំដោយនាយកដ្ឋាន នគរូបនីយកម្មនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

សហគមន៍ អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍ច្បាប់ស្តីពី នគរូបនីយកម្មទីប្រជុំជន និងទីក្រុង ដែលមានតម្លាភាព និងបើកទូលាយចំពោះការពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នករស់នៅទីក្រុងក្នុងប្រទេសកម្ពុជា។

ទោះជាយ៉ាងណាក៏ដោយ សេចក្តីព្រាងអនុក្រឹត្យនេះទើបតែត្រូវបានផ្សព្វផ្សាយជូនអង្គការមិនមែនរដ្ឋាភិបាល នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលស្នើឲ្យមានការពិគ្រោះយោបល់រយៈពេលកន្លះថ្ងៃលើសេចក្តីព្រាងនេះ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១។ ការជូនដំណឹងរយៈពេលដ៏ខ្លីបែបនេះ ធ្វើឲ្យសង្គមស៊ីវិលមិនអាចវិភាគសេចក្តីព្រាងនេះឲ្យបានស៊ីជម្រៅ ឬចូលរួមចំណែកធាតុចូលប្រកបដោយអត្ថន័យលើសេចក្តីព្រាងនេះឡើយ។ លើសពីនេះទៀត ការពិគ្រោះយោបល់មិនត្រូវបានចូលរួមយ៉ាងទូលាយពីសំណាក់ក្រសួងសំខាន់ៗ ដៃគូអភិវឌ្ឍន៍ឬ តំណាងសហគមន៍ទេ។ ក្រសួង MLMUPC បានប្រកាសជាពាក្យសម្តីថា អង្គការមិនមែនរដ្ឋាភិបាលអាចដាក់យោបល់ជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេលមួយសប្តាហ៍ ដែលជារយៈពេលមិនគ្រប់គ្រាន់ដែរ។

ការបារម្ភនេះទាក់ទិនមិនត្រឹមតែកិច្ចដំណើរការពិគ្រោះយោបល់ប៉ុណ្ណោះទេ ដោយផ្អែកលើការវិភាគដំបូងមួយ គេឃើញមានការបារម្ភច្រើនអំពីមាតិការដែលចាំបាច់ត្រូវដោះស្រាយ នៅក្នុងនោះ រួមមាន៖

- ថ្វីបើគោលដៅនៃអនុក្រឹត្យ ជាទូទៅ មានលក្ខណៈជាទីពេញចិត្តក្តី ក៏មាត្រាបន្ទាប់នោះមិនបានបំពេញតាមគោលដៅទាំងនេះទេ ហើយមាត្រាខ្លះគឺផ្ទុយពីគោលដៅទាំងនេះ។
- សេចក្តីព្រាង គឺមានលក្ខណៈខ្វះចក្ខុវិស័យរួមមួយនៃនគរូបនីយកម្ម ទន្ទឹមនឹងនេះ មាត្រាខ្លះមានលក្ខខណ្ឌលម្អិតលើសលុបពេក (ឧទាហរណ៍ មាត្រា ២២ ស្តីពីចំនួនដើមឈើលើផ្ទៃដីទំហំ ១៥០ ម៉ែត្រការ៉ែ) មាត្រាខ្លះទៀតមានលក្ខណៈមិនច្បាស់លាស់ និងមិនមានការចង្អុលបង្ហាញថាតើត្រូវធ្វើដូចម្តេចដើម្បីឲ្យវាអាចអនុវត្តបាន (ឧទាហរណ៍ មាត្រា ២, ៦ និង២៨) ខណៈដែលមាត្រាផ្សេងទៀត គឺមិនសមដាក់នៅក្នុងអនុក្រឹត្យមួយស្តីពីការធ្វើនគរូបនីយកម្មទេ (ឧទាហរណ៍ មាត្រា ៣១)។
- ថ្វីបើការចូលរួមរបស់សហគមន៍ សង្គមស៊ីវិល និង ការពិគ្រោះយោបល់ត្រូវបានលើកឡើងនៅក្នុងឯកសារនោះក្តី ក៏ពុំមានការផ្តល់ព័ត៌មានលម្អិតអំពីរបៀបធានាឲ្យបានថាការពិគ្រោះយោបល់បែបនេះ គឺមានអត្ថន័យ និងប្រព្រឹត្តទៅមិនត្រឹមតែនៅពេលដែលផែនការណាមួយបានបញ្ចប់ហើយទេ ប៉ុន្តែ ថែមទាំងនៅក្នុងពេលរៀបចំផែនការទាំងនេះទៀតផង។ ពេលវេលាសម្រាប់ការផ្តល់យោបល់លើផែនការផ្សេងៗ គឺមិនមានពេលគ្រប់គ្រាន់។ កម្រិតផ្សេងៗនៃការចូលរួមចាំបាច់ត្រូវគិតគូរ នៅពេលរៀបចំផែនការសម្រាប់ការពិគ្រោះយោបល់ និងការចូលរួមប្រកបដោយអត្ថន័យ។
- មាត្រា ២៩ ហាក់បីដូចជាផ្តល់ឆន្ទានុសិទ្ធិទាំងស្រុងជូន MLMUPC ឲ្យអនុញ្ញាតឲ្យម្ចាស់ដីធ្វើហួសកម្រិតអតិបរមានៃការប្រើប្រាស់ដី។ ដូចគ្នាដែរ មាត្រា ៣២ ផ្តល់ឆន្ទានុសិទ្ធិជូន MLMUPC ក្នុងការសម្រេចលើស្តង់ដារអប្បបរមាសម្រាប់ទំហំក្បាលដី។ ចំណុចនេះអាចបណ្តាលឲ្យមានការបណ្តេញចេញ ដោយសារទំហំអប្បរមានៃក្បាលដីដែលមានចែងនៅក្នុងអនុក្រឹត្យធ្វើឲ្យក្បាលដីស្ទើរតែទាំងអស់មានលក្ខណៈខុសច្បាប់។ មាត្រាដដែលក៏ប្រឈមផងដែរនូវនិយមន័យនៃតំបន់គ្រប់គ្រង (CA)។ ជារួម យើងឃើញមានការសន្មតដែលអនុញ្ញាតឲ្យ MLMUPC មានឆន្ទានុសិទ្ធិទាំងស្រុងក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយ។
- ភាគរយ និងអនុបាតដែលចែងនៅក្នុងមាត្រា២២ និង ២៣ មានលក្ខណៈធ្វើឲ្យច្រឡំខ្លាំង។ គេមិនដឹងច្បាស់ទេថាតើមាត្រាទាំងនេះនឹងត្រូវមានអានុភាពប្រតិសកម្មឬទេ ដែលក្នុងករណីនេះ វាអាចនាំឲ្យមានការបណ្តេញចេញច្រើន។ ដូចគ្នានេះដែរ មាត្រា ៣២ ចែងពីទំហំក្បាលដីមានលក្ខណៈមិនប្រាកដនិយមនឹងអាចមានគ្រោះថ្នាក់។ វាអាចឈានដល់ការបណ្តេញចេញក៏ដូចជា ធ្វើឲ្យដីក្នុងទីក្រុងមានតម្លៃថ្លៃពេកសម្រាប់ប្រជាជនក្រីក្រ។ បទប្បញ្ញត្តិចែងនៅក្នុងអនុក្រឹត្យនេះមានលក្ខណៈផ្ទុយ និងត្រួតគ្នាជាមួយនឹងច្បាប់ អនុក្រឹត្យ និងគោលនយោបាយមានស្រាប់

ទាក់ទិននឹងការអភិវឌ្ឍដី សំណង់ និងការប្រើប្រាស់ដី។ ទោះបីជាមានការអះអាងថាគោរពតាមគោលការណ៍នៃវិសហមជ្ឈការ និងវិមជ្ឈការក្តី ក៏ចំណុចនេះនៅតែជាយន្តការធ្វើផែនការបែបមជ្ឈការពីលើចុះក្រោមដែរ។ យន្តការនៅថ្នាក់ជាតិ និងក្រោមជាតិត្រួតគ្នាលើយន្តការមានស្រាប់។

៣. អនុសាសន៍

- បើគ្មានការគ្រប់គ្រងដីរដ្ឋឲ្យបានពេញលេញ និងប្រកបដោយតម្លាភាពទេ ការចាប់យកដី និងការដណ្តើមយកដីក៏នៅតែបន្តមាន ក៏ដូចជាការផ្តល់សម្បទានខុសច្បាប់ និង ការសឹករេចរឹលបរិស្ថានធម្មជាតិ ព្រមទាំងការរំលោភសិទ្ធិរបស់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។
- អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវឲ្យមានការកំណត់ព្រំដីរដ្ឋប្រកបដោយតម្លាភាព និងពេញលេញ។ ទិន្នន័យនេះ គប្បីត្រូវដាក់ផ្សាយជាសាធារណៈ។ យើងខ្ញុំកត់សម្គាល់ឃើញថាពុំទាន់មានវឌ្ឍនភាពជាក់លាក់ដើម្បីឆ្ពោះទៅកាន់គោលដៅដ៏សំខាន់ នផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) នៅឡើយទេ។ យើងខ្ញុំស្នើសុំយ៉ាងទទូចឲ្យរាជរដ្ឋាភិបាលកម្ពុជារៀបចំឯកសារ និងបង្ហាញជាសាធារណៈថាចំណាត់ថ្នាក់ដីគឺជាអាទិភាពបន្ទាន់ទីមួយ។
- យើងខ្ញុំសង្ឃឹមថា ការជួយគាំទ្រជុំវិញវិស័យដីធ្លីក្រោមការគាំទ្រថវិកាពីដៃគូរអភិវឌ្ឍន៍ នឹងរួមចំណែកបង្កើនសុវត្ថិភាពកាន់កាប់សម្រាប់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះបំផុតនៃសង្គមកម្ពុជានាពេលអនាគត។ យើងខ្ញុំសូមអំពាវនាវសូមឲ្យម្ចាស់ជំនួយផ្តល់ការគាំទ្ររបស់ខ្លួនប្រកបដោយតម្លាភាពខ្ពស់បំផុត និងសូមស្នើឲ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃដ៏តឹងរ៉ឹងមួយ ដែលយកចិត្តទុកដាក់ជាក់ស្តែងលើការជៀសវាងការរំលោភសិទ្ធិមនុស្សដោយអចេតនា។
- ដោយពិចារណាទៅលើយន្តការនៃការផ្តល់ប័ណ្ណកម្មសិទ្ធិថ្មី [43] សង្គមស៊ីវិលសង្ឃឹមថា ការអនុវត្តនឹងមានភាពជាវិជ្ជមានចំពោះសុវត្ថិភាពដីធ្លី និងសិទ្ធិក្នុងការកាន់កាប់ដីឯកជន (ប្រើប្រាស់ដី និងអភិរក្ស) គោលការណ៍នីតិរដ្ឋ និងការអនុវត្ត ប្រព័ន្ធគតិយុត្តិក្នុងការគ្រប់គ្រងដីធ្លីដែលមានស្រាប់នឹងផ្សាភ្ជាប់ទៅសហគមន៍ប្រកបដោយនិរន្តភាព។ ខណៈយន្តការនៃការ ផ្តល់ប័ណ្ណកម្មសិទ្ធិថ្មីនឹងមិនអាចដោះស្រាយជម្លោះដីធ្លីបានទាំងស្រុងនោះយើង ខ្ញុំសូមគាំទ្ររាជរដ្ឋាភិបាលក្នុងការពន្លឿនការដោះស្រាយជម្លោះដែលមានស្រាប់។
- យើងខ្ញុំសូមស្នើរសុំយ៉ាងទទូចឲ្យបង្កើនតម្លាភាពក្នុងដំណើរការនៃការអនុវត្តយន្តការ និងផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់អំពីគោលបំណង និង នីតិវិធីក្នុងយន្តការផ្តល់ប័ណ្ណកម្មសិទ្ធិជាសាធារណៈ។

សារាចរលេខ០៣

យើងខ្ញុំសូម ស្នើរាជរដ្ឋាភិបាលជាពិសេស MLMUPC សូមផ្តល់ការបណ្តុះបណ្តាលសមត្ថភាពជូនអាជ្ញាធរមូលដ្ឋានដើម្បីឲ្យយល់ច្បាស់អំពីដំណើរការសារាចរលេខ ០៣ ដើម្បីជួយឲ្យពួកគេអាចពន្យល់ និងពិគ្រោះយោបល់បានសមស្របជាមួយសមាជិកសហគមន៍។ យើងខ្ញុំក៏សង្ឃឹមផងដែរថានឹងបានឃើញការចូលរួមកាន់តែច្រើនឡើងពីអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការអនុវត្តសារាចរលេខ ០៣។

[43] រដ្ឋាភិបាលបានចេញបទបញ្ជាកាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ ផ្អាកជាបណ្តោះអាសន្នក្នុការផ្តល់ដីសម្បទានសេដ្ឋកិច្ចនិងធ្វើការសើររើឡើងវិញចំពោះដីសម្បទានដែលមានស្រាប់។ បទបញ្ជាក៏បានរួមបញ្ចូលបទបញ្ជត្តិដែលសំដៅដល់ការអនុវត្តគោលនយោបាយស្បែកខ្លា ដែលមានគោលបំណងកម្រិតការចាប់យកដីរបស់សហគមន៍។ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ នាយករដ្ឋមន្ត្រីកម្ពុជាបានបង្ហាញនូវចេតនាអនុវត្តគោលនយោបាយស្បែកខ្លាក្នុងពេលថ្លែងសន្ទរកថាមួយដើម្បីប្រកាសឲ្យប្រើរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ ស្តីអំពី ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។

ពេលវេលាសម្រាប់ផ្តល់យោបល់លើគោលនយោបាយអនុក្រឹត្យផ្សេងៗ

ពេលវេលាសម្រាប់ផ្តល់យោបល់លើសេចក្តីព្រាងក្របខ័ណ្ឌគតិយុត្តិគឺមិនគ្រប់គ្រាន់។ យើងខ្ញុំសូមស្នើថាស្ថាប័នរាជរដ្ឋាភិបាលគួរតែផ្តល់ពេលវេលាគ្រប់គ្រាន់ជូនសង្គមស៊ីវិល សម្រាប់វិភាគសេចក្តីព្រាងណាមួយ និង ផ្តល់យោបល់ ដើម្បីអនុញ្ញាតឲ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។

ដំណើរការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

- កំណត់អាទិភាពហើយធ្វើចំណាត់ថ្នាក់ដីរដ្ឋជាក់ស្តែងដោយអាជ្ញាធរមូលដ្ឋាន នៅក្នុងអំឡុងពេលដំណើរការប្រកាសតំបន់វិនិច្ឆ័យ។ ដីរដ្ឋគួរតែត្រូវបានកំណត់អត្តសញ្ញាណ កំណត់ព្រំ និងត្រូវចុះបញ្ជីតាមរយៈដំណើរការមួយប្រកបដោយតម្លាភាពស្របតាមនីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យលេខ ១១៨ ស្តីពីការគ្រប់គ្រងដីរដ្ឋមុនពេលធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធនូវក្បាលដីបុគ្គល។ លើសពីនេះផែនទី និងទិន្នន័យមូលដ្ឋានដីរដ្ឋគប្បីត្រូវផ្សព្វផ្សាយជាសាធារណៈ។
- ពិនិត្យមើលនីតិវិធីបច្ចុប្បន្នឡើងវិញ សម្រាប់ជ្រើសរើសតំបន់វិនិច្ឆ័យ និងផ្សព្វផ្សាយជាសាធារណៈនូវទម្រង់នៃដំណើរការនេះ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស។ យោងតាមអនុក្រឹត្យលេខ ៤៦ តំបន់វិនិច្ឆ័យត្រូវតែប្រកាសដោយអភិបាលខេត្តឬរាជធានីពាក់ព័ន្ធ។[44]
- តំបន់វិនិច្ឆ័យគួរតែត្រូវបានជ្រើសរើសតំបន់សម្រាប់កំនើនសេដ្ឋកិច្ច និងតំបន់អភិវឌ្ឍដូចជា តំបន់ដែលត្រូវអនុវត្តដីសម្បទានសេដ្ឋកិច្ចជាដើម។ ប៉ុន្តែ គេមិនឃើញមាននីតិវិធីជ្រើសរើសលម្អិតកំណត់នៅក្នុងឯកសារផ្លូវការណាមួយដែលសាធារណជនអាចរកបានមើលទេ។
- បន្តយកចិត្តទុកដាក់លើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ (SLR) នៅតំបន់ទីប្រជុំជនដោយបង្កើនតម្លាភាពនៅក្នុងការជ្រើសរើសតំបន់វិនិច្ឆ័យ។
- យកចិត្តទុកដាក់ផងដែរក្នុងការបង្កើនលទ្ធភាពបន្ថែម ចំពោះដំណើរការនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ (SLR) រាប់បញ្ចូលទាំងការអនុវត្តនីតិវិធីកាន់តែប្រសើរឡើងសម្រាប់នីតិវិធីបំពេញបន្ថែម នៅតាមគ្រួសារដែលត្រូវបានបដិសេធចេញពីកិច្ចដំណើរការ SLR នៅតាមខេត្ត/រាជធានី ដែលអនុវត្តកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី។ ពង្រឹងយន្តការដោះស្រាយវិវាទ។
- អង្គការមិនមែនរដ្ឋាភិបាល សូមកោតសរសើរចំពោះការយកបញ្ហាឃ្មៀលតំបន់ស្មុគស្មាញចេញដាច់ដោយលែកក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដែលបានក្លាយជាសូចនាករដោយឡែកមួយ នៅក្នុងការចរចារលើកទីពីរ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអាល្លឺម៉ង់ដែលផ្សារភ្ជាប់ការផ្តល់មូលនិធិ និងការបន្តជួយគាំទ្ររបស់អាល្លឺម៉ង់ចំពោះកម្មវិធីកំណែទម្រង់វិស័យដីធ្លីដើម្បីទទួលបានវឌ្ឍនភាព និងការសម្រេចបានរសូចនាករទាំងនេះ។ យើងខ្ញុំកំពុងសង្ឃឹមថានឹងបានទទួលព័ត៌មានទាំងស្រុងអំពីផែនការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់លើវិធានការដោះស្រាយបញ្ហាឃ្មៀល ចេញ មុនពេលមានការពិគ្រោះយោបល់ណាមួយដែលបានគ្រោង ដើម្បីអាចចូលរួមចំណែកដល់ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។

ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព

- ពេលចុះបញ្ជីក្នុងតំបន់សាកល្បងទាំងបីរបស់សហគមន៍ ជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិល សូមស្នើរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាដៃគូអភិវឌ្ឍន៍សូមឲ្យគូសបង្ហាញបញ្ហា ដែលកើតមាននៅក្នុងអំឡុងពេលដំណើរការចុះប

[44] រាជរដ្ឋាភិបាលកម្ពុជា *អនុក្រឹត្យលេខ លេខ៤៦ស្តីពីនីតិវិធី នៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី* ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ (មាត្រា២)។

ញ្ជី។ ផ្អែកលើមេរៀនដែលទទួលបានទាំងនេះ អនុក្រឹត្យបច្ចុប្បន្នស្តីពីផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព គួរតែកែលម្អ ដើម្បីពន្លឿនការចុះបញ្ជីដីសមូហភាព។

- ដើម្បីបំពេញបន្ថែមកិច្ចប្រឹងប្រែងទាំងនេះ យើងខ្ញុំក៏សូមស្នើផងដែរសូមឲ្យចាត់វិធានការដូចតទៅ៖ បង្កើតគម្រោងមួយ ដោយមានការគាំទ្រខាងបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើន និងពន្លឿនការចុះបញ្ជីដីរបស់ជនជាតិដើមភាគតិចមិនត្រឹមតែនៅខេត្តរតនគិរី និងមណ្ឌលគិរីប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងនៅតាមខេត្តណាដែលមានសហគមន៍ជនជាតិដើមភាគតិចថែមទៀត។ សហគមន៍ទាំងឡាយដែលដីរបស់ខ្លួនត្រូវបានគម្រោមកំហែងដោយសម្បទានដីសេដ្ឋកិច្ច រ៉ែ ឬសកម្មភាពអភិវឌ្ឍន៍ផ្សេងទៀត គួរតែត្រូវបានទទួលអាទិភាពសម្រាប់ការចុះបញ្ជី។ អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ជនជាតិដើមភាគតិច គប្បីបានចូលរួមក្នុងគម្រោងនេះ ដើម្បីធានាថាដំណើរការចុះបញ្ជីគឺត្រឹមត្រូវដោយ អនុលោមតាមកាតព្វកិច្ចរបស់កម្ពុជាក្នុងការការពារ យ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាតិដើមភាគតិច។
- យើងខ្ញុំសូមស្នើយ៉ាងទទូចសូមបង្កើនចំនួនប័ណ្ណកម្មសិទ្ធិដីសមូហភាពឲ្យលើសពី ៣ ក្នុងមួយឆ្នាំ។
- អង្គការមិនមែនរដ្ឋាភិបាលសូមស្នើសុំឲ្យរដ្ឋាភិបាលបង្កើនល្បឿននៃដំណើរការទទួល ស្គាល់សហគមន៍ជនជាតិដើមភាគតិច ឲ្យបានយ៉ាងហោចណាស់ ៣៥ សហគមន៍ក្នុងមួយឆ្នាំ ដោយសារការទទួលស្គាល់នេះវាមានសារសំខាន់ ក្នុងការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅ MLMUPC វិធានការនៃការពារបណ្តោះអាសន្នត្រូវបានផ្តល់ ក្រោយ ពេលសហគមន៍ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាពទៅ MLMUPC តែប៉ុណ្ណោះ។
- លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលសូមស្នើឲ្យបង្កើនតំបន់គោលដៅសម្រាប់ផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពរហូតដល់ឆ្នាំ ២០១៣ ឲ្យបានដល់ចំនួន ២៩ តំបន់ ដែលជាកន្លែងសហគមន៍ត្រូវបានចុះបញ្ជីជានីតិបុគ្គលរួចហើយដោយក្រសួងមហាផ្ទៃ។ យើងខ្ញុំក៏សូមស្នើផងដែរសូមឲ្យរាជរដ្ឋាភិបាលកម្ពុជាចែករំលែកផែនការសម្រាប់អនុវត្តអនុក្រឹត្យសម្រាប់ចុះបញ្ជីដីរបស់ជនជាតិដើមភាគតិច តំបន់គោលដៅដែលរួមមានទាំងពេលវេលាជាក់លាក់ និងការជួយគាំទ្រខាងបច្ចេកទេស/ហិរញ្ញវត្ថុដែលមានពីដៃគូអភិវឌ្ឍន៍។
- យើងខ្ញុំក៏ស្នើផងដែរសូមឲ្យរាជរដ្ឋាភិបាលកម្ពុជាជួយបញ្ចាក់ចំណុចខាងក្រោម នៅក្នុងសារាចរមួយស្តីពីការចុះបញ្ជីដីរបស់ជនជាតិដើមភាគតិច៖
    - ប្រសិនបើសមាជិកចង់ចាកចេញពីសហគមន៍មួយរបស់ជនជាតិដើមភាគតិច សេចក្តីសម្រេចចុងក្រោយតាមរយៈនីតិវិធីសម្រេចចិត្តជាប្រពៃណីរបស់សហគមន៍ថាតើពួកគេគប្បីទទួលបានដី ឬសំណង។
    - សហគមន៍ដែលពាក់ព័ន្ធក្នុងវិវាទដីធ្លី គួរតែអាចចុះបញ្ជីតំបន់មិនមានជម្លោះនៃដីរបស់ពួកគេ។ នីតិវិធីមួយគួរតែត្រូវបានបង្កើតឡើង សម្រាប់ចុះបញ្ជីដីដាច់ដោយដុំបន្ទាប់ពីវិវាទបានដោះស្រាយរួច។
- វិធានការខាងក្រោម គួរតែត្រូវបានអនុវត្តដើម្បីការពារដីរបស់ជនជាតិដើមភាគតិចមុនពេលចុះបញ្ជី៖
    - យុទ្ធនាការបង្កើនការយល់ដឹងថ្នាក់ជាតិ ដោយពន្យល់ថាការលក់ដីប្រពៃណីរបស់ជនជាតិដើមភាគតិចទៅឲ្យអ្នកមកពីក្រៅសហគមន៍គឺខុសច្បាប់។
    - បង្កើនការយល់ដឹងជាមួយរាជរដ្ឋាភិបាលកម្ពុជា អំពីកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួន រួមមានប្រការដែលថាការធ្វើសាក្សីនៃការផ្ទេរ និង ការផ្តល់សម្បទានលើដីរបស់ជនជាតិដើមភាគតិច គឺជាទម្រង់ខុសច្បាប់។
    - គាំទ្រកិច្ចប្រឹប្រែងគូសផែនទីជាមូលដ្ឋាន របស់សហគមន៍។ ផែនទី GPS ដែលបង្ហាញព្រំដី គួរតែដាក់បង្ហាញនៅតាមការិយាល័យរាជរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងខេត្ត និងបង្កើនការយល់ដឹងក្នុងព្រឹត្តិការណ៍ផ្សេងៗ។
    - ការអនុវត្តបទប្បញ្ញត្តិមានស្រាប់នៃច្បាប់ភូមិបាលដែលហាមឃាត់ការជ្រៀតជ្រែក ដីក្នុងតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ រហូតដល់ដំណើរការនៃការចុះបញ្ជីដីត្រូវបានបញ្ចប់។

- លើសពីនេះទៀត យើងខ្ញុំស្នើសូមឲ្យពង្រឹងការប្រតិបត្តិបទប្បញ្ញត្តិនានានៅក្នុងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចក៏ដូចជាច្បាប់ភូមិបាល ដែលមានប្រយោជន៍ដល់កិច្ចការពារបណ្តោះអាសន្ន ដូចជា មាត្រា ២៣ (កថាខណ្ឌ ២) នៃច្បាប់ភូមិបាលជាដើម។
- ភាគីពាក់ព័ន្ធទាំងអស់គួរតែធ្វើឲ្យប្រសើរឡើងនូវដំណើរការពិគ្រោះយោបល់ផ្អែកលើគោលការណ៍នៃ "ការយល់ព្រមដោយសេរី ជាមុន និង ដោយមានព័ត៌មានពេញលេញ" មុនពេលអនុវត្តគម្រោងអភិវឌ្ឍណាមួយនៅលើដីរបស់ជនជាតិដើមភាគតិច។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ចាំបាច់ត្រូវធ្វើដោយផ្អែកលើស្តង់ដារអន្តរជាតិ។ ការតាមដានការដោះដូរដីនៅក្នុងតំបន់ទាំងឡាយដែលមានជនជាតិដើមភាគតិចរស់នៅ ចាំបាច់ត្រូវផ្តាកបណ្តោះ អាសន្នលើសម្បទាន ដីសេដ្ឋកិច្ច និង ការលក់ដីនៅក្នុងតំបន់ទាំងនោះ។
- អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការដើម្បីជួយគាំទ្រសិទ្ធិរបស់ជនជាតិដើមភាគតិច ស្នើសុំការបំភ្លឺថាហេតុអ្វីបានជាសូចនាករតាមដានរួមទាំងនេះមិនត្រូវបានសម្រេច។ ការមិនសម្រេចបានសូចនាករតាមដានរួម គួរតែមានផលវិបាកចំពោះភាគីមិនគោរពតាម។ វិធានការការពារបណ្តោះអាសន្នសម្រាប់ដីរបស់ជនជាតិដើមភាគតិច ត្រូវតែអនុវត្ត។ ស្របតាមមាត្រា ២៣ នៃច្បាប់ភូមិបាល សហគមន៍ជនជាតិដើមភាគតិចទាំងអស់ត្រូវបានការពារ ដោយមិនគិតថាតើពួកគេត្រូវបានទទួលស្គាល់ជានីតិបុគ្គលដោយរាជរដ្ឋាភិបាលហើយឬនៅទេ។ សង្គមស៊ីវិលសូមជម្រុញរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ សូមឲ្យបន្ថែមសូចនាករតាមដានរួមលើកិច្ចការពារបណ្តោះអាសន្ននូវដីរបស់ជនជាតិដើមភាគតិច ដែលអាចវាស់បាន និងសម្រេចបាន។

សម្បទានដីសង្គមកិច្ច

- ទីមួយ និងសំខាន់បំផុត រាជរដ្ឋាភិបាលកម្ពុជាគប្បីរិះរកមើលរាល់យន្តការផ្សេងទៀត ដើម្បីបង្កើនសមធម៌នៅក្នុងការបែងចែកដី។ យន្តការទាំងនោះ អាចបំពេញបន្ថែមលើទស្សនាទាននៃសម្បទានដីសង្គមកិច្ច ឬអនុវត្តទស្សនាទាននេះ។
- លទ្ធភាពសម្របសម្រួលនីតិវិធីទាំងនេះ គួរតែច្នៃប្រឌិតថែមទៀត។ លើសពីនេះទៀត ក្រសួងពាក់ព័ន្ធទាំងអស់ដូចជា MLMUPC ក្រសួងមហាផ្ទៃ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គួរតែរួមបញ្ចូលក្នុង ដំណើរការសម្បទានដីសង្គមកិច្ច។ កិច្ចសហប្រតិបត្តិការរបស់ពួកគេ ត្រូវតែពង្រឹងដើម្បីរៀបចំវិធីសាស្ត្ររួមមួយដើម្បីកំណត់ដីកសិកម្មសមស្របសម្រាប់សម្បទានដីសង្គមកិច្ច និងដើម្បីអភិវឌ្ឍផែនការសម្បទានដីសង្គមកិច្ចជាតិ។
- សម្បទានដីសេដ្ឋកិច្ចដែលបានលុបចោល គួរតែត្រូវផ្ទេរទៅជាសម្បទានដីសង្គមកិច្ចវិញ។
- ចំពោះកិច្ចប្រឹងប្រែងនៃការពង្រឹងវិមជ្ឈការ និង វិសហមជ្ឈការ ភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិ នៅទីនេះ គឺក្រុមប្រឹក្សាឃុំ ចាំបាច់ត្រូវបានពង្រឹង និងគាំទ្រក្នុងការកំណត់អត្តសញ្ញាណ និងការបែងចែកដីសមស្របសម្រាប់សម្បទានដីសង្គមកិច្ច ក៏ដូចជា ក្នុងការអភិវឌ្ឍផែនការសម្បទានដីសង្គមកិច្ច។ ការផ្តួចផ្តើម និងការអនុវត្តសម្បទានដីសង្គមកិច្ចនៅថ្នាក់មូលដ្ឋាន ចាំបាច់ត្រូវបង្កើនដើម្បីចែកចាយដីថែមទៀតជូនដល់គោលដៅអ្នកទទួលដី។ អាជ្ញាធរឃុំត្រូវជួយគាំទ្រ និង កិច្ចសហប្រតិបត្តិការថែមទៀតជាមួយភាគីពាក់ព័ន្ធ ជាពិសេសនៅថ្នាក់ជាតិ។
- ចំពោះសម្បទានដីសង្គមកិច្ចដែលបានអនុវត្តរួចហើយ កិច្ចប្រឹងប្រែងគប្បីត្រូវបានពង្រឹង ដើម្បីបង្កើនការយល់ដឹងអំពីការប្រតិបត្តិល្អនៅក្នុងការដាំដុះ (សរីរាង្គ) នូវផលិតផលកសិកម្មផ្សេងៗ។ ឱកាសរកទីផ្សារសម្រាប់ផលិតផលទាំងនោះ គប្បីត្រូវបានស្វែងយល់ថែមទៀត។ ការធានាបានលទ្ធភាពចូលទីផ្សារ និងតម្លៃទីផ្សារត្រឹមត្រូវ ធានាសន្តិសុខស្បៀង និង ជីវភាពរស់នៅរបស់ក្រុមគោលដៅឲ្យមានភាពប្រសើរឡើង។
- លទ្ធភាពនានា គប្បីត្រូវបានស្វែងយល់ដើម្បីជៀសវាងការទន្ទ្រានយកដីលើតំបន់ដែលបានកំណត់សម្រាប់សម្បទានដីសង្គមកិច្ច។ អាជ្ញាធរមូលដ្ឋានមានតួនាទីសមស្របជាពិសេសសម្រាប់ទប់ស្កាត់ និងជៀសវាងការទន្ទ្រានយកដី តាមរយៈការអប់រំដោយអាជ្ញាធរមូលដ្ឋាន និងការផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងនីតិវិធីច្បាប់ និងនីតិវិធីផ្សេងទៀត។ យើងខ្ញុំសូមផ្តល់អនុសាសន៍សូមឲ្យអាជ្ញាធរមូលដ្ឋានពន្លឿនការផ្តល់សម្បទានដីសង្គមកិច្ច។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

បណ្តាញប្រព្រឹត្តកម្មតាំងទីតាំងទីលំនៅថ្មី បណ្តាញដីធ្លីដើម្បីអភិវឌ្ឍន៍ និងបណ្តាញអង្គការគាំទ្រសិទ្ធជនជាតិដើមភាគតិច

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
លោក ឈិត សំអាត នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩ ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh គេហទំព័រ៖ www.ngoforum.org.kh និង www.cambodianbudget.org

សមាគមសិទ្ធិមនុស្ស និង អភិវឌ្ឍកម្ពុជា (ADHOC)
លោក នី ចរិយា ប្រធានផ្នែកឃ្លាំមើលសិទ្ធិមនុស្ស
ទូរស័ព្ទ៖ (៨៥៥) ១១ ២៧៤ ៩៥៩ អ៊ីម៉ែល៖ adhoc-chakrya@gmail.com គេហទំព័រ៖ www.adhoc-cambodia.org

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់**សហគមន៍ (CLEC)**
លោក យ៉ែង វីរៈ នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥) ១២ ៨០១ ២៣៥ អ៊ីម៉ែល៖ virakyeng@clec.org.kh គេហទំព័រ៖ www.clec.org.kh

អភិវឌ្ឍ និង ភាពជាដៃគូក្នុងសកម្មភាព (DPA)
លោក ម៉ម សម្បត្តិ នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥) ១២ ៧៧៩ ៧៣៨ អ៊ីម៉ែល៖ mam.sambath@dpacam.org គេហទំព័រ៖ www.dpacam.org

ស្តារកម្ពុជា (SK)
លោកស្រី ជេត ចរិយា នាយិកាប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥) ១២ ៨០២៤៦០
អ៊ីម៉ែល៖ Star-director@starkampuchea.org.kh គេហទំព័រ៖ www.starkampuchea.org.kh

ដៃគូរៀបចំការអភិវឌ្ឍសហគមន៍ (CMDP)
លោក អៀង ហោ នាយក
ទូរស័ព្ទ៖ (៨៥៥) ៦៧ ៨៦៨ ៧៣៧ អ៊ីម៉ែល៖ hoaieng@yahoo.com

វិស័យព្រៃឈើ

១. សេចក្តីផ្តើម

ចំពោះបញ្ហាទាក់ទងនឹងវិស័យព្រៃឈើ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សម្របសម្រួលបណ្តាញជីវភាពអាស្រ័យព្រៃឈើ និងចំការឈើដាំ (FLPN) ដែលធ្វើការរួមគ្នាទៅលើបញ្ហាព្រៃឈើនៅកម្ពុជា ជាពិសេស ការចូលរួមពិគ្រោះយោបល់ខាងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។ បណ្តាញនេះរួមមានសមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

យើងខ្ញុំសូមអរគុណរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលព្រៃឈើចំពោះសកម្មភាពប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មព្រៃឈើនៅកម្ពុជា រួមមានគោលនយោបាយថ្មីៗមួយចំនួនរបស់រាជរដ្ឋាភិបាលសំដៅការពារព្រៃឈើនិងធនធានធម្មជាតិ។ គោលនយោបាយទាំងនេះ រួមមានកម្មវិធីព្រៃឈើជាតិ (NFP) និងផែនទីបង្ហាញផ្លូវ REDD កម្ពុជា។

ប៉ុន្តែ យើងខ្ញុំនៅតែបារម្ភអំពីកំណើនដ៏ខ្លាំងនៅក្នុងចំនួនសម្បទានដីសេដ្ឋកិច្ច ដែលត្រូវបានផ្តល់នៅកម្ពុជា ជាពិសេសនៅក្នុងតំបន់ការពារដែលជាឃ្លាំងចុងក្រោយនៃធនធានធម្មជាតិសម្បូរណ៌បែបរបស់ប្រទេសកម្ពុជា។ យើងខ្ញុំបានសង្កេតឃើញថាសម្បទានដីសេដ្ឋកិច្ចបានប៉ះពាល់អវិជ្ជមានទាំងទៅលើបរិស្ថាន និងជីវភាពរស់នៅរបស់សហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើ ជាពិសេស ជនជាតិដើមភាគតិចដែលជីវភាពរបស់ខ្លួនពឹងផ្អែកលើធនធានធម្មជាតិនិងព្រៃឈើទាំងនោះ។ ទោះបីជាមានច្បាប់ដែលតម្រូវឲ្យមានតម្លាភាពលើការងារសម្បទានដីសេដ្ឋកិច្ចក្តី ក៏ព័ត៌មានសាធារណៈស្តីពីសម្បទានដីសេដ្ឋកិច្ចនៅមានកម្រិត និងលាក់លៀម។ ហេតុដូចនេះ យើងខ្ញុំសូមស្វាគមន៍ចំពោះការផ្អាកការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងការពិនិត្យមើលឡើងវិញនូវសម្បទានដីដែលមានស្រាប់របស់រាជរដ្ឋាភិបាល។[45]

ដោយសារការផ្តល់សម្បទានដីសេដ្ឋកិច្ចកើនឡើងយ៉ាងច្រើន អង្គការមិនមែនរដ្ឋាភិបាលក៏មានកង្វល់ខ្លាំងផងដែរអំពីស្ថានភាពកាន់កាប់ដីនៅកម្ពុជា។ យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្ទៃដីសរុបដែលសហគមន៍បានប្រើសម្រាប់ធ្វើកសិកម្មក្នុងឆ្នាំ២០១០ មានទំហំប្រហែល ៣,៤៧៨,៥៩២[46]ហិកតា ដែលគឺជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាប្រហែល៧២.៣០%[47] ។ ពោលគឺប្រជាជនចំនួនប្រហែល៩,៦៨៥,០៧៨នាក់ ខណៈដែលដីប្រហែល១,៩៧០,៤១៥ ហិកតាត្រូវបានបែងចែកទុកសម្រាប់សម្បទានដីសេដ្ឋកិច្ច ដែលត្រូវបានកាន់កាប់ដោយសម្បទានិកចំនួនតែ២៧៧។[48]

យោងតាមប្រភពមួយផ្សេងទៀត សម្បទានដីសេដ្ឋកិច្ចគ្របដណ្តប់ផ្ទៃដី ២,០៣៦,១៧០ហិកតា ដែលស្មើនឹង ៥៣% នៃផ្ទៃដីដែលអាចដាំដុះបាននៅកម្ពុជា។ បន្ថែមលើនេះ ផ្ទៃដីចំនួន ១,៩០០,៣១១ហិកតា ត្រូវបានផ្តល់ជាសម្បទានរ៉ែ។ ផ្ទៃដីសរុបចំនួន ៣,៩៣៦,៤៨១ហិកតា នៃសម្បទានដីរ៉ែ និងសេដ្ឋកិច្ច បច្ចុប្បន្ននេះគ្របដណ្តប់ ២២% នៃផ្ទៃដីសរុបរបស់កម្ពុជា។[49]

---

[45] រាជរដ្ឋាភិបាលកម្ពុជា បទបញ្ជាលេខ ០១ ថ្ងៃទី៧ ខែឧសភា បទបញ្ជាស្តីពីវិធានការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច។

[46] http://www.stats.maff.gov.kh/km/index.php?option=com_content&view=article&id=1&Itemid=2

[47] យោងតាមជំរឿនប្រជាជនឆ្នាំ២០០៨ ៧២.៣០% នៃប្រជាពលរដ្ឋកម្ពុជាគឺជាកសិករ។

[48] យោងតាម ប្រព័ន្ធទិន្នន័យសម្បទានដីសេដ្ឋកិច្ចនៃ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

[49] Carving up Cambodia, one Concession at a time, a joint LICADHO and Cambodia Daily analysis, The Cambodia Daily, Issue 730, Saturday, March 10-11, 2012.

២. សូចនាករតាមដានរួម (ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំ CDCF ទីបី កាលពីថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១០)

ស្ថាប័នសម្របសម្រួល៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ស្ថាប័នអនុវត្ត៖** រដ្ឋបាលព្រៃឈើ				
លទ្ធផលរយៈពេលមធ្យម	**ធាតុចេញ**	**សូចនាករធាតុចេញ**	**សកម្មភាព៖ ចំនុចដៅសកម្មភាព**	**សកម្មភាពដើម្បីបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការ**
ថែរក្សាគម្របព្រៃឈើដោយបង្កើនបរិមាណ និងគុណភាពព្រៃឈើដោយកែលំអការគ្រប់គ្រងធនធានព្រៃឈើ	ពង្រឹងការអនុវត្តន៍កម្មវិធីព្រៃឈើជាតិដោយកែលំអការរៀបចំផែនការ និងការគ្រប់គ្រងវិស័យព្រៃឈើ	ជំរុញការអនុវត្តន៍កម្មវិធីព្រៃឈើជាតិទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយតម្រឹមធនធានសម្រាប់វិស័យព្រៃឈើទៅនឹងក្របខ័ណ្ឌកម្មវិធីព្រៃឈើជាតិឲ្យបានយ៉ាងតិច ៧៥%	១. ដាំព្រៃឡើងវិញលើដីរេចរិលឲ្យបាន២៥.000 ហ.ត ២. បោះព្រំប្រទល់ព្រៃឈើឲ្យបាន ៧៥0 គ.ម និងកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឲ្យបាន ៤ តំបន់ ៣. អនុម័តសហគមន៍ព្រៃឈើឲ្យបាន១00 និងសហគមន៍តំបន់ការពារធម្មជាតិឲ្យបាន ៧ សហគមន៍ ៤. អនុម័តនិងអនុវត្តផែនទីចង្អុលបង្ហាញផ្លូវ/ផែនការស្តីពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការអនុវត្តន៍យន្តការ REDD	១. ពង្រឹងការការរៀបចំផែនការប្រចាំឆ្នាំ ដើម្បីគាំទ្រដល់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ២. អនុម័តផែនការរៀបចំ តំបន់សហគមន៍ព្រៃឈើចំនួន ២លានហ.ត នៅលើផែនទីដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៣. រៀបចំនីតិវិធី និងបទបញ្ញត្តិសម្រាប់ REDD។

៣. វឌ្ឍនភាពដែលបានតាមដានលើសកម្មភាពវាស់

២.១. ដាំព្រៃឡើងវិញលើដីរេចរិលឲ្យបាន២៥,000 ហិកតា

អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យព្រៃឈើ ទទួលស្គាល់បំណងរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការដាំដើមឈើលើដីរិចរិលដោយរដ្ឋបាលព្រៃឈើ ដូចដែលត្រូវបានលើកឡើងនៅក្នុងសូចនាករតាមដានរួម។ ប៉ុន្តែអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលផ្សេងទៀត ខកចិត្តដោយសារ "ការដាំដើមឈើឡើងវិញ" រាប់បញ្ចូលទាំងការដាំដើមកៅស៊ូនៅក្នុងសម្បទានដីសេដ្ឋកិច្ច (ELCs) ក៏ដូចជា ដើមអាកាស្យានិងដើមប្រេងខ្យល់។

អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលមិនឯកភាពជាមួយនិយមន័យបច្ចុប្បន្ននៃពាក្យ"ព្រៃឈើ" ដែលរាប់បញ្ចូលទាំងចំការឈើដាំដែលបានកំណត់ដោយនៅក្នុងកម្មវិធីព្រៃឈើជាតិទេថា។ ចំការឈើដាំ មិនអាចជំនួសគុណតម្លៃនៃព្រៃឈើធម្មជាតិទេ ដោយសារព្រៃឈើធម្មជាតិផ្តល់នូវជីវចម្រុះ សេវាអេកូឡូស៊ី (ដូចជានិយ័តកម្មដីល្បប់និងទឹក ជាដើម)។ វាក៏ចូលរួមចំណែកដល់ការលើកកំពស់សេដ្ឋកិច្ច និងជីវភាពរបស់សហគមន៍មូលដ្ឋាន និងជាពិសេស ជាអត្តសញ្ញាណនៃជនជាតិដើមភាគតិច និងសហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើ។

អង្គការមិនមែនរដ្ឋាភិបាលសូមឲ្យរាជរដ្ឋាភិបាលកម្ពុជា/រដ្ឋបាលព្រៃឈើកំណត់និយមន័យនៃព្រៃឈើជា "ព្រៃឈើធម្មជាតិ" និងបែងចែកឲ្យបានច្បាស់លាស់រវាងសកម្មភាពនៃការដាំដើមឈើឡើងវិញ ដូចជា ការស្តារព្រៃធម្មជាតិ និង ការដាំឡើងវិញនូវព្រៃឈើធម្មជាតិ និងសកម្មភាពនៃការដាំដំណាំតែមួយមុខ ដូចជាការដាំដើមអាកាស្យា ដើមប្រេងខ្យល់ ដើមកៅស៊ូ និង ដើមដូងប្រេង ជាដើម។

២.២. បោះព្រំប្រទល់ព្រៃឈើឲ្យបាន ៧៥០ គ.ម និងកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឲ្យបាន៤តំបន់

អង្គការមិនមែនរដ្ឋាភិបាលសូមវាយតម្លៃខ្ពស់ចំពោះការកំណត់ព្រំប្រទល់ព្រៃឈើ និងតំបន់ការពារទៅតាមផែនការ ក៏ប៉ុន្តែ យើងខ្ញុំមានការបារម្ភយ៉ាងខ្លាំងចំពោះកំណើនដ៏លឿនចំពោះចំនួនសម្បទានដីសេដ្ឋកិច្ចដែលត្រូវបានផ្តល់នៅក្នុងតំបន់ការពាររួមមានបូកគោ បុទុមសាគរ វិរៈជ័យ ឱរ៉ាល់ បឹងពែរ លំជាត់ ណាមលៀរ និង កែវសីមា។

តំបន់ការពារទាំងនេះ គឺជាជង្រុករតនសម្បត្តិនៃធនធានធម្មជាតិ ជាពិសេសព្រៃឈើ ដែលផ្តល់អត្ថប្រយោជន៍ច្រើនប្រការ រួមមានសេវាអេកូឡូស៊ីដែលសំខាន់ក្រៃលែងចំពោះនិរន្តរភាពបរិស្ថាននៃប្រទេសកម្ពុជា។ យើងខ្ញុំបានសង្កេតឃើញថាសម្បទានដីសេដ្ឋកិច្ចធ្វើឲ្យខូចខាតដល់បរិស្ថាន ដែលបណ្តាលឲ្យមានការបាត់បង់ ឬការថយចុះនៃសេវាអេកូឡូស៊ីដ៏សំខាន់ដែលប្រទេសកម្ពុជាទាំងមូលពឹងអាស្រ័យ ក៏ដូចជាប៉ះពាល់ជាអវិជ្ជមានលើសេដ្ឋកិច្ចប្រជាជនមូលដ្ឋាន វប្បធម៌ ជីវភាព និងសន្តិសុខស្បៀងនៃសហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើ ជាពិសេសជនជាតិដើមភាគតិច។

២.៣. អនុម័តសហគមន៍ព្រៃឈើឲ្យបាន១០០ និងសហគមន៍តំបន់ការពារធម្មជាតិឲ្យបាន៧សហគមន៍

គិតមកដល់ខែវិច្ឆិកា ឆ្នាំ២០១១ មាន សហគមន៍ព្រៃឈើចំនួន១៣០ ដែលមានផ្ទៃដីសរុបទំហំ១៤១,០៣១ហិកតា ដែលត្រូវបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ យើងអបអរសាទរកិច្ចប្រឹងប្រែងនេះ។ ទោះជាយ៉ាងណាក្តី អង្គការមិនមែនរដ្ឋាភិបាលនិងសហគមន៍មួយចំនួន បានសង្កេតឃើញថានីតិវិធីនៃការទទួលការយល់ព្រមពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទគឺយឺត និង លំបាក ជាពិសេសនៅពេលដែលប្រៀបធៀបទៅនឹងនីតិវិធីនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច សូម្បីតែសមាជិកនៃក្រុមការងារ TWG-FE ក៏ទទួលស្គាល់ចំណុចនេះដែរ[50]។

អង្គការមិនមែនរដ្ឋាភិបាល មានការបារម្ភផ្សេងទៀតមួយចំនួន៖

- សហគមន៍ព្រៃឈើនិងតំបន់ការពារសហគមន៍ មានទំហំតូច ដែលជាមធ្យមមានទំហំ១០០០ ហិកតាក្នុងមួយកន្លែងៗ ប្រៀបធៀបទៅនឹងសម្បទានដីសេដ្ឋកិច្ច ដែលយោងតាមច្បាប់អាចមានទំហំធំជាងដល់១០ដង[51]។
- សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារ ច្រើនតែត្រូវបានគេផ្តល់នៅក្នុងតំបន់ដែលគេមិនសូវចង់បាន ដែលមានលក្ខណៈរិចរិលណាស់រួចទៅហើយ ដែលជាហេតុធ្វើឲ្យពួកគេជួបការលំបាក ដោយសារពួកគេខិតខំស្តារព្រៃ និងប្រើប្រាស់ព្រៃឈើក្នុងពេលតែមួយ។
- គេឃើញមានករណីមួយចំនួននៃសម្បទានដីសេដ្ឋកិច្ចត្រួតស៊ីគ្នា ឬបំពានលើសហគមន៍ព្រៃឈើ និង សហគមន៍តំបន់ការពារ ដែលនាំឲ្យតំបន់សហគមន៍ទាំងនោះរួមតូចទៅៗ ឬដែលធ្វើឲ្យតំបន់ទាំងនោះកាន់តែរិចរិលទៅ។
- សហគមន៍ព្រៃឈើ និងតំបន់សហគមន៍ការពារ កំពុងក្លាយទៅជាកោះនៅក្នុងសមុទ្រសម្បទានដីសេដ្ឋកិច្ចនិងតំបន់អភិវឌ្ឍន៍ ដែលកាត់ផ្តាច់ច្រករបៀងសត្វព្រៃនិងកាត់បន្ថយគុណតម្លៃជីវៈចម្រុះ។
- នៅពេលពេលដែលសម្បទានដីសេដ្ឋកិច្ចស្ថិតនៅក្នុងចន្លោះរវាងសហគមន៍ព្រៃឈើ ឬសហគមន៍តំបន់ការពារ និងភូមិកររបស់ប្រជាជននោះ គេសង្កេតឃើញថា សមាជិកសហគមន៍ច្រើនតែមានការលំបាកក្នុងការចេញចូលតំបន់ការពាររបស់ពួកគេ។
- សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារ ទទួលរងផលប៉ះពាល់អវិជ្ជមានពីផលិតកម្មនៃសម្បទានដីសេដ្ឋកិច្ចដែលជារឿយៗរួមមានថ្នាំកសិកម្ម និងរបបជាតិគីមី ដែលកាត់បន្ថយគុណភាពទឹកនិងខ្យល់ និងធ្វើឲ្យអន្តរាយដល់រុក្ខជាតិក្នុងស្រុក និងការភ្ជួររាស់និងប្រព័ន្ធស្រោចស្រពដែលប៉ះពាល់គុណភាពដីនៅក្នុងតំបន់ និងធារាសាស្ត្រ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានប្រញាប់ប្រញាល់ ហួសពេល និង/ឬ ដែលអនុវត្តមិនបានល្អ រួមចំណែកដល់ប្រការនេះ ដោយខកខានមិនបានព្យាករណ៍បញ្ហានិងផែនការសម្រាប់កាត់បន្ថយហេតុប៉ះពាល់។

---

[50] សូមមើលផ្នែក "បញ្ហាប្រឈម" នៅក្នុងរបាយការណ៍ស្តីពីវឌ្ឍនភាពនៅក្នុងការអនុវត្តសូចនាករតាមដានរួម ខែកញ្ញា ឆ្នាំ២០១១។

[51] ថ្វីបើការកំណត់ទំហំស្របច្បាប់នៃសម្បទានមួយគឺ១០,០០០ហិកតាក្តី ក៏គេឃើញមានសម្បទាននៅក្នុងឯកសារដែលមានទំហំធំជាងដែរ។ សម្បទានទាំងនេះ រួមមានសម្បទានភាគីម៉ិចនៅខេត្តកំពង់ឆ្នាំ និង ពោធិសាត់ ដែលមានទំហំធំជាង៣០០,០០០ហិកតា។

សហគមន៍ព្រៃឈើ គឺគ្មានប្រសិទ្ធភាពទេក្រោមស្ថានភាពទាំងនេះ ឬ ក្រោមស្ថានភាព ដែលនៅក្នុងនោះ មានតែផ្នែដី តូចៗប៉ុណ្ណោះដែលត្រូវបានទទួលយកថាជា សហគមន៍ព្រៃឈើ ឬ សហគមន៍តំបន់ការពារ ។

ម្យ៉ាងទៀត អង្គការមិនមែនរដ្ឋាភិបាលបានសង្កេតឃើញថាការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងព្រៃឈើ គឺសំខាន់ចំពោះការអភិរក្សព្រៃឈើនៅកម្ពុជា។ សហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើនិងជនជាតិដើមភាគតិចគឺជាអ្នកទទួលរងផលប៉ះពាល់ទីមួយនិងដោយផ្ទាល់ពីការបាត់បង់ព្រៃឈើ និងជីវៈចម្រុះនៅក្នុងតំបន់របស់ពួកគេ។ ដោយសារសហគមន៍មូលដ្ឋានស្និទ្ធិស្នាលជាមួយនឹងព្រៃឈើ ពួកគេក៏មានសមត្ថភាពសមរម្យផងដែរដើម្បីរួមចំណែកដល់ការគ្រប់ គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (គួរកត់សម្គាល់ថាសហគមន៍មូលដ្ឋានមានមានចំនាប់អារម្មណ៍បំផុតក្នុងការថែរក្សាធនធានព្រៃឈើ ខុសពីជនចំណាកស្រុកដែលរួមចំណែកច្រើនដល់ការកាប់បំផ្លាញព្រៃឈើ។)

នៅជុំវិញប្រទេស យើងបានឃើញសហគមន៍ធ្វើចលនាដើម្បីការពារព្រៃឈើ។ ប្រការនេះកើតមានឡើងហួសពីសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារ ដែលបានចុះបញ្ជីទៅទៀត។ឧទាហរណ៍ជាក់ស្តែងបំផុតនៃចំណុចនេះ គឺបណ្តាញសហគមន៍ព្រៃឡង់[52] ដែលត្រូវបានផ្តួចផ្តើមតាំងពីឆ្នាំ២០០៨ដោយសមាជិកសហគមន៍ដែលមានការបារម្ភ ជាពិសេស ជនជាតិដើមភាគតិចកួយ ពីតំបន់ជុំវិញព្រៃឈើ នៅក្នុងខេត្តជាប់ព្រៃឡង់ទាំង ៤ (កំពង់ធំ ព្រះវិហារ ក្រចេះ និងស្ទឹងត្រែង)។ ក្រុមនេះ ដែលនៅពេលនេះរួមមានសមាជិកមកពីភូមិជិត ១៥០ នៅក្នុង និងនៅជុំវិញព្រៃឡង់បានធ្វើសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ធ្វើការល្បាតព្រៃឈើយ៉ាងទៀងទាត់ ដោយចាយប្រាក់ខ្លួនឯង
- បណ្តុះបណ្តាលយុវជនលើជំនាញព្រៃឈើ
- ធ្វើការតស៊ូមតិដ៏ក្លៀវក្លាដើម្បីការពារព្រៃឡង់ ដោយធ្វើឲ្យមានការយកចិត្តទុកដាក់លើគុណតម្លៃនៃព្រៃឈើពីសំណាក់ប្រទេសជាតិទាំងមូលនិងរហូតដល់ពិភពលោកថែមទៀត និងបាន
- បង្កើតរចនាសម្ព័ន្ធគ្រប់គ្រងបណ្តាញស្នូលមួយ ដែលអាចអភិវឌ្ឍថែមទៀតទៅជាស្ថាប័នមួយសម្រាប់ការគ្រប់គ្រងព្រៃឈើក្នុងលក្ខណៈសហការគ្នា។

បណ្តាញនេះ បានជម្រុញឲ្យរាជរដ្ឋាភិបាលផ្តល់ឋានៈការពារដល់ព្រៃឈើនេះ ទន្ទឹមគ្នានឹងការអំពាវនាវសុំធ្វើជាអ្នកគ្រប់គ្រងរួមដើម្បីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ គំនិតរបស់ពួកគេគឺសំដៅថែរក្សាតំបន់ស្នូលមួយដែលភាគច្រើនមិនត្រូវបានគេប៉ះពាល់ស្ថិតនៅកណ្តាលទ្រុងព្រៃ ដែលត្រូវបានព័ទ្ធការពារដោយព្រៃឈើប្រើប្រាស់ដោយសហគមន៍ផ្សារភ្ជាប់គ្នានិងដីកសិកម្មរបស់សហគមន៍ ជារបាំងការពារមួយសម្រាប់ព្រៃទាំងមូល។ លក្ខណៈបែបនេះ មិនត្រឹមតែធ្វើឲ្យគង់វង្សព្រៃឈើនៅកម្រិតទ្រង់ទ្រាយធំនោះ (ដែលមានគុណតម្លៃធំធេងបំផុតរបស់វា) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយគាំទ្រផលប្រយោជន៍របស់សមាជិកសហគមន៍នៅក្នុងកិច្ចការពារព្រៃឈើទៀតផង ទន្ទឹមគ្នានឹងការផ្តល់ឱកាសជួយអភិវឌ្ឍតំបន់ទ្រនាប់នៃព្រៃឈើសហគមន៍ និងដីកសិកម្ម ដែលអាចជួយគាំទ្រចំពោះសកម្មភាពសហគ្រិនសមស្របផ្សេងៗបានដល់សហគមន៍មូលដ្ឋាន។

ទោះបីជានៅក្នុងកម្មវិធីព្រៃឈើជាតិមានវិធីសាស្ត្រច្រើនសម្រាប់ការគ្រប់គ្រងព្រៃឈើក្តី ប៉ុន្តែមកដល់ពេលនេះ គំរូនៃការការពារព្រៃឈើក្នុងភាពជាដៃគូ មានតែគំរូនៃសហគមន៍ព្រៃឈើមួយប៉ុណ្ណោះដែលត្រូវបានផ្តួចផ្តើម។ ករណីព្រៃឡង់អាចផ្តល់ជាមេរៀនដើម្បីអភិវឌ្ឍគំរូថ្មីមួយក្នុងការការពារព្រៃឈើក្នុងភាពជាដៃគូ ពោលគឺគំរូមួយដែលបានបង្ហាញភស្តុតាងជោគជ័យ នៅតំបន់ផ្សេងទៀតនៃពិភពលោក និងដែលនឹងអាចផ្តល់ផលប្រយោជន៍ដល់ទាំងរាជរដ្ឋាភិបាលកម្ពុជា សហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើ និងប្រជាជនកម្ពុជាទាំងមូល។

យើងខ្ញុំសូមជម្រុញឲ្យម្ចាស់ជំនួយសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បី៖

- ការពារព្រៃឡង់ និងតំបន់ព្រៃឈើផ្សេងទៀត ដែលផ្តល់សេវាបរិស្ថានដ៏សំខាន់ដល់ការទ្រទ្រង់ជីវិត

[52]ដើម្បីព័ត៌មានបន្ថែមស្តីពីព្រៃឡង់ និង ស្តីពីបណ្តាញសហគមន៍ព្រៃឡង់ សូមមើល:http://www.facebook.com/pages/Prey-Lang-Its-Our-Forest-Too/139354142798072; http://ourpreylang.wordpress.com; និងhttp://mouthtosource.org/rivers/preylang/

- អភិវឌ្ឍគំរូផ្សេងទៀតសម្រាប់ឲ្យប្រជាជនចូលរួមក្នុងការគ្រប់គ្រងព្រៃឈើ រួមទាំងចូលរួមប្រែក្លាយបណ្តាញសហគមន៍ ការពារព្រៃឡង់ឲ្យទៅជា ដៃគូមួយក្នុងការការពារព្រៃឡង់ ដោយសហការ។

២.៤. អនុម័តនិងអនុវត្តផែនទីចង្អុលបង្ហាញផ្លូវ/ផែនការស្តីពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការអនុវត្តយន្តការ REDD

អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលទទួលស្គាល់ថា គំនិតផ្តួចផ្តើមនៃការរៀបចំផែនទីបង្ហាញផ្លូវ REDD+ ថ្នាក់ជាតិ មានលក្ខណៈកាន់តែចូលរួមជាងកិច្ចដំណើរការរៀបចំគោលនយោបាយព្រៃឈើផ្សេងៗទៀត ដោយផ្តល់ឱកាសឲ្យអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលផ្សេងទៀតលើកឡើងការបារម្ភ និងចូលរួមគំនិត។ យើងក៏ទទួលស្គាល់ផងដែរថានៅក្នុងរចនាសម្ព័ន្ធនៃផែនទីបង្ហាញផ្លូវនេះអនុញ្ញាតិឲ្យអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលមានតំណាងនៅក្នុងក្រុមដែលធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ រួមមាន ក្រុមប្រឹក្សាយោបល់រ៉េដបូក ក្រុមបច្ចេកទេសពិគ្រោះយោបល់ និងសុវត្ថិភាព ក្រុមបច្ចេកទេសបែងចែកផលប្រយោជន៍ ក្រុមបច្ចេកទេសសាកល្បងរ៉េដបូក ក្រុមបច្ចេកទេស MRV/REL និងជាពិសេសក្រុមពិគ្រោះយោបល់រ៉េដបូក (REDD+ CONSULTATION GROUP)។ អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលជឿថាក្រុមទាំងនេះ និងនីតិវិធីពាក់ព័ន្ធទាំងឡាយនឹងអនុញ្ញាតឲ្យមានការផ្តល់ធាតុចូលដ៏ពិតប្រាកដនិងមានតម្លៃរបស់សង្គមស៊ីវិលដល់ការអភិវឌ្ឍជាបន្តនៃយុទ្ធសាស្ត្រនិងគោលនយោបាយរ៉េដបូក។

ទោះជាយ៉ាងនេះក្តី អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលបានសង្កេតឃើញថា កម្មវិធីរ៉េដបូក និងសម្បទានដីសេដ្ឋកិច្ចតំណាងឲ្យយន្តការពីរផ្ទុយគ្នាសម្រាប់ការគ្រប់គ្រងព្រៃឈើ។ REDD+ រួមចំណែកដល់កិច្ចការពារព្រៃឈើធម្មជាតិ ខណៈដែលសម្បទានដីសេដ្ឋកិច្ចបំផ្លាញព្រៃឈើធម្មជាតិសម្រាប់អភិវឌ្ឍន៍កសិ-ឧស្សាហកម្មធុនធំ។ យើងខ្ញុំទទួលស្គាល់ថា REDD+ តំណាងឲ្យកាលានុវត្តភាពមួយសម្រាប់ការពារព្រៃឈើនៅសេសសល់នៃប្រទេសកម្ពុជា ប៉ុន្តែយើងក៏បារម្ភផងដែរថា REDD+ នឹងមិនរួមចំណែកដល់ការអភិរក្សព្រៃឈើទេ ប្រសិនបើរាជរដ្ឋាភិបាលបន្តផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានរ៉ែ និងខកខានមិនបានពាក់ព័ន្ធ និងផ្តល់អំណាចឲ្យបានសមស្របជូនសហគមន៍ឲ្យចូលរួមក្នុងការការពារ និងការគ្រប់គ្រងព្រៃឈើ។

យើងខ្ញុំវាយតម្លៃខ្ពស់ចំពោះការយកចិត្តទុកដាក់របស់ម្ចាស់ជំនួយក្នុងការគាំទ្រកម្ពុជាក្នុងការអនុវត្ត REDD+ ជាយុទ្ធសាស្ត្រមួយដើម្បីទ្រទ្រង់សម្បត្តិព្រៃឈើកម្ពុជានិងសេវាបរិស្ថានរបស់វា។ យើងខ្ញុំសូមស្នើសុំការជួយគាំទ្ររបស់ម្ចាស់ជំនួយដើម្បីធានាឲ្យបានថាកិច្ចដំណើរការ REDD+ ត្រូវបានអនុវត្ត តាមវិធីទាំងឡាយដែលមានយុត្តិធម៌សង្គម ទន្ទឹមគ្នានឹងការរួមចំណែកដល់ចីរភាពបរិស្ថានកម្ពុជា។

៣. ទិសដៅអនាគតសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

យើងខ្ញុំសូមជម្រុញចំណុចខាងក្រោម៖

- វាជាការចាំបាច់ក្នុងការពិនិត្យមើលឡើងវិញនូវសម្បទានដែលមានស្រាប់ ដោយយោងតាមបទបញ្ជាលេខ ០១ ដើម្បីធានាថាសម្បទានទាំងអស់នេះ ត្រូវបានអនុលោមតាមក្របខណ្ឌគតិយុត្តិជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ។ កង្វះខាតធនធាន និងសមត្ថភាពបច្ចេកទេសគួរតែប្តឹត្រូវបានកំណត់ និងដោះស្រាយ ហើយការអនុវត្តបទបញ្ជាលេខ ០១ និងឯកសារដែលពាក់ព័ន្ធនានាគប្បីត្រូវបានតាមដាន និងរាយការណ៍ជាសាធារណៈឲ្យបានកាន់តែច្រើនជាងមុន។
- រាជរដ្ឋាភិបាលកម្ពុជាគប្បីផាកពិន័យសម្បទានិកចំពោះការរំលោភលើកិច្ចសន្យា និងការធ្វើឲ្យខូចខាតដល់សហគមន៍។
- រាជរដ្ឋាភិបាលកម្ពុជាគប្បីកែប្រែនិយមន័យនៃព្រៃឈើ ដើម្បីរាប់បញ្ចូលតែ "ព្រៃឈើធម្មជាតិ" និងមិនរាប់បញ្ចូលចំការឈើដាំ។

- ដោយមានជំនួយគាំទ្រ និងជំនួយបច្ចេកទេសពីម្ចាស់ជំនួយ រាជរដ្ឋាភិបាលកម្ពុជាគប្បីជម្រុញការរៀបចំផែនទីប្រើប្រាស់ដី ដើម្បីធានាថាដីត្រូវបានប្រើប្រាស់ដោយសមស្របបំផុត។
- រាជរដ្ឋាភិបាលកម្ពុជាគប្បីសម្រួល និងពន្លឿននីតិវិធីចុះបញ្ជីសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារ ដែលមានទំហំធំសម្រាប់ទីតាំងនីមួយៗ។
- ដោយមានជំនួយគាំទ្រ និងជំនួយបច្ចេកទេសពីម្ចាស់ជំនួយ អភិវឌ្ឍគម្រោងទៀតសម្រាប់ការចូលរួមរបស់ប្រជាជននៅក្នុងការគ្រប់គ្រងព្រៃឈើរួមទាំងការពង្រឹងព្រៃឡង់ជាព្រៃឈើភាពជាដៃគូ ដែលត្រូវបានគ្រប់គ្រងដោយសហការជាមួយបណ្តាញសហគមន៍ព្រៃឡង់នៅថ្នាក់ទេសភាព ដែលមានលក្ខណៈសមស្របសម្រាប់គម្រោង REDD+។
- ម្ចាស់ជំនួយនិងរាជរដ្ឋាភិបាលកម្ពុជា គប្បីធានាឲ្យបាននូវការបន្តនិងភាពជាតំណាងនិងការចូលរួមដ៏មានអត្ថន័យរបស់តួអង្គសង្គមស៊ីវិលនៅក្នុងរាល់កិច្ចដំណើរការ REDD+ ទាំងអស់។
- ដោយមានជំនួយគាំទ្រ និងជំនួយបច្ចេកទេសពីម្ចាស់ជំនួយ រាជរដ្ឋាភិបាលកម្ពុជាគប្បីកែលម្អការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIAs) ដើម្បីផ្តល់ព័ត៌មានឲ្យបានកាន់តែប្រសើរឡើងដល់ការធ្វើផែនការទីលំហរ និងការប្រើប្រាស់ដី។
- រាជរដ្ឋាភិបាលកម្ពុជាគប្បីផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ច ធ្វើឲ្យព័ត៌មាននេះមានលក្ខណៈបច្ចុប្បន្ន និងពេញលេញ។
- រាជរដ្ឋាភិបាលកម្ពុជា គប្បីអនុវត្តច្បាប់ស្តីពីធនធានទឹកដើម្បីថែរក្សាធារាសាស្ត្រកម្ពុជា និងដើម្បីធានាឲ្យបាននូវលទ្ធភាពរបស់សហគមន៍ក្នុងការប្រើប្រាស់ទឹកសម្រាប់រាល់តម្រូវការទាំងអស់របស់ពួកគេ រួមទាំងសហគមន៍ព្រៃឈើ និងតំបន់ការពារដីកសិកម្ម និងភូមិ។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
លោក ឈិត សំអាត នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh និង www.cambodianbudget.org
អាសយដ្ឋាន៖ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

ផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានពីការពង្រីកឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា

១. សេចក្តីផ្តើម

សង្គមស៊ីវិលកម្ពុជាបានដាក់របាយការណ៍លើកទីពីរស្តីពីផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាននៃឧស្សាហកម្មរ៉ែ កាលពីខែឧសភា ឆ្នាំ២០១០។ រហូតមកដល់ពេលនោះ មានក្រុមហ៊ុនប្រមាណ ៦០ បានទទួលអាជ្ញាប័ណ្ណស្រាវជ្រាវរុករករ៉ែ ចំនួន ១៦២អាជ្ញាប័ណ្ណ (ក្នុងនោះមានក្រុមហ៊ុនតិចតួចប៉ុណ្ណោះបានទទួលអាជ្ញាប័ណ្ណធ្វើអាជីវកម្ម) នេះបើយោងតាមទិន្នន័យដែលយើងទទួលបានពីអ្នកពាក់ព័ន្ធ។ ដោយមានការចាប់អារម្មណ៍កាន់តែខ្លាំងពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលជាច្រើនឆ្នាំមកនេះ សាធារណជនបានយល់ដឹងច្រើនពីវិស័យដែលកំពុងរីកចម្រើននេះ។

ក្នុងនាមជាប្រទេសមួយកំពុងអភិវឌ្ឍ កម្ពុជាទើបតែចាប់ផ្តើមយល់ដឹងអំពីផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានដែលអាចមានពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្ម។ ឧទាហរណ៍ អាជ្ញាប័ណ្ណត្រួតស៊ីគ្នាពីរត្រូវបានចេញឲ្យរុករករ៉ែក្នុងតំបន់តែមួយជាដើម។[53] ក្របខ័ណ្ឌច្បាប់របស់កម្ពុជាដើម្បីដោះស្រាយបញ្ហានានាដែលអាចកើតចេញពីសកម្មភាពរុករករ៉ែនេះ ក៏នៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ។ ទោះជាយ៉ាងណា កម្ពុជាបានឈានមួយជំហានគួរឲ្យកោតសរសើរដោយបានបង្ហាញអំពីបំណងរបស់ខ្លួនក្នុងការបញ្ចេញព័ត៌មានអំពីការផ្តល់សម្បទានរុករករ៉ែជាសាធារណៈក្នុងសូចនាករតាមដានរួម នៅក្នុងវេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍកម្ពុជា (CDCF) លើកទី២ (ខែតុលា ឆ្នាំ២០០៨) និងលើកទី៣ (ខែមិថុនា ឆ្នាំ២០១០)។ រាជរដ្ឋាភិបាលក៏បានទទួលស្គាល់ពីកង្វល់ផ្សេងៗក្នុងវិស័យនេះ តាមរយៈការត្រួតពិនិត្យប្រចាំឆ្នាំនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ផងដែរ។

ទោះជាយ៉ាងនេះក្តី វឌ្ឍនភាពដើម្បីសម្រេច JMIs មានជំហានយឺត ជាពិសេសពាក់ព័ន្ធនឹងការទទួលបានព័ត៌មានពីឧស្សាហកម្មនិស្សារណកម្មនេះ។ ស្រដៀងគ្នានេះដែរ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ មិនបានដោះស្រាយបញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ចក្នុងវិស័យនិស្សារណកម្មឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ ហេតុដូច្នេះ អង្គការសង្គមស៊ីវិលបានរៀបចំឯកសារគោលជំហរនេះ ដើម្បីគូសបង្ហាញពីកង្វល់ដែលពាក់ព័ន្ធនានា សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និងក្រុមហ៊ុនទាក់ទងនឹងវិស័យនិស្សារណកម្មក្នុងប្រទេសកម្ពុជា។ ជាពិសេស ឯកសារគោលជំហរនេះមានគោលបំណង៖

- បន្តកំណត់បញ្ហាក្នុងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្ម
- ប្រាស្រ័យទាក់ទងជាមួយប្រជាជនមូលដ្ឋានដែលរងផលប៉ះពាល់ និងធ្វើការបូកសរុបក្តីកង្វល់សំខាន់ៗរបស់ពួកគាត់អំពីផលប៉ះពាល់សង្គម និងបរិស្ថាននៃឧស្សាហកម្មនិស្សារណកម្ម
- ធ្វើការបន្ទរបន្តុយទំនាស់អំពីផលប្រយោជន៍ និងលើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការរវាងអ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យនិស្សារណកម្មនៅកម្ពុជា។

នៅក្នុងរបាយការណ៍នេះ ក៏មានដាក់បញ្ចូលផងដែរនូវករណីសិក្សាចំនួនពីរដែលបានធ្វើការសិក្សាក្នុងខេត្តពីរក្នុងឆ្នាំ ២០១០-១២ ដើម្បីគូសបញ្ជាក់ពីវឌ្ឍនភាពដែលសម្រេចបាន។ នេះជាប្រវត្តិសាស្ត្រដ៏សំខាន់មួយ ដែលវិស័យរ៉ែរបស់កម្ពុជាមានភាពលូតលាស់ជាលំដាប់ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ ប៉ុន្តែ ប្រសិនបើមិនមានគណនេយ្យភាព និងតម្លាភាពឲ្យ

[53] ដីសម្បទានរ៉ែដែលបានផ្តល់ទៅឲ្យក្រុមហ៊ុនចិនមួយនៅខេត្តបន្ទាយមានជ័យ បានអនុញ្ញាតឲ្យក្រុមហ៊ុននេះកាប់ព្រៃក្នុងតំបន់នោះ ដែលព្រៃនោះពីមុនត្រូវបានទទួលស្គាល់ថាជាព្រៃសហគមន៍ដោយរដ្ឋបាលព្រៃឈើ។ ទោះយ៉ាងណា ក្រុមហ៊ុនបានកាប់ព្រៃដោយផ្អែកលើអាជ្ញាប័ណ្ណរបស់ខ្លួន។

កាន់តែប្រសើរជាងនេះក្នុងជួររដ្ឋាភិបាល និងវិស័យឯកជន វិស័យឧស្សាហកម្មនិស្សារណកម្មនឹងមិនអាចទទួលបាននូវភាពរីកចម្រើនខ្លាំងក្លាបានឡើយ។

ដោយសារតែច្បាប់បច្ចុប្បន្នរបស់កម្ពុជា មិនបានដោះស្រាយបញ្ហាដែលកើតចេញពីឧស្សាហកម្មនិស្សារណកម្មឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ជនឱកាសនិយមមួយចំនួនក្នុងវិស័យនេះ នឹងអាចកេងចំណេញពីកង្វះខាតផ្នែកច្បាប់ដោយបង្កឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរ និងមិនអាចស្រោចស្រង់វិញបានចំពោះប្រជាជន និងបរិស្ថានរបស់ប្រទេសកម្ពុជា។ ដោយបានគិតឃើញពីបញ្ហាប្រឈមនេះហើយ បានជាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់អង្គការ **ភាពជាដៃគូ និងអភិវឌ្ឍក្នុងសកម្មភាព** (DPA) ដែលសម្របសម្រួលបណ្តាញ **ផលប៉ះពាល់សង្គម និងបរិស្ថានដោយឧស្សាហកម្មនិស្សារណកម្ម (EISEI)** ដើម្បីសម្របសម្រួលកិច្ចសន្ទនាក្នុងរវាង សហគមន៍មូលដ្ឋាន រដ្ឋាភិបាល និងឧស្សាហកម្មឯកជនផ្សេងៗ។ DPA-EISEI ជាវេទិកាប្រាស្រ័យទាក់ទង និងចែករំលែកចំណេះដឹងថ្នាក់ជាតិមួយដែលសម្របសម្រួលការសិក្សា និងចែកចាយព័ត៌មានពាក់ព័ន្ធនឹងផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានពីវិស័យនិស្សារណកម្មនៅកម្ពុជា ដែលកំពុងតែរីកចម្រើននេះ។ បណ្តាញនេះមានចក្ខុវិស័យដើម្បីផ្តល់មូលដ្ឋានដ៏រឹងមាំសម្រាប់ការអនុវត្ត ការអប់រំ កិច្ចគាំទ្របច្ចេកទេស និងការផ្តួចផ្តើមការតស៊ូមតិនាពេលអនាគត ក្នុងការដោះស្រាយនូវកង្វល់របស់សហគមន៍ និងសង្គមស៊ីវិលអំពីផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានដែលកើតឡើងពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មនិស្សារណកម្មក្នុងប្រទេសកម្ពុជា។

២. សូចនាករត្រួតពិនិត្យរួម (JMI)

ចំណុចក្នុង JMI ទី៩ ដែលបានព្រមព្រៀងនៅក្នុងកិច្ចប្រជុំ CDCF (កាលពីថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១០) នឹងត្រូវអនុវត្ត និងតាមដានក្នុងចន្លោះកិច្ចប្រជុំ CDCF លើកទីបី និងទីបួន ដែលពាក់ព័ន្ធដោយប្រយោលនឹងឧស្សាហកម្មនិស្សារណកម្ម៖

លទ្ធផល៖ លទ្ធផល ធាតុចេញ និងសូចនាករ			**សកម្មភាព៖ ចំណុចដៅសកម្មភាព**	
លទ្ធផលរយៈពេលមធ្យម	**ធាតុចេញ**	**សូចនាករធាតុចេញ**	**សកម្មភាព**	**សកម្មភាពដើម្បីបង្កើនប្រសិទ្ធិភាពហិរញ្ញប្បទាន សហប្រតិបត្តិការ**
ការអនុវត្ត និងការគ្រប់គ្រងនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម				
សូចនាករតាមដានរួមគ្នាទី ៩៖ ព្រៃឈើ				
ថែរក្សាគម្របព្រៃឈើដោយបង្កើនបរិមាណ និងគុណភាពព្រៃឈើ ដោយកែលំអការគ្រប់គ្រងធនធានព្រៃឈើ	ពង្រឹងការអនុវត្តន៍កម្មវិធីជាតិព្រៃឈើ ដោយកែលំអរការរៀបចំផែនការ និងការគ្រប់គ្រងវិស័យព្រៃឈើ	ជំរុញការអនុវត្តន៍កម្មវិធីព្រៃឈើជាតិទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយតម្រឹមធនធានសម្រាប់វិស័យព្រៃឈើ ទៅនឹងក្របខ័ណ្ឌកម្មវិធីព្រៃឈើជាតិឲ្យបានយ៉ាងតិច៧៥%	១. ដាំព្រៃឡើងវិញលើដីរេចរឹលឲ្យបាន២០.០០០ហ.ត ២. បោះព្រំប្រទល់ព្រៃឈើឲ្យបាន ៧៥០ គ.ម និងកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឲ្យបាន ៤តំបន់ ៣. អនុម័តសហគមន៍ព្រៃឈើឲ្យបាន១០០ និងសហគមន៍តំបន់ការពារឲ្យបាន ៧ សហគមន៍ ៤. អនុម័ត និងអនុវត្តផែនទីចង្អុលផ្លូវ/ផែនការស្តីពីការត្រៀមខ្លួនរបស់កម្ពុជា ក្នុងការអនុវត្តន៍យន្តការREDD	១. ពង្រឹងការរៀបចំផែនការប្រចាំឆ្នាំដើម្បីគាំទ្រដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ២. អនុម័តផែនការរៀបចំតំបន់សហគមន៍ព្រៃឈើចំនួន ២ លានហ.ត នៅលើផែនទី ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៣. រៀបចំនិតិវិធី និងបទបញ្ញត្តិសម្រាប់ REDD

ដោយហេតុតែមិនទាន់មានភាពពេញចិត្តចំពោះវឌ្ឍនភាពក្នុងការអនុវត្ត JMI នេះនៅឡើយ អង្គការសង្គមស៊ីវិល (CSOs) សូមផ្តល់អនុសាសន៍យ៉ាងមុតមាំថា កិច្ចប្រជុំបន្ទាប់របស់ CDCF គួរតប្បីដោះស្រាយជាពិសេសនូវបញ្ហានានាក្នុងឧស្សាហកម្មនិស្សារណកម្ម និងគួរបង្កើតឲ្យមានក្រុមការងារបច្ចេកទេសឧស្សាហកម្មនិស្សារណកម្ម ដែលដឹកនាំដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ខណៈពេលដែលឯកសារគោលជំហរនេះផ្តោតលើការរុករករ៉ែ វាក៏ត្រូវនឹងការរុករកប្រេង និងឧស្ម័នផងដែរ។

វឌ្ឍនភាពនៃការអនុវត្ត JMI ទី៩

ក្រសួងបរិស្ថាន បានបង្កើតអនុផ្នែកមួយដែលកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ដែលជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាល ដើម្បីធានាថាការផ្តល់អាជ្ញាប័ណ្ណដីសម្បទានសេដ្ឋកិច្ចនឹងកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានទៅលើសហគមន៍។ ក្រសួងបរិស្ថានក៏មាននាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានដែលកំពុងពង្រីកវិសាលភាពច្បាប់ស្តីពីសម្លេងរំខាន និងការបំពុលទឹករបស់កម្ពុជាឲ្យទៅជាច្បាប់មួយមានវិសាលភាពទូលំទូលាយជាងមុនដោយគ្របដណ្តប់ការបំពុលបរិស្ថានគ្រប់ទម្រង់។ យើងខ្ញុំសូមលើកទឹកចិត្តនាយកដ្ឋាន EIA និងនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានឲ្យសហការគ្នាបន្ថែមទៀតដើម្បីតម្រឹម និងចែករំលែករបៀបវារៈគ្នាទៅវិញទៅមក។ លើសពីនេះ យើងខ្ញុំសូមជំរុញឲ្យក្រសួងបរិស្ថានអនុញ្ញាតឲ្យសាធារណជនចូលរួមក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់ EIA និងការបំពុលបរិស្ថាន និងដាក់របាយការណ៍ EIA តាមប្រព័ន្ធអ៊ីនធើណិត។ វិធានការទាំងនេះមិនត្រឹមតែធ្វើឲ្យការយល់ដឹងមានភាពប្រសើរឡើងនោះទេ តែវាក៏ស្វាគមន៍ឲ្យមានការចូលរួមពីសំណាក់សាធារណជន និងសហគមន៍ដែលរងផលប៉ះពាល់។

ជាមួយនឹងការមកដល់ថ្មីនៃធនធានរ៉ែ និងប្រេង/ឧស្ម័នក្នុងប្រទេសកម្ពុជា អនុក្រឹត្យបច្ចុប្បន្ន នាឆ្នាំ១៩៩៩ ពាក់ព័ន្ធនឹងគោលការណ៍ណែនាំ EIA មិនបានពន្យល់ឲ្យបានច្បាស់លាស់គ្រប់គ្រាន់ ដើម្បីគ្រប់គ្រងវិស័យថ្មីទាំងពីរនេះឡើយ។ បច្ចុប្បន្ន ក្រសួងបរិស្ថានកំពុងធ្វើការជាមួយដៃគូអភិវឌ្ឍ ក្នុងការបង្កើតគោលការណ៍ណែនាំវិស័យឧស្សាហកម្មនិស្សារណកម្មជាក់លាក់ ដើម្បីជួយឲ្យទីប្រឹក្សាឯករាជ្យ និងក្រុមហ៊ុនរុករករ៉ែរៀបចំរបាយការណ៍ EIA សម្រាប់វិស័យនិស្សារណកម្មធនធានរ៉ែ និងប្រេងកាត។

បន្ថែមលើនេះ រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាបង្កើតក្របខ័ណ្ឌច្បាប់មួយ ដើម្បីធានានូវតម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អក្នុងវិស័យនិស្សារណកម្មធនធានរ៉ែ និងប្រេង/ឧស្ម័ន។ អ្នកពាក់ព័ន្ធទាំងអស់គួរតប្បីចូលរួមក្នុងដំណើរការត្រួតពិនិត្យ ដើម្បីព្រមព្រៀងគ្នាក្នុងទិសដៅល្អបំផុតមួយសម្រាប់វិស័យឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា។

៣. ក្របខ័ណ្ឌស្ថាប័នសម្រាប់វិស័យរ៉ែនៅកម្ពុជា

មាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញនៃកម្ពុជាចែងថា រាល់ធនធានរ៉ែជាសម្បត្តិរដ្ឋក្រោមបទបញ្ញត្តិនៃច្បាប់។ ច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ (២០០១) និងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) គឺជាច្បាប់ពីរដ៏សំខាន់ក្នុងការគ្រប់គ្រងវិស័យឧស្សាហកម្មនិស្សារណកម្ម។ លើសពីនេះទៅទៀត ច្បាប់ដីធ្លី (២០០១) ក៏រំលេចពីឧស្សាហកម្មនិស្សារណកម្មដែរ ព្រោះច្បាប់នេះបានកំណត់ពីលក្ខណៈនៃដីដែលមានរ៉ែ។ បំពេញបន្ថែមលើច្បាប់ខាងលើនេះ យើងក៏នៅមានបទបញ្ញត្តិក្នុងទម្រង់ជាអនុក្រឹត្យ ប្រកាស និងសារាចរដែលបានដាក់ចេញដោយក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលផ្សេងៗ។

ក្តីកង្វល់របស់សង្គមស៊ីវិលអំពីក្របខ័ណ្ឌច្បាប់គ្រប់គ្រងប្រតិបត្តិការរុករករ៉ែនៅកម្ពុជា នៅតែមានដូចគ្នាដដែលក្នុងឯកសារគោលជំហរខែធ្នូ ឆ្នាំ២០០៨ និងខែឧសភា ឆ្នាំ២០១០ ស្តីពីប្រធានបទដូចគ្នានេះ។ កង្វល់ភាគច្រើននៅមិនទាន់បានដោះស្រាយនៅឡើយ។ ឧទាហរណ៍ ឯកសារគោលជំហររបស់យើងខ្ញុំក្នុងឆ្នាំ២០១០ បានផ្តល់អនុសាសន៍ឲ្យរាជរដ្ឋាភិបាលធ្វើវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែដោយប្រកាន់យកបទដ្ឋានអន្តរជាតិជាការអនុវត្តល្អៗ។ ទោះជាយ៉ាងនេះក្តី មិនមានវឌ្ឍនភាពសម្រេចបានក្នុងចំណុចនេះឡើយ។

ខាងក្រោមនេះជាការសរុបនូវក្តីកង្វល់ស្តាប័នសំខាន់ៗដែលសង្គមស៊ីវិលមានចំពោះឧស្សាហកម្មនិស្សារណកម្ម។

ខ្វះការអនុវត្តច្បាប់ដែលមានជាធរមាន

អនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩ បានទាមទារឲ្យមានការរៀបចំ EIA ដែលជាតម្រូវការចាំបាច់ក្នុងការផ្តល់អាជ្ញាប័ណ្ណរុករករ៉ែ។ ទោះជាយ៉ាងនេះក្តី ភស្តុតាងដែលទទួលបាននៅខេត្តបាត់ដំបងបានបង្ហាញថា មិនមានការអនុវត្តតាមលំនាំនេះឲ្យបានតឹងរឹងនៅឡើយទេ ដោយមានក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណដោយមិនបានផ្តល់របាយការណ៍ EIA។ ជាងនេះទៅទៀត មានសហគមន៍មួយចំនួនបានចោទប្រកាន់ថា ក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណរុករករ៉ែពីរឆ្នាំទេ តែបានធ្វើសកម្មភាពអាជីវកម្មរបស់ខ្លួនដោយគ្រាន់តែបន្តអាជ្ញាប័ណ្ណរុករករបស់ខ្លួនសារជាថ្មីម្តងហើយម្តងទៀត។

ការប្តូរទីលំនៅថ្មី និងសំណង

ប្រជាជនកម្ពុជាតាមជនបទភាគច្រើន ជាពិសេសប្រជាជនរស់ក្នុងសហគមន៍ជនជាតិដើមភាគតិច មិនទទួលបានសិទ្ធិកាន់កាប់អចលនទ្រព្យលើដីដែលខ្លួនកំពុងមានទេ ដោយសារតែការសុំសិទ្ធិ/លិខិតស្នាមមានតម្លៃថ្លៃ។ ដូច្នេះ ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណរុករករ៉ែមានសិទ្ធិស្របច្បាប់ក្នុងការបណ្តេញពួកគាត់។ ខណៈដែលសហគមន៍មូលដ្ឋានមួយចំនួនតូចទទួលបានសិទ្ធិកាន់កាប់ដីធ្លីពីឃុំក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដំណើរការផ្តល់លិខិតកាន់កាប់នេះមានភាពយឺតយ៉ាវខ្លាំង បើធៀបទៅនឹងចំនួនអាជ្ញាប័ណ្ណដែលចេញទៅឲ្យក្រុមហ៊ុនរុករករ៉ែនោះ ហើយប្រការនេះមានទំនាក់ទំនងទៅនឹងការបណ្តេញចេញពីលំនៅដ្ឋានដោយមិនមានប្រាក់សំណងនាពេលអនាគត។ សកម្មភាពរុករករ៉ែគួរតែប្តីត្រូវបានគេពន្យាររហូតដល់មានការផ្តល់លិខិតកាន់កាប់ដីធ្លីដល់ប្រជាជនពីឃុំចប់សព្វគ្រប់។

ការទទួលបានព័ត៌មាន

អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩) តម្រូវឲ្យចេញផ្សាយរបាយការណ៍EIA ជាសាធារណៈ។ ប៉ុន្តែ តាមភាពជាក់ស្តែង មិនមែនគ្រប់របាយការណ៍EIA ទាំងអស់សុទ្ធតែត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ។ លើសពីនេះ មិនមែនគ្រប់ឯកសារអាជ្ញាប័ណ្ណទាំងអស់ក៏សុទ្ធតែត្រូវបានផ្សព្វផ្សាយជាសាធារណៈដែរ។ យើងខ្ញុំសូមលើកទឹកចិត្តឲ្យមានការដាក់របាយការណ៍ EIA និងឯកសារផ្តល់អាជ្ញាប័ណ្ណនៅលើគេហទំព័រក្រសួងពាក់ព័ន្ធ ដើម្បីសម្រួលដល់ការទទួលបានព័តមានរបស់សាធារណជន។

យើងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលដែលបានចេញផ្សាយបញ្ជីក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណកាលពីឆ្នាំកន្លងទៅនេះ។ ទោះជាយ៉ាងណា ព័ត៌មានដែលផ្សាយនោះមិនទាន់បានពិស្តារនៅឡើយទេ។ បន្ទាប់ពីមានការធ្វើការប្រឹក្សាជាមួយសាធារណជនមក យើងបានជ្រាបច្បាស់ថា ពិតជាមានការលំបាកក្នុងការស្វែងរក និងទទួលបានព័ត៌មានស្តីពីការចេញអាជ្ញាប័ណ្ណធនធានរ៉ែ។ យើងក៏មិនអាចទទួលបានទិន្នន័យអំពីទីតាំងធនធានរ៉ែដែរ។ យើងសូមជំរុញឲ្យក្រសួងផ្សព្វផ្សាយព័ត៌មានឲ្យបានពិស្តារ ដែលអាចឲ្យសាធារណជនងាយទទួល និងយល់បាន។

ខ្វះការប្រឹក្សាឲ្យបានស៊ីជម្រៅ

បច្ចុប្បន្ន លេខាធិការដ្ឋាននៃបណ្តាញ DPA-EISEI និងសមាជិករបស់ខ្លួនទទួលបានរបាយការណ៍ EIA មួយចំនួន (រៀបចំដោយទីប្រឹក្សាឯករាជ្យ) ពីក្រសួងបរិស្ថាន។ ទោះជាយ៉ាងនេះក្តី រយៈពេលនៃទទួលបានរបាយការណ៍សម្រាប់ផ្តល់យោបល់មានតិចបំផុត(៣-៥ថ្ងៃ) តែប៉ុណ្ណោះ។ ពេលវេលាដ៏តិចតួចនេះធ្វើឲ្យយើងពិបាកផ្តល់ការប្រឹក្សាស៊ីជម្រៅ និងមានប្រសិទ្ធភាពដើម្បីធ្វើឲ្យគុណភាពនៃរបាយការណ៍ EIA មានភាពប្រសើរឡើង។ វានឹងមានប្រសិទ្ធផលជាងនេះ ប្រសិនបើទីប្រឹក្សាឯករាជ្យទាំងនោះអាចចាប់ផ្តើមធ្វើការជាមួយសង្គមស៊ីវិលចាប់តាំងពីដំណើរនៃការរៀបចំរបាយការណ៍ EIA តាំងពីដំបូង ដោយមិនចាំដល់ពេលបញ្ចប់ទើបសហការនោះទេ។

ខ្វះសម្ភាពផ្នែកស្ថាប័ន

កម្ពុជាមានការខ្វះខាតខ្លាំងនូវមន្ត្រីជំនាញ ដែលបានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធផ្នែកផលប៉ះពាល់បរិស្ថានដោយឧស្សាហកម្មនិស្សារណកម្ម។ ទោះបីជាសាកលវិទ្យាល័យក្នុងស្រុកបានចាប់ផ្តើមផ្តល់ការបង្រៀនលើមុខវិជ្ជាភូគព្ភសាស្ត្រ និងបរិស្ថានក៏ដោយ ក៏យើងត្រូវការពេលជាច្រើនឆ្នាំទៀត មុននឹងអាចប្រើប្រាស់ធនធាននិស្សិតទាំងនេះធ្វើការក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មនេះបាន។ ទន្ទឹមគ្នានេះ តម្រូវការបុគ្គលិកក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មមានការកើនឡើងខ្ពស់ក្នុងពេលដែលវិស័យនេះត្រូវបានពង្រីកយ៉ាងលឿន។ បច្ចុប្បន្ននេះ ជនជាតិបរទេស (ជាពិសេសជនជាតិចិន និងវៀតណាម) ត្រូវបានជួលឲ្យកាន់មុខតំណែងជាអ្នកបច្ចេកទេសក្នុងក្រុមហ៊ុនរុករករ៉ែ។ ប្រជាជនមូលដ្ឋានបានត្រឹមតែធ្វើជាពលករសម្រាប់សកម្មភាពរុករករ៉ែក្នុងក្រុមហ៊ុនទាំងនេះ។ ប្រឈមមុខនឹងការកើនឡើងនូវតម្រូវការចំពោះមុខតំណែងជំនាញនេះ យើងសូមផ្តល់មតិយោបល់ឲ្យរដ្ឋាភិបាលរៀបចំផែនការជាមុន ដើម្បីធ្វើឲ្យជនជាតិខ្មែរអាចឆាប់ចូលកាន់តួនាទីជាអ្នកបច្ចេកទេសក្នុងវិស័យឧស្សាហកម្មនិស្សារណកម្មនេះ។

កម្ពុជាបច្ចុប្បន្នក៏ខ្វះនូវកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបណ្តុះបណ្តាលឲ្យប្រជាជនឲ្យចេះរៀបចំរបាយការណ៍ EIA ជាពិសេសសម្រាប់វិស័យរ៉ែ ប្រេង និងឧស្ម័ន។ ដូចនេះ វាមានសារសំខាន់ណាស់សម្រាប់រាជរដ្ឋាភិបាល និងវិស័យអប់រំបង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធានាឲ្យការរៀបចំរបាយការណ៍ EIA មានលក្ខណៈជាអាជីព។ ប្រទេសជិតខាងកម្ពុជាត្រូវបានគេដឹងថា បានបញ្ជូនមន្ត្រីរដ្ឋាភិបាលរបស់ខ្លួនទៅបណ្តុះបណ្តាលនៅបរទេសរួចហើយ។ ការបណ្តុះបណ្តាលបែបនេះក៏មានអត្ថប្រយោជន៍ចំពោះកម្ពុជាផងដែរ។

៤. ករណីសិក្សា

យើងខ្ញុំសូមធ្វើការសង្ខេបករណីសិក្សាចំនួនពីរ ដែលត្រូវបានពិភាក្សាយ៉ាងពិស្តារក្នុងការបោះពុម្ពផ្សាយរបស់អង្គការ DPA ឆ្នាំ២០១១ ក្រោមចំណងជើងថា *និន្នាការបច្ចុប្បន្ននៃផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន ចំពោះការរុករករ៉ែនៅកម្ពុជា* (ឯកសារនេះអាចទទួលបានតាមការស្នើសុំ)។

ករណីសិក្សាទី ១៖ ផលប៉ះពាល់លើជនជាតិដើមភាគតិច៖ ករណីនៅ ពូទឹត ឃុំប៊ូស្រា ខេត្តមណ្ឌលគិរី

ងឹតកុក គឺជាឈ្មោះតំបន់ថ្មធម្មជាតិម៉្យាងនៅភូមិ ពូទឹត ឃុំប៊ូស្រា ស្រុកពេជ្រតា ខេត្តមណ្ឌលគិរី។ ជនជាតិភាគតិចព្នងជឿជាក់ថា តំបន់នេះជាប្រភពដ៏សំខាន់នៃវេទមន្ត និងបានគោរពតំបន់នេះជាជំនឿប្រពៃណីរបស់ពួកគាត់។ ពួកគាត់បានធ្វើការសែនព្រេននៅងឹតកុកតាមរដូវកាល ដើម្បីបួងសួងឲ្យសហគមន៍មានសេចក្តីសុខ មានភ្លៀងគ្រប់គ្រាន់ និងទទួលបានការប្រមូលផលល្អ។

តំបន់ងឹតកុក នេះកំពុងរងការគំរាមកំហែងពីប្រតិបត្តិការរុករករ៉ែរបស់ក្រុមហ៊ុនក្នុងស្រុកមួយដែលមិនមានការព្រមព្រៀងពីសហគមន៍មូលដ្ឋាន។ ករណីសិក្សានេះត្រូវបានធ្វើឡើង ដើម្បីជួយជនជាតិព្នងលើកឡើងពីក្តីកង្វល់របស់ខ្លួនអំពីការធ្វើអាជីវកម្មរ៉ែនៅតំបន់ងឹតកុកនេះ ហើយក៏បានគូសបញ្ជាក់ពីការទទួលខុសត្រូវរបស់មន្ទីររ៉ែ និងថាមពលខេត្ត រាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជនពាក់ព័ន្ធនឹងផលប៉ះពាល់ផ្នែកសង្គម វប្បធម៌ និងបរិស្ថានចេញពីសកម្មភាពរុករករ៉ែ។ ក្នុងកិច្ចសម្ភាសន៍រវាងថ្ងៃទី៦ ដល់ ៩ ខែមិថុនា ឆ្នាំ២០១១ ព្រឹទ្ធាចារ្យចាស់ៗ ក្នុងឃុំប៊ូស្រា បានប្រាប់ DPA-EISEI អំពីការភ័យខ្លាចរបស់ពួកគាត់ ប្រសិនបើតំបន់ងឹតកុកនេះ បន្តរងនូវការរុករករ៉ែបែបនេះ។

ស្ថិតក្រោមសម្មតិកម្មនេះ សកម្មភាពរុករករ៉ែរបស់ឧស្សាហកម្មរ៉ែក្នុងស្រុកដែលមិនមានការត្រួតពិនិត្យនឹងផ្តល់ផលអវិជ្ជមាន យ៉ាងធ្ងន់ធ្ងរលើវប្បធម៌ និងជំនឿរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា នេះបើយោងតាមការស្ទាបស្ទង់មតិរបស់ក្រុម DPA-EISEI នៅតំបន់ងឹតកុកក្នុងឆ្នាំ ២០១១។

គេប្រទះឃើញឧបករណ៍ធ្វើតេស្ត និងខួងដីនៅជិតតំបន់ដែលបានធ្វើការស្ទាបស្ទង់មតិនេះ គឺនៅភាគនិរតីនៃតំបន់នេះ។ យោងតាមអ្នកដែលពាក់ព័ន្ធខាងព្រៃឈើក្នុងតំបន់ គាត់បានប្រាប់ថាក្រុមហ៊ុននោះជាក្រុមហ៊ុនវៀតណាម។ បន្ទាប់មក

បណ្តាញ DPA-EISEI និងសមាជិកក្រុមការងារស្នាបស្នង់មតិបានស្នើសុំព័ត៌មានបន្ថែមពីតំណាងរបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត នៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ ប៉ុន្តែ មិនមានចម្លើយ ដែលប្រការនេះបានបង្ហាញពីការលំបាកក្នុងការទទួលបានព័ត៌មានសុក្រិត និងថ្មីៗស្តីពីសកម្មភាពរុករករ៉ែនៅកម្ពុជា។

ផ្ទុយទៅវិញ គ្រប់ចាស់ព្រឹទ្ធាចារ្យដែលមានវត្តមានក្នុងពេលសម្ភាសន៍យល់ស្របថា ការអភិវឌ្ឍតំបន់អេកូទេសចរណ៍ភ្នំយ៉ាណាង នឹងផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចសហគមន៍ និងជួយអភិរក្សតំបន់ងឹតកុកនេះទៀត។ ដូចនេះ យើងសូមទទូចឲ្យរាជរដ្ឋាភិបាលកម្ពុជាវាយតម្លៃ និងពិចារណាឡើងវិញលើការចេញអាជ្ញាប័ណ្ណដល់ការធ្វើអាជីវកម្មរ៉ែក្នុងតំបន់ងឹតកុកនេះ ពីព្រោះសកម្មភាពរុករករ៉ែអាចបំផ្លាញប្រពៃណីសង្គម វប្បធម៌ និងបរិស្ថាន និងយោគយល់ចំពោះសិទ្ធិរបស់ជនជាតិដើមភាគតិចឲ្យពួកគាត់អាចកាន់កាប់ដី និងរក្សាវប្បធម៌ និងសាសនារបស់ខ្លួន ។

លេខាធិការដ្ឋានបណ្តាញ DPA-EISEI និងក្រុមការងារស្តីពីរ៉ែនៅខេត្តមណ្ឌលគិរីបានលើកបញ្ហាទាំងនេះរាយការណ៍ដល់អភិបាលខេត្ត ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ក៏ដូចជាមន្ទីរពាក់ព័ន្ធក្នុងខែមិថុនា ឆ្នាំ២០១១។ បន្ទាប់មក មន្ទីរក៏បានធ្វើមចុះត្រួតពិនិត្យក្រុមហ៊ុនរ៉ែ ដើម្បីពិភ្សាបញ្ហាទាំងនេះ។ វឌ្ឍនភាពលើបញ្ហានេះកំពុងត្រូវបានធ្វើហើយ។

ករណីសិក្សាទី ២៖ កិច្ចខិតខំប្រឹងប្រែងរបស់ DPA-EISEI និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃដើម្បីបញ្ឈប់ការរុករករ៉ែទីតានីញ៉ូមនៅឃុំជីផាត់ ខេត្តកោះកុង

យូណាយធីតខ្មែរគ្រុប (UKG) គឺជាក្រុមហ៊ុនមួយដែលអនុវត្តសកម្មភាពរុករករ៉ែនៅឃុំជីផាត ខេត្តកោះកុង ដែលជាតំបន់អេកូឡូស៊ីដ៏សំខាន់ក្នុងខេត្តកោះកុង។ បណ្តាញ DPA-EISEI បានសហការជាមួយអង្គការសម្ព័ន្ធមិត្តសត្វព្រៃធ្វើយុទ្ធនាការប្រឆាំងនឹងក្រុមហ៊ុន UKG និងបានគូសបញ្ជាក់ជាច្រើនលើកច្រើនសារអំពីការគំរាមកំហែងមិនត្រឹមតែទៅលើព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប៉ះពាល់ដល់ជីវភាពប្រជាជនចំនួន ៥៥៣ គ្រួសារដែលកំពុងរស់នៅក្នុងឃុំនេះផងដែរ។ ទាំង DPA-EISEI និងសមាជិករបស់ខ្លួន រួមជាមួយនឹងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ បាននិងកំពុងធ្វើការលើកកម្ពស់ការអភិរក្សតំបន់ធម្មជាតិនេះ និងលើកទឹកចិត្តប្រជាជនមូលដ្ឋានឲ្យបង្កើតអាជីវកម្មផ្ទាល់ខ្លួន (ដូចជាអេកូទេសចរណ៍) ដោយប្រើប្រាស់ព្រៃដ៏អស្ចារ្យរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ។

អង្គការទាំងពីរបានចូលរួមជាមួយសហគមន៍មូលដ្ឋានធ្វើសំណើជូនក្រុមហ៊ុន UKG ថា គាត់គួរធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលគ្រប់កម្រិត អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ដើម្បីកាត់បន្ថយផលប៉ះពាល់ និងការបំផ្លាញពីសកម្មភាពធ្វើអាជីវកម្មរ៉ែរបស់ខ្លួន។ យើងបានទទូចសុំក្រុមហ៊ុន UKG ឲ្យសម្របសម្រួល និងធ្វើផែនការសកម្មភាពរុករករ៉ែសិន មុននឹងធ្វើសកម្មភាពកាប់ព្រៃបន្តទៀត។ ជាការឆ្លើយតប ក្រុមហ៊ុនបានសន្យាថានឹងដាំដើមឈើឡើងវិញនៅគ្រប់កន្លែងដែលខ្លួនបានជីក ឬខួងរករ៉ែទីតានីញ៉ូម។ ការដាំកូនឈើឡើងវិញមិនត្រឹមតែអាចជួសជុលការខូចខាតប៉ុណ្ណោះទេ តែវាក៏ចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាពអ្នកភូមិមូលដ្ឋានផងដែរ ព្រោះពួកគាត់នឹងត្រូវបានក្រុមហ៊ុនជួលឲ្យទៅដាំកូនឈើ។

បន្ទាប់ពីអង្គការមិនមែនរដ្ឋាភិបាលបានជម្រាបពីស្ថានភាពនៅឃុំជីផាត ក្រសួងមន្ទីររបស់រាជរដ្ឋាភិបាលបានថ្លឹងថ្លែងពីផលប៉ះពាល់សង្គម និងបរិស្ថានអវិជ្ជមានដែលអាចកើតមានក្នុងតំបន់អភិរក្សនេះធៀបទៅនឹងអត្ថប្រយោជន៍សេដ្ឋកិច្ចដែលទទួលបានពីគម្រោងធ្វើអាជីវកម្មរ៉ែ។ ប្រការនេះបាននាំឲ្យមានការប្រកាសរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ឈប់រាល់សកម្មភាពធ្វើអាជីវកម្ម និងរុករករ៉ែនៅឃុំជីផាត់ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១។ ដោយគ្មានការគំរាមកំហែងពីអាជីវកម្មនិងការរុករករ៉ែ សហគមន៍នានានៅឃុំជីផត បច្ចុប្បន្ននេះ បន្តបង្ហាញខ្លួនជាគំរូក្នុងការអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជា។ ពិតណាស់ នេះជារឿងដ៏ជោគជ័យមួយដែលជាគំរូសម្រាប់ការអនុវត្តនាពេលអនាគត។

៥. អនុសាសន៍

គួរឲ្យសោកស្តាយ វេទិកា CDCF លើកទីបួនត្រូវបានពន្យារពេល។ យើងជឿជាក់ថាវេទិកា CDCF នេះគឺជាមធ្យោបាយមួយដ៏សំខាន់ និងមានលក្ខណៈស្ថាបនា សម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងការកំណត់និងផ្លាស់ប្តូរទស្សនៈលើបញ្ហាចម្បងនានា ហើយយើងសង្ឃឹមថាវេទិកានេះនឹងត្រូវបានរៀបចំក្នុងពេលឆាប់ៗ។

អនុសាសន៍ចំពោះរាជរដ្ឋាភិបាល

ខណៈនេះ យើងជឿជាក់ថា វាមានសារសំខាន់ដែលរាជរដ្ឋាភិបាលគួរគប្បី៖

- ពិភាក្សាលើ JMIs ថ្មីក្នុងវេទិកា CDCF លើកក្រោយ ដែលផ្តោតលើឧស្សាហកម្មនិស្សារណកម្មជាពិសេស
- ពង្រឹងក្របខ័ណ្ឌច្បាប់មានជាធរមានដោយធ្វើឲ្យច្បាប់ពាក់ព័ន្ធមានកម្រិតបទដ្ឋានអន្តរជាតិនៃការអនុវត្តល្អ
- លើកទឹកចិត្តសាធារណជនឲ្យផ្តល់ធាតុចូលផ្សេងៗ ក្នុងសេចក្តីព្រាងច្បាប់ និងគោលនយោបាយស្តីពីឧស្សាហកម្មនិស្សារណកម្ម
- ធ្វើការត្រួតពិនិត្យឡើងវិញនូវច្បាប់ជាធរមាន ដើម្បីបង្ការការផ្តល់អាជ្ញាប័ណ្ណជាន់គ្នាសម្រាប់ប្រភេទនៃសកម្មភាពរុករករ៉ែផ្សេងគ្នានៅក្នុងតំបន់តែមួយ។
- ផ្តួចផ្តើមឲ្យមានការត្រួតពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រង និងធ្វើអាជីវកម្មធនធានរ៉ែ ដោយមានការប្រឹក្សាយ៉ាងជិតស្និទ្ធជាមួយផ្នែកផ្សេងៗនៃសង្គមដែលរងផលប៉ះពាល់ ដើម្បីធានាដល់ការការពារប្រជាជន និងបរិស្ថានប្រកបដោយប្រសិទ្ធភាពខ្ពស់អនុលោមតាមបទដ្ឋានអនុវត្តល្អៗរបស់អន្តរជាតិក្នុងវិស័យរ៉ែនេះ។

ក្នុងរយៈពេលវែង ប្រជាជាតិយើងនឹងប្រសើរជាងមុន ប្រសិនបើយើង៖

- រៀបចំផែនការបណ្តុះបណ្តាលប្រជាជនឲ្យមានលទ្ធភាពចាប់យកមុខតំណែងបច្ចេកទេស ក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម។ ការបណ្តុះបណ្តាលនោះគួរតែរួមមានការសិក្សាក្នុងថ្នាក់ និងអនុវត្តផ្ទាល់នៅមូលដ្ឋាន។ រាជរដ្ឋាភិបាលគួរតម្រូវឲ្យក្រុមហ៊ុនអនុញ្ញាតឲ្យមានការបណ្តុះបណ្តាលក្នុងពេលបំពេញការងារ និងមានចែងក្នុងកិច្ចសន្យារវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុន។
- កសាងកម្មវិធីស្តង់ដារ ដើម្បីជួយរៀបចំរបាយការណ៍ EIA ប្រកបដោយវិជ្ជាជីវៈ
- ធ្វើយ៉ាងណាឲ្យមានព័ត៌មានជាស្រេច អនុញ្ញាតឲ្យសាធារណជនយល់ដឹង ដូចជាការដាក់លើប្រព័ន្ធអ៊ីនធើណិតជាដើម។

អនុសាសន៍ចំពោះដៃគូអភិវឌ្ឍន៍

- ដៃគូអភិវឌ្ឍន៍មកពីប្រទេសដូចគ្នានឹងក្រុមហ៊ុនដែលមានវត្តមានក្នុងប្រទេសកម្ពុជា គួរគប្បីធ្វើការងារជាមួយរដ្ឋាភិបាលរបស់ខ្លួន និងក្រុមហ៊ុនទាំងនោះ ដើម្បីធានាថា ក្រុមហ៊ុនធ្វើប្រតិបត្តិការអនុលោមតាមបទដ្ឋាននៃការអនុវត្តល្អៗអន្តរជាតិ
- ជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការរៀបចំបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងវិស័យឧស្សាហកម្មនិស្សារណកម្ម។

អនុសាសន៍សម្រាប់ក្រុមហ៊ុនរុករក ធ្វើអាជីវកម្មរ៉ែ

- បណ្តុះបណ្តាលគ្រប់បុគ្គលិកសន្តិសុខយោងតាមគោលការណ៍ស្មគ្រចិត្តរបស់ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិកស្តីពីសន្តិសុខ និងសិទ្ធិមនុស្ស។ ចៀសវាងការជួលទាហានក្នុងកងយុទ្ធពលខេមរភូមិន្ទឲ្យធ្វើជាសន្តិសុខ។

- បង្កើតកម្មវិធីអប់រំ និងផែនការបណ្តុះបណ្តាល (ព្រមជាមួយនឹងពេលវេលាអនុវត្តដែលបានកំណត់) សម្រាប់បុគ្គលិកក្នុងស្រុក ដើម្បីធានាថានិយោជិកក្នុងស្រុកអាចធ្វើការក្នុងមុខតំណែងបច្ចេកទេស។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមស្តីពីបញ្ហាលើកឡើងក្នុងឯកសារនេះ សូមទាក់ទង៖

អង្គការអភិវឌ្ឍ និងភាពជាដៃគូក្នុងសកម្មភាព(DPA)
បណ្តាញផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានក្នុងឧស្សាហកម្ម និស្សារណកម្ម (EISEI)
លោក ម៉ម សម្បត្តិ នាយកប្រតិបត្តិនៃ DPA និងជាប្រធានគណកម្មការអចិន្ត្រៃយ៍បណ្តាញ EISEI
ទូរស័ព្ទ៖ (855-23) 216 369/216 495
អ៊ីម៉ែល៖ mam.sambath@dpacam.org
អាសយដ្ឋាន៖ ផ្ទះលេខ ៦៩Z ផ្លូវ ៤៥0 ក្រុងភ្នំពេញ
លោក ធី ទ្រី អ្នកសម្របសម្រួលលេខាធិការដ្ឋានបណ្តាញ DPA-EISEI
ទូរស័ព្ទ៖ (855-16) 210 006
អ៊ីម៉ែល៖ eiseicoordinator@gmail.com

វិស័យជលផល

១. ទស្សនៈទូទៅ

បណ្តាឆ្នាំថ្មីៗនេះ គឺជារយៈពេលដ៏លំបាកសម្រាប់សហគមន៍នេសាទ។ អ្នកនេសាទ និងគ្រួសារអ្នកនេសាទក្រីក្រ បន្តជួបការលំបាកដ៏ធំធេង ដែលជាផលវិបាកនៃតម្លៃស្បៀងអាហារដ៏ខ្ពស់ និងការធ្លាក់ចុះសេដ្ឋកិច្ច។ ដោយសារតែគ្មានដី និងមានដីតិចតួច គ្រួសារអ្នកនេសាទពឹងផ្អែកច្រើនលើការនេសាទ។ ការរួមចំណែកខាងអាហារូបត្ថម្ភនៃសេដ្ឋកិច្ច ដោយផ្អែកលើធនធានជលផលនៃប្រទេសកម្ពុជា ត្រូវបានគេទទួលស្គាល់តិចតួច។ អង្គការសង្គមស៊ីវិល (CSOs) តាមរយៈក្រុមការងារបច្ចេកទេសស្តីពីជលផល (TWGF) គប្បីខិតខំធានាឲ្យបានថាវិស័យជលផលទទួលបានការទទួលស្គាល់ដ៏ពេញលេញនៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាល (NGOs) ក្នុងវិស័យជលផល ដៃគូអភិវឌ្ឍន៍ និងស្ថាប័នរាជរដ្ឋាភិបាល កំពុងធ្វើការរួមគ្នាដើម្បីអភិវឌ្ឍ និងរក្សាយន្តការនានា ដែលទ្រទ្រង់ជលផលប្រកបដោយនិរន្តរភាព និង ការរួមចំណែកនៃវិស័យនេះ ដល់សន្តិសុខស្បៀង និង ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ប្រកបដោយនិរន្តរភាព និងជីវភាពពាក់ព័ន្ធ គឺជាគន្លឹះចំពោះសន្តិសុខស្បៀងជាតិនៃប្រទេសកម្ពុជា។

អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) រួមជាមួយសមាជិកបណ្តាញអង្គការមិនមែនរដ្ឋាភិបាលធ្វើការដោយផ្ទាល់ជាមួយអ្នកនេសាទកម្ពុជា និងសហគមន៍របស់ពួកគេ ដើម្បីធានាឲ្យបានថាសម្លេងរបស់ពួកគេអំពីការសម្រេចចិត្តសំខាន់ៗស្តីពីជលផលដែលប៉ះពាល់បរិស្ថាននិងជីវភាពរបស់ពួកគេ ត្រូវបានគេដឹងនិងស្តាប់ឮ។ អង្គការ FACT និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ បានយកចិត្តទុកដាក់លើកិច្ចដំណើរការនៃការអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ (SPF) រយៈពេល១០ឆ្នាំ ដោយទទួលស្គាល់យ៉ាងពេញលេញនូវសិទ្ធរបស់អ្នកនេសាទ និង ការចូលរួមរបស់អ្នកនេសាទ និងឫតំណាងស្របច្បាប់របស់ពួកគេ។ អង្គការ FACT នឹងធ្វើការសហការគ្នាជាមួយរដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល សាមីស្ថាប័ន ក្រសួងដទៃទៀត និង ផ្នែកឯកជន ដើម្បីអភិវឌ្ឍ ជលវប្បកម្មប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍របស់ប្រជាជនកម្ពុជាគ្រប់រូប។

២. សូចនាករតាមដានរួម

ចំណុចដៅ	សកម្មភាព៖ សកម្មភាពរង្វាស់	ស្ថាប័នរាជរដ្ឋាភិបាលដែលទទួលបន្ទុក
ផែនការវិស័យជលផលសម្រាប់គាំទ្រ សន្តិសុខស្បៀង ជីវភាពរស់នៅ និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច ត្រូវបាន ធ្វើឲ្យល្អប្រសើរឡើង	១. ប្រែសម្រួលសេចក្តីព្រាងបញ្ជាប់នៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំ របស់វិស័យជលផលជាភាសាខ្មែរ នៅដំណាច់ត្រីមាសទី២ ឆ្នាំ២០១០ ហើយ អនុម័តនាដំណាច់ត្រីមាសទី៤ ឆ្នាំ ២០១០។ ២. អនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់រាជ រដ្ឋាភិបាលជលផលថ្នាក់កណ្តាលដោយផ្អែកទៅនឹងចំណុចគោលដៅនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ រយៈពេល ១០ ឆ្នាំនៅដំណាច់ត្រីមាសទី៣ ឆ្នាំ២០១១។ ៣. រៀបចំដំណើរការធ្វើការកសាងផែនការខណ្ឌរដ្ឋបាលជលផលដោយស្របទៅនឹងចំណុចដៅនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ វិស័យជលផលរយៈពេល ១០ ឆ្នាំ និង កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយអនុវត្ត នៅខណ្ឌរដ្ឋបាលជលផលក្នុងខេត្តចំនួន៤ មុនដំណាច់ត្រីមាសទី៤ ឆ្នាំ២០១០។	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

មតិយោបល់លើសកម្មភាពទី ៣ នៃសូចនាករតាមជានរួម៖

"រៀបចំដំណើរការធ្វើការកសាងផែនការខណ្ឌរដ្ឋបាលជលផល ដោយស្របទៅនឹងចំណុចដៅនៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ វិស័យជលផលរយៈពេល ១០ ឆ្នាំ និង កម្មវិធីជាតិស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយអនុវត្តនៅខណ្ឌរដ្ឋបាលជលផលចំនួន៤ខេត្ត មុនដំណាច់ត្រីមាសទី៤ ឆ្នាំ២០១០។"

ការធ្វើផែនការជលផលថ្នាក់ក្រោមជាតិ ជាទូទៅ នៅមិនទាន់បានអនុវត្តបានល្អនៅឡើយ ដោយសារវាមិនត្រូវបានដាក់បញ្ចូលជាមួយអាទិភាពរបស់ឃុំ និងស្រុក។ កង្វះធនធានគឺជាមូលហេតុដ៏សំខាន់មួយ ប៉ុន្តែ បញ្ហាប្រឈមមួយទៀត គឺភាពមិនចំណុះរបស់រដ្ឋបាលជលផលខេត្ត ដោយសារជួនកាលពួកគេមិនទាន់សហការជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ឧទាហរណ៍ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមានបំណងបញ្ឈប់សកម្មភាពនេសាទខុសច្បាប់។ បើគ្មានកិច្ចសហប្រតិបត្តិការល្អរវាងអាជ្ញាធរនៅថ្នាក់ក្រោមជាតិ អាទិភាពទាំងឡាយរបស់ប្រជាពលរដ្ឋមូលដ្ឋាន នឹងមិនត្រូវបានបំពេញឡើយ។ ម្យ៉ាងទៀត កង្វះកិច្ចសហប្រតិបត្តិការបែបនេះ ធ្វើឲ្យខូចខាតដល់គោលដៅនៃការធានាជលផលប្រកបដោយនិរន្តរភាពនៅក្នុងដែនទឹកកម្ពុជា។

បញ្ហានេះ គឺពាក់ព័ន្ធនឹងសមត្ថភាពទាំងរបស់រដ្ឋបាលជលផលថ្នាក់ខេត្តផង និងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលដែលមិនមែនសុទ្ធតែដឹង អំពីកិច្ចដំណើរការវិមជ្ឈការ និងតួនាទីនិងការទទួលខុសត្រូវរបស់ពួកគេផ្ទាល់ឡើយ។ លើសពីនេះទៀត ជួនកាលសមាជិកក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមិនដឹងថាពួកគេអាចចូលរួមក្នុងបញ្ហាជលផល ដោយសារពួកគេអាចនៅតែយល់ថាបញ្ហាបែបនេះគឺសម្រាប់តែរដ្ឋបាលជលផលប៉ុណ្ណោះ។

អនុសាសន៍ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា៖

- ផ្សព្វផ្សាយក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល៖ ឆ្នាំ ២០១០-២០១៩ (SPF) ជូនសមាជិកក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីជម្រុញឲ្យពួកគេចូលរួមក្នុងការធានាឲ្យបាននូវការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព។
- ផ្សព្វផ្សាយកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជូនដល់រដ្ឋបាលជលផល ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។
- រិះរកវិធីតម្លើងប្រាក់ខែរបស់មន្ត្រីរាជការ ដើម្បីកាត់បន្ថយហានិភ័យនៃឥរិយាបថពុករលួយ។
- ពាក់ព័ន្ធក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនិងអង្គការសង្គមស៊ីវិលក្នុងភាពជាដៃគូដ៏ពេញលេញ ដើម្បីអនុវត្តក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

៣. សកម្មភាព/យុទ្ធសាស្ត្រសំខាន់ៗពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣

ផ្នែក	សារ
១០១	សមិទ្ធិផលគួរឲ្យកត់សម្គាល់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រេចបាន រួមមាន៖ ក្នុងការបង្កើនផ្ទៃដីដាំដុះដំណាំកសិកម្ម ផ្ទៃដីដាំដុះស្រូវ ទិន្នផលក្នុងមួយហិកតា តំបន់ឡូត៍នេសាទ និងតំបន់ឡូត៍នេសាទសម្រាប់តំបន់សហគមន៍នេសាទ ផលនេសាទ (ពីគ្រប់ប្រភព) ផ្ទៃដីគ្រប់ដណ្តប់ដោយព្រៃឈើ និងភាគរយនៃផ្ទៃដីដាំ ដែលបានដាំដុះព្រៃឈើឡើងវិញ។
១១៩	ច្បាប់ស្តីពីជលផល ត្រូវបានប្រកាសឲ្យប្រើ កាលពីខែឧសភា ឆ្នាំ២០០៦។ ចាប់តាំងពីមានកំណែទម្រង់វិស័យជលផលមក ការអភិវឌ្ឍវិស័យជលផល ត្រូវបានបោះជំហានយ៉ាងខ្លាំង ដោយត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើប្រជាជនក្រីក្រ។
១១៩	ផែនការទាំងនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើក្រមប្រតិបត្តិសម្រាប់នេសាទ ប្រកបដោយការទទួលខុសត្រូវសម្រាប់វិស័យជលផលកម្ពុជា "កាំកូដ"។ ចាប់តាំងពីមានកំណែទម្រង់ឡូត៍នេសាទមក មានសហគមន៍នេសាទចំនួន៤៦៩ ត្រូវបានរៀបចំឡើង (ទឹកសាប៤៣៤ និងសមុទ្រ៣៥) ហើយក្នុងនោះសហគមន៍នេសាទ

	ចំនួន ១៧៣ ត្រូវបានចុះបញ្ជីជាផ្លូវការកាលពីខែតុលា ឆ្នាំ២០០៨ កន្លងទៅនេះ។
៤១៧	រាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តនូវសកម្មភាពយ៉ាងម៉ឺងម៉ាត់ប្រឆាំងនឹងទប់ស្កាត់បទល្មើស កាប់បំផ្លាញការព្រៃលិចទឹក ការធ្វើនេសាទខុសច្បាប់ និងទប់ស្កាត់រាល់សកម្មភាពអនាធិបតេយ្យគ្រប់ប្រភេទដែលប៉ះពាល់ដល់កិច្ចប្រឹងប្រែងខិតខំអភិរក្ស តាមរយៈការលើកទឹកចិត្តឲ្យមានការចូលរួមពីសមត្ថកិច្ចដែលពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

វឌ្ឍនភាពដែលបានតាមដាន / ការវិភាគលើស្នាដៃអនុវត្ត

ភស្តុតាងនៃចំណុចខ្វះខាត/ការមិនគោរពតាម/សកម្មភាព

១០១៖ វឌ្ឍនភាពគួរឲ្យកត់សម្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គេឃើញមានវឌ្ឍនភាពខ្លះក្នុងបណ្តាឆ្នាំថ្មីៗនេះ ក្នុងទម្រង់ជាការបំផ្លាញអាងស្តុកទឹកខុសច្បាប់ និងការលុបចោលឡូត៍នេសាទ។ ប៉ុន្តែ គេនៅតែគប្បីគូសបង្ហាញបញ្ហាប្រឈមមួយចំនួនក្នុងវិស័យជលផល ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៩-២០១៣៖

- វិស័យជលផលកំពុងតែត្រូវបានគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរតាមរយៈការបំផ្លាញព្រៃលិចទឹក ការឆ្ការព្រៃ ដើម្បីកម្មសិទ្ធិដីដោយប្រជាជនធម្មតាផងនិងអ្នកមានអំណាចផង ដែលតម្រូវឲ្យមានអន្តរាគមន៍ទាន់ពេលនិងប្រកបដោយប្រសិទ្ធភាពពីរាជរដ្ឋាភិបាល។
- កង្វះធនធានសម្រាប់បំពេញមុខងាររបស់ខ្លួន៖ មធ្យោបាយដឹកជញ្ជូន បរិក្ខារ ថវិកា និងប្រេងសាំងសម្រាប់ការងារគ្រប់គ្រង ការស្រាវជ្រាវ និងការសិក្សា ដើម្បីអភិវឌ្ឍនិងអភិរក្សធនធានជលផល។
- ការនេសាទដោយប្រើឧបករណ៍ឆក់ មុងវែង និងការបំផ្លាញកន្លែងត្រីពងកូននៅក្នុងព្រៃលិចទឹក នៅតែកើតមាន។

នៅចុងឆ្នាំ ២០១១ បញ្ហាប្រឈមទាំងនេះនៅតែមាន ហើយគេឃើញមានភាពចាំបាច់បន្ទាន់មួយដែលត្រូវចាត់វិធានការដើម្បីកែលម្អស្ថានភាពនេះ។

១១៩៖ ច្បាប់ជលផល

ថ្វីបើមានភាពប្រសើរឡើងខ្លះៗនៅពេលថ្មីៗនេះ ចំពោះការផ្តល់ឡូត៍នេសាទ និងការការពារតំបន់ខ្លះនៃព្រៃលិចទឹក ប៉ុន្តែ គេនៅតែឃើញមានភាពចាំបាច់បន្ទាន់ដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើនកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយការនេសាទខុសច្បាប់នៅកម្រិតអប្បបរមា និងត្រូវការពារព្រៃលិចទឹក ព្រៃកោងកាង និងតំបន់មានរុក្ខជាតិសមុទ្រ ដែលជាជម្រកត្រីដ៏សំខាន់សម្រាប់បង្កើនជីវភាពរបស់អ្នកនេសាទក្រីក្រ។

១១៩៖ សហគមន៍នេសាទ

ក្នុងចំណោម សហគមន៍នេសាទទាំង ៤៦៩ ដែលត្រូវបានបង្កើត សហគមន៍នេសាទមួយចំនួនធំនៅមិនទាន់បានចុះបញ្ជីស្របច្បាប់នៅឡើយ ហើយសហគមន៍នេសាទជាច្រើនមិនមានថវិកាគ្រប់គ្រាន់ ដើម្បីអនុវត្តសកម្មភាព យ៉ាមល្អាត ឬរៀបចំកិច្ចប្រជុំទៀងទាត់ឡើយ។

៤១៧៖ ការចូលរួមពីអាជ្ញាធរមានសមត្ថកិច្ចក្នុងមូលដ្ឋាន

ការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការលើកទឹកចិត្តឲ្យមានការចូលរួមពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចក្នុងមូលដ្ឋាន ត្រូវបានស្វាគមន៍យ៉ាងខ្ពស់។ ប៉ុន្តែការសង្កេតបច្ចុប្បន្នបង្ហាញថារដ្ឋបាលជលផល ច្រើនតែយល់ថាជលផលគឺជាការងាររបស់ខ្លួន ហើយដោយហេតុនេះ ពួកគេមិនបានរាប់បញ្ចូលភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀតក្នុងមូលដ្ឋាននៅក្នុងកិច្ច

ប្រឹងប្រែង ដើម្បីធានាឲ្យបាននូវការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងការពិចារណាអំពីសេចក្តីត្រូវការនិងកង្វល់របស់អ្នកនេសាទតូចតាច។ អាស្រ័យហេតុនេះ គេនៅតែឃើញមានភាពចាំបាច់បន្ទាន់នៃកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើងនៅក្នុងចំណោម អាជ្ញាធរនិងសាមីស្តាប័នថ្នាក់ក្រោមជាតិ ក៏ដូចជាការរាប់បញ្ចូលនិងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល។

អនុសាសន៍ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា

សូមផ្តល់អនុសាសន៍ ឲ្យរដ្ឋបាលជលផលបង្កើនកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធផ្សេងទៀត នៅក្នុងកិច្ចប្រឹងប្រែងរបស់ពួកគេក្នុងការទប់ស្កាត់និងបង្ក្រាបការទន្ទ្រានយកដីព្រៃលិចទឹក។ ធានាឲ្យបានថាគោលនយោបាយជលផលរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្លុះបញ្ចាំងសកម្មភាពច្បាស់លាស់ ដើម្បីជួយអ្នកនេសាទក្នុងការអភិវឌ្ឍន៍ជីវភាពប្រកបដោយនិរន្តរភាព និងជម្រុញការអភិរក្សចម្រុះប្រកបដោយប្រសិទ្ធភាព និងធ្វើផែនការអភិវឌ្ឍន៍ដែលរួមចំណែកដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ។

៤. បញ្ហាសំខាន់ៗដែលមិនត្រូវបានដាក់បញ្ចូលក្នុងសូចនាករតាមដានរួម ឬផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម

ផែនការគ្រប់គ្រងជាក់ស្តែងនិងប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវអភិវឌ្ឍដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវស្ថានភាពសង្គមនិងអេកូឡូស៊ី ដែលត្រូវបានរកឃើញនៅក្នុងបឹងទន្លេសាប។ ដំណោះស្រាយលើការងារគ្រប់គ្រង ត្រូវតែត្រូវបានបង្កើតឡើងដោយមានការចូលរួមដ៏ពេញលេញ និងប្រកបដោយប្រសិទ្ធភាពពីសំណាក់អ្នកប្រើប្រាស់ក្នុងមូលដ្ឋាន។ វេទិកាចូលរួមគឺជាការចាំបាច់ផ្តល់នូវយន្តការមួយ ដើម្បីជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងការអភិរក្សនិងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព តាងនាមឲ្យប្រជាពលរដ្ឋទាំងអស់។

បន្ថែមលើបញ្ហាប្រឈមទាំងឡាយដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៩-២០១៣ បញ្ហាប្រឈមផ្សេងទៀតដែលត្រូវបានកំណត់ដោយអង្គការសង្គមស៊ីវិលនៅក្នុងវិស័យជលផល រួមមាន៖

- កង្វះកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងសាមីស្តាប័ន (ជាពិសេស រដ្ឋបាលជលផល) ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ក្នុងការគ្រប់គ្រងធនធានជលផល នៅតែស្ថិតជាបញ្ហាមួយដែលរារាំងដល់ឥទ្ធិពលវិជ្ជមានរួមនៅក្នុងវិស័យជលផល។
- ក្រៅពីឆ្នាំនេះ (២០១១) នៅពេលដែលឡូត៍នេសាទត្រូវបានបញ្ចេញ និងមានគ្រោះទឹកជំនន់ធំ សហគមន៍នេសាទកំពុងជួបប្រទះនូវការថយចុះផលនេសាទតាមគ្រួសារ ហើយគ្រួសារនេសាទអាជីពជាច្រើនទៀត ដូចជាសហគមន៍អណ្តែតទឹកជាដើម ជួបប្រទះអសន្តិសុខស្បៀង។
- សហគមន៍នេសាទ សមត្ថភាពនៅមានកម្រិត និងខ្វះធនធានសម្រាប់គ្រប់គ្រងតំបន់សហគមន៍របស់ខ្លួន។ ការបង្កើនការជួយគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជាចំពោះការគ្រប់គ្រងសហគមន៍នេសាទ គឺមានការចាំបាច់។
- ការបាត់បង់ជម្រកមច្ឆាជាតិ ដូចជាព្រៃលិចទឹក ព្រៃកោងកាង និងតំបន់មានរុក្ខជាតិសមុទ្រ ដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍នានា គឺជាការគម្រាមកំហែងមួយចំពោះនិរន្តរភាពនៃធនធានធម្មជាតិ និងជីវភាពរបស់អ្នកនេសាទ។
- ការប្រែប្រួលកម្ពស់ទឹកនៃទន្លេមេគង្គ និងបឹងទន្លេសាប ដោយសារអាងស្តុកទឹក និងការអភិវឌ្ឍវារីអគ្គិសនី គឺជាសក្តានុពលហានិភ័យមួយដែលមានវិសាលភាពធំធេង ដែលចាំបាច់ត្រូវដោះស្រាយដោយរាជរដ្ឋាភិបាលថ្នាក់កំពូលដោយសារចរឹតលក្ខណៈអន្តរជាតិរបស់វា។ ប្រសិនបើទំនប់ត្រូវបានសាងសង់នៅលើទន្លេមេគង្គក្រោម វាអាចមានហេតុប៉ះពាល់អវិជ្ជមានដ៏ធ្ងន់ធ្ងរលើធនធានជលផល និងសន្តិសុខស្បៀងនៃប្រទេសកម្ពុជា។

ចំពោះការគ្រប់គ្រងធនធានជលផលនៅកម្ពុជា វាគឺជាប្រការសមហេតុផលដែលចំណុចសំខាន់ៗខាងក្រោមត្រូវប្រកាន់យក៖

- ច្បាប់ជលផលថ្មីត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ក្នុងលក្ខណៈមានតម្លាភាព និងគណនេយ្យភាព។
- ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងលទ្ធភាពស្មើភាពក្នុងការប្រើប្រាស់ធនធានជលផល ត្រូវបានធានា។
- ការគ្រប់គ្រងធនធានជលផល ត្រូវបានសំដៅលើជីវភាពរបស់អ្នកនេសាទ និងការគោរពសិទ្ធិមនុស្ស។
- ការចូលរួមរបស់អ្នកនេសាទ នៅក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍជលផល ត្រូវបានលើកកំពស់។
- ការគ្រប់គ្រងធនធានជលផល ដោយអនុវត្តតាមគោលនយោបាយវិមជ្ឈការ។
- រាជរដ្ឋាភិបាលធានាឲ្យបានថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ត្រូវបានធ្វើមុនពេលអនុម័តគម្រោងអភិវឌ្ឍនណាមួយ នៅក្នុង ឬនៅជិតដែនទឹកកម្ពុជា។
- សន្ធិសញ្ញាអន្តរជាតិទាំងអស់ដែលចុះហត្ថលេខាដោយរាជរដ្ឋាភិបាលកម្ពុជា និងដែលទាក់ទិនទៅនឹងការគ្រប់គ្រងនិងការអភិវឌ្ឍន៍ធនធានជលផល ត្រូវបានគោរព និងអនុវត្ត។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល – FACT
លោក ឱម សាវ៉ាត នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥-២៣) ៩៩២ ០៤៤
ទូរសារ៖ (៨៥៥-២៣) ៩៩២ ០៤៤
អ៊ីម៉ែល៖ savath@fact.org.kh / fact@online.com.kh
គេហទំព័រ៖ www.fact.org.kh
អាសយដ្ឋាន៖ ផ្ទះលេខ ២១៥ ផ្លូវលេខ ១៥០ សង្កាត់ទឹកល្អក់ ២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

កិច្ចការពារ ការអភិរក្សបរិស្ថាន និងការប្រែប្រួលអាកាសធាតុ

១. សេចក្តីផ្តើម

បណ្តាញវេទិកាបរិស្ថានរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គឺជាបណ្តាញអង្គការជាតិ និងអន្តរជាតិ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ មានសមាជិកសរុប ៤០ អង្គការ ។ បណ្តាញនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីសហការគ្នាក្នុងការចូលរួមចំណែកផ្តល់មតិយោបល់ទៅលើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលពាក់ព័ន្ធនឹងវិស័យបរិស្ថាន ជាពិសេសការប្រែប្រួលអាកាសធាតុ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គមឲ្យបានកាន់តែប្រសើរឡើង។

ព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងប្រែក្លាយមកជាប្រទេសដែលកំពុងអភិវឌ្ឍន៍លើផ្នែកសេដ្ឋកិច្ច និងសង្គមស្ទើរគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ គមនាគមន៍ ទូរគមនាគមន៍ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធនានា។ ទោះជាយ៉ាងនេះក្តី បញ្ហាបរិស្ថាន បន្តកើតមានឡើង ដូចជា ការទន្ទ្រានដីព្រៃឈើធ្វើជាកម្មសិទ្ធិ ការធ្វើអាជីវកម្មសត្វព្រៃ ការចោលសំណល់រឹង/រាវតាមទីសាធារណៈ ការចាក់ដីលប់បំពេញមាត់ឆ្នេរ បឹង អូរធម្មជាតិ និងការកាប់បំផ្លាញព្រៃលិចទឹក ពិសេសព្រៃកោងកាង និងព្រៃលិចទឹកតាមមាត់បឹងទន្លេសាប។ល។[54]

សហគមន៍អន្តរជាតិទទួលស្គាល់ថា កម្ពុជាជាប្រទេសដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដោយសារចំណេះដឹង ធនធានបច្ចេកវិទ្យា និងសមត្ថភាពបន្សាំនៅមានកម្រិតទាបនៅឡើយ។ ដោយសារមូលហេតុនេះ រាជរដ្ឋាភិបាលកម្ពុជា បានចំណាយថវិកាជាតិអស់យ៉ាងសន្ធឹកសន្ធាប់សម្រាប់ស្តារហេដ្ឋារចនាសម្ព័ន្ធ និងជួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះពីទឹកជំនន់។

យោងតាមរបាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០១១ របស់ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) បានបង្ហាញថា សីតុណ្ហភាពនៅក្នុងប្រទេសកម្ពុជាកំពុងតែកើនឡើង និងបន្តកើនឡើង របបទឹកភ្លៀងមានការប្រែប្រួលយ៉ាងខ្លាំង ដែលមានភ្លៀងធ្លាក់ខ្លាំងក្នុងរយៈពេលខ្លីជាងមុន រដូវប្រាំងកាន់តែរាំងស្ងួតជាងមុន និងមានរយៈពេលវែងជាងមុន ទឹកជំនន់និងភាពរាំងស្ងួតធ្ងន់ធ្ងរកើតមានកាន់តែញឹកញាប់ ហើយកម្តស់ទឹកសមុទ្របានកើនឡើង។ ជាអកុសល ពុំទាន់មានវិទ្យាសាស្ត្រណាមួយព្យាករណ៍ឲ្យបានជាក់លាក់ថា តើបញ្ហាការប្រែប្រួលអាកាសធាតុនឹងមានឥទ្ធិពលយ៉ាងណានោះទេ នាពេលអនាគត។

ដូច្នេះ ផែនការអភិវឌ្ឍន៍ជាតិចាំបាច់ត្រូវមានការចូលរួមពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ដើម្បីកំណត់នូវតំរូវការពិតប្រាកដ និងស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ ដើម្បីឈានទៅសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងខិតខំប្រឹងប្រែងក្នុងការស្វែងរកដំណោះស្រាយលើបញ្ហាការប្រែប្រួលអាកាសធាតុនេះ ដោយបានបង្កើតជាគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ដែលមានក្រសួងបរិស្ថានជាស្ថាប័នបង្គោលជាតិ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក៏បានបង្កើតកម្មវិធីសកម្មភាពជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NAPA) ផងដែរ ប៉ុន្តែ ថវិកាសម្រាប់ការអនុវត្តផែនការនេះមិនមានគ្រប់គ្រាន់ទេ។

២. សូចនាករតាមដានរួម

យោងតាមសូចនាករតាមដានរួម (JMI) ផ្នែកព្រៃឈើ និងបរិស្ថាន យើងខ្ញុំសង្កេតឃើញថា របាយការណ៍បានផ្តោតសំខាន់តែលើវិស័យព្រៃឈើ ដោយពុំបានដាក់បញ្ចូលផែនការដែលដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅកម្ពុជានោះទេ ខណៈដែលក្រសួងបរិស្ថាន បាន និងកំពុងខិតខំប្រឹងប្រែងក្នុងការសំរបសំរួលលើបញ្ហាទាំងពីរនេះទាំងថ្នាក់ជាតិ និង

[54] របាយការណ៍វឌ្ឍនភាពរបស់ក្រសួងបរិស្ថានឆ្នាំ២០១០ និងផែនការប្រចាំឆ្នាំ២០១១

អន្តរជាតិ។ អង្គការមិនមែនរដ្ឋាភិបាល សូមសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជា រៀបចំដាក់បញ្ចូលនូវសូចនាករតាមដានរួមដោយឡែកមួយបន្ថែមទៀត ដែលផ្តោតសំខាន់តែលើការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ដើម្បីងាយស្រួលក្នុងវាយតម្លៃការងាររបស់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធនឹងបញ្ហានេះ។

៣. សកម្មភាព និងយុទ្ធសាស្ត្រសំខាន់ៗក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជាជាគោលនយោបាយ និងសកម្មភាពអាទិភាពពាក់ព័ន្ធនឹងកិច្ចការពារ ការអភិរក្សបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ សកម្មភាព និងយុទ្ធសាស្ត្រសំខាន់ៗទាំងនេះ មានដូចខាងក្រោម៖

ចំនុច	ខ្លឹមសារ
៤២៦	ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ក្រសួងបរិស្ថាននឹងអនុវត្តសកម្មភាពដូចខាងក្រោម៖ - ធានាការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ហើយអនុវត្តនូវវិធានការនានាដែលតម្រូវឲ្យមានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើគម្រោងអភិវឌ្ឍន៍នានាដែលបានស្នើឡើង មុននឹងមានការអនុញ្ញាតឲ្យអនុវត្តនូវគម្រោងទាំងនោះ។
៤២៧	ក្រសួងបរិស្ថាននឹងរៀបចំលិខិតបទដ្ឋាន និងឯកសារច្បាប់មួយចំនួនដូចខាងក្រោម៖ - …… - បន្តរៀបចំគោលការណ៍ណែនាំស្តីពី *ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន* តាមវិស័យនីមួយៗ - ……
៤៣០	នៅក្នុងផ្នែក ការគ្រប់គ្រងធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន នឹងអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖ - ជំរុញ និងសម្របសម្រួលការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងវិស័យពាក់ព័ន្ធ។ - រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ - ជំរុញនូវការបង្កើតមូលនិធិប្រែប្រួលអាកាសធាតុជាតិ។ - ជំរុញការអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ។ - បន្តកំណត់រក និងជំរុញការអនុវត្តយន្តការអភិវឌ្ឍន៍ស្អាតនិងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នានា។ - អប់រំ និងផ្សព្វផ្សាយដល់សាធារណៈជន ស្តីពីការប្រែប្រួលអាកាសធាតុ។
៤៣២	នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតការយកចិត្តទុកដាក់លើការអនុវត្តផែនការសកម្ម ភាព និងយុទ្ធសាស្ត្រជាតិសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-២០១៣។ - រៀបចំក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និតិវិធីប្រតិបត្តិការស្តង់ដារ និងគោលការណ៍ណែនាំជាគោលនយោបាយ សម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ។ - រៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ និងផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីលើកកម្ពស់ការបញ្ជ្រាប និងការធ្វើសមាហរណកម្ម ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការត្រៀមបង្ការសម្រាប់ឆ្លើយតបគ្រោះអាសន្ន ទៅក្នុងការអភិវឌ្ឍន៍វិស័យសង្គមកិច្ច និងសេដ្ឋកិច្ច-សង្គមកិច្ច និងការស្តារឡើងវិញក្រោយគ្រោះមហន្តរាយ។
៤៣៣	រាជរដ្ឋាភិបាល នឹងពង្រឹងតួនាទីរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការសម្របសម្រួលការអនុវត្តផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០០៨-

	២០១៣ ដែលមានសមាសភាពសំខាន់ៗចំនួន ៦ គឺ - ធានាឲ្យបាននូវការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការត្រៀមបង្ការសម្រាប់ឆ្លើយតបគ្រោះអាសន្នទាំងនៅថ្នាក់ជាតិ និងមូលដ្ឋាន - ……

៤. វឌ្ឍនភាព/ការវិភាគទៅលើការអនុវត្តន៍

៤.១ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

យើងខ្ញុំសូមសំដែងនូវការកោតសរសើរ និងមានមោទនភាពចំពោះរាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងបរិស្ថាន ដែលបានខិតខំប្រឹងប្រែងសម្រេចបាននូវលទ្ធផលយ៉ាងធំធេង ដែលបានបង្កើតឡើងប្រកបដោយភាពជោគជ័យនូវអនុក្រឹត្យ លេខ ៧២ អនក្រ បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងបានចេញជាប្រកាសលេខ ៣៧៦ ប្រក ប.ស្ថ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ ក្រសួងក៏កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីឲ្យក្រុមហ៊ុនវិនិយោគនៅក្នុងប្រទេសកម្ពុជាអនុវត្តប្រកបដោយទំនួលខុសត្រូវ និងធានាបាននូវនិរន្តរភាពធនធានធម្មជាតិ និងបរិស្ថាន។

ទន្ទឹមនឹងនេះដែរ យោងតាមរបាយការណ៍វឌ្ឍនភាពរបស់ក្រសួងបរិស្ថានឆ្នាំ២០១០ និងផែនការឆ្នាំ២០១១ អង្គការសង្គមស៊ីវិលសង្កេតឃើញថា មានក្រុមហ៊ុនមួយចំនួនបាន និងកំពុងអនុវត្តគម្រោងរបស់ខ្លួនមុនពេលដែលរបាយការណ៍ EIA មិនទាន់បានទទួលការអនុម័តជាគោលការណ៍ពីក្រសួងបរិស្ថាន។ ក្រុមហ៊ុនទាំងនោះ រួមមាន ក្រុមហ៊ុន CRCK អភិវឌ្ឍន៍កៅស៊ូនៅក្នុងតំបន់ព្រៃឡង់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ និងក្រុមហ៊ុន Great Field (Cambodia) និងក្រុមហ៊ុន Yellow Field (Cambodia) International Limited ដែលអភិវឌ្ឍន៍ចំការដំណាំអំពៅ នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ជាដើម។ យោងតាមបទពិសោធន៍កន្លងមក ក្រសួងបានផ្តល់ឲ្យអង្គការសង្គមស៊ីវិលនូវពេលវេលាតិចតួចបំផុត គឺជាធម្មតាត្រឹមតែ ២ ទៅ ៣ថ្ងៃនៃថ្ងៃធ្វើការប៉ុណ្ណោះ ដើម្បីពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ EIA។ ជាមួយនឹងរយៈពេលខ្លីយ៉ាងនេះ សង្គមស៊ីវិលពុំអាចចែករំលែករបាយការណ៍ទាំងនេះជាមួយប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធនៅក្នុងតំបន់គម្រោង ដើម្បីពិគ្រោះយោបល់ឲ្យបានកាន់តែទូលំទូលាយ និងការចុះអង្កេតមើលដោយផ្ទាល់ពីហេតុប៉ះពាល់បរិស្ថាន ក្នុងការកំណត់នូវវិធានការកាត់បន្ថយផលប៉ះពាល់។ ប្រសិនបើពួកគាត់អាចធ្វើដូច្នេះបាន របាយការណ៍ទាំងនោះនឹងកាន់តែផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងការពារបរិស្ថានប្រកបដោយនិរន្តរភាព។

លើសពីនេះទៀត អង្គការសង្គមស៊ីវិលសង្កេតឃើញថា របាយការណ៍ EIA ពិចារណាតិចតួចណាស់អំពីការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHGs) ពីការប្រើប្រាស់ដី និងការប្រែប្រួលនៃការប្រើប្រាស់ដី និងព្រៃឈើ (LULUCF) ពីគម្រោងវិនិយោគ។

សំណូមពរ/អនុសាសន៍

- អង្គការសង្គមស៊ីវិល ស្នើសុំយ៉ាងទទូចដល់ក្រសួងបរិស្ថានមេត្តាផ្តល់របាយការណ៍ EIA មកយើងខ្ញុំយ៉ាងហោចណាស់ឲ្យបាន ២ សប្តាហ៍មុនពេលកិច្ចប្រជុំពិគ្រោះយោបល់អន្តរក្រសួង។ ប្រការនេះនឹងឲ្យយើងខ្ញុំមានពេលវេលាគ្រប់គ្រាន់ក្នុងពិនិត្យ និងផ្ទៀងផ្ទាត់របាយការណ៍ជាមួយព័ត៌មានជាក់ស្តែងនៅក្នុងតំបន់គម្រោង ជាពិសេសផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន សង្គម និងវិធានការកាត់បន្ថយផលប៉ះពាល់។
- ក្រសួងបរិស្ថានគួរតែបន្តការតាមដានការអនុវត្តគម្រោងរបស់ក្រុមហ៊ុន ដោយបង្កើតជាគណៈកម្មាធិការតាមដានចាត់តាំង។ ក្រសួងគួរតែបន្តត្រួតពិនិត្យការអនុវត្តរបាយការណ៍EIA និងកិច្ចសន្យារបស់ក្រុមហ៊ុន ដោយមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាថាគម្រោងទាំងអស់ដែលបានអនុម័តត្រូវបានអនុវត្តយ៉ាងពេញលេញប្រកបដោយទំនួលខុសត្រូវដោយក្រុមហ៊ុន។

- សេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គប្បីដាក់បញ្ចូលជាមួយនឹងការសិក្សាបន្ថែមអំពីទំនាក់ទំនងរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុនៅគ្រប់ដំណាក់កាលនៃការរៀបចំរបាយការណ៍ EIA រួមទាំងការអនុវត្តជាក់ស្តែង និងការត្រួតពិនិត្យផងដែរ។
- ក្រសួងបរិស្ថានគួរតែរឹតបន្តឹង និងជាកពិន័យ ឬក៏ផ្អាកសកម្មភាពចំពោះក្រុមហ៊ុនណាដែលពុំបានរៀបចំ និងដាក់របាយការណ៍ EIA ជូនក្រសួងបរិស្ថាន និងអនុវត្តគម្រោងមុនពេលដែលរបាយការណ៍ EIA មិនទាន់ទទួលបានការអនុម័តជាគោលការណ៍។
- រាល់របាយការណ៍ EIA ដែលបានអនុម័តរួច គួរតែចែកជូនដល់គ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីជាព័ត៌មានជាក់លាក់។
- ទម្រង់របាយការណ៍ EIA គួរដាក់បញ្ចូលបន្ថែមអំពី**យន្តការដោះស្រាយបណ្តឹងតវ៉ារវាងម្ចាស់គម្រោង និងក្រុមមនុស្សរងផលប៉ះពាល់**។
- វាជាការប្រសើរ ប្រសិនបើទម្រង់របាយការណ៍ EIA អនុលោមតាមគោលការណ៍ណែនាំរបស់ ADB ដែលមានចែងក្នុងទំព័រទី៣0 នៃលក្ខខណ្ឌតម្រូវសម្រាប់ការពារបរិស្ថាន (ADB safeguard policy, ខែមិថុនា ឆ្នាំ ២00៩)

៤.២ ការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

យើងខ្ញុំសង្កេតឃើថា ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមានភាពយឺតយ៉ាវ ដែលជាហេតុអាចនឹងពិបាកក្នុងសម្រេចឲ្យបានក្នុងឆ្នាំ២0១៣ ដូចដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២00៩-២0១៣។ ម្យ៉ាងវិញទៀត កម្មវិធីជាតិជាច្រើនដូចជា កម្មវិធីសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ(NAPA) ដែលមាន៣៩ គម្រោង (២0គម្រោងអាទិភាព) ត្រូវការថវិកាសរុបរហូតដល់ជិត ២00លាន ដុល្លាអាមេរិក ក្នុងនោះមានតែ 0២ គម្រោងប៉ុណ្ណោះដែលបានអនុវត្ត[55]។

បញ្ហាការប្រែប្រួលអាកាសធាតុកាន់តែមានសភាពធ្ងន់ធ្ងរទៅៗ ពីមួយឆ្នាំទៅមួយឆ្នាំដែលពុំអាចទប់ស្កាត់បានទេ។ ជាក់ស្តែងទឹកជំនន់ក្នុងឆ្នាំ២0១១ បានប៉ះពាល់ខេត្តចំនួន១៨ ទូទាំងប្រទេសកម្ពុជា សំលាប់មនុស្សចំនួន២៤៧នាក់ ប៉ះពាល់ដល់ផ្ទៃដីកសិកម្មចំនួនច្រើនជាង៥៩0,000ហិកតា ដែលក្នុងនោះផ្ទៃដីស្រូវចំនួន ២0,000ហិកតា ត្រូវបានខូចខាតទាំងស្រុង[56]។

- ជាប្រទេសមួយក្នុងប្រទេសដែលងាយរងគ្រោះមហន្តរាយបំផុតក្នុងតំបន់
    - ជាពិសេសងាយនឹងមានគ្រោះទឹកជំនន់ និងរាំងស្ងួត
    - ប្រជាជនភាគច្រើនពឹងផ្អែកលើធនធានធម្មជាតិ
    - ភាពក្រីក្របង្កើនឲ្យមានភាពងាយរងគ្រោះ
- បានកាត់បន្ថយទិន្នផលកសិកម្ម និងជលផល
- បញ្ហាទាក់ទងនឹងសុខភាព ដូចជាជំងឺគ្រុនឈាម និងគ្រុនចាញ់
- ការកើនឡើងនូវជាតិ អំបិល និងការរេចរឹលតំបន់ឆ្នេរ
- ខ្វះការយល់ដឹង និងភាពច្បាស់លាស់ស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នៅកម្រិតជាតិ និងសហគមន៍
- ការសម្របសម្រួលមិនល្អរវាងក្រសួង និងស្ថាប័ន និងរវាងរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងសង្គមស៊ីវិល
- ខ្វះការចូលរួម៖ គោលនយោបាយត្រូវបានរៀបចំសឹងតែទាំងស្រុងនៅកម្រិតជាតិ ដោយមិនមានការចូលរួមពីប្រជាជនងាយរងគ្រោះក្នុងកិច្ចដំណើរការអភិវឌ្ឍ

[55] បទបង្ហាញរបស់អង្គការ Oxfam ក្នុងវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុ ខែតុលា ឆ្នាំ២0១១ សណ្ឋាគាររ៉ាំងទែកង់ទីណង់តាល់

[56] របាយការណ៍The Cambodia daily ថ្ងៃទី១៦ ខែតុលា ឆ្នាំ២0១១

- ខ្វះធនធានមនុស្ស៖ ចំណេះដឹង និងបទពិសោធន៍របស់មន្ត្រីមានកម្រិត និងមានចំនួនតិចតួចធ្វើការលើបញ្ហាការប្រែប្រួលអាកាសធាតុ
- ខ្វះមូលនិធិ៖ ដោយសារតែរដ្ឋាភិបាលបានវិភាជន៍ថវិកាតិចតួច បញ្ហាការប្រែប្រួលអាកាសធាតុពឹងផ្អែកខ្លាំងលើមូលនិធិពីខាងក្រៅ

បញ្ហាផ្សេងៗទៀត៖

- គោលនយោបាយជាតិ DRR កំពុងផ្តោតជាសំខាន់លើជំនួយសង្គ្រោះបន្ទាន់ក្រោយមហន្តរាយ
- កម្មវិធីមិនមានដាក់បញ្ចូលនូវគោលនយោបាយពិភពលោកស្តីពីការប្រែប្រួលអាកាសធាតុ
- មិនមានយុទ្ធសាស្ត្រ និងផែនការជាតិគ្រប់ជ្រុងជ្រោយស្តីពីការប្រែប្រួលអាកាសធាតុនៅឡើយទេ និងមិនមានច្បាប់ និងគោលនយោបាយគ្រប់គ្រាន់
- ខ្វះការតាមដាន និងវាយតម្លៃលើគោលនយោបាយ ដើម្បីវាស់វែងប្រសិទ្ធភាពគោលនយោបាយទាំងនេះ

សំណូមពរ/អនុសាសន៍៖

- គួររៀបចំឲ្យមានជាគោលការណ៍ណែនាំ បរិធាន បទដ្ឋានគតិយុត្ត និងយន្តការច្បាស់លាស់ ដើម្បីបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសវិស័យកសិកម្ម ថាមពល ព្រៃឈើ ធនធានទឹក ឧស្សាហកម្ម និងសុខាភិបាល។
- ផ្សារភ្ជាប់ចំណេះដឹងដែលមានស្រាប់នៅថ្នាក់មូលដ្ឋាន ទៅនឹងការរៀបចំគោលនយោបាយ/យុទ្ធសាស្ត្រពាក់ព័ន្ធនឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ។
- ថវិកាសម្រាប់ការប្រែប្រួលអាកាសធាតុគួរតែវិភាជន៍ដល់ក្រុមជនងាយរងគ្រោះបំផុត និងអង្គការសហគមន៍មូលដ្ឋាន ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈម និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុឲ្យមានប្រសិទ្ធភាព។
- ពង្រឹង និងពង្រីកការអប់រំ ផ្សព្វផ្សាយ ព្យាការណ៍អាកាសធាតុឲ្យបានទូលំទូលាយដល់សាធារណជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយដូចជា ទូរទស្សន៍ វិទ្យុ ទូរស័ព្ទ និងតាមមធ្យោបាយផ្សេងៗដែលអាចផ្សព្វផ្សាយដល់តំបន់ដាច់ស្រយាល និងតំបន់ងាយរងគ្រោះឲ្យទាន់ពេលវេលា និងអាចគេចផុតពីគ្រោះមហន្តរាយ។
- ការរៀបចំគោលជំហររបស់កម្ពុជាសម្រាប់កិច្ចប្រជុំ CoP-១៨ គួរតែមានការពិគ្រោះយោបល់ឲ្យបានទូលំទូលាយជាមួយតំណាងប្រជាពលរដ្ឋមូលដ្ឋាន និងសង្គមស៊ីវិល ដើម្បីលើកឡើងពីតំរូវការសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។
- ម្ចាស់ជំនួយ និងប្រទេសជឿនលឿនគួរតែបង្កើនមូលនិធិរបស់ខ្លួន និងគាំទ្រគម្រោងដែលពាក់ព័ន្ធនឹងការប្រែប្រួល អាកាសធាតុរបស់រដ្ឋាភិបាល សង្គមស៊ីវិល ដោយមិនត្រូវភ្ជាប់មកជាមួយនូវលក្ខណ្ឌអ្វីទាំងអស់។ សហគមន៍មូលដ្ឋានជាច្រើនមានសំណើគម្រោងផ្សេងៗ ក្នុងការចូលរួមដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។
- រាជរដ្ឋាភិបាលគួរតែបង្កើនចំនួនថវិកានៅក្នុងច្បាប់ថវិកាជាតិឆ្នាំ២០១២ និងឆ្នាំបន្តបន្ទាប់ ដើម្បីដោះស្រាយហានិភ័យនៃគ្រោះមហន្តរាយដែលតែងកើតឡើងជាយថាហេតុ ហើយពិបាកក្នុងការគៀងគរធនធានមកសង្គ្រោះបន្ទាន់។ ការធ្វើបែបនេះនឹងកាន់តែមានភាពងាយស្រួលសម្រាប់ម្ចាស់ជំនួយក្នុងការគាំទ្រ និងចូលរួមធនធានផងដែរ។ ផែនការថវិកាប្រែប្រួលអាកាសធាតុ គួរតែវិភាជន៍ទៅដល់ថ្នាក់ក្រោមជាតិ ពិសេស ឃុំ-សង្កាត់ ដែលរស់នៅដោយផ្ទាល់ជាមួយនឹងបញ្ហាការប្រែប្រួលអាកាសធាតុ ដើម្បីអនុវត្តផែនការបន្សាំ។
- ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ គួរតែត្រូវបានដាក់បញ្ចូលផែនការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ដើម្បីងាយស្រួលក្នុងការគៀងគរធនធានហិរញ្ញវត្ថុពីប្រភពផ្សេងៗ។

- ដើម្បីឲ្យបញ្ហាប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ រាជរដ្ឋាភិបាល គួរមានយន្តការច្បាស់លាស់ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយនៅកម្រិតថ្នាក់ក្រោមជាតិ ហើយយន្តការទាំងនេះគួរត្រូវបានអនុម័តដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងដៃគូអភិវឌ្ឍនានា។
- រាជរដ្ឋាភិបាលគួរពង្រឹងសមត្ថភាពបន្ថែមដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ ឃុំ ស្រុក និងខេត្ត ដែលមានស្រាប់ ព្រមទាំងមធ្យោបាយនានា ដើម្បីត្រៀមឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងគ្រោះមហន្តរាយឲ្យទាន់ពេលវេលា។
- ពង្រឹង និងពង្រីកយន្តការផ្តល់ព័ត៌មានប្រកាសអាសន្នជាមុននៅកម្រិតមូលដ្ឋាន ភូមិ ឃុំ ឲ្យមានប្រសិទ្ធភាព។ បង្កើតមជ្ឈមណ្ឌលប្រមូល និងផ្តល់ព័ត៌មាន រួមទាំងមធ្យោបាយ ដើម្បីចែករំលែកព័ត៌មាន និងប្រើប្រាស់ព័ត៌មានរហ័ស និងទាន់ពេល។
- ពង្រឹងការអនុវត្តន៍គោលការណ៍ណែនាំបទដ្ឋានប្រតិបត្តិការសម្រាប់ការឆ្លើយតបនឹងហានិភ័យនៃគ្រោះមហន្តរាយដល់គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់។
- ចេញជាគោលការណ៍ណែនាំស្តីពីវិធានការត្រៀមបង្ការ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ តាមរយៈការបញ្ជ្រាបការងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងគ្រប់វិស័យ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើស្ត្រី និងកុមារ។
- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីពង្រឹងសមត្ថភាព និងកៀងគរធនធានបន្ថែមទៀតក្នុងការដឹកនាំសម្របសម្រួលទៀងទាត់ និងរៀបចំការប្រជុំបន្ទាន់ នៅពេលស្ថានភាពគ្រោះមហន្តរាយស្ថិតក្នុងស្ថានភាពអាសន្ន។
- គោលនយោបាយមានចន្លោះប្រហោង ក្នុងការគាំទ្រការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការធ្វើផែនការ និងដំណើរការថវិកា។ ដោយបង្កើតនូវគោលនយោបាយបែបនេះ វាអាចជួយធានាថា បំណងនៃចំណេះដឹង ប្រព័ន្ធ និងរចនាសម្ព័ន្ធនៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងផ្តល់មូលនិធិយ៉ាងបិតថេរ។
- គោលនយោបាយមួយ គឺត្រូវការជាចាំបាច់ ដើម្បីគាំទ្រការចូលរួមរបស់សហគមន៍ដែលពឹងផ្អែកការធ្វើកសិកម្ម និងនេសាទ ក្នុងការធ្វើផែនការជាតិ និងសេដ្ឋកិច្ចវិមជ្ឈការ។ ប្រការនេះ នឹងញុំាងឲ្យ "គោនយោបាយ" កាន់តែខិតទៅជិតការអនុវត្ត និងការគាំទ្រចំពោះការអនុវត្តដែលអាចធ្វើទៅបាននៅនឹងកន្លែង តួយ៉ាងគឺការធ្វើឲ្យប្រសើរឡើងនូវភាពពាក់ព័ន្ធ និងចីរភាពនៃការអន្តរាគមន៍។
- គោលនយោបាយមួយ គឺត្រូវការជាចាំបាច់ ដើម្បីបង្កើតនូវការសម្រេចចិត្តក្នុងគ្រប់វិស័យ ដែលផ្អែកលើការសិក្សាស្រាវជ្រាវជាផ្លូវការ និងមិនផ្លូវការ/ចេញពីមូលដ្ឋាន។ តាមរយៈការធ្វើដូចនេះ ចំណាប់អារម្មណ៍ជាពិសេសនឹងត្រូវបានកាត់បន្ថយតាមការគាំទ្រតាមវិស័យ ការសម្រេចចិត្តនឹងត្រូវធ្វើឡើងដោយផ្អែកលើព័ត៌មានសុក្រិត និងពេញលេញ ហើយទីបំផុត លទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនឹងត្រូវបានធ្វើឲ្យប្រសើរឡើង។
- គោលនយោបាយមួយ គឺត្រូវការជាចាំបាច់ ដើម្បីគាំទ្រដល់ការដាក់បញ្ចូលផែនការបន្សាំក្នុងអនុវិស័យនានា ដូចជាជលផល និងវារីវប្បកម្ម ក្នុងកម្មវិធីសកម្មភាពជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ប្រការនេះ នឹងបង្វែរធនធានដែលត្រូវការប្រកបដោយប្រសិទ្ធភាព ទៅកាន់ផ្នែក/វិស័យ ដែលត្រូវបានគេមើលរំលងដោយការគាំទ្រមូលនិធិអាទិភាព ហើយនៅទីបំផុត ធានានូវសមធម៌ក្នុងចម្លើយតបដែលបានអនុវត្ត និងរិតត្បិតនូវឧបសគ្គនានាដែលបង្កដោយចន្លោះប្រហោងនៃតម្រូវការនៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ គោលនយោបាយមួយ គឺត្រូវការជាចាំបាច់ ដើម្បីផ្តល់នូវការដាក់បញ្ចូលវិស័យការគ្រប់គ្រងធនធានធម្មជាតិ ក្នុងគោលនយោបាយឆ្លើយតបនឹងគ្រោះមហន្តរាយ និងការធ្វើផែនការអភិវឌ្ឍន៍។ តាមរយៈការធ្វើដូចនេះ វានឹងបន្ថែមតម្លៃឲ្យកិច្ច

ខិតខំប្រឹងប្រែងការពារធនធានធម្មជាតិ និងការការពារសេវាកម្មបរិស្ថានដែលផ្អែកលើប្រព័ន្ធអេកូឡូហ្ស៊ីដែលគួរឲ្យបារម្ភ ក្នុងកំឡុងពេលនៃការឆ្លើយតបនឹងគ្រោះមហន្តរាយ - សេវាកម្មនានាដែលសំខាន់ខ្លាំងសម្រាប់ដំណាក់កាលស្តារឲ្យដូចដើមនូវផលប៉ះពាល់ពីគ្រោះមហន្តរាយ។

- គោលនយោបាយគាំទ្រ គឺត្រូវការជាចាំបាច់ ដើម្បីលើកទឹកចិត្តឲ្យមានការចូលរួមរបស់វិស័យឯកជនក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ តាមរយៈការធ្វើដូចនេះ គំនិតបង្កើតថ្មីក្នុងការបន្សាំ និងធនធានដែលត្រូវការសម្រាប់គាំទ្រការបង្កើតថ្មី អាចនឹងត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធផល ព្រមទាំងផ្តល់នូវយន្តការចីរភាពមួយក្នុងការជម្រុញការបន្សាំទៅមុខដោយផ្អែកលើមូលដ្ឋានស្របគ្នាមួយ។

៤.៣ ការរៀបចំបទដ្ឋានគតិយុត្ត និងឯកសារច្បាប់

អង្គការសង្គមស៊ីវិលសូមអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងបរិស្ថានដែលបានបង្កើតជាច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំ សារាចរណែនាំ ជាច្រើនពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ យោងតាមសេចក្តីថ្លែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្រសួងបរិស្ថាននឹងរៀបចំច្បាប់មួយចំនួនដូចជា ច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលទឹក ច្បាប់ស្តីពីការគ្រប់គ្រងសំណល់រឹង និងសំណល់គ្រោះថ្នាក់ ច្បាប់ស្តីពីការគ្រប់គ្រងការបំពុលខ្យល់ និងការរំខាន់ដោយសំឡេង និងរំញ័រ និងច្បាប់ស្តីពីការគ្រប់គ្រងសារធាតុគីមី ព្រមជាមួយនិងអនុក្រឹត្យមួយចំនួនទៀត។ តាមរយៈរបាយការណ៍វឌ្ឍនភាពរបស់ក្រសួងបរិស្ថាន ឆ្នាំ២០១០ និងទិសដៅឆ្នាំ២០១១ សង្គមស៊ីវិលពិនិត្យឃើញថា ច្បាប់ទាំងអស់ខាងលើនេះពុំទាន់បានពង្រាងនៅឡើយទេ ខណៈពេលដែលរយៈពេលសម្រាប់ការអនុវត្ត ផយអជ ២០០៩-២០១៣ ជិតដល់ឆ្នាំបញ្ចប់ (២០១៣) ទៅហើយនោះ។

សំណូមពរ/អនុសាសន៍៖

- ក្រសួងបរិស្ថានគួរតែពន្លឿនការរៀបចំសេចក្តីព្រាងច្បាប់ដែលមានថ្លែងនៅក្នុង ផយអជ ២០០៩-២០១៣ ពីឆ្នាំនេះទៅ ព្រោះច្បាប់នីមួយៗត្រូវការពេលវេលាយ៉ាងហោចណាស់០២ឆ្នាំក្នុងការរៀបចំ និងពិគ្រោះយោបល់មុនពេលដែលសភា អនុម័ត។ បើមិនដូច្នោះទេ ក្រសួងមិនអាចសម្រេចបាននូវគោលដៅរបស់ខ្លួននៅចុងឆ្នាំ ២០១៣នោះទេ។
- បញ្ហាប្រែប្រួលអាកាសធាតុគួរតែបញ្ចូលទៅក្នុងច្បាប់ និងគោលនយោបាយទាំងអស់របស់ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ពីព្រោះវាជាបញ្ហាអភិវឌ្ឍន៍អន្តរវិស័យ និងមិនអាចមើលរំលងបាននៅក្នុងរបៀបវារៈនៃការអភិវឌ្ឍស្របតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានថ្លែងនៅក្នុងឱកាសបើកវេទិកាថ្នាក់ជាតិលើកទី១ ស្តីពីការប្រែប្រួលអាកាសធាតុ នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩។
- ក្រសួងបរិស្ថានគួរតែពន្លឿនការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឲ្យបានឆាប់ ពីព្រោះច្បាប់នេះមានសារៈសំខាន់បំផុតសម្រាប់កម្ពុជា ខណៈពេលដែលគម្រោងអភិវឌ្ឍន៍ និងលំហូរវិនិយោគទុនក្នុងប្រទេសកម្ពុជា កំពុងតែមានសន្ទុះយ៉ាងខ្លាំងក្លា។ នេះជាសញ្ញាណនៃការបង្កើននូវការប្រើប្រាស់ធនធានធម្មជាតិដែលគ្មាននិរន្តរភាពដោយជនឆ្លៀតឱកាសមួយចំនួន តាមរយៈរូបភាពនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងការរុករ៉ែជាដើម។
- រាល់អត្ថបទច្បាប់ទាំងអស់របស់ក្រសួងបរិស្ថាន គួរតែមានដាក់នៅក្នុងគេហទំព័ររបស់ក្រសួងបរិស្ថានដែលអាចឲ្យសាធារណជនស្វែងរកបាន និងងាយស្រួលក្នុងការរៀនសូត្រផងដែរ។
- ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា គួរគប្បីត្រូវបានពន្លឿនការពង្រាង និងចែករំលែកដល់សង្គមស៊ីវិលសម្រាប់ផ្តល់ជាធាតុចូល។

៤.៤ ការអភិវឌ្ឍន៍ថាមពលអគ្គិសនី និងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់

យោងតាមលទ្ធផលស្រាវជ្រាវស្តីពីរោងចក្រអគ្គិសនីដើរដោយដុតធ្យូងថ្មកំលាំង ១០០ មេហ្គាវ៉ាត់ (MW)នៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ២០១១ ការដុតធ្យូងថ្ម បានចូលរួមចំណែកនៅក្នុងការបញ្ចេញនូវឧស្ម័នផ្ទះកញ្ចក់ចំបងៗ ជាពិសេសឧស្ម័នកាបូនិក។ ការដុតធ្យូងថ្ម ក៏ជាប្រភពនៃការបញ្ចេញមេតានដែលជាឧស្ម័នដ៏ចំបងមួយទៀត ដែលពិភពលោកមានការព្រួយបារម្ភ។ វាមានឥទ្ធិពលខ្លាំងជាងឧស្ម័នកាបូនិកចំនួន ២០ដង ខណៈពេលដែលប្រទេសកម្ពុជាកំពុង ខិតខំប្រឹងប្រែងក្នុងការលក់កាបូនតាមរយៈគម្រោងយន្តការអភិវឌ្ឍន៍ស្អាត។ រោងចក្រអគ្គិសនីនេះ នឹងបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់គុណភាពខ្យល់ ផ្ទៃដីកសិកម្ម សុខភាពសាធារណៈ ជីវៈចំរុះក្នុងសមុទ្រ ជាដើម។ ដោយហេតុនេះ វានឹងមានផលលំបាកចំពោះអ្នកនេសាទរស់នៅតំបន់នោះ[57]។

សំណូមពរ/អនុសាសន៍៖

- យោងតាមផែនការអភិវឌ្ឍន៍ថាមពលអគ្គិសនីរយៈពេលវែង ឆ្នាំ២០១២ ដល់ឆ្នាំ២០២០ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងប្រើប្រាស់ថាមពលអគ្គិសនីដែលបានមកពីការដុតធ្យូងថ្ម ដែលមានកំលាំង ៩០០ MW ដែលរោងចក្រនេះនឹងត្រូវបានសាងសង់ក្នុងដំណាក់កាលផ្សេងៗគ្នា។ ក្រសួងគួរពិចារណាអំពីជំរើសបច្ចេកវិទ្យាទំនើបដែលអាចកាត់បន្ថយការបញ្ចេញនូវឧស្ម័នពុល។ បច្ចេកទេសទាំងនេះ ប្រើប្រាស់វត្តុធាតុដើមផ្សេងៗមកជំនួស ដូចជាការប្រើប្រាស់ម៉ាស៊ីនចំហាយទឹកប្រភេទ Circulating Fluidised Bed (CFB) ដែលអាចដុតកាកសំណល់កសិកម្ម កំទិចឈើជំនួសឲ្យធ្យូងថ្មបាន ហើយមានលក្ខណៈរក្សាការពារបរិស្ថានទៀតផង។ បើទោះជាយ៉ាងនេះក្តី ប្រទេសកម្ពុជាពុំទាន់មានធ្យូងថ្មនៅឡើយទេ ហើយចាំបាច់ត្រូវតែនាំចូលពីប្រទេសមួយចំនួនដូចជាប្រទេសចិន អូស្ត្រាលី និងឥណ្ឌូនេស៊ីជាដើម។ ដូចនេះ តម្លៃអគ្គិសនីនៅតែមានតម្លៃថ្លៃដដែល ប្រសិនបើតម្លៃនៃការនាំចូលធ្យូងថ្មមានការកើនឡើងនោះ។
- ម្យ៉ាងវិញទៀត ការសិក្សាបានបង្ហាញឲ្យឃើញថា ម៉ាស៊ីន CFB នេះ មានប្រសិទ្ធភាពថាមពលតែ ២៨ ភាគរយប៉ុណ្ណោះ ដែលនាំឲ្យខាតបង់ផ្នែកសេដ្ឋកិច្ចរាប់លានដុល្លារអាមេរិក និងបានបញ្ចេញនូវឧស្ម័នពុលយ៉ាងច្រើនទៅក្នុងខ្យល់។ ប្រសិនបើម៉ាស៊ីននេះ បង្កើនប្រសិទ្ធភាពថាមពលរហូតដល់ ៣៦% នោះការចំណេញផ្នែកសេដ្ឋកិច្ចរហូតដល់ច្រើនជាង ៦ដង (៩០០លានដុល្លារអាមេរិក) នៃថវិកាវិនិយោគសរុប (១៧៥លាន ដុល្លារអាមេរិក) ហើយបានចូលរួមកាត់បន្ថយផលប៉ះពាល់ដល់គុណភាពខ្យល់យ៉ាងច្រើនផងដែរ[58]។
- ក្រសួងបរិស្ថានដែលមាននាយកដ្ឋានត្រួតពិនិត្យការបំពុល គួរតែរៀបចំជាគណៈកម្មាធិការអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដានត្រួតពិនិត្យដំណើការសាងសង់រោងចក្រអគ្គិសនីដើរដោយដុតធ្យូងថ្ម។ រោងចក្រនេះ គួរតម្រូវឲ្យបានបំពាក់បរិក្ខាបច្ចេកវិទ្យា ដែលបានសន្យានៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របស់ក្រុមហ៊ុនដែលក្រសួងបរិស្ថានបានអនុម័តកាលពីឆ្នាំ២០១០កន្លងទៅ ដើម្បីធានាការគោរពទៅតាមស្តង់ដារនៃការបញ្ចេញឧស្ម័នរបស់ប្រទេសកម្ពុជាដូចដែលមានចែងនៅក្នុងអនុក្រឹត្យលេខ ៤២ អនក្រ-បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ របស់ក្រសួងបរិស្ថាន ស្តីពីការបំពុលខ្យល់ និងការរំខានដោយសំឡេង។
- មេរៀនដែលទទួលបានពីបណ្តាប្រទេសនានា ដូចជាប្រទេសចិន អាមេរិក ថៃ អូស្ត្រាលី ហ្វីលីពីន និងបណ្តាប្រទេសអភិវឌ្ឍន៍មួយចំនួនទៀត គឺការបំពុលខ្យល់បង្កឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើសុខភាព។ វាមានការពិបាកក្នុងការទប់ស្កាត់ដំណើរការរោងចក្រណាស់ ពីព្រោះគេត្រូវចំណាយរាប់លានដុល្លារក្នុងដំណើរការរោងចក្រអគ្គិសនីបែបនេះ។ យើងខ្ញុំមានការព្រួយបារម្ភនៅរយៈពេលវែងខាងមុខ អាចនឹងមានវិវាទកើតឡើងរវាង

[57] Gregg Eisenberg, Iron Mountain Consulting, November 14, 2011, research report on coal fired power plant in Stung Hav, Shihanuk Ville

[58] របាយការណ៍វិទ្យុអាស៊ីសេរី ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១២ ដោយលោក សុខ សេរី។

ប្រជាពលរដ្ឋនៅជុំវិញតំបន់គម្រោង ដោយសារតែផលប៉ះពាល់ដល់ជីវភាពរស់នៅដែលពឹងអាស្រ័យលើផលនេសាទទាំងស្រុង។

យោងតាមរបាយការណ៍ EIA ឆ្នាំ២០១០ ទំព័រ៧-៣ របស់ក្រុមហ៊ុនថាមពលកម្ពុជាលីមីតធីត ការខាតបង់បរិស្ថានដោយសារតែដំណើរការគម្រោងដែលអាចវាយតម្លៃជាទឹកប្រាក់ គឺការបាត់បង់ផលនេសាទក្នុងសហគមន៍រហូតដល់ ៤២,៣០០ ដុល្លារអាមេរិកក្នុងមួយខែ ពេញមួយកំឡុងពេលប្រតិបត្តិការគម្រោង។ នេះគឺជាប្រភពចំណូលតែមួយគត់របស់ប្រជាជនទាំងនេះ។ ឥណទានដែលមានតម្លៃ ១០,០០០ ដុល្លារអាមេរិកគឺជាសំណងតែមួយគត់ ដែលត្រូវបានផ្តល់ដល់សហគមន៍។ ដូចនេះ យើងខ្ញុំសូមសំណូមពរដល់ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធគួរតែពិចារណាឡើងវិញចំពោះគម្រោងរោងចក្រអគ្គិសនីដើរដោយដុតធ្យូងថ្មលើកក្រោយៗទៀត។

- ថាមពលអគ្គិសនីកកើតឡើងវិញ សម្រាប់ផ្គត់ផ្គង់ថាមពលនៅប្រទេសកម្ពុជា នឹងរក្សានូវគុណភាពបរិស្ថាន និងផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ច និងសមធម៌សង្គម។
- ធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធផលថាមពល និងបង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ ជាពិសេសថាមពលដែលដើរដោយពន្លឺព្រះអាទិត្យ និងទំនប់វារីអគ្គិសនីខ្នាតតូច។

៤.៥ ការបង្កើតក្រុមការងារបច្ចេកទេសបរិស្ថាន និងការប្រែប្រួលអាកាសធាតុ

កន្លងមក អង្គការសង្គមស៊ីវិលសង្កេតឃើញថា នៅក្នុងសូចនាករតាមដានរួម (JMI) ផ្នែកព្រៃឈើ និងបរិស្ថាន (TWG-F&E) ភាគច្រើនបានកំណត់តែក្នុងវិស័យព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បញ្ហាបរិស្ថានត្រូវបានគិតគូរតិចតួច បើទោះបីជាព្រៃឈើមានសារសំខាន់ចាំបាច់ក្នុងការការពារ និងស្តារឡើងវិញ ជាពិសេសប្រសិនបើគោលដៅគឺដើម្បីសម្រេចឲ្យបាននូចគំរបព្រៃទូទាំងប្រទេស ៦០ភាគរយ នៅឆ្នាំ២០១៣ ក៏ដោយ។ សូចនាករនេះគួរត្រូវបានបំបែកឲ្យដាក់ដោយឡែកពីគ្នារវាងក្រុមការងារបច្ចេកទេសព្រៃឈើ ដែលមានក្រសួងកសិកម្មជាអ្នកដឹកនាំ និងក្រុមការងារបច្ចេកទេសផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ដែលមានក្រសួងបរិស្ថានជាអ្នកដឹកនាំ។ ការរៀបចំបែបនេះ ក្រសួងបរិស្ថានមានឱកាសក្នុងបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការការពារ អភិរក្សបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ដែលជាការងារចាំបាច់ត្រូវតែដោះស្រាយជាបន្ទាន់។ នៅក្នុងក្រុមការងារបច្ចេកទេសផ្នែកបរិស្ថាន អនុក្រុមការងារបច្ចេកទេសគួរត្រូវបានបង្កើត ដើម្បីផ្តោតសំខាន់ទៅលើកិច្ចការច្បាប់ ការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការគ្រប់គ្រងការបំពុល ការងារប្រែប្រួលអាកាសធាតុ ការងារអភិរក្សតំបន់ការពារធម្មជាតិ និងការគ្រប់គ្រងសំណល់រឹង និងរាវ ជាដើម។ អនុក្រុមការងារទាំងនេះ គួរមានសមាសភាពសមាជិកមកពីស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ដែលជំរុញ និងរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងបរិស្ថាន ក្នុងការការពារធនធានធម្មជាតិ និងបរិស្ថានឲ្យមាននិរន្តរភាព ស្របតាមគោលដៅរបស់ ជយអជ ២០០៩-២០១៣ និងផែនការអភិវឌ្ឍន៍សហវត្សរ៍។

ករណីសិក្សា ស្តីពីផលប៉ះពាល់ពីរោងចក្រអគ្គិសនីដើរដោយដុតធ្យូងថ្ម នៅខេត្តវ៉ាក់យ៉ង និងខេត្តសាក់សឹងសាវ ប្រទេសថៃ

ក. ករណីនៅតំបន់ឧស្សាហកម្មម៉ាប់តាភុត ខេត្តវ៉ាក់យ៉ង

តំបន់ម៉ាប់តាភុត នៃខេត្តវ៉ាក់យ៉ង ជាតំបន់ទេសចរណ៍ដែលមានឆ្នេរខ្សាច់សស្អាតសំបូរទៅដោយភ្ញៀវទេសចរមកទស្សនា និងលំហែកំសាន្ត។ បច្ចុប្បន្ន ក្រោយពីមានវត្តមានរោងចក្រអគ្គិសនីដើរដោយដុតធ្យូងថ្ម តំបន់នេះបានក្លាយទៅជាតំបន់ឧស្សាហកម្មដែលមានរោងចក្រធំៗជាង ១,០០០ រោងចក្រ។ ខេត្តនេះជាខេត្តដែលជាប់ចំណាត់ថ្នាក់លេខ ១ នៅប្រទេសថៃ ចំពោះអត្រាអ្នកកើតជំងឺមហារីក ជាពិសេសជំងឺប្រព័ន្ធផ្លូវដង្ហើមដែលបណ្តាលមកពីការបំពុលខ្យល់នៅទីនោះ។

ប្រជាជនដែលកំពុងរស់នៅតំបន់នោះ បានក្រោកឡើងធ្វើការតវ៉ាជាមួយរដ្ឋាភិបាល តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់តំបន់ ប៉ុន្តែ ពួកគាត់ពុំអាចសូមឲ្យរដ្ឋាភិបាលបញ្ឈប់ដំណើរការរោងចក្រទាំងនេះបានទេ ដោយសារ រោងចក្ករទាំងនេះបានគោរពតាមច្បាប់នៃការបំភាយឧស្ម័នរបស់ប្រទេសថៃ។ សូមបញ្ជាក់ថា ក្រោយពីមានរោងចក្រអគ្គិសនីដើរដោយដុតធ្យូងថ្មកើតឡើង មានរោងចក្រជាង ១,០០០ បានមកសាងសង់ជាបន្តបន្ទាប់ក្នុងតំបន់នោះ។ ប្រជាជនទាំងនោះត្រូវទ្រាំរស់នៅក្នុងបរិស្ថានអាប់អួរ ដោយសារតែខ្យល់កខ្វក់ដែលបញ្ចេញពីរោងចក្រទាំងនោះ។ ប្រជាជនត្រូវចំណាយថវិកាយ៉ាងច្រើនសម្រាប់ការព្យាបាលជំងឺ ហើយប្រជាជនមួយចំនួនត្រូវបង្ខំចិត្តចំណាកស្រុកទៅកន្លែងផ្សេងទៀតដែលមានសុវត្ថិភាព។

ខ. ករណីនៅតំបន់ឧស្សាហកម្មខេត្តសាក់សឹងសាវ

ករណីស្រដៀងគ្នា បានកើតមាននៅខេត្តសាក់សឹងសាវ។ ប្រជាជននៅទីនោះភាគច្រើនប្រកបរបរកសិកម្ម ហើយបច្ចុប្បន្ននេះ តំបន់នេះត្រូវបានបំពុលដោយសារតែសកម្មភាពអភិវឌ្ឍន៍ដោយរោងចក្រអគ្គិសនីដើរដោយដុតធ្យូងថ្ម និងរោងចក្រនានាដែលមាននៅទីនោះ។ រោងចក្រអគ្គិសនីនៅទីនោះបានបំពុលទឹកក្រោមដីដែលប្រជាពលរដ្ឋ មិនអាចប្រើប្រាស់បាន។ ចំការស្វាយនៅទីនោះត្រូវទទួលរងការបំផ្លាញ មិនអាចចេញផ្កាបាន ដោយសារលំអងធូលីពីការដុតធ្យូងថ្ម និងការបំពុលខ្យល់ ហើយម្ចាស់ចំការបានត្អូញត្អែរថាគាត់ត្រូវខាតបង់ប្រាក់រាប់លានបាតក្នុងមួយឆ្នាំៗ។

សំណូមពរ៖

ផ្អែកលើករណីសិក្សានេះ ផលប៉ះពាល់ពីសកម្មភាពអភិវឌ្ឍន៍ថាមពលមិនស្អាត បានបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម។ ប្រទេសកម្ពុជា បាននិងកំពុងសាងសង់រោងចក្រអគ្គិសនីដើរដោយដុតធ្យុងថ្ម កំលាំង ១០០មេហ្គាវ៉ាត់ នៅស្រុកស្ពឹងហាវ។ រាជរដ្ឋាភិបាលបានអនុម័តគម្រោងនេះកាលពីខែមីនា ឆ្នាំ២០០៨ និងកំពុងបន្តសិក្សា EIA ក្នុងការវិនិយោគរោងចក្រអគ្គិសនីដើរដុតធ្យូងថ្ម កំលាំង ១,៨០០ មេហ្គាវ៉ាត់ បន្ថែមនៅខេត្តកោះកុងរបស់ក្រុមហ៊ុនថៃ ដែលមានឈ្មោះថា រាច្ឆាបុរី អេឡិចត្រិចស៊ីធី ជិនណឺរ៉ែតធីង ហូលឌីង ផាប់ប្លីក[59]។

អង្គការសង្គមស៊ីវិលសូមសំណូមពរដល់រាជរដ្ឋាភិបាល ពិចារណាចំពោះការអភិវឌ្ឍន៍គម្រោងរោងចក្រអគ្គិសនីដើរដោយដុតធ្យូងថ្មដែលមានទំហំធំៗបែបនេះ ដែលអាចបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវៈចំរុះសមុទ្រទេសចរណ៍ធម្មជាតិ ផលនេសាទ កសិកម្ម និងសុខភាពសាធារណៈ។ យើងខ្ញុំសូមគោរពស្នើសុំរាជរដ្ឋាភិបាលពិចារណាជំរើសថាមពលដែលស្អាត ដោយមានផលប៉ះពាល់តិចតួចដល់បរិស្ថាន ដើម្បីបំពេញតំរូវការថាមពលនៅក្នុងប្រទេសកម្ពុជា។

ព័ត៌មានទំនាក់ទំនង

ព័ត៌មានបន្ថែមទាក់ទងនឹងបញ្ហាដែលបានលើកឡើងក្នុងឯកសារនេះ សូមទាក់ទង៖

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងបណ្តាញវេទិកាបរិស្ថាន
លោក ឈិត សំអាត នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩ ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh និង www.cambodianbudget.org
អាសយដ្ឋាន៖ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

[59] របាយការណ៍វិទ្យុអាស៊ីសេរី ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១២ ដោយលោក សុខ សេរី។

ការអភិវឌ្ឍន៍ទប់ទារីអគ្គិសនី និងវិស័យថាមពល

១. សេចក្តីផ្តើម

នៅក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលប្រទេសកម្ពុជាបានធ្វើឲ្យប្រសើរឡើងក្នុងការអភិវឌ្ឍន៍វិស័យថាមពល ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣ តាមរយៈការបង្កើនតម្លាភាពទៅលើ ផែនការវិស័យថាមពលអាទិភាពមួយចំនួន ដូចជា ការបង្កើនអគ្គិសនីនៅតំបន់ជនបទ ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវក្នុងការពន្យាពេលឲ្យមានការសិក្សាស្រាវជ្រាវលម្អិតបន្ថែមទៀត លើផលប៉ះពាល់ឆ្លងដែនដែលអាចបណ្តាលមកពីគម្រោងទំនប់វារីអគ្គិសនី សាយ៉ាបូរី។ ទំនប់វារីសាយ៉ាបូរី ត្រូវបានគេគ្រោងសាងសង់នៅតាមដង ទន្លេមេនៃទន្លេមេគង្គ ភាគខាងជើង របស់ប្រទេសឡាវមានអានុភាព ១២៦០ មេហ្គាវ៉ាត់ ក្នុងទឹកប្រាក់ចំនួន ៣,៥ កោដិដុល្លារសហរដ្ឋអាមេរិក។ នៅក្នុងសេរីនៃកិច្ចប្រជុំនានាជាមួយប្រទេសដែលជាសមាជិកគណៈកម្មាទន្លេមេគង្គ និងប្រទេសជាសមាជិកអាស៊ាន ជាពិសេសគឺ កិច្ចប្រជុំលើកទី១៨ នៃក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីនៃគណៈកម្មការទន្លេមេគង្គ នៅថ្ងៃទី៧-៩ ខែធ្នូ ខេត្តសៀមរាប ឆ្នាំ២០១១។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានព្យាយាម ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយ សង្គមស៊ីវិលដើម្បីផ្សព្វផ្សាយឲ្យមានការចូលរួមក្នុងការថែរក្សា ក៏ដូចជាការគ្រប់គ្រងធនធានធម្មជាតិ និងធនធានទឹក ជាពិសេសក្រសួងបរិស្ថាន គណៈកម្មាជាតិទន្លេមេគង្គកម្ពុជា និងទីស្តីការគណៈរដ្ឋមន្ត្រី។ កិច្ចសហប្រតិបត្តិការទាំងនោះរួមមានសិក្ខាសាលាស្តីពី *សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២* នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដោយបានបកស្រាយ និងពន្យល់សហគមន៍ ក៏ដូចជាអ្នកពាក់ព័ន្ធអំពីដំណើរការនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីបញ្ចាំងកុនឯកសារក្រោមចំណងជើងថា *តើត្រីទៅណា? និងកិច្ចពិភាក្សាលើអនាគតធនធានជលផលទន្លេមេគង្គ* នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១១ ដើម្បីបកស្រាយក៏ដូចជាពន្យល់ដល់និស្សិតអំពីផលប៉ះពាល់ នៃការសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំតាមដងទន្លេមេនៃទន្លេមេគង្គ ចំពោះជីវចំរុះក្នុងទន្លេ ការចូលរួមជាគណៈអធិបតីកិត្តិយសក្នុង *វេទិកាយុវជនស្តីពីទំនប់សាយ៉ាបូរី* ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១១ និង *សន្និសិទថ្នាក់ជាតិលើកទី១ស្តីពីបំរែបំរួលអាកាសធាតុ កសិកម្ម និងថាមពល* ថ្ងៃទី១-២ ខែធ្នូ ឆ្នាំ២០១១ ដើម្បីលើកឡើងពីនិតិវិធីច្បាប់នៃដំណើរការអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនីតាមដងទន្លេមេនៃទន្លេមេគង្គ កិច្ចព្រមព្រៀង កិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ១៩៩៥។ល។

យើងខ្ញុំសូមកោតសរសើរចំពោះរដ្ឋាភិបាលដែលតែងតែផ្តល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មកដល់សង្គមស៊ីវិលដើម្បីធ្វើការផ្តល់មតិយោបល់កែលំអរឲ្យរបាយការណ៍កាន់តែមានភាពល្អប្រសើរឡើង។ ប៉ុន្តែ បើសង្កេតពីរយៈពេលក្នុងការផ្តល់ឱកាសដល់សង្គមស៊ីវិលក្នុងការផ្តល់មតិកែលំអរគឺមានរយៈពេលខ្លី ក្នុងចន្លោះពី ៣-៤ ថ្ងៃប៉ុណ្ណោះ។ នេះជាបញ្ហាលំបាកសម្រាប់សង្គមស៊ីវិលក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍ ធ្វើការប្រមូលព័ត៌មានពីស្ថាប័នពាក់ព័ន្ធ ក៏ដូចជាឯកសារសិក្សាស្រាវជ្រាវបន្ថែមទៀតសម្រាប់ធ្វើការវិភាគឲ្យបានស៊ីជំរៅ និងត្រឹមត្រូវដើម្បីយកមតិយោបល់ដែលពេញលេញដាក់បញ្ចូលក្នុង របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យកាន់តែល្អប្រសើរ។

ទាក់ទងនឹងវិស័យអភិវឌ្ឍន៍ទំនប់វារីអគ្គីសនី រាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមធ្វើឲ្យប្រសើរឡើងនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយការពន្យាពេលការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ (៤០០មេហ្គាវ៉ាត់) ដែលគ្រោងសាងសង់នៅខេត្តស្ទឹងត្រែងឲ្យមានការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញជាច្រើនលើកច្រើនសារដើម្បីឲ្យមានព័ត៌មានលម្អិតមុននឹងធ្វើការសម្រេចចិត្ត។ នេះបង្ហាញពីភាពខុសគ្នារវាង គម្រោងទំនប់ផ្សេងទៀតដែលកំពុងតែសាងសង់ និងត្រៀមនឹងសាងសង់នៅប្រទេសកម្ពុជាដែលបានចុះកិច្ចព្រមព្រៀង និង/ឬកំពុងអនុវត្តន៍ការសាងសង់មុនរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានបញ្ចប់។ ករណីដូចជាទំនប់វារីអគ្គិសនីកំចាយ (១៩៣មេហ្គាវ៉ាត់) ទំនប់

គីរីរម្យ ៣ (១៨ មេហ្គាវ៉ាត់) ទំនប់ស្ទឹងអាតៃ(១២០មេហ្គាវ៉ាត់) ទំនប់ឫស្សីជ្រុំក្រោម (៣៣៨ មេហ្គាវ៉ាត់) ទំនប់តាតៃ (២៤៦ មេហ្គាវ៉ាត់) ។

បើទោះជាគម្រោងទំនប់វារីអគ្គិសនីសេសានក្រោមពីរមានការសិក្សាច្រើនលើកច្រើនសារក៏ដោយ ក៏ការសិក្សាឲ្យបានល្អិតល្អន់លើផលប៉ះពាល់វិស័យផលផលដែលអាចបណ្តាលមកពីទំនប់វារីអគ្គិសនីសេសានក្រោមពីរ និងការព្យាករណ៍ពីផលប៉ះពាល់ និងផលចំណេញដែលទទួលបានពីទំនប់នេះគឺមិនទាន់បានសិក្សាឲ្យបានលម្អិតនោះទេ។ និយាយឲ្យចំ ផលប៉ះពាល់បរិស្ថាន សង្គម និងសេដ្ឋកិច្ចនៅផ្នែកខាងក្រោម និងខាងលើនៃទំនប់ក៏មិនបានដាក់បញ្ចូលទៅក្នុងទំហំនៃការ សិក្សា និងរបាយការណ៍ហេតុប៉ះពាល់បរិស្ថានដែរ។ ជាងនេះទៅទៀត ប្រសិនបើការប្រតិបត្តិការទំនប់សេសានក្រោម ២ នេះដោយមិនមានបរិមាណទឹកគ្រប់គ្រាន់នោះ (យោងតាមរបាយការណ៍ 3STA របស់ធនាគារអភិវឌ្ឍន៍អាស៊ី) ប្រទេសកម្ពុជានឹងទទួលរងនូវផលប៉ះពាល់ ក៏ដូចជាការវិនិយោគទុនដែលមាន ហានិភ័យខ្ពស់សម្រាប់ក្រុមហ៊ុនរួយ៉ាល់គ្រុប ដែលជាក្រុមហ៊ុនមួយរបស់ប្រទេសកម្ពុជាបានចូលរួមវិនិយោគ ៤៩ ភាគរយចំពោះទំនប់នេះ។ វាជាការលំបាកផងដែរសម្រាប់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាព្រះរាជាណាចក្រកម្ពុជា ក្នុងការទាមទារនូវសំណងចំពោះផលប៉ះពាល់ដែលបណ្តាលមកពីទំនប់វារីអគ្គិសនីដែលបានសាងសង់ និងប្រតិបត្តិការនៅ តាមដងទន្លេសេសានផ្នែកខាងលើពីរដ្ឋាភិបាលវៀតណាម និងក្រុមហ៊ុនវិនិយោគលើទំនប់វារីអគ្គិសនីទាំងនោះ ប្រសិនបើទំនប់សេសានក្រោមពីរនេះពិតជាត្រូវបានអនុម័តិឲ្យសាងសង់នៅលើទឹកដីប្រទេសកម្ពុជាមែននោះ។ ករណីដូចជាទំនប់វារីអគ្គិសនី *យ៉ាលី* ដែលផ្តល់ផលប៉ះពាល់ដល់ប្រជាជនកម្ពុជាតាំងពីកំលុងទស្សវត្សន៍ទី៩០ រហូតមកដល់ពេលបច្ចុប្បន្នគឺមិនទាន់ទទួលបានសំណងសមស្របនៅឡើយទេ។ ជាងនេះទៅទៀត របាយការណ៍តាំងទីលំនៅថ្មី និងសំណងសមស្របចំពោះទំនប់សេសានក្រោម២ក៏មិនទាន់បានផ្សព្វផ្សាយជាសាធារណៈ។ នេះគឺបង្ហាញពីការរឹតត្បិត និងមិនបើកចំហរព័ត៌មានទាក់ទងនឹងការអភិវឌ្ឍ ដែលធាតុពិត ប្រជាពលរដ្ឋគឺមានសិទ្ធិគ្រប់គ្រាន់ក្នុងការទទួលបានព័ត៌មានពិតប្រាកដពីរាជរដ្ឋាភិបាលព្រោះប្រជាពលរដ្ឋជាម្ចាស់ឆ្នោត ហើយរាជរដ្ឋាភិបាលជាអ្នកតំណាងឲ្យប្រជាពលរដ្ឋដើម្បីផ្តល់សេវាសង្គម ក៏ដូចជាការគ្រប់គ្រងប្រទេសឲ្យប្រកប ដោយនិតិរដ្ឋ សុខដុមនីយកម្ម និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

ការចូលរួមពិគ្រោះយោបល់ជាសាធារណៈ ជាមួយសហគមន៍ដែលបានទទួលរងគ្រោះ និងសហគមន៍ដែលនឹងទទួលរងផលប៉ះពាល់ពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅកម្ពុជាគឺនៅមានកម្រិតនៅឡើយ។ រីឯការចូលអនុវត្តន៍ការសាងសង់ ឬឈូសឆាយសំអាតអាងស្តុកទឹកក៏មិនទាន់បានផ្តល់ព័ត៌មានលម្អិតអំពី ថាតើបរិវេណពីចំនុចណាទៅដល់ចំនុចណាដែលនឹងត្រូវធ្វើការឈូសឆាយទៅដល់សាធារណៈជនឲ្យបានទូលំទូលាយផងដែរ។ ករណីនេះអាចធ្វើឲ្យជនល្មើសមួយចំនួនឆ្លៀតឱកាសកាប់បំផ្លាញព្រៃឈើល្មើសច្បាប់ និងបរបាញ់សត្វព្រៃដែលមានក្នុងតំបន់នោះផងដែរ។

ដោយបញ្ហាទាំងនេះបាន និងកំពុងកើតមានឡើងក្នុងប្រទេសកម្ពុជាទាក់ទងនឹងការអភិវឌ្ឍទំនប់វារីអគ្គិសនី សម្ព័ន្ធទន្លេកម្ពុជា ដែលជាអង្គការសង្គមស៊ីវិលធ្វើការពាក់ព័ន្ធនឹងការស្ថាប្រព័ន្ធអេកូឡូស៊ីទន្លេ និងជីវភាពប្រជាជនផ្នែកលើទន្លេបានលើកឡើងនូវក្តីបារម្ភ ព្រមទាំងព្យាយាមពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយរាជរដ្ឋាភិបាល ក៏ដូចជា ស្ថាប័នស្រាវជ្រាវជាតិ និងអន្តរជាតិដើម្បីពាំនាំនូវដំណោះស្រាយដែលសមស្របសម្រាប់រាជរដ្ឋាភិបាលធ្វើការពិចារណាយក មកអនុវត្តន៍ក្នុងផែនការអភិវឌ្ឍវិស័យថាមពលដែលប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តភាពក្នុងន័យជាប្រយោជន៍សម្រាប់ប្រជាជនរួមជាតិទូទាំងប្រទេស។

២. សូចនាករតាមដានរួម

គេពុំឃើញមានសូចនាការតាមដានរួមទាក់ទិននឹងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី និងវិស័យថាមពលទេ។

៣. សកម្មភាព/យុទ្ធសាស្ត្រសំខាន់ៗនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣

កថាខ័ណ្ឌ	ខ្លឹមសារ
៤៦៧	រាជរដ្ឋាភិបាលកម្ពុជា លើកទឹកចិត្តដល់ការប្រើប្រាស់ថាមពល ប្រកបដោយប្រសិទ្ធភាព និងមានផលប៉ះពាល់តិចតួចដល់បរិស្ថាន។
៤៦៨	ផ្តោតការយកចិត្តទុកដាក់លើ ការបង្កើតគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់វិស័យថាមពលដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា

ការតាមដានវឌ្ឍនភាព/ការវិភាគទៅលើការអនុវត្តន៍

ក. ការប្រើប្រាស់ថាមពលដែលមានប្រសិទ្ធភាព និងមានផលប៉ះពាល់តិចតួចដល់បរិស្ថាន

យើងខ្ញុំសូមកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបាន និងកំពុងខិតខំប្រឹងប្រែងបង្កើននូវគម្រោងប្រើប្រាស់ថាមពលកកើតឡើងវិញតាមរយៈការធ្វើអគ្គិសនីកម្មជនបទ និងជំរុញការផលិតថាមពលបៃបវិមជ្ឈការដែលមានផលប៉ះពាល់តិចតួចទៅដល់បរិស្ថាន ព្រោះថាមពលប្រភេទនេះគឺបិតនៅជិត ឬផ្គាល់ជាមួយប្រជាពលរដ្ឋ ឧទាហរណ៍ដូចជាថាមពលពីពន្លឺព្រះអាទិត្យ ថាមពលពីជីវឧស្ម័ន ថាមពលពីអង្កាម។ល។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំនៅតាមដងទន្លេធំៗ ករណីដូចជាទន្លេសេសានគឺអាចធ្វើឲ្យមានផលប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងរព្រោះទន្លេនេះបានរួមចំណែកផ្តល់បរិមាណទឹកមួយភាគធំ និងធនធានជលផលមកបឹងទន្លេសាបដែលជាជង្រុកត្រីទឹកសាបក្នុងប្រទេសកម្ពុជា។ ក្រៅពីនេះទៀត ទំនប់វារីអគ្គិសនីកំចាយដែលបច្ចុប្បន្នបានដាក់ឲ្យដំណើរការ ក៏ដូចជាទំនប់ខ្នាតធំផ្សេងទៀតដែលកំពុងតែបិតក្នុងតំណាក់កាលសាងសង់នោះ គឺអាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថានធម្មជាតិ រួមមានទាំងធនធានធម្មជាតិលើគោក និងក្នុងទឹក។ ជាងនេះទៀត ពាក់ព័ន្ធនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ការសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំនៅតំបន់ភាគនិរតីនៃប្រទេសកម្ពុជា នឹងក្លាយជាការព្រួយបារម្ភអំពីការកើនឡើងនូវបរិមាណកំហាប់អំបិលក្នុងទឹកក្រោមដីនៅតំបន់ឆ្នេរដែលជាហេតុនាំឲ្យមានផលប៉ះពាល់ដល់ប្រព័ន្ធកសិកម្មនៃតំបន់នេះ។ ទោះជាយ៉ាងណាក៏ដោយ គេមិនទាន់ឃើញមានការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យស៊ីជំរៅអំពីឥទ្ធិពលនៃទំនប់វារីអគ្គិសនីទៅលើវិស័យកសិកម្ម ក៏ដូចជាការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ឆ្នេរផងដែរ។

សំណូមពរ

ដូច្នេះយើងខ្ញុំសូមសំណូមពរឲ្យរដ្ឋាភិបាលកម្ពុជា៖

១. ធ្វើការសហការជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នស្រាវជ្រាវដើម្បីសិក្សាស្រាវជ្រាវឲ្យបានលម្អិតពីផលប៉ះពាល់ផលចំណេញ និងផលខាតមុនការសម្រេចចិត្តឲ្យមានការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំក្នុងប្រទេស។ ករណីទំនប់ខ្នាតធំសេសានក្រោមពីរដែលអាចមានផលប៉ះពាល់អវិជ្ជមានច្រើនជាង ផលចំណេញដែលបានពីការលក់ថាមពលទៅប្រទេសក្រៅ ដូច្នេះសូមឲ្យមានការសិក្សាពីផលប៉ះពាល់ បរិស្ថាន សង្គម និងសេដ្ឋកិច្ចនៅផ្នែកខាងលើ និងខាងក្រោមនៃគម្រោងទំនប់ ជាពិសេសផលប៉ះពាល់ដល់វិស័យផលផលនៅតាមដងទន្លេ សេសានទៅដល់បឹងទន្លេសាបឲ្យបានលម្អិតបន្ថែមទៀតមុននឹងអនុញ្ញាតិឲ្យមានការសាងសង់។

២. ធ្វើការសហការជាមួយរដ្ឋាភិបាលវៀតណាមដើម្បីឲ្យរដ្ឋាភិបាលវៀតណាម រៀបចំសំណងសមស្របចំពោះផលប៉ះពាល់ដែលបង្កឡើង ពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំៗកន្លងមកនៅតាមដងទន្លេសេសាន និងស្រែពកភាគខាងលើក្នុងទឹកដីវៀតណាម មកលើប្រជាជនកម្ពុជាដែលកំពុងរស់នៅតាមដងទន្លេសេសាន ស្រែពកនៃខេត្តមណ្ឌលគីរី រតនៈគីរី និងស្ទឹងត្រែង នៃប្រទេសកម្ពុជាជាមុនសិន មុននឹងធ្វើការអភិវឌ្ឍន៍ទំនប់សេសានក្រោមពីរ។

៣. ករណីទំនប់នៅតាមតំបន់និរតីគួរតែ ផ្តល់ព័ត៌មានជាចំហឲ្យបានទូលំទូលាយអំពីគម្រោង ផ្តល់ការពិគ្រោះយោបល់ជា

មួយអ្នកពាក់ព័ន្ធឲ្យបានគ្រប់ជ្រុងជ្រោយ និងធ្វើការសិក្សាពីផលប៉ះពាល់ទាក់ទងនឹងការកើនឡើងកំហាប់ជាតិ អំបិលទៅក្នុងទឹកក្រោមដីដែលអាចប៉ះពាល់ដល់ វិស័យកសិកម្មក្នុងតំបន់ និងភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។
៤. សូមស្នើសុំរាជរដ្ឋាភិបាលផ្តល់ឱកាសដល់ អង្គការសង្គមស៊ីវិលមានពេលវេលាគ្រប់គ្រាន់ក្នុងការផ្តល់មតិយោបល់ចំពោះរបាយការណ៍វាយតម្លៃបរិស្ថានក្នុងរយៈពេល យ៉ាងតិច១៥ ថ្ងៃនៃថ្ងៃធ្វើការ។

ខ. ការបង្កើតគោលនយោបាយច្បាប់សម្រាប់វិស័យថាមពល

របាយការណ៍តាំងទីលំនៅថ្មី និងសំណងសមស្របចំពោះទំនប់សេសានក្រោម២ ក៏មិនទាន់បានផ្សព្វផ្សាយជាសាធារណៈ។ ជាការប្រសើរ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់វិស័យថាមពល គួរតែត្រូវបានផ្សព្វផ្សាយទូលំទូលាយ ដើម្បីឲ្យសាធារណៈជន ក៏ដូចជាអ្នកស្រាវជ្រាវមានភាពងាយស្រួលក្នុងការស្វែងរក និងអាចប្រើប្រាស់ជាប្រយោជន៍សម្រាប់ពង្រឹងសមត្ថភាពផ្នែកច្បាប់ទាក់ទងនឹងថាមពលឲ្យបានជុំសជុំល។

សំណូមពរ៖

ដូច្នេះយើងខ្ញុំសូមសំណូមពរឲ្យរដ្ឋាភិបាលកម្ពុជាធ្វើការផ្សព្វផ្សាយរបាយការណ៍តាំងទីលំនៅថ្មី និងសំណងសមស្របចំពោះទំនប់សេសានក្រោម២ ក៏ដូចជាដាក់នូវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ទាក់ទងនឹងថាមពលនៅលើគេហទំព័ររបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក៏ដូចជាក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗ។ ដើម្បីធានាថាគោលនយោបាយវិស័យថាមពលអាចធានាបាននូវនិរន្តរភាព កិច្ចការពារបរិស្ថាន និងបំពេញតំរូវការប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា ក៏ដូចជាប្រសិទ្ធភាពថាមពលក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គ (GMS) ការលើកកំពស់ការប្រើប្រាស់ជម្រើសថាមពលបៃបវិមជ្ឈការ និងថាមពលកកើតឡើងវិញគឺចាំបាច់ ។ នេះគឺមិនរាប់បញ្ចូលចំពោះការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំដែលបញ្ចេញបរិមាណមេតានច្រើន ដែលជាធាតុចំបងមួយក្នុងការកើនឡើងកំដៅផែនដី ជាពិសេសក្នុងតំបន់ត្រូពិច ករណីដូចជាក្នុងប្រទេសកម្ពុជាជាដើម។

៣.ចំនុចខ្វះចន្លោះដែលមិនបានដាក់បញ្ចូលក្នុងសូចនាករតាមជានរួម (JMIs) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម

ក. និតិការ ការអនុវត្តប្រសើរបំផុត

ទាក់ទងនឹងច្បាប់ដែលតម្រូវឲ្យមានការផ្តល់សំណងយុត្តធម៌ និងសមធម៌ ក្នុងការចែករំលែកផលប្រយោជន៍ និងការចំណាយសម្រាប់ផែនការសេវាប្រព័ន្ធអេកូឡូស៊ី នីតិការការអនុវត្តអន្តរជាតិប្រសើរបំផុតចំពោះសំណងសមស្រប ទៅដល់សហគមន៍រងផលប៉ះពាល់ជាអវិជ្ជមានពីគម្រោងទំនប់វារីអគ្គិសនី គឺមិនទាន់មានការអនុវត្តន៍ពេញលេញនៅឡើយទេ។ សូមមើលបន្ថែមអំពីគោលការណ៍ណែនាំ និងអនុសាសន៍របស់គណៈកម្មការពិភពលោកស្តីពីទំនប់តាមរយៈគេហទំព័រ៖ http://wwf.panda.org/what_we_do/footprint/water/dams_initiative/dams/wcd/ ឬរបាយការណ៍គណៈកម្មការពិភពលោកស្តីពីទំនប់ "ទំនប់ និងការអភិវឌ្ឍន៍៖ក្រមខ័ណ្ឌការងារថ្មីសម្រាប់ការសម្រេចចិត្ត"[60] ។

[60] Earthscan (November, 2000).The report of the World Commission on Dam: Dams and Development-A New Framework for Decision Making. London and Sterling, VA.

សំណូមពរ៖

ដូច្នេះយើងខ្ញុំសូមសំណូមពរឲ្យរដ្ឋាភិបាលកម្ពុជាធ្វើការ

១. ដាក់បញ្ចូលសូចនាករតាមដានរួមចំពោះវិស័យថាមពល និងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី។

២. ពង្រឹងការអនុវត្តន៍ ផែនការសេវាប្រព័ន្ធអេកូឡូស៊ី។

៣. រៀបចំនីតិការការអនុវត្តអន្តរជាតិប្រសើរបំផុតចំពោះសំណងសមស្របទៅដល់សហគមន៍រងផលប៉ះពាល់។

ខ. ដំណោះស្រាយវិវាទទឹកឆ្លងព្រំដែន

ទាក់ទិននឹងបញ្ហាដោះស្រាយទឹកឆ្លងព្រំដែន កិច្ចព្រមព្រៀងច្បាស់លាស់ និងប្រកបដោយគណេនយ្យភាព និងការរួបរួមគ្នារវាងប្រទេសក្នុងតំបន់នីមួយៗដើម្បីធានាថា រាល់គម្រោងវារីអគ្គិសនីឆ្លងដែនមិនប៉ះពាល់ដល់ប្រជាពលរដ្ឋគឺចាំបាច់។

សំណូមពរ៖

ដូច្នេះយើងខ្ញុំសូមសំណូមពរឲ្យរដ្ឋាភិបាលកម្ពុជា៖

១. បន្តលើកពីកង្វល់បញ្ហាឆ្លងដែនលើទំនប់វារីអគ្គិសនីតាមដងទន្លេមេនៃទន្លេមេគង្គទៅដល់ប្រទេសជិតខាង និងភ្នាក់ងារអន្តរជាតិ ព្រមទាំងចូលរួមត្រួតពិនិត្យការសិក្សាដែលប្រតិបត្តិដោយប្រទេសជប៉ុនលើការប៉ាន់ប្រមាណហេតុប៉ះពាល់បរិស្ថាន សង្គម និងសេដ្ឋកិច្ចឆ្លងដែន ក្នុងគោលបំណងរួមដៃគ្នាការពារប្រព័ន្ធអេកូឡូស៊ីទន្លេមេគង្គ និងដើម្បីធានាសន្តិសុខស្បៀងប្រជាពលរដ្ឋខ្មែរ ក៏ដូចជាប្រជាជនដែលរស់នៅតំបន់ដីសណ្តទន្លេមេគង្គ។ ការសិក្សាលម្អិតទាំងនេះគួរតែត្រូវបានអនុវត្តន៍ចំពោះទំនប់តាមដែនទន្លេមេគង្គផងដែរករណីដូចជាទំនប់ដែលបាន និងកំពុងសាងសង់នៅក្នុងប្រទេសវៀតណាម។

២. ការសិក្សាពីបញ្ហាផលប៉ះពាល់ឆ្លងដែននៅតាមដងទន្លេសេសាន និងស្រែពក គួរតែត្រូវបានដោះស្រាយជាមុនសិនមុននឹងអនុញ្ញាតិឲ្យមានការ សាងសង់ទំនប់នៅក្នុងប្រទេសកម្ពុជាផ្ទាល់។

៣. បង្កើតកិច្ចព្រមព្រៀងផ្លូវការមួយជាមួយប្រទេសជិតខាង ជាពិសេសរដ្ឋាភិបាលវៀតណាម ដើម្បីផ្តល់សំណងយុត្តិធម៌ជូនប្រជាពលរដ្ឋរងផលប៉ះពាល់ពីទំនប់តាមទន្លេ សេសាន និង ស្រែពក។

៤. ផ្សព្វផ្សាយជាសាធារណៈជាភាសាតាមតំបន់ចំពោះកិច្ចព្រមព្រៀងទាំងអស់ទាក់ទងនិងការប្រើប្រាស់ទឹកឆ្លងកាត់ព្រំដែន និងធានាថាអាចទៅដល់ប្រជាជនក្រីក្រ ឬងាយរងគ្រោះ។

ករណីសិក្សាពីសកម្មភាពការឈូសឆាយព្រៃធ្វើអាងស្តុកទឹកទំនប់វារីអគ្គិសនីសេសានក្រោមពីរ

ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១២

សកម្មភាពត្រៀមសម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២

ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា៖ ក្រុមហ៊ុនវៀតណាមបានចាប់ផ្តើមរៀបចំសម្អាតអាងស្តុកទឹកសម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២នៅក្នុងខេត្តស្ទឹងត្រែង។

កម្មករវៀតណាមបានមកដល់ភូមិស្រែគរ និងភូមិក្បាលរមាស និងចាប់ផ្តើមបាញ់ថ្នាំ និងកាប់រំលំដើមឈើតាមព្រំប្រទល់អាងស្តុកទឹកនៃទំនប់វារីអគ្គិសនីសេសានក្រោម២។ ពីថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ តំណាងសហគមន៍ទន្លេបីខេត្តរតនគិរី បានចុះយកព័ត៌មានបន្ថែមនៅភូមិទាំងពីរដើម្បីបញ្ជាក់ឲ្យបានកាន់តែច្បាស់ពីស្ថានភាពនេះ។ សម្រាប់ឈ្មោះក្រុមហ៊ុនវៀតណាមនោះ គឺមិនមានបញ្ជាក់ច្បាស់លាស់នោះទេ ប៉ុន្តែយោងតាមសម្តីរបស់កម្មករវៀតណាមម្នាក់ និងប៉ូលីស៊ីប៉ុស៊ីស្រុកសេសានម្នាក់បានឲ្យដឹងថា ក្រុមហ៊ុនវៀតណាមមួយនេះ គឺជាក្រុមហ៊ុនមួយដែលដេញថ្លៃ ឬទទួលបានសិទ្ធិក្នុងការសម្អាតផ្ទៃអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីសេសានក្រោម២។

ភូមិស្រែគរ

ស្រែគរជាភូមិមួយដែលឋិតនៅក្នុងអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីសេសានក្រោម២ ហើយអ្នកភូមិនៅទីនេះនឹងត្រូវជំលៀសចេញ ឬរើតាំងទីលំនៅថ្មីប្រសិនបើទំនប់វារីអគ្គិសនីនេះត្រូវសាងសង់មែននោះ។ ចាប់តាំងពីចុងខែធ្នូ ឆ្នាំ ២០១១ មក អ្នកភូមិបានសង្កេតឃើញថា មានវត្តមានរបស់កម្មកររៀតណាមមួយក្រុមដែលមានគ្នាជាង ៣០នាក់ចូលមកក្នុងភូមិរបស់ពួកគេ។ កម្មករទាំងនោះគឺត្រូវបានការពារដោយប៉ូលីសប៉ុស៍ស្រុកសេសាន។ ការចុះយកព័ត៌មានរបស់តំណាងសហគមន៍ទន្លេបីខេត្តរតនគិរីបានបញ្ជាក់ឲ្យឃើញថា ដើមឈើជាច្រើនត្រូវបានបាញ់ថ្នាំចំណាំ និងកាប់រំលំនៅតាមតំបន់ព្រំប្រទល់នៃអាងស្តុកទឹកទំនប់វារីអគ្គិសនី។ កម្មកររៀតណាមបានចាប់ផ្តើមបាញ់ថ្នាំចំណាំ និងកាប់រំលំនៅតំបន់ដែលឋិតនៅខាងក្រោយភូមិ (ខាងជើងឈាងខាងលិចនៃភូមិ) ចុះទៅក្រោមរហូតដល់ទីតាំងទំនប់សេសានក្រោម២ ដែលកាត់តាមតំបន់ព្រៃសហគមន៍ផងដែរ។

សហគមន៍ភូមិស្រែគរបង្ហាញដើមឈើដែលបានបាញ់ថ្នាំចំណាំដើម្បីកាប់រំលំ និងដើមឈើដែលបានកាប់រំលំរួច

តំណាងសហគមន៍មកពីភូមិស្រែគរបាននិយាយថា *"ប្រសិនបើពួកគេកាប់ឈើយ៉ាងនេះ ខ្ញុំមានអារម្មណ៍សោកស្តាយខ្លាំងណាស់ចំពោះព្រៃសហគមន៍ដែលយើងខ្ញុំបានថែរក្សាការពារច្រើនឆ្នាំមកហើយ ឥឡូវព្រៃឈើទាំងនេះត្រូវទទួលរងនូវការកាប់បំផ្លាញទៅវិញ"*។ អ្នកភូមិស្រែគរម្នាក់ទៀតបាននិយាយថា *"ខ្ញុំពិតជាភ័យណាស់ពេលដែលខ្ញុំឃើញរឿងបែបនេះ ខ្ញុំបានរត់ទៅកណ្តាលវាលស្រែ ពេលឃើញរៀតណាមដើរមកជិតខ្ទមស្រែរបស់ខ្ញុំ ហើយពេលយប់យើងចាំបាច់ត្រូវត្រលប់មកដេកនៅភូមិវិញ ហេតុការណ៍ធ្វើឲ្យខ្ញុំនឹកឃើញសម័យប៉ុលពត គឺដូចគ្នាណាស់"*។ ក្រុមហ៊ុនរៀតណាមនេះ បានចុះមកធ្វើការនៅភូមិស្រែគរដោយគ្មានការជូនដំណឹងដល់សហគមន៍ ឬអាជ្ញាធរភូមិ ឃុំ អំពីសកម្មភាពរបស់ពួកគេនោះទេ។ អ្នកភូមិជាច្រើនមានការភ័យខ្លាច និងបារម្ភនៅពេលបានឃើញកម្មកររៀតណាម មិនស្គាល់ មុខទាំងនេះនៅក្នុងភូមិរបស់ពួកគេ។ ជាងនេះទៀត ប៉ូលីសប៉ុស៍ ស្រុកសេសានបាននិយាយគម្រាមថា *"ប្រសិនបើអ្នក ណាហ៊ានប្រឆាំង នឹងចាប់ដាក់ខ្នោះយកទៅដាក់គុកភ្លាម"*។

ភូមិក្បាលរមាស

ក្បាលរមាស ក៏ជាភូមិមួយដែលបិតនៅក្នុងអាងស្តុកទឹកនៃទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលប្រជាជនក្នុងភូមិនេះ ក៏នឹងត្រូវតាំងទីលំនៅថ្មីដែរប្រសិនបើទំនប់វារីអគ្គិសនីនេះត្រូវបានសាងសង់ពិតមែននោះ។ អាជ្ញាធរភូមិក្បាលរមាស មួយរូបបានបង្ហាញពីកង្វល់របស់គាត់ជុំវិញសកម្មភាពដែលកម្មករក្រុមហ៊ុនវៀតណាមបានមកដល់ភូមិរបស់គាត់ដោយគ្មានការជូនដំណឹងដល់សហគមន៍ និងអាជ្ញាធរក្នុងតំបន់បែបនេះ *"ពួកគេធ្វើនេះ ហាក់បីដូចជាចាត់ទុកអាជ្ញាធរភូមិ និងសហគមន៍មូលដ្ឋានមិនមានសិទ្ធិ និងចំណែកអ្វីសោះនៅក្នុងដំណើរការអភិវឌ្ឍន៍"*។ យោងតាមសម្តីមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (សុំមិនបញ្ចេញឈ្មោះ) បានឲ្យដឹងថា គម្រោងវារីអគ្គិសនីសេសានក្រោម២ គឺកំពុងបិត នៅក្នុងការពិភាក្សាពីថ្នាក់ជាតិ និងមិនទាន់មានសេចក្តីសម្រេចចិត្តណាមួយសម្រេចឲ្យសាងសង់ ឬសម្អាតផ្ទៃអាងទំនប់ នោះនៅឡើយទេ។ *យោងប្រភពព័ត៌មានចុះផ្សាយដោយវិទ្យុអាស៊ីសេរីនៅថ្ងៃទី២៤ និង២៦ ខែមករា ឆ្នាំ២០១២[61]*។

អ្នកភូមិស្រែគរម្នាក់បានរាយការណ៍ឲ្យដឹងថា បន្ទាប់ពីប្រតិកម្មខ្លាំងពីអ្នកភូមិ និងអាជ្ញាធរភូមិ ឃុំ ព្រមទាំងព័ត៌មានដែលបានចុះផ្សាយកន្លងមក កម្មករវៀតណាមបានបញ្ឈប់សកម្មភាព និងរើចេញពីភូមិស្រែគរ។ តែទោះជាយ៉ាងណាក៏ដោយ កម្មករវៀតណាមចាកចេញតែក្នុងមួយរយៈប៉ុណ្ណោះ ហើយនឹងវិលត្រឡប់មកវិញនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២។

វត្តមានរបស់កម្មករវៀតណាមនៅភូមិស្រែគរ និងភូមិក្បាលរមាស ធ្វើឲ្យអ្នកភូមិមានការភ័យខ្លាច និងព្រួយបារម្ភណាស់។ អ្នកភូមិមួយចំនួនដែលមានបំណងសង់ផ្ទះថ្មី ក៏មិនហ៊ានលើកសង់ទេ ព្រោះបើសង់ហើយ គង់តែរើចេញដដែល។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងឯកសារនេះ សូមទាក់ទង៖

សម្ព័ន្ធទន្លេកម្ពុជា (RCC)

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
លោក ឈិត សំអាត នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩ ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh គេហទំព័រ៖ www.ngoforum.org.kh និង www.cambodianbudget.org
អាសយដ្ឋាន៖ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក និង សេកុង (3SPN)
លោក មៀច មាន អ្នកសម្របសម្រួល
ទូរស័ព្ទ៖ (៨៥៥)១១ ៧៥៨ ៩៧០ អ៊ីម៉ែល៖ mean@3spn.org គេហទំព័រ៖ http://3spn.cfsites.org
អាសយដ្ឋាន៖ ស្រុកបានលុង ខេត្តរតនគីរី

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA)
លោក ទេព ប៊ុណ្ណារិទ្ធ នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥)២៣ ៨៨១ ៦១៣ អ៊ីម៉ែល៖ cepa@cepa-cambodia.org គេហទំព័រ៖ www.cepa-cambodia.org
អាសយដ្ឋាន៖ ផ្ទះលេខ ៥១ អេហ្វ ផ្លូវ ២១០ ស/ង ទឹកល្អក់៣ ខ័ណ្ឌទួលគោក ភ្នំពេញ ប្រអប់សំបុត្រ ១៤៨៦

[61] http://www.rfa.org/khmer/indepth/villagers_concern_about_hydro_dam
http://www.rfa.org/khmer/indepth/rattanakiri_report-01262012061356.htm

អង្គការសមាគមអាជីវកុក
លោកស្រី ច្រី ឈួន អ្នកសម្របសម្រួលកម្មវិធី
ទូរស័ព្ទ៖ (៨៥៥) ១២ ៨២០ ៩៨៨ អ៊ីម៉ែល៖ chhountry@yahoo.com
អាសយដ្ឋាន៖ ខេត្តកំពត

អង្គការជំនួយអភិវឌ្ឍន៍ និងសន្តិភាព (PDAO)
លោក ស៊ូ សូជាតិ អ្នកសម្របសម្រួលកម្មវិធី
ទូរស័ព្ទ៖ (៨៥៥) ៨៩ ៣០០ ៣០៧
អ៊ីម៉ែល៖ socheath@pdao-cambodia.org គេហទំព័រ៖ http://pdao-cambodia.org/
អាសយដ្ឋាន៖ ខេត្តតាកែវ

ការអភិវឌ្ឍធនធានមនុស្ស

ទិស័យអប់រំ

១. ទស្សនៈរួម

អង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំនៃប្រទេសកម្ពុជា រួមមានអង្គការ NEP ដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកំពុងខិតខំយ៉ាងខ្លាំងដើម្បីកែលម្អការអប់រំសម្រាប់ពលរដ្ឋនៃប្រទេសកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំបំពេញតួនាទីដ៏សំខាន់ចំពោះការដោះស្រាយគម្លាតក្នុងការអប់រំសម្រាប់ក្រុមជួបការលំបាក ពោលគឺ អ្នកក្រីក្រ ជនជាតិដើមភាគតិច កុមារី កុមារពិការ និងអ្នករស់នៅតំបន់ដាច់ស្រយាល។

អង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ មិនត្រឹមតែជួយពង្រីកវិសាលភាពនៃការអប់រំកម្រិតមូលដ្ឋានក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ពួកគេថែមទាំងគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចប្រឹងប្រែងរបស់ក្រសួងដើម្បីកែលម្អគុណភាពនៃសេវាអប់រំទៀតផង ដោយពង្រីកវិសាលភាពនៃអន្តរាគមន៍។ ស្របតាមគោលនយោបាយសាលាកុមារមេត្រី (CFS) របស់ក្រសួងអប់រំ យុវជន និងកីឡា អង្គការមិនមែនរដ្ឋាភិបាលជួយរៀបចំ និងអនុវត្តសកម្មភាពជាច្រើន ដើម្បីរួមចំណែកដល់ការសម្រេចជោគជ័យនូវកម្មវិធីសាលាកុមារមេត្រី។ សកម្មភាពទាំងនោះ រួមមានការបង្រៀននិងការសិក្សាប្រកបដោយប្រសិទ្ធភាព ការកសាងសមត្ថភាពសម្រាប់អង្គការនិងស្ថាប័ន ការកែលម្អបរិស្ថានសាលា ការលើកទឹកចិត្តដល់កម្មវិធីស្ម័គ្រចិត្តក្នុងមូលដ្ឋានតាមរយៈការចូលរួមរបស់ក្រុមប្រឹក្សាសិស្សនិងក្រុមប្រឹក្សាឃុំ ការអប់រំសុខភាព ការបណ្តុះបណ្តាលវិជ្ជាជីវៈ/បច្ចេកទេស ការអប់រំពីបំណិនជីវិត ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងការជួយគាំទ្រការងារគ្រប់គ្រងនៅកម្រិតវិមជ្ឈការ ការអប់រំជាពីរភាសា ការជួយគាំទ្រសហគមន៍ អាហារូបករណ៍ បញ្ហាយេនឌ័រ និងការលើកសំណើដោយផ្អែកលើភស្តុតាងសម្រាប់ការពិភាក្សាគោលនយោបាយជាតិ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអប់រំនៅកម្ពុជា។

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) គឺជាអង្គការសមាជិកភាពមួយ ដែលសមាជិកចំនួន ១០០ របស់ខ្លួន ប្តេជ្ញាចិត្តចំពោះការជួយប្រទេសកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំ ដែលធានា "ថាកុមារនិងយុវជនកម្ពុជាទាំងអស់មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំជាមូលដ្ឋាន ទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ដោយគ្មានការរើសអើងលើមូលហេតុនៃពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា និន្នាការនយោបាយរបស់មាតាបិតា ទីកន្លែងកំណើត ឬឋានៈក្នុងសង្គមឡើយ[62]"។ NEP គាំទ្រគោលដៅនេះតាមរយៈការស្រាវជ្រាវ ការតស៊ូមតិនិងយុទ្ធនាការ និងការងារកសាងសមត្ថភាពជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ និង ការរៀបចំការពិភាក្សាជាបន្តបន្ទាប់ជាមួយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់ការអប់រំទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ដើម្បីគាំទ្រការប្តេជ្ញារបស់រាជរដ្ឋាភិបាលចំពោះគោលដៅជាសាកលស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា ដែលធានាឲ្យបាននូវការអប់រំប្រកបដោយគុណភាព និងការចូលរួមពេញលេញសម្រាប់កុមារទាំងអស់នៃប្រទេសកម្ពុជា NEPសូមស្នើឡើងនូវសកម្មភាពដូចខាងក្រោម៖

២. សូចនាករតាមដានរួម (JMIs)

សូចនាករតាមដានរួមសម្រាប់វិស័យអប់រំ ដែលត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) លើកទីបី ក្នុងខែមិថុនា ឆ្នាំ២០១០។

[62] សេចក្តីដកស្រង់ពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ ផ្នែកទី ៦.៥២៥។

ស្ថាប័នសម្របសម្រួល៖ ក្រសួងអប់រំ យុវជន និងកីឡា **ស្ថាប័នអនុវត្ត៖** ក្រសួងអប់រំ យុវជន និងកីឡា				
លទ្ធផលភ្លាមៗ	**ទិន្នផល**	**សូចនាករទិន្នផល**	**សកម្មភាព៖ សកម្មភាពរង្វាស់**	**សកម្មភាពប្រសិទ្ធភាពជំនួយពាក់ព័ន្ធ**
៣. អត្រាចុះឈ្មោះចូលរៀននៅមធ្យមសិក្សាបឋមភូមិកើនឡើង	ការឡើងថ្នាក់របស់សិស្សនៅបឋមសិក្សាកើនឡើង	អត្រាឡើងថ្នាក់នៅបឋមសិក្សា កើនឡើងពី ៨២,៨% ក្នុងឆ្នាំសិក្សា ២០០៨-០៩ ដល់ ៨៥% ក្នុងឆ្នាំសិក្សា ២០១០-២០១១	១. ពង្រឹងការអនុវត្តន៍បទបញ្ញត្តិពាក់ព័ន្ធនឹងការឡើងថ្នាក់របស់សិស្សនៅគ្រប់សាលាបឋមសិក្សា ២. ចាត់បញ្ជូនគ្រូដែលទើបថ្មីពីសាលាគរុកោសល្យចំនួន៩៥%ទៅសាលារៀនដែលខ្វះគ្រូបង្រៀន និងតំបន់ដាច់ស្រយាល ៣. កាត់បន្ថយភាគរយនៃសាលារៀនមិនគ្រប់ថ្នាក់ពី ១៨% ក្នុងឆ្នាំសិក្សា ២០០៩-២០១០ ដល់ ១៥% ក្នុងឆ្នាំសិក្សា ២០១០-១១ ៤. ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនានាដោយផ្អែកលើភស្តុតាង ឧទាហរណ៍៖ ទិន្នន័យថ្មីៗស្តីពី ជំរឿនប្រជាជនជាដើម	១. ការពិនិត្យឡើងវិញវិស័យអប់រំរួមគ្នាប្រចាំឆ្នាំដែលមានលក្ខណៈប្រាកដប្រជា និងទាន់ពេលវេលា ២. សម្របសម្រួលគំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍន៍សមត្ថភាព

វឌ្ឍនភាពដែលត្រូវបានតាមដានលើសកម្មភាពចាំបាច់ / ការវិភាគលើស្នាដៃអនុវត្ត

២.១ បញ្ជូនគ្រូទើបបណ្តុះបណ្តាលហើយថ្មីឲ្យទៅបង្រៀននៅសាលាដែលខ្វះគ្រូ និងនៅតំបន់ដាច់ស្រយាល

ថ្វីបើ៩៥% នៃគ្រូបង្រៀនទើបបណ្តុះបណ្តាលហើយថ្មី ត្រូវបានបញ្ជូនទៅបង្រៀននៅសាលាដែលខ្វះគ្រូ និងនៅតំបន់ដាច់ស្រយាលក្តី ក៏កង្វះគ្រូនៅតែជាបញ្ហាដ៏ធំមួយសម្រាប់វិស័យអប់រំ។ ការសម្រេចចិត្តរបស់គ្រូក្នុងការជ្រើសរើសកន្លែងទៅបង្រៀន មិនបានឆ្លើយតបទៅនឹងសំណើពីសាលាក្នុងមូលដ្ឋានឡើយ។ គេនៅឃើញមិនទាន់មានគ្រូគ្រប់គ្រាន់នៅតំបន់ដាច់ស្រយាលនៅឡើយទេ ខណៈដែលមានគ្រូលើសតម្រូវការនៅតាមតំបន់ទីក្រុង។ ជាលទ្ធផល សាលាខ្លះមានគ្រូបង្រៀនតែមួយដែលបំពេញតួនាទីជានាយកសាលាផង ជាគ្រូផង និងជាបណ្ណារក្សផង។

ការជ្រើសរើសគ្រូចំនួន ៥.000 នាក់រៀងរាល់ឆ្នាំ និងការបញ្ជូនគ្រូទាំងនោះ ដូចដែលបានរៀបរាប់ខាងលើ មិនអាចដោះស្រាយបញ្ហាខ្វះគ្រូបានទេ ដោយសារចំនួននៃការជ្រើសរើសនេះ គឺគ្រប់សម្រាប់តែជំនួសគ្រូដែលចូលនិវត្តន៍ប៉ុណ្ណោះ។

ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ ក៏គប្បីធានាឲ្យបានប្រាកដផងដែរថាគ្រូបង្រៀននៅគ្រប់កម្រិតទាំងអស់ទទួលបានប្រាក់ខែគ្រប់គ្រាន់សម្រាប់ជីវភាព ដើម្បីកុំឲ្យពួកគាត់ត្រូវរកការងារទីពីរមួយទៀត។ ចំណុចនេះ គប្បីគឺជាអាទិភាពចម្បងមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មិនត្រឹមតែប្រាក់ខែត្រូវកែលម្អប៉ុណ្ណោះទេ ប៉ុន្តែប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់កែលម្អការបើកប្រាក់ខែគ្រូក៏ត្រូវអនុវត្តផងដែរ ដើម្បីជៀសវាងអំពើពុករលួយ និងការទូទាត់ប្រាក់ខែយឺត។

ផែនការសកម្មភាពអភិវឌ្ឍន៍គ្រូ (ឆ្នាំ២០១០-១៤) ទទួលស្គាល់ថាការបង្កើនគុណវុឌ្ឍិសិក្សារបស់គ្រូបង្រៀនមានសារៈសំខាន់សម្រាប់លើកកម្ពស់ជំនាញរបស់ពួកគាត់។ សំណើទាំងឡាយនៅក្នុងផែនការសកម្មភាពនេះ ផ្តល់នូវឱកាសមួយដែលមិនធ្លាប់មានកាលពីមុនសម្រាប់ឲ្យក្រសួងអប់រំ យុវជន និងកីឡា រក្សាបាននូវសមធម៌គ្រូនៅកម្ពុជា ប្រសិនបើផែនការសកម្មភាពនេះត្រូវបានអនុវត្តបានល្អ។ ដើម្បីឲ្យប្រការនេះអាចប្រព្រឹត្តទៅបាន ការគ្រប់គ្រងប្រកបដោយភាពប្រសើរឡើងនិងការបញ្ជូនគ្រូត្រូវផ្អែកលើការព្យាករណ៍ និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ ក្រសួងអប់រំ យុវជន និងកីឡា

អាចកាត់បន្ថយកង្វះគ្រូបង្រៀនជាច្រើន នៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ដោយផ្តល់ឱកាសបណ្តុះបណ្តាលដល់យុវជនមកពីតំបន់ទាំងនោះ និងបញ្ជូនពួកគាត់ទៅកាន់ស្រុកកំណើតរបស់ពួកគាត់វិញ។

សំណូមពរ៖

- ចំពោះការបញ្ជូនគ្រូទើបបណ្តុះបណ្តាលហើយថ្មី យើងខ្ញុំសូមឲ្យពង្រីកបន្ថែមទៀតនូវគោលនយោបាយស្តីពីការជ្រើសរើសគ្រូក្នុងមូលដ្ឋាន។
- ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍ គប្បីបង្កើនចំនួនគ្រូដែលត្រូវជ្រើសរើស ជាពិសេស នៅតំបន់ដាច់ស្រយាល។
- ផ្តល់វិភាជន៍ថវិកាឡើងវិញសម្រាប់បុគ្គលិកអប់រំដោយអនុញ្ញាតឲ្យមានប្រាក់ខែសមរម្យជូនគ្រូបង្រៀន ដើម្បីជួយកាត់បន្ថយការយកថ្លៃសិក្សាក្រៅផ្លូវការ និងលើកទឹកចិត្តឲ្យពួកគាត់នៅកន្លែងដែលពួកគាត់ត្រូវបានបញ្ជូនទៅ។
- ក្រសួងអប់រំ យុវជន និងកីឡា ចាត់វិធានការដើម្បីជំរុញការបញ្ជូនគ្រូបង្រៀន ដើម្បីធានាឲ្យបានថាពុំមានសាលាណាមានបុគ្គលិកលើស និង/ឬខ្វះបុគ្គលិក ព្រោះថាចំណុចនេះក៏នឹងជួយផងដែរដល់ការកាត់បន្ថយការចំណាយថវិកាមិនចាំបាច់។
- លើកស្ទួយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីកែលម្អការបើកប្រាក់ខែគ្រូបង្រៀន។

២.២ កែសម្រួលបទប្បញ្ញត្តិស្តីពីការឡើងថ្នាក់ និងធានាឲ្យបាននូវការអនុវត្តបទប្បញ្ញត្តិទាំងនោះនៅក្នុងកម្មវិធីអប់រំ ដែលត្រូវបានជួយគាំទ្រដោយដៃគូអភិវឌ្ឍន៍

បទប្បញ្ញត្តិកែសម្រួលស្តីពីការឡើងថ្នាក់ ត្រូវបានចេញនិងអនុវត្ត។[63] នៅក្នុងបទប្បញ្ញត្តិកែសម្រួលនេះសិស្សដែលទទួលពិន្ទុក្រោមមធ្យមភាគត្រូវបានផ្តល់ឱកាសឲ្យធ្វើតេស្តនៅចុងឆ្នាំសិក្សាដដែល និងនៅដើមឆ្នាំសិក្សាបន្ទាប់។ ជាលទ្ធផល អត្រាឡើងថ្នាក់នៅបឋមសិក្សាបានកើនឡើងដល់ ៨៤,២% ក្នុងឆ្នាំសិក្សា (២០០៩-២០១០)។ អត្រានេះបានបង្ហាញពីវឌ្ឍនភាពកំណើនគួរឲ្យកត់សម្គាល់ ដោយកើនឡើង ១,៤% ពី ៨២,៨% ក្នុងឆ្នាំសិក្សា ២០០៨-២០០៩។ អត្រាឡើងថ្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៨៥% ក្នុងឆ្នាំ ២០១០-២០១១ (តួលេខមាននៅក្នុងខែមីនា ឆ្នាំ២០១២)។

សំណូមពរ៖

បទប្បញ្ញត្តិកែសម្រួលថ្មីនេះស្តីពីការឡើងថ្នាក់ មានសារៈសំខាន់ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា។ ប៉ុន្តែ ការអប់រំប្រកបដោយគុណភាពនៅតែជាកង្វល់ចម្បងមួយ ជាពិសេស នៅថ្នាក់ទី ១ ទី២ និងទី៣។ អាស្រ័យហេតុនេះ យើងខ្ញុំសូមផ្តល់ជាសំណូមពរដូចខាងក្រោម:

- ទិន្នន័យសិស្សដែលបានប្រឡងនៅចុងឆ្នាំសិក្សាដដែល និងនៅដើមឆ្នាំសិក្សាបន្ទាប់ គប្បីត្រូវផ្សព្វផ្សាយ ដើម្បីឲ្យយើងខ្ញុំអាចសិក្សាលម្អិតអំពីនិន្នាការនៃគុណភាពអប់រំ។
- ជំរុញការអនុវត្តគោលនយោបាយ ជាពិសេស អត្រាឡើងថ្នាក់ និងការកាត់បន្ថយការបង់ថ្លៃសិក្សាក្រៅផ្លូវការ ដោយសារចំណុចនេះគឺជាឧបសគ្គចម្បងចំពោះការទៅរៀន គុណភាព និងការរក្សាទុកសិស្ស។
- ថ្វីបើអត្រារៀនចប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៦ បានកើនឡើងជាបណ្តើរៗពីមួយឆ្នាំទៅមួយឆ្នាំក្តី ក៏តួលេខនេះនៅតែជាកង្វល់មួយដែរ។ គេគប្បីធ្វើសកម្មភាពបន្ថែមទៀតដើម្បីបង្កើនអត្រានេះឲ្យឡើងហួស ៦១,២% (៥៩,៣៣% ឆ្នាំសិក្សា ២០០៨-២០០៩ ដល់ ៦១,២% ២០០៩-២០១០)[64]។ យ៉ាងណាមិញ គេគប្បីគិតគូរដល់ការអប់រំប្រកបដោយគុណភាព។ សិស្សអាចពូកែលើមុខវិជ្ជាមួយ ប៉ុន្តែអាចមិនពូកែលើមុខវិជ្ជាផ្សេងទៀត។

[63] ប្រកាសលេខ ១២៥៨ ដែលត្រូវបានចេញដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩។

[64] EMIS ២០១០/២០១១។

ដូច្នេះ ពិន្ទុមធ្យមភាគពីមុខវិជ្ជាសិក្សា មិនគ្រប់គ្រាន់ទេសម្រាប់កំណត់ការជាប់ ឬការធ្លាក់។ ហេតុដូច្នេះ កត្តាខ្លះគប្បីត្រូវគិតគូរដល់ក្នុងការវាយតម្លៃលើស្នាដៃរបស់សិស្ស។ ប្រការនេះ អាចរួមមានការពិនិត្យមើលប្រវត្តិរូបសិស្ស និងពិន្ទុនៃកិច្ចការគម្រោង ដែលផ្អែកលើចំណាប់អារម្មណ៍របស់សិស្ស ។ល។

៣. សកម្មភាព/ យុទ្ធសាស្ត្រគន្លឹះនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣

កថាខ័ណ្ឌ	ខ្លឹមសារ
៥៣០	ធានាទល្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌
៥៣០	បង្កើនគុណភាព និងប្រសិទ្ធភាពសេវាអប់រំ
៥៣០	អភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពមន្ត្រីអប់រំ

រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានវឌ្ឍនភាពគួរឲ្យកត់សម្គាល់មួយចំនួន ក្នុងការធានាឲ្យបាននូវការចូលរៀនបឋមសិក្សាគ្រប់អាយុប្រាំមួយឆ្នាំ តាមរយៈ៖

៥៣០៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

ការសាងសង់អាគារសិក្សា៖ ចំនួននៃសាលាបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ បានកើនឡើងពីចំនួន ៨.៦២៨ ក្នុងឆ្នាំសិក្សា ២០០៥/២០០៦ ដល់ ៩.៨៣៤ ក្នុងឆ្នាំសិក្សា ២០០៨/២០០៩។ សាលាបឋមសិក្សាបានកើនឡើងពីចំនួន ៦.២៧៧ ដល់ ៦.៥៦៥។ ដើម្បីលើកស្ទួយលទ្ធភាពទទួលបានសេវាអប់រំសម្រាប់កុមារក្រីក្រនៅតំបន់ដាច់ស្រយាល សាលាបឋមសិក្សាចំនួន៥៤៧ ត្រូវបានសាងសង់នៅតំបន់ដាច់ស្រយាលក្នុងឆ្នាំ ២០០៨/២០០៩។

ប៉ុន្តែ ទោះបីជាមានការកែលម្អនេះក្តី ក៏ចំនួនសាលារៀនមិនគ្រប់ថ្នាក់នៅមានច្រើនបង្គួរ ពោលគឺ ១.១៨៥ នៅ ទូទាំងប្រទេស។ បន្ថែមលើនេះ វាគឺជាប្រការសំខាន់ដែលត្រូវកត់សម្គាល់ថា ការសាងសង់សាលារៀនតែមួយមុខមិនមែនជាវិធានការជោគជ័យនោះទេ ពីព្រោះថា មិនមែនសាលារៀនទាំងអស់សុទ្ធតែដំណើរការពេញម៉ោងរាល់ថ្ងៃនោះឡើយ ហើយកង្វះគ្រូបង្រៀននាពេលបច្ចុប្បន្នដែលទទួលបានការបណ្តុះបណ្តាល នៅតែជាបញ្ហាសំខាន់មួយនៅកម្ពុជា។

សំណូមពរ៖

- បន្តកិច្ចប្រឹងប្រែងបច្ចុប្បន្នក្នុងការសាងសង់សាលារៀនថ្មី និងផ្តល់គ្រឿងលើកទឹកចិត្តដើម្បីឲ្យគ្រូទៅបង្រៀននៅតំបន់ដាច់ស្រយាល
- ពន្លឿនដំណើរការសាងសង់/ជួសជុលសាលារៀនដើម្បីកាត់បន្ថយចំនួនសាលារៀនមិនគ្រប់ថ្នាក់ និងសាលារៀនជួបការលំបាកក្នុងអនាគតដ៏ខ្លី
- ពង្រឹងការគ្រប់គ្រងសាលារៀនប្រកបដោយតម្លាភាព និងគណនេយ្យភាពដើម្បីទាក់ទាញការចូលរួមបន្ថែមទៀតពីសហគមន៍។

ចំនួនបុគ្គលិកបង្រៀន៖ ជាការឆ្លើយតបទៅនឹងកំណើនចំនួនសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា គប្បីបង្កើនចំនួនបុគ្គលិកបង្រៀន ពី ៧៨.៦០៦ ក្នុង ឆ្នាំសិក្សា ២០០៥/២០០៦ ដល់ ៨១.៣៥០ ក្នុងឆ្នាំសិក្សា ២០០៨/២០០៩ ជាពិសេសនៅមធ្យមសិក្សា។ ចំនួនគ្រូបឋមសិក្សាបានថយចុះពីចំនួន ៥០.៣៧៨ ដល់ ៤៥.៥១១ ក្នុងរយៈពេលដូចគ្នា ដោយសារការថយចុះចំនួនសិស្ស។

*ការផ្តល់ការអប់រំប្រកបដោយគុណភាព តម្រូវឲ្យមានគ្រូបង្រៀន ដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានឆន្ទៈខ្ពស់ ព្រមទាំងមានការបំពាក់ធនធានគ្រប់គ្រាន់។ កង្វះគ្រូបង្រៀន[65] និងការបាក់ទឹកចិត្ត[66] របស់គ្រូបង្រៀននៅតាមសាលារដ្ឋ ដោយសារប្រាក់បៀវត្សន៍ទាប និងសមត្ថភាពគ្រប់គ្រងនៅមានកម្រិតរបស់នាយកសាលា នៅតែជាបញ្ហាប្រឈមដ៏ធំចំពោះការកែលម្អលទ្ធភាពទទួលបានការអប់រំ និងការអប់រំប្រកបដោយគុណភាព។ (*សម្រាប់ព័ត៌មានអំពីកង្វះគ្រូបង្រៀន សូមមើលសូចនាករតាមដានរួមខាងលើ។) ដោយសារអត្រាចុះឈ្មោះចូលរៀនកើនឡើង ការយកចិត្តទុកដាក់គប្បីផ្តោតលើគុណភាពនៃការអប់រំ ដែលនៅក្នុងនោះ បរិមាណនិងគុណភាពគ្រូ (វិធីសាស្ត្របង្រៀននិងសិក្សា) គប្បីគឺជាអាទិភាពទីមួយ។*

សំណូមពរ៖

- ពង្រឹងការអនុវត្តការជ្រើសរើសគ្រូបង្រៀននៅកម្រិតមូលដ្ឋាន និងរៀបចំប្តូរកន្លែងគ្រូបង្រៀននៅតាមសាលារៀនដែលមានគ្រូលើសតម្រូវការ។
- ធ្វើវិភាជន៍ការផ្តល់មូលនិធិដល់បុគ្គលិកអប់រំឡើងវិញ ដើម្បីឲ្យមានប្រាក់បៀវត្សរ៍សមរម្យ និងសាងសង់លំនៅឋានជូនគ្រូបង្រៀន ដែលត្រូវបានចាត់ទៅបង្រៀននៅឆ្ងាយពីផ្ទះរបស់ខ្លួន។
- កសាងសមត្ថភាពរបស់នាយកសាលា ដើម្បីកែលម្អការគ្រប់គ្រងសាលារៀន និងលើកទឹកចិត្តគ្រូបង្រៀន រួមទាំងការចូលរួមរបស់សហគមន៍។

កាត់បន្ថយឧបសគ្គចំណាយរបស់មាតាបិតាសិស្ស និងរក្សាទុកសិស្សនៅសាលារៀន ៖ ថវិកាសម្រាប់ប្រតិបត្តិការសាលាត្រូវបានបង្កើន ដោយគេបានចេញប្រកាសមួយស្តីពីការលុបបំបាត់ថ្លៃសិក្សាក្រៅផ្លូវការ ហើយអាហារូបករណ៍ត្រូវបានផ្តល់ជូនសិស្សក្រីក្រ ជាពិសេសសិស្សនារីនិងសិស្សពិការ។ ប៉ុន្តែ ទោះបីជាមានកិច្ចប្រឹងប្រែងទាំងនេះក្តី ក៏កុមារជាច្រើននៅតែមិនបានទទួលអត្ថប្រយោជន៍ពេញលេញដែរ ដោយសារស្ថានភាពសេដ្ឋកិច្ច ក្រុមភាគតិច ពិការភាព និងការឲ្យតម្លៃទាបលើការអប់រំរបស់មាតាបិតាសិស្សមួយចំនួនជាដើម។ បំណងនិងការប្តេជ្ញារបស់រាជរដ្ឋាភិបាលចំពោះការលុបបំបាត់ការបង់ប្រាក់ក្រៅផ្លូវការនៅតាមសាលារៀន គឺគួរឲ្យសរសើរ ប៉ុន្តែការអនុវត្តនៅតែកើតមានដដែល និងចាំបាច់គួរត្រូវដោះស្រាយជាបន្ទាន់ ដើម្បីធានាឲ្យបាននូវលទ្ធភាពទទួលការអប់រំប្រកបដោយសមធម៌សម្រាប់កុមារទាំងអស់ ជាពិសេស កុមារក្រីក្រ។

សំណូមពរ៖

- ធ្វើវិភាជន៍ការផ្តល់មូលនិធិដល់បុគ្គលិកអប់រំឡើងវិញ ដើម្បីឲ្យគ្រូបង្រៀនទទួលបានប្រាក់បៀវត្សសមរម្យ ដែលអាចជួយកាត់បន្ថយការយកថ្លៃសិក្សាក្រៅផ្លូវការ និងជួយលើកទឹកចិត្តពួកគាត់ឲ្យនៅកន្លែងដែលពួកគាត់ត្រូវបានបញ្ជូនទៅ។
- បង្កើនថវិកាអាហារូបករណ៍សម្រាប់កុមារក្រីក្រ និងកុមារដែលរស់នៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល។
- ការសាងសង់អន្តេវាសិកដ្ឋានសម្រាប់សិស្សស្រី គប្បីត្រូវបានពង្រីកនៅទូទាំងប្រទេស ហើយជាពិសេសសម្រាប់កុមារក្រីក្រនិងបាត់បង់ឱកាស ដោយមិនត្រូវគិតត្រឹមតែឧត្តមសិក្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់មធ្យមសិក្សាផងដែរ និងនៅតាមទីកន្លែងដាច់ស្រយាលនានា ដែលនៅទីនោះ ពលកម្មកុមារនិងចំណាកស្រុកកុមារមានលក្ខណៈខ្ពស់។

៥៣០៖ បង្កើនគុណភាព និងប្រសិទ្ធភាពសេវាអប់រំ

[65] របាយការណ៍សង្ខេបសម្រាប់មហាសន្និបាតអប់រំ ខែ មីនា ឆ្នាំ ២០១០។

[66] ផ្តល់តម្លៃជូនគ្រូបង្រៀន (NEP និង VSO, ឆ្នាំ ២០០៨)

ពង្រីកគំនិតផ្តួចផ្តើមនៃសាលាកុមារមេត្រី (CFS)៖ ក្រសួងអប់រំ យុវជន និង កីឡា បានអនុម័តគោលនយោបាយសាលាកុមារមេត្រី ផែនការមេនៃគោលនយោបាយនេះ និងគោលនយោបាយស្តីពីការអប់រំសម្រាប់កុមារនិងកុមារពិការ។ ក្រសួងអប់រំ យុវជន និងកីឡា បានកែកម្មវិធីសិក្សារបស់ខ្លួនជាថ្មី ដោយចេញគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាថ្មីនេះសម្រាប់ការអប់រំកម្រិតមូលដ្ឋាន រួមមានស្តង់ដារកម្មវិធីសិក្សា និងផែនការសកម្មភាពសម្រាប់ណែនាំគ្រូស្តីពីគោលនយោបាយកម្មវិធីសិក្សាថ្មីនេះ។ គោលការណ៍ណែនាំស្តីពីការរៀបចំមុខវិជ្ជាសិក្សា និងគោលការណ៍ណែនាំសម្រាប់ឲ្យសិស្សជ្រើសរើសមុខវិជ្ជាដើម្បីសិក្សានៅវិទ្យាល័យក៏ត្រូវបានដាក់ឲ្យអនុវត្តផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡា កំពុងអភិវឌ្ឍក្របខ័ណ្ឌមួយសម្រាប់ផ្តល់សៀវភៅសិក្សាស្នូលសម្រាប់កម្មវិធីសិក្សាថ្មីនេះ។

ទោះបីជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្តី ក៏គុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំមិនអាចត្រូវបានធានាឡើយ ប្រសិនបើសៀវភៅសិក្សានិងឯកសារអានបន្ថែម មិនមានគ្រប់គ្រាន់និងមិនត្រូវបានចែកជូនសិស្សឲ្យបានទាន់ពេល។ ម្យ៉ាងទៀត ការបាត់បង់ពេលបង្រៀននិងសិក្សា ដោយសារកង្វះថ្នាក់រៀន ព្រមទាំងការទៅបង្រៀនមិនទៀងទាត់របស់គ្រូបង្រៀនមួយចំនួន មិនទាន់ត្រូវបានពង្រឹង។ បញ្ហាប្រឈមផ្សេងទៀត កង្វះមធ្យោបាយពង្រឹងមុខវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនមិនត្រូវបានដោះស្រាយ។ ជាចុងក្រោយ ការកែលម្អវិញ្ញាសានិយាមដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សមិនទាន់ត្រូវបានយកមកអនុវត្តនៅឡើយ។

សំណូមពរ៖

- សៀវភៅសិក្សាដែលបានផលិត ត្រូវមានគុណភាពល្អនិងបរិមាណគ្រប់គ្រាន់ ដោយត្រូវធ្វើការបែងចែកដល់គ្រូបង្រៀន និងសិស្សានុសិស្សឲ្យបានទាន់ពេលវេលា។ បន្ថែមលើនេះទៀត យន្តការតាមដានការចែកចាយសៀវភៅសិក្សាគួរតប្បីត្រូវបានបង្កើតឡើងនិងអនុវត្តតាម។
- បន្ថែមលើសៀវភៅសិក្សា ឯកសារអានបន្ថែមនានាក៏គប្បីត្រូវពិចារណាផងដែរ ដើម្បីធានាឲ្យបានថាសិស្សមានជម្រើសច្រើនសម្រាប់ការអាននិងការលើកកម្ពស់ទម្លាប់អានរបស់ពួកគេ។
- ពង្រឹងយន្តការគាំទ្រសាលាកុមារមេត្រី ដូចជា ក្រុមបំប៉ន(DTMT)ជាដើម ដោយយកចិត្តទុកដាក់លើការគ្រប់គ្រង ដូចជាការធ្វើផែនការ ការធ្វើរបាយការណ៍ និងការត្រួតពិនិត្យសាលាកុមារមេត្រី។
- ពន្លឿនការសាងសង់សាលារៀន ជាពិសេស សាលាដែលមិនទាន់មានគ្រប់កម្រិតថ្នាក់ ដើម្បីធានាឲ្យបានថាយើងមានថ្នាក់រៀនគ្រប់គ្រាន់សម្រាប់សិស្ស។ លើសពីនេះទៀត ប្រាក់ខែរបស់គ្រូបង្រៀនគួរត្រូវតម្លើងឲ្យបានដល់កម្រិតមួយដែលសមរម្យសម្រាប់ជីវភាពរស់នៅ ដោយអាចលើកទឹកចិត្តពួកគាត់យកចិត្តទុកដាក់លើការងារបង្រៀន។ លើសពីនេះ ទៀត ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនក៏ត្រូវមានការគិតគូរពិចារណាផងដែរ។
- ធានាឲ្យបានថាការអប់រំបំណិនជីវិត (តាមមូលដ្ឋាន) គឺជាផ្នែកមួយនៃកម្មវិធីសិក្សា ហើយធានាថាសាលារៀនមានធនធានគ្រប់គ្រាន់ (ទាំងមនុស្ស និងសម្ភារៈ) ដើម្បីអនុវត្តសកម្មភាពទាំងនេះក្នុងគោលបំណងធានាឲ្យបាននូវកម្មវិធីសិក្សាអប់រំកាន់តែសមស្រប និងការត្រៀមលក្ខណៈសម្រាប់ការចូលរួមក្នុងទីផ្សារការងារ។
- ការបញ្ចេញថវិកាផ្អែកលើកម្មវិធី (PB) គួរគប្បីធ្វើឡើងឲ្យបានទាន់ពេលវេលា ដែលអាចអនុញ្ញាតដល់ការចាយប្រាក់ប្រកបដោយប្រសិទ្ធភាព។
- អនុវត្ត/ពង្រឹង និងកែលម្អវិញ្ញាសានិយាមដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស យ៉ាងហោចណាស់នៅថ្នាក់ទី ៣, ៦, ៩ និង ១២។
- ដើម្បីសម្រេចបាននូវភារកិច្ចខាងលើ ក្រសួងអប់រំ យុវជន និងកីឡា គប្បីធ្វើវិភាជន៍ថវិកាបន្ថែមក្នុងឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន។

៥៣០៖ អភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពមន្ត្រីអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា ចូលរួមក្នុងការពង្រឹងប្រព័ន្ធតាមដាន ក៏ដូចជាការរៀបចំរចនាសម្ព័ន្ធនៃនីតិវិធីនៃការធ្វើការងារ ការរៀបចំលិខិតតូបកវ័ច្ឆាប់ និងការបណ្តុះបណ្តាលមន្ត្រីអប់រំនៅគ្រប់កម្រិតលើជំនាញបច្ចេកទេស។ កិច្ចប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ផ្តោតលើការសម្រេចឲ្យបាន និងការអនុវត្តច្បាប់ស្តីពីការអប់រំ និងការពង្រឹងមណ្ឌលគ្រប់គ្រងថវិកា (BMCs)។

គោលនយោបាយខាងលើនេះមិនអាចសម្រេចបានទេ ប្រសិនបើសមត្ថភាពរបស់នាយកសាលាមិនត្រូវបានពង្រឹងដើម្បីអនុវត្តវិមជ្ឈការ ដូចជាការគ្រប់គ្រងសាលារៀន ការគ្រប់គ្រងថ្នាក់រៀន សកម្មភាពបង្រៀននិងសិក្សា ការវាយតម្លៃលើការសិក្សារបស់សិស្ស និង ការប្រើប្រាស់ធនធានថវិកាប្រកបដោយប្រសិទ្ធភាព។

ជាងនេះទៅទៀត ការអនុវត្តវិមជ្ឈការក៏ពឹងផ្អែកយ៉ាងច្រើនផងដែរលើការចូលរួមរបស់សហគមន៍និងក្រុមប្រឹក្សាឃុំ។ ប៉ុន្តែ សហគមន៍និងក្រុមប្រឹក្សាឃុំខ្លះមិនបានដាក់បញ្ចូលផែនការអភិវឌ្ឍន៍សាលា ទៅក្នុងផែនការអភិវឌ្ឍន៍របស់ពួកខ្លួនទេ[67] ។ សហគមន៍និងអាជ្ញាធរមូលដ្ឋានខ្លះយល់ថា ការអប់រំគឺជាការទទួលខុសត្រូវរបស់សាលារៀន គ្រូបង្រៀន និងក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា កំពុងរៀបចំគោលនយោបាយគ្រូបង្រៀន ដើម្បីកែលម្អស្ថានភាពរស់នៅរបស់ពួកគាត់ តាមរយៈការជួយគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍និងសង្គមស៊ីវិល។ ធានាឲ្យបាននូវការចូលរួមប្រកបដោយអត្ថន័យរបស់គ្រូបង្រៀនក្នុងឋានៈជា ភាគីពាក់ព័ន្ធចម្បងនៅក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយសម្រាប់ពួកគាត់។ មូលហេតុចម្បងដែលពួកគាត់គិតថាមិនបានចូលរួម គឺថានាយកសាលាភាគច្រើនមិនបានពិគ្រោះយោបល់ជាមួយពួកគាត់ និងមិនបានបញ្ចេញរបាយការណ៍ហិរញ្ញវត្ថុ។ ការរើសអើងប្រឆាំងនឹងគ្រូបង្រៀនម្នាក់ៗក៏ត្រូវបានគូសបង្ហាញផងដែរ។

សំណូមពរ៖

- កសាងសមត្ថភាពរបស់នាយកសាលាដើម្បីកែលម្អការគ្រប់គ្រងសាលារៀន ដោយសារប្រការនេះអាចលើកទឹកចិត្តគ្រូបង្រៀន និងការចូលរួមរបស់សហគមន៍។
- ក្រសួងអប់រំ យុវជន និងកីឡា លើកស្ទួយគោលនយោបាយវិមជ្ឈការសម្រាប់ការអប់រំជូនដល់សហគមន៍ និង ក្រុមប្រឹក្សាឃុំ ដើម្បីកែលម្អការចូលរួមរបស់ពួកគាត់ (ក្នុងការអភិវឌ្ឍសាលារៀន និងការលើកកម្ពស់គុណភាពអប់រំ)។
- ផ្សព្វផ្សាយដល់សហគមន៍ និងជម្រុញពួកគាត់ឲ្យចូលរួមក្នុងកិច្ចការសាលារៀន ដើម្បីផ្តល់តម្លៃដល់ការអប់រំ និងវាយតម្លៃខ្ពស់ដល់ការងារដែលគ្រូបង្រៀនធ្វើ។ តាមរយៈការងារនេះ ជំនឿចិត្តរបស់គ្រូបង្រៀននឹងត្រូវបានលើកកម្ពស់ ហើយគុណភាពនៃការអប់រំក៏នឹងត្រូវបានកែលម្អផងដែរ។ ការយកចិត្តទុកដាក់ និងការបង្កើនការគៀងគរការជួយគាំទ្រចំពោះបុព្វហេតុដ៏ឧត្តុង្គឧត្តមនេះ គប្បីត្រូវផ្តោតលើចំណុចទាំងឡាយណា ដែលមានការវិវឌ្ឍយឺតក្រោយគេ។
- ធានាឲ្យបាននូវការចូលរួមប្រកបដោយអត្ថន័យរបស់គ្រូបង្រៀនក្នុងការរៀបចំគោលនយោបាយគ្រូបង្រៀន។

៤. បញ្ហាសំខាន់ៗដែលមិនត្រូវបានដាក់បញ្ចូលក្នុងសូចនាករតាមដានរួម ឬផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម៖ ថ្លៃសិក្សាក្រៅផ្លូវការ និង អំពើពុករលួយ

ការយក***ថ្លៃសិក្សាក្រៅផ្លូវការ*** ដើម្បីបំពេញបន្ថែមលើប្រាក់បៀវត្សទាបរបស់គ្រូបង្រៀន គឺជាបន្ទុកដ៏ធ្ងន់មួយលើប្រាក់ចំណូលគ្រួសារ ជាពិសេសក្រុមប្រជាជនក្រីក្រខ្លាំង និងក្រុមជួបការលំបាកផ្សេងៗទៀត។ បើការអនុវត្តបែបនេះនៅ

[67] របាយការណ៍សង្ខេបសម្រាប់សន្និបាតអប់រំ ខែ មីនា ឆ្នាំ ២០១០។

តែបន្ត ប្រទេសកម្ពុជានឹងមិនសម្រេចបាននូវកំណើនប្រកបដោយអត្ថន័យនៅក្នុងអត្រាចុះឈ្មោះចូលរៀន និងអត្រាគង់វង្សច្រើន (survival rate) នៅទូទាំងប្រទេសបានទេ។

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់បញ្ហានៃការយកថ្លៃសិក្សាក្រៅផ្លូវការ ដោយបានចែងនៅក្នុងច្បាប់អប់រំកម្ពុជាថា ការអនុវត្តនេះគឺខុសច្បាប់។ ក្រសួងអប់រំ យុវជន និងកីឡា បានប្តេជ្ញាលុបបំបាត់ថ្លៃសិក្សាក្រៅផ្លូវការឲ្យបានមុនដំណាច់ឆ្នាំ២០០៨ នៅក្នុងផែនការយុទ្ធសាស្ត្រ (ESP) របស់ខ្លួន។

> ផ្តល់ជូនគ្រូបង្រៀននូវប្រាក់ចំណូលសមរម្យ ដែលឆ្ពុះបញ្ចាំងពីថ្លៃចំណាយលើការរស់នៅនិងអតិផរណា ដើម្បីឲ្យពួកគាត់មិនចាំបាច់យកថ្លៃសិក្សាក្រៅផ្លូវការ ដើម្បីបំពេញបន្ថែមលើប្រាក់បៀវត្សរ៍របស់ខ្លួន។ លើកទឹកចិត្តដល់កិច្ចសហការល្អរបស់សហគមន៍ដើម្បីជួយគ្រូបង្រៀននៅតំបន់ដាច់ស្រយាល។

ជាចុងក្រោយ គ្រូបង្រៀនយល់ឃើញថា អំពើពុករលួយគឺជាកត្តាធ្វើឲ្យបាក់ទឹកចិត្តចម្បងមួយ[68]។ ចំណុចនេះប៉ះពាល់ដល់គុណភាពនៃការអប់រំដែលផ្តល់ឲ្យសិស្ស និងជះឥទ្ធិពលលើអត្រាគង់វង្ស។

> ប្រតិបត្តិឲ្យបានត្រឹមត្រូវនូវច្បាប់ប្រឆាំងនឹងអំពើពុករលួយ ដែលត្រូវបានអនុម័តដោយរដ្ឋសភា ជាអាទិភាពកំពូលមួយ។

សកម្មភាពលើអនុសាសន៍ទាំងនេះ គឺជាតម្រូវការជាបន្ទាន់ ដើម្បីជួយរាជរដ្ឋភិបាលកម្ពុជា និង ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការកាត់បន្ថយឧបសគ្គចំពោះការអប់រំសម្រាប់ទាំងអស់គ្នា។ ផលប៉ះពាល់លើការចូលរៀននៅបឋមសិក្សា និងអត្រាគង់វង្ស គឺជាចំណុចសំខាន់មួយ។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

ភាពជាដៃគូនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យអប់រំ (NEP)
លោក អ៊ិន សំរិទ្ធី នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥)២៣ ២២៤ ៧៧៤
អ៊ីម៉ែល៖ info@nepcambodia.org or dir@nepcambodia.org
គេហទំព័រ៖ www.nepcambodia.org

[68] ផ្តល់តម្លៃជូនគ្រូបង្រៀន (NEP និង VSO ឆ្នាំ ២០០៨)

សុខាភិបាល

១. សាវតាពាក់ព័ន្ធ

អង្គការម៉េឌីខាំ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៩ គឺជាអង្គការសមាជិកភាពនៃអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារសកម្មនៅក្នុងវិស័យសុខាភិបាលនៅកម្ពុជា ហើយបច្ចុប្បន្ននេះ តំណាងឲ្យអង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពចំនួន១២៣ (សូមមើលគេហទំព័ររបស់អង្គការម៉េឌីខាំ)។ ពាក្យថា "ម៉េឌីខាំ" ឬ "អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាព" ដែលត្រូវបានប្រើជំនួសគ្នាទៅវិញទៅមកនៅក្នុងឯកសារគោលជំហរនេះ គ្រាន់តែជាតំណាងសំលេង និងទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពដែលជាសមាជិករបស់អង្គការម៉េឌីខាំតែប៉ុណ្ណោះ។ យ៉ាងនេះក្តី អង្គការទាំងនេះតំណាងឲ្យប្រហែល ៩០% នៃអង្គការជាតិ និងអន្តរជាតិទាំងអស់ ដែលបំពេញការងារនៅក្នុងវិស័យសុខាភិបាលកម្ពុជា។

ឯកសារគោលនយោបាយរបស់អង្គការម៉េឌីខាំ ត្រូវបានរៀបចំឡើង ដោយមានការពិភាក្សាយ៉ាងទូលំទូលាយ ប្រកបដោយតម្លាភាព និងភាពបើកចំហ ជាមួយនឹងសមាជិកទាំងអស់របស់ខ្លួន។ កិច្ចប្រជុំតាមតំបន់ នៅថ្នាក់ខេត្ត គឺជាយន្តការទីមួយ ដែលអង្គការនៅមូលដ្ឋានជួបពិភាក្សាពីបញ្ហាប្រឈម និងអនុសាសន៍នានាសម្រាប់វិស័យសុខាភិបាលកម្ពុជា ដែលតាមរយៈយន្តការនេះ ពួកគេបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួនឲ្យបញ្ចេញសម្លេងរួមរបស់ពួកគេ នៅក្នុងកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំរបស់អង្គការម៉េឌីខាំ។ បន្ទាប់ពីអង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខាភិបាល ពិភាក្សាគ្នាយ៉ាងហ្មត់ចត់អស់ជាច្រើនម៉ោងនៅក្នុងមហាសន្និបាតនៅថ្នាក់ជាតិរួចមក តំណាងអង្គការមិនមែនរដ្ឋាភិបាល បោះឆ្នោត ផ្តល់អាទិភាពចំពោះបញ្ហា/បញ្ហាប្រឈម និងអនុសាសន៍នានាដែលត្រូវលើកឡើងនៅក្នុងឯកសារគោលជំហរនេះ។

លើសពីនេះទៀត អង្គការម៉េឌីខាំក៏អញ្ជើញអង្គការជាសមាជិកមកជួបពិភាក្សាជាក្រុមទៅតាមប្រធានបទនីមួយៗ ដែលរួមមាន៖ សុខភាពបន្តពូជ សុខភាពមាតានិងទារក (RMNCH) ជំងឺឆ្លង ជំងឺមិនឆ្លង ការផ្តល់សេវាថែទាំសុខភាព ធនធានមនុស្សសម្រាប់វិស័យសុខាភិបាល ហិរញ្ញប្បទានសុខាភិបាល ព័ត៌មានសុខាភិបាល អភិបាលកិច្ចសុខាភិបាល ជាដើម។

ផ្នែកតាមការពិភាក្សាយ៉ាងហ្មត់ចត់តាមក្រុមនីមួយៗ នាយកប្រតិបត្តិរបស់អង្គការម៉េឌីខាំ ចងក្រងជាពង្រាងទីមួយនៃឯកសារគោលជំហររបស់អង្គការម៉េឌីខាំ រួចដាក់ជូនគណៈកម្មាធិការដឹកនាំការគ្រប់គ្រង ដើម្បីពិនិត្យនិងផ្តល់យោបល់។ គណៈកម្មាធិការនេះ បានជួបប្រជុំចំនួនពីរដង ដែលលើកទីមួយនៅថ្ងៃទី៦ ខែឧសភា និងម្តងទៀតនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ដើម្បីពិភាក្សាលើពង្រាងនេះ ហើយមតិយោបល់ទាំងឡាយដែលទទួលបានត្រូវបានដាក់បញ្ចូលទៅក្នុងពង្រាងទីពីរនៃឯកសារគោលជំហរនេះ។ ពង្រាងទីពីរនេះ ត្រូវបានផ្ញើជូនសមាជិកទាំងអស់នៃគណៈកម្មាធិការដឹកនាំការគ្រប់គ្រង ដើម្បីផ្តល់យោបល់ម្តងទៀត ហើយកិច្ចប្រជុំម្តងទៀតនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ រវាងគណៈកម្មាធិការនេះបានបញ្ចប់ឯកសារគោលជំហរនេះជាស្ថាពរ។

ឯកសារគោលជំហររបស់អង្គការម៉េឌីខាំឆ្នាំ២០១១នេះ ពុំមានបំណងធ្វើការតស៊ូមតិលើអាទិភាពថ្មីៗ សម្រាប់ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០០៨-២០១៥ ដែលនៅក្នុងនោះយោបល់របស់អង្គការមិនមែនរដ្ឋាភិបាលត្រូវបានដាក់បញ្ចូលរួចហើយនោះទេ ប៉ុន្តែមានគោលបំណង រំលេចនូវបញ្ហា/បញ្ហាប្រឈមចំបងៗ និងអនុសាសន៍នានា សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលជំហាន២នេះ ដើម្បីឲ្យក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា អាចឈរនៅក្នុងស្ថានភាពប្រសើរឡើងថែមទៀត សំដៅសម្រេចបាននូវការតាំងចិត្តទាំងឡាយនៅក្នុងគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ជាពិសេសគោលដៅទី៤ ទី៥ និងទី៦ នៅត្រឹមឆ្នាំ២០១៥។ ឯកសារគោលជំហរនេះ មានបំណងពិនិត្យមើលបញ្ហា/បញ្ហាប្រឈមទាំងនោះជារៀងរាល់ឆ្នាំ។

២-សេចក្តីផ្តើម

អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាព សូមអបអរសាទរចំពោះសមិទ្ធផលគួរឲ្យកត់សម្គាល់នានារបស់ក្រសួងសុខាភិបាល ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយមានការសហការពីសហគមន៍អន្តរជាតិ រួមទាំងដៃគូសុខាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ សមិទ្ធផលសំខាន់ៗរួមមាន៖ (១)ប្រទេសកម្ពុជាសម្រេចបានជាសកលនូវការផ្តល់ថ្នាំពន្យារជីវិតសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ ហើយអត្រាប្រ៉ាវ៉ាឡង់នៃមេរោគអេដស៍បានធ្លាក់ចុះមកនៅត្រឹម ០,៨០% នៅក្នុងឆ្នាំ២០១១ ដែលនេះគឺយោងតាមការសិក្សារបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ (២)សមិទ្ធផលគួរឲ្យកត់សម្គាល់នៃបទអន្តរាគមន៍ជំងឺរបេង ដែលរួមមានការអនុវត្តបាន១០០% នៃការព្យាបាលដោយដូត៍នៅតាមកម្រិតមណ្ឌលសុខភាព សហគមន៍ដូត៍នៅក្រោមតំបន់គ្របដណ្តប់របស់មណ្ឌលសុខភាពទាំង៨៣៩ រដ្ឋ-ឯកជនចំរុះស្តីពីការព្យាបាលដោយដូត៍ដែលត្រូវបានអនុវត្តនៅក្នុងស្រុកប្រតិបត្តិចំនួន៣៩នៅក្នុងខេត្តចំនួន ១១ អត្រាព្យាបាលបានសម្រេចកើនដល់៩២% អត្រារកឃើញករណីថ្មីកើនដល់៦២% និងការអនុវត្តរកអ្នកផ្ទុកមេរោគអេដស៍លើអ្នកកើតរបេងនៅគ្រប់ស្រុកប្រតិបត្តិទាំងអស់ឆ្នាំ២០១០។ (៣)លទ្ធផលជាបឋមនៃការអង្កេតប្រជាសាស្ត្រសុខាភិបាល និងប្រជាសាស្ត្រឆ្នាំ២០១០ បានបង្ហាញពីការធ្លាក់ចុះគួរឲ្យកត់សម្គាល់នៃអត្រាស្លាប់របស់ទារក និងកុមារក្រោមអាយុ៥ឆ្នាំ ដែលក្នុងនោះអាត្រាស្លាប់របស់ទារកមានការថយចុះមកត្រឹម ៤៥នាក់ ក្នុង១០០០កំណើតរស់ និងកុមារក្រោមអាយុ៥ឆ្នាំចុះមកត្រឹម ៥៤នាក់ ក្នុង១០០០កំណើតរស់។ (៤)សូចនាករសំខាន់ៗទាំងអស់ទាក់ទងនឹងសុខភាពមាតាមានការរីកចំរើនច្រើន។ (៥)ជំងឺគ្រុនចាញ់កំពុងស្ថិតនៅលើផ្លូវត្រូវ សម្រាប់ឲ្យផែនការលុបបំបាត់ជំងឺនេះទាំងស្រុងសម្រេចបានត្រឹមឆ្នាំ២០២៥។ (៦)ជំងឺតេតាណូសនិងជំងឺកញ្ជ្រឹលក៏កំពុងជិតត្រូវបានលុបបំបាត់ទាំងស្រុង (៧)មូលនិធិសមធម៌ សុខភាពបាននឹងកំពុងជួយប្រជាពលរដ្ឋរស់នៅក្រោមបន្ទាត់ក្រីក្រ ឲ្យទទួលបាននូវសេវាថែទាំសុខភាពដោយឥតបង់ថ្លៃកាន់តែច្រើនឡើង។ (៨)ទីភ្នាក់ងារប្រតិបត្តិការពិសេស កញ្ចប់ថវិកាសម្រាប់ផ្តល់សេវាកំពុងត្រូវបានពង្រីកដើម្បីធានាឲ្យប្រព័ន្ធសុខាភិបាលនៅថ្នាក់ប្រតិបត្តិមានដំណើរការកាន់តែប្រសើរឡើង។ (៩)សំខាន់ជាងនេះទៀត ទិសដៅនិងគោលនយោបាយជាយុទ្ធសាស្ត្រ ដូចជាផែនការយុទ្ធសាស្ត្រសុខាភិបាលជំហាន២ ផែនទីផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយមរណៈភាពមាតានិងទារក យុទ្ធសាស្ត្រសម្រាប់ការរស់រានរបស់កុមារ យុទ្ធសាស្ត្រអាហារូបឧបត្ថម្ភ។ល។ ត្រូវបានដាក់ឲ្យប្រើប្រាស់។ (១០)ការបន្តមាននូវភាពប្រសើរឡើងនៃសុខដុមនីយកម្មនិងការដាក់តំរូវតាមបរិបទប្រទេសតាមរយៈយន្តការដូចជា ក្រុមការងារបច្ចេកទេសសុខាភិបាល ក្រុមការងារបច្ចេកទេសសុខាភិបាលថ្នាក់ខេត្ត និងផែនការប្រតិបត្តិប្រចាំ ជាដើម។

ទោះជាបែបនេះក្តី អង្គការម៉េឌីខាំ និងសមាជិករបស់ខ្លួនសូមស្នើឲ្យអ្នករៀបចំគោលនយោបាយ និងដៃគូអភិវឌ្ឍន៍សុខាភិបាលទាំងអស់យកចិត្តទុកដាក់លើបញ្ហាប្រឈមដែលកំពុងតែបន្តមាន និងអនុសាសន៍នានា ដែលគួរត្រូវបានដោះស្រាយដើម្បីបន្តសម្រេចបាននូវលទ្ធផលប្រកបដោយនិរន្តភាពបន្ថែមទៀត។

៣. បញ្ហានិងអនុសាសន៍សំខាន់ៗ

ក-សុខភាពបន្តពូជ សុខភាពមាតា ទារកនិងកុមារ

មហាសន្និបាតជាតិសុខាភិបាលលើកទី៣២ និងការពិនិត្យរួមគ្នាលើសមិទ្ធផលសុខាភិបាលប្រចាំឆ្នាំលើកទី៩ កាលពីថ្ងៃទី១៤-១៥ ខែមីនា ឆ្នាំ២០១១ បានបង្ហាញពីការរីកចំរើនគួរឲ្យកត់សំគាល់មួយចំនួនក្នុងផ្នែកសុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ ដូចជាកំនើននៃការសំរាលកូនដោយគ្រូពេទ្យជំនាញ (៦៩,៦%) [69] កំនើននៃការសំរាលកូននៅមូលដ្ឋានសុខាភិបាល (៥២%) កំនើននៃការមកពិនិត្យផ្ទៃពោះលើកទីពីរ (៧២%) និងកំនើននៃការប្រើប្រាស់ មធ្យោបាយពន្យារកំណើតទំនើបនៅក្នុងចំណោមស្ត្រីរៀបការពីអាយុ១៥-៤៩ឆ្នាំ (៣៥%)[70]។ ជាងនេះទៀត ការរកឃើញបឋមនៃអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១០ បានបង្ហាញពីការធ្លាក់ចុះជាង៥០% នៃអត្រាស្លាប់របស់កុមារចាប់ពីឆ្នាំ២០០០ ដល់

[69] ក្រសួងសុខាភិបាល. The 32nd National Health Congress and the 9th Joint Annual Performance Review 2011.

[70] ក្រសួងផែនការ និងក្រសួងសុខាភិបាល. Cambodia Demographic and Health Survey 2010, Preliminary Report.

ឆ្នាំ២០១០ ដែលប្រការនេះមានន័យថាកំពុងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៤ របស់កម្ពុជាសម្រាប់ឆ្នាំ២០១៤ (សូមមើលរូបភាពទី១)។ បច្ចុប្បន្ននេះ អត្រាស្លាប់របស់ទារកគឺ ៤៥នាក់ ក្នុង១០០០កំណើតរស់ ខណៈដែលអត្រាស្លាប់របស់កុមារក្រោមអាយុ៥ឆ្នាំគឺ ៥៤នាក់ ក្នុង១០០០កំណើតរស់។

ការកាត់បន្ថយបាននូវអត្រាស្លាប់របស់កុមារខាងលើនេះ បានបង្ហាញនូវការពន្លឿនការប្តេជ្ញាចិត្តផ្នែកគោលនយោបាយ ការបង្កើនការវិនិយោគផ្នែកហិរញ្ញវត្ថុទាំងពីរាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍សុខាភិបាលនានា ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកសុខាភិបាលនៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៅក្នុងប្រព័ន្ធសុខាភិបាល ដើម្បីធ្វើឲ្យសុខភាពទារក/កុមារមានភាពប្រសើរឡើង។ យ៉ាងណាក្តី ខណៈដែលកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍ជាតិសម្រាប់ឆ្នាំ ២០១៥ អត្រាមរណភាពរបស់កុមារនៅតែមានកម្រិតខ្ពស់មិនអាចទទួលយកបានដដែល បើប្រៀបធៀបជាមួយប្រទេសជិតខាងនៅក្នុងតំបន់។



បញ្ហាគន្លឹះស្តីពីសុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ

១- ការអនុវត្តនបទអន្តរាគមន៍អាទិភាពដើម្បីសម្រេចបានលទ្ធផលខ្ពស់ នៅតែជាបញ្ហាប្រឈមចំបង

ទោះបីជាមានវឌ្ឍនភាពដូចដែលបានបង្ហាញខាងលើក្តី អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងបំពេញការងារផ្នែកសុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ បានបង្ហាញពីវិស័យជាអាទិភាពសំខាន់ៗខ្លះ ដែលគួរតែមានការឆ្លើយតបដើម្បីបន្តពង្រឹងការផ្តល់សេវាសុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ។ វិស័យជាអាទិភាពទាំងនេះរួមមាន៖ (១)សង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារក (២)ការរំលូតកូនដោយសុវត្ថិភាព និង (៣)ការថែទាំទារកក្រោយសំរាល និងអាហារូបត្ថម្ភ។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាព ក៏បានយល់ស្របផងដែរទៅលើអាទិភាពសំខាន់ៗដទៃទៀត ដែលទាមទារឲ្យមានភាពប្រសើរឡើងដូចជា៖ ការពិនិត្យផ្ទៃពោះមុនសំរាល/ការថែទាំក្រោយសំរាល ផែនការគ្រួសារ ជាពិសេសការលើកកម្ពស់វិធីសាស្ត្រពន្យាកំណើតរយៈពេលវែងនិងអចិន្ត្រៃយ៍ ការសំរាលដោយបុគ្គលិកសុខាភិបាល ការកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន សមាហរណកម្មទទួលបន្ទុកពិនិត្យព្យាបាលកុមារជំងឺកុមារនៅសហគមន៍ សុខភាពមនុស្សវ័យជំទង់យុវវ័យនិងសិទ្ធិនិងការរួមភេទ ដែលត្រូវបានរំលេចនៅក្នុងផែនទីចង្អុលផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាស្លាប់របស់ម្តាយនិងទារក និងយុទ្ធសាស្ត្រគោលសម្រាប់ការរស់រានរបស់កុមាររបស់ក្រសួងសុខាភិបាល។ ទោះជាបែបនេះក្តី បញ្ហាប្រឈមនៅត្រង់ថាតើត្រូវជំរុញការអនុវត្តបទអន្តរាគមន៍ដែលផ្តល់លទ្ធផលខ្ពស់នេះ យ៉ាងដូចម្តេច ដើម្បីកាត់បន្ថយអត្រាស្លាប់របស់មាតា និងកុមារអាយុក្រោម៥ឆ្នាំ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ទី៤ និងទី៥ នៅត្រឹមកាលកំណត់ឆ្នាំ២០១៥ ខាងមុខនេះ។

២- បុព្វហេតុរួមនៃមរណភាពមាតា

ស្ត្រីមានផ្ទៃពោះភាគច្រើនស្លាប់ដោយផលវិបាកក្នុងពេលមានផ្ទៃពោះ (ការធ្លាក់ឈាម ក្រឡាផ្លើង ការពន្យារពេល និងការលំបាកក្នុងពេលសំរាល) ការក្លាយរោគជុំវិញការសំរាល ការថែទាំក្រោយសំរាលពុំបានត្រឹមត្រូវ ការរំលូតកូនគ្មាន

សុវត្ថិភាព ឬការថែទាំក្រោយការរំលូតពុំបានត្រឹមត្រូវ (សូមមើលតារាងទី១)[71] ។ បុព្វហេតុនៃការស្លាប់របស់មាតាទាំងនេះ ក្លាយទៅជារឿងធម្មតាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ហើយមានភាពស្រដៀងគ្នាទៅនឹងការប៉ាន់ស្មានជាសាកលថ្មីអំពីបុព្វហេតុនៃការស្លាប់របស់មាតា ដូចដែលបានរាយការណ៍នៅក្នុងរបាយការណ៍របស់អង្គការសុខភាពពិភពលោក និងអង្គការយូនីសេហ្វឆ្នាំ២០១០ ដែលក្នុងនោះ ការធ្លាក់ឈាម និងក្រឡាភ្លើង គឺជាបុព្វហេតុឈានមុខគេនៃការស្លាប់របស់មាតា ដែលបុព្វហេតុទាំងពីរនេះទទួលខុសត្រូវលើ ៣៥% និង ១៨% រៀងគ្នានៃការស្លាប់ ហើយការក្លាយរោគ(សិបស៊ិស) មាន៩ % ការរំលូតមាន៨% និងបុព្វហេតុផ្ទាល់និងមិនផ្ទាល់មាន ២៩% (សូមមើលតួលេខខាងក្រោម)[72]។

តារាង១៖ បុព្វហេតុសំខាន់ៗនៃការស្លាប់របស់មាតា(%)

	2005 (n=50)	2006 (n=55)	2007 (n=86)	2008 (n=101)	2009 (n=104)
Hemorrhage	54	47	47	59	49
Eclampsia	18	9	16	11	8
Infection	6	18	10	3	6
Abortion	6	7	8	3	4
Uterus rupture	4	4	1	5	6
Others	12	15	18	20	27

ប្រភព៖ មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក។ សវនកម្មមរណភាពមាតា២០០៥-២០០៩។

ការប៉ាន់ប្រមាណសកលអំពីបុព្វហេតុនៃការស្លាប់របស់មាតា ២០០៧-២០១០



ប្រភព៖ អង្គការសុខភាពពិភពលោក និងអង្គការយូនីសេហ្វ។ ទស្សវត្សរ៍នៃរបាយការណ៍ខិតមកជិតឆ្នាំ២០១៥ (២០០០-២០១០)៖ ការលុបបំបាត់នូវមរណភាពមាតានិងទារក និងការរស់រានរបស់កុមារ ២០១០។

[71] Tung Rathavy. Maternal mortality in Cambodia. Handout distributed during the launch of maternal death durveillance and fast track initiative 2010.

[72] The World Health Organization and the UNICEF. Countdown to 2015 decade report (2000-2010): taking stock of maternal, newborn and child survival 2010.

៣-ស្ថានភាពពិតប្រាកដស្តីពីការលំបាកពេលពរពោះនិងការសំរាល

នៅពេលស្ត្រីធ្លាក់ឈាម គាត់ត្រូវការភ្លាមៗនូវសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពដើម្បីជួយសង្គ្រោះជីវិតរបស់គាត់។ ជាក់ស្តែង ការទទួលបាននូវសេវាទាំងនេះសម្រាប់ស្ត្រីក្រីក្រម្នាក់ស្ទើរតែមិនអាចធ្វើទៅបានទេ។ គាត់រស់នៅឆ្ងាយពីមូលដ្ឋានសុខាភិបាល ហើយប្រព័ន្ធបញ្ជូនពុំសូវដំណើរការល្អនៅតាមតំបន់ជាច្រើននៅទូទាំងប្រទេស។ ស្ថិតនៅក្នុងស្ថានភាពទាំងអស់នេះ ស្ត្រីជាច្រើនស្លាប់នៅផ្ទះ ឬតាមផ្លូវទៅកាន់មូលដ្ឋានសុខាភិបាល។ ជាងនេះទៀត មានការសង្កេតឃើញថា ស្ត្រីជាច្រើនក៏ស្លាប់នៅពេលទៅដល់មន្ទីរពេទ្យដែរ ខណៈដែលបុគ្គលិកសុខាភិបាលពុំបានយកចិត្តទុកដាក់មើលពួកគាត់ឲ្យបានទាន់ពេលវេលា ដោយសារតែពួកគាត់ពុំមានលទ្ធភាពបង់សេវាផ្នែកសង្គ្រោះបន្ទាន់ (របាំងហិរញ្ញវត្ថុដ៏ធំសម្រាប់ស្ត្រីក្រីក្រ) ឬពុំមានសេវាផ្នែកនេះ ឬកំហុសបច្ចេកទេសរបស់ដោយបុគ្គលិកពេទ្យដែលជំនាញ/បទពិសោធន៍របស់គាត់នៅមានកម្រិត។

៤-បញ្ហាជុំវិញប្រព័ន្ធបញ្ជូន

ជារឿយៗ ការបញ្ជូនស្ត្រីមានផ្ទៃពោះដែលជួបបញ្ហាក្នុងពេលសំរាល ពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែកតែងតែមានការពន្យារពេល។ ផ្អែកតាមការសង្កេតរបស់អង្គការមិនមែនរដ្ឋាភិបាលធ្វើការងារផ្នែកសុខភាពនៅមូលដ្ឋាន ការពន្យារពេលនេះសំខាន់បណ្តាលមកពីឆ្មបនៅមណ្ឌលសុខភាពពុំមានជំនាញគ្រប់គ្រាន់ ទំនាក់ទំនងរវាងឆ្មបនៅមណ្ឌលសុខភាពនិងឆ្មបនៅមន្ទីរពេទ្យបង្អែក ឬក៏ប្រាក់លើកទឹកចិត្ត (១៥ដុល្លារ) ផ្តល់ឲ្យឆ្មបនៅតាមមណ្ឌលសុខភាព ដែលធ្វើឲ្យពួកគាត់ខិតខំប្រឹងប្រែងរហូតដល់ជួនកាលធ្វើឲ្យហួសពេលក្នុងការបញ្ជូនចំពោះករណីធ្ងន់ធ្ងរ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបាននឹងកំពុងឆ្លើយតបចំពោះបញ្ហាទាំងនេះ ដោយបង្កើនកម្រិតជំនាញរបស់គេ និងផ្តល់លេខទូរស័ព្ទទាន់ហេតុការណ៍នៅតាមមន្ទីរពេទ្យបង្អែក ដើម្បីងាយស្រួលពិគ្រោះយោបល់អំពីបញ្ហាផ្សេងៗជាមួយនឹងអ្នកផ្តល់សេវានៅតាមមន្ទីរពេទ្យបង្អែក មុននឹងករណីត្រូវបានបញ្ជូន។ ចំពោះបញ្ហាទំនាក់ទំនងរវាងឆ្មបនៅមណ្ឌលសុខភាពនិងនៅមន្ទីរពេទ្យបង្អែក អង្គការមិនមែនរដ្ឋាភិបាល តែងតែជួយរៀបចំជាទៀងទាត់នូវកិច្ចប្រជុំក្រុមសម្ព័ន្ធសម្របសម្រួលឆ្មប (យន្តការរៀបចំ និងអនុម័តដោយមជ្ឈមណ្ឌលជាតិសុខភាពមាតានិងទារក) ដើម្បីដោះស្រាយបញ្ហានៅនឹងកន្លែង។ ជាងនេះទៀត អង្គការទាំងនោះបានផ្តល់នូវប្រាក់លើកទឹកចិត្តដល់ឆ្មបដែលបានបញ្ជូនស្ត្រីមានផ្ទៃពោះ ដែលមានសញ្ញាគ្រោះថ្នាក់ មកកាន់មន្ទីរពេទ្យបង្អែកទាន់ពេលវេលា។

៥-បញ្ហាជុំវិញការរំលូត និងផែនការគ្រួសារ

ការរំលូតគ្មានសុវត្ថិភាពនៅតែបន្តជាឃាតកលាក់មុខដែលសម្លាប់ស្ត្រីវ័យក្មេងនៅកម្ពុជា។ ទោះជាអត្រាប្រ៉ាវ៉ាឡង់នៃការពន្យារកំណើតមានការរីកចំរើនក្តី កង្វះនូវជម្រើសផែនការគ្រួសាររយៈពេលវែង និងអចិន្ត្រៃយ៍ជាច្រើន ដូចជា កងដាក់ក្នុងស្បូន កងដាក់ដៃ ការវះកាត់ចងបំពង់មេជីវិតញី ការវះកាត់ចងបំពង់មេជីវិតឈ្មោល និងជាមួយនឹងការមានតែថ្នាំពន្យារកំណើតនិងស្រោមអនាម័យដ៏ច្រើនសន្ធឹកសន្ធាប់ បណ្តាលឲ្យមានការបរាជ័យនិងការឈប់ប្រើប្រាស់ច្រើននូវការពន្យារកំណើត។



ក្រុមស្ត្រីទាំងនេះ និងស្ត្រីវ័យក្មេងដទៃទៀតជាច្រើនប្រឈមនឹងការមានផ្ទៃពោះដោយឥតចង់បាន ហើយជាធម្មតាគេដោះស្រាយបញ្ហានេះដោយការប្រើថ្នាំរំលូត។ ការសិក្សារបស់អង្គការសុខភាពប្រជាជនអន្តរជាតិ បានបង្ហាញនូវតួលេខស្រដៀងគ្នានេះថា ៣០%[73] នៃស្ត្រីបម្រើនៅតាមសេវាកំសាន្ត រាយការណ៍ថាមានការប្រើថ្នាំរំលូតក្នុងឆ្នាំមុន ដោយសារការមានផ្ទៃពោះពុំចង់បាន។ ទំហំនៃការរំលូតហាក់ស្ថិតនៅក្នុងស្ថានភាពអាក្រក់តែលាក់កំបាំងនៅឡើយ ហើយការឆ្លើយតបនៅមានកម្រិត និងមានការយល់ដឹងតិចតួចនៅឡើយសអំពីច្បាប់ស្តីពីការរំលូតកូន ដូចដែលបានលើកឡើងដោយការសិក្សាថ្មីមួយរបស់អង្គការសុខភាពប្រជាជនអន្តរជាតិថា ៨០% [74] នៃអ្នកមករកសេវារំលូតគិតថា ពួកគេកំពុងធ្វើអ្វីមួយផ្ទុយនឹងច្បាប់។ ជាការគួរឲ្យសោកស្តាយ ដែលការព្រងើយកន្តើយអំពីការរំលូតមានកម្រិតខ្ពស់ ហើយវត្តមានដ៏ច្រើននៃអ្នកផ្តល់សេវារំលូតដែលគ្មានគុណវុឌ្ឍិនៅតែបន្ត។ ការគ្របដណ្តប់នៃគ្លីនិកដែលមានការអនុញ្ញាតស្របច្បាប់ និងបុគ្គលិករំលូតដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ នៅមានកម្រិតនិងមានតម្លៃថ្លៃ។ មានតែបុគ្គលិកនៅតាមមន្ទីរពេទ្យបង្អែកតែប៉ុណ្ណោះត្រូវបានបណ្តុះបណ្តាលអំពីការរំលូតតាមបែបវេជ្ជសាស្ត្រ ទោះបីជាវិធីសាស្ត្រនេះកំពុងមានប្រជាប្រិយភាពនៅកម្ពុជាក្តីហើយ ទាំងផលិតផលរំលូតមានច្បាប់ ទាំងពុំមានច្បាប់ កំពុងចរាចរយ៉ាងច្រើននៅតាមឱសថស្ថាននានានៅទូទាំងប្រទេស។ ផែនការគ្រួសារក្រោយពេលរំលូតនៅមានកម្រិត ហើយការព្រងើយកន្តើយ និងការរើសអើងសង្គមលើស្ត្រីនិងស្ត្រីវ័យក្មេងជាច្រើនតម្រូវឲ្យពួកគេទៅរកសេវាលួចលាក់ ឬសម្ងាត់ ដែលតែងតែបង្ករគ្រោះថ្នាក់ និងមិនមានការថែទាំត្រឹមត្រូវក្រោយពេលរំលូតជាដើម។



[73] 2010 Behavioral Survey on Condom use among Entertainment Workers with Sweethearts (PSI)

[74] អង្កេតដដែល ដែលធ្វើឡើងដោយ PSI

៦-សុខភាពទារកទើបនឹងកើត ទារក និងកុមារ

ការបណ្តុះបណ្តាលសមាហរណកម្មទទួលបន្ទុកពិនិត្យព្យាបាលជំងឺកុមារ នៅសហគមន៍នៅតាមមណ្ឌលសុខភាព សម្រេចគោលដៅបាន ១០០% រួចហើយ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាសំខាន់ស្ថិតនៅលើការអនុវត្តយុទ្ធសាស្ត្រនេះ។ ការថែទាំទារកទើបនឹងកើត និងអាហារូបត្ថម្ភ នៅតែជាអាទិភាពសំខាន់បំផុត។ លទ្ធផលអង្កេតបឋមនៃការអង្កេតប្រជាសាស្ត្រសុខភាពឆ្នាំ២០១០បានបង្ហាញអំពីការរីកចម្រើនយឺតលើផ្នែកនេះ។

អាហារូបត្ថម្ភគឺជាបញ្ហាចំបងមួយទៀត ដែលទាមទារឲ្យមានការឆ្លើយតបជាបន្ទាន់និងឲ្យបានសមស្រប ប្រយោជន៍ដើម្បីធ្វើឲ្យសុខភាពទារកនិងកុមារមានភាពប្រសើរឡើង។ ទោះបីជាការលើកកម្ពស់ការតាមដានការរីកលូតលាស់ត្រូវបានទទួលស្គាល់ជាវិធីសាស្ត្រមូលដ្ឋានជាសកលក្នុងការកំណត់អំពីបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារក្តី ក៏វិធីសាស្ត្រនេះកម្រត្រូវបានអនុវត្តនៅតាមមណ្ឌលសុខភាពណាស់។ ការអង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១០ បានបង្ហាញពីប្រ៉ាំឡង់កម្រិតខ្ពស់នៃកង្វះអាហារូបត្ថម្ភ ដែលទាមទារចាំបាច់ឲ្យមានការផ្លាស់ប្តូរឥរិយាបទយ៉ាងសំខាន់ក្នុងការថែទាំកុមារ ទាំងក្នុងចំណោមមាតាបិតានិងអ្នកផ្តល់សេវាសុខភាព។



អនុសាសន៍ស្តីពីសុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ

១-សង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត និងប្រព័ន្ធបញ្ជូន

ជួយសង្គ្រោះជីវិតស្ត្រីទាមទារការធ្វើវិនិយោគធំមួយក្នុងការបង្កើតឲ្យមានប្រព័ន្ធបញ្ជូននានា ដែលមានប្រសិទ្ធភាពដោយរួមបញ្ចូលទាំង សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងការថែទាំទារកមូលដ្ឋាន ២៤ម៉ោង នៅតាមមូលដ្ឋានសុខាភិបាលនិងដោយពុំមានរបាំងហិរញ្ញវត្ថុ ឬការរើសអើងដល់ប្រជាជនក្រីក្រ ក្នុងការទទួលសេវាទាំងនេះពេលណាពួកគាត់ត្រូវការ។ នេះជាការទទួលខុសត្រូវរបស់រដ្ឋ ហើយរដ្ឋអាចធ្វើបាន។ បទពិសោធន៍នៅរដ្ឋតាមីលណាឌូ ប្រទេសឥណ្ឌា ដែលរដ្ឋនេះបានចុះកិច្ចសន្យាជាមួយនឹងវិស័យឯកជនឲ្យផ្តល់សេវាដឹកជញ្ជូនរហ័សដល់ស្ត្រីមានផ្ទៃពោះ ដែលត្រូវការសេវាសង្គ្រោះបន្ទាន់ គឺជាឧទាហរណ៍មួយដ៏ល្អដែលអាចសម្រេចបាននូវការងារខាងលើ។ នៅពេលដែលស្ត្រីមានផ្ទៃពោះត្រូវការមធ្យោបាយធ្វើដំណើរទៅទទួលសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព ពួកគាត់គ្រាន់តែទូរស័ព្ទទៅកាន់បញ្ជារទូរស័ព្ទឥតបង់ថ្លៃដើម្បីឲ្យអ្នកផ្តល់មធ្យោបាយធ្វើដំណើរ ឬគិលានសង្គ្រោះមកទទួលពួកគាត់ទៅមន្ទីរពេទ្យជាបន្ទាន់ ហើយខណៈដែលពួកគាត់ទៅដល់មូលដ្ឋានសុខាភិបាល សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងសេវាថែទាំទារកទើបនឹងកើត ចាំចាច់ត្រូវមាននៅទីនោះ ដោយពុំមានបញ្ហាចោទផ្នែកហិរញ្ញវត្ថុ។ រដ្ឋាភិបាលគួរធានាឲ្យមាននូវសេវា និងការទទួលបាននូវសេវាទាំងអស់នេះសម្រាប់ស្ត្រីទាំងអស់នៅកម្ពុជា។

២-ការបញ្ជូនករណីស្ត្រីមានផ្ទៃពោះដែលលំបាកសំរាល

សម្រាប់ការបញ្ជូនយឺតនៃស្ត្រីមានផ្ទៃពោះលំបាកសំរាលពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែក អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាព សំណូមពរឲ្យមានការពង្រីក និងការអនុវត្តបន្តនូវ៖ (១)ការប្រជុំក្រុមសម្ព័ន្ធភាពសម្របសម្រួលឆ្លប (២)ការផ្តល់ប្រាក់ឧបត្ថម្ភសមរម្យដល់ឆ្លបនៅមណ្ឌលសុខភាព សម្រាប់ការបញ្ជូនករណីលំបាកសំរាលទាំងឡាយទៅមន្ទីរពេទ្យបង្អែកទាន់ពេលវេលា (៣)បង្កើនជំនាញដល់ឆ្លបនៅមណ្ឌលសុខភាព (៤)គាំទ្រឲ្យមានលេខទូរស័ព្ទទាន់ហេតុការណ៍សម្រាប់ទំនាក់ទំនងរវាងមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក ដើម្បីធ្វើការពិគ្រោះយោបល់ជាមុន មុននឹងករណីត្រូវបញ្ជូន និង(៥)បង្កើតបន្ទប់បន្ថែមនៅតាមមណ្ឌលសុខភាពនានា សម្រាប់ធ្វើជាកន្លែងរង់ចាំនិងកន្លែងទទួលការថែទាំក្រោយសំរាលជាពិសេសនៅតាមតំបន់ដែលមានតម្រូវការខ្ពស់។

៣-ការរំលូត

ពង្រីកការផ្សព្វផ្សាយការយល់ដឹងអំពីច្បាប់ស្តីពីការរំលូតកូន និងធ្វើឲ្យប្រជាជនយល់ថាការរំលូតកូនពុំមែនជាការខុសច្បាប់ ដើម្បីឲ្យពួកគាត់អាចទៅរកកន្លែងរំលូតដែលមានសុវត្ថិភាព។

ពង្រីក និងធ្វើឲ្យប្រសើរឡើងនូវការបណ្តុះបណ្តាលជំនាញរំលូតដល់បុគ្គលិកថែទាំសុខភាព។ ទទួលស្គាល់ថាការរំលូតគ្មានសុវត្ថិភាពជាផ្នែកដែលទាមទារឲ្យមានការសិក្សា អន្តរាគមន៍ និងការគាំទ្របន្ថែម ប្រសិនបើរាជរដ្ឋាភិបាលតាំងចិត្តសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍ទី៥ និងស្នើសុំឲ្យមានការគាំទ្រពីដៃគូអភិវឌ្ឍន៍។

អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាព សូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ និងរាជរដ្ឋាភិបាល សូមបន្តជួយគាំទ្រផ្នែកសម្ភារៈសម្រាប់ផែនការគ្រួសារ។ ការសិក្សាជាច្រើនបានបង្ហាញថា កងដាក់ក្នុងស្បូន កងដាក់ដៃ និងវិធីពន្យារកំណើតរយៈពេលវែងដទៃទៀតមានប្រសិទ្ធភាពចំណាយ។ ដូច្នេះ វិធីសាស្ត្រទាំងអស់នេះគួរត្រូវបានលើកកម្ពស់ក្នុងការធ្វើឲ្យអត្រាប្រើវ៉ាឡង់ពន្យារកំណើតមានភាពប្រសើរឡើងនៅកម្ពុជា។

៤- សុខភាពទារក កុមារ និងអាហារូបត្ថម្ភ

បទអន្តរាគមន៍ការពារដើម្បីសុខភាពកុមារនិងទារក ដូចជាសមាហរណកម្មទទួលបន្ទុកពិនិត្យព្យាបាលជំងឺកុមារនៅសហគមន៍ សហគមន៍ស្រឡាញ់ទារក កំពុងត្រូវបានដាក់ឲ្យដំណើរការ ប៉ុន្តែការអនុវត្តកម្មវិធីទាំងអស់នេះកំពុងជួបបញ្ហាប្រឈមនៅឡើយ។ អាស្រ័យហេតុនេះហើយ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពស្នើសុំឲ្យមានការគាំទ្របន្ថែមដល់ការអនុវត្តកម្មវិធីខាងលើ។

ឧបករណ៍តាមដានការីកលូតលាស់គួរត្រូវយកមកប្រើប្រាស់ឲ្យបានទៀងទាត់ និងបុគ្គលិកសុខាភិបាលនៅមូលដ្ឋានសុខាភិបាលត្រូវធ្វើរបាយការណ៍អំពីការតាមដាននេះ ដើម្បីតាមដានអំពីស្ថានភាពអាហារូបត្ថម្ភរបស់ទារក/កុមារឲ្យបានជាប់លាប់។ ឥរិយាបទ/ការប្រព្រឹត្តបច្ចុប្បន្នរបស់បុគ្គលិកសុខាភិបាលគួរមានការកែប្រែឲ្យបានឆាប់ ប្រយោជន៍ដើម្បីឲ្យការថែទាំសុខភាពរបស់កុមារមានភាពប្រសើរឡើងប្រកបដោយគុណភាព។

អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាព ស្នើសុំឲ្យមានការឆ្លើយតបជាពហុវិស័យ ដើម្បីធ្វើឲ្យស្ថានភាពអាហារូបត្ថម្ភរបស់ទារក/កុមារ និងស្ត្រីមានផ្ទៃពោះបានប្រសើរឡើង។ ការប្តេជ្ញាចិត្តនិងឆន្ទៈនយោបាយរបស់ថ្នាក់លើ ពិតជាមានសារៈសំខាន់បំផុត ក្នុងការគៀរគរឲ្យមានការឆ្លើយតបពីក្រសួងពាក់ព័ន្ធដើម្បីកែលម្អអាហារូបត្ថម្ភ ហើយក៏ទាមទារផងដែរឲ្យមានការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ ដើម្បីជួយឲ្យចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្លាយមកជាការពិត។ ការផ្លាស់ប្តូរឥរិយាបទនៅតាមសហគមន៍ស្តីពីការប្រព្រឹត្តសមស្របនៅតាមផ្ទះ និងការលើកកម្ពស់សុខភាពពិតជាមានសារៈសំខាន់បំផុត និងគួរត្រូវបានពង្រឹងនិងពង្រីកបន្តទៀត។ ការបន្តការថែទាំមាតានិងទារក គួរត្រូវបានលើកកម្ពស់ដោយហេតុថាសុខភាពមាតាប៉ះពាល់ដល់សុខភាព ទារកក្នុងផ្ទៃនិងទារកទើបនឹងកើត។ ការធ្វើឲ្យរីកចម្រើនឡើងនូវបច្ចេកវិទ្យានិងជំនាញថែទាំទារកទើបនឹងកើត កំពុងមានតម្រូវការខ្លាំង និងគួរត្រូវបានធ្វើឲ្យប្រសើរឡើងនៅតាមមូលដ្ឋានសុខាភិ

បាលទាំងអស់ ជាមួយនឹងការធានាឲ្យបាននូវការទទួលសេវាដោយពុំមានរបាំងហិរញ្ញវត្ថុសម្រាប់អ្នកប្រើប្រាស់ ដើម្បីជួយកាត់ បន្ថយនូវអត្រាស្លាប់របស់ទារកនាពេលបច្ចុប្បន្ន។

ខ- ជំងឺឆ្លង

ការឆ្លើយតបចំពោះជំងឺអេដស៍និងមេរោគអេដស៍ក្នុងឆ្នាំកន្លងមកទទួលបានជោគជ័យគួរឲ្យកត់សំគាល់ពោលគឺ៖ (១)ទទួលបានការគ្របដណ្តប់ជាសកល ដោយអ្នករស់នៅជាមួយមេរោគអេដស៍ទទួលបានថ្នាំពន្យាជីវិត និងការព្យាបាលជំងឺឱកាសនិយម (ជាង៩០%)[75] និង (២)អត្រាប្រេវ៉ាឡង់អេដស៍នៅក្នុងចំណោមប្រជាជនទូទៅពីអាយុ១៥ឆ្នាំ ទៅ៤៩ឆ្នាំ មានតិចជាង១% ដែលជាលទ្ធផល អង្គការសហប្រជាជាតិបានផ្តល់រង្វាន់កិត្តិយសដល់ប្រទេសកម្ពុជាចំពោះការឆ្លើយតបការប្រយុទ្ធនឹងជំងឺអេដស៍បានជោគជ័យ។

បញ្ហាគន្លឹះស្តីពីជំងឺឆ្លង

១-ការរក្សាបាននូវនិរន្តភាពលទ្ធផល និងការគ្របដណ្តប់បាននូវគ្រប់អ្នករស់នៅជាមួយមេរោគអេដស៍

ប្រទេសកម្ពុជាអាចក្លាយជាអ្នករងគ្រោះចំពោះភាពជោគជ័យរបស់ខ្លួនស្តីពីការឆ្លើយតប ចំពោះជំងឺអេដស៍ និងមេរោគអេដស៍កន្លងមក។ នេះគឺដោយសារ មូលនិធិកន្លងមកបានផ្តោតការយកចិត្តទុកដាក់ខ្លាំងលើលទ្ធផលភ្លាមៗ ដែលនាំឲ្យកើតជាស្ថានភាពមួយដែលប្រព័ន្ធថែទាំសុខភាពនៅកម្ពុជា និងការឆ្លើយតបពហុវិស័យរបស់រាជរដ្ឋាភិបាល ពុំបានបំពាក់ឧបករណ៍ទាន់សម័យ និងពុំទាន់មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដែលអាចឆ្លើយតបចំពោះបញ្ហាខាងលើដោយខ្លួនឯងបាន។ ទាក់ទិននឹងការគ្របដណ្តប់ជាសកល អ្នករស់នៅជាមួយមេរោគអេដស៍នៅខេត្តមណ្ឌលគិរីនៅតែបន្តធ្វើដំណើរទៅទទួលថ្នាំពន្យារជីវិតនៅមណ្ឌលផ្តល់ថ្នាំនៅឯខេត្តស្ទឹងត្រែង។

២- មូលនិធិសកលដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ មេរោគអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់

ចក្ខុវិស័យរបស់មូលនិធិសកលនេះគឺ ការលើកកម្ពស់ភាពជាម្ចាស់របស់ប្រទេស និងអនុញ្ញាតឲ្យប្រទេសទាំងឡាយដឹកនាំកម្មវិធីមូលនិធិសកលដោយខ្លួនឯង។ ការបង្កើតឲ្យមានយន្តការសម្របសម្រួលប្រចាំប្រទេស គឺជាជំហានដ៏ល្អមួយក្នុងការផ្តល់អំណាចឲ្យប្រទេសទាំងនោះជាអ្នកដឹកនាំ តែយ៉ាងណាក្តី តួនាទីរបស់ភ្នាក់ងារមូលនិធិប្រចាំប្រទេសហាក់បីដូចជាផ្ទុយនឹងចក្ខុវិស័យខាងលើ ខណៈដែលភ្នាក់ងារមូលនិធិប្រចាំប្រទេស ដែលជាភ្នាក់ងារមានចំណងផ្លូវច្បាប់របស់មូលនិធិសកល ធ្វើការត្រួតពិនិត្យផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុស្តីពីការអនុវត្តមូលនិធិរបស់មូលនិធិសកលនៅតាមប្រទេស ហើយរាយការណ៍ផ្ទាល់ទៅលេខាធិការដ្ឋានរបស់មូលនិធិសកលទៅវិញ។ ការអនុវត្តបែបនេះពុំបានជូនដំណឹង ឬក៏សុំយោបល់ឬអនុសាសន៍ពីយន្តការសម្របសម្រួលប្រចាំប្រទេស ដែលជាយន្តការបង្កើតឡើងដើម្បីតំណាងឲ្យប្រទេសទាំងមូល និងដែនយុត្តាធិការគន្លឹះរបស់ខ្លួន ហើយជាអ្នកដែលយល់ច្បាស់នូវបរិបទសង្គម នយោបាយ វប្បធម៌ និងច្បាប់របស់ប្រទេសនោះ។ តួនាទីបច្ចុប្បន្នរបស់ភ្នាក់ងារមូលនិធិប្រចាំប្រទេស ហាក់កំពុងធ្វើឲ្យខូចនូវភាពជាម្ចាស់របស់ប្រទេស និងកំពុងធ្វើឲ្យតួនាទីរបស់យន្តការសម្របសម្រួលប្រចាំប្រទេសចុះខ្សោយថែមទៀតផង ជាពិសេសនៅពេលដែលភ្នាក់ងារមូលនិធិប្រចាំប្រទេសបំពេញតួនាទីក្នុងការចុះត្រួតពិនិត្យបច្ចេកទេសនៃការអនុវត្តកម្មវិធី ដោយពុំមានកិច្ចសហការជាមួយនឹងយន្តការសម្របសម្រួលប្រចាំប្រទេសអ្វីសោះ។

បញ្ហារួមដទៃទៀតរួមមាន៖ (១)ភាពស្មុគស្មាញ និងការផ្លាស់ប្តូរទម្រង់នៃការអភិរ្ឋន៍សំណើគម្រោង និងរបាយការណ៍ញឹកញាប់ពេក និង (២)គោលនោយបាយតឹងតែងពេក ឧទាហរណ៍ ទាក់ទងទៅនឹងលទ្ធកម្មថ្នាំពេទ្យ ដែលធ្វើឲ្យមូលនិធិពុំអាចចាយវាយបាន និងបង្ករឲ្យការពន្យារពេលក្នុងការអនុវត្តគម្រោងជាដើម។

[75] យោងតាម NCHADS website report 2010

៣-ការតំរូវឲ្យអ្នករស់នៅជាមួយមេរោគអេដស៍បង់លុយចំពោះសេវាសុខភាពផ្សេងៗទៀត

អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពដែលធ្វើការផ្នែកជំងឺអេដស៍និងមេរោគអេដស៍សង្កេតឃើញថា មូលដ្ឋានសុខភាពខ្លះបានយកលុយពីអ្នកផ្ទុកមេរោគអេដស៍ ខណៈដែលពួកគាត់ទៅពិគ្រោះនិងធ្វើតេស្តជំងឺផ្សេងៗដូចជា ការធ្វើតេស្តពិនិត្យថ្លើម ការពិនិត្យមុខងាររបស់ក្រលៀន ការថតកាំរស្មី និងការធ្វើតេសពិនិត្យរកមេរោគអេដស៍ជាដើម។ អ្នករស់នៅជាមួយមេរោគអេដស៍ខ្លះ នៅតែបន្តមានបញ្ហាក្នុងការទទួលបានសេវាព្យាបាលជំងឺឱកាសនិយម ដោយសារការមានកំណត់នៃម៉ោងធ្វើការរបស់គ្លីនិក ឬមូលដ្ឋានសុខាភិបាលផ្នែកជំងឺអេដស៍ទាំងនោះ និងការលំបាករបស់ពួកគេក្នុងការធ្វើដំណើរទៅកាន់មូលដ្ឋានសុខាភិបាលដែលបណ្តាលមកពីសោហ៊ុយក្នុងការធ្វើដំណើរជាដើម។

៤-ប្រ៉ាំឡង់ខ្ពស់នៃប្រជាជនប្រឈមនឹងគ្រោះថ្នាក់ខ្ពស់

ទោះបីជាប្រ៉ាំឡង់នៃមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅមានការថយចុះយ៉ាងច្រើនក្តី ក៏ចំនួនប្រជាជនប្រឈមនឹងគ្រោះថ្នាក់ខ្ពស់នៅតែមានកម្រិតខ្ពស់នៅឡើយដូចជា ស្ត្រីបម្រើសេវាកំសាន្ត ស្ត្រីបម្រើផ្លូវភេទនៅតាមផ្ទះបន (១៤%) បុរសស្រឡាញ់បុរស (៨,៧%) អ្នកប្រើប្រាស់ថ្នាំ (អាយឌីយូ ២៤,៤% និងមិនប្រើអាយយូឌី ១,១%)[76] ។ បច្ចុប្បន្ននេះការថែទាំនិងការការពារនៅតាមសហគមន៍ ពុំទាន់បានគ្របដណ្តប់ប្រជាជនប្រឈមគ្រោះថ្នាក់ខ្ពស់បានជាសកលនៅឡើយ ដែលប្រការនេះអាចនឹងនាំឲ្យមានរលកនៃការឆ្លងជំងឺអេដស៍ មេរោគអេដស៍ជាលើកទីពីរ។



FEW: Female Entertainment Worker more than 7 sexual partner per week in 2010 (HSS 2010)
MSM: Men who have Sex with Men (Source: NCHADS, 2007)
IDU: Injection Drug User (Source: NCHADS, 2007)
Non-IDU: Non-Injection Drug User (Source: NCHADS, 2007)

HIV Prevalence among FEW with More than 7 Clients per Week in 2010, Compared to FSW



FSW: Female sex worker
FEW: Female entertainment worker

[76] NCHADS HSS 2006 and 2005 STI Prevalence Survey

៥-ការគាំទ្ររបស់សង្គម

បទអន្តរាគមន៍ដល់ការរស់នៅរបស់អ្នករស់នៅជាមួយមេរោគអេដស៍ ពុំទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការធ្វើឲ្យជីវិតរបស់ពួកគេមានគុណភាពល្អប្រសើរ នឹងដែលអាចឲ្យពួកគេមានលទ្ធភាពទប់ទល់នឹងតម្លៃនៃការព្យាបាលយូរអង្វែងនៅឡើយ។

៦-ការលេបថ្នាំបានត្រឹមត្រូវតាមពេលវេលាកំណត់

ការឲ្យអ្នក រស់នៅជាមួយមេរោគអេដស៍ត្រឹមត្រឹមតាមពេលកំណត់ពិតជាមានសារៈសំខាន់បំផុត ពីព្រោះនៅប្រទេសកម្ពុជា ពុំទាន់មានការផ្តល់ថ្នាំពន្យារជីវិតខ្សែទី៣នៅឡើយទេ។ បច្ចុប្បន្ននេះ ៥% [77] នៃអ្នករស់នៅជាមួយមេរោគអេដស៍ ដែលកំពុងទទួលបានការព្យាបាល គឺស្ថិតនៅក្រោមការព្យាបាលដោយខ្សែទី២ ហើយពួកគាត់ពុំអាចមានជម្រើសអ្វីផ្សេងទៀតទេ ប្រសិនបើការព្យាបាលរបស់ពួកគាត់នៅខ្សែទី២ជួបបញ្ហា។

៧-បញ្ហាជំងឺរបេង ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម

ជំងឺរបេង

កម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមប្រទេស ២២ ដែលមានបន្ទុកជំងឺរបេងខ្ពស់។ ទោះបីជាអត្រាប៉ាន់ស្មានគ្រប់ទម្រង់ទាំងអស់នៃជំងឺរបេងមានការថយចុះពី ១.២២៥ ក្នុងប្រជាជន ១០០.០០០នាក់ ក្នុងឆ្នាំ១៩៩០ មកនៅត្រឹម ៦៩៣ ក្នុងប្រជាជន ១០០.០០០នាក់ នៅឆ្នាំ២០១០ (ទិសដៅសម្រាប់គោលដៅអភិវឌ្ឍន៍៖ ៦២៦/១០០.០០០នាក់) ដែលនេះគឺជាជោគជ័យដ៏សំខាន់មួយ ក៏អត្រាជំងឺរបេងនៅតែមានកម្រិតខ្ពស់មិនអាចទទួលយកបាន។ ទិន្នន័យដទៃទៀតដែលអនុញ្ញាតឲ្យមានការពិនិត្យមើលបានប្រសើរជាងមុននូវបន្ទុកជំងឺរបេងនៅកម្ពុជារួមមាន៖ (១)អត្រាអាំងស៊ីដង់ប៉ាន់ប្រមាណនៃគ្រប់ទម្រង់របស់ជំងឺរបេង (៤៩៥/១០០០០) (២)អត្រាអាំងស៊ីដង់ប៉ាន់ប្រមាណនៃកំហាករបេងវិជ្ជមាន (២១៩/១០០.០០០) (៣)អត្រាស្លាប់ប៉ាន់ប្រមាណដោយគ្រប់ទម្រង់នៃជំងឺរបេង (៨៩/១០០.០០០) និង (៤)មានអ្នកផ្ទុកមេរោគអេដស៍ ៦,៤% ក្នុងចំណោមប្រេ៉ាឡង់ជំងឺរបេង១០០នាក់[78]។

អង្គការមិនមែនរដ្ឋាភិបាលបំពេញការងារផ្នែកជំងឺរបេងនៅកម្ពុជា បានលើកឡើងនូវបញ្ហាប្រឈមដែលទាមទារការដោះស្រាយ រាប់បញ្ចូលទាំង ជំងឺរបេងអេដស៍ ភាពស៊ាំទៅនឹងថ្នាំច្រើនប្រភេទ ជំងឺរបេងមិនបានព្យាបាល និងកម្មករចំណាកស្រុកជាដើម។ យ៉ាងណាក្តី បញ្ហាធំៗដទៃទៀតនៃការប្រយុទ្ធនឹងជំងឺរបេងរួមមាន (១)វិស័យឯកជនដែលមានភាពអនាធិបតេយ្យនិងពុំមាននិយតកម្មត្រឹមត្រូវ ដែលគឺជាកន្លែងដែលប្រជាជនភាគច្រើនទៅប្រើប្រាស់ដោយពុំមានវេជ្ជបញ្ជាត្រឹមត្រូវ ពីគ្រូពេទ្យ ដែលប្រការនេះគឺជាមូលហេតុដ៏ចំបងសម្រាប់ពេលបច្ចុប្បន្ន/អនាគតដែលធ្វើឲ្យមានភាពស៊ាំទៅនឹងថ្នាំច្រើនប្រភេទ និង (២)មានតែ ២១,៦%ក្នុងចំណោមប្រជាជនទាំងអស់ប៉ុណ្ណោះបានទទួលសេវាថែទាំសុខភាពសាធារណៈដែលនេះមានន័យថា ភាគច្រើននៃប្រជាជនប្រើប្រាស់សេវានៅផ្ទះ ឬក៏ប្រើប្រាស់វិស័យឯកជនទាំងផ្លូវការ និងមិនផ្លូវការជាដើម។ ប្រការនេះបង្ហាញថា បញ្ហាប្រឈមដែលទាមទារនូវដំណោះស្រាយ ដើម្បីឲ្យមានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរបេង គប្បីគួរមើឲ្យហួសពីវិស័យសាធារណៈទៀត។

ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម

នៅក្នុងឆ្នាំ២០១០ ករណីថ្មីជំងឺគ្រុនចាញ់មាន ៤០៧ករណី ក្នុងចំណោមប្រជាជន១០០.០០០នាក់ ហើយក្នុងនោះ ១៣៥នាក់ បានស្លាប់។

[77] វេបសាយ NCHADS

[78] របាយការណ៍ WHO ឆ្នាំ២០១០

- ទោះបីជាអត្រាប្រេវ៉ាឡង់នៃជំងឺគ្រុនចាញ់មានការថយចុះក្នុងរយៈពេល១០ឆ្នាំ កន្លងមកនេះក្តីបញ្ហានៅតែមានដដែល ដោយបណ្តាលមកពី (១)ការវិវឌ្ឍននៃភាពស៊ាំថ្នាំច្រើនប្រភេទ (២)ការធ្វើចំណាកស្រុក/ការចល័តរបស់ប្រជាជន (៣)បញ្ហានៃវិស័យឯកជន (ការប្រើប្រាស់ច្រើន ប៉ុន្តែពុំមានច្បាប់គ្រប់គ្រង ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ច្រើនដូចជា ករណីឱសថក្លែងក្លាយជាដើម ។ល។)។
- ការធ្វើលទ្ធកម្មនៃថ្នាំព្យាបាលជំងឺគ្រុនចាញ់ប្រកបដោយប្រសិទ្ធផល ចុងក្រោយបំផុត (ACT ដោយថ្នាំអាតេស៊ូណាត និងថ្នាំផ្សេងទៀត) តាមរយៈមូលនិធិសកលមានការពិបាក ដោយសារតែភាពស្មុគស្មាញនៃតម្រូវការរបស់មូលនិធិសកលដូចជាដំណើរការនិយតកម្មមូលនិធិសកលមានភាពរឹតត្បិត។
- ជំងឺគ្រុនឈាម នៅតែជាបញ្ហាប្រឈមយ៉ាងធំនៅកម្ពុជា ប៉ុន្តែមូលនិធិសម្រាប់ប្រយុទ្ធនឹងជំងឺនេះនៅមានកម្រិតតិច។

អនុសាសន៍សម្រាប់ជំងឺឆ្លង

- ការលើកកម្ពស់ភាពជាម្ចាស់របស់ប្រទេសទាមទារឲ្យ មូលនិធិសកលមានអានុភាពលើតួនាទីរបស់យន្តការសម្របសម្រួលប្រចាំប្រទេស ក្នុងការពិនិត្យមើលការអនុវត្តគម្រោងមូលនិធិ ដែលប្រការនេះទាមទាឲ្យមានធនធានបន្ថែមសម្រាប់ដំណើរការយន្តសម្របសម្រួលនេះ ហើយលេខាធិការដ្ឋានរបស់មូលនិធិសកល គួរតែមានបណ្តាញទំនាក់ទំនងផ្លូវការមួយ សម្រាប់ពិនិត្យការអនុវត្តគម្រោងមូលនិធិរបស់ប្រទេស ដែលការងារនេះគួរត្រូវបានបំពេញដោយយន្តការសម្របសម្រួលប្រចាំប្រទេស។ ភ្នាក់ងារមូលនិធិប្រចាំប្រទេសគួរបន្តធ្វើកិច្ចការរបស់ខ្លួនដដែលប៉ុន្តែសង្កត់ធ្ងន់លើការត្រួតពិនិត្យ ផ្នែកហិរញ្ញវត្ថុ ហើយការិយាល័យទទួលជំនួយផ្ទាល់ពីមូលនិធិសកល ផ្តោតលើផ្នែកបច្ចេកទេសនៃកម្មវិធីវិញ។ ទាំងភ្នាក់ងារ មូលនិធិសកលប្រចាំប្រទេស ទាំងការិយាល័យទទួលជំនួយផ្ទាល់ពីមូលនិធិសកល គួរបំពេញការងារក្រោមការអភិបាលរបស់យន្តការសម្របសម្រួលមូលនិធិសកលប្រចាំប្រទេស ដើម្បីធានាឲ្យបាននូវភាពជាម្ចាស់របស់ប្រទេស និងគណនេយ្យ ភាព។
- ប្រទេសកម្ពុជានៅតែបន្តត្រូវការការគាំទ្រយូរអង្វែង ដើម្បីរក្សានូវជោគជ័យក្នុងការឆ្លើយតបចំពោះមេរោគអេដស៍ជំងឺអេដស៍នៅកម្ពុជា។ យ៉ាងនេះក្តី ការគាំទ្រផ្នែកហិរញ្ញវត្ថុគួរតែផ្តោតគោលដៅបន្ថែមទៀត ដើម្បីកសាងប្រព័ន្ធថែទាំសុខភាពមួយដែលរឹងមាំ ដែលអាចមានលទ្ធភាពទ្រទ្រង់នឹងឆ្លើយតបចំពោះបញ្ហាដោយខ្លួនឯងបាន។
- អ្នករស់នៅជាមួយ មេរោគអេដស៍គួរទទួលបានគ្រប់ការព្យាបាល និងតំរូវការផ្នែកពិសោធន៍ដោយឥតបង់ថ្លៃ។
- សោហ៊ុយធ្វើដំណើរគួរត្រូវបានផ្តល់ជូនដល់អ្នករស់នៅជាមួយមេរោគអេដស៍ ដើម្បីធានាឲ្យពួកគាត់មកទទួលការព្យាបាលដោយទៀងទាត់។
- សេវាព្យាបាលមេរោគអេដស៍ ជំងឺអេដស៍ សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍គួរតែមាន ២៤ម៉ោង។
- ការពន្យារជីវិតដល់អ្នករស់នៅជាមួយមេរោគអេដស៍ ពិតជាមានភាពចាំបាច់និងសំខាន់បំផុត ប៉ុន្តែការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅ និងគុណភាពជីវិត របស់គាត់ក៏មានសារៈសំខាន់ដូចគ្នាសម្រាប់ពួកគាត់អាចរស់នៅបាន។
- បង្កើតការងារសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍ និងគ្រួសាររបស់គាត់ ដើម្បីឲ្យពួកគាត់ក្លាយជាសមាជិកដែលអាចផ្តល់ផលប្រយោជន៍ដល់សង្គមដូចមនុស្សទូទៅដែរ។
- ពង្រឹងការការពារ និងការថែទាំនៅតាមសហគមន៍ ជាពិសេសក្នុងចំណោមប្រជាជនប្រឈមគ្រោះថ្នាក់ខ្ពស់គឺចាំបាច់ក្នុងការគ្រប់គ្រងឲ្យបាននូវការរីករាលដាលរបស់ជំងឺ ហើយក៏មានតម្រូវការវិភាជន៍ធនធានហិរញ្ញវត្ថុសម្រាប់ផ្នែកនេះដើម្បីឲ្យប្រជាជនដែលមានសុខភាពល្អនៅតែមានសុខភាពល្អបន្តទៀត។
- រៀបចំអភិក្រមពេញលេញ ដើម្បីធានាការលេបថ្នាំបានត្រឹមត្រូវតាមពេលវេលាកំណត់ ការព្យាបាលដោយថ្នាំពន្យារជីវិត ដោយយកចិត្តទុកដាក់ចំពោះកត្តាមិនមែនសុខភាពទាំងឡាយដូចជា ស្ថានភាពសេដ្ឋកិច្ច និងផ្លូវចិត្ត និងសង្គមរបស់អ្នកជំងឺជាដើម។

- ការផ្តល់នូវសេវាថែទាំសុខភាពនានា ដោយឥតបង់ថ្លៃនៅគ្រប់មូលដ្ឋានសុខភាពសាធារណៈទាំងអស់ សម្រាប់ករណីសង្ស័យរបេងនិងអ្នកជំងឺរបេង គឺជាការចាំបាច់។
- អ្នកជំងឺរបេងនិងករណីសង្ស័យរបេងគួរមានការគាំទ្រសោហ៊ុយ ធ្វើដំណើរ។
- បង្កើនការគាំទ្រដល់ការការពារនិងថែទាំសុខភាពសហគមន៍សម្រាប់ជំងឺរបេង ជាពិសេសក្រុមប្រជាជនប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ (អ្នកក្រីក្រនៅតាមទីក្រុងនិងជនបទ អ្នកទោស ការតាមដានរកអ្នកជំងឺរបេង ជាដើម)។
- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមតួអង្គពាក់ព័ន្ធនានា ដើម្បីដោះស្រាយការចំលងមេរោគរបេងអេដស៍ និងអ្នកជំងឺរបេងពុំបានទៅព្យាបាល។
- ត្រូវការឲ្យមានភ័ស្តុតាងបន្ថែម ដើម្បីធ្វើឲ្យប្រសើរឡើងនូវបទអន្តរាគមន៍លើភាពស៊ាំដោយថ្នាំច្រើនប្រភេទ និងជំងឺរបេងក្នុងចំណោមប្រជាជនចំណាកស្រុកនិងប្រជាជនចល័ត។
- ត្រូវការឲ្យមានអភិក្រមពហុវិស័យ រាប់បញ្ចូលទាំងវិស័យមិនមែនសុខភាពនានា ដើម្បីឆ្លើយតបនឹងភាពស៊ាំថ្នាំគ្រុនចាញ់ច្រើនប្រភេទ និងប្រជាជនចំណាកស្រុក និងប្រជាជនចល័ត។
- មូលនិធិសកល គួរចេញនូវលិខិតគាំទ្រស្តីពីលទ្ធកម្មដើម្បីទិញឱសថព្យាបាលរួមផ្សំនិងអាតេមីស៊ូណាត ដែលផ្តល់អនុសាសន៍ដោយអង្គការសុខភាពពិភពលោក និងដែលជាផ្នែកមួយនៃសេចក្តីណែនាំការព្យាបាលតាមកម្មវិធីជាតិ។ បើពុំដច្នោះទេ ប្រទេសកម្ពុជាគួរស្វែងរកម្ចាស់ជំនួយមួយ ដែលនិយតកម្មរបស់គេពុំសូវ រឹតត្បិត ហើយដែលមានឆន្ទៈក្នុងការគាំទ្រនូវប្រសិទ្ធផលឱសថព្យាបាលរួមផ្សំនិងអាតេមីស៊ូណាតនៅកម្ពុជា។
- ត្រូវការឲ្យ មានមូលនិធិបន្ថែម សម្រាប់អនុវត្តបទអន្តរាគមន៍តាមសហគមន៍ដើម្បីឆ្លើយតបនឹងជំងឺគ្រុនឈាម។

គ-ជំងឺមិនឆ្លង

បញ្ហាគន្លឹះស្តីពីជំងឺមិនឆ្លងនៅកម្ពុជា

- ជំងឺមិនឆ្លងកំពុងតែមានការកើនឡើងនៅកម្ពុជា។ អង្គការសុខភាពពិភពលោកបានប៉ាន់ប្រមាណថា អត្រាស្លាប់ជាងពាក់កណ្តាល (៥៣%) នៅកម្ពុជា បណ្តាលមកពីជំងឺមិនឆ្លងរួមមាន ជំងឺបេះដូង ដែលជំងឺនេះរួមចំណែក ២៤% នៃការស្លាប់ (ឃាតករដ៏ចំបង) ជំងឺមហារីករួមចំណែក ៩% និង ៥% នៃការស្លាប់បណ្តាលមកពីការរងរបួស[79]។
- យោងតាម ការអង្កេតជាជំហានស្តីពីជំងឺមិនឆ្លងរបស់ក្រសួងសុខាភិបាលនិងអង្គការសុខភាពពិភពលោក នៅកម្ពុជាឆ្នាំ២០១០ ១,៤% នៃមនុស្សពេញវ័យមានជាតិស្ករមិនប្រក្រតី និង ២,៩% នៃអ្នកទាំងនោះលើសជាតិស្ករឬក្លាយទៅជាជំងឺទឹកនោមផ្អែម។ អត្រាប្រ៉ាវ៉ាឡង់នៃជំងឺលើសឈាមមាន ១១,២% ដែលក្នុងនោះ ៤/៥ ពុំបានធ្វើការព្យាបាលទេ។ ១/៥ នៃមនុស្សពេញវ័យមានជាតិកូឡេស្តេរ៉ូលឡើងខ្ពស់។ ការលើសទម្ងន់ ជំងឺធាត់លើសជាតិកូឡេស្តេរ៉ូល និងជំងឺទឹកនោមផ្អែម កើតមានច្រើនចំពោះស្ត្រី ខណៈដែលជំងឺលើសឈាមជារួមកើតច្រើនលើបុរស[80]។

[79] Age-standardized deaths from WHO global Health Observatory: http://apps.who.int/ghodata/?vid=100001

[80] MoH/WHO STEP Survey 2010



- ការធ្វើរោគវិនិច្ឆ័យថ្មីៗបានបង្ហាញថា ស្ត្រី ៣៣ក្នុង១០០.០០០នាក់ មានជំងឺមហារីកមាត់ស្បូន (ស្ត្រីអាយុពី ២៥ឆ្នាំឡើងទៅ)[81]។ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតបាន បញ្ជាក់ថា ជំងឺមហារីកមាត់ស្បូន និងមហារីកដោះមានការឈានមុខគេនៅទីនោះ។



- មានទិន្នន័យតិចតួចអំពីព័ត៌មាន ស្តីពីអត្រាប្រ៉ាំឡង់បញ្ហាសុខភាពផ្លូវចិត្តមិនប្រក្រតីនៅកម្ពុជា ប៉ុន្តែទិន្នន័យនេះអាចខ្ពស់ ដោយផ្អែកទៅលើប្រវត្តិជំលោះ និងរបបប្រល័យពូជសាសន៍នៅក្នុងប្រទេស។ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតបានរាយការណ៍ថា មានអ្នកជំងឺប្រមាណពី ២០០ ទៅ ៣០០នាក់ មកពិគ្រោះយោបល់ស្តីពីសុខភាពផ្លូវចិត្តមិនប្រក្រតីក្នុងមួយថ្ងៃ។ ហើយភាពឆាប់ឆេវឆាវខុសប្រក្រតីគឺជាលទ្ធផលធម្មតាបំផុតនៃការធ្វើរោគវិនិច្ឆ័យ[82] ។ ចំនួនករណីសុខភាពផ្លូវចិត្ត ដែលត្រូវបានរាយការណ៍ដោយមូលដ្ឋាន សុខភាពសាធារណៈ បានកើនឡើងគួរឲ្យកត់សម្គាល់ពី ១៩.៨៥២ ករណីនៅក្នុងឆ្នាំ២០០៩ ទៅ ៥២.២៩៩ ករណីក្នុងឆ្នាំ២០១០[83]។
- អ្នកមានជំងឺមិនឆ្លងសភាពស្រួចស្រាល់ តែងតែឆ្លងកាត់ការបង់ប្រាក់ពីហោប៉ៅយ៉ាងច្រើន ទោះបីជាមូលនិធិសមធម៌បានគ្របដណ្តប់តម្លៃព្យាបាលជាមូលដ្ឋានពេលគាត់ចូលសំរាកពេទ្យក្តី។ អ្នកមានជំងឺមិនឆ្លងសភាពរ៉ាំរ៉ៃភាគច្រើនធ្វើការព្យាបាលដោយខ្លួនឯង ឬមិនធ្វើការព្យាបាលរហូតដល់ស្ថានភាពជំងឺសភាពធ្ងន់ធ្ងរ។ អ្នកជំងឺជាច្រើន ក្លាយជាក្រីក្រ បន្ទាប់ពីព្យាយាមរកការព្យាបាលដោយពេទ្យឯកជន ឬគ្រូថ្នាំបុរាណ ហើយភាគច្រើនបំផុតនៃ

[81] Health Sector Progress in 2010, MoH

[82] Addressing NCD and Injuries in Cambodia: An opportunity for intra and inter sectoral synergies, a world bank mission policy note, 30 May 2011.

[83] Health Sector Progress in 2010, MoH

អ្នកជំងឺទាំងនោះ ត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាស្ថិតនៅក្នុងកម្រិតធ្ងន់ធ្ងរបំផុត ដែលការព្យាបាលមានតម្លៃថ្លៃខ្លាំង និងអាចជាបន្ទុកថវិកា ដ៏សម្បើមសម្រាប់ឯអ្នកជំងឺ ក៏ដូចជាកម្រោងធានារ៉ាប់រងឯទៀត។

- ការព្យាបាលដោយបង់ថ្លៃបង្កជាគ្រោះថ្នាក់ធ្ងន់ធ្ងរមួយ ដែលបណ្តាលឲ្យអ្នកជំងឺរុាំរ៉ៃក្លាយជាអ្នកផ្តល់ប្រភពធនធានហិរញ្ញប្បទានដ៏ចំបងនិងអយុត្តធម៌ សម្រាប់ប្រព័ន្ធថែទាំសុខភាព ជំងឺស្រួចស្រាល់មួយ ដែលពុំមានមូលនិធិគ្រប់គ្រាន់។ ភាគច្រើននៃថវិការបស់កម្មវិធីទ្រទ្រង់វិស័យសុខាភិបាល ផ្តោតសំខាន់លើការធ្វើឲ្យប្រសើរនូវមូលដ្ឋានសុខាភិបាលសាធារណៈ ជាជាងការរៀបចំឲ្យមានគំរូការថែទាំសុខភាពបន្តពេញលេញ សម្រាប់អ្នកជំងឺមិនឆ្លង ដែលរួមបញ្ចូលទាំងសហគមន៍និងវិស័យឯកជនផងដែរ។ ជាលទ្ធផល អ្នកជំងឺមិនឆ្លង ជារឿយៗត្រូវបានជំរុញដោយពុំចាំបាច់ឲ្យទៅរកគ្លីនីក ដើម្បីទទួលបាននូវសេវារបស់វិស័យសាធារណៈ ដោយផ្អែកលើអភិក្រមមូលដ្ឋានសុខភាព ជំនួសឲ្យការផ្តោតលើតម្រូវការរបស់អ្នកជំងឺ ដោយផ្អែកលើអភិក្រមសហគមន៍។
- អ្នកផ្តល់សេវាសុខាភិបាល ផ្តោតលើការព្យាបាលជំងឺ ជាជាងការផ្សព្វផ្សាយការអប់រំអំពីសុខភាព និងវិធានការនៃការការពារ។ មានការគ្របដណ្តប់លើ អភិក្រមវេជ្ជសាស្ត្រក្នុងការឆ្លើយតបនឹងជំងឺមិនឆ្លងរុាំរ៉ៃ។ ការបណ្តុះបណ្តាលនិងការផ្តល់ប្រាក់លើកទឹកចិត្ត ត្រូវបានតម្រង់ ទិសចំពោះការព្យាបាលវេជ្ជសាស្ត្រ ជាជាងការការពារ ហើយអ្នកផ្តល់សេវាថែទាំសុខភាព ត្រូវបានបណ្តុះបណ្តាល ឲ្យក្លាយជាគ្រូពេទ្យឯកទេស ជាជាងគ្រូព្យាបាលទូទៅ។
- ជាងនេះទៀត គ្រូពេទ្យជំនាញភាគច្រើន ត្រូវបានបណ្តុះបណ្តាលជំនាញអំពីសុខភាពបន្តពូជ សុខភាពមាតា និងទារក និងជំងឺឆ្លង ប៉ុន្តែខ្វះជំនាញចាំបាច់សម្រាប់ព្យាបាលជំងឺរុាំរ៉ៃ។
- ឱសថសម្រាប់ជំងឺមិនឆ្លង ជារឿយៗពុំអាចរកបាន នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈទេ។

អនុសាសន៍ស្តីពីជំងឺមិនឆ្លង

- បង្កើនជាអតិប្បរមានូវការគាំទ្រហិរញ្ញវត្ថុ សម្រាប់ពង្រឹងការលើកកម្ពស់សុខភាព និងការការពារ ដើម្បីប្រយុទ្ធនឹងជំងឺមិនឆ្លង ដែលនេះជាបទអន្តរាគមន៍ត្រូវការឲ្យមានជាបន្ទាន់ ដើម្បីអាចទប់ស្កាត់កំណើននៃជំងឺមិនឆ្លង។
- ត្រូវការឲ្យមានឱសថសម្រាប់ជំងឺមិនឆ្លង នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដែលឱសថទាំងនោះគួរត្រូវបានផ្តល់ជូនប្រជាពលរដ្ឋក្រីក្រដោយឥតបង់ថ្លៃ។
- ប្តូរការងារឲ្យបានច្រើនតាមដែលអាចធ្វើទៅបានពីអភិក្រមមូលដ្ឋានសុខាភិបាល មកជាអភិក្រមសហគមន៍ ដោយរួមបញ្ចូលនូវស្ថ័យគ្រប់គ្រងដោយអ្នកជំងឺជំនាញ បុគ្គលិកសុខាភិបាល និងគិលានុប្បដ្ឋាយិកាមិនមែនជំនាញអាជីពគ្រូពេទ្យព្យាបាលទូទៅ ដោយផ្តោតលើបច្ចេកវិជ្ជាដែលមានតម្លៃថោក និងផ្សាភ្ជាប់ទៅនឹងមូលដ្ឋានសុខាភិបាល។ កំណត់និងកាត់បន្ថយតម្រូវការក្នុងការធ្វើដំណើរឆ្ងាយរបស់ប្រជាពលរដ្ឋ ដើម្បីទៅទទួលការថែទាំសេវាសុខាភិបាល។
- អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពលធ្វើការលើផ្នែកជំងឺមិនឆ្លងយល់ឃើញថា ការថែទាំសុខភាព បន្តផ្នែកជំងឺមិនឆ្លង គួររៀបចំឡើងដោយយោងទៅតាមគោលការណ៍ដូចខាងក្រោម៖
  - ការយកប្រជាជនជាចំណុចកណ្តាល
  - ការដឹកនាំដោយសហគមន៍ និងភាពជាម្ចាស់
  - ការមានអភិក្រមពហុវិស័យ ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន
  - ការរៀបចំឲ្យមានការថែទាំបន្តដែលមានប្រសិទ្ធភាពចំណាយ ដែលប្រជាពលរដ្ឋអាចទ្រទ្រង់បាន (ផ្សាភ្ជាប់ទៅនឹងកម្រិតមធ្យមនៃចំណូលជនបទសម្រាបមនុស្សម្នាក់ ដោយយោងលើអង្កេតសេដ្ឋកិច្ច សង្គមកិច្ច)
  - ឧបត្ថម្ភធនសម្រាប់ការផ្តល់សេវាថែទាំបន្តដល់អ្នកក្រីក្រ
  - ការរៀបចំឲ្យមានសូចនាករជាក់លាក់ ដែលវាស់វែងប្រសិទ្ធភាពនៃការថែទាំបន្តសម្រាប់អ្នកជំងឺមិនឆ្លង និងដោយមិនគ្រាន់តែវាស់វែងការប្រើប្រាស់សេវាថែទាំវេជ្ជសាស្ត្រតែមួយមុខនោះទេ
  - រាជរដ្ឋាភិបាលទទួលបន្ទុកនិងតាំងចិត្តផ្តល់ការដឹកនាំ ដើម្បីអនុវត្តនូវគោលការណ៍ខាងលើ។

ឃ-បញ្ហាសំខាន់ៗជារួមនៅក្នុងប្រព័ន្ធសុខាភិបាល

តាមនិយមន័យ ប្រព័ន្ធសុខាភិបាលរួមបញ្ចូលទាំងសេវារដ្ឋនិងឯកជន។ ការគាំទ្របច្ចុប្បន្ន ទាំងខាងក្នុង និងមកពីខាងក្រៅ ផ្តោតខ្លាំងលើប្រព័ន្ធសុខាភិបាលរដ្ឋ ដោយទុកឲ្យវិស័យឯកជនពុំមានការត្រួតពិនិត្យនិង គ្រប់គ្រងដោយ ច្បាប់។ ដោយជាក់ស្តែង ប្រជាជនភាគច្រើនប្រើប្រាស់សេវាសុខភាពក្រៅប្រព័ន្ធរបស់រដ្ឋ យុទ្ធសាស្ត្រទាមទារឲ្យមាន ការផ្លាស់ប្តូរ ដើម្បីដាក់បញ្ចូលនូវនិយ័តកម្ម ការតាមដាន និងការកែលម្អច្រើនជាងមុនទៅក្នុងវិស័យឯកជន។ ការធ្វើឲ្យ ប្រសើរឡើងនូវប្រសិទ្ធផលនៃការចំណាយលើផ្នែកសុខភាព និងសុខភាពប្រជាជនគ្រប់រូបអាចនឹងត្រូវសម្រេចបាន ល្អីកណា តែគុណភាពនិងគណនេយ្យភាពនៃវិស័យឯកជនត្រូវបានឆ្លើយតបជាបន្ទាន់។

ដោយសារតែរបាំងទាំងឡាយដូចដែលបាន រៀបរាប់ខាងក្រោមក្នុងផ្នែកផ្តល់សេវា ប្រជាជនជាច្រើននាំគ្នាប្រើ ប្រាស់ឱសថស្ថាន និងអ្នកលក់ថ្នាំ ជាកន្លែងទីមួយ ក្នុងការស្វែងរកសេវាថែទាំសុខភាពរបស់ខ្លួន។ ចំពោះជំងឺធ្ងន់ ពួកគាត់ ស្វែងរកការព្យាបាលនៅគ្លីនិកមិនផ្លូវការតួចៗ។ កន្លែងទាំងពីរប្រភេទនេះ ធ្វើឲ្យមានការពន្យារពេលក្នុងការផ្តល់ការថែទាំ សមស្របនិងប្រកបដោយជំនាញ ធ្វើឲ្យស្ថានភាពជំងឺកាន់តែដុនដាបទៅ និងធ្វើឲ្យប្រជាជនធ្លាក់ក្នុងភាពក្រីក្រថែមទៀត។

ដើម្បីឲ្យវិស័យឯកជនរីកដុះដាលប្រកបដោយ វិជ្ជាជីវៈ និងដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធសុខាភិបាល សាធារណៈ រាល់របាំងទាំងអស់ដែលរួមមានរបាំងហិរញ្ញវត្ថុ គួរដកចេញពីប្រព័ន្ធសាធារណៈ។ បើពុំមានរបាំងទាំងនោះទេ ប្រជាជននឹងបង្កើនការប្រើប្រាស់សេវាសាធារណៈ ហើយតម្រូវការរបស់សហគមន៍លើសេវាឯកជនដែលគ្មានគុណភាព នឹង ត្រូវបានកាត់បន្ថយ។ ជាមួយនឹងនិយ័តកម្មកើនឡើង វិស័យឯកជនអាចរស់រានានិងរីកដុះដាលបាន ប៉ុន្តែពួកគេនឹងត្រូវផ្តល់ សេវាក្នុងចរិតដែលប្រកបដោយវិជ្ជាជីវៈនិងមានលក្ខណៈប្រកួតប្រជែងជាងមុន ដើម្បីធានានូវជាសុកភាពនិងមានគុណភាព ខ្ពស់ ដែលដូចនេះពួកគេអាចស្រូបយក អតិថិជនណាដែលមានលទ្ធភាពបង់ថ្លៃសេវាថែទាំសុខភាព។

More emphasis on Public System but less on the Proliferation of Formal and Informal Private Sector *(Source: CDHS 2010)*



ង-ការផ្តល់សេវា

ការផ្តល់សេវាគឺជាផលិតផលចុងក្រោយនៃប្រព័ន្ធសុខាភិបាល។ ការផ្តល់សេវាត្រូវតែមានគុណភាពល្អ និងដែល អាចទទួលបានគ្រប់ៗគ្នា ទោះជាយ៉ាងណាក៏ដោយ ក៏វានៅតែបញ្ហាប្រឈមសម្រាប់ប្រព័ន្ធថែទាំសុខាភាពណាក៏ដោយ ក្នុងការធានាឲ្យបានប្រសើរនូវសមធម៌ និងប្រសិទ្ធផល។ ពុំមានប្រព័ន្ធថែទាំសុខភាពណាមួយ ដែលអាចដោះស្រាយគ្រប់ បញ្ហាទាំងអស់បាននោះទេ។ ប្រទេសមួយគប្បីត្រូវប្រមូលភ័ស្តុតាងថ្នាក់តំបន់ និងពិភពលោកមកដាក់បញ្ចូលគ្នា ដើម្បីតម្រូវ ទៅតាមបរិបទវប្បធម៌ នយោបាយ សេដ្ឋកិច្ច និងច្បាប់របស់ខ្លួន។ គ្រប់សមាសធាតុទាំងអស់នៃប្រព័ន្ធសុខាភិបាលមានការ ប៉ះពាល់ដល់ការផ្តល់សេវា។

បញ្ហាគន្លឹះ

ការគ្រប់គ្រងផ្នែកភ័ស្តុភារឱសថ

ការផ្គត់ផ្គង់ឱសថ សម្ភារៈ និងបរិក្ខារវេជ្ជសាស្ត្រ ប្រកបដោយប្រសិទ្ធផល គឺជាឆ្អឹងខ្នងមួយដ៏សំខាន់នៃការផ្តល់ សេវាសុខាភិបាល។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពនៅតែសង្កេតឃើញមានការផ្គត់ផ្គង់ពុំទាន់ពេលវេលា និង ពុំគ្រប់គ្រាន់នូវឱសថសារវន្ត សម្ភារៈសុខាភិបាល និងបរិក្ខារវេជ្ជសាស្ត្រចាំបាច់ នៅតាមគ្រប់មូលដ្ឋានសុខាភិបាល

ជាពិសេសមូលដ្ឋានដែលនៅតំបន់ជនបទដាច់ស្រយាលនៅទូទាំងប្រទេស ដែលនេះបង្ហាញយ៉ាងច្បាស់នូវបញ្ហាដ៏ចំបង ទាក់ទិននឹងការងារលទ្ធកម្ម ការគ្រប់គ្រង និងការចែកចាយឱសថសារវ័ន្ត និងសម្ភារៈសុខាភិបាល។ ឱសថពុំចាំបាច់មួយចំនួនមានលើសសេចក្តីត្រូវការ ហើយត្រូវធ្វើការដុតបំផ្លាញចោលដោយសារការខូចគុណភាព (ឧទាហរណ៍ៈ ឱសថផុតកំណត់ប្រើប្រាស់) រីឯឱសថសារវ័ន្តដែលមានតម្រូវការចាំបាច់ខ្លះវិញពុំមានទាន់ពេលវេលាសម្រាប់ការប្រើប្រាស់ឡើយ។ ជារឿយៗ ឱសថខ្លះបានបញ្ជូនមកដល់មូលដ្ឋានសុខាភិបាលដោយមានកាលបរិច្ឆេទប្រើប្រាស់ជិតផុតកំណត់ទៅហើយ ដែលបញ្ហានេះអាចបញ្ជៀសបានដោយការមានប្រព័ន្ធគ្រប់គ្រងប្រសើរជាងមុន។

បញ្ហាដ៏យូរលង់នេះ ត្រូវបានលើកឡើងជាច្រើនដងមកហើយ ហើយទាមទារឲ្យមានការត្រួតពិនិត្យឲ្យបានហ្មត់ចត់ និងឲ្យមានវិធានការបន្ទាន់ដើម្បីដោះស្រាយផងដែរ។ ថវិកាជាតិសម្រាប់ឱសថមានការកើនឡើងជារៀងរាល់ឆ្នាំ ប៉ុន្តែមូលដ្ឋានសុខាភិបាលទាំងឡាយនៅតែបន្តប្រឈមនឹងការខ្វះ ក៏ដូចជាការគ្រប់គ្រងមិនបានត្រឹមត្រូវនូវឱសថ និងសម្ភារៈជាសារវ័ន្ត។

ការទទួលបានសេវាថែទាំសុខភាព

បញ្ហាធំទី២នៃការផ្តល់សេវាគឺ ការទទួលបានដ៏មានកម្រិតនូវសេវាថែទាំសុខភាពសាធារណៈ សម្រាប់ប្រជាជនជាពិសេសជនក្រីក្រ ងាយរងគ្រោះ និងមិនត្រូវបានគេយកចិត្តទុកដាក់។ ការអង្កេតប្រជាសាស្ត្រសុខាភិបាលនិងប្រជា-សាស្ត្រឆ្នាំ២០០៥ បានបង្ហាញថា មានតែ ២១,៦% នៃចំនួនប្រជាជនទាំងអស់ប៉ុណ្ណោះ ដែលអាចទទួលបានសេវាសុខភាពសាធារណៈ។

បញ្ហាសំខាន់ៗពីមូលហេតុនៃការដែលប្រជាជនមិនបានប្រើប្រាស់សេវាសាធារណៈនេះរួមមាន៖ (១)របាំងហិរញ្ញវត្ថុ (២)អាកប្បកិរិយាមិនសមរម្យរបស់បុគ្គលិកផ្តល់សេវាសុខភាព (៣)សេវា ជាពិសេសនៅតាមមណ្ឌលសុខភាពមិនមានសម្រាប់ការប្រើប្រាស់ ២៤ម៉ោង ក្នុងមួយថ្ងៃ (៤)អ្នកជំងឺតម្រូវឲ្យបង់ថ្លៃក្រៅផ្លូវការបន្ថែមទៀត និងទិញឱសថ និងសម្ភារៈ និងគ្រឿងសុខភាពដទៃទៀត (៥)គុណភាពនៃការថែទាំ និងជំនាញដែលគេយល់ឃើញថានៅមានកម្រិត និងកង្វះនូវឧបករណ៍គ្រប់គ្រាន់និងទាន់សម័យ (៦)កង្វះនូវការយោគយល់គ្នារទៅវិញទៅមករវាងអ្នកប្រើប្រាស់និងអ្នកផ្តល់សេវា និង (៧)ប្រព័ន្ធបញ្ជូនដែលមិនដើរបានល្អ និងមានតម្លៃថ្លៃ។

ប្រព័ន្ធបញ្ជូននៅតាមបណ្តាខេត្ត និងមន្ទីរពេទ្យបង្អែកមួយចំនួន នៅតែពុំទាន់ដំណើរការបានល្អនៅឡើយ។ ទោះបីជាកន្លែងខ្លះមានដំណើរការក្តី ក៏ចំណាយ សម្រាប់បញ្ជូនអ្នកជំងឺធ្ងន់ធ្ងរមានតម្លៃថ្លៃពេកសម្រាប់ប្រជាជនក្រីក្រ ឬសូម្បីតែប្រជាជនដែលមានកម្រិតជីវភាពមធ្យម ក្នុងការទ្រទ្រង់ចំណាយនេះ។ បញ្ហាកាន់តែធំនោះគឺប្រព័ន្ធបញ្ជូនពីសហគមន៍ទៅមូលដ្ឋានសុខាភិបាល និងពីមណ្ឌល សុខភាពទៅមន្ទីរពេទ្យបង្អែក។

របាំងហិរញ្ញវត្ថុ ដែលជាបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាចំបងៗរារាំងការ ទទួលបាននូវសេវាថែទាំសុខភាព នឹងត្រូវបង្ហាញបន្ថែមជាមួយនឹងអនុវិសាសន៍ជាក់លាក់ នៅក្នុងផ្នែកហិរញ្ញប្បទានសុខាភិបាលនៃឯកសារគោលជំហរនេះ។

គុណភាពនៃសេវាថែទាំសុខភាព

ថ្មីៗនេះក្រសួងសុខាភិបាលបានយកចិត្តទុកដាក់បន្ថែមក្នុងការធ្វើឲ្យប្រសើរឡើងនូវគុណភាព នៃសេវាថែទាំសុខភាព។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាព បានសង្កេតឃើញនូវការរីកចំរើនខ្លះៗកន្លងមក ប៉ុន្តែការធានាឲ្យបាននូវការពេញចិត្ត និងជំនឿចិត្តខ្ពស់ពីអ្នកប្រើប្រាស់នូវសេវាទាំងនោះនៅតែជាបញ្ហាប្រឈមនៅឡើយ។ ក្រៅពីមានការកើនឡើងនូវការប្រើប្រាស់សេវា ដូចដែលបានបង្ហាញនៅក្នុងការពិនិត្យរួមគ្នាលើសមិទ្ធផលសុខាភិបាលលើកទី៩ កាលពីថ្ងៃទី១៤-១៥ ខែមីនា ឆ្នាំ២០១១ ប្រជាជនក្រីក្រជាច្រើននៅតែប្រើប្រាស់វិស័យឯកជន ហើយមួយចំនួនក្នុងចំណោមអ្នកទាំងនោះថែមទាំងចាកចេញពីប្រទេសកម្ពុជាដើម្បីទៅស្វែងរកសេវាថែទាំសុខភាពដែលគេជឿទុកចិត្តច្រើនជាង ដូចជានៅប្រទេសថៃ វៀតណាម និងសឹង្ហបុរីជាដើម។ បញ្ហាដែលលេចធ្លោនានា ដែលធ្វើឲ្យប៉ះពាល់ដល់គុណភាពនៃការថែទាំរួមមាន សមត្ថភាពរបស់អ្នកផ្តល់សេវានៅមានកម្រិត ការគោរពមិនបានតាមប្រូតូកូល ការពង្រឹងមិនបានល្អនូវក្រមសីលធម៌និងឥរិយាបទ

គ្រូពេទ្យ ការធ្វើអភិបាលកិច្ចមិនបានដិតដល់និងមិនបានទៀងទាត់នៅគ្រប់កម្រិតនៃមូលដ្ឋានសុខាភិបាលទាំងអស់ ការពុំអាចត្រួតពិនិត្យបាននូវគុណភាពសេវានៅតាមនៅតាមវិស័យឯកជនស្របច្បាប់និងមិនស្របច្បាប់ អសកម្មនៃការចូលរួមរបស់សហគមន៍និងអាជ្ញាធរមូលដ្ឋានក្នុងការពង្រឹងគុណភាពនៃសេវាថែទាំសុខភាពសាធារណៈ និងបញ្ហាដទៃទៀត។

ក្រសួងសុខាភិបាលមានការត្រួតពិនិត្យតិចតួចបំផុតទៅលើវិស័យសុខភាពឯកជន ក្នុងការធានាឲ្យបាននូវគុណភាពនៃការថែទាំ។ រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសុខាភិបាល គួរមើលទៅលើការពង្រឹងប្រព័ន្ធថែទាំសុខភាពឲ្យបានឆ្ងាយជាងការសង្កត់ធ្ងន់តែលើប្រព័ន្ធសាធារណៈ ដែលបច្ចុប្បន្ននេះទុកឲ្យផ្នែកមួយដ៏ធំនៃប្រព័ន្ធសុខាភិបាលនៅក្នុងវិស័យឯកជន មិនបានត្រួតពិនិត្យស្តីពីការធានាឲ្យបាននូវគុណភាពនៃការថែទាំ។ ដោយពុំមានការត្រួតពិនិត្យលើគុណភាពបែបនេះទេ វិស័យឯកជនអាចធ្វើឲ្យប្រជាជនធ្លាក់ក្នុងភាពក្រីក្រ និងសម្លាប់ជីវិតមនុស្សកាន់តែច្រើន ដែលហេតុដូចនេះនឹងធ្វើឲ្យ ប្រព័ន្ធសាធារណៈកាន់តែចុះខ្សោយ។

អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពក៏បង្ហាញពីក្តីបារម្ភផងដែរអំពីគុណភាពនៃការបណ្តុះបណ្តាលដែលផ្តល់ដោយគ្រឹះស្ថានឯកជន។ និស្សិតបង់ថ្លៃភាគច្រើនរៀននៅចុងសប្តាហ៍ ហើយគណៈកម្មការត្រួតពិនិត្យគុណភាពអាចពុំដំណើរការបានល្អគ្រប់គ្រាន់ ក្នុងការធានាឲ្យបាននូវគុណភាពនៃការបណ្តុះបណ្តាលនេះទេ។

អនុសាសន៍

ការគ្រប់គ្រងភ័ស្តុភា និងឱសថ

អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពសូមស្នើសុំឲ្យមានវិធានការតឹងរ៉ឹងនានា និងការតាមមើលឲ្យបានហ្មត់ចត់លើ (១)ការប្រើប្រាស់ថវិកាជាតិសម្រាប់ឱសថសារវ័ន្ត សម្ភារៈ និងបរិក្ខារពេទ្យ (២)កិច្ចលទ្ធកម្មដែលមានតម្លាភាពនៃសម្ភារៈទាំងអស់នេះ និង (៣)ការគ្រប់គ្រងនិងចែកចាយឱសថសារវ័ន្ត សម្ភារៈ និងបរិក្ខារពេទ្យ ដើម្បីធានាឲ្យបានថារបស់ទាំងនេះពិតជាឆ្លើយតបបាននឹងតម្រូវការរបស់មូលដ្ឋានសុខាភិបាល។

ការទទួលបានសេវាសុខភាព

វិសាលភាពសំខាន់ៗនានាដែលគួរក្រលេកមើលឲ្យបានហ្មត់ចត់ដើម្បីធានាឲ្យបាននូវការផ្តល់សេវាថែទាំសុខភាពកាន់តែប្រសើរឡើងរួមមាន (១)កែលម្អនូវឥរិយាបទនិងជំនាញរបស់អ្នកផ្តល់សេវាសុខភាព (២)ធ្វើឲ្យប្រសើរឡើងនូវការដែលអាចរកបាននូវសេវាសុខភាព (៣)ដោះស្រាយបញ្ហាប្រព័ន្ធបញ្ជូននិងថ្លៃធ្វើដំណើរ (៤)ដកចេញនូវរបាំងហិរញ្ញវត្ថុនានានៅតាមកន្លែងផ្តល់សេវា (៥)បញ្ឈប់ការតម្រូវឲ្យបង់ប្រាក់ក្រៅផ្លូវការ និងបញ្ឈប់ការឲ្យអ្នកជំងឺទិញរបស់គ្រប់យ៉ាងដូចជាឱសថ សម្ភារៈនិងរបស់ប្រើប្រាស់សុខភាព។ល។ និង (៦)បង្កើនការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានក្នុងការធ្វើឲ្យមានការទទួលបានកាន់តែប្រសើរនូវសេវាថែទាំសុខភាព។

ប្រព័ន្ធបញ្ជូន

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបាននឹងកំពុងផ្តល់ការគាំទ្រដល់ថ្លៃធ្វើដំណើរសម្រាប់ប្រជាជនក្រីក្រ ដើម្បីឲ្យពួកគេអាចមានលទ្ធភាពមកទទួលសេវានៅមូលដ្ឋានសុខាភិបាលនៅពេលពួកគាត់មានជំងឺ។ ការប្រតិបត្តិបែបនេះជាសក្ខីភាពបង្ហាញថា មានការកើនឡើងច្រើននូវចំនួនប្រជាពលរដ្ឋក្រីក្រ ប្រជាជនងាយរងគ្រោះ និងប្រជាជនដែលមិនត្រូវបានគេយកចិត្តទុកដាក់ ដែលបានមកប្រើប្រាស់សេវាសុខភាពនៅមូលដ្ឋានសុខាភិបាល។ ជាមួយនឹងបរិបទសេដ្ឋកិច្ចប្រទេសបច្ចុប្បន្ន ការប្រតិបត្តិបែបនេះ គួរត្រូវបានពង្រីកបន្ថែម និងបន្ត ជាពិសេសសម្រាប់ក្រុមគោលដៅជាអាទិភាពដូចជាស្ត្រីមានផ្ទៃពោះ ទារក និងកុមារអាយុក្រោម ៥ឆ្នាំ ជាដើម។ ប្រព័ន្ធបញ្ជូននៅតាមសហគមន៍ ដែលបាននឹងកំពុងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗជាច្រើនគួរត្រូវបានសិក្សា ហើយការប្រតិបត្តិល្អស្តីពីប្រព័ន្ធបញ្ជូនគួរត្រូវបានប្រមូលនិងផ្សៀងផ្ទាត់ សម្រាប់សក្តានុពលពង្រីកបន្ថែម។ សំខាន់ជាងនេះទៀត មូលដ្ឋានសុខាភិបាលនីមួយៗ ត្រូវមានយ៉ាងហោច

ណាស់រថយន្តសង្គ្រោះមួយ ដែលអាចប្រើការកើតដោយពុំមានបញ្ហាអ្វីនៅពេលត្រូវការបញ្ជូនអ្នកជំងឺភ្លាមៗពីសហគមន៍ទៅមូលដ្ឋានសុខាភិបាល។

គុណភាពនៃការថែទាំជំងឺ

ដើម្បីដោះស្រាយបញ្ហាគុណភាពនៃសេវាថែទាំសុខភាព វិធានការរយៈពេលវែងនិងខ្លីនានាត្រូវបានផ្តល់ជូនជាមតិយោបល់នៅក្នុងឯកសារគោលជំហរមុនៗរបស់អង្គការម៉ែឌីខាំ។

វិធានការរយៈពេលវែង

យុទ្ធសាស្ត្ររយៈពេលវែងគឺ ដោះស្រាយបញ្ហាគុណភាពនៃការបណ្តុះបណ្តាលមុនពេលចូលបម្រើការងារ ដោយធានាឲ្យបានថា គ្រូពេទ្យជំនាញផ្នែកវេជ្ជសាស្ត្រដែលចេញពីសាលារដ្ឋនិងសាលាឯកជនពិតជាមានគុណភាពខ្ពស់។

គណៈកម្មាធិការត្រួតពិនិត្យគុណភាពសញ្ញាបត្រ និងគណៈគ្រូពេទ្យកម្ពុជា ដែលដំណើរការល្អ រួមជាមួយនឹងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃដ៏មានប្រសិទ្ធភាពគឺជាកត្តាតម្រូវមុនសម្រាប់ធានាឲ្យមានការផ្តល់សេវាថែទាំសុខភាពក្នុងវិស័យទាំងពីរនេះ។

វិធានការរយៈពេលខ្លី

- ការវាយតម្លៃដ៏ពេញលេញលើគុណភាពនៃការផ្តល់សេវាថែទាំ ក៏ដូចជាការត្រួតពិនិត្យលើគុណភាព គួរត្រូវអនុវត្តទាំងលើវិស័យរដ្ឋនិងឯកជន។
- ក្រសួងសុខាភិបាលគួរធានាឲ្យបាននូវដំណើរការទៀងទាត់នៃប្រព័ន្ធត្រួតពិនិត្យនិងគ្រប់គ្រង នៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៃការផ្តល់សេវាថែទាំ។ ប្រព័ន្ធរង្វាន់ឬទណ្ឌកម្ម គួរត្រូវបានរៀបចំ ដើម្បីធានាឲ្យបានថា កំហុសឆ្គងនឹងត្រូវបានកែប្រែ ហើយអ្នកដែលធ្វើការបានល្អត្រូវបានផ្តល់រង្វាន់។
- សហគមន៍និងអាជ្ញាធរមូលដ្ឋានគួរត្រូវបានផ្តល់សិទ្ធិអំណាច ក្នុងការពិនិត្យតាមដាននិងគ្រប់គ្រងគុណភាពនៃសេវាថែទាំដែលផ្តល់ដោយមូលដ្ឋានសុខភាពសាធារណៈ។ ពួកគាត់ត្រូវមានសិទ្ធិបញ្ចេញមតិយ៉ាងសកម្មក្នុងការផ្តល់នូវសេវាថែទាំសុខភាព ដោយហេតុថាពួកគាត់ជាម្ចាស់ថវិកាជាតិ ដែលថវិកានេះបានមកពីការបង់ពន្ធអាកររបស់គាត់។
- ដើម្បីឲ្យមានប្រសិទ្ធភាពខ្ពស់ជាងនេះទៀតនោះ ការបណ្តុះបណ្តាល ក្នុងពេលបំពេញការងារពុំគួរត្រូវបានធ្វើឡើងក្នុងរូបភាពជាសមាសធាតុមួយដាច់តែឯងនោះទេ។ ការបណ្តុះបណ្តាលត្រូវតែ ជាផ្នែកមួយនៃកញ្ចប់រួមតែមួយដោយផ្តោតលើលទ្ធផល ដែលដូចនេះ ជំនាញដែលទទួលបានត្រូវបានយកទៅប្រើប្រាស់។ ការបណ្តុះបណ្តាលនេះគួរជាផ្នែកមួយនៃកម្មវិធីអនុវត្តទាំងមូលដែលមានការគាំទ្រ។ ជាទូទៅ ជំនាញមិនអាចត្រូវបានប្រើប្រាស់ដោយសារតែប្រព័ន្ធសាធារណៈពុំមានថវិកាគ្រប់គ្រាន់សម្រាប់គាំទ្រដល់ការអនុវត្តបែបនេះទេ។ លើសពីនេះទៀត ការបណ្តុះបណ្តាលក្នុងពេលបំពេញការងារ គួរតែធ្វើឡើងដោយមានការសម្របសម្រួលក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ផ្នែកសុខភាពទាំងអស់ និងក្រសួងសុខាភិបាល។

ច-ហិរញ្ញប្បទានសុខាភិបាល

បញ្ហាគន្លឹះ

- ថវិកាជាតិសម្រាប់វិស័យសុខាភិបាលមានការកើនឡើងជារៀងរាល់ឆ្នាំ ដែលឥឡូវនេះមានចំនួន ១៨១លានដុល្លារអាមេរិក ដែលស្មើនឹងជាង៦0% នៃចំណាយថែទាំសុខភាពទាំងមូល (ផែនការប្រតិបត្តិប្រចាំឆ្នាំ២0១១ របស់ក្រសួងសុខាភិបាល)។ ថវិកាជាតិនេះបានមកពីប្រាក់ចំណូលរដ្ឋ ដែលប្រមូលពីការបង់ពន្ធនៃប្រព័ន្ធហិរញ្ញប្បទានសុខាភិបាលដែលប្រព័ន្ធហិរញ្ញប្បទានយកពន្ធនេះនៅកម្ពុជា មានលក្ខណៈខុសគ្នាពីនៅប្រទេសថៃ ម៉ាឡេស៊ី ឬក៏ស្រីលង្កា ដោយសារការយកថ្លៃប្រើប្រាស់សេវានៅក្នុងប្រព័ន្ធនេះ។

- មុនឆ្នាំ១៩៩៦ ប្រព័ន្ធសុខាភិបាលសាធារណៈរបស់ប្រទេសកម្ពុជា ផ្តល់សេវា ថែទាំសុខភាពដោយឥតបង់ថ្លៃ ហើយបន្ទាប់ពីឆ្នាំ១៩៩៦មក ថ្លៃប្រើប្រាស់សេវាត្រូវបានអនុវត្ត ដែលកំរៃនេះត្រូវ បានគេរាយការណ៍ថាជារបាំងដ៏ធំសម្រាប់ប្រជាជន ជាពិសេសជនក្រីក្រ ក្នុងការទទួលយកសេវាថែទាំសុខភាព។ យោងតាម ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១០និងឆ្នាំ២០១១ ថ្លៃប្រើប្រាស់សេវាដែលប្រមូលបានរួមចំណែករៀងគ្នា ២,៨% និង ៥% ហើយថវិកាជាតិបច្ចុប្បន្នរួមចំណែកជាង ៦០% នៃចំណាយប្រតិបត្តិការទាំងមូលសម្រាប់ប្រព័ន្ធថែទាំសុខភាពសាធារណៈ (ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១១)។ ទោះជាយ៉ាងនេះក្តី ច្រកចូលទៅកាន់ប្រព័ន្ធសាធារណៈមានសភាពតូចចង្អៀត ដោយសារតែរបាំងនៃ ថ្លៃប្រើប្រាស់សេវា ដែលបង្កើតឲ្យមានតម្រូវការខ្ពស់នៅតាមសហគមន៍ ហើយដែលប្រការនេះនាំឲ្យមានការរីករាលដាលនៃវិស័យឯកជនក្រៅផ្លូវការដ៏អាណាធិបតេយ្យ ដែលកំពុងតែសម្លាប់និងធ្វើឲ្យប្រជាជនធ្លាក់ក្នុងភាពក្រីក្រ។ បច្ចុប្បន្នមានគម្រោងហិរញ្ញប្បទានមួយចំនួន រាប់បញ្ចូលទាំងមូលនិធិសមធម៌ ធានារ៉ាប់រងសុខភាពសហគមន៍ ប័ណ្ណសុខភាពសម្រាប់ស្ត្រី និងការផ្តេរសាច់ប្រាក់ដោយមានលក្ខខណ្ឌដល់អ្នកក្រីក្រ ដើម្បីដោះស្រាយបញ្ហារបាំងហិរញ្ញវត្ថុទាំងអស់នោះ។ គម្រោងនីមួយៗមានផលវិជ្ជមាន និងផលអវិជ្ជមាន ហើយជួនកាលគម្រោងទាំងនោះមានការដើរបញ្ច្រាស់គ្នាជាជាងបំពេញឲ្យគ្នាទៅវិញទៅមក។ ប្រសិទ្ធភាពនិងសមធម៌នៃគម្រោងទាំងអស់នោះទាមទារឲ្យមានភស្តុតាងនិងការវាយតម្លៃបន្ថែម។
- អភិក្រមឬយន្តការហិរញ្ញប្បទានសុខាភិបាលដែលមានលក្ខណៈបែកខ្ញែកគ្នានិងដាក់តម្រូវភ្លាមៗ អាចចូលរួមជួយប្រជាពលរដ្ឋបានតិចតួច ដោយសារតែបច្ចុប្បន្ននេះយន្តការទាំងនេះពុំមាននិរន្តរភាពនិងប្រសិទ្ធផលក្នុងការធានាឲ្យបាននូវគុណភាពនិងសមធម៌នៃសេវាថែទាំ។
- មូលនិធិសមធម៌ ដែលកន្លងមកបានជួយប្រជាពលរដ្ឋក្រីក្រ ឲ្យទទួលបាននូវសេវាថែទាំសុខភាពសាធារណៈ និងបានជួយផ្តល់ធនធានបន្ថែមដើម្បីគាំទ្រដល់ដំណើរការនៃប្រព័ន្ធសុខាភិបាលសាធារណៈនោះ ទំនងជាមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ការពង្រីកបន្ត។ យ៉ាងនេះក្តី មានគម្រោងមូលនិធិសមធម៌ជាង៥០ កំពុងត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ដោយមានកញ្ចប់ផលប្រយោជន៍ វិធីសាស្ត្រ បង់ថ្លៃសេវា និងយន្តការត្រួតពិនិត្យគុណភាពរបស់គេផ្ទាល់ផ្សេងៗគ្នា។ ប្រសិនបើមូលនិធិសមធម៌នឹងត្រូវពង្រីកទៅទូទាំងប្រទេស ក្រសួងសុខាភិបាលចាំបាច់ត្រូវរៀបចំតម្លៃស្តង់ដារដែលគ្រប់គ្រងដោយច្បាប់ សម្រាប់សេវាថែទាំសុខភាពសាធារណៈទាំងឡាយ និងកំណត់ជាបទដ្ឋានផងដែរសម្រាប់កញ្ចប់ផលប្រយោជន៍ និងវិធីសាស្ត្របង់ថ្លៃសេវាផ្សេងៗគ្នាទាំងអស់នេះ។ លើសពីនេះទៀតក្រសួងក៏ត្រូវការពង្រឹងយន្តការត្រួតពិនិត្យគុណភាពនានា ដើម្បីធានាឲ្យបានថាអ្នកប្រើប្រាស់សេវាបានចូលរួមយ៉ាងពេញលេញក្នុងការធ្វើឲ្យប្រសើរឡើងនូវគុណភាពសេវាថែទាំសុខភាព។ នៅក្នុងទិសដៅនេះ គម្រោងធានារ៉ាប់រងសុខភាពសហគមន៍ ដែលបានបង្ហាញពីបញ្ហាប្រឈមខ្លាំងក្នុងការពង្រីកប្រាក់សមាជិកភាពក្នុងចំណោមប្រជាជនក្រីក្រ គួរមានការបញ្ចូលគ្នាជាមួយនឹងមូលនិធិសមធម៌។ យ៉ាងនេះក្តី មូលនិធិសមធម៌អាចមានបន្ទុកចំណាយ មិនចាំបាច់ ដោយសារតែភាពញឹកញាប់នៃការកំណត់អត្តសញ្ញាណកម្មអ្នកក្រីក្រមុននិងក្រោយការមកទទួលសេវាថែទាំសុខភាព និងតួនាទីរបស់អ្នកទីបី។ ប្រជាជននៅតែបន្តតួញញែរឲ្យដំណើរការនៃការជ្រើសរើសមានតម្លាភាព ដើម្បីធានាឲ្យបានថាប្រជាពលរដ្ឋក្រីក្រពិតប្រាកដនឹងទទួលបានសេវាថែទាំសុខភាព ហើយអ្នកផ្តល់សេវានៅតែបន្ត ព្យាបាលពួកគាត់ក្នុងល័ក្ខខ័ណ្ឌជាអ្នកក្រីក្រ ទោះបីជាថ្លៃប្រើប្រាស់សេវារបស់ពួកគាត់ត្រូវបានបង់ជំនួសដោយភាគីទីបីក៏ដោយ។ ជារឿយៗ ការតួញញែរដែលទទួលបានច្រើនបំផុតនោះមានដូចជា៖ មូលនិធិសមធម៌គឺមានសម្រាប់តែជំងឺ ដង្កាត់តិចតួច។ ពួកគាត់ត្រូវទិញថ្នាំសង្កូវដោយខ្លួនឯង អ្នកផ្តល់សេវាសុខភាពពុំមានភាពរាក់ទាក់ ការខ្វល់ខ្វាយ និងយកចិត្តទុកដាក់គ្រប់គ្រាន់ដល់អ្នកកាន់ប័ណ្ណមូលនិធិសមធម៌។ ប្រជាជនមានការខ្លាចរអាវក្នុងការប្រើប្រាស់ប័ណ្ណមូលនិធិសមធម៌ម្តងទៀតនៅពេលត្រូវទៅមូលដ្ឋានសុខភាពលើកក្រោយ[84] ដោយហេតុថាពេលមុនពួកគាត់មិនត្រូវបានគេយកអាសារបានសមរម្យឡើយ។ ជាងនេះ

[84] MEDiCAM's consolidated report on Community Health Forums 2011, funded by EU, DFID, and GFATM

ទៀត មូលនិធិសមធម៌ ឆ្លើយតបចំពោះតែប្រជាជនដែលស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែង ប្រជាជនជាច្រើនដែលរស់នៅជាប់នឹងបន្ទាត់ក្រីក្រ ឬក៏លើបន្ទាត់ក្រីក្របន្តិចបន្តួចពុំអាចមានលទ្ធភាពទ្រទ្រង់សេវាថែទាំសុខភាពកម្រិតពីរនិងកម្រិតបីបានទេ។

អនុសាសន៍

- ការបង្កើនថវិកាជាតិសម្រាប់វិស័យសុខាភិបាលជារៀងរាល់ឆ្នាំពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា គឺជាឱកាសគួរលើកទឹកចិត្តមួយ។ អ្វីដែលយើងត្រូវការក្នុងការចូលរួមជាមួយនឹងរដ្ឋាភិបាលគឺ ការបង្កើនតម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អក្នុងការប្រើប្រាស់ថវិកាជាតិ តាមរយៈការផ្តល់អំណាចដល់អាជ្ញាធរមូលដ្ឋាន សហគមន៍ និងអង្គការសង្គមស៊ីវិលក្នុងការចូលរួមតាមដាន និងជម្រុញឲ្យមានគណនេយ្យភាពនៃចំណាយសាធារណៈ។
- ការមើលឲ្យបានឆ្ងាយ លើសពីគម្រោងសាកល្បងបច្ចុប្បន្ននានាដូចជា មូលនិធិសមធម៌ គម្រោងធានារ៉ាប់រងសុខភាពសហគមន៍ ឬក៏ប័ណ្ណសុខភាពសម្រាប់ស្ត្រី ឃើញថា មានការផ្តល់ជាមតិយោបល់ជូនអ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីឲ្យសិក្សាពីភស្តុតាងនៅតាមបណ្តាប្រទេសដទៃ ដែលមានប្រាក់ចំណូលទាប និងមធ្យមនៅក្នុងតំបន់ដូចជា ប្រទេសថៃ ម៉ាឡេស៊ី ស្រីលង្កា និងកោះហុងកុង ដែលគេបានអនុវត្តការដាក់បញ្ចូលគ្នានូវហិរញ្ញប្បទានសុខាភិបាលយកពន្ធ និងធានារ៉ាប់រងសុខភាពសង្គម ដែលទង្វើនេះនាំឲ្យមានភាពប្រសើរឡើងនូវសមធម៌ ប្រសិទ្ធផល និងគុណភាពនៃសេវាថែទាំសុខភាព។
- ប្រសិនបើ ថ្លៃប្រើប្រាស់សេវាត្រូវបានលុបចោល ច្រកចូលទៅកាន់ប្រព័ន្ធសុខាភិបាលសាធារណៈនឹងត្រូវបានបើកចំហយ៉ាងធំ ហើយរាល់តម្រូវការនៅក្នុងសហគមន៍នឹងនឹងសាបរលាប ដោយសារប្រជាជននឹងងាកមកប្រើប្រាស់ប្រព័ន្ធសុខាភិបាលសាធារណៈវិញ។ វិស័យឯកជននឹងត្រូវខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីដំណើរការក្នុងលក្ខណៈប្រកួតប្រជែង និងប្រកបដោយវិជ្ជាជីវៈ ដែលដូច្នេះ ពួកគេនឹងអាចផ្តល់នូវសេវាថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់ និងជាសុកភាព ដើម្បីមានលទ្ធភាពទាក់ទាញអ្នកមានធនធានមកប្រើប្រាស់។ គោលនយោបាយនេះនឹងអនុញ្ញាតឲ្យអ្នកក្រីក្របានប្រើប្រាស់ នូវប្រព័ន្ធសុខាភិបាលសាធារណៈ ហើយអ្នកមានធនធានប្រើប្រព័ន្ធឯកជន។ ការផ្តល់សេវាថែទាំសុខភាពដោយឥតបង់ ថ្លៃនៅមូលដ្ឋានសុខាភិបាលសាធារណៈ អាចកាត់បន្ថយនូវការរីកដុះដាលដោយអណាធិប្បតេយ្យនៃវិស័យឯកជនមិនស្របច្បាប់ ពីព្រោះប្រជាជនកាន់តែច្រើនឡើងនឹងងាកមកប្រើប្រាស់សេវាសាធារណៈវិញ។
- អភិបាលកិច្ចល្អនៃប្រព័ន្ធថែទាំ សុខភាពដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាព ទទួលបានសេវាថែទាំសុខភាព និងសមធម៌ អាចសម្រេចបានតាមរយៈការសម្របសម្រួលឲ្យមានការចូលរួមដោយប្រជាធិបតេយ្យពីតួអង្គពាក់ព័ន្ធនិងអ្នកប្រើប្រាស់ទាំងអស់។ អំណាចទិញនៃកំរៃប្រើប្រាស់សេវា ដែលបច្ចុប្បន្នរួមចំណែក ៥% នៃចំណាយសុខភាពនោះ គឺតិចតួចណាស់ក្នុងការជម្រុញឲ្យមានការផ្លាស់ប្តូរនៅក្នុងប្រព័ន្ធ។ ថវិកាជាតិ (បានមកពីការប្រមូលពន្ធ) ដែលរួមចំណែកលើសពី ៦០% នៃចំណាយថែទាំ សុខភាពទាំងមូលគួរត្រូវមានការទទួលខុសត្រូវ តាមរយៈការអនុវត្តការចូលរួមប្រកបដោយប្រជាធិបតេយ្យ។

ឆ-ធនធានមនុស្សសម្រាប់វិស័យសុខាភិបាល

បញ្ហាសំខាន់ៗបំផុតនៃធនធានមនុស្សសម្រាប់វិស័យសុខាភិបាលរួមាន (១)សមត្ថភាពមានកម្រិត (២)ការបែងចែកបុគ្គលិកនិងការរក្សាបុគ្គលិកឲ្យនៅ (៣)តិរិយាបទគ្រូពេទ្យ (៤)ការដឹកនាំនិងគ្រប់គ្រងខ្សោយ និង (៥)ការបម្រើការងារពីរកន្លែង។

បញ្ហាគន្លឹះ

- ជាច្រើនទសវត្សរ៍មកហើយ ការអភិវឌ្ឍសមត្ថភាព ឬការកសាងសមត្ថភាពគឺជាប្រធានបទដ៏សំខាន់សម្រាប់អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពនៅកម្ពុជា និងដៃគូសុខាភិបាល ក្នុងការជួយគាំទ្រដល់ប្រព័ន្ធសុខាភិបាល។ បញ្ហា និងអនុសាសន៍នានាត្រូវបានលើកឡើងនៅក្នុងផ្នែកផ្តល់សេវានៃឯកសារគោលជំហរនេះ។
- ការបែងចែកបុគ្គលិកនិងការរក្សា បុគ្គលិកឲ្យនៅគឺជាបញ្ហាប្រឈមយ៉ាងខ្លាំងសម្រាប់ក្រសួងសុខាភិបាល ដោយសារតែអ្នកផ្តល់សេវាសុខភាពសាធារណៈទទួលបានប្រាក់បៀវត្សរ៍ទាបជាងតម្លៃទីផ្សារការងារ។ នៅក្នុងស្ថានភាពបែបនេះ បុគ្គលិកដែលមានគុណវុឌ្ឍិខ្ពស់ តែងតែនាំគ្នាចាកចេញពីប្រព័ន្ធសាធារណៈទៅរកការងារដែលមានប្រាក់បៀវត្សរ៍ខ្ពស់ ដែលប្រការនេះនាំឲ្យមានការចាក ចេញនៃអ្នកមានប្រាជ្ញាទៅក្រៅវិស័យ និងក្រៅប្រទេសរបស់ខ្លួន។
- ការដឹកនាំនិងការគ្រប់គ្រងគឺជាក្បាលម៉ាស៊ីនដ៏សំខាន់ មួយនៅក្នុងការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យសុខាភិបាល។ គ្រូពេទ្យអាជីពនៅគ្រប់កម្រិតទាំងអស់ ត្រូវបានបណ្តុះបណ្តាលលើជំនាញបច្ចេកទេស ជាពិសេសការអនុវត្តវេជ្ជសាស្ត្ររបស់ពួកគេ ប៉ុន្តែពុំបានបណ្តុះបណ្តាលច្រើនលើផ្នែកសុខភាពសាធារណៈ ជំនាញដឹកនាំនិងគ្រប់គ្រងទេ។ ដូច្នេះ តាមទស្សនៈវិស័យសុខភាពសាធារណៈ ការដឹកនាំនិងគ្រប់គ្រង ហាក់ដូចជាពុំសូវត្រូវគេបានពន្យល់បកស្រាយឲ្យបានច្បាស់លាស់ នៅក្នុងប្រព័ន្ធគ្រប់គ្រងនិងវាយតម្លៃការថែទាំសុខភាព ទាំងមូលនោះទេ។ ផ្ទុយទៅវិញ ប្រព័ន្ធមេកើយនិយមក្លាយជានិយាមឬវប្បធម៌ ដែលអាចធ្វើឲ្យអន្តរាយដល់ការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងពិតប្រាកដរបស់បុគ្គលិកដែលមានគុណវុឌ្ឍិខ្ពស់ជាច្រើន។
- ការបម្រើការងារពីរកន្លែងកើតមានគ្រប់ ទីកន្លែងទាំងអស់ ដែលបច្ចុប្បន្នកំពុងតែធ្វើឲ្យអន្តរាយដល់ប្រព័ន្ធសុខាភិបាលសាធារណៈ។ នេះគឺជាទំនាស់ផលប្រយោជន៍ដ៏ចំបងនិងពិបាកដោះស្រាយ ពីព្រោះបុគ្គលិកគ្រប់រូបរាប់ចាប់ពីគិលានុបដ្ឋាក រហូតដល់វេជ្ជបណ្ឌិត អ្នកគ្រប់គ្រង និងថ្នាក់ដឹកទាំងឡាយ កំពុងនាំគ្នាបើកគ្លីនិកឯកជនរៀងៗខ្លួន ហើយវាគឺជាស្ថានភាពចុះទឹកក្រពើឡើងលើខ្លានាពេលបច្ចុប្បន្ន។ បុគ្គលិកមួយចំនួន កំពុងធ្វើការងារយ៉ាងដុតដៃដុតជើងដើម្បីកែលម្អប្រព័ន្ធសុខាភិបាលសាធារណៈឲ្យផ្តល់សេវា ថែទាំសុខភាពជូនប្រជាជនបានកាន់តែប្រសើរឡើង ជាពិសេសសម្រាប់ប្រជាជនក្រីក្រ ខណៈដែលបុគ្គលិកខ្លះទៀតប្រើប្រាស់ប្រព័ន្ធសុខាភិបាលសាធារណៈជាកន្លែងកសាងបទពិសោធន៍ និងមុខមាត់ និងដើម្បីទាញយកអ្នកជំងឺទៅព្យាបាលនៅក្នុងគ្លីនិករបស់ខ្លួន ឬក៏ប្រើប្រាស់ប្រព័ន្ធសារធារណៈសម្រាប់ជាកន្លែងបញ្ជូនអ្នកជំងឺសង្គ្រោះបន្ទាន់ទៅ នៅពេលគ្លីនិករបស់ពួកគាត់ពុំអាចជួយសង្គ្រោះបាន។

អនុសាសន៍

- អនុសាសន៍ស្តីពីការកសាងសមត្ថភាពត្រូវបានលើកឡើងនៅក្នុងផ្នែកនៃការផ្តល់សេវានៃឯកសារគោលជំហរនេះ។
- អង្គការមិនមែនរដ្ឋាភិបាល ផ្នែកសុខាភិបាលសូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជាមេត្តារៀបចំឲ្យមានយុទ្ធសាស្ត្ររក្សាបុគ្គលិករួមគ្នាមួយ។ បច្ចុប្បន្ននេះ ស្ថានភាពនៃការចំណាយប្រតិបត្តិការអាទិភាព ដែលត្រូវបានគេស្គាល់ជាអក្សរកាត់ ភាសាអង់គ្លេសថា "ភីអូស៊ី" ដែលចំណាយនេះគឺសម្រាប់បំពេញបន្ថែមលើបៀវត្សរ៍បុគ្គលិក គឺពុំមានភាពច្បាស់លាស់ និងប្រាកដនិយមទេ។ អ្នករៀបចំគោលនយោបាយកម្ពុជា និងដៃគូអភិវឌ្ឍន៍ ត្រូវការធ្វើការជាមួយគ្នាឲ្យជិតស្និទបន្ថែមទៀត ដើម្បីរៀបចំយុទ្ធសាស្ត្រប្រាក់លើកទឹកចិត្តដកចេញនិងដាក់ចូលរយៈពេលវែង។ កំណែទម្រង់រដ្ឋបាលសាធារណៈនឹងត្រូវការពេល វេលាវែងទៀត ហើយយុទ្ធសាស្ត្រដែលបានផ្តល់ជាមតិយោបល់នេះគួរត្រូវបានដាក់បញ្ចូលទៅក្នុងកំណែទម្រង់នេះ។ តម្រូវការឲ្យមានយុទ្ធសាស្ត្រប្រាក់លើកទឹកចិត្តមួយដែលមានភាពប្រាកដនិយម ដើម្បីរក្សាបុគ្គលិកឲ្យនៅបានកាន់តែយូរនិងការបែងចែកបុគ្គលិកបានប្រសើរជាងមុន ពុំគួរត្រូវបានមើលរំលងឡើយ ហើយយុទ្ធសាស្ត្រនេះទាមទារឲ្យមានវិធានការជាបន្ទាន់។
- គ្រូពេទ្យជំនាញអាជីពនានា ជាពិសេសអ្នកដែលស្ថិតនៅក្នុងថ្នាក់គ្រប់គ្រងនិងគោលនយោបាយ ទាមទារឲ្យមានការយល់ដឹងឲ្យបានទូលំទូលាយអំពីជំនាញសុខភាពសាធារណៈ ហើយនិស្សិតវេជ្ជសាស្ត្រដែលប្រាថ្នាចង់បម្រើការងារក្នុងតួនាទីរៀបចំគោលនយោបាយនិងគ្រប់គ្រង គួរមានការបណ្តុះបណ្តាលជំនាញបន្ថែមស្តីពីសុខភាព

សាធារណៈ។ ដូចគ្នានេះដែរ ជំនាញដឹកនាំនិងគ្រប់គ្រង និងជំនាញសុខភាពសាធារណៈ គួរតែជាលក្ខខណ្ឌ សម្រាប់មន្ត្រីក្នុងតួនាទី ដូចជា ប្រធានមន្ទីរពេទ្យ ប្រធានការិយាល័យស្រុកប្រតិបត្តិ ប្រធានមន្ទីរសុខាភិបាល ប្រធានយកដ្ឋាននានាក្នុងក្រសួងសុខាភិបាល និងមន្ត្រីរៀបចំគោលនយោបាយជាដើម។ ការផ្លាស់ប្តូរពីប្រព័ន្ធ មេកើយនិយម ទៅរកប្រព័ន្ធសមត្ថភាពនិយម គួរតែជាផ្នែក មួយនៃយុទ្ធសាស្ត្ររក្សាបុគ្គលិកឲ្យនៅដែលរៀបចំបាន ល្អមួយ ដែលនេះគឺជាការលើកទឹកចិត្តមួយក្នុងការប្រតិបត្តិតាមពុទ្ធឱវាទ "ធ្វើល្អ បានផលល្អ" ដែលប្រជាជនខ្មែរជា ច្រើនមានជំនឿ។

- ទីភ្នាក់ងារប្រតិបត្តិការពិសេស/កញ្ចប់ថវិកាស ម្រាប់ផ្តល់សេវា គួរត្រូវបានពង្រីកបន្ថែម ដោយហេតុថាទីភ្នាក់ងារ ទាំងពីរហាក់ដូចជាយុទ្ធសាស្ត្រប្រាក់លើកទឹកចិត្ត ដ៏ប្រសើរមួយសម្រាប់គាំទ្រដល់កម្រិតប្រតិបត្តិការ។ ការកែលម្អ នូវគុណភាពនៃការផ្តល់សេវាថែទាំសុខភាព ពុំអាចធ្វើទៅ បានដោយគ្រាន់តែផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើប្រព័ន្ធសាធារណៈនោះទេ ប៉ុន្តែសំខាន់បំផុតត្រូវផ្តោតលើការ គ្រប់គ្រងនៃប្រព័ន្ធសុខាភិបាលទាំងមូល ទាំងវិស័យសាធារណៈនិងវិស័យឯកជនផងដែរ។

ជ-ប្រព័ន្ធព័ត៌មានសុខាភិបាល

ផ្នែកនេះមានភាពប្រសើរឡើងគួរឲ្យកត់សំគាល់ ដោយបានប្រែក្លាយពីប្រព័ន្ធព័ត៌មានសុខាភិបាលដែលគ្រប់គ្រង ដោយដៃ ទៅជាប្រព័ន្ធដែលប្រើដោយកំព្យូទ័រនិងអ៊ិនធឺនែត។ ប្រព័ន្ធដែលប្រើដោយកំព្យូទ័រនេះ មាននៅចាប់ពីថ្នាក់មន្ទីរ ពេទ្យបង្អែកនិងការិយាល័យស្រុកប្រតិបត្តិ រហូតដល់ថ្នាក់ខេត្តនិងថ្នាក់ជាតិ តែយ៉ាងនេះក្តីថ្នាក់មណ្ឌលសុខភាពនៅតែ បំពេញរបាយការណ៍មណ្ឌលសុខភាពប្រចាំខែដោយដៃនៅឡើយ រួចបញ្ជូនទៅការិយាល័យស្រុកប្រតិបត្តិដើម្បីបញ្ចូល ទៅក្នុងប្រព័ន្ធអ៊ិនធឺនែត។

បញ្ហាគន្លឹះ

- យ៉ាងណាក្តី អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពក៏សង្កេតឃើញមានបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែល ត្រូវមានការដោះស្រាយដូចជា (១)គុណភាពទិន្នន័យនៃប្រព័ន្ធព័ត៌មានសុខាភិបាល (២)ការមិនដាក់បញ្ចូលនូវ ទិន្នន័យពីវិស័យឯកជនទៅក្នុងប្រព័ន្ធ (៣)ការមានរបាយការណ៍ហើយដែលមានលក្ខណៈទាន់ពេលសម្រាប់គ្រប់ ភាគីពាក់ព័ន្ធដែលចាប់អារម្មណ៍ទាំងអស់ (៤)ការវិភាគ និងការប្រើប្រាស់ទិន្នន័យ (ល្អបើដឹង ប៉ុន្តែមិនចាំបាច់ត្រូវ ដឹង) (៥)កង្វះសមត្ថភាពក្នុងការវិភាគទិន្នន័យ ជាពិសេសនៅថ្នាក់មណ្ឌលសុខភាព។
- គុណភាពនៃទិន្នន័យ៖ ភាពត្រឹមត្រូវនៃទិន្នន័យនៅតែជាបញ្ហា គន្លឹះគួរឲ្យបារម្ភនៅឡើយ ដែលនេះអាច បណ្តាលមកពីកំហុសបង្ករដោយមនុស្ស (ជំនាញមានកម្រិត ឆន្ទៈ ការតាំងចិត្ត និងការខំប្រឹងប្រែង) និងប្រព័ន្ធ ព័ត៌មានសុខាភិបាលខ្លួនឯងផ្ទាល់ ដែលរួមមានដូចជាយន្តការត្រួតពិនិត្យគុណភាព ទិន្នន័យដែលដំណើរការនៅ មានកម្រិតជាដើម។ ជាងនេះទៀត ប្រព័ន្ធព័ត៌មានសុខភិបាលហាក់ដូចជាមានសូចនាករច្រើន ប៉ុន្តែពុំមែនជា សូចនាករដែលបង្ហាញពីហេតុផលសមរម្យសម្រាប់តម្រូវការនោះទេ។
- របាយការណ៍ទិន្នន័យពីប្រព័ន្ធព័ត៌មានសុខាភិបាល នៅពុំទាន់មានចែកចាយជាសាធារណៈដល់ភាគីពាក់ព័ន្ធនានា ដែលចាប់អារម្មណ៍ឲ្យបានទាន់ពេលវេលានៅឡើយទេ។ របាយការណ៍តាមប្រព័ន្ធអ៊ិនធឺនែតនៅកំពុងត្រូវបាន រៀបចំ និងមិនទាន់បានផ្សព្វផ្សាយជាសាធារណៈនៅឡើយ។
- អ្នករៀបចំគោលនយោបាយ មានការតាំងចិត្តរួចទៅហើយក្នុងការដាក់បញ្ចូលវិស័យឯកជនទៅក្នុងប្រព័ន្ធព័ត៌មាន សុខាភិបាល ប៉ុន្តែយ៉ាងណាក្តីបញ្ហាប្រឈមគឺការអនុវត្តនូវការតាំងចិត្តនេះ។ បច្ចុប្បន្ន ក្រសួងសុខាភិបាលបានដាក់ បញ្ចូលទិន្នន័យរបស់អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនមួយចំនួនទៅក្នុងប្រព័ន្ធទិន្នន័យព័ត៌មាន សុខាភិបាលរួចហើយ។ ការដាក់បញ្ចូលនេះ ទាមទារឲ្យមានកិច្ចសហការនិងសហប្រតិបត្តិការប្រសើរជាងមុនពី

វិស័យឯកជន ហើយវាជាតួនាទីមួយ ដែលប្រកបដោយភាពប្រឈមសម្រាប់មន្ទីរសុខាភិបាលក្នុងការធានាឲ្យបាននូវការរាយការណ៍ទៀងទាត់ប្រកបដោយគុណភាពពីវិស័យឯកជន។

អនុសាសន៍

- ការធ្វើឲ្យប្រសើរឡើងនូវគុណភាពទិន្នន័យទាមទារទាំងការតាំងចិត្តផ្នែកយោបាយនិងការត្រួតពិនិត្យទៀងទាត់ហ្មត់ចត់ និងការគាំទ្រពីអ្នកគ្រប់គ្រងតាមវិស័យ ឬមន្ត្រីនៃនាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលដើម្បីធានាឲ្យបានថា (១)ទិន្នន័យមានភាពត្រឹមត្រូវ (២)ការពិនិត្យឬបញ្ជាក់ឡើងវិញពីភាពត្រឹមត្រូវរបស់វាដោយថ្នាក់ខេត្តនិងថ្នាក់ជាតិ (៣)មានការផ្តល់ប្រាក់លើកទឹកចិត្តពិសេសខ្លះដល់បុគ្គលិកទទួលខុសត្រូវក្នុងការកត់ត្រានិងបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធអ៊ិនធឺណែត និង (៤)មានការផ្តល់ឲ្យបានទៀងទាន់នូវព័ត៌មានត្រឡប់ការបណ្តុះបណ្តាល និងការតំរែតម្រង់ផ្លូវដល់ពួកគាត់។
- របាយការណ៍ទិន្នន័យពីប្រព័ន្ធព័ត៌មានសុខាភិបាលគួរមានចែកចាយជាសាធារណៈជូនភាគីពាក់ព័ន្ធនានាដែលចាប់អារម្មណ៍ប្រើប្រាស់បានទាន់ពេលវេលា។ ការបច្ចេញទិន្នន័យនេះឲ្យសាធារណជនប្រើប្រាស់នឹងជម្រុញឲ្យមានការប្រើប្រាស់ទិន្នន័យ នៃប្រព័ន្ធព័ត៌មានសុខាភិបាល ហើយក៏នឹងបង្កើនផងដែរនូវភាពបើកចំហនិងតម្លាភាព ដែលទីបំផុតប្រការនេះនឹងនាំមានសុក្រឹត្យភាពព័ត៌មានកាន់តែប្រសើរឡើង។
- អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពសូមស្នើជាមតិយោបល់ថា សូចនាករ សុខាភិបាលទាំងអស់នៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលបច្ចុប្បន្នត្រូវមានការកែលម្អនិងបង្ហាញពីហេតុផលជាក់លាក់ ដែលជាការល្អគប្បីប្រមូលតែព័ត៌មានដែលត្រូវដឹង មិនមែនព័ត៌មានដែលគ្រាន់តែល្អមើលឡើយ។ ការបង្ហាញពីហេតុផលនៃទិន្នន័យដែលត្រូវការនេះ នឹងធ្វើឲ្យប្រព័ន្ធព័ត៌មានសុខាភិបាលកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផលជាងនេះ ហើយក៏នឹងកាត់បន្ថយបន្ទុកការងាររបស់បុគ្គលិកផ្នែកប្រព័ន្ធព័ត៌មានសុខាភិបាលនៅថ្នាក់ប្រតិបត្តិផងដែរ។
- ការកសាងសមត្ថភាព លើការវិភាគនិងប្រើប្រាស់ទិន្នន័យ ជាពិសេសសម្រាប់អ្នករៀបចំផែនការសុខាភិបាលនៅថ្នាក់ប្រតិបត្តិ នឹងចូលរួមក្នុងការបង្កើនគុណភាពទិន្នន័យនិងការរៀបចំផែនការឲ្យកាន់តែប្រសើរឡើង។ ការវិភាគទិន្នន័យនឹងជួយយើងឲ្យយល់កាន់ តែច្បាស់ថាយើងកំពុងនៅទីណា ហើយត្រូវការកែលម្អអ្វីបន្ថែមទៀតដើម្បីសម្រេចនូវគោលដៅឬលទ្ធផលដែលចង់បាន។

ឈ. អភិបាលកិច្ចប្រព័ន្ធសុខាភិបាល

អភិបាលកិច្ចគឺឆ្អឹងខ្នងនៃការពង្រឹងប្រព័ន្ធថែទាំសុខភាព ហើយការបង្កើនធនធានបន្ថែមសម្រាប់ពង្រឹងប្រព័ន្ធសុខាភិបាលសាធារណៈជាការសំខាន់ ប៉ុន្តែពុំទាន់គ្រប់គ្រាន់ក្នុងកាជម្រុញការផ្លាស់ប្តូរឡើយ។ ក្រសួងសុខាភិបាលបានកំណត់អភិបាលកិច្ចប្រព័ន្ធសុខាភិបាល ជាសសរស្តម្ភយុទ្ធសាស្ត្រពហុវិស័យមួយដ៏សំខាន់ នៅក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០០៨-២០១៥។ យ៉ាងណាក្តី ការពង្រឹងអភិបាលកិច្ចល្អទាមទារឲ្យមានការចូលរួមយ៉ាងសកម្មពីសហគមន៍ក្នុងការកែលម្អនូវប្រព័ន្ធប្រតិបត្តិសុខាភិបាល។

បញ្ហាគន្លឹះ

- ការចូលរួមរបស់សហគមន៍ក្នុងកិច្ចអភិបាលកិច្ចល្អនៅមានកម្រិត ឧទាហរណ៍ កង្វះសមត្ថភាព ប្រព័ន្ធឬយន្តការនានា ព័ត៌មានសាធារណៈស្តីពីថវិកាសុខាភិបាលនិងការទំលាក់សាច់ប្រាក់ និងកាតាលីករឌីណាមិកក្នុងការសម្របសម្រួលឬធ្វើជាស្ពានរវាងសហគមន៍និងប្រព័ន្ធព័ត៌មានប្រតិបត្តិសុខាភិបាល។
- ការយល់ដឹងមានកំណត់របស់សហគមន៍នានាអំពី សិទ្ធិនិងកាតព្វកិច្ចរបស់អតិថិជន និងរបស់អ្នកផ្តល់សេវា។

- ការបង្កើនការចូលរួមរបស់សហគមន៍គឺជាសសរស្តម្ភគន្លឹះនៃ ផែនការយុទ្ធសាស្ត្រសុខាភិបាលរបស់រាជរដ្ឋាភិបាល។ ក្រសួងសុខាភិបាលបានបង្កើតនូវគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាពដែលរួមមានសមាសភាពមកពីថ្នាក់ដឹកនាំក្រុមទ្រទ្រង់សុខភាពភូមិ ជំទប់ក្រុមប្រឹក្សាឃុំ និងប្រធានមណ្ឌលសុខភាព និងឆ្មបដែលនេះគឺជារចនាសម្ព័ន្ធមួយ ដែលបង្កើតឡើងសម្រាប់ការចូលរួមរបស់សហគមន៍ក្នុងការកែលម្អអភិបាលកិច្ចលើ ប្រព័ន្ធសុខាភិបាលសាធារណៈ។ ទោះជាបែបនេះក្តី រចនាសម្ព័ន្ធដែលមានស្រាប់នេះពុំសូវមានដំណើរការល្អនៅទូទាំងប្រទេសទេ លើកលែងតែនៅតាមតំបន់មួយចំនួនដែលមានការគាំទ្រពីខាងក្រៅ ជាពិសេសដោយអង្គការមិនមែនរដ្ឋាភិបាល ហើយលើសពីនេះទៀត គោលនយោបាយស្តីពីការចូលរួមរបស់សហគមន៍ ដែលត្រូវបានធ្វើការកែសម្រួលនៅក្នុង ឆ្នាំ២០០៨នោះ រហូតមកដល់ពេលនេះពុំទាន់ត្រូវបានបញ្ចប់ទេ ដែលប្រការនេះធ្វើឲ្យមានការយល់ច្រឡំពីច្រើនក្នុង ចំណោមភាគីពាក់ព័ន្ធនានា។
- សហគមន៍ និងអាជ្ញាធរមូលដ្ឋានហាក់ដូចជាពុំសូវមានសម្លេងនិងការចូលរួមនៅក្នុងការផ្តល់សេវាការថែទាំសុខភាពកម្រិតទីពីរនិងទីបី ពោលគឺថ្នាក់មន្ទីរពេទ្យដែលពុំមានយន្តការដូចបានរៀបរាប់ដូចជានៅថ្នាក់មណ្ឌលសុខភាព។
- ក្រសួងសុខាភិបាលគឺជាអ្នកទទួលបន្ទុកលើលទ្ធកម្មដែលមានតម្លៃរាប់លានដុល្លារសម្រាប់ទិញឱសថ សម្ភារៈ និងបរិក្ខារសុខាភិបាល។ល។ ជារៀងរាល់ឆ្នាំ ដោយប្រើប្រាស់ថវិកាជាតិ ហើយនៅក្នុងដំណើរការលទ្ធកម្មដ៏សំខាន់នេះ ការចូលរួមពាក់ព័ន្ធរបស់អង្គការសង្គមស៊ីវិលនិងសហគមន៍ ហាក់មានតូច ឬពុំមានសោះ។

អនុសាសន៍

- អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពសូមស្នើសុំបន្ទាន់ដល់ក្រសួងសុខាភិបាល មេត្តាអនុម័តលើគោលនយោបាយស្តីពីការចូលរួមរបស់សហគមន៍ឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដើម្បីសម្រេចបាននូវការចូលរួមកាន់តែច្រើនរបស់សហគមន៍ ដូចដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាល។
- មន្ទីពេទ្យបង្អែកគួរបង្កើតគណៈ កម្មាធិការគ្រប់គ្រងមន្ទីរពេទ្យបង្អែក ដែលមានតំណាងមកពីសហគមន៍និងអាជ្ញាធរមូលដ្ឋានដូចជាសមាជិកក្រុម ប្រឹក្សាឃុំចូលរួម ហើយពួកគាត់គួរជាម្ចាស់លើគណៈកម្មាធិការនេះ ដែលជាកន្លែងដែលអ្នកប្រើប្រាស់សេវាអាចបញ្ចេញមតិយោបល់អំពីគុណភាព និងការទទួលបានសេវាថែទាំសុខភាពទាំងឡាយ។
- ទាំងគណៈកម្មាធិការគ្រប់គ្រងមណ្ឌល សុខភាព ទាំងគណៈកម្មាធិការគ្រប់គ្រងមន្ទីរពេទ្យបង្អែក គប្បីមានដំណើរការល្អ ដើម្បីសហគមន៍និងអាជ្ញាធរមូលដ្ឋានអាចចូលរួម នៅក្នុងដំណើរការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ មានការយល់ដឹងអំពីថវិកាប្រចាំឆ្នាំ និងការទំលាក់ថវិកាប្រចាំត្រីមាស របស់មូលដ្ឋានសុខាភិបាល អាចចូលរួមយ៉ាងសកម្មក្នុងការកែលម្អគុណភាពនិងការទទួលបាននូវសេវាថែទាំសុខភាពរបស់ប្រជាជន។ យន្តការគណៈកម្មាធិការទាំងពីរនេះ គួរស្ថិតនៅក្រោមភាពជាម្ចាស់របស់អាជ្ញាធរមូលដ្ឋាន និងមានការគាំទ្រហិរញ្ញវត្ថុតាមរយៈផែនការអភិវឌ្ឍន៍មូលដ្ឋានតាមបែបវិមជ្ឈការនិងវិសហមជ្ឈការ។
- បង្កើតនូវវប្បធម៌នៃកិច្ចពិភាក្សាគ្នាជា បន្តរវាងសហគមន៍ អាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធប្រតិបត្តិសុខាភិបាល ដែលទង្វើបែបនេះនឹងចូលរួមជាបណ្តើរៗ ក្នុងការពង្រឹងអភិបាលកិច្ចល្អនៃប្រព័ន្ធសុខាភិបាល។
- វេទិកាសុខភាពសហគមន៍ ដែលជាឧទាហរណ៍មួយនៃយន្តការពិភាក្សា ហើយត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋានដោយមានកិច្ចសហការណ៍ជាមួយអង្គការ ម៉ែឌីខាំ បានទទួលជោគជ័យក្នុងការទាមទារឲ្យមានគុណភាពនិងការទទួលបានកាន់តែប្រសើរឡើងនូវសេវាថែទាំសុខភាព ដូចជា ការប្រើប្រាស់កាន់តែច្រើននូវសេវាសាធារណៈ តវិយាបទកាន់តែប្រសើររបស់អ្នកផ្តល់សេវា ការយល់ដឹងកាន់តែច្បាស់ ពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់និងអ្នកផ្តល់សេវា និងការប្រើប្រាស់សិទ្ធិកាន់តែច្រើនរបស់ពួកគាត់ក្នុងការទាមទារឲ្យមានការ

ផ្តល់សេវាសុខភាពកាន់តែប្រសើរឡើង[85] ដែលយន្តការនេះគួរត្រូវបានពិចារណាឲ្យមានការពង្រីក និងការយកជាគំរូអនុវត្តបន្ត។

- កិច្ចលទ្ធកម្មគួរមានការបើកចំហនិងតម្លាភាពបន្ថែម ដែលដំណើរការនេះគួរមានការពិនិត្យនិងចូលរួមពីសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ។

ញ-ច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល

ការរៀបចំនិងខ្លឹមសារនៃច្បាប់ថ្មីសម្រាប់គ្រប់គ្រងសមាគមន៍និងអង្គការមិនមែនរដ្ឋាភិបាល គឺជាបញ្ហាបារម្ភដ៏ធំរបស់អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងឆ្នាំ២០១១ ទាំងមូល។ អង្គារម៉េឌីខាំ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានចូលរួមយ៉ាងសកម្មពាក់ព័ន្ធនឹងដំណើរការនេះជាមួយនឹងរាជរដ្ឋាភិបាល សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីបញ្ចេញនូវទស្សនៈ និងការព្រួយបារម្ភរបស់អង្គការជាសមាជិករបស់ខ្លួន។

យើងខ្ញុំមានការសោកស្តាយដែលការអនុញ្ញាតឲ្យសង្គមស៊ីវិលនិងអង្គការមិនមែនរដ្ឋាភិបាលចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំច្បាប់ថ្មីនេះនៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ ហើយមកទល់សព្វថ្ងៃភាគច្រើននៃមតិយោបល់និងការព្រួយបារម្ភរបស់សង្គមស៊ីវិលនិងអង្គការមិនមែនរដ្ឋាភិបាលនៅពុំទាន់បានអ្នករៀបចំខ្លឹមសារច្បាប់ទទួលពិចារណាគ្រប់គ្រាន់នៅឡើយ។ បញ្ហាគន្លឹះៗនៅក្នុងសេចក្តីថ្លែងការណ៍រួមនៃសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ដែលអង្គការម៉េឌីខាំសូមស្នើសុំយ៉ាងទទូចនៅក្នុងឯកសារនេះរួមមាន៖

- ដំណើរការចុះឈ្មោះនៅក្នុងទម្រង់បច្ចុប្បន្នមានភាពស្មុគស្មាញ ពុំមានការស្ម័គ្រចិត្ត និងសាមញ្ញទេ។
- នៅក្នុងពង្រាងច្បាប់បច្ចុប្បន្ន ពុំមានការការពារទាល់តែសោះដើម្បីធានាឲ្យបានថាទាំងការបដិសេធនូវការចុះឈ្មោះ ឬការរំលាយដោយមិនស្ម័គ្រចិត្តត្រូវបានចាប់បង្ខំ។
- ច្បាប់នេះពុំបានដាក់បញ្ចូលនូវរយៈពេលនៃដំណើរការប្តឹងឧទ្ធរចំពោះការបដិសេធការចុះឈ្មោះ។
- ពាក្យគន្លឹះនៅក្នុងច្បាប់ពុំមានការកំណត់និយមន័យច្បាស់លាស់ ហើយជំពូកនិងពាក្យបច្ចេកទេសជាច្រើនមានភាពស្រពិចស្រពិល ដែលប្រការនេះទាមទារឲ្យមានការពិនិត្យឡើងវិញប្រសិនបើច្បាប់ថ្មីនេះនឹងត្រូវបង្កើតឡើងដើម្បីអនុវត្តក្នុងលក្ខណៈស្របគ្នានិងមិនលម្អៀង។

អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលកន្លងមក បានបំពេញតួនាទីមួយយ៉ាងសំខាន់នៅក្នុងដំណើរការអភិវឌ្ឍន៍នៅកម្ពុជាក្នុងរយៈពេលជា ២០ឆ្នាំ ចុងក្រោយនេះ ហើយការបន្តតួនាទីនេះគឺជាការសំខាន់។ អង្គការម៉េឌីខាំ និងសមាជិករបស់ខ្លួនសូមធ្វើការស្នើសុំដល់អ្នកធ្វើគោលនយោបាយ និងសហគមន៍អន្តរជាតិឲ្យជួយធានាថាខ្លឹមសារនៃច្បាប់ថ្មីនេះនឹងផ្តល់នូវបរិយាកាសអំណោយផលមួយសម្រាប់ឲ្យអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជនកម្ពុជាបានចូលរួមដោយសកម្ម ពេញលេញ និងប្រកបដោយអត្ថន័យ នៅក្នុងការរីកចំរើននិងអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាក្នុងពេលអនាគត។

ត-តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល

ដើម្បីចូលរួមយូរអង្វែងក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល និងស្ថានភាពសុខភាពរបស់ប្រជាជន ក៏ដូចជារួមគ្នាឆ្លើយតបនឹងបញ្ហាប្រឈម និងអនុវត្តនូវសំណូមពរនៅក្នុងឯកសារគោលជំហរនេះ អង្គការមិនមែនរដ្ឋាភិបាលគួរបន្តរបំពេញតួនាទី ដែលពុំមានកំណត់ត្រឹមតែតួនាទីសំខាន់ៗខាងក្រោមនេះប៉ុណ្ណោះ៖

- ការតស៊ូមតិ៖ ការចូលរួមយ៉ាងសកម្មនិងប្រកបដោយអត្ថន័យនៅក្នុងការរៀបចំអាទិភាពគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់ប្រទេស។

[85] MEDiCAM's consolidated report on Community Health Forums 2011, funded by EU, DFID, and GFATM

- អ្នកឃ្លាំមើល៖ ការចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យនៅក្នុងការត្រួតពិនិត្យនិងវាយតម្លៃរួមលើការអនុវត្ត អាទិភាពគោលនយោបាយ និងយុទ្ធសាស្ត្រទាំងនោះ។
- ការផ្តល់នូវសេវាថែទាំសុខភាពនិងគំនិតផ្តួចផ្តើមថ្មីៗ បង្ក្រប់បន្ថែម៖ បន្តបំពេញចន្លោះប្រហោងទាំងឡាយណា ដែលប្រព័ន្ធសាធារណៈមិនអាចទៅដល់ និងគាំទ្រវិស័យសាធារណៈដើម្បីឲ្យប្រព័ន្ធនេះនៅទីបំផុតអាចទទួល បន្ទុកក្នុងការបម្រើប្រជាពលរដ្ឋ។
- លើកកម្ពស់ការយល់ដឹងនិងការផ្លាស់ប្តូរឥរិយាបទចំពោះសហគមន៍ ដើម្បីឲ្យពួកគាត់អាចចូលរួមយ៉ាងសកម្មនិង ប្រកបដោយអត្ថន័យក្នុងការលើកកម្ពស់អភិបាលកិច្ចល្អនិងគណនេយ្យភាពសង្គម។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

អង្គការមេឌីខាំ (MEDiCAM)
លោកវេជ្ជបណ្ឌិត ស៊ីន សុមុនី នាយកប្រតិបត្តិ
ទូរស័ព្ទ៖ (៨៥៥-១២) ៥៧៣ ០៦២ ឬ (៨៥៥-២៣) ៨៨០ ២៩១ - លេខភ្ជាប់ ១០៧
ទូរសារ៖ (៨៥៥-២៣) ៨៨០ ២៩២
អ៊ីម៉ែល៖ info@medicam-cambodia.org គេហទំព័រ៖ www.medicam-cambodia.org
អាសយដ្ឋាន៖ ផ្ទះលេខ៤ ផ្លូវលេខ ៥២២ សង្កាត់ បឹងកក់ ១ខណ្ឌទួលគោក រាជធានីភ្នំពេញ (ប្រអប់សំបុត្រ ១១៦៤)

ការព្រួយបារម្ភលើបញ្ហាពលកម្ម និងលក្ខខណ្ឌការងារនៅក្នុងប្រទេសកម្ពុជា

១. ទស្សនៈរួម

នៅប្រទេសកម្ពុជា ចំនួនកំលាំងពលកម្មមានការផ្លាស់ប្តូរយ៉ាងច្រើននៅប៉ុន្មានទស្សវត្សរ៍ចុងក្រោយនេះ។ ទោះជាយ៉ាងណាក៏ដោយ ចំនួនអ្នកដែលមានការងារធ្វើមានការកើនឡើងតិចតួចនៅឡើយ គឺត្រឹមតែ ១.៣% ប៉ុណ្ណោះ ក្នុង១ ឆ្នាំ នៅចន្លោះឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០០៨[86]។ ទោះបីរបាយការណ៍ជាផ្លូវការរបស់រដ្ឋាភិបាលបង្ហាញថា ចំនួនអ្នកគ្មានការងារធ្វើនៅក្នុងប្រទេសកម្ពុជាមានចំនួនតិចតួចក៏ដោយ ប៉ុន្តែអ្នកដែលមានការងារធ្វើមួយចំនួនធំគឺនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ វិស័យកសិកម្ម និងវិស័យឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌដែលមានការកើនឡើងដែរនៅទស្សវត្សរ៍ចុងក្រោយនេះ។ លើសពីនេះទៅទៀត ទិន្នន័យនៃអ្នកដែលធ្វើការនៅក្នុងវិស័យទាំងនេះ មានការកើនឡើងតិចតួច ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមូលហេតុចំណាកស្រុកទៅស្វែងរកការងារធ្វើ ទាំងក្នុងស្រុក និងក្រៅស្រុក។

សហភាពការងារកម្ពុជា (CLC) ជាសហភាពការងារឯករាជ្យ និងប្រជាធិបតេយ្យ ដែលមានសមាជិក ៦៣,៨៨០ នាក់ មកពីវិស័យកាត់ដេរ និងវាយនភ័ណ្ឌ ទេសចរណ៍ សេវាកម្ម ចំណីអាហារ សេដ្ឋកិច្ចក្រៅប្រព័ន្ធ សំណង់ កសិកម្ម វិស័យសាធារណៈ និងវិស័យការងារមួយចំនួនផ្សេងទៀត។ សហភាពការងារកម្ពុជា មានទស្សនវិស័យ ដើម្បីធានាថា ប្រជាពលរដ្ឋខ្មែរទាំងអស់ ទទួលបានសង្គមមួយមាននីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្សពេញលេញភាពស្មើគ្នារវាងបុរស និងស្ត្រី ជីវភាពរស់នៅសមរម្យ និងថ្លៃថ្នូរ។

នាបច្ចុប្បន្ននេះ សហភាពការងារកម្ពុជា បានមើលឃើញបញ្ហាជាច្រើនដែលកំពុងតែកើតមាន នៅក្នុងវិស័យការងារទូទាំងប្រទេសកម្ពុជា ដែលក្នុងនោះរួមមានដូចជា ប្រាក់ចំណូលទាប មានកិច្ចការពារតិចតួចពីសង្គម ជាពិសេស ចំពោះកម្មករអន្តោប្រវេសន៍ និងអ្នកបំរើការងារតាមផ្ទះ សុវត្ថិភាពការងារ និងប្រាក់ចំណូល លក្ខខណ្ឌការងារមិនល្អប្រសើរ និងមិនមានសេរីភាពពេញលេញក្នុងការចូលរួមជាសមាជិក ក៏ដូចជាការចូលរួមសកម្មភាពរបស់សហជីព ឬសមាគមជាដើម។

២. សូចនាករតាមដានរួម

បញ្ហាពលកម្ម និងលក្ខខណ្ឌការងារ មិនមានសូចនាករតាមដានរួមទេ។

៣.គោលនយោបាយ/សកម្មភាព/យុទ្ធសាស្ត្រសំខាន់ៗពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣

ផ្នែក	សារ
៤៩៦	សេរីភាពសហជីព ត្រូវបានលើកកម្ពស់។ យន្តការត្រួតពិនិត្យការងារ និងដោះស្រាយវិវាទការងារត្រូវបានពង្រឹងដើម្បីតាមដាន ត្រួតពិនិត្យ ការជំរុញការអនុវត្តច្បាប់ស្តីពីការងារ និងធានានូវបរិស្ថានការងារប្រកបដោយសុខដុមរមនា។
៤៩៧	រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្ម ទៅនឹងលក្ខខណ្ឌការងារ
៤៩៩	ការធានាឲ្យមានលក្ខខណ្ឌការងារល្អ មានសុវត្ថិភាពត្រឹមត្រូវមានអនាម័យ និងមានលក្ខខណ្ឌកិច្ចសន្យាត្រឹមត្រូវ និងយុត្តិធម៌សម្រាប់ពលករ នៅកន្លែងការងារ។

[86] និន្នាការពលកម្ម និងការងារកម្ពុជា ឆ្នាំ២០១០ (ILO & NIS, 2010)

៨៩៩	ដាក់កម្រិតអប្បរមានៃប្រាក់ឈ្នួលប្រចាំខែ និងថ្ងៃឈប់សម្រាក កាត់បន្ថយវិសមភាពប្រាក់ឈ្នួលបុរស និងស្ត្រីដោះស្រាយជម្លោះ និងមិនឯកភាពគ្នាដោយសន្តិវិធី។
៨៩៨	កសាងច្បាប់សហជីព ព្រមទាំងក្របខណ្ឌបទដ្ឋានគតិយុត្តិនានា ស្តីពីការបង្កើតតុលាការការងារតាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធ។
៨៩៩	ជំរុញការអភិវឌ្ឍសមត្ថភាពជំនាញបច្ចេកទេស និងវិជ្ជាជីវៈជូនប្រជាពលរដ្ឋសំដៅរួម ចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ជាពិសេស ការលើកកម្ពស់ជនពិការ និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

សេរីភាពសហជីព ត្រូវបានលើកម្ពស់។ យន្តការត្រួតពិនិត្យការងារ និងដោះស្រាយវិវាទការងារត្រូវបានពង្រឹងដើម្បីតាមដានត្រួតពិនិត្យ ជំរុញការអនុវត្តច្បាប់ស្តីពីការងារ និងធានានូវបរិស្ថានការងារប្រកបដោយសុខដុមរមនា។

ប្រទេសកម្ពុជានៅតែជួបប្រទះនូវការរំលោភសិទ្ធិការងារ និងសិទ្ធិសហជីព ក្នុងនោះមានការគុំគួន និងការបញ្ឈប់ថ្នាក់ដឹកនាំសហជីព។ ការបង្កើតសហជីពនៅក្នុងវិស័យសាធារណៈ (មន្ត្រីរាជការ) ដូចជាវិស័យគ្រូបង្រៀននៅតែជាបញ្ហា[87]។ ជាការពិត នៅក្នុងប្រទេសកម្ពុជា តែងតែមានការគំរាមកំហែង បាញ់ប្រហារ គាបសង្កត់មកលើកម្មករ និយោជិត និងជាពិសេសគឺសកម្មជនសហជីព។ ភាពជាតំណាងបំផុត (Most Representative Status-MRS) និងកិច្ចព្រមព្រៀងអនុសញ្ញារួមមួយចំនួនមិនទាន់គោរពតាមបទដ្ឋានស្តង់ដារជាតិ និងអន្តរជាតិ ហើយយន្តការទាំងនេះ មិនទាន់មានការត្រួតពិនិត្យ និងធ្វើអធិការកិច្ចពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យបានត្រឹមត្រូវនៅឡើយ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលមិនទាន់មានយន្តការបង្ខំឲ្យក្រុមនិយោជកអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិនៅឡើយ ដែលនេះជាឫសគល់នៃវិវាទការងារ និងជាឫសគល់នៃការបំផ្លាញទំនាក់ទំនងវិជ្ជាជីវៈ។

អនុសាសន៍៖

- ត្រូវមានវិធានការ និងផ្តន្ទាទោសឲ្យបានធ្ងន់ធ្ងរតាមច្បាប់លើជនដែលបានបាញ់ និងបង្កហិង្សាមកលើកម្មករ។
- ចាត់វិធានការយ៉ាងម៉ឺងម៉ាត់ឲ្យនិយោជក បញ្ឈប់ការធ្វើទុក្ខបុកម្នេញ និងការកេងប្រវ័ញ្ចមកលើកម្មករនិយោជិត។
- ពិនិត្យមើលស្តង់ដារ និងភាពត្រឹមត្រូវនៃភាពជាតំណាងបំផុត (Most Representative Status-MRS) និងអនុសញ្ញារួមនៅតាមគ្រឹះស្ថាន ឬសហគ្រាសនីមួយៗ។
- ប្រើយន្តការបង្ខំឲ្យបានម៉ឺងម៉ាត់ដើម្បីឲ្យនិយោជិតគោរពតាមច្បាប់ស្តីពីការងារ និងបទដ្ឋានគតិយុត្តិផ្សេងៗ ដើម្បីជៀសវាងការរំលោភសិទ្ធិកម្មករនិយោជិត។

*រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារតាមរយៈការអនុវត្តប្រកបដោយ**ប្រសិទ្ធភាព**នូវ ស្តង់ដារការងារ បទដ្ឋានពលកម្ម និងច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិនានា រួមទាំងការបន្តជំរុញយន្តការរោងចក្រប្រសើរនៅកម្ពុជា ការនាំចេញពលករទៅបរទេស ការពង្រឹងសមត្ថភាពជំនាញតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យសម្របតាមតម្រូវការទីផ្សារ ។*

គោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារនេះនឹងមិនអាចសម្រេចបានទេ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជានៅតែបន្តអនុវត្តយន្តការ និងគោលនយោបាយយោគយល់ និងបន្ធូរបន្ថយការអនុវត្តច្បាប់ដល់អ្នកវិនិយោគ។ កម្មករដែលកំពុងតែធ្វើការនៅក្នុងវិស័យការងារមួយចំនួនដូចជាវិស័យកាត់ដេរសំលៀកបំពាក់ សំណង់ សេវាកម្មជាដើម បានកំពុងតែធ្វើការថែមម៉ោងហួសហេតុ។ ដោយឡែកនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងដេរស្បែកជើងវិញ

[87] កម្មវិធីការងារសមរម្យប្រចាំប្រទេសកម្ពុជា (២០១១-២០១៥) របស់អង្គការពលកម្មអន្តរជាតិ (២០១២)

ការអនុវត្តត្រឹមត្រូវតាមបទដ្ឋាន ការងារថែមម៉ោងមានត្រឹមតែ១១% ប៉ុណ្ណោះ នេះបើយោងតាមរបាយការណ៍សំយោគលើកទី២១ របស់អង្គការពលកម្មអន្តរជាតិ។ កម្មករ និយោជិតបានកំពុងនឹងជួបប្រទះនូវ បញ្ហាលក្ខខណ្ឌការងារដ៏អាក្រក់នៅកន្លែងការងាររបស់ពួកគេ ដូចជាជាតិគីមី និងឧបករណ៍អេឡិចត្រូនិចផ្សេងៗ ដែលនាំឲ្យពួកគេខូចសុខភាព ដួលសន្លប់ជិត ២០០នាក់នៅក្នុងឆ្នាំ២០១១ នៅក្នុងវិស័យកាត់ដេរ និងគ្រោះថ្នាក់ការងារជាច្រើន នៅក្នុងវិស័យការងារមួយចំនួនទៀត ដូចជា កម្មករនិយោជិតដែលធ្វើការនៅក្នុងវិស័យសំណង់ និងកម្មកររសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាដើម ដោយគ្មានការត្រួតពិនិត្យ និងអធិការកិច្ចត្រឹមត្រូវនៅតាមសហគ្រាស ឬស្ថាប័នទាំងនោះ។

បញ្ហាចំណាកស្រុក ទៅធ្វើការនៅក្រៅប្រទេស មិនមែនជាបញ្ហាថ្មីនោះទេ។ នៅពេលបច្ចុប្បន្ននេះ ការនាំចេញពលករទៅធ្វើការនៅក្រៅប្រទេសបានកំពុងតែមានការកើនឡើងជាគំហុក ដោយគ្មានយន្តការ ឬគោលនយោបាយជាក់លាក់ណាមួយក្នុងការតាមដានដើម្បីការពារសិទ្ធិពលករចំណាកស្រុកទាំងនោះនៅឡើយទេ។ លើសពីនេះទៅទៀត ការងារមួយភាគធំជាការងារគ្មានជំនាញ ដូចជា ការងារបំរើតាមផ្ទះដែលពេញនិយមបំផុតសម្រាប់ពលករដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ប្រទេសថៃ និងប្រទេសក្នុងតំបន់មួយចំនួនទៀត។

អនុសាសន៍៖

- បង្កើតយន្តការបន្ថែម និងអនុវត្តយន្តការដែលមានស្រាប់ឲ្យមានប្រសិទ្ធភាពដើម្បីការពារសិទ្ធិ និងលើកកម្ពស់លក្ខខណ្ឌការងាររបស់កម្មករនិយោជិតគ្រប់វិស័យឲ្យមានភាពល្អប្រសើរ។
- ពង្រឹងការអនុវត្តច្បាប់ដោយជំរុញឲ្យអ្នកវិនិយោគិនគោរពច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិដទៃទៀត។
- បង្កើតឲ្យមានក្រុមអធិការកិច្ចការងារដែលមានជំនាញច្បាស់លាស់ក្នុងការចុះអង្កេតជាទៀងទាត់ នៅតាមសហគ្រាស និងគ្រឹះស្ថានការងារនានាទូទាំងប្រទេស។
- ធ្វើអនុស្សារណៈយោគយល់ ឬកិច្ចព្រមព្រៀងឲ្យបានច្បាស់លាស់ជាមួយបណ្តាប្រទេសដែលទទួលពលករខ្មែរទៅធ្វើការ ដោយត្រូវធានាឲ្យបាននូវសិទ្ធិឈប់សម្រាកប្រចាំសប្តាហ៍ សិទ្ធិជួបជុំ សិទ្ធិចូលរួម និងចងក្រងសហជីព ឬសមាគមស្របតាមអនុសញ្ញា ILO។

ធានាឲ្យមានលក្ខខណ្ឌការងារល្អ មានសុវត្ថិភាពត្រឹមត្រូវ មានអនាម័យ និងមានលក្ខខណ្ឌកិច្ចសន្យាត្រឹមត្រូវ និងយុត្តិធម៌សម្រាប់ពលករ នៅកន្លែងការងារគឺជាកិច្ចការមួយដ៏សំខាន់ក្នុងការជំរុញការអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធវិស័យការងារ។

លក្ខខណ្ឌការងារ និងសុវត្ថិភាពការងារ ពិតជាមានការជាប់ពាក់ព័ន្ធទៅនឹងកិច្ចសន្យាការងារ។ លក្ខខណ្ឌការងារ និងសុវត្ថិភាពការងារនឹងមិនត្រូវបានធានានោះទេ នៅពេលដែលនិយោជិតប្រើប្រាស់កិច្ចសន្យាការងារដែលមានលក្ខខណ្ឌមិនត្រឹមត្រូវ។

យោងតាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ *១០/០៣* បានធ្វើការបកស្រាយយ៉ាងច្បាស់នូវមាត្រា ៦៧ នៃច្បាប់ស្តីពីការងារ ដែលថា កិច្ចសន្យាការងារ មានចិរវេលាកំណត់ត្រូវ ក្លាយទៅជាកិច្ចសន្យាការងារមានចិរវេលាមិនកំណត់ជាស្វ័យប្រវត្តិ កាលណារយៈពេលសរុបនៃកិច្ចសន្យាការងារ (ដោយបូកបញ្ចូលចិរវេលានៃកិច្ចសន្យាដើម និងចិរវេលានៃកិច្ចសន្យាបន្ត) មានចិរវេលាលើសពី ពីរឆ្នាំ។ តែទោះជាយ៉ាងណាក៏ដោយ និយោជកនៅតែបន្តបដិសេធនូវការបកស្រាយមួយនេះ ហើយនៅតែបន្តការប្រើប្រាស់កិច្ចសន្យាការងារដែលមានចិរវេលាកំណត់ ផ្ទុយពីច្បាប់ស្តីពីការងារ នៅស្ទើរគ្រប់វិស័យទាំងអស់ ជាពិសេសចំពោះកម្មករដែលធ្វើការនៅវិស័យកាត់ដេរ និងវិស័យទេសចរណ៍ និងសេវាកម្ម។ លើសពីនេះ សព្វថ្ងៃនេះ និយោជកបានកំពុងតែធ្វើការផ្លាស់ប្តូរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ពីកិច្ចសន្យាការងារដែលមានចិរវេលាកំណត់ មកជាកិច្ចសន្យាការងារដែលមានចិរវេលាមិនកំណត់។ ទាំងនេះ នឹងបង្កើតឲ្យមានអស្ថិរភាពការងារ និងប៉ះពាល់យ៉ាងខ្លាំងចំពោះទំនាក់ទំនងវិជ្ជាជីវៈ។

អនុសាសន៍៖

- បង្កើតយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការជំរុញឲ្យនិយោជកបញ្ឈប់ការប្រើប្រាស់កិច្ចសន្យាការងាររយៈពេលកំណត់ខ្លី។ ដែលជាបុព្វហេតុនាំឲ្យមានការកេងប្រវ័ញ្ចកំលាំងពលកម្ម និងរំលោភសិទ្ធិកម្មករនិយោជិត។
- បង្កើតយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការជំរុញឲ្យនិយោជកបញ្ឈប់ការប្រើប្រាស់កិច្ចសន្យាជួលផលិតបន្តដែលកំពុងតែត្រូវបានអនុវត្តយ៉ាងសកម្មនៅក្នុងវិស័យកាត់ដេរ និងវាយនភ័ណ្ឌ។
- អនុវត្តឲ្យមានប្រសិទ្ធភាពនូវសេចក្តីប្រកាស អន្តរក្រសួងស្តីអំពីការគ្រប់គ្រងកិច្ចសន្យាជួលផលិតបន្ត។
- បង្កើតយន្តការប្រកបដោយប្រសិទ្ធភាព ក្នុងការជំរុញឲ្យនិយោជកគោរពតាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបាននឹងកំពុងដោះស្រាយជាប្រចាំដោយបានដាក់កម្រិតអប្បរមានៃប្រាក់ឈ្នួលប្រចាំខែ និងថ្ងៃឈប់សម្រាក កាត់បន្ថយវិសមភាពប្រាក់ឈ្នួល បុរស និងស្ត្រី ដោះស្រាយជម្លោះ និងមិនឯកភាពគ្នាដោយសន្តិវិធីដោយមិនបង្កឡើងនូវការអាក់ខានចង្វាក់ផលិតកម្ម និងការបាត់បង់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត។

ជាការពិត យោងតាមច្បាប់ស្តីពីការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានសិទ្ធិកំណត់ប្រាក់ឈ្នួលអប្បរមាសម្រាប់វិស័យសេដ្ឋកិច្ចនីមួយៗ ដោយផ្អែកលើអនុសាសន៍ដែលផ្តល់ឲ្យដោយគណៈកម្មាធិការប្រឹក្សាការងារ (LAC)។ គណៈកម្មាធិការប្រឹក្សាការងារ គឺជាស្ថាប័នត្រីភាគីដែលមានសិទ្ធិក្នុងការផ្តល់អនុសាសន៍លើការកំណត់ប្រាក់ឈ្នួលនេះ ប៉ុន្តែនៅក្នុងស្ថាប័នមួយនេះ មានតំណាងសហជីពជាសមាជិកជាច្រើន ដែលមាននិន្នាការគាំទ្ររដ្ឋាភិបាល និងនិយោជក។ ហេតុដូច្នេះ អ្នកទាំងនោះត្រៀមខ្លួនជាស្រេចក្នុងការទទួលយកមតិយោបល់ និងការសម្រេចរបស់រាជរដ្ឋាភិបាល និងនិយោជក ដែលជាហេតុនាំឲ្យមានការកំណត់ប្រាក់ឈ្នួលមិនតាមឆន្ទៈរបស់កម្មករ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលមិនទាន់បានកំណត់ប្រាក់ឈ្នួលអប្បរមាសម្រាប់វិស័យផ្សេងៗនៅឡើយទេ ក្រៅពីវិស័យកាត់ដេរ។ ប្រសិនបើមិនមានការកំណត់ប្រាក់ឈ្នួលអប្បរមាសមស្របសម្រាប់វិស័យនីមួយៗនោះទេ កម្មករនិយោជិតនឹងទទួលរងនូវទុក្ខលំបាកកេងប្រវ័ញ្ចកំលាំងពលកម្ម ធ្វើការច្រើនម៉ោង ដោយមានប្រាក់ឈ្នួលតិចទៅតាមការកំណត់របស់និយោជក។

អនុសាសន៍៖

- បង្កើតនូវយន្តការឯករាជ្យដើម្បី កំណត់សមាសភាព ក្នុងគណៈកម្មាធិការប្រឹក្សាការងារ (LAC) ឡើងវិញ។
- ធ្វើការកំណត់ប្រាក់ឈ្នួលអប្បរមា ដើម្បីធានាជីវភាពរស់នៅសមរម្យសម្រាប់កម្មករនិយោជិតនៅគ្រប់វិស័យ។
- ពិនិត្យឡើងវិញ ក្នុងការកំណត់ប្រាក់ឈ្នួលអប្បរមាក្នុងវិស័យកាត់ដេរ និងវាយនភ័ណ្ឌដើម្បីឲ្យស្របតាមស្ថានភាពកំណើនសេដ្ឋកិច្ចជាតិ។

កសាងច្បាប់សហជីព ព្រមទាំងក្របខណ្ឌបទដ្ឋានគតិយុត្តិនានា ស្តីពីការបង្កើតតុលាការការងារតាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធ។

ខ្លឹមសារពង្រាងច្បាប់សហជីព មិនបានលើកមួស់ដល់ការអនុវត្តសិទ្ធិ និងការលើកតម្កើងដល់ដំណើរការប្រជាធិបតេយ្យនោះទេ។ ផ្ទុយទៅវិញ ខ្លឹមសារនៃច្បាប់នេះកាន់តែមើលឃើញនូវចេតនារឹតត្បិត និងមានក្តណៈ ជាការគ្រប់គ្រងដល់សិទ្ធិសហជីព ដែលជាដៃគូរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិទៅវិញ។ ការពិភាក្សាទៅលើពង្រាងច្បាប់នេះ នៅមិនទាន់ទទួលយកនូវមតិយោបល់ពីសំណាក់សហជីពឲ្យបានទូលំទូលាយនោះទេ។ ជាក់ស្តែង សិទ្ធិរបស់មន្ត្រីរាជការក្នុងការរៀបចំ និងប្រព្រឹត្តិទៅនៃសហជីពមិនទាន់ត្រូវបានទទួលយក ហើយម្យ៉ាងទៀតកម្រិតនៃការជាកពិន័យមកលើសកម្មជនសហជីពមានលក្ខណៈធ្ងន់ធ្ងរ។

លើសពីនេះទៅទៀត បទដ្ឋានគតិយុត្តិនានាស្តីពីការបង្កើតតុលាការការងារ នៅមិនទាន់ចេញជារូបរាងនៅឡើយ។ សំណុំរឿងវិវាទការងារ គឺត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការអាជ្ញាគតិមិនឯករាជ្យ ដែលជាទូទៅ កម្មករ និយោជិតមិនមានទំនុកចិត្ត និងមិនដែលទទួលបានយុត្តិធម៌ពីស្ថាប័នមួយនេះឡើយ។

អនុសាសន៍៖

- បង្កើតច្បាប់សហជីព ដែលស្របទៅនឹងបទដ្ឋានស្តង់ដារអន្តរជាតិ ដើម្បីធានាសិទ្ធិសេរីភាព កម្មករ និយោជិត និងមន្ត្រីរាជការក្នុងការចូលរួមជាសមាជិកសហជីព។
- បង្កើតតុលាការការងារឯករាជ្យ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយមានការចូលរួម ពីសមាសភាពត្រីភាគី (និយោជិត រាជរដ្ឋាភិបាល និងនិយោជក) ។

ជំរុញការអភិវឌ្ឍសមត្ថភាពជំនាញបច្ចេកទេស និងវិជ្ជាជីវៈជូនប្រជាពលរដ្ឋសំដៅរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ជាពិសេស ការលើកកម្ពស់ជនពិការ និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ដូចដែលរបាយការណ៍របស់រាជរដ្ឋាភិបាល បានចេញជាបន្តបន្ទាប់ ប្រទេសកម្ពុជាខ្វះកម្មករជំនាញ។ ចំនួនមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់រដ្ឋ នៅមានកម្រិតតិចតួចបំផុតសម្រាប់ប្រជាជនទូទាំងប្រទេស លើសពីនេះ ព័ត៌មានស្តីពី ទីផ្សារការងារ មិនត្រូវបានផ្សព្វផ្សាយឲ្យបានទូលំទូលាយនៅឡើយ ដែលជាហេតុនាំឲ្យប្រជាពលរដ្ឋខ្មែរមួយចំនួនធំបានកំពុងតែធ្វើការដោយទទួលបានប្រាក់ឈ្នួលតិច មានលក្ខខណ្ឌការងារមិនល្អប្រសើរ មិនមានការគោរពសិទ្ធិការងារ ជាពិសេសចំពោះកម្មករជាស្ត្រី។

អនុសាសន៍៖

- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមបណ្តាខេត្តក្រុងទូទាំងប្រទេស និងបណ្តុះបណ្តាលប្រជាពលរដ្ឋដោយមិនយកប្រាក់កំរៃ ឬយកប្រាក់កំរៃទាបបំផុត។
- បង្កើនការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាឲ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព។
- ផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៨៣ និងបង្កើតយន្តការការពារសិទ្ធិ លក្ខខណ្ឌការងារជូនកម្មករនិយោជិតជាស្ត្រីលើគ្រប់វិស័យ។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

សហភាពការងារកម្ពុជា (CLC)
លោក អាត់ ធន់ ប្រធាន
ទូរស័ព្ទ៖ ០១២ ៩៩៨ ៩០៦
អ៊ីម៉ែល៖ clccambodia@online.com.kh or thorn.clc@gmail.com
គេហទំព័រ៖ www.clccambodia.org

ពិការភាព៖ កិច្ចអភិវឌ្ឍន៍ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ

១. សេចក្តីសង្ខេប

សារៈសំខាន់នៃបញ្ហា៖ ភាពក្រីក្រ និងពិការភាព

ភាពក្រីក្រ និងពិការភាពពង្រឹងនិងអូសបន្លាយគ្នាទៅវិញទៅមក។ ជនពិការ គឺជាអ្នកក្រីក្របំផុតក្នុងចំណោមជនក្រីក្រ ហើយជនក្រីក្រមានការប្រឈមច្រើនទៅនឹងគ្រោះថ្នាក់នៃពិការភាពជាងអ្នកឯទៀត។ ជនពិការទទួលបានការថែទាំសុខភាព និងការអប់រំតិចតួច ហើយមានការលំបាកក្នុងការស្វែងរកការងារធ្វើ ព្រមទាំងត្រូវប្រឈមមុខនឹងការម៉ាក់ងាយ ការរើសអើងយ៉ាងខ្លាំង និងការទាត់ចោលនូវសិទ្ធិរបស់ពួកគេ ដែលកត្តាទាំងអស់នេះធ្វើឲ្យជនពិការងាយធ្លាក់ចូលក្នុងវិបត្តិសេដ្ឋកិច្ច និងត្រូវបានផ្តាច់ចេញពីសង្គម។ បន្ទាប់ពីនេះ សមាជិកគ្រួសារក្រីក្រកម្រទទួលបានស្បៀងអាហារគ្រប់គ្រាន់ ទីជម្រក អនាម័យ ការផ្គត់ផ្គង់ទឹក និងសេវាថែទាំសុខភាព ដែលកង្វះនូវលក្ខណៈទាំងនេះ នឹងធ្វើឲ្យភាពក្រីក្រមានសភាពកាន់តែធ្ងន់ធ្ងរឡើង និងបង្កើនគ្រោះថ្នាក់នានាដែលបង្កឲ្យមានពិការភាព។

ដូចនេះ ការពិចារណាអំពីពិការភាពនៅក្នុងកិច្ចអភិវឌ្ឍន៍ និងការផ្តល់ឱកាសប្រកបដោយសមធម៌ដល់ជនពិការក្នុងការចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ ដោយសម្រួលធ្វើយ៉ាងណាឲ្យការរស់នៅរបស់ពួកគេមានអត្ថប្រយោជន៍ គឺមានសារៈសំខាន់កាន់តែខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ ទាំងនៅកម្រិតបុគ្គល គ្រួសារ សហគមន៍ និងនៅថ្នាក់ជាតិ។ ដោយមានក្តីបារម្ភអំពីទំនាក់ទំនងរវាងពិការភាព និងភាពក្រីក្រ ផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ (NSDP) គឺជាឱកាសតែមួយគត់ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនពិការ។

សារៈសំខាន់នៃបញ្ហា៖ ស្ថិតិពិការភាព និងភាពរាតត្បាតនៃពិការភាពដែលចេះតែផ្លាស់ប្តូរ

របាយការណ៍ស្តីពីពិការភាពនាពេលថ្មីៗ (ខែមិថុនា ឆ្នាំ២០១១) របស់អង្គការសុខភាពពិភពលោក និងធនាគារពិភពលោក បានបង្ហាញថា អត្រាប្រៀវ៉ាឡង់នៃពិការភាពបានកើនឡើងពីកម្រិតប៉ាន់ប្រមាណ ១០,១២% ទៅដល់១៥,៣% នៃចំនួនប្រជាពលរដ្ឋសរុបនៅទូទាំងពិភពលោក។ អត្រាប្រៀវ៉ាឡង់ដែលកើនឡើងនេះ គឺមានភាពជាក់ស្តែងនៅកម្ពុជា ដូចដែលស្ថិតិនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា នៃវិទ្យាស្ថានជាតិស្ថិតិ បានបង្ហាញថា អត្រា ៤,៧% ពីឆ្នាំ២០០៤ បានកើនឡើងដល់ ៨,១% នៅក្នុងឆ្នាំ២០០៩[88]។ កំណើននេះអាចកើតឡើងដោយសារកត្តាផ្សេងៗជាច្រើនរួមមាន ដំណើរការស្ទង់មតិនិងកំណត់អត្តសញ្ញាណកម្មប្រសើរជាងមុន ជាមួយនឹងអត្ថន័យកាន់តែទូលំទូលាយនៃកត្តាគ្រោះថ្នាក់ទាំងឡាយ ដែលបណ្តាលឲ្យមានពិការភាពដូចជា ជរាភាព បរិយាកាសជុំវិញដូចជា សុវត្ថិភាពផ្លូវគោក ភាពក្រីក្រ កង្វះអាហារូបត្ថម្ភ និងកង្វះការទទួលបាននូវសេវាបង្ការ ព្យាបាល និងស្តារសុខភាព។ ថ្មីៗនេះ គេប៉ាន់ប្រមាណថាអត្រាកំណើនប្រៀវ៉ាឡង់នៃជម្ងឺដែលមិនឆ្លង បានរួមចំណែករហូតដល់ ៤៦% នៃមរណភាពទាំងអស់នៅកម្ពុជា ដែលនេះជាកត្តាគ្រោះថ្នាក់មួយ អាចនាំឲ្យមានកំណើនអត្រាប្រៀវ៉ាឡង់ពិការភាព ពោលគឺអ្នកមានជម្ងឺលើសឈាមត្រូវប្រឈមនឹងគ្រោះថ្នាក់នៃជម្ងឺពិការមួយចំហៀងខ្លួន និងអ្នកកើតជម្ងឺទឹកនោមផ្អែមត្រូវប្រឈមនឹងគ្រោះថ្នាក់នៃការកាត់អវយវៈណាមួយចេញ។ ៤០% នៃកុមារអាយុក្រោម ៥ឆ្នាំមានជម្ងឺក្រិន (កម្ពស់មិនសមាមាត្រនឹងអាយុ) ហើយជម្ងឺក្រិននេះគឺទាក់ទងទៅនឹងការរៀនសូត្រខ្សោយ និងភាពយឺតយ៉ាវនៃការលូតលាស់ផ្នែករាងកាយនិងប្រាជ្ញា[89]។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ គ្រោះថ្នាក់ចរាចរណ៍បានកើនឡើង ២១៧% ហើយតួលេខនៃការស្លាប់ស្ទើតែកើនឡើងទ្វេដង។ គ្រោះថ្នាក់ចរាចរណ៍ អាចបណ្តាលឲ្យរងគ្រោះផ្នែកខួរក្បាល ខួរឆ្អឹងខ្នង

[88] អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ ដែលវិភាគដោយ Knowles ឆ្នាំ២០០៥។ http://www.nis.gov.kh.index.php/social-statistics/cses/cses-tables

[89] ឯកសារគោលជំហររបស់អង្គការម៉ែឌីខាំឆ្នាំ២០99 http://www.thelancet.com/journals/lancet/article/PIIS0140-6736(05)66967-X/fulltext

បាក់បែកឆ្អឹងនិងការកាត់អវយវៈណាមួយចេញ [90] ។ ជនពិការប្រឈមខ្លាំងនឹងការឆ្លងមេរោគអេដស៍ ដែលកត្តាគ្រោះថ្នាក់នៃការឆ្លងនេះគឺទាក់ទងទៅនឹងកង្វះព័ត៌មាន ការតាំងចិត្តខ្សោយក្នុងការចរចាស្តីពីសុវត្ថភាពនៃការរួមភេទ និងភាពប្រឈមខ្លាំងទៅនឹងការរំលោភបំពានផ្លូវភេទ ហើយអាត្រាប្រែវ៉ាឡង់នៃការឆ្លងនេះមិនមានព័ត៌មានទេ។

របៀបប្រមូលទិន្នន័យ

កន្លងមកមិនមានអង្កេតស៊ីជម្រៅពីពិការភាពនៅក្នុងប្រទេសកម្ពុជាទេ ហើយកង្វះនូវមូលដ្ឋានភស្តុតាងនេះចោទជាបញ្ហាប្រឈមសម្រាប់ការតស៊ូមតិ។ ឯកសារគោលជំហរនេះ ប្រមែប្រមូលភស្តុតាងពីអង្កេតខ្នាតតូចនានានិងការសិក្សាផ្សេងៗ ដែលតាមរយៈវិធីសាស្ត្រនេះ ភាពដូចគ្នានៃរបកគំហើញនិងអនុសាសន៍ទាំងឡាយបានផ្តល់នូវភាពត្រឹមត្រូវមួយចំនួនដល់អ៊ំនៈអ៊ំនាងទាំងឡាយនៅក្នុងឯកសារគោលនេះ តែយ៉ាងណាក្តី កង្វះនូវការប្រមូលទិន្នន័យដែលមានលក្ខណៈជាប្រព័ន្ធ និងខ្នាតធំគឺជាបញ្ហាប្រឈមសម្រាប់វិស័យនេះ។ ឯកសារគោលជំហរនេះ ត្រូវបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយក្រុមដែលរួមមានជនពិការ និងធ្វើការដើម្បីជនពិការដូចជា៖ អង្គការជនពិការកម្ពុជា(CDPO) អង្គការសកម្មភាពលើជនពិការនិងការអភិវឌ្ឍ (ADD) អង្គការ Aide et Action International និងអង្គការជនពិការអន្តរជាតិ (HI)។

អនុសាសន៍៖

- ការសិក្សាថ្នាក់ជាតិដែលអាចជឿទុកចិត្តបានទៅលើស្ថានភាពរបស់ជនពិការ ដើម្បីប្រសិទ្ធភាពនៃការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យលើ គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ទាំងឡាយដែលមានភាពជាក់លាក់សម្រាប់ពិការភាព និងដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

វឌ្ឍនភាព ឧបសគ្គ និងអនុសាសន៍ ព្រមទាំងការរៀបចំគោលនយោបាយ និងការអនុវត្តក្នុងវិស័យ

អនុក្រឹត្យនិងប្រកាសផ្សេងៗត្រូវបានរៀបចំ ចាប់តាំងពីច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ត្រូវបានអនុម័តនៅខែកក្កដា ឆ្នាំ២០០៩ ដើម្បីជំនួយជាឯកសារគតិយុត្តិដល់ផែនការសកម្មភាពជាតិស្តីពីជនពិការ ដែលរាប់បញ្ចូលនូវជនរងគ្រោះដោយសារមីននិងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមពីឆ្នាំ២០០៨ ដល់ ២០១១ (ពន្យារពេលមួយឆ្នាំ)។ អនុក្រឹត្យទាំងនេះរួមមាន៖ ប្រកាសស្តីពីការបង្កើតរដ្ឋបាលសិទ្ធិជនពិការ នៅខែមករា ឆ្នាំ២០១០ អនុក្រឹត្យស្តីពីការរៀបចំសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ នៅខែមិថុនា ឆ្នាំ២០១០ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ នៅខែកញ្ញា ឆ្នាំ២០១០ អនុក្រឹត្យស្តីពីអត្រាកំណត់អត្រានិងបែបបទក្នុងការជ្រើសរើសជនពិការចូលបំរើការងារ នៅខែតុលា ឆ្នាំ២០១០។ អនុក្រឹត្យលេខ១៣៧ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រតាមសហគមន៍ និងប្រកាសអន្តរក្រសួង(ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល) ស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យនៃពិការភាព ខែកក្កដា ឆ្នាំ២០១១។

ផែនការសកម្មភាពជាតិស្តីពីជនពិការ ដែលរាប់បញ្ចូលនូវជនរងគ្រោះដោយសារមីននិងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមពីឆ្នាំ២០០៨ ដល់ ២០១១ ឆ្លុះបញ្ចាំងអំពីតម្រូវការអភិវឌ្ឍរបស់ជនពិការ៖ ផ្នែកទី១- ទំហំនៃការយល់ដឹងពីឧបសគ្គ។ ផ្នែកទី២-ការសង្គ្រោះបន្ទាន់ និងបន្តការទទួលថ្នាំបង្ការ។ ផ្នែកទី៣-ការស្តារលទ្ធភាពពលកម្ម។ ផ្នែកទី៤-ការគាំទ្រ ផ្នែកចិត្តសាស្ត្រ និងការទំនាក់ទំនងសង្គម។ ផ្នែកទី៥-សមាហរណកម្មសេដ្ឋកិច្ច។ ផ្នែកទី៦-ច្បាប់ និងនយោបាយ សាធារណៈ។

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ដែលរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាក្នុងឆ្នាំ២០០៧ កំពុងស្ថិតនៅក្នុងដំណើរការនៃការផ្តល់សច្ចាប័ន។

[90] http://www.roadsafetycambodia.info/

បញ្ហាប្រឈម៖

ការពិនិត្យឡើងវិញនៃ ផែនការសកម្មភាពជាតិស្តីពីជនពិការ ដែលរាប់បញ្ចូលនូវជនរងគ្រោះដោយសារមីននិងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមនៃក្រុមប្រឹក្សាសកម្មភាពជនពិបានកំណត់បញ្ហាប្រឈមដូចខាងក្រោម៖

- កង្វះនូវយន្តការត្រួតពិនិត្យសកម្មភាពមួយដែលមានដំណើរការល្អ។
- ទិន្នន័យស្តីពីពិការភាពនិងការផ្តល់សេវានៅមានកំណត់។
- ធនធានហិរញ្ញវត្ថុ មនុស្ស និងបច្ចេកទេសនៅមានកំណត់។
- ការសម្របសម្រួលនិងសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធនានានៅមានកំណត់។

អនុសាសន៍៖

- ការឆ្លើយតបជាលក្ខណៈប្រព័ន្ធទៅនឹងបញ្ហាប្រឈមដែលបានកំណត់ ជាមួយនឹងការអនុវត្ត ផែនការសកម្មភាពជាតិស្តីពីជនពិការ ដែលរាប់បញ្ចូលនូវជនរងគ្រោះដោយសារមីននិងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។
- រៀបចំនិងអនុវត្តយុទ្ធសាស្ត្រនានា ដោយរាប់បញ្ចូលនូវការធ្វើផែនការ ធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីគាំទ្រការសម្រេចឲ្យបាននូវប្រកាសនិងអនុក្រឹត្យទាំងឡាយ។
- ផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងកែសម្រួលឯកសារគតិយុត្តិជាតិដែលមិនស្របទៅនឹងអនុសញ្ញានេះ ហើយត្រួតពិនិត្យនិងប្រមូលស្ថិតិស្របតាមឆន្ទៈនៃអនុសញ្ញានេះ និងUNESCAP។ កំណត់នូវភាពខុសគ្នារវាងមូលហេតុបង្កឲ្យមានពិការភាព និងការដាក់កំហិតទៅលើតួនាទី និងបណ្តាលមកពីស្ថានភាពពិការ និងឧបសគ្គរារាំងនៅក្នុងការចូលរួម។

២. សូចនាករតាមដានរួម (JMIs) និងសកម្មភាព/យុទ្ធសាស្ត្រគន្លឹះៗនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ និងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១

ការមិនរំលេចឲ្យឃើញនូវពិការភាព នៅក្នុងពង្រាងទីមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) ក៏ដូចជាអវត្តមាននៃបញ្ហាពិការភាពនៅក្នុងសូចនាករតាមដានរួម គឺជាឧបសគ្គមួយចំបងក្នុងការត្រួតពិនិត្យថាតើសកម្មភាពនិងផលប៉ះពាល់បានជាអត្ថប្រយោជន៍ដល់ពិការដែរឬទេ។ ការឆ្លើយតបទៅនឹងបញ្ហាពិការភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការដាក់បញ្ចូលចំនុចនេះទៅក្នុងសូចនាករតាមដានរួម គឺជាជំហានដ៏សំខាន់មួយសម្រាប់ធានាឲ្យបានថាប្រជាពលរដ្ឋគ្រប់រូបទទួលផលប្រយោជន៍ពីការអភិវឌ្ឍ និងសម្រាប់គាំទ្រដល់ប្រទេសកម្ពុជាក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍។

អនុសាសន៍៖

- ការដាក់បញ្ចូលនូវពិការភាពដែលមានភាពទាក់ទងគ្នា ទៅក្នុងសូចនាករតាមដានរួម និងយុទ្ធសាស្ត្រនានា ឲ្យស្របតាមមាត្រា១៨ នៃ PPRPD៖ ក្រសួងនិងស្ថាប័នពាក់ព័ន្ធដែលមានសមត្ថភាព គួរសម្របសម្រួលឲ្យជនពិការបានចូលរួមនៅក្នុងផែនការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងវប្បធម៌ ទាំងឡាយដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ និងបញ្ចូលនូវតម្រូវការរបស់ពួកគេទៅក្នុងកម្មវិធីអភិវឌ្ឍន៍នានារបស់ក្រសួងនិងស្ថាប័ន។
- បញ្ចូលជនពិការទៅក្នុងការត្រួតពិនិត្យសកម្មភាពកាត់បន្ថយភាពក្រីក្រ និងវិភាជថវិកានិងធនធានមនុស្សជាក់លាក់សម្រាប់ពិការភាពនៅក្នុងក្រសួងនីមួយៗ។
- ពិចារណាតែងតាំងជនបង្គោល/ក្រុមការងារជនពិការនានា នៅកម្រិតទាំងឡាយណាដែលមានប្រសិទ្ធភាពនៅតាមបណ្តាក្រសួង ដើម្បីគាំទ្រដល់គណៈកការសម្របសម្រួលពិការភាពថ្នាក់ជាតិ និងផ្តល់ជាធាតុចូលដល់ការរៀបចំសូចនាករតាមដានរួម។

- ពិចារណារៀបចំក្រុមការងារបច្ចេកទេសផ្តល់យោបល់លើពិការភាព ដែលមានដែនសមត្ថកិច្ចគាំទ្រដល់គណៈកម្មាធិការសម្របសម្រួលពិការភាពថ្នាក់ជាតិ ក្នុងអភិក្រមចម្រុះវិស័យមួយ។
- ទោះបីជារហូតមកដល់ពេលនេះ PPRPD និងផែនការសកម្មភាពជាតិស្តីពីជនពិការដែលរាប់បញ្ចូលនូវជនរងគ្រោះដោយសារមីននិងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ត្រូវបានអនុម័តរួចមកហើយនៅក្នុងឆ្នាំ២០០៩ ហើយអនុសញ្ញាស្តីពីសិទ្ធិជនពិការត្រូវបានផ្តល់សច្ចាប័នដោយរាជរដ្ឋាភិបាលនៅក្នុងឆ្នាំ២០០៧ ក្តី ក៏មិនមានការបញ្ចូលបញ្ហាពិការភាពនេះទៅក្នុងគោលដៅនិងសូចនាករនានា ក៏ដូចជាមិនមានវិភាជន៍ថវិកាឬការត្រួតពិនិត្យលើវឌ្ឍនភាពទាក់ទិននឹងពិការភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករតាមដានរួមដែរ។

៣. បញ្ហាសំខាន់ៗដែលមិនបានគ្របដណ្តប់ដោយសូចនាករតាមដានរួម ឬផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិបច្ចុប្បន្នកម្ម

ក្រុមដែលធ្វើការលើពិការភាព បានជ្រើសរើសវិស័យអាទិភាពប្រាំមួយដែលរួមមាន៖ ការបង្កលក្ខណៈងាយស្រួល - អង្គការតំណាងជនពិការ សិទ្ធិ និងការចូលរួម - ការអប់រំ - សុខភាពនិងនិតិសម្បទា - ការងារនិងការចិញ្ចឹមជីវិត - និងយេនឌ័រ។

បញ្ហាទូទៅ (ក)៖ ការបង្កលក្ខណៈងាយស្រួល ហេដ្ឋារចនាសម្ព័ន្ធ និងទំនាក់ទំនង

ការបង្ករលក្ខណៈងាយស្រួល គឺការបង្កើតនិងថែរក្សានូវបរិយាកាសនានាដែលមនុស្សអាចចូលរួមតាមគ្រប់មធ្យោបាយដែលមានសមធម៌ សេចក្តីថ្លៃថ្នូរ ឯករាជ្យភាពអតិប្បរមា សុវត្ថិភាព ភាពសមរម្យ និងរក្សាសេចក្តីស្វាហាប់ ហើយបរិយាកាសដែលគ្មានឧបសគ្គរារាំង ដែលលើកកម្ពស់ដល់ការបង្កលក្ខណៈងាយស្រួលនេះ គឺជាកត្តាសំខាន់សម្រាប់ការដាក់បញ្ចូលជនពិការទៅក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច។ នៅក្នុងជំពូកប្រាំនៃ PPRPD៖ ការបង្កលក្ខណៈងាយស្រួលជាសាធារណៈ មាត្រា២១-២៦ ផ្តល់សារៈសំខាន់ដល់ការបង្កលក្ខណៈងាយស្រួលនៅទីកន្លែងសាធារណៈ រួមមានបញ្ហា ដូចជាគម្រោងនិងការសាងសង់ មធ្យោយបាយធ្វើដំណើរនិងប័ណ្ណបើកបររថយន្តសម្រាប់ជនពិការជាដើម ដែលចំនុចទាំង នេះត្រូវបានពង្រឹងបន្ថែមដោយមាត្រា៩ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ៖ ការបង្កលក្ខណៈងាយស្រួលទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ និងទំនាក់ទំនង និងមាត្រា២១៖ សេរីភាពក្នុងការបញ្ចេញមតិ និងការទទួលបានព័ត៌មាន។

កង្វះខាត៖ មិនមានការរំលេចចេញជាប្រព័ន្ធ ឲ្យឃើញនូវការបង្កលក្ខណៈងាយស្រួល នៅក្នុងច្បាប់ ឬប្បញ្ញាត្តិជាតិនានាស្តីពីសំណង់ មិនមានការណែនាំ ឬប្បញ្ញត្តិនានា ស្តីពីការទទួលបានព័ត៌មាន/ទំនាក់ទំនងនៅក្នុងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នៅមូលដ្ឋាន និងថ្នាក់ជាតិនានា។

អនុសាសន៍៖

- អនុម័ត និងពង្រឹងច្បាប់នានាស្តីពីសំណង់ដែលបង្កនូវលក្ខណៈងាយស្រួល និងមធ្យោបាយនៃការទទួលបានព័ត៌មាននានាតាមរយៈវិស័យអភិវឌ្ឍន៍ទាំងអស់។
- ធានាឲ្យបានថា ការដែលគម្រោងទាំងឡាយណាដែលកំពុងស្ថិតក្នុងការរៀបចំ ឬកម្មវិធីនានាដែលត្រូវបានគាំទ្រអាចបង្កលក្ខណៈងាយស្រួល គឺជាតម្រូវការចាំបាច់មុនមួយសម្រាប់ការជ្រើសតាំង។
- លើកកម្ពស់ការទទួលបានព័ត៌មាននិងទំនាក់ទំនង ជាយុទ្ធសាស្ត្រមួយ៖ ពិចារណាលើតម្រូវការជាក់លាក់នានាសម្រាប់អ្នកមានបញ្ហាក្នុងការមើលនិងស្តាប់ ។

យោងតាម៖ អង្គការជនពិការអន្តជាតិ "របៀបស្ថាបនាបរិស្ថានក្នុងប្រទេសកំពុងអភិវឌ្ឍន៍" អាចស្នើសុំបានពីអ៊ីម៉ែល៖ office@hicambodia.org លេខទូរស័ព្ទ៖ ៨៥៥ (0) ២៣ ២១២ ៨៩៧។

បញ្ហាជាក់លាក់ (ខ)៖ អង្គការជនពិការ ច្បាប់ និងការចូលរួម

ច្បាប់រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាបានចែងថា៖ "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"។ ច្បាស់ណាស់ "ប្រជាពលរដ្ឋខ្មែរ" នៅទីនេះគឺរួមបញ្ចូលទាំង "ជនពិការ"។ អង្គការជនពិការមាននៅក្នុងខេត្តចំនួន ២៣ ដែលជាក្រុមសង្គមស៊ីវិលនានាមានកាតព្វកិច្ចក្នុងការលើកកម្ពស់ការយល់ដឹង ការបញ្ចុះបញ្ចូល និងការតស៊ូមតិ ក្នុងចំណោមអ្នកមានភារកិច្ច សហគមន៍ និងជនពិការ ស្តីពីសិទ្ធិ និងតម្រូវការនានារបស់ជនពិការ ។

កង្វះខាត៖ ការទទួលបាននូវបរិយាកាសវប្បធម៌ សេដ្ឋកិច្ច សង្គម និងធម្មជាតិ ការទទួលបាននូវសុខភាព ការអប់រំ ពត៌មាន និងទំនាក់ទំនង ដើម្បីធ្វើឲ្យជនពិការអាចរីករាយក្នុងការទទួលបាននូវសិទ្ធិមនុស្សទាំងឡាយ និងសេរីជាមូលដ្ឋានដោយពេញលេញ គួរតែបន្តជាអទិភាពអភិវឌ្ឍន៍មួយ។ រាជរដ្ឋាភិបាល បានចេញជាក្របខ័ណ្ឌច្បាប់នានាក្នុងរូបភាពជាប្រកាស និងអនុក្រឹត្យ ដើម្បីគាំទ្រដល់ការអនុវត្ត PPRPD ប៉ុន្តែការប្រឹក្សាយោបល់ ឬការចូលរួមរបស់ជនពិការនិងអង្គការរបស់ពួកគាត់នៅក្នុងការរៀបចំគោលនយោបាយពិការភាពពាក់ព័ន្ធនានាមិនទាន់មានគ្រប់គ្រាន់នៅឡើយ និងមានការខ្វះខាតធនធានវិភាជន៍។

អនុសាសន៍៖

- ប្រឹក្សាយោបល់ និងបញ្ចូលជនពិការទៅក្នុងការអភិវឌ្ឍន៍ ការអនុវត្ត និងការវាយតម្លៃគ្រប់កម្មវិធីទាំងអស់ឲ្យបានសកម្ម។
- ការវិភាជធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្សដល់ការគាំទ្រ PPRPD។
- បង្កើនការយល់ដឹងអំពីច្បាប់ពិការភាព ដល់ជនពិការ នៅតាមមូលដ្ឋាននិងអន្តរក្រសួងនានា ព្រោះថាពិការភាពគឺជាបញ្ហាចម្រុះវិស័យ។

បញ្ហាជាក់លាក់ (គ)៖ ការអប់រំសម្រាប់កុមារពិការ

ផែនការអប់រំជាតិរួមបញ្ចូលកុមារពិការ ហើយផែនការមេលើការអប់រំសម្រាប់កុមារពិការឆ្នាំ២០០៩-២០១១ បានលម្អិតពីយុទ្ធសាស្ត្រក្នុងលើកកម្ពស់វិស័យអប់រំ។ ផែនការទាំងនេះ លើកកម្ពស់ការអនុវត្តច្បាប់ដោយរួមបញ្ចូលទាំងជំពូកទី៦ មាត្រា២៧ នៃPPRPD មាត្រា២៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា២៤ នៃអនុសញ្ញាស្តីអំពីសិទ្ធិជនពិការ ។

កង្វះខាត៖ ៣៥% នៃកុមារពិការមិនដែលចូលសាលា[91]។ យោងតាម ប្រព័ន្ធព័ត៌មាននិងត្រួតពិនិត្យនៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងចំណោមកុមារទាំងអស់ដែលចុះឈ្មោះចូលរៀនតាមសាលារៀនសាធារណៈកម្ពុជា ០,៨២% (១០៩,៩០០) គឺជាកុមារពិការ។ ភាគរយដ៏ទាបនេះ ដែលផ្តុយពីអត្រាប្រជាំឡង់ពិការភាពជាតិ ត្រូវបានភ្ជាប់ពាក់ព័ន្ធនឹងការកំណត់ជំនាញគ្រូបង្រៀន និងបញ្ហាប្រឈមនៃការកំណត់និយមន័យពិការភាព លាយជាមួយនឹងអត្រាចុះឈ្មោះចូលរៀននិងអត្រានៃការចូលរួម[92]។ ឧបសគ្គនៃការចូលរួមទាំងឡាយរួមមាន ការបង្កភាពងាយស្រួល ការបញ្ជ្រាបវិធីសាស្ត្របង្រៀនដែលពាក់ព័ន្ធនានា ចំណេះដឹង និងសមត្ថភាពរបស់គ្រូបង្រៀន និងសម្ភារៈសម្រាប់បង្រៀនកុមារពិការ កង្វះការលើកទឹកចិត្តនិងគាំទ្រពីមាតាបិតានិងសហគមន៍ ការរើសអើងនិងកង្វះការយកចិត្តទុកដាក់ពីគ្រូបង្រៀន កង្វះឧបករណ៍ជំនួយពាក់ព័ន្ធនានា ការគាំទ្រខ្សោយរបស់អាជ្ញាធរមូលដ្ឋាននិងក្រុមប្រឹក្សាឃុំ ដល់ការសម្របសម្រួលការទទួលបាននូវការអប់រំ និងអាហារូបករណ៍សម្រាប់កុមារពិការ។[93]

[91] CESES 2004/Knowles, 2005

[92] CDPO Report on Current Situation of Education for Children with Disabilities (2010)

[93] Disability issues and recommendations from national workshop on "recognize our rights – fulfill our needs" August 18-19, 2009

អនុសាសន៍៖

- រៀបចំនូវអនុក្រឹត្យអន្តរក្រសួងស្តីពីការសិក្សាសម្រាប់កុមារពិការ ដើម្បីធានាឲ្យបាននូវការអនុវត្តដ៏មានប្រសិទ្ធភាព នៃជំពូកទី៦ នៃPPRPD៖ ការអប់រំ។
- រៀបចំ ត្រួតពិនិត្យ និងវាយតម្លៃសូចនាករច្បាស់លាស់នៅក្នុងផែនការមេស្តីពីការអប់រំសម្រាប់កុមារពិការ។
- ធានាឲ្យបានថាបុគ្គលិកទាំងឡាយណា ដែលធ្វើការនៅក្នុងវិស័យអប់រំ ជាពិសេសនាយក និងគ្រូបង្រៀននៅតាមតំបន់ដាច់ស្រយ៉ាល បានយល់ដឹងអំពីផែនការមេស្តីពីការអប់រំសម្រាប់កុមារពិការ។
- ផលិតឧបករណ៍ជំនួយសមរម្យនានាសម្រាប់ជំនួយដល់កុមារពិការកាយសម្បទា វិញ្ញាណ ផ្លូវចិត្ត និងសតិបញ្ញា។
- ឆ្លើយតបនឹងតម្រូវការនៃការបង្កលក្ខណៈងាយស្រួលផ្សេងៗដល់កុមារដែលមានពិការភាពផ្សេងៗដូចជា កាយសម្បទា ឬចក្ខុវិញ្ញាណ និងធានាឲ្យមានការផ្តល់នូវជម្រាល បង្គន់អនាម័យដែលអាចប្រើប្រាស់បាន និងបង្កាន់ដៃជាដើម។
- គាំទ្រផ្នែកបច្ចេកទេសដល់សាលាពិសេស និងសាលាចំនេះដឹងទូទៅ និងធ្វើការអប់រំផ្សព្វផ្សាយអំពីការទទួលបានការអប់រំសម្រាប់កុមារដែលមានតម្រូវការរៀនសូត្រពិសេស។
- ពិនិត្យតាមដានអំពីភាពរីកចម្រើន បន្ទាប់ពីការបណ្តុះបណ្តាលចំនេះដឹងអំពីការអប់រំបញ្ចូលគ្នា ទៅលើសមត្ថភាពជំនាញជាមូលដ្ឋាន និងឥរិយាបថរបស់បុគ្គលិកសិក្សា។ រៀបចំនិងអនុវត្តនូវយុទ្ធសាស្ត្រសម្រាប់សេវាបណ្តុះ បណ្តាលអំពីការអប់រំបញ្ចូលគ្នា។

បញ្ហាជាក់លាក់ (ឃ)៖ សុខភាព និងការស្តារលទ្ធភាពពលកម្ម ការថែទាំសុខភាព ការស្តារលទ្ធភាពពលកម្មតាមបែបវេជ្ជសាស្ត្រ ការស្តារលទ្ធភាពពលកម្មកាយសម្បទា និងការស្តារលទ្ធភាពពលកម្មនៅសហគមន៍

ជំពូកទី៤ នៃPPRPD បានចែងអំពីការស្តារលទ្ធភាពពលកម្មខាងផ្នែកកាយសម្បទា និងផ្លូវចិត្ត ការថែទាំសុខភាព និងការការពារ ហើយដែលមានបញ្ជាក់បន្ថែមទៀតនៅក្នុងអនុសញ្ញាស្តីពីស្តីពីសិទ្ធិជនពិការនៃអង្គការសហប្រជាជាតិ ក្នុងមាត្រា២៥៖ សុខភាព មាត្រា២៦៖ ការធ្វើឲ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម។ ប្រកាសលេខ១៣៥ (២០០៤) បង្ហាញពីការផ្តល់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃដល់ជនពិការគ្រប់រូប និងប្រកាសលេខ២៤៩៣ (ខែវិច្ឆិកា ២០១១) ចែងពីការធ្វើចំនាត់ថ្នាក់ពិការភាពក្នុងគោលបំនងលើកកម្ពស់ការទទួលបានសេវា។ប្រកាសលេខ ១៦៤ (២០០៨) គាំទ្រឲ្យមានការបង្កើតនិងដំណើរការនៃមណ្ឌលស្តារលទ្ធភាពពលកម្មខេត្ត ហើយមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តចំនួន ១១ កន្លែងបានកំពុងតែផ្តល់សេវាព្យាបាលដោយចលនា ការផ្តល់អវៈយវៈសិប្បនិម្មិត រណប និងសេវាសង្គមនានាតាមតម្រូវការ ដល់ជនពិការចំនួនជាង ២០.០០០នាក់ ក្នុងមួយឆ្នាំៗដោយឥតបង់ថ្លៃ។

ការស្តារលទ្ធភាពពលកម្មនៅសហគមន៍គឺជាយុទ្ធសាស្ត្រមួយ ដែលមានជាទូទៅនៅក្នុងការអភិវឌ្ឍសហគមន៍ សម្រាប់ការស្តារលទ្ធភាពពលកម្ម ការផ្តល់នូវសមភាពនៃឱកាស និងការបញ្ចូលកុមារពិការនិងជនពិការទៅក្នុងសង្គម។ [94] ប្រទេសកម្ពុជាបានធ្វើការកែសម្រួល និងយល់ព្រមទៅលើសេចក្តីណែនាំអំពីការស្តារលទ្ធភាពពលកម្មនៅសហគមន៍ របស់អង្គការសុខភាពពិភពលោក៖ សេចក្តីណែនាំថ្នាក់ជាតិស្តីពីការស្តារលទ្ធភាពពលកម្មនៅសហគមន៍ (២០១០) ដែលផ្តោតលើសុខភាព ការអប់រំ ការផ្តល់សិទ្ធិអំនាច ជីវភាព និងការដាក់បញ្ចូលគ្នានៅក្នុងសង្គម។ សកម្មភាពស្តារលទ្ធភាពពលកម្មនៅសហគមន៍នៅក្នុងកម្រិតខ្លះ ត្រូវបានអនុវត្តនៅក្នុងខេត្តចំនួន ២១ ហើយក្រុមជួយខ្លួនឯងប្រហែលចំនួន១.៩០០ ត្រូវបានបង្កើតឡើងនៅកម្រិតសហគមន៍ ដើម្បីអប់រំផ្សព្វផ្សាយអំពីសុខុមាលភាពផ្នែកសេដ្ឋកិច្ច និងចិត្តសាស្ត្រសង្គម។

កង្វះខាត វិស័យសុខភាព៖ ចំពោះប្រកាសលេខ១៣៥ មានជនពិការ និងអ្នកផ្តល់សេវាមួយចំនួនតូចប៉ុណ្ណោះដែលបានទទួលព័ត៌មានពីសេចក្តីប្រកាសនេះ។ ការយល់ដឹងក្នុងចំណោមបុគ្គលិកសុខភាព និងអ្នកតាក់តែងគោលនយោបាយ ស្តីពីប្រេវ៉ាឡង់និងសិទ្ធិជនពិការនៅមានកម្រិតទាប និងនៅមានចន្លោះប្រហោងក្នុងការសម្របសម្រួល ការងាររវាង

[94] ILO, UNESCO, WHO 2004

ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច និងអង្គការពាក់ព័ន្ធនានា[95]។ ប្រព័ន្ធព័ត៌មានរបស់ក្រសួងសុខាភិបាល មិនបានបំបែកលម្អិតទិន្នន័យស្តីពីជនពិការ សំណុំសកម្មភាពបង្ក្រប់បន្ថែមនៅកម្រិតថ្នាក់ខេត្ត ឬបញ្ជូន (CPA) សំណុំសកម្មភាពអប្បបរមានៅថ្នាក់មជ្ឈឹម(MPA) ទេ។ មូលនិធិសមធម៌សុខភាព(HEF) និងគម្រោងធានារ៉ាប់រងសុខភាពសហគមន៍ (CBHI)គឺជាយន្តការច្រកចូលទៅក្នុងប្រព័ន្ធសុខាភិបាល ដែលមិនបានឆ្លុះបញ្ចាំងពីការទទួលបានសេវាជាក់លាក់ស្របទៅតាមប្រភេទពិការភាពសម្រាប់ជនពិការ និង/ឬ បញ្ហាប្រឈម/ឧបសគ្គនានា ដែលរារាំងការទទួលបាននូវ សេវាដែលបានផ្តល់ឲ្យនោះ។ សំណុំសកម្មភាពបង្ក្រប់បន្ថែមនៅកម្រិតថ្នាក់ខេត្ត (កម្រិតបញ្ជូន) (CPA) សំណុំ សកម្មភាពអប្បបរមានៅថ្នាក់មជ្ឈឹម (MPA) មូលនិធិសមធម៌សុខភាព (HEF)និងសេវាធានារ៉ាប់រងសុខភាពសហគមន៍ (CBHI) មានការឆ្លើយតបចំពោះសង្គ្រោះបន្ទាន់ និងស្ថានភាពធ្ងន់ធ្ងរនានា ប៉ុន្តែមិនបានឆ្លុះបញ្ចាំងពីតម្រូវការសុខភាពទាក់ទិននឹងពិការភាពដែលជារឿយៗមានតម្លៃថ្លៃ និងតម្រូវការរយៈពេលវែង ដែលជនពិការជាច្រើនធ្លាប់បានប្រឈម។

អនុសាសន៍៖

- ដោះស្រាយបញ្ហាឧបសគ្គដែលរារាំងជនពិការមិនឲ្យទទួលបានសេវា ដូចជា បញ្ហាថវិកា គុណភាពនៃការថែទាំសុខភាព ការសម្របសម្រួលរូបវ័ន្ត ចំនេះដឹង (ទាំងអ្នកប្រើប្រាស់សេវា និងអ្នកផ្តល់សេវា) ឧបសគ្គទាក់ទងនឹងសង្គមវប្បធម៌ និងចន្លោះប្រហោងទាំងឡាយក្នុងការសម្របសម្រួលការងាររវាងក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច និងអង្គការពាក់ព័ន្ធនានា។
- ពិនិត្យតាមដាន និងបង្កើតផែនការផ្តល់សេវាកម្ម៖ ស្ថិតិដែលមានលក្ខណៈលម្អិតនៅក្នុងប្រព័ន្ធព័ត៌មានរបស់ក្រសួងសុខាភិបាល រួមបញ្ចូលទាំងមូលនិធិសមធម៌សុខភាព និងគម្រោងធានារ៉ាប់រងសុខភាពសហគមន៍ដែរ។
- ការផ្តល់សេវា៖ អនុវត្តផ្នែកទី៤ នៃផែនការសកម្មភាពជាតិស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារគ្រាប់មីន ស្តីពីការដាក់បញ្ចូលសេវាសុខភាពសម្រាប់ជនពិការទៅក្នុងយុទ្ធសាស្ត្រសុខភាពឆ្នាំ២០០៦-២០១៥ ដូចជាតាមរយៈសំណុំសកម្មភាពអប្បបរមានៅថ្នាក់មជ្ឈឹម(MPA) និងសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្ក្រប់បន្ថែមនៅកម្រិតថ្នាក់ខេត្តឬកម្រិតបញ្ជូន (CPA) របស់ក្រសួងសុខាភិបាល ដែលឆ្លុះបញ្ចាំងពីសេវារយៈពេលវែង និងសេវាពិការភាពជាក់លាក់ទាំងឡាយ ការវិភាជថវិកា ការបណ្តុះបណ្តាល និងផ្តល់ឱកាសដល់បុគ្គលិកក្នុងការបំប៉ន ជំនាញជាបន្ត និងបង្កើតឲ្យមានយន្តការពិនិត្យតាមដាន។
- អនុវត្តប្រព័ន្ធធ្វើចំនាត់ថ្នាក់ពិការភាព ដើម្បីផ្សព្វផ្សាយការអនុវត្តប្រកាសលេខ១៣៥។
- ផ្សព្វផ្សាយពីការចុះឈ្មោះក្នុងការទទួលបានប័ណ្ណក្រីក្រទៅដល់ជនពិការ។
- អនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមស្តីពីការដាក់បញ្ចូលពិការភាព និងការផ្តល់សេវាជាក់លាក់ស្របទៅតាមប្រភេទពិការភាពទៅក្នុងកម្មវិធីមូលនិធិសមធម៌សុខភាព និងគម្រោងធានារ៉ាប់រងសុខភាពសហគមន៍។
- បញ្ចូលជនពិការទៅក្នុងសកម្មភាពលើកកម្ពស់សុខភាពសហគមន៍ទាំងឡាយ ហើយធានាឲ្យបាននូវការទទួលបានព័ត៌មានស្តីពីសកម្មភាពនិងគំនិតផ្តួចផ្តើមទាំងឡាយអំពីសុខភាព។

កង្វះខាត ការស្តារលទ្ធភាពពលកម្មតាមបែបវេជ្ជសាស្ត្រ៖ គោលនយោបាយនិងនិតិវិធី និយាយជុំវិញតែការបញ្ជូនទៅរកសេវានៅក្នុងមន្ទីរពេទ្យ ប៉ុន្តែ មិនបាននិយាយអំពីសេវាកម្មដែលផ្តល់ដោយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មនៅកម្រិតថ្នាក់ខេត្តនិងការស្តារលទ្ធភាពពលកម្មនៅសហគមន៍ ដែលប្រការនេះបណ្តាលឲ្យការថែទាំបន្តរមានកម្រិតខ្សោយ និងអាចបណ្តាលឲ្យមានភាពឯកោ និងការធ្វើឲ្យកាន់តែយ៉ាប់យឺនដល់ផ្នែករាងកាយនិងផ្លូវចិត្តរបស់អ្នកដែលមានពិការភាពជានិរន្ត នៅពេលដែលពួកគាត់ត្រឡប់ទៅសហគមន៍របស់ខ្លួនវិញ។

[95] CBM Adapting health systems and services to be inclusive of Persons with Disabilities, 2011, P.Kleinitz et al; GIZHealthcare for vulnerable groups in Cambodia, 2010, A, Platt; HIAccess to HIV and SV Protection among persons with disabilities, 2009, Dr. Tia Phalla.

អនុសាសន៍៖

- បង្កើត អនុវត្ត និងពិនិត្យតាមដាន ផែនការសកម្មភាពស្តីពីសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្ក្រប់បន្ថែមនៅកម្រិតថ្នាក់ខេត្តឬបញ្ជូន(CPA) និងយន្តការអនុវត្តសំណុំសកម្មភាពអប្បបរមានៅថ្នាក់មជ្ឈឹម សម្រាប់ក្រុមជនពិការដែលមានស្ថានភាពសុខភាពស្រដៀងគ្នា ដែលផែនការសកម្មភាពនេះឆ្លើយតបនឹងស្ថានភាពធ្ងន់ធ្ងរ និងការជួយគាំទ្ររយៈពេលវែងនៅតាមក្រសួងផ្សេងៗដូចជា ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ចជាដើម។
- កំនត់ និងបែងចែកធនធានហិរញ្ញវត្ថុ ធនធានមនុស្សនិងបច្ចេកទេស ដើម្បីគាំទ្រដល់ការបន្តផ្តល់នូវសេវា។

កង្វះខាត ផ្នែកការស្តារលទ្ធភាពពលកម្មកាយសម្បទា៖ ការផ្លាស់ប្តូរ និងអសមធម៌ក្នុងការផ្តល់សេវា៖ ការពង្រីក ទីតាំងភូមិសាស្ត្រ ការបង្កើតគោលនយោបាយស្តីពីការបញ្ជូនទៅរកសេវា។ កង្វះខាតក្នុងការបញ្ជាក់រវាងមណ្ឌលស្តារ លទ្ធភាពខេត្ត ដែលជាមណ្ឌលផ្តល់សេវាចំបងទីពីរ។ ទំនាក់ទំនងនិងការគ្របដណ្តប់ខ្សោយរបស់ការស្តារលទ្ធភាពពលកម្មនៅសហគមន៍ ដែលប្រការនេះបណ្តាលឲ្យផលវិជ្ជមាននៃការស្តារលទ្ធភាពពលកម្មមានការថយចុះ នៅពេលដែលបរិស្ថាននៅតាមផ្ទះរបស់អតិជនពិការពុំមានការសម្របសម្រួល។ ការគម្រាមកំហែងដល់ការផ្តល់សេវា ដោយសារតែមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តត្រូវបានពាក់ព័ន្ធ ក្នុងដំណើរការនៃការផ្ទេរការគ្រប់គ្រងឲ្យទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា។

អនុសាសន៍៖

- បង្កើតឲ្យមានយុទ្ធសាស្ត្រស្តារលទ្ធភាពពលកម្មថ្នាក់ជាតិ។
- ការសម្របសម្រួលការងាររវាងក្រសួងសង្គមកិច្ច និងក្រសួងសុខាភិបាល ដើម្បីធ្វើឲ្យយន្តការនានានៃការបញ្ជូនទៅមកទទួលសេវានៅមណ្ឌលស្តារលទ្ធភាពពលកម្មខេត្ត មានប្រសិទ្ធិភាព ត្រូវកំណត់ឲ្យបានច្បាស់លាស់សម្រាប់ក្រុមជនពិការដែលមានស្ថានភាពសុខភាពស្រដៀងគ្នា ដោយកំណត់ផ្តាល់ក្នុងដំណាក់កាលធ្ងន់ធ្ងរ ឬដំណាក់កាលដែលអាចប្រឈមនៅក្នុងករណីធ្ងន់ធ្ងរ៖ សំណុំសកម្មភាពបង្ក្រប់បន្ថែមនៅកម្រិតថ្នាក់ខេត្ត ឬកម្រិតបញ្ជូន (CPA) សំណុំសកម្មភាពអប្បបរមានៅថ្នាក់មជ្ឈឹម (MPA) មជ្ឈមណ្ឌល**ស្តារលទ្ធភាពពលកម្ម**កាយសម្បទានិង**ការស្តារលទ្ធភាពពលកម្មនៅសហគមន៍**។
- បង្កើតយុទ្ធសាស្ត្រសម្រាប់ការអនុវត្ត និងតាមដានជានិតិវិធីបទដ្ឋាននៃការងារ។
- ធ្វើឲ្យប្រសើរឡើងថែមទៀតនូវការទទួលស្គាល់លើផ្នែកអង្គភាពសង្គម និងបុគ្គលិកសង្គម ដែលជាផ្នែកមួយនៃក្រុមអន្តរវិន័យ។
- បង្កើត និងតាមដាន ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់បុគ្គលិកស្តារលទ្ធភាពពលកម្ម។

កង្វះខាត ផ្នែកការស្តារលទ្ធភាពពលកម្មនៅសហគមន៍ (CBR)៖ ពុំមានវិភាជន៍ថវិកាសម្រាប់អនុវត្តសកម្មភាព ការស្តារលទ្ធភាពពលកម្មនៅសហគមន៍ឡើយ ហើយអវត្តមាននៃការគ្រប់គ្រងដោយច្បាប់របស់រាជរដ្ឋាភិបាលលើការផ្តល់សេវា នាំឲ្យមានភាពមិនស្របគ្នារវាងគុណភាព និងគោលវិធីនៃការអនុវត្ត។

អនុសាសន៍៖

- ការគ្រប់គ្រងដោយច្បាប់លើការផ្តល់សេវា៖ រៀបចំការបណ្តុះបណ្តាលអនុលោមតាមសមត្ថភាព។ ផ្តល់ការទុកចិត្តដល់អង្គការណាដែលផ្តល់នូវបទអន្តរាគមន៍ស្តង់ដារជាអប្បបរមាមួយ ដោយគោរពតាមទស្សនវិជ្ជានិងអភិក្រមនៃការស្តារលទ្ធភាពពលកម្មសហគមន៍ និងសម្របសម្រួលការទទួលបានថវិការបស់ពួកគេពីរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ។
- ដាក់បញ្ចូលការស្តារលទ្ធភាពពលកម្មសហគមន៍ទៅក្នុងផែនការសកម្មភាពជាតិស្តីពីជនពិការ ដែលរាប់បញ្ចូលនូវជនរងគ្រោះដោយសារមីននិងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម តាមរយៈប្រព័ន្ធកំណត់ក្រុមជនពិការ ព្រមទាំងលើកកម្ពស់ការសហការរវាងភាគីពាក់ព័ន្ធទាំងឡាយ។

- ដាក់បញ្ចូលកម្មវិធីទាំងឡាយនៃការស្តារលទ្ធភាពពលកម្មសហគមន៍ និងច្បាប់ស្តីកិច្ចការ និងលើកកំពស់សិទ្ធិជនពិការ (PPRPD) ជាផ្នែកមួយនៃយុទ្ធសាស្ត្រផ្តល់សេវានានាថ្នាក់ឃុំ ដោយដាក់បញ្ចូលថវិកាផង ដូចជា កម្មវិធីវិនិយោគថ្នាក់ឃុំ និងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ ដែលស្ថិតនៅក្រោមកម្មវិធីវិមជ្ឈការនិងសហវិមជ្ឈការ។
- ដាក់ជាបទដ្ឋាននូវការប្រមូលទិន្នន័យពិការភាពដែលបំបែកលម្អិត និងការត្រួតពិនិត្យមើលចាប់ពីកម្រិតសហគមន៍។
- ដាក់បញ្ចូលគោលដៅនានាដើម្បីគាំទ្រដល់ការលើកកម្ពស់ការយល់ដឹងស្តីពីបញ្ហាពិការភាព និងការពង្រីកបន្ថែមនូវទំហំពិការភាព នៃកម្មវិធីជាតិ ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។
- រៀបចំសេចក្តីណែនាំសម្រាប់ការដាក់បញ្ចូលពិការភាព និងការលើកកម្ពស់ការយល់ដឹងស្តីពីសិទ្ធជនពិការទៅក្នុងសកម្មភាពរបស់ក្រសួងមហាផ្ទៃ និងដំណើរការកែទម្រង់រដ្ឋបាល និងការអភិវឌ្ឍសមត្ថភាពរបស់ក្រសួង។

បញ្ហាជាក់លាក់ (ង)៖ ការមានការងារធ្វើ

PPRPD លើកកម្ពស់ការមានការងារធ្វើ នៅក្នុងមាត្រា៣៣៖ សិទ្ធិទទួលបានការងារធ្វើដោយគ្មានការរើសអើង ដោយរាប់ទាំងការបម្រើការងារជាន្ត្រីរាជការ កម្មករ និយោជិត កូនជាង ឬកម្មសិក្សាការី និងមាត្រា៣៨៖ នីតិបុគ្គលត្រូវរៀបចំឲ្យមានការសម្របសម្រួលសមស្របសម្រាប់ជនពិការដែលជាបេក្ខជនដាក់ពាក្យសុំបម្រើការងារជាកម្មករ និយោជិត កូនជាង និងកម្មសិក្សាការី។ អនុក្រឹត្យស្តីពីកូតាជ្រើសរើសជនពិការឲ្យចូលបម្រើការងារត្រូវបានអនុម័តកាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១០ ដែលតម្រូវឲ្យនិយោជកផ្នែកសាធារណៈ និងឯកជននានា ត្រូវផ្តល់ឱកាស និងលទ្ធភាពចេញចូលរបស់ជនពិការគ្រប់រូបនៅក្នុងកន្លែងការងារ ដោយរួមបញ្ចូលទាំងការតម្រូវក្នុងការផ្តល់ការងារ និងការធ្វើរបាយការណ៍ ព្រមទាំងការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្មដល់និយោជកផងដែរ។

កង្វះខាត៖ ការទទួលបានតិចតួចនូវការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការធ្វើជំនួញ និងការបណ្តុះបណ្តាលជំនាញឯកទេសផ្សេងទៀត ធ្វើឲ្យជនពិការមិនមានភាពប្រកួតប្រជែងនៅក្នុងទីផ្សារការងារ ហើយជនពិការបានលើកពីបញ្ហានៃការរើសអើងនៅក្នុងដំណើរនៃការជ្រើសលើសបុគ្គលិក នៅតាមស្ថាបន័ឯកជន រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ព្រមទាំងបញ្ហាលក្ខណ៍ការងារ និងប្រាក់ចំណាច់ផ្សេងៗមិនស្មើគ្នា៖ ជនពិការរកចំណូលបាន ៦៥% តិចជាងជនមិនពិការ។

អនុសាសន៍៖

- ផ្សព្វផ្សាយ (ចាប់តាំងពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ) និងត្រួតពិនិត្យការអនុវត្ត PPRPD និងអនុក្រឹត្យស្តីពីកូតាជ្រើសរើសជនពិការឲ្យចូលបម្រើការងារ និងវិភាជនថវិកាសម្រាប់ការអនុវត្ត។
- ចងក្រងនូវបញ្ជីឈ្មោះអង្គការ/ស្ថាប័នវិស័យឯកជនទាំងឡាយ ដែលមានបុគ្គលិកចាប់ពី៥០ ទៅ ១០០នាក់ ដើម្បីត្រូវត្រួតពិនិត្យលើអនុវត្តកូតាជ្រើសរើសជនពិការឲ្យចូលបម្រើការងារ។
- បង្កើតនូវបទដ្ឋានអប្បបរមាមួយសម្រាប់និយោជកស្តីពី "ការស្នាក់នៅឲ្យបានសមស្រប" នៅឯកន្លែងធ្វើការសម្រាប់ជនពិការ។
- ផ្សព្វផ្សាយឱកាសការងារតាមប្រពន្ធ័ផ្សព្វផ្សាយផ្សេងៗ ដើម្បីលើកកម្ពស់ការទទួលបានការងារធ្វើ។
- ដាក់បញ្ចូលជនពិការទៅក្នុងក្រុមគោលដៅ ដើម្បីធ្វើការបណ្តុះបណ្តាលជំនាញឯកទេស និងជំនួញផ្សេងៗ និងពិនិត្យមើលនូវការយល់ដឹងរបស់ពួគេ។

បញ្ហាជាក់លាក់ (ច)៖ ទំនាក់ទំនងរវាងយេនឌ័រនិងការចិញ្ចឹមជីវិត ការអប់រំ អំពើហិង្សាលើផ្លូវភេទនិងផ្នែកយេនឌ័រ

នារីរតនៈ៣ ដែលគឺជាផែនការជាតិរបស់ក្រសួងកិច្ចការនារី បានបញ្ចូលនូវគោលដៅមួយចំនួនសម្រាប់ការដាក់បញ្ចូលពិការភាព ក្រោមផ្នែកទី១៖ ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច។ សកម្មភាពដែលបានស្នើឡើងនៅក្នុងកម្មវិធីជាតិតួយ៉ាងការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិឆ្នាំ២០១០-២០១៩ បានសង្កត់ធ្ងន់ទៅលើការបង្កើនលទ្ធភាពក្នុងការទទួលបានរបស់ស្ត្រី ក្រុមជនជាតិដើមភាគតិច និងក្រុមប្រជាជនងាយរងគ្រោះដទៃទៀតមនូវសេវានានា និងការគ្រប់គ្រង

លើធនធានអភិវឌ្ឍទាំងឡាយ ដែលសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។ មាត្រា៦ នៃ UNCRPD បានទទួលស្គាល់ថា នារី និងស្ត្រីពិការ គឺទទួលរងការរើសអើងច្រើន ហើយមាត្រា១៦បានចែងពីវិធានការផ្សេងៗក្នុងការការពារជនពិការពីរាល់ទម្រង់នៃការកេងប្រវ័ញ្ច ការរំលោភ និងការបំពាន ដែលរួមទាំងការរើសអើងផ្លូវភេទ ទាំងនៅក្នុងផ្ទះ និងក្រៅផ្ទះរបស់ពួកគេ ។

អនុសាសន៍៖

- ធ្វើការវិភាគពីស្ថានភាពរបស់នារី និងស្ត្រីពិការដោយយកCEDAW នារីរតន: និងUNCRPD ធ្វើជាគម្រោងផែនការយោងដើម្បីជាមូលដ្ឋានគ្រឹះក្នុងការរៀបចំ អនុវត្ត និងតាមដានសកម្មភាព និងយុទ្ធសាស្ត្រនានា។
- ផ្តល់ឲ្យនារី និងស្ត្រីពិការនូវអំណះអំណាងជាក់លាក់នៅក្នុងច្បាប់ស្តីពីការលុបបំបាត់ការជួយដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ និងច្បាប់ស្តីពីការបង្ការការពារអំពីហឹង្សាក្នុងគ្រួសារនិងការគាំពារជនរងគ្រោះ។
- រំលេចពីការគាំពារនារី និងស្ត្រីពិការនៅក្នុងច្បាប់ការងារ (ក្រសួងសង្គមកិច្ច ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ និងក្រសួងការងារ)
- ផ្តល់ដល់នារី និងស្ត្រី បុរស និងកុមារពិការនូវលទ្ធភាពទទួលបានព័ត៌មានស្តីអំពីអំពើហឹង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ និងសេវាសង្គមដទៃទៀតដែលពួកគេត្រូវទទួលបាន និងបង្កើនលទ្ធភាពរបស់ពួកគេក្នុងការទទួលបាននូវសេវាគាំពារទាំងនោះ។
- លើកកម្ពស់និងតាមដាននូវលទ្ធភាពក្នុងការចូលរួមក្នុងការអភិវឌ្ឍសង្គម ទទួលបានការអប់រំ ការចញ្ចឹមជីវិត និងសេវាសុខភាពនានា តាមរយៈការប្រមូលទិន្នន័យលម្អិតទាក់ទងនឹងការរើសអើងផ្លូវភេទ និងបញ្ហាផ្សេងៗទៀតរបស់ជនពិការ។

កង្វះខាត៖ នារី និងស្ត្រីពិការដែលមិនអាចទទួលបានការអប់រំពេញលេញ តែងតែទទួលបាននូវការងារដែលត្រូវនឹងជំនាញ និងចំណេះដឹងរបស់ពួកគេតិចជាងនារី និងស្ត្រីដែលមិនពិការ ហើយពួកគេជាញឹកញាប់តែងទទួលរងការកេងប្រវ័ញ្ចកម្លាំងពីសំណាក់ថៅកែ ជាពិសេសប្រសិនបើពួកគេមិនមានស្វាមី នៅមេម៉ាយ ឬក៏ពុំមានការជួយជ្រោមជ្រែងពីសំណាក់ក្រុមគ្រួសារបងប្អូនរបស់គេ។ ពួកគេតែងតែប្រឈមមុខនឹងគ្រោះថ្នាក់ ហើយតែងតែទទួលបានព័ត៌មានតិចតួចស្តីពីអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ ហើយជាទូទៅមិនមានលទ្ធភាពទទួលបានសេវាគាំទ្រទាំងឡាយឡើយ និងមិនសូវទទួលបានការគិតគូនៅក្នុងគំនិតផ្តួចផ្តើមកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរបស់ពួកគេឡើយ។ ក្នុងចំនួនស្ត្រីពិការ ១៨៧ នាក់ គឺមានតែ ៤% ប៉ុណ្ណោះដែលដឹងពីគម្រោង CIP បើប្រៀបនឹងបុរសពិការដែលមានចំនួនដល់ ១៥% (ក្នុងចំណោម ២០៦នាក់) ហើយសមាជិកគ្រួសាររបស់គេគឺមានចំនួន ២៧% (ក្នុងចំណោម ១៧៥នាក់)។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមស្តីពីបញ្ហាលើកឡើងក្នុងឯកសារនេះ សូមទាក់ទង៖

អង្គការជនពិការកម្ពុជា (CDPO)
លោក ងិន សៅវ័ន្ត នាយកប្រតិបត្តិ
អស័យដ្ឋាន៖ ក្នុងបរិវេណវត្តថាន់ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ ០២៣ ២២១ ៨២៣
អ៊ីម៉ែល៖ director@cdpo.org

សិទ្ធិកុមារ

១. ទិដ្ឋភាពទូទៅ

ចាប់តាំងពីឆ្នាំ១៩៩២ នៅពេលដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ អង្គការ មិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ រដ្ឋាភិបាល និងកុមារនិងយុវជន បាន និងកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការលើកកម្ពស់ និងការពារសិទ្ធិកុមារ។ ស្ថាប័ននិងភាគីពាក់ព័ន្ធខាងលើ បានបង្កើតនូវវឌ្ឍនភាពនានា ដើម្បីកែលម្អស្ថានភាពសិទ្ធិកុមារនៅកម្ពុជា។ យ៉ាងណាមិញ យើងនៅតែសម្គាល់ឃើញនូវចន្លោះប្រហោងលើវិស័យជាច្រើន។ មានយន្តការសក្តានុពលមួយចំនួន ដែលមិនទាន់បានបង្កើតឡើងនាពេលបច្ចុប្បន្ន ហើយដែលគប្បី រៀបចំបង្កើតឡើងនាពេលខាងមុខ រួមមាន៖ យន្តការថ្នាក់ជាតិ ដើម្បីបង្កើតនូវប្រព័ន្ធប្រកបដោយប្រសិទ្ធភាពសម្រាប់ការកំណត់នូវអំពើហិង្សា (ការរាយការណ៍ ការបញ្ជូនបន្ត ការស៊ើបអង្កេត ការព្យាបាល ការតាមដាន និងការបញ្ចូលទៅក្នុងប្រព័ន្ធតុលាការ) យន្តការឯករាជ្យ(ដូចជាស្ថាប័នឯករាជ្យលើបញ្ហាសិទ្ធិកុមារ ដែលកុមារអាចប្តឹងទារសំណងលើការរំលោភសិទ្ធិរបស់ពួកគេ) គោលការណ៍ណែនាំនិងយន្តការថ្នាក់ជាតិ (សម្រាប់ការគាំទ្រ និងការលើកទឹកចិត្តឲ្យមានការចូលរួមរបស់កុមារក្នុងសង្គម) និងប្រព័ន្ធគ្រប់គ្រងព័ត៌មានក្នុងការតាមដានការអនុវត្តសិទ្ធិកុមារ (ជាពិសេសការអនុវត្តច្បាប់ស្តីពីគោលនយោបាយពាក់ព័ន្ធកុមារជាតិ) ដែលប្រព័ន្ធនេះអាចជួយពង្រឹងគោលនយោបាយពាក់ព័ន្ធនឹងកុមារដែលមានស្រាប់ និងបង្កើនធនធានដល់ស្ថាប័នរដ្ឋាភិបាល ដែលធ្វើការពាក់ព័ន្ធនឹងសិទ្ធិកុមារ។

សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) ជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួន ៥៣ ដែលមានគោលបំណងរួមផ្តោតជាសំខាន់លើសិទ្ធិកុមារ។ គ.អ.ស.ក ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៤ ដើម្បីលើកកម្ពស់ការយល់ដឹងពីអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្នុងចំណោមកុមារ ឪពុកម្តាយរបស់ពួកគេ និងស្ថាប័នដែលពាក់ព័ន្ធ។ គ.អ.ស.ក ផ្តល់នូវកិច្ចខិតខំប្រឹងប្រែង និងធនធាន ដើម្បីប្រសិទ្ធភាព និងប្រសិទ្ធិផលនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ តាមរយៈការតស៊ូមតិដើម្បីសិទ្ធិកុមារ។ ជាពិសេស គ.អ.ស.ក ផ្តោតលើការជម្រុញឲ្យមានការរៀបចំ និងកែប្រែច្បាប់ គោលនយោបាយ និងផែនការសកម្មភាពដែលពាក់ព័ន្ធនឹងកុមារ។ ជាក់ស្តែង ស្ថាប័នក្រសួងរបស់រដ្ឋាភិបាល មានដូចជា ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាពិសេសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានសហការជាមួយ គ.អ.ស.ក លើការងារពិនិត្យលើរបាយការណ៍ជាតិ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា រៀបចំពង្រាងច្បាប់យុត្តិធម៌អនីតិជន និងជ្រើសរើសតំណាងកុមារឲ្យចូលរួមក្នុងអជ្ញាធរស្មុំកូនអន្តរប្រទេស និងវេទិកាកុមារអាស៊ី។ គ.អ.ស.ក ក៏ធ្វើការតាមដានការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា និងរៀបចំរបាយការណ៍បន្ថែមស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា ដាក់ជូនគណៈកម្មាធិការអង្គការសហប្រជាជាតិ។ អនុលោមតាមបេសកកម្មរបស់ខ្លួន គ.អ.ស.ក បាននិងកំពុងបំពេញនូវតួនាទី ព្រមទាំងកាតព្វកិច្ចរបស់ខ្លួន ដើម្បីលើកកម្ពស់និងការពារសិទ្ធិកុមារ រួមទាំងការចូលរួមរបស់កុមារ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គការសមាជិក អង្គការបណ្តាញ ឪពុកម្តាយ អង្គការអន្តរជាតិ កុមារ និងយុវជន និងស្ថាប័នរដ្ឋាភិបាល ជាពិសេសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

២. សូចនាករតាមដានរួម

ពុំមានសូចនាករតាមដានរួម សម្រាប់វិស័យសិទ្ធិកុមារទេ ព្រោះសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ពុំបានចូលរួមក្នុងក្រុមការងារបច្ចេកទេសដើម្បីកំណត់សូចនាករទាំងនោះ ហើយដែលវិស័យសិទ្ធិកុមារជាបញ្ហាពហុវិស័យ។

៣. ការចុះបញ្ជីកំណើត

ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ការចុះបញ្ជីកំណើតមានការរីកចម្រើនទូទាំងប្រទេសគួរឲ្យកត់សម្គាល់។ រដ្ឋាភិបាលអនុវត្តការងារចុះបញ្ជីកំណើតទៅតាមគោលនយោបាយជាតិ។ ការពិន័យលើការចុះបញ្ជីកំណើតយឺតយ៉ាវក្រោយរយៈពេល ៣០ថ្ងៃ ដែលមានចែងក្នុងច្បាប់ ជាឧបសគ្គសម្រាប់គ្រួសារក្រីក្រក្នុងការចុះបញ្ជីកំណើត។

កុមារនៃជនអន្តោប្រវេសន៍ខុសច្បាប់ ពុំមានសិទ្ធិទទួលបានការចុះបញ្ជីកំណើតនោះទេ។ ការអនុញ្ញាតដល់ពួកគេឲ្យទទួលបានការចុះបញ្ជីកំណើត នឹងបង្កឲ្យមានភាពស្មុគស្មាញលើបញ្ហាផ្នែកច្បាប់ ខណៈដែលការមិនផ្តល់សំបុត្រកំណើតឲ្យកុមារដែលទើបនឹងកើតរបស់ជនអន្តោប្រវេសន៍ខុសច្បាប់ទាំងនោះ នឹងនាំឲ្យមានការកើនឡើងនូវកុមារដែលកើតនៅ កម្ពុជាដោយខ្វះលក្ខខណ្ឌច្បាប់។

សំណូមពរ៖

- ការិយាល័យឃុំដែលទទួលខុសត្រូវចំពោះភូមិដាច់ស្រយាល គួររៀបចំឲ្យមានការិយាល័យចុះបញ្ជីកំណើតនៅជិតភូមិដាច់ស្រយាលទាំងនោះ ហើយគួរលើកលែងរាល់ការពិន័យចំពោះការចុះបញ្ជីកំនើតសម្រាប់ប្រជាជនក្នុងតំបន់នោះ។ ដូចគ្នានេះដែរ រដ្ឋាភិបាលគួរសម្របសម្រួលឲ្យការចុះបញ្ជីកំណើត នៅតែត្រូវធ្វើឡើងដោយពុំគិតកំរៃ ហើយការជាកពិន័យគួរត្រូវបានលើកលែងសម្រាប់ពលករចំណាកស្រុកដែលត្រឡប់មកពីក្រៅប្រទេស។
- ការចុះបញ្ជីកំណើតរបស់កុមារទាំងអស់ដែលកើតនៅប្រទេសកម្ពុជា ត្រូវប្រព្រឹត្តទៅដោយស្របច្បាប់ ដោយពុំគួរគិតពីស្ថានភាពផ្លូវច្បាប់របស់ឪពុកម្តាយពួកគេឡើយ។

៤. ការចូលរួមរបស់កុមារ

ការចូលរួមរបស់កុមារក្នុងកិច្ចការដែលពាក់ព័ន្ធសំខាន់ៗជាមួយពួកគេ ពុំទាន់មានភាពទូលំទូលាយនៅឡើយ។ យើងកត់សម្គាល់ថា ក្រុមប្រឹក្សាឃុំ-សង្កាត់ បានផ្តល់ឱកាសខ្លះសម្រាប់មនុស្សវ័យក្មេង រួមបញ្ចូលទាំងកុមារ ដើម្បីចូលរួមលើដំណើរការអភិវឌ្ឍន៍សហគមន៍ ប៉ុន្តែពុំទាន់បានធ្វើទូលំទូលាយទូទាំងប្រទេសនៅឡើយទេ។ ការចូលរួមរបស់កុមារ និងមនុស្សវ័យក្មេង ពុំទាន់ត្រូវបានទទួលស្គាល់ជាផ្លូវការនៅឡើយ ដោយសារកង្វះគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការ ចូលរួមរបស់កុមារ ដែលនឹងជួយដល់ការសម្រេចចិត្តរបស់អាជ្ញាធរមូលដ្ឋានក្នុងការបញ្ចូលកុមារទៅក្នុងការងាររបស់ពួកគេ។ ស្ថានភាពនេះ បានឆ្លុះបញ្ចាំងឲ្យឃើញពីស្ថានភាពទូទៅ និងផ្នត់គំនិតស្តីពីកុមារក្នុងសង្គមកម្ពុជា ដែលហាក់ដូចជាបដិសេធគោលគំនិតដែលកុមារអាចដើរតួនាទីយ៉ាងសកម្ម និងមានការទទួលខុសត្រូវក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។ លក្ខណៈនេះបានកម្រិតជាខ្លាំងលើឱកាសរបស់កុមារក្នុងការយល់ដឹង និងការអភិវឌ្ឍតួនាទីរបស់ពួកគេសម្រាប់អនាគតរបស់ខ្លួន។ រាជរដ្ឋាភិបាលមានគោលនយោបាយ ឬយន្តការគាំទ្រតិចតួចបំផុត ដើម្បីលើកកម្ពស់ការចូលរួមរបស់កុមារ។

សំណូមពរ៖

- ភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមផ្សេងទៀតក្នុងសង្គម គួរតែមានសកម្មបន្ថែមទៀត ក្នុងការបង្កឲ្យមានការចូលរួមរបស់កុមារក្នុងសកម្មភាពរបស់ខ្លួន។
- រដ្ឋាភិបាលគួរចាប់ផ្តើមរៀបចំគោលការណ៍ណែនាំ និងគម្រោងថវិកាជាតិសម្រាប់ការចូលរួមរបស់កុមារ នៅកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលដែលដំណើរការនៅកម្ពុជា គួរតែបន្តលើកកម្ពស់ និងបង្កឱកាសបន្ថែមទៀតឲ្យមានការចូលរួមរបស់កុមារក្នុងដំណើរការកម្មវិធី ការរៀបចំផែនការ ជាពិសេសក្នុងផ្នែកដែលពាក់ព័ន្ធនឹងបញ្ហាកុមារ។

៥. សិទ្ធិដែលពុំមែនជាកម្មវត្ថុនៃការធ្វើទារុណកម្ម ភាពឃោរឃៅ ភាពអមនុស្សធម៌ និងការប្រមាទឬការធ្វើទារុណកម្ម

អំពើហិង្សា ត្រូវបានជ្រួតជ្រាប និងចាក់ឫសយ៉ាងជ្រៅក្នុងសង្គមកម្ពុជា ហើយបានបង្កើតជាបរិយាកាសមួយ ដែលកុមារីកចម្រើនធំធាត់ក្នុងបរិយាកាសនេះ។ នៅមានកង្វះការយល់ដឹងពីផលប៉ះពាល់ភ្លាមៗលើផ្លូវចិត្ត និងផលប៉ះពាល់លើអត្តចរិតទៅអនាគត ដែលកើតចេញពីអំពើហិង្សាលើកុមារ។ បើទោះជាអង្គការមិនមែនរដ្ឋាភិបាលបានធ្វើការងារជាច្រើនក្នុងការជួយជនរងគ្រោះ ក៏ពួកគេនៅតែពុំអាចជួយជនរងគ្រោះទាំងអស់ ឬពុំអាចដោះស្រាយគ្រប់ករណី ដោយសារតែកង្វះខាតធនធានជាច្រើន។ ដោយយល់ពីកាតព្វកិច្ចអាទិភាពរបស់រដ្ឋាភិបាល និងដោយសារពុំមានថវិកាគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាទូទាំងប្រទេស ទីភ្នាក់ងាររដ្ឋាភិបាលពឹងផ្អែកយ៉ាងពេញទំហឹងលើអង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយបរទេស។

សំណូមពរ៖

- រដ្ឋាភិបាលគួរតែបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់កិច្ចការពារកុមារជាអាទិភាពក្នុងកម្មវិធីថ្នាក់ជាតិ និងថវិកាជាតិ។ រដ្ឋាភិបាលក៏គួរបន្តការព្យាយាមជាមួយឪពុកម្តាយ គ្រូបង្រៀន និងសង្គមផ្សេងទៀត ដើម្បីឲ្យពួកគេមានការយល់ដឹងពីផលប៉ះពាល់អវិជ្ជមានលើកុមារ ដោយសារការដាក់វិន័យផ្លូវកាយ និងគួរប្រើប្រាស់ការដាក់ពិន័យដោយអហិង្សាលើ កុមារតាមសាលារៀន និងតាមផ្ទះ។
- គួរលុបចោលមាត្រា ១០៤៥ នៃក្រមរដ្ឋប្បវេណី និងបញ្ញត្តិដែលចែងអំពីការបង្ការអំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ ដែលមានសិទ្ធិប្រើអំពើហិង្សាលើរូបរាងកាយរបស់កុមារ។
- រដ្ឋាភិបាលគួរបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យស្តីពីកុមាររងគ្រោះដោយសារអំពើហិង្សា ដើម្បីតាមដានស្ថានភាព និងផ្តល់នូវបទអន្តរាគមន៍ឲ្យបានសមស្រប។
- ទោះបីច្បាប់ស្តីពីការប្រឆាំងអំពើហិង្សាថ្មី បានហាមរាល់អំពើហឹង្សាលើសមាជិកទាំងអស់របស់គ្រួសារក៏ដោយ ប៉ុន្តែច្បាប់នេះ ចែងមិនច្បាស់លាស់ទាក់ទងនឹងការផ្តន្ទាទោសលើអំពើហិង្សាលើរូបរាងកាយកុមារ ក្នុងគោលបំណងដាក់វិន័យលើកុមារនោះទេ។ ច្បាប់នេះ គួរតែធ្វើវិសោធនកម្ម ឬរាជរដ្ឋាភិបាលគួរតែបញ្ជាក់ឲ្យបានច្បាស់អំពីច្បាប់នេះ ថាករណី អំពើហិង្សាលើរូបរាងកាយណា ដែលមានសភាពជ្រុលហួសពីចំណាត់ការទទួលស្គាល់ជាអន្តរជាតិ គឺត្រូវបានហាមឃាត់។

៦. ការថែទាំជំនួស

តួនាទីរបស់រដ្ឋក្នុងការផ្តល់ការថែទាំជំនួសសម្រាប់កុមារក្នុងស្ថានភាពលំបាក មិនត្រូវបានកំណត់ទេ ហើយបញ្ហានេះ ហាក់បីដូចជាមិនមែនជាផ្នែកមួយនៃរបៀបវារៈនយោបាយសម្រាប់ពេលអនាគត ដែលអាចដឹងមុននោះទេ។ ទោះបី ជាមានការរៀបចំបង្កើតស្តង់ដាអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារក៏ដោយ ប៉ុន្តែកង្វះថវិកាពីរដ្ឋាភិបាលដើម្បីថែរក្សាចំពោះកុមារទាំងអស់ដែលពុំមានឪពុកម្តាយ ឬកុមារស្ថិតក្នុងស្ថានភាពលំបាក នឹងបន្តឲ្យពួកគេរស់នៅក្នុងស្ថានភាពមិនមានសុវត្ថិភាព និងមិនល្អសម្រាប់សុខភាពនៅក្នុងមណ្ឌល ដែលគ្រប់គ្រងដោយរដ្ឋ។ លើសពីនេះទៅទៀត ការអនុវត្តរបស់ទីភ្នាក់ងាររដ្ឋាភិបាលក្នុងការដាក់កុមារក្នុងស្ថាប័ននានា ដោយជំនួសឲ្យការស្វែងរកមធ្យោបាយផ្សេង នឹងទំនងជាមិនមានការផ្លាស់ប្តូរទេ ប្រសិនបើមិនមានថវិកាបន្ថែម។

សំណូមពរ៖

- ការគួសបញ្ជាក់ពីការថែទាំកុមារ គួរតែស្វែងរកនូវជំរើសផ្សេងឲ្យបានច្រើនដើម្បីថែទាំកុមារ ប្រសិនបើ បរិយាកាសគ្រួសារ មិនផ្តល់លទ្ធផលសម្រាប់ការអភិវឌ្ឍន៍សមរម្យសម្រាប់កុមារ។ ការផ្តល់ជំនាញដល់ឪពុកម្តាយ គួរតែត្រូវបានលើកកំពស់ដើម្បីកែលម្អបរិយាកាសរស់នៅក្នុងគ្រួសាររបស់កុមារ ហើយការថែទាំកុមារនៅតាមស្ថាប័ន គួរតែជា ជម្រើសសម្រាប់រយៈពេលខ្លី និងជាជម្រើសចុងក្រោយ។

- រដ្ឋាភិបាល គួរដឹកនាំក្នុងការបង្កើតដំណោះស្រាយផ្សេងៗសម្រាប់ការថែទាំជំនួសចំពោះកុមារ និងបញ្ចេញថវិកាគ្រប់គ្រាន់ ដើម្បីផ្តល់ឲ្យភ្នាក់ងារសុខមាលភាពកុមាររបស់ខ្លួន ក្នុងការបំពេញតួនាទីរបស់ពួកគេ និងតាមដានគំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិល ។

៧. ការស្នុំកូន

យន្តការតាមដានក្នុងក្របខណ្ឌនៃការស្នុំកូនអន្តរប្រទេស នៅតែជាបញ្ហាគួរឲ្យបារម្ភដដែល។ ច្បាប់ស្តីពីការស្នុំកូនអន្តរប្រទេសនៅមិនទាន់ផ្សព្វផ្សាយទូលំទូលាយ ឬមិនទាន់ត្រូវបានយល់ច្រឡំនៅឡើយ។

សំណូមពរ៖

- បម្រាមការស្នុំកូនដោយជនបរទេស ត្រូវបានរឹតបន្តឹង ប៉ុន្តែបម្រាមនេះមិនបានហាមឃាត់ការស្នុំកូនកម្ពុជា ដោយជនបរទេសនោះទេ។ ការណែនាំក្នុងការអនុវត្តច្បាប់ថ្មីស្តីពីការស្នុំកូនអន្តរប្រទេស ត្រូវធ្វើជាបន្ទាន់ ដើម្បីចាត់វិធានការសមស្របក្នុងការអនុវត្តការស្នុំកូនអន្តរប្រទេស និងដើម្បីជៀសវាងការមានប្រតិកម្មផ្សេងលើករណីនេះ។
- គួរផ្សព្វផ្សាយឲ្យបានច្រើនលើច្បាប់ស្តីពីការស្នុំកូនអន្តរប្រទេស។
- រាជរដ្ឋាភិបាល គួរបង្កើតយន្តការតាមដានការស្នុំកូនអន្តរប្រទេសនេះ។

៨. ការស្លាប់របស់កុមារ

មានកង្វះខាតសំភារៈទំនើប និងថ្នាំពេទ្យមិនគ្រប់គ្រាន់ ហើយជារឿយថ្នាំពេទ្យមានគុណភាពអន់និងហួសកាលបរិច្ឆេទ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ សេវាសុខាភិបាលឥតគិតកម្រៃមិនត្រូវបានផ្តល់ ដល់កុមារតាមចិញ្ចើម ផ្តល់និងកុមារក្រីក្រនោះឡើយ ក្រៅពីសេវាដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល។ សេវាកម្មថែទាំសុខភាពសាធារណៈមិនត្រូវបានផ្តល់នៅក្នុងតំបន់ដាច់ស្រយ៉ាលទេ។ លើសពីនេះទៅទៀត មានកង្វះចំពោះវេជ្ជបណ្ឌិតដែលមានវិជ្ជាជីវៈច្បាស់លាស់ ហើយជាក់ស្តែងកង្វះខាតបែបនេះតែងកើតមាននៅតាមតំបន់ជនបទ។ ការអប់រំសុខភាពនៅតាមតំបន់ទាំងនេះ នៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ។

តម្រូវការចំពោះគិលានុបដ្ឋាយិកាផ្នែកសម្ភព និងពេទ្យឆ្មបដែលមានវិជ្ជាជីវៈ បាននិងកំពុងកើនឡើង ដោយសារមានការយល់ដឹងច្រើនចំពោះហានិភ័យ ដែលបណ្តាលមកពីការទទួលយកសេវាសម្ភពពីគ្រូឆ្មបបុរាណ។ សម្រាប់ពេលបច្ចុប្បន្ន កង្វះគ្រូពេទ្យប្រកបដោយវិជ្ជាជីវៈមិនអាចបំពេញតម្រូការបានទេ ជាពិសេសនៅតាមតំបន់ជនបទ។

កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ គឺជាមូលហេតុចំបងនៃការស្លាប់របស់កុមារ ហើយការខ្វះចំណីអាហារកំឡុងពេលវែងដែលបណ្តាលមកពីជីវភាពក្រីក្រ គឺជាមូលហេតុសំខាន់នៃការស្លាប់របស់កុមារផងដែរ។ ដូចនេះ យុទ្ធសាស្ត្រសំខាន់បំផុតគឺការជួយដល់គ្រួសារទាំងនេះ ដើម្បីទទួលបានអាហារគ្រប់គ្រាន់។ ហេតុផលផ្សេងទៀតគឺថា កង្វះអាហារូបត្ថម្ភអាចកើតឡើងដោយសារមានការយល់ដឹងខុសអំពីជីវជាតិអាហារដ៏ត្រឹមត្រូវសម្រាប់កុមារ ជាជាងកង្វះអាហារូបត្ថម្ភដែលបណ្តាលមកពីកង្វះចំណីអាហាររបស់កុមារ។ ប្រការនេះ អាចបង្កឧបសគ្គដល់ការលូតលាស់របស់កុមារ និងអាចឲ្យពួកគេងាយរងគ្រោះធ្លាក់ខ្លួនឈឺ។

សំណូមពរ៖

- រដ្ឋាភិបាលគួរធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធចំណាយថវិការបស់ខ្លួន ដើម្បីជៀសវាងការពន្យាពេលក្នុងការផ្ទេរថវិកាទៅឲ្យមន្ទីរសុខាភិបាលខេត្ត ដើម្បីអនុញ្ញាតឲ្យមន្ទីរទាំងនោះធ្វើអន្តរាគមប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។
- កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ គឺជាកត្តាធំមួយចំពោះអត្រាមរណៈភាពខ្ពស់សម្រាប់កុមារ និងកុមារមានជម្ងឺស្ថិតក្នុងអាយុក្រោម៥ឆ្នាំ។ មូលហេតុចម្បងនៃអសន្តិសុខស្បៀងអាហារយៈពេលវែង គួរតែត្រូវបានដោះស្រាយ ចំពោះ

គ្រួសារក្រខ្សត់ដែលមានកុមាររស់នៅជាមួយ ដោយជួយពួកគាត់ក្នុងការស្វែងរកប្រាក់ចំណូល ឬប្រសិនជាមិនអាចធ្វើទៅបានទេ គួរតែជួយពួកគាត់ក្នុងការទទួលបានលុយធ្វើដើមទុន។

- រាជរដ្ឋាភិបាលគួរចាត់វិធានការឲ្យបានសមស្រប ក្នុងការធ្វើអធិការកិច្ច និងពិនិត្យគុណភាពលើថ្នាំពេទ្យ ដើម្បីជៀសវាងការចែកចាយថ្នាំពេទ្យហួសកាលបរិច្ឆេទប្រើប្រាស់។ រាជរដ្ឋាភិបាលគួរដាក់ចេញនូវវិធានការ ដើម្បីប្រកាន់ខ្ជាប់នូវក្រមសីលធ៌មសុខាភិបាលជាសកល ដើម្បីផ្តល់ការថែរក្សា និងការព្យាបាលប្រកបដោយវិជ្ជាជីវៈទៅដល់កុមារណាដែលមានតម្រូវការជាចាំបាច់ ដោយមិនគិតពីស្ថានភាពរបស់កុមារ ឬពីលទ្ធភាពនៃការបង់ប្រាក់ ជាពិសេស កុមារដែលគ្មានផ្ទះសំបែង ឬកុមារសុំទាន។

៩. យុត្តិធម៌អនីតិជន

មានការព្រួយបារម្ភណ៍ជាច្រើន ដែលត្រូវបានកត់សំគាល់ដោយទីភ្នាក់ងារអន្តរជាតិ និងអង្គការមិនមែន រដ្ឋាភិបាលនានា ដូចជា ការមិនផ្តល់ព័ត៌មានអំពីការចាប់ខ្លួនកុមារដល់ឪពុកម្តាយ ការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលយូរ ការទទួលបានជំនួយផ្លូវច្បាប់មិនសមស្រប កង្វះច្បាប់កាត់ទោសដាច់ដោយឡែក មិនមានប្រព័ន្ធយុត្តធម៌សម្រាប់អនីតិជន និងកង្វះបញ្ញត្តិនៃការកាត់ទោសដោយមិនមានការឃុំឃាំងចំពោះអនីតិជន។ ការឃុំខ្លួនកុមារជាមួយមនុស្សចាស់ នៅតែមានចំពោះពន្ធនាគាមួយចំនួន ទោះបីជាមាននីតិវិធីដែលមានស្រាប់ក៏ដោយ ដែលពីមុនការឃុំខ្លួននេះមានស្ទើរតែ គ្រប់ពន្ធនាគារនៅតាមខេត្ត។ យ៉ាងណាមិញនាពេលថ្មីៗនេះ តាមរយៈទស្សនកិច្ចរបស់បុគ្គលិកអង្គការយូនីសេហ្វ បានរកឃើញថាក្នុងពន្ធនាគាមួយចំនួន កុមារត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកពីមនុស្សចាស់។ យើងមិនអាចដឹងថា តើទិន្នន័យនេះអាចទុកចិត្តបានប៉ុណ្ណានោះទេ ខណៈដែលទស្សនកិច្ចក្នុងពន្ធនាគារតម្រូវឲ្យមានការជូនដំណឹងជាមុន។ ជាទូទៅ កង្វះចំណីអាហារគ្រប់គ្រាន់សម្រាប់កុមារនៅក្នុងពន្ធនាគារ បណ្តាលឲ្យពួកគេជួបប្រទះបញ្ហាសុខភាព។ កុមារទាំង នោះមានឱកាសតិចតួចណាស់ ឬមិនមែនទាល់តែសោះ ចំពោះការទទួលបានការអប់រំ។

សំណូមពរ៖

- សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានបញ្ចប់ ហើយកំពុងរង់ចាំការអនុម័ត។ កិច្ចការនេះគប្បីត្រូវធ្វើឡើងជាបន្ទាន់ ដោយហេតុថាតាមប្រព័ន្ធតុលាការ កុមារត្រូវគេធ្វើចំណាត់ការដូចមនុស្សចាស់ឡើយ។ ដូចនេះ យន្តការតាមដានដើម្បីឲ្យសមស្របនឹងប្រព័ន្ធថ្មីនេះ គួរតែត្រូវបានបង្កើតឡើង ដោយរួមបញ្ចូលទាំងយន្តការទទួលពាក្យបណ្តឹង ឯករាជ្យ ឬមន្ត្រីទទួលពាក្យបណ្តឹងឯករាជ្យរបស់កុមារ។
- រដ្ឋាភិបាលគួរតែចាត់វិធានការជាបណ្តើរៗ ដើម្បីធានាថា មន្ត្រីតុលាការ និងមន្ត្រីពន្ធនាគារអនុវត្តតាមច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងកុមារ ដោយផ្តល់ឲ្យពួកគេនូវវគ្គបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យពួកគេមានសមត្ថភាពក្នុងអនុវត្តច្បាប់ទាំងនេះបាន។
- រដ្ឋាភិបាលត្រូវតែការពារអនីតិជននៅក្នុងពន្ធនាគារពីការធ្វើទុក្ខទោស និងការរំលោភបំពានផ្សេងៗ ដោយមនុស្សចាស់។

១០. ពលកម្មកុមារ

រដ្ឋាភិបាលមិនបានវិភាជថវិកាឲ្យបានគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាពលកម្មកុមារនៅទូទាំងប្រទេសនោះទេ ហើយភាគច្រើន រដ្ឋាភិបាលពឹងផ្អែកលើមូលនិធិរបស់ម្ចាស់ជំនួយ។ គ្រួសារក្រីក្រធ្វើចំណាកស្រុកទៅទីក្រុងផ្សេងៗ និងបញ្ជូនកូនរបស់ពួកគាត់ ដើម្បីរកការងារធ្វើទោះបីបានកំរៃ ប៉ុន្មានក៏ដោយ បញ្ហានេះវានឹងបណ្តាលឲ្យកូនរបស់ពួកគាត់ជួបនឹងគ្រោះថ្នាក់ដោយត្រូវបានគេជួញដូរ រំលោភបំពាន និងកេងប្រវ័ញ្ច។ ទោះបីរាជរដ្ឋាភិបាលដោះស្រាយករណីខ្លះនៃការជួញដូរក៏ដោយ ប៉ុន្តែពុំមានច្បាប់ណាមួយត្រូវបានអនុវត្តដើម្បីឲ្យឪពុកម្តាយទទួលខុសត្រូវ ចំពោះការកេងប្រវ័ញ្ចកូនរបស់ពួកគាត់ទៅតុលាការនោះទេ។

សំណូមពរ៖

- ការបណ្តុះបណ្តាលវិជ្ជាជីវៈអាចបង្វែរកុមារពីស្ថានភាពនៃការធ្វើការងារដ៏ធ្ងន់ធ្ងរ និងអាចអនុញ្ញាតឲ្យកុមាររកប្រាក់ចំណូលគ្រប់គ្រាន់ ប្រសិនបើការបណ្តុះបណ្តាលនោះមានស្តេរភាព និងមានប្រសិទ្ធិភាព។ ការវិភាគលើទីផ្សារគួរណែនាំអំពីការផ្តល់ឲ្យនូវការបណ្តុះបណ្តាលសម្រាប់ការធ្វើការងារដើម្បីខ្លួនឯង (Self-employment) ហើយ ការរួមសហការ រវាងរដ្ឋាភិបាល និយោជិក និងអង្គការសង្គមស៊ីវិលគប្បីត្រូវបានលើកកម្ពស់។
- ការចុះឈ្មោះចូលរៀនឡើងវិញ នៅក្នុងប្រព័ន្ធសាលារបស់រដ្ឋសម្រាប់កុមារដែលបានបោះបង់ការសិក្សាមួយរយៈដោយគ្មានការត្រៀមខ្លួនរៀបចំគ្រប់គ្រាន់ អាចនាំទៅដល់ការបោះបង់សាលាមុនពេលកំណត់។ ការអប់រំជាផ្នែកមួយនៃដំណោះស្រាយ ក៏ប៉ុន្តែត្រូវតែពិនិត្យមើលដោយភ្ជាប់ជាមួយនឹងភាពជាក់ចំពោះកុមារដែលធ្វើការងារ។ ហេតុនេះ ប្រព័ន្ធអប់រំដែលជាកាតព្វកិច្ចរបស់រដ្ឋ នឹងជួយដល់ការកាត់បន្ថយពលកម្មកុមារ ប្រសិនបើប្រព័ន្ធនេះអនុវត្តទៅដោយសមស្រប។

១១. គ្រឿងញៀន

មានក្តីកង្វល់ជាច្រើនចំពោះការរីករាលដាលមេរោគហ៊ីវ/អេដស៍ក្នុងពេលអនាគត ក្នុងចំណោមក្រុមងាយរងគ្រោះជាពិសេសការរួមភេទដោយពុំមានសុវត្ថិភាពក្រោមឥទ្ធិពលនៃថ្នាំអំភេតតាមីនលើកកម្លាំង ដែលត្រូវបានទទួលស្គាល់ ទូលំទូលាយថាជាថ្នាំលើកកម្លាំងដល់ពួកគេក្នុងការរួមភេទ ។ ការកើនឡើងនៃការប្រើប្រាស់ថ្នាំចាក់តាមសរសៃនឹងនាំទៅរកអត្រាខ្ពស់ក្នុងការចម្លងរោគ។ វាហាក់ដូចជាទំនាក់ទំនងដែលបង្កើតឡើងវាងការប្រើប្រាស់ថ្នាំ ឥរិយាបថក្រុមទំនើង និងបទឧក្រិដ្ឋ។ ក្តីបារម្ភជាងនេះទៅទៀតនោះគឺការរាលដាលនៃមេរោគហ៊ីវ/អេដស៍ ក្នុងចំណោមអ្នកដែលប្រើប្រាស់គ្រឿង ញៀននៅតំបន់ដាច់ស្រយ៉ាល។

ការខ្វះខាតមធ្យោបាយក្នុងការព្យាបាលការញៀនថ្នាំញៀនគឺជាក្តីបារម្ភដ៏ធំមួយ។ ជាក់ស្តែង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូច និងស្ថាប័នរដ្ឋាភិបាលដែលបានដំណើរការមជ្ឈមណ្ឌលស្តារនីតិសម្បទា ពុំមានសមត្ថភាព ឬថវិកាក្នុងការព្យាបាលការញៀនថ្នាំញៀន និងសារធាតុញៀនឲ្យបានគ្រប់គ្រាន់។ រាជរដ្ឋាភិបាល បានគាំទ្រទៅដល់ស្ថាប័នកងរាជអាវុធហត្ថ ជាទីកន្លែងដែលអ្នកញៀនថ្នាំត្រូវបានបញ្ជូនទៅទីនោះ ដើម្បីធ្វើការព្យាបាលតាមរយៈការព្យាបាលដោយការប្រើវិធីសាស្ត្រព្យាបាលតាមកម្លាំងបង្ខំ។ ជាទូទៅ ការព្យាបាលរបៀបនេះត្រូវបានគេទទួលស្គាល់ថា អាចធ្វើឲ្យមានអត្រាខ្ពស់ក្នុងការមានជំងឺនេះឡើងវិញ ព្រមទាំងធ្វើឲ្យមានករណីរំលោភសិទ្ធិមនុស្សចំពោះអ្នកជំងឺផងដែរ។

សំណូមពរ៖

- ការអនុវត្តច្បាប់ទាក់ទងនឹងការនាំចូល ការផលិត និងការលក់ថ្នាំ ត្រូវធ្វើឲ្យប្រសើរឡើង និងគប្បីយកចិត្តទុកដាក់ជាអាទិភាព ក្នុងខណៈដែលគួរមានបទបញ្ញត្តិគ្រប់គ្រងសារធាតុញៀន ដូចជាការជាដើម ដើម្បីជៀសវាងភាពងាយស្រួលក្នុងការប្រើប្រាស់គ្រឿងញៀន ដែលក្មេងៗកំពុងអនុវត្តនាពេលបច្ចុប្បន្ន។
- ការកសាងសមត្ថភាពគួរផ្តល់ជូនអ្នកផ្តល់សេវាកម្មទាក់ទងនឹងការពិគ្រោះយោបល់ ការបន្សាប និងការគាំទ្រក្នុងការតាមដាន។ គំនិតផ្តួចផ្តើមក្នុងការព្យាបាលតាមបែបសហគមន៍ ដូចជាមណ្ឌលស្តារយុវនីតិសម្បទា គួរត្រូវបានលើកទឹក ចិត្តជាជាងការពឹងផ្អែកតែទៅលើការព្យាបាលតាមបែបគ្រឹះស្ថានតែមួយមុខ។ ស្តង់ដារអប្បបរិមា គួររៀបចំបង្កើតឡើង ហើយអនុវត្តចំពោះការព្យាបាលកុមារដែលញៀនថ្នាំញៀននៅគ្រប់មជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនទាំងអស់ ហើយការគាំទ្រផ្នែកហិរញ្ញវត្ថុគួរធ្វើវិភាជ ដើម្បីធ្វើការព្យាបាលកុមារដែលញៀនថ្នាំញៀន។ ការព្យាបាលគ្រឿងញៀន គប្បីជាបន្ទុករបស់ស្ថាប័នស៊ីវិល។

១២. ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

រដ្ឋាភិបាល ជាអ្នកឆ្លើយតបទៅនឹងការដាក់សម្ពាធពីសហរដ្ឋអាមេរិក នៅពេលមានការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ផ្ទុយទៅវិញ ឆន្ទៈនយោបាយក្នុងការលុបបំបាត់គ្រប់ទម្រង់នៃការកេងប្រវ័ញ្ចលើកុមារ ជាពិសេសការកេងប្រវ័ញ្ចជួញដូរផ្លូវភេទ ហាក់នៅមានកម្រិតនៅឡើយ។ រដ្ឋាភិបាលពុំអាចផ្តល់ហិរញ្ញប្បទាន ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហានេះឲ្យបានគ្រប់គ្រាន់នោះទេ។ ជាផ្នែកមួយនៃការខ្វះខាតធនធានទាំងនេះ ទីភ្នាក់ងាររដ្ឋាភិបាលនៅខ្វះសមត្ថភាព និង/ឬការលើកទឹកចិត្ត ក្នុងការដឹកនាំប្រយុទ្ធប្រឆាំង ទៅនឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

ហេតុផលចម្បងមួយក្នុងចំណោមហេតុផលចម្បងជាច្រើនក្នុងការផ្តន្ទាទោសទៅលើករណីរំលោភ គឺការប្រតិបត្តិនូវការសងសំណងជំងឺចិត្តក្រៅប្រព័ន្ធតុលាការ ដែលការប្រតិបត្តិបែបនេះ គឺបានលើកទឹកចិត្តដល់មន្ត្រីអនុវត្តច្បាប់ឲ្យធ្វើបែបនេះទៀត។ មិនត្រឹមតែក្រុមគ្រួសារជនរងគ្រោះប៉ុណ្ណោះទេ តែរួមទាំងអាជ្ញាធរមូលដ្ឋានមួយចំនួនផងដែរ មិនបានយល់ថាការសងសំណងជំងឺចិត្តគឺមិនមែនជាការឃារឃាំងដល់ការផ្តន្ទាទោសបទល្មើសបានទេ។

សំណូមពរ៖

- កង្វះខាតបទប្បញ្ញត្តិស្តីពីការការពារកុមារនៅប្រទេសកម្ពុជា និងគោលការណ៍ណែនាំផ្សេងៗទៀត ក្នុងការធ្វើ អន្តរាគមន៍ ត្រូវតែរៀបចំឲ្យមានជាបន្ទាន់។
- រដ្ឋាភិបាលត្រូវខិតខំប្រឹងប្រែងថែមទៀត ក្នុងការទទួលខុសត្រូវដោះស្រាយបញ្ហានេះ ដោយការធ្វើវិភាជថវិកាឲ្យបានគ្រប់គ្រាន់ទៅឲ្យទីភ្នាក់ងាររដ្ឋាភិបាល និងនាយកដ្ឋានក្រសួងនានា ដែលទទួលបន្ទុកការងារនេះ។
- រដ្ឋាភិបាល ត្រូវបង្កើតឲ្យមានស្ថាប័នត្រួតពិនិត្យតាមដានឯករាជ្យមួយ ដើម្បីធានាចំពោះស្តង់ដារអប្បបរិមា ក្នុងការថែរក្សា និងបង្កើតឲ្យមានយន្តការទទួលពាក្យបណ្តឹង។
- ការកសាងសមត្ថភាពសម្រាប់ការព្យាបាលជម្ងឺនិងការងារសង្គម គប្បីយកចិត្តទុកដាក់ជាអាទិភាព ដោយយកចិត្តទុកដាក់ជាសំខាន់លើកម្រិតនៃការអប់រំទាបរបស់អ្នកធ្វើការងារសង្គម។

ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទាក់ទង៖

សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGOCRC)
លោកស្រី យឹម សុខារី ប្រធានគណៈកម្មាធិការប្រតិបត្តិ
លោក មាស សំណាង អគ្គលេខាធិការ
ទូរស័ព្ទ៖ (៨៥៥) ២៣ ៨៨២ ៤១២
អ៊ីម៉ែល៖ info@ngocrc.org
អាសយដ្ឋាន៖ ផ្ទះលេខ ៨A ផ្លូវ ១៣៨ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ

ផែនការអភិវឌ្ឍន៍ជាតិ

ធ្វើការរួមគ្នាឆ្ពោះទៅកាន់ការសម្រេចបានភាពជាម្ចាស់របស់ប្រទេសលើផែនការអភិវឌ្ឍន៍ជាតិ

១. សេចក្តីផ្តើម

ផែនការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា បានវិវត្តចេញពីផែនការជាតិសម្រាប់ការស្តារនីតិសម្បទានិងការកសាងប្រទេសកម្ពុជាឡើងវិញ (ឆ្នាំ១៩៩៣-១៩៩៥) ទៅជាផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច (SEDP) ១ (ឆ្នាំ១៩៩៦-២០០០) ផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច (SEDP) ២ (ឆ្នាំ២០០១-២០០៥) ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្របណ្តោះអាសន្ន (ឆ្នាំ២០០០) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ឆ្នាំ២០០៣-២០០៥ រហូតដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ ២០០៦-២០១០ និង ចុងក្រោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) តាមរយៈគម្រោងគោលនយោបាយអភិវឌ្ឍន៍របស់ខ្លួន ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងគ្រប់វិស័យនៅកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការរៀបចំ និងការតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា តាំងពីឆ្នាំ ២០០០។

ជាសមាជិកមួយនៃក្រុមការងារបច្ចេកទេសស្តីពីការធ្វើផែនការនិងកាត់បន្ថយភាពក្រីក្រ (TWG-PPR) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលសមាជិកភាពចំនួនពីរ ដែលរួមមានគណៈ កម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា(CCC) និង MEDiCAM បានសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យចំនួន ១៨ ដើម្បីផ្តល់យោបល់និងធាតុចូល ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ នៅក្នុងឆ្នាំ ២០០៩ និង ឆ្នាំ ២០១០។ ក្នុងឆ្នាំ ២០១១ក្រសួងផែនការបានដឹកនាំការរៀបចំការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ដោយប្រើយន្តការមានស្រាប់ ដែលត្រូវបានធ្វើតាមរយៈ ក្រុមការងារបច្ចេកទេស និងក្រុមការងារដែលបានបង្កើតនៅតាមក្រសួង/ស្ថាប័នទទួលបន្ទុកនីមួយៗរបស់រាជរដ្ឋាភិបាលកម្ពុជា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានសម្របសម្រួលអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យក្នុងការចូលរួមក្នុងកិច្ចដំណើរការនេះ ដោយអនុវត្តតាមយន្តការមានស្រាប់ដែលបានស្នើដោយក្រសួងផែនការ។ ជាលទ្ធផលមានអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យតែ៧ប៉ុណ្ណោះ ដែលបានចូលរួមក្នុងកិច្ចដំណើរការនេះ និង បានផ្តល់យោបល់របស់ខ្លួនលើសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិ(MTR) លើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម[96] ។ យោបល់របស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យទាំង៧រួមមាន:១-ការទទួលព័ត៌មាន ២-ការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្ម ៣- ជលផល ៤-ភាពជាដៃគូក្នុងអភិវឌ្ឍន៍ ៥-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៦-កំណែទម្រង់ដីធ្លី និង ៧- ព្រៃឈើ។

អង្គការមិនមែនរដ្ឋាភិបាលវាយតម្លៃខ្ពស់ចំពោះឱកាសដែលផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ និង ការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការនេះ និង សូមអះអាងសារជាថ្មីនូវការប្តេជ្ញារបស់យើងចំពោះការចូលរួមក្នុងលក្ខណៈស្ថាបនាជាមួយរាជរដ្ឋាភិបាល

[96]ក្នុងពេលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ក្នុងឆ្នាំ២០០៩និង២០១០អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យចំនួន ១៨បានផ្តល់យោបល់និងធាតុចូលសរុបចំនួន៣៧៥លើសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្មហើយមានតែយោបល់ចំនួន៦៥ប៉ុណ្ណោះដែលត្រូវបានទទួលយកឬដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្មចុងក្រោយ តាមការវាយតម្លៃដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលក្នុងឆ្នាំ២០១១។ យោបល់ទាំងនេះ និងការវាយតម្លៃលឿនលើការដាក់បញ្ចូលយោបល់របស់អង្គការមិនមែនរដ្ឋាភិបាល អាចរកឃើញនៅក្នុងគេហទំព័រ:http://www.ngoforum.org.kh/eng/enpublications.php?docs=dppdoc

កម្ពុជាក្នុងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម និង យុទ្ធសាស្ត្រចតុកោណ។ ដើម្បីរួមចំណែកដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកាត់បន្ថយភាពក្រីក្រអង្គការមិនមែនរដ្ឋាភិបាលបានធ្វើការប្រកបដោយការទទួលខុសត្រូវ នៅក្នុងតួនាទីឯករាជ្យរបស់ខ្លួន តាមរយៈការចូលរួមដ៏សកម្ម ការជួយគាំទ្រនិងវិភាគទានបំពេញបន្ថែមរបស់ខ្លួន និង ការតាមដានរបាយការណ៍ពីកម្រិតមូលដ្ឋាន ចំពោះការរៀបចំនិងការអនុវត្តផែនការនិងយុទ្ធសាស្ត្រខាងលើ។ ហេតុដូច្នេះ វាគឺជាមនសិការខាងសង្គមកិច្ចនិងសេដ្ឋកិច្ចរបស់យើង ដោយផ្អែកលើផលប្រយោជន៍រួម ក្នុងការសម្តែងការវាយតម្លៃខ្ពស់របស់យើងចំពោះសមិទ្ធផលរបស់រដ្ឋាភិបាលកម្ពុជាក៏ដូចជាកង្វល់របស់យើងអំពីសកម្មភាពជាក់ស្តែង ដែលហាក់បីដូចជាមិនស្របគ្នា ឬ ខុសពីគោលដៅគោលនយោបាយទាំងឡាយដែលមានចែងនៅក្នុងសូចនាករតាមដានរួម (JMIs) និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣។ ក្នុងន័យនេះ អង្គការមិនមែនរដ្ឋាភិបាល[97]ដែលបានចូលរួមក្នុងកិច្ចដំណើរការរៀបចំផែនការជាតិ សូមលើកឡើងនូវបញ្ហាមួយចំនួនដែលកើតឡើងក្នុងអំឡុងពេលរៀបចំការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ដូចខាងក្រោម។

២. សូចនាករតាមដានរួម៖[98] ការធ្វើផែនការ និង ការកាត់បន្ថយភាពក្រីក្រ

ស្ថាប័នសម្របសម្រួល៖ TWG-PPR/ក្រសួងផែនការ
ស្ថាប័នអនុវត្ត៖ ក្រសួងផែនការ

លទ្ធផលភ្លាម	ទិន្នផល	សូចនាករទិន្នផល	សកម្មភាពវាស់	សកម្មភាពប្រសិទ្ធភាពជំនួយពាក់ព័ន្ធ
១.ពង្រឹងសមត្ថភាពក្រសួងផែនការ និងក្រសួង/ស្ថាប័នពាក់ព័ន្ធ ដើម្បីតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ រួមទាំងការរៀបចំការត្រួតពិនិត្យពាក់កណ្តាលអាណត្តិក្នុងឆ្នាំ ២០១១ ដោយប្រើអភិក្រមនៃការចូលរួមដូចការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។	១. ផែនការយុទ្ធសាស្ត្រក្រសួងផែនការ ឆ្នាំ ២០០៩-២០១៣ ២. របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១១	១.តម្រឹមធនធានដែលមានទាំងធនធានរបស់ដៃគូអភិវឌ្ឍន៍ ទាំងខាងរាជរដ្ឋាភិបាល ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការ ឆ្នាំ ២០១០-២០១១ ដែលត្រូវបញ្ចប់ក្នុងខែមិថុនា ឆ្នាំ ២០១០ ២. របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១១ នឹងត្រូវបញ្ចប់ក្នុងខែកញ្ញា ឆ្នាំ២០១១	១.ក្រសួងផែនការនិងដៃគូអភិវឌ្ឍន៍ពិនិត្យមើលនិងអនុម័តផែនការយុទ្ធសាស្ត្រក្រសួងផែនការឆ្នាំ ២០០៩-២០១៣ ត្រឹមខែឧសភា ឆ្នាំ២០១០។ ២. រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ពិនិត្យ និងអនុម័តផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់ឆមាសទី ២ ឆ្នាំ២០១០ត្រឹមខែមិថុនា ឆ្នាំ ២០១០ និង សម្រាប់ឆ្នាំ២០១១ ត្រឹមខែធ្នូ ឆ្នាំ២០១០។ ៣. រៀបចំនិងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ក្រសួងផែនការ ត្រឹមខែមិថុនា ឆ្នាំ ២០១១។ ៤. អនុក្រុមសម្រាប់តាមដាន និងវាយតម្លៃ នៃក្រុមការងារ**ផែនការនិងការកាត់បន្ថយភាពក្រីក្រ**ត្រូវប	១.បញ្ចប់និងអនុម័តគោលការណ៍ភាពជាដៃគូ ដើម្បី រៀបចំ PBA មួយជូនក្រសួងផែនការមុនដំណាច់ខែមិថុនា ឆ្នាំ ២០១០។ ២. ធ្វើបច្ចុប្បន្នកម្មផែនទីបង្ហាញផ្លូវ PBA ដើម្បីគាំទ្រការចាប់ផ្តើមអនុវត្ត PBA សម្រាប់ក្រសួងផែនការ។

[97]ពាក្យអង្គការមិនមែនរដ្ឋាភិបាល គឺសំដៅលើអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ដែលបានចូលរួមក្នុងកិច្ចដំណើរការធ្វើផែនការជាតិ ជាពិសេស ក្នុងការរៀបចំការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម។

[98]បញ្ជីទាំងស្រុងមួយនៃសូចនាករតាមដានរួមទាំងអស់ ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំ CDCF លើកទី ៣ កាលពីខែ មិថុនា ឆ្នាំ២០១០អាចរកបានពី http://www.cdc-crdb.gov.kh/cdc/third_cdcf/session4/jmis_en.htm

			ព្រាប់ការងារស្តីពីការធ្វើបច្ចុប្បន្នកម្ម សូចនាករនៃផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ មុនដំណាច់ខែមិថុនា ឆ្នាំ២០១១។ ៥. រៀបចំនិង និងបញ្ចប់របាយការណ៍ត្រួតពិនិត្យការអនុវត្តពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងខែកញ្ញា ឆ្នាំ២០១១ដែលត្រូវគាំទ្រដោយកិច្ចប្រជុំប្រចាំខែរបស់អនុក្រុមតាមដាននិងវាយតម្លៃនៃក្រុមការងារ**ផែនការ និងការកាត់បន្ថយភាពក្រីក្រ** នៅក្នុងអំឡុងពេលរៀបចំការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិ។	
២. ពង្រឹងចំណាត់ការស្តាប័នដើម្បីធ្វើសុខុដុមនីយកម្មការរៀបចំផែនការចំណាយលើការវិនិយោគសាធារណៈនិងកិច្ចដំណើរការហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍	៣. របាយការណ៍វិភាគស្ថានភាព ៤. ផែនការសកម្មភាពដើម្បីសម្រេចបានការពង្រឹងចំណាត់ការស្តាប័ន ដើម្បីធ្វើសុខុដុមនីយកម្មការរៀបចំផែនការចំណាយលើការវិនិយោគសាធារណៈនិងកិច្ចដំណើរការហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍	៣. របាយការណ៍វិភាគស្ថានភាព ត្រូវបញ្ចប់ឲ្យបានមុនដំណាច់ខែធ្នូ ឆ្នាំ ២០១០ ហើយផែនការសកម្មភាពរបាយការណ៍វិភាគស្ថានភាពត្រូវបញ្ចប់ឲ្យបានមុនដំណាច់ខែធ្នូ ឆ្នាំ២០១១	ក្រោមការដឹកនាំរបស់ក្រុមការងារគ្រប់គ្រងកិច្ចដំណើរការនៃការធ្វើសុខុដុមនីយកម្មការរៀបចំផែនការចំណាយលើការវិនិយោគសាធារណៈ និងហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការ៖ ៦. អនុវត្តការវិភាគស្ថានភាព ដែលនឹងអភិវឌ្ឍអនុសាសន៍ដើម្បីធ្វើសុខុដុមនីយកម្មការរៀបចំផែនការ (ក្រសួងផែនការ) ចំណាយលើការវិនិយោគសាធារណៈ(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) និងកិច្ចដំណើរការហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (CRDB/CDC) មុនដំណាច់ខែធ្នូ ឆ្នាំ ២០១០ ៧. បញ្ចប់ផែនការសកម្មភាពមួយរួមជាមួយសូចនាករតាមដានសមស្របដើម្បីអនុវត្តអនុសាសន៍មុនដំណាច់ខែមិថុនា ឆ្នាំ ២០១១។	

២.១ ការរៀបចំការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិក្នុងឆ្នាំ ២០១១ដោយអនុវត្តតាមអភិក្រមចូលរួមដែលត្រូវបានប្រើនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

អង្គការមិនមែនរដ្ឋាភិបាល សូមអបអរសាទររាជរដ្ឋាភិបាលកម្ពុជា ចំពោះការបញ្ចប់ការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ២០១១លើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ទោះបីជាវាយឺតជាងការគ្រោងបន្តិចដូចដែលមានលើកឡើងនៅក្នុងសូចនាករតាមដានរួមខាងលើក្តី។ អង្គការមិនមែនរដ្ឋាភិបាល ជឿថាការប្រកាសគោល

នយោបាយដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ក្រោយពេលមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយអង្គការសង្គមស៊ីវិលដូចជាក្រុមសាសនា អង្គការសហគមន៍ (CBOs) តំណាងសហគមន៍ សមាជិកសភា ។ល។ និង ភាគីពាក់ព័ន្ធ ដូចជាដៃគូអភិវឌ្ឍន៍ និង ផ្នែកឯកជន អាចមានសក្តានុពលរួមចំណែកដល់ការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងជីវិតរបស់ប្រជាជនក្រខ្សត់និងងាយរងគ្រោះ នៅក្នុងរយៈពេលប្រាំឆ្នាំនេះ។ ការសម្រេចបានចំណុចដៅទាំងឡាយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិង ការសម្រេចបានយន្តការតាមដាននិងវាយតម្លៃប្រកបដោយប្រសិទ្ធភាព តម្រូវឲ្យមានការដឹកនាំជាបឋមពីរាជរដ្ឋាភិបាលកម្ពុជាដោយមានការរួមចំណែកពីភាគីពាក់ព័ន្ធនានា ដូចជាដៃគូអភិវឌ្ឍន៍ផ្នែកឯកជន និង អង្គការសង្គមស៊ីវិល ជាដើម។ ការប្តេជ្ញាខាងលើក៏ត្រូវបានលើកឡើងផងដែរនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម (ទំព័រ១១៩កថាខ័ណ្ឌ៣៨៧)៖ "រាជរដ្ឋាភិបាលចាត់ទុកអង្គការសង្គមស៊ីវិល (CSOs) ជាដៃគូអភិវឌ្ឍន៍ដ៏សំខាន់មួយនៅក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ជាតិ។ រាជរដ្ឋាភិបាលនឹងបន្តលើកទឹកចិត្តអង្គការសង្គមស៊ីវិលទាំងឡាយដែលបានបង្កើតស្របច្បាប់ និង ធ្វើប្រតិបត្តិការដោយផ្អែកលើគោលការណ៍អភិបាលកិច្ចល្អឲ្យចូលរួមក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ប្រទេស និងនៅក្នុងការជម្រុញលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស និង លើកទឹកចិត្តដល់ការចូលរួមប្រកបដោយការទទួលខុសត្រូវរបស់ពួកគេក្នុងការតាមដានការអនុវត្តយុទ្ធសាស្ត្រនិងគោលនយោបាយអភិវឌ្ឍន៍ជាតិ"។ លើសពីនេះទៀត កថាខ័ណ្ឌ៣៨៩ក៏គូសបញ្ជាក់ផងដែរថា "រាជរដ្ឋាភិបាលវាយតម្លៃខ្ពស់ដល់ការចូលរួមដ៏សកម្មក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ជាតិ ដោយអង្គការសង្គមស៊ីវិលទាំងឡាយដែលមានឆន្ទៈពិតប្រាកដក្នុងការរួមវិភាគទានធនធានទាំងហិរញ្ញវត្ថុនិងធនធានប្រតិបត្តិការ។ រាជរដ្ឋាភិបាល ចាត់ទុកធនធាននិងជំនាញដែលពាំនាំមកដោយអង្គការសង្គមស៊ីវិលថាជាធាតុចូលដ៏សំខាន់មួយនៅក្នុងកិច្ចដំណើរការគោលនយោបាយ ដើម្បីឈានដល់លទ្ធផលអភិវឌ្ឍន៍ដែលគេចង់បាន។ រាជរដ្ឋាភិបាលនឹងបន្តធានាឲ្យបាននូវការចូលរួមដ៏ស្វាហាប់របស់អង្គការសង្គមស៊ីវិលនៅក្នុងយន្តការសុន្ទនា។"

ផ្អែកលើកថាខ័ណ្ឌ៥៨៨នៅក្នុងទំព័រ១៩២នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម និង សូចនាករតាមដានរួមខាងលើ ក្រសួងផែនការបានសន្យាចាប់ផ្តើមការរៀបចំការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិដ៏ពេញលេញមួយលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ក្នុងខែមេសា និងបញ្ចប់ការពិនិត្យវាយតម្លៃនេះមុនដំណាច់ខែកញ្ញា ឆ្នាំ ២០១១។ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ក្រសួងផែនការបានបញ្ចេញសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ជូនដៃគូអភិវឌ្ឍន៍នាំមុខនៅក្នុង TWG-PPR សម្រាប់ចែកចាយបន្តជូនដៃគូអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងក្រុមការងារបច្ចេកទេស។ យោបល់ទាំងអស់ត្រូវបានកំណត់ឲ្យផ្តល់ជូន និង ត្រូវតាមដានបន្តជាមួយក្រសួងនិងស្ថាប័នទទួលបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រុមការងារបច្ចេកទេស។ អង្គការមិនមែនរដ្ឋាភិបាលបានវាយតម្លៃខ្ពស់ចំពោះឱកាសផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ដែលត្រូវបានផ្ញើសុំការអនុម័តពីគណៈរដ្ឋមន្ត្រីនៅដើមឆ្នាំ២០១២ដោយក្រសួងផែនការ។ ផ្អែកលើការសង្កេតរបស់យើងសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ត្រូវបានកែលម្អជាទូទៅ ប្រៀបធៀបទៅនឹងការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិមុន (ឆ្នាំ ២០០៨) លើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០។ ឧទាហរណ៍បរិមាណនៃព័ត៌មានដែលបានបង្ហាញមានលក្ខណៈផ្តល់ព័ត៌មានច្រើនជាង ហើយមានសូចនាករតាមដានច្រើនជាងជាមួយការកំណត់ពេលវេលាជាបណ្តើរៗត្រូវបានបន្ថែមនៅក្នុងរបាយការណ៍នេះ។

ការប្រើក្រុមការងារបច្ចេកទេសសម្រាប់រៀបចំកិច្ចដំណើរការ នៃការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិមិនសូវមានប្រយោជន៍និងងាយស្រួលទេសម្រាប់ការចូលរួមប្រកបដោយអត្ថន័យ និងប្រសិទ្ធភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានសង្កេតឃើញដូចគ្នានឹងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម។ ចំណុចនេះគឺដោយសារប្រការដែលថាមានក្រុមការងារបច្ចេកទេសតិចតួចណាស់(ដូចជាក្រុមការងារបច្ចេកទេសTWG-PPR ក្រុមការងារបច្ចេកទេស-ភាពជាដៃគូនិងសុខុដុមនីយកម្ម) ដែលបានជួបប្រជុំគ្នាដោយមានរបៀបវារៈច្បាស់លាស់សម្រាប់ពិភាក្សាការរៀបចំការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិតាមការរាយការណ៍ដោយអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ខណៈដែលពេល

វេលាសម្រាប់ផ្តល់យោបល់ និង ធ្វើការពិគ្រោះយោបល់ មានរយៈពេលខ្លី ពោលគឺតិចជាងពីរសប្តាហ៍។ រយៈពេលខ្លីនេះបានរឹតត្បិតឱកាសសម្រាប់ការចូលរួមឲ្យបានទូលាយពីអង្គការសង្គមស៊ីវិល ដែលធ្វើការនៅក្នុងវិស័យផ្សេងៗគ្នា និងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ផ្សេងៗគ្នានៅថ្នាក់ក្រោមជាតិ។ ក្នុងចំណោមយោបល់របស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យទាំង ៧ ដែលត្រូវបានដាក់ជូនក្រសួងពាក់ព័ន្ធ មិនមានយោបល់មួយណាបានទទួលចម្លើយពីក្រសួងទាំងនេះទេ។

ម្យ៉ាងទៀតអង្គការមិនមែនរដ្ឋាភិបាលបានកត់សម្គាល់ឃើញថាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣ដែលត្រូវបានដាក់សុំការអនុម័តពីរដ្ឋសភា ផ្តល់មូលដ្ឋានច្បាប់សម្រាប់ឲ្យស្ថាប័ននីតិបញ្ញត្តិតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជាមានគណនេយ្យភាពលើការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម។ អង្គការមិនមែនរដ្ឋាភិបាលជឿថាវាគឺជាប្រការដែលផ្តល់ព័ត៌មានច្រើនជាងនិងមានគណនេយ្យភាពជាងដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវរាយការណ៍ជូនរដ្ឋសភាឬ ដាក់របាយការណ៍ស្តីពីការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិសុំការអនុម័តពីរដ្ឋសភា។ យ៉ាង ហោចណាស់ប្រការនេះនឹងជួយឲ្យសមាជិកសភានិងសាធារណជនទូទៅកាន់តែមានការយល់ដឹង និងកាន់តែទទួលបានព័ត៌មានអំពីវឌ្ឍនភាពដែលសម្រេចបានមកដល់ពេលនេះ ដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងការអនុវត្ត និងការសម្រេចបានចំណុចដៅនានាដែលមានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម។យើងជឿថាគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើបច្ចុប្បន្នកម្មកាលវិភាគនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ឲ្យស្របតាមអាណត្តិនីតិកម្មទីបួននៃរាជរដ្ឋាភិបាលកម្ពុជា បង្ហាញការប្តេជ្ញាដ៏រឹងមាំរបស់ខ្លួនដើម្បីអាចវាយតម្លៃសមិទ្ធផលអភិវឌ្ឍន៍នៅក្នុងអាណត្តិនីតិកម្មរបស់ខ្លួន និង មានគណនេយ្យភាពចំពោះស្ថាប័ននីតិបញ្ញត្តិនិងម្ចាស់ឆ្នោត។

ដើម្បីធានាភាពជាម្ចាស់របស់ប្រទេសជាតិលើកិច្ចដំណើរការអភិវឌ្ឍន៍ជាតិ អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវសូមឲ្យរាជរដ្ឋាភិបាលកម្ពុជាសម្រេចការប្តេជ្ញារបស់ខ្លួន ដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម និងសូមឲ្យពិចារណាអនុសាសន៍ខាងក្រោមសម្រាប់ការរៀបចំរបាយការណ៍អនាគតស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍ជាតិ និង សម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ថ្មី។

២.២ អនុសាសន៍

- សម្រាប់អនាគត ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ (APR) នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) និងផែនការអភិវឌ្ឍន៍ជាតិ យើងខ្ញុំសូមស្នើសូមឲ្យពង្រីកកិច្ចដំណើរការរៀបចំឲ្យបានហួសពីកិច្ចដំណើរការនៃក្រុមការងារបច្ចេកទេសដើម្បីអនុញ្ញាតឲ្យមានការចូលរួមបានកាន់តែទូលាយថែមទៀតដោយអង្គការសង្គមស៊ីវិល និងក្រុមចាប់អារម្មណ៍ផ្សេងទៀត។ សេចក្តីព្រាងឯកសារទាំងឡាយទាក់ទិននឹងផែនការអភិវឌ្ឍន៍ជាតិគប្បីផ្សព្វផ្សាយឲ្យបានឆាប់និងយ៉ាងទូលាយ ដោយផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ផ្តល់យោបល់ (ពោលគឺ យ៉ាងហោចណាស់រយៈពេលមួយខែ)។
- ក្រៅពីអង្គការមិនមែនរដ្ឋាភិបាល តួអង្គសង្គមស៊ីវិលពាក់ព័ន្ធផ្សេងទៀត (ដូចជា អង្គការសហគមន៍ (CBOs) គ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នសាសនា អង្គការពលកម្ម និង គ្រឹះស្ថានស្រាវជ្រាវ) និង រដ្ឋសភាគប្បីត្រូវបានអញ្ជើញជាចំហរឲ្យចូលរួមក្នុងកិច្ចដំណើរការនេះ ក្នុងលក្ខណៈសកម្មមុននិងប្រកបដោយការទទួលខុសត្រូវ។
- រដ្ឋសភាដែលបានអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្មគប្បីអាចតាមដានវឌ្ឍនភាពដោយផ្ទៀតផ្ទាត់ជាមួយការអនុវត្តផែនការតាមរយៈការដាក់បញ្ចូលសូចនាករតាមដានដែលអាចវាស់បាននិងវាយតម្លៃបានទាន់ពេល ដែលត្រូវបានកំណត់មួយឆ្នាំម្តង។ ការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិគប្បីត្រូវបានរាយការណ៍ជូនឬត្រូវបានអនុម័តដោយរដ្ឋសភា។
- ការធ្វើឲ្យមានតុល្យ ភាពលើសូចនាករនៃធាតុចូល ទិន្នផល លទ្ធផល និងផលប៉ះពាល់ គប្បីត្រូវកែលម្អបន្ថែមទៀតនៅក្នុងផែនការអភិវឌ្ឍន៍ជាតិអនាគត។ ប្រការនេះនឹងអនុញ្ញាតឲ្យភាគីពាក់ព័ន្ធខាងលើ ជាពិសេសរដ្ឋសភាដែលបានអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ អាចតាមដានបានកាន់តែល្អថែមទៀតនូវការផ្លាស់ប្តូររយៈពេលខ្លី

MEDICAM

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

អង្គការម៉េឌីខាំ គឺជាភ្នាក់ងារបណ្តាញបឋម ដែលព្យាយាមផ្សារភ្ជាប់ភាគីពាក់ព័ន្ធទាំងអស់ ទៅនឹងវិស័យសុខាភិបាលតាមរយៈ ការសម្របសម្រួល និងភាពជាតំណាងឲ្យអង្គការសង្គមស៊ីវិល ការលើកស្ទួយការអភិវឌ្ឍគោលនយោបាយ ផ្អែកលើភាពជាក់ស្តែង ការកសាងសមត្ថភាពដល់អង្គការជាសមាជិករបស់ខ្លួន ការពង្រឹងគណនេយ្យភាពសង្គម និងការចែករំលែកព័ត៌មានសុខាភិបាលសំខាន់នានា។ អង្គការម៉េឌីខាំត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៩ ក្នុងរូបភាពជាអង្គការសមាជិកភាពនៃអង្គការមិនមែនរដ្ឋាភិបាល ដែលបំពេញការងារលើវិស័យសុខាភិបាលរបស់ប្រទេសកម្ពុជា ខណៈដែលកម្ពុជាស្ថិតក្រោមការហ៊ុមព័ទ្ធសេដ្ឋកិច្ច ពីលោកខាងលិច។ ក្រុមអង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខភាពអន្តរជាតិ បានបង្កើតបណ្តាញនេះឡើងដើម្បីទំនាក់ទំនង និងចែករំលែកព័ត៌មានស្តីពីសុខភាពជាមួយនឹងដៃគូ នៃរដ្ឋាភិបាលរបស់ពួកគេ។ អង្គការម៉េឌីខាំ គឺជាអង្គការមួយក្នុងចំណោមអង្គការសមាជិកភាពធំបំផុត ក្នុងប្រទេស ដែលមានអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៣០ ស្ថិតក្រោមការសម្របសម្រួលរបស់ខ្លួន។

អង្គការម៉េឌីខាំ
អាសយដ្ឋាន៖ ផ្ទះលេខ២១ ផ្លូវលេខ ២៨៧
សង្កាត់បឹងកក់១ ខណ្ឌទួលគោក ប្រអប់សំបុត្រ
ប្រៃសណីយ៍ ១១៦៨ ភ្នំពេញ កម្ពុជា។
ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨០ ២៩១
ទូរសារ៖ (៨៥៥-២៣) ៨៨០ ២៩២
អ៊ីម៉ែល៖ info@medicam-cambodia.org
គេហទំព័រ៖ www.medicam-cambodia.org

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) គឺជាអង្គការសមាជិកភាពមួយ ដែលមានសមាជិកជាអង្គការក្នុងស្រុក និងអន្តរជាតិ ដែលមានបទពិសោធន៍ ធ្វើការលើជំនួយមនុស្សធម៌និងជំនួយអភិវឌ្ឍន៍មកកម្ពុជា ហើយធ្វើការតស៊ូមតិលើបញ្ហាពហុវិស័យនានា។ ក្រោយពីបានបង្កើតនៅដើមទសវត្សរ៍ឆ្នាំ១៩៨0 NGOF បានចាប់ផ្តើមយុទ្ធនាការជាលើកដំបូង ដើម្បីសុំបញ្ឈប់ការដាក់ទណ្ឌកម្ម និងហាមឃាត់ជំនួយដែលបានដាក់លើប្រទេសកម្ពុជានាពេលនោះ និងបន្តយុទ្ធនាការហាមឃាត់គ្រាប់មីនដាក់ក្នុងដី។ បច្ចុប្បន្ន NGOF មានអង្គការជាសមាជិកពេញសិទ្ធិចំនួន ៩0 និងអង្គការសមាជិកជាបណ្តាញប្រមាណ ៣00 អង្គការ។ NGOF មានបេសកកម្មសម្របសម្រួលអង្គការសមាជិក បណ្តាញ និងអង្គការសង្គមស៊ីវិលដទៃទៀត ដើម្បីចូលរួមយ៉ាងសកម្មក្នុងការជជែកពិភាក្សាលើគោលនយោបាយ ព្រមទាំងធ្វើការតស៊ូមតិជាមួយ និងដើម្បីប្រជាជនក្រីក្រ និងងាយរងគ្រោះនៅប្រទេសកម្ពុជា។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
អាសយដ្ឋាន៖ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦
សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ប្រអប់សំបុត្រ
ប្រៃសណីយ៍ ២២៩៥ ភ្នំពេញ កម្ពុជា។
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) គឺជាអង្គការសមាជិកភាពដែលមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិជាសមាជិកច្រើនជាងចំនួន១៥0។ ចាប់តាំងពីឆ្នាំ ១៩៩0 មក CCC ធ្វើការដើម្បីពង្រឹងសហប្រតិបត្តិការ វិជ្ជាជីវៈ គណនេយ្យភាព អភិបាលកិច្ច និងប្រសិទ្ធភាពអភិវឌ្ឍន៍របស់អង្គការសង្គមស៊ីវិលនៅកម្ពុជា។ CCC ប្តេជ្ញាទៅតាមចក្ខុវិស័យមួយដើម្បីឲ្យមានសង្គមស៊ីវិលដ៏មាំទាំ និងមានសមត្ថភាព ដើម្បីធ្វើការសហការ និងឆ្លើយតបទៅនឹងកិច្ចប្រឈមលើការអភិវឌ្ឍនៅកម្ពុជា។ អង្គការសមាជិកទាំងអស់បានរួបរួមគ្នានៅក្រោមឆ័ត្ររបស់អង្គការ CCC តែមួយ ដែលអាចទទួលបាននូវអត្ថប្រយោជន៍ជាច្រើន និងធនធានដ៏សម្បូរបែបរបស់ CCC រួមមានការធ្វើការជាបណ្តាញ និងការចែករំលែកព័ត៌មាន ការចូលរួមតាមរយៈសម្លេងគាំទ្រ និងការចូលរួមក្នុងការអភិវឌ្ឍអង្គការ ព្រមទាំងការរៀនសូត្រពីគ្នាទៅវិញទៅមក។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
អាសយដ្ឋាន៖ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦
សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ប្រអប់សំបុត្រ
ប្រៃសណីយ៍ ៨៨៥ ភ្នំពេញ កម្ពុជា។
ទូរស័ព្ទ៖ (៨៥៥-២៣) ២៤១ ១៥២
ទូរសារ៖ (៨៥៥-២៣) ២១៦ ០០៩
អ៊ីម៉ែល៖ info@ccc-cambodia.org
គេហទំព័រ៖ www.ccc-cambodia.org

បោះពុម្ពផ្សាយដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា